KH/2008/ED/TLK/43
Phnom Penh, November 2008
Original: English

សម្ដីចុងក្រោយ : ការបង្កើតបរិយាកាសរៀនមេត្រី ដោយបញ្ចូលគ្រប់សមាសភាព



បរិយាកាសរៀនមេត្រី
ដោយបញ្ចូលគ្រប់សមាសភាព

UNESCO



អារម្ភកថា

ការអប់រំកុមារដែលមានប្រែវត្តិ និងសមត្ថភាពផ្សេងៗគ្នា ជាកាតព្វកិច្ចចម្បងមួយ ដែលត្រូវអនុវត្តឲ្យបាន នៅតំបន់អាស៊ីប៉ាស៊ីភិច។ វេទិកាអប់រំពិភពលោកនៅទីក្រុងដាកា ប្រទេសសេណេហ្គាល់ កាលពីខែមេសាឆ្នាំ ២០០០ បានដាក់ចេញនូវគោលដៅលើកទីពីររបស់ខ្លួន ដូចតទៅ : "ជានាថា នៅមុន ឬត្រឹមឆ្នាំ ២០១៥ កុមារទាំងអស់ ជាពិសេស កុមារី កុមារដែលស្ថិតក្នុងកាលៈទេសៈលំបាក និងក្រុមកុមារមកពីក្រុមជនជាតិភាគតិចបានទទួល និង បំពេញចប់នូវកាតព្វកិច្ចអប់រំបឋមសិក្សាដោយឥតបង់ថ្លៃ និងប្រកបដោយគុណភាព។" ការធានាសម្រេច គោលដៅនេះ មានន័យថា ការចូលរៀនក្នុងសាលារបស់កុមារ និងការរៀនចប់ថ្នាក់របស់កុមារ ការលុបបំបាត់ ភាពលម្អៀង និងការរើសអើងក្នុងសាលា ក្នុងប្រព័ន្ធអប់រំជាតិ ក្នុងកម្មវិធីសិក្សា ក្នុងសង្គម និងក្នុងទម្លាប់វប្បធម៌ ដែលធ្លាប់តែកំណត់ដែននៃតម្លៃវការរៀនសូត្ររបស់កុមារដែលមានប្រែវត្តិ និងសមត្ថភាពខុសគេ។

វិសមភាពក្នុងវិស័យអប់រំនៅតែជាបញ្ហាព្រួយបារម្ភគ្រប់ប្រទេសទាំងអស់ ហើយការរើសអើងក៏នៅ តែបន្តកើតមានឥតឈប់ក្នុងសាលា និងក្នុងប្រព័ន្ធអប់រំ។ ដើម្បីបំព្រួញគម្លាតវិសមភាពនេះ គ្រូបង្រៀន និង អ្នករដ្ឋបាលសាលាត្រូវយល់ច្បាស់ និងគាំទ្រនូវសារៈសំខាន់នៃការអប់រំដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព។ សំខាន់ដូចគ្នានេះដែរ ត្រូវមានឯកសារ និងគោលដើម្បីឲ្យអ្នកពាក់ព័ន្ធប្រើ ដើម្បីវិភាគអំពីស្ថានភាពរបស់កុមារ ហើយ ធានាថា កុមារទាំងអស់បានចូលរៀនក្នុងសាលា និងរៀនរហូតអស់លទ្ធភាព ហើយធានាឲ្យមានសមធម៌ក្នុង ថ្នាក់រៀន ក្នុងឯកសាររៀន និងបង្រៀន ក្នុងសកម្មភាពរៀន និងបង្រៀន ក្នុងគោលនយោបាយសាលា និង ក្នុងការ តាមដាន វាយតម្លៃលទ្ធផលសិក្សារបស់សិស្ស ។

កម្រងសៀវភៅនេះទទួលស្គាល់នូវកាតព្វកិច្ចដ៏លំបាកនេះ ហើយក៏ផ្តល់នូវទស្សនវិស័យប្រែវត្តិសាស្ត្រ និង ជាក់ស្តែងមួយស្តីពីវិធីប្រែក្លាយសាលារៀន និងថ្នាក់រៀនឲ្យទៅជាកន្លែងដែលមានបរិយាកាសរៀនមេត្រី ដោយ ដាក់បញ្ចូលគ្នាគ្រប់សមាសភាព ហើយកម្រងសៀវភៅនេះក៏ផ្តល់ជូននូវវិធីសាស្ត្រសម្រាប់អនុវត្តជាដែរ។ កម្រងសៀវភៅនេះប្រមូលផ្តុំបទពិសោធ ដែលបានអនុវត្តជាច្រើនឆ្នាំកន្លងមក និងយុទ្ធសាស្ត្រ ព្រមទាំងក្បួនច្បាប់ ដែលអង្គការនានា និងអ្នកជំនាញមួយចំនួនបានបង្កើតឡើងកន្លងមក ស្តីពីការអប់រំដោយដាក់បញ្ចូលគ្នាគ្រប់ សមាសភាព ហើយថ្មីៗនេះ គឺការបង្កើតសាលារៀនកុមារមេត្រី។ កម្រងសៀវភៅនេះ មានលក្ខណៈមេត្រីភាព សម្រាប់អ្នកប្រើ និងជាក្បួនច្បាប់សម្រាប់គ្រូដែលបង្រៀនក្នុងថ្នាក់ដែលមានសិស្សមកពីគ្រប់សមាសភាព និង មានប្រែវត្តិ និងសមត្ថភាពខុសៗគ្នា។ ខ្ញុំសង្ឃឹមថា មិត្តអ្នកអានទាំងអស់នឹងមើលឃើញអំពីសារប្រយោជន៍ របស់កម្រងសៀវភៅ នេះក្នុងការបង្កើតបរិយាកាសរៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព និងក្នុងការ គ្រប់គ្រងថ្នាក់រៀនកុមារមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព ដោយមានការចូលរួមពេញលេញ និងសកម្ម ពីសំណាក់អ្នកអប់រំ សិស្ស មាតាបិតា និងសហគមន៍។

Sheldon Shaeffer
Director
UNESCO Asia and Pacific Regional Bureau for Education



ថ្លែងអំណរគុណ

ដំណើរការតាក់តែងកម្រងសៀវភៅនេះ មានការចូលរួមពីសំណាក់អ្នកឯកទេសអប់រំ គ្រូបង្រៀន និងអ្នកជំនាញ ព្រមទាំងអ្នកផ្សេងទៀតមកពីតំបន់ផ្សេងក្រៅពីតំបន់អាស៊ី។ ឈ្មោះអ្នកចូលរួមទាំងនេះ មានបង្ហាញក្នុងតារាងខាងក្រោម ហើយឆ្លៀតឱកាសនេះ យើងសូមថ្លែងអំណរគុណដល់អ្នកចូលរួមទាំងអស់ចំពោះការចូលរួមរៀបចំកម្រងសៀវភៅនេះ។ រាល់គំនិត និងយោបល់នានាត្រូវបានយកមកពិចារណា និងបញ្ចូលទៅក្នុងកម្រងសៀវភៅនេះ ដើម្បីបំពេញព័ត៌មានឲ្យកាន់តែសម្បូរបែប។

លើសនេះទៀត មូលនិធិអភិវឌ្ឍបំណិនជីវិតនៅឈាងមែប្រទេសថៃ ការិយាល័យអង្គការ UNICEF ប្រចាំនៅទីក្រុងម៉ានីឡា ប្រទេសភីលីពីន និងការិយាល័យអង្គការ UNICEF ប្រចាំនៅទីក្រុងឥស្លាម៉ាបាដ ដែលបានរួមសហការរៀបចំសិក្ខាសាលាសម្រាប់គ្រូបង្រៀន ដើម្បីប្រមូលយោបល់កែលំអលើខ្លឹមសារកម្រងសៀវភៅនេះ និងសៀវភៅផ្សេងៗទៀតផងដែរ។ យើងចាត់ទុកថា កិច្ចសហការនេះមានសារៈសំខាន់និងផ្តល់ផ្លែផ្កាដល់កម្រងសៀវភៅនេះ ហើយយើងសង្ឃឹមថា កិច្ចសហការបែបនេះ នឹងកើតមានជាបន្តបន្ទាប់ទៀតក្នុងដំណើរការចែកចាយកម្រងសៀវភៅនេះ។

យើងក៏បានប្រើប្រាស់នូវគំនិត និងក្បួនច្បាប់ពីប្រភពផ្សេងៗជាច្រើន ដូចខាងក្រោម :

Child-to-Child: A Resource Book. Part 2: The Child-to-Child Activity Sheets, by Baily D, Hawes H and Bonati B (1994) and published by The Child-to-Child Trust, London.

FRESH: A Comprehensive School Health Approach to Achieve EFA. UNESCO (2002) Paris.

Local Action: Creating Health Promoting Schools. World Health Organization (2000) Geneva. Also valuable resources were the documents in the WHO Information Series on School Health dealing with violence prevention, healthy nutrition, and preventing discrimination due to HIV/AIDS.

Renovating the teaching of health in multigrade primary schools: A teacher's guide to health in natural and social sciences (Grades 1,2,3) and science (Grade 5), by Son V, Pridmore P, Nga B, My D and Kick P (2002) and published by the British Council and the National Institute of Educational Sciences, Hanoi, Vietnam.

Understanding and Responding to Children's Needs in Inclusive Classrooms. UNESCO (2001) Paris.

UNICEF's Web sites on Life Skills as well as "Teachers Talking About Learning," New York. Accessible through http://www.unicef.org/

យើងក៏សូមថ្លែងអំណរគុណ ដល់ការងារខាងលើ និងបំផុសឲ្យអ្នកប្រើកម្រងសៀវភៅនេះប្រើឯកសារយោងទាំងនេះដដែរ។

ជាទីបញ្ចប់នេះ យើងសូមថ្លែងអំណរគុណជាពិសេសដល់ Ray Harris, Dr. Shirley Miske and George Attig, ដែលជាអ្នកត្រួតពិនិត្យកម្រងសៀវភៅទាំងថ្មីមួយនេះ។ George Attig បានចូលរួមក្នុងការងារនេះតាំងពីចាប់ផ្តើមដំបូង រហូតរៀបចំបញ្ជូនទៅរោងពុម្ព។ ដំណើរការបញ្ជូនចូលរោងពុម្ពនេះបានបញ្ជូនត្រលប់ចុះឡើង ទោះជាយ៉ាងណា George Attig នៅតែគាំទ្រគម្រោងរហូតចប់ចុងចប់ដើម។ យើងសូមថ្លែងអំណរគុណគាត់ចំពោះភាពអត់ធ្មត់ និងការតស៊ូរបស់គាត់។ Vibeke Jensen អ្នកឯកទេសកម្មវិធីរបស់អង្គការយូណេស្កូប្រចាំទីក្រុងបាងកក ក៏បានសម្របសម្រួលគម្រោងនេះ និងដោះស្រាយរាល់បញ្ហា និងការលំបាករបស់គម្រោងនេះរហូតចប់ចុងចប់ដើម។

តារាងខាងក្រោម គឺអ្នកចូលរួមផ្តល់ពេលវេលា និងបទពិសោធដើម្បីបញ្ចប់កម្រងសៀវភៅនេះ។ យើងសូមអភ័យទោសដង ប្រសិនជាយើងភ្លេចបញ្ចូលអ្នកណាម្នាក់ដែលបានជួយក្នុងគម្រោងនេះ។

អ្នកចូលរួមជួយក្នុងការផលិតកម្រងសៀវភៅនេះ

ប្រទេសចូលរួម

បង់ក្លាដែស
កម្ពុជា
ចិន
បារាំង
ឥណ្ឌា
ឥណ្ឌូណេស៊ី
សាធារណៈរដ្ឋប្រជាមានិតឡាវ
ប៉ាគីស្ថាន
ភីលីពីន
ថៃ
សហរដ្ឋអាមេរិក
ចក្រភពអង់គ្លេស
វៀតណាម

គណៈកម្មការរៀបរៀងកម្រងសៀវភៅ

Laetitia Antonowicz
George A. Attig
Tutiya Buabuttra
Tamo Chattopadhay
Ray Harris
Vibeke Jensen
Intiranee Khanthong
Shirley Miske
Hildegunn Olsen
Ann Ridley
Sheldon Shaeffer

គណៈកម្មការត្រួតពិនិត្យ

Teresa Abiera
Koen Van Acoleyen
Vonda Agha
Khalida Ahmed
Mohammad Tariq Ahsan
Anupam Ahuja
Safia Ali
Shabana Andaleeb
Arshi
Rukhshunda Asad
Mahmooda Baloch
Sultana Baloch
Sadiqa Bano
Shamim Bano
Anne Bernard
Flora Borromeo
Naeem Sohail Butt
Yasmin Kihda Bux
Gilda Cabran
Kreangkrai Chaimuangdee
Nikom Chaiwong
Sangchan Chaiwong
Renu Chamnannarong
Aporn Chanprasertporn
Tamo Chattopadhay
Francis Cosstick
Charles Currin
Benedicta Delgado
Rosemary Dennis
Supee Donpleg
Kenneth Eklindh
Siwaporn Fafchamps
Farhat Farooqui
Aida Francisco
He GuangFeng
Els Heijnen
Budi Hermawan
Evangeline Hilario
Masooma Hussain
H. Moch. Sholeh Y.A. Ichrom
Gobgeua Inkaew
Souphan Inthirat
Heena Iqbal
Shaista Jabeen
Salma M. Jafar
Venus Jinaporn
Najma Kamal
Kartini
Lyka Kasala
Chaweewan Khaikaew
Uzma Khalid
M. Khalil
Bilal Khan
Shaista Nasim Khan
Pralong Krutnoi
Ran Kuenpet
Chij Kumar
Nongnuch Maneethong
Rosalie Masilang

Ragnhild Meisfjord
Cliff Meyers
Cynthia Misalucha
Thanandon Na Chiangmai
Benjalug Namfa
Sompol Nantajan
Maria Fe Nogra-Abog
Thongpen Oatjareanchai
Sithath Outhaithany
Elizabeth Owit
Wittaya Pa-in
Marivic Panganiban
Wantanee Panyakosa
Manus Pasitvilaitum
Chalerm Payarach
Linda Pennells
Nongkran Phichai
Mary Pigozzi
Penny Price
Kunya Pundeng
Tahira Qazalbask
Nora N Quetulio
Sabiha Rahim
Florencia Ramos
Shyda Rashid
Ann Ridley
Clarina Rigodon
Wendy Rimer
Maurice Robson

Porntip Roongroj
Rubina
Sobia Saqlain
Naheed Sajjad
Estelita Samson
Lourdes Santeco
Sadia Shahid
Ruchnee Somboot
Teresita Sotto
Norkham Souphanouvong
Persy Sow
Milagros Sucgang
Pensri Supavasit
Farida Tajamul
Sritoon Tathun
Philippa Thomas
Anchalee Thongsook
Nguyen Thi Thanh Thuy
Jocelyn Tuguinayo
Erlinda Valdez
Zenaida Vasquez
Sangwan Wangcham
Terje M. Watterdal
Marc Wetz
Mantariga Witoonchat
Somkid Wongsuntorn
Nuttapong Yoswungjai
Shahzad Yousaf
Susana Zulueta



សង្ខេបអំពីកម្រងសៀវភៅ

បរិយាកាសរៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព ស្វាគមន៍ ផ្តល់ការបណ្តុះបណ្តាល និងការអប់រំសម្រាប់កុមារទាំងអស់ ដោយមិនប្រកាន់ភេទ រូបរាងកាយ បញ្ញា ឋានៈសង្គម និងភាសាឡើយ។ កុមារទាំងនេះអាច ជាកុមារពិការ ចាត់បង់លទ្ធភាព កុមារតាមចិញ្ចើមថ្នល់ ឬកុមារពលកម្ម កុមារកូនអ្នករស់នៅតំបន់ដាច់ស្រយាល កុមារកូនជនជាតិភាគតិចដែលប្រើភាសាខុសគេ និងមានវប្បធម៌ខុសគេ កុមាររងគ្រោះដោយសារមេរោគអេដស៍/ជំងឺអេដស៍ ឬកុមាររស់នៅតំបន់ដែលមិនសូវមានឱកាស និងជួបការលំបាកខ្លាំង។

អ្នកណាខ្លះអាចប្រើកម្រងសៀវភៅនេះ?

កម្រងសៀវភៅនេះត្រូវបានសរសេរសម្រាប់អ្នកអានទាំងអស់គ្នា។ អ្នកអានអាចជាគ្រូបង្រៀន ដែលបង្រៀននៅសាលាមត្តេយ្យ បឋមសិក្សា មធ្យមសិក្សា អ្នករដ្ឋបាលសាលា និស្សិតរៀននៅវិទ្យាស្ថានបណ្តុះបណ្តាលគ្រូ ឬសាស្ត្រាចារ្យបង្រៀននៅវិទ្យាស្ថានបណ្តុះបណ្តាលគ្រូ និងអ្នកដែលមានបំណងចង់ផ្តល់ឱកាសទទួលការអប់រំសម្រាប់ អ្នកដែលមិនបានចូលសាលា ដូចជាកុមារដែលមានប្រវត្តិ និងសមត្ថភាពខុសគេ។ កម្រងសៀវភៅនេះមានតម្លៃជាពិសេសសម្រាប់គ្រូបង្រៀន ដែលបង្រៀននៅតាមសាលា ហើយមានបំណងចង់បង្កើតវិធីសាស្ត្រសិក្សាគោលមជ្ឈមណ្ឌល និងបរិយាកាសរៀនកុមារមេត្រី ដែលត្រូវអនុវត្តតាមគោលការណ៍កំណែទម្រង់របស់ក្រសួងអប់រំ និងអង្គការនានា។

ខ្លឹមសារដ៏សំខាន់មួយ ដែលមនុស្សគ្រប់រូបឯកភាពគឺថា "កុមារទាំងអស់គឺ ខុសគ្នា ហើយកុមារទាំងអស់មានសិទ្ធិស្មើគ្នាក្នុងការទទួលការអប់រំ ដោយមិនប្រកាន់ប្រវត្តិ និងសមត្ថភាពឡើយ។ សាលា និងប្រព័ន្ធអប់រំជារឿយៗ កំពុងធ្វើដំណើរឈានឆ្ពោះទៅអនុវត្ត "ការអប់រំដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព"។ ការអប់រំបែបនេះនឹងប្រមូលយកកុមារដែលមានប្រវត្តិ និងសមត្ថភាពខុសគេឲ្យចូលរៀននៅសាលាធម្មតាដូចកុមារធម្មតាដែរ។ ម្យ៉ាងវិញទៀត ការចូលរៀនរបស់កុមារទាំងនេះក្នុងសាលា នឹងបង្កើនឱកាសឲ្យកុមារទាំងនេះបានរៀន ព្រោះកុមារទាំងនេះនឹងមានឱកាសទំនាក់ទំនងជាមួយកុមារដទៃ ផ្តល់ឱកាសរៀនសូត្រដល់កុមារទាំងនេះ លើកកម្ពស់ការចូលរួមរបស់កុមារទាំងនេះ ក្នុងការរួមចំណែកដល់ជីវភាពគ្រួសារ និងសហគមន៍។ ម្យ៉ាងវិញទៀត កុមារធម្មតាដែលមានទំនាក់ទំនងជាមួយកុមារដែលមានប្រវត្តិ និងសមត្ថភាពខុសគេ ក៏នឹងទទួលប្រយោជន៍ពីការអប់រំប្រភេទនេះជាដែរ។ កុមារនឹងរៀនអំពីការគោរព និងការឲ្យតម្លៃចំពោះសមត្ថភាព ការរៀនសូត្ររបស់អ្នកដទៃ និងចេះអត់ឱន និងយោគយល់គ្នាដោយមិនប្រកាន់អ្វីឡើយ។

សម្រាប់យើងជាគ្រូបង្រៀន ប្រមូលផ្តុំកុមារច្រើនប្រភេទបែបនេះឲ្យចូលរៀនក្នុងថ្នាក់របស់យើង មិនមែនជាការកិច្ចដែលងាយស្រួលនោះទេ។ គ្រូមួយចំនួនមានសិស្សច្រើន និងមានអារម្មណ៍ថា មានការងារច្រើនដែលត្រូវធ្វើរួចទៅហើយ។ ប្រសិនបើបញ្ចូលកុមារដែលមានប្រវត្តិ និងសមត្ថភាពខុសគេក្នុងថ្នាក់ថែមទៀត មានន័យថា យើងប្រមូលការងារមកធ្វើកាន់តែច្រើន ប៉ុន្តែជាក់ស្តែងមិនមែនច្រើនដូច យើងគិតនោះទេ។ ការងារដែលយើងត្រូវធ្វើ គឺគ្រប់គ្រងភាពខុសគ្នារបស់កុមារឲ្យបាន។ យើងត្រូវទទួលស្គាល់ភាពខ្លាំង និងភាពខ្សោយរបស់កុមារ រៀបចំកិច្ចតែងការបង្រៀន ប្រើប្រាស់វិធីសាស្ត្របង្រៀន និងកែលំអកម្មវិធីសិក្សាឲ្យស្របតាមប្រវត្តិ និងសមត្ថភាពរបស់កុមារ។ សំខាន់ជាងនេះទៀតគឺ ត្រូវចលនាឲ្យមិត្តរួមការងារ មាតាបិតា សហគមន៍ និងអ្នកជំនាញ ជួយផ្តល់ការអប់រំដែលមានគុណភាពសម្រាប់កុមារគ្រប់ៗរូប។

កម្រងសៀវភៅនេះនឹងជួយអ្នកអានឲ្យមានសម្តភាពអនុវត្តការងារទាំងអស់នេះ។ កម្រងសៀវភៅនេះក៏ផ្តល់គោលសំខាន់ៗសម្រាប់ប្រែក្លាយសាលា និងថ្នាក់រៀនរបស់អ្នកឲ្យទៅជាសាលា និងថ្នាក់រៀនដែលមានមេត្រីភាព សម្រាប់កុមារទាំងអស់ និងសម្រាប់គ្រូបង្រៀនផងដែរ ប្រែក្លាយសាលា និងថ្នាក់រៀន មិនត្រឹមតែឲ្យទៅជាសាលា និងថ្នាក់រៀនកុមារមេត្រីប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងឲ្យក្លាយទៅជាសាលា និងថ្នាក់រៀនដែលមានមេត្រីភាពសម្រាប់មាតាបិតា និងសហគមន៍ថែមទៀតផង។ កម្រងសៀវភៅនេះ មានបង្ហាញឯកសារយោងជាច្រើន ដែលអ្នកអាចយកទៅប្រើ ដើម្បីវិភាគអំពីស្ថានភាពផ្ទាល់ខ្លួន និងអនុវត្តសកម្មភាព ដោយប្រើសេចក្តីណែនាំក្នុងកម្រងសៀវភៅនេះ ហើយកម្រងសៀវភៅនេះក៏ផ្តល់ជាគំនិត សម្រាប់អ្នកអានយកទៅប្រើផងដែរ។ សៀវភៅទាំងអស់ក្នុងកម្រងសៀវភៅនេះ បង្ហាញនូវគំនិតមួយចំនួនដែលអាចយកទៅសាកល្បង។ កម្រងសៀវភៅនេះ ក៏បង្ហាញផ្លូវឲ្យអ្នកអានឆ្លុះបញ្ចាំងអំពីខ្លឹមសារ និងពិភាក្សាអំពីខ្លឹមសារដែលមានសរសេរក្នុងសៀវភៅនីមួយៗ ជាមួយអ្នករៀននៅតាមសហគមន៍ និងបង្កើតបរិយាកាសរៀនមេត្រីដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាពឲ្យកាន់តែប្លែក និងសកម្មរស់រវើក។

កម្រងសៀវភៅនេះមិននិយាយអំពីនិយមន័យគ្រប់ជ្រុងជ្រោយទេ ហើយមិនបានបង្ហាញផ្លូវនៃដំណោះស្រាយគ្រប់បញ្ហាទាំងអស់ដែលអ្នកជួបប្រទះនោះទេ។ ដើម្បីជួយអ្នកអានយល់កាន់តែច្រើន នៅទំព័រចុងបញ្ចប់នៃសៀវភៅនីមួយៗ យើងមានដាក់ឯកសារយោងដែលមានតម្លៃជាច្រើនសម្រាប់អ្នកអាន។ ការបង្កើតបរិយាកាសរៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព ជាដំណើរការមួយដែលត្រូវចំណាយពេលយូរណាស់ ហើយក៏មិនទាន់មានដំណោះស្រាយដាក់លាក់ ដែលយើងអាចយកមកប្រើជាគំរូបានដែរ។ ដំណើរការនេះ ជាសកម្មភាពដែលអាចរកដំណោះស្រាយជាបណ្តើរៗ ហើយដំណើរការនេះ ក៏ត្រូវការពេលវេលាយូរអង្វែង ដើម្បីបង្កើតបរិយាកាសថ្មីមួយផងដែរ។ យ៉ាងណា យើងត្រូវចាំពាក្យស្លោកមួយដែលនិយាយថា "ការធ្វើដំណើរគ្រាប់ពាន់យោជន៍ ត្រូវចាប់ចេញដំណើរពីដំហានទីមួយសិន។" កម្រងសៀវភៅនេះ ជួយអ្នកឲ្យចាប់ផ្តើមដើរដំហានទីមួយ ទីពីរ ទីបី និងទីបួនសិន។ល។ ដោយសារអ្នក និងសិស្សរបស់អ្នក តែងរៀនអ្វីដែលថ្មីដូច្នេះការរៀនសូត្រគឺ មិនចេះចប់ឡើយ។ កម្រងសៀវភៅនេះ នឹងបំពេញបំណង និង ការពេញចិត្តរបស់សិស្ស គ្រូបង្រៀន អ្នករដ្ឋបាលសាលា អ្នកឯកទេសអប់រំ មាតាបិតា និងសហគមន៍ជាមិនខាន។

តើអ្នកអាចប្រើកម្រងសៀវភៅនេះដោយរបៀបណា?

កម្រងសៀវភៅនេះមានថ្រាំមួយសៀវភៅ។ សៀវភៅនីមួយៗមានគោល និងសកម្មភាពដែលអ្នកអាចអនុវត្តបានដោយខ្លួនឯង ដើម្បីចាប់ផ្តើមបង្កើតបរិយាកាសរៀនមេត្រីដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព។ សកម្មភាពមួយចំនួនក្នុងសៀវភៅទាំងនេះ ណែនាំឲ្យអ្នកចេះវិភាគ ឆ្លុះបញ្ចាំងអំពីអ្វីដែលអ្នក និងសាលារបស់អ្នក អាចធ្វើបាន ដើម្បីបង្កើតបរិយាកាសរៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព។ សកម្មភាពមួយចំនួនទៀត ណែនាំអ្នកឲ្យបង្កើនជំនាញ ដើម្បីក្លាយខ្លួនជាគ្រូបង្រៀន ក្នុងថ្នាក់ដែលមានសិស្សគ្រប់ប្រភេទ។ អ្នកប្រហែលជាចង់សាកល្បងសកម្មភាពមួយចំនួន ដើម្បីស្វែងយល់ឲ្យកាន់តែស៊ីជម្រៅអំពីបរិយាកាសរៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព និងរកវិធីប្រែក្លាយថ្នាក់រៀន និងសាលារៀនរបស់អ្នកឲ្យមានបរិយាកាសរៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព ព្រមទាំងទទួលប្រយោជន៍ពីបរិយាកាសបែបនេះផងដែរ។

ដោយសារ ការបង្កើតបរិយាកាសរៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព ត្រូវការការងារជាក្រុម មានគោល និងសកម្មភាពមួយចំនួន ដែលអ្នកអាចសហការជាមួយសហសេវិក និងប្រធានរបស់អ្នក ជាមួយសិស្ស និងគ្រួសារសិស្ស និងសហគមន៍បានដែរ។ សកម្មភាពទាំងនេះ នឹងជួយអ្នកក្នុងការកែប្រែថ្នាក់រៀន និងសាលារៀនរបស់អ្នកឲ្យក្លាយជាថ្នាក់រៀន និងសាលាកុមារមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព។ ដើម្បីធ្វើការងារនេះបាន អ្នកត្រូវការការគាំទ្រពីអ្នកដទៃ ត្រូវការធនធានមនុស្ស និងសម្ភារ។

សៀវភៅទាំងថ្រាំមួយក្នុងកម្រងសៀវភៅនេះ អាចយកទៅប្រើតាមមធ្យោបាយពីរបែប។ សម្រាប់សាលាដែលបានចាប់ផ្តើមបង្កើតបរិយាកាសរៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព ក៏ដូចជាសាលាដែលកំពុងព្យាយាមប្រែក្លាយទៅជា"សាលាកុមារមេត្រី" អ្នកអាចជ្រើសរើសយកសៀវភៅមួយ ឬសៀវភៅទាំងថ្រាំមួយដែលមានប្រយោជន៍ អាចជួយអ្នកតាមតម្រូវការ ដូចជាធ្វើការជាមួយគ្រួសារ និងសហគមន៍ ឬគ្រប់គ្រងថ្នាក់រៀនដែលមានសិស្សច្រើនប្រភេទ។ សម្រាប់សាលាដែលកំពុងចាប់ផ្តើមប្រែក្លាយទៅជាសាលាដែលមានបរិយាកាសរៀនមេត្រីដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព អ្នកត្រូវអនុវត្តតាមការណែនាំក្នុងសៀវភៅម្តងមួយ។ ដោយចាប់ផ្តើមពីកម្រងសៀវភៅលេខ១ និងបន្តរហូតដល់កម្រងសៀវភៅលេខ៦។ កម្រងសៀវភៅនេះ នឹងជួយអ្នកមួយជំហានម្តងៗ។ ព្រោះសៀវភៅនីមួយៗទាក់ទងគ្នាជាលំដាប់។

លើសនេះទៀត ទោះជាពាក្យ"សាលារៀន"ត្រូវបានប្រើរហូតក្នុងកម្រងសៀវភៅនេះ។ ពាក្យសាលារៀនក្នុងកម្រងសៀវភៅនេះ មានន័យគ្របដណ្តប់ទាំងសាលាក្រៅប្រព័ន្ធ និងក្នុងប្រព័ន្ធ សម្រាប់ទាំងមត្តេយ្យ បឋមសិក្សា និងមធ្យមសិក្សា។ ក្នុងកម្រងសៀវភៅនេះ ពាក្យ"សាលារៀន"ប្រើក្នុងន័យទូទៅ សម្រាប់បរិយាកាសអប់រំទាំងអស់។ បរិយាកាស គិតទាំងសាលាក្នុងប្រព័ន្ធ ឬសាលាក្រៅផ្លូវការ ដូចជា រៀនក្រោមដើមឈើជាដើម។ ទោះបីជាអ្នកជាគ្រូបង្រៀនជំនាញ ក៏ដោយ ក៏អ្នកអាចប្រើកម្រងសៀវភៅនេះបានដែរ។ ទោះបីជាអ្នកជាមនុស្សធម្មតាម្នាក់ ដែលមានបំណងចង់ជួយកុមារដែលមានប្រវត្តិ និងសមត្ថភាពខុសគេឲ្យចូលរៀនក្នុងថ្នាក់ក្រៅផ្លូវការ (ថ្នាក់ក្រោមដើមឈើ) ក៏អ្នកអាចប្រើកម្រងសៀវភៅនេះបានដែរ។

តើអ្នកនឹងរៀនអ្វីខ្លះពីកម្រងសៀវភៅនេះ?

ក្នុងកម្រងសៀវភៅនេះ អ្នកនឹងបានរៀនអំពី"បរិយាកាសរៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព" និង រៀនអំពីវិធីកែប្រែសាលា និងថ្នាក់រៀនរបស់អ្នក ឲ្យទៅជាបរិយាកាសរៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព។ (កម្រងសៀវភៅលេខ១)។

អ្នកនឹងរៀនអំពីសារៈសំខាន់របស់គ្រួសារ និងសហគមន៍ក្នុងសកម្មភាពបង្កើតបរិយាកាសរៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព និងរៀនអំពីវិធីចូលនាឲ្យមាតាបិតាសិស្ស និងសហគមន៍ចូលរួមក្នុងសកម្មភាពសាលា និងវិធីចូលនាឲ្យកុមារ ចូលរួមក្នុងសកម្មភាពសហគមន៍ (កម្រងសៀវភៅលេខ ២)។

អ្នកនឹងរៀនអំពីឧបសគ្គរារាំងកុមារមួយចំនួនមិនឲ្យមានឱកាសចូលរៀននៅសាលា រៀនអំពីវិធីកំណត់រកអត្តសញ្ញាណកុមារ ដែលមិនបានចូលសាលា និងរៀនអំពីវិធីជំនះរាល់ឧបសគ្គទាំងនោះ ដើម្បីបញ្ចូលកុមារគ្រប់សមាសភាពចូលរៀនក្នុងសាលា (កម្រងសៀវភៅលេខ ៣)។

អ្នកនឹងរៀនអំពីវិធីបង្កើតថ្នាក់រៀនដែលដាក់បញ្ចូលគ្នាគ្រប់សមាសភាព និងអំពីមូលហេតុដែលថាបរិយាកាសរៀនមេត្រីដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព មានសារៈសំខាន់សម្រាប់ជោគជ័យរបស់កុមារក្នុងការសិក្សា រៀនអំពីវិធីធ្វើការជាមួយកុមារជាច្រើនប្រភេទដែលរៀនក្នុងថ្នាក់របស់អ្នក និងរៀនអំពីវិធីធ្វើឲ្យសកម្មភាពរៀនសូត្រមានអត្ថន័យសម្រាប់កុមារទាំងអស់ (កម្រងសៀវភៅលេខ៤)។

អ្នកនឹងរៀនអំពីវិធីគ្រប់គ្រងថ្នាក់រៀន ដែលបញ្ចូលគ្រប់សមាសភាព គិតទាំងវិធីរៀបចំកិច្ចតែងការបង្រៀន វិធីរកធនធាន ដែលមានស្រាប់ឲ្យបានច្រើនដល់កម្រិតអតិបរមា វិធីគ្រប់គ្រងការងារជាក្រុម និងការរៀនដែលមានកិច្চសហការគ្នា ក៏ដូចជាវិធីវាយតម្លៃការរៀនសូត្ររបស់សិស្ស (កម្រងសៀវភៅលេខ៥)។

ជាទីបញ្ចប់ អ្នកនឹងរៀនអំពីវិធីធ្វើឲ្យសាលារៀនក្លាយជាកន្លែងដែលមានសុខភាព និងសុវត្ថិភាពសម្រាប់កុមារគ្រប់រូប ហើយជាពិសេសសម្រាប់កុមារដែលមានប្រវត្តិ និងសមត្ថភាពខុសគេ ដែលងាយរងគ្រោះដោយសារជំងឺ ខ្វះអាហារូបត្ថម្ភ និងជាជនរងគ្រោះ (កម្រងសៀវភៅលេខ៦)។

រៀនសូត្រពីអ្នកដទៃ

គ្រូបង្រៀន និងអ្នកអនុវត្តការងារអប់រំនៅជុំវិញពិភពលោកបានជួយរៀបរៀងកម្រងសៀវភៅនេះ។ អ្នកទាំងអស់នេះ ក៏បានចូលរួមក្នុងសិក្ខាសាលាតំបន់ទាំងបួនលើក ហើយបានចែករំលែកបទពិសោធ និងចំណេះដឹង ហើយបង្កើតជាគោលសម្រាប់ប្រើ ដើម្បីប្រមូលកុមារទាំងអស់ឲ្យចូលរៀនក្នុងសាលា និងខំរៀន។ ការរៀបរៀងកម្រងសៀវភៅនេះមានការចូលរួមពីសំណាក់មនុស្សមួយចំនួន ដែលបានចែករំលែកចំណេះដឹង និងគោលមួយចំនួន តាមរយៈឯកសារបោះពុម្ព និងអ៊ីនធឺណែត។ ការរៀបរៀងកម្រងសៀវភៅនេះក៏មានការចូលរួមរបស់មនុស្សមួយចំនួន ដែលជា "អ្នកទិដ្ឋៀន" ដែលបានចូលរួមកែលំអសេចក្តីព្រាង

កម្រងសៀវភៅនេះ។ សំខាន់ជាងគេបំផុតនោះគឺ ការរៀបចំកម្រងសៀវភៅនេះ ក៏មានការចូលរួមពីសំណាក់សាលា និងគ្រូបង្រៀនមកពីប្រទេសជាច្រើន ដែលបានចូលរួមពិនិត្យ ផ្តល់យោបល់ និងផ្តល់គោលបន្ថែមសំរាប់តែលំអកម្រងសៀវភៅនេះដែរ។ ដូច្នេះ អ្នកនឹងរៀនបានច្រើនពីមនុស្សជាច្រើន ព្រោះកម្រងសៀវភៅនេះបានប្រមូលផ្តុំបទពិសោធមកពីប្រទេសជាច្រើន ហើយគោលដែលមានចែងក្នុងកម្រងសៀវភៅនេះក៏មានប្រើនៅសាលាជាច្រើនដែរ ជាពិសេស សាលានៅតំបន់អាស៊ីប៉ាស៊ីភិច។ សំណួរដ៏សំខាន់បំផុតមួយក្នុងកម្រងសៀវភៅនេះគឺ ត្រូវសួរខ្លួនឯងថា "តើខ្ញុំអាចកែប្រែកម្រងសៀវភៅនេះសម្រាប់ប្រើប្រាស់ ក្នុងថ្នាក់រៀន និងសាលារៀនរបស់ខ្ញុំដោយរបៀបណា?"

កំណត់សម្គាល់ពាក្យប្រើក្នុងកម្រងសៀវភៅនេះ

បញ្ហាមួយដែលត្រូវពិចារណាក្នុងការរៀបរៀងកម្រងសៀវភៅនេះគឺថា តើគួរប្រើពាក្យណាទើបសម? តាមធម្មតា ការប្រើពាក្យខុសគ្នា តែអាចពណ៌នារឿងតែមួយបាន។ លើសនេះទៀត ពាក្យមួយអាចបង្ហាញអំពីគំនិត ឬអារម្មណ៍ ដោយគ្មានចេតនា។ ជាក់ស្តែង យើងគួរជៀសវាងប្រើពាក្យណាដែលបង្ហាញពីការរើសអើង។ យើងក៏គួរប្រើពាក្យសាមញ្ញ និងមានលក្ខណៈមេត្រីភាព។

ដើម្បីរក្សានិយមក្នុងកម្រងសៀវភៅនេះ យើងបានប្រើពាក្យសាមញ្ញៗឲ្យបានច្រើនបំផុត។ ពាក្យនិងឃ្លាមួយចំនួន ដែលប្រើញឹកញាប់ក្នុងកម្រងសៀវភៅនេះគឺ :

- កុមារដែលមានប្រវត្តិ និងសមត្ថភាពខុសគេ ប្រហែលជាឃ្លាដែលប្រើញឹកញាប់បំផុតក្នុងកម្រងសៀវភៅនេះ។ ឃ្លានេះសំដៅដល់កុមារទាំងឡាយណា ដែលនៅក្រៅប្រព័ន្ធ និងត្រូវគេទាត់ចោលឲ្យនៅក្រៅប្រព័ន្ធអប់រំ ដោយសារហេតុផល ដូចជា យេនឌ័រ រូបរាងកាយ បញ្ញា ស្ថានភាពសង្គម ភាសា វប្បធម៌ សាសនា ឬស្ថានភាពផ្សេងៗទៀត។

- ពាក្យបរិយាកាសរៀន មានន័យថា ជាបរិយាកាសរៀនក្នុងប្រព័ន្ធ ឬក្រៅប្រព័ន្ធដែលកុមារមានឱកាសស្រូបយកចំណេះដឹង និងជំនាញសម្រាប់ប្រើប្រាស់ ក្នុងជីវភាពរស់នៅ។ បរិយាកាសរៀនក៏គិតទាំងសាលា មណ្ឌលវប្បធម៌ និងមជ្ឈមណ្ឌលកីឡា និងសមាគមផ្សេងៗ។

- "ការអប់រំដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព" និង"ការរៀនដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព" មានន័យថា ជាការបញ្ចូល និងបង្រៀនកុមារទាំងអស់ ទាំងក្នុងបរិយាកាសរៀនក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធ ដោយមិនប្រកាន់យេនឌ័រ រូបរាងកាយ បញ្ញា ស្ថានភាពសង្គម ភាសា វប្បធម៌ សាសនា ឬ ស្ថានភាពផ្សេងៗទៀតផ្តើយ។

- "រៀនមេត្រី" មានន័យថា បញ្ចូលកុមារឲ្យស្ថិតក្នុងវង្វង់នៃសកម្មភាពរៀន ហើយត្រូវទទួលស្គាល់ថាបរិយាកាសរៀនទូទៅរបស់កុមារ គឺមានកត្តាផ្សេងៗ ដូចជា (គ្រូបង្រៀន អ្នករដ្ឋបាលសាលា

មាតាបិតា អ្នកដឹកនាំសហគមន៍) ដែលមិនត្រឹមតែជួយណែនាំដល់ការរៀនសូត្ររបស់កុមារទេ ប៉ុន្តែថែមទាំងដើរតួជាអ្នករៀនដោយខ្លួនឯងផងដែរ។ បរិយាកាសរៀនមេត្រី ជាបរិយាកាសដែលកុមារបានទទួលផលប្រយោជន៍ មិនត្រឹមតែពីការរៀនសូត្រដោយខ្លួនឯងទេ ប៉ុន្តែថែមទាំងពីការរៀនសូត្ររបស់អ្នកដទៃ ដែលមានតម្លៃវិភាពិសេសផងដែរ។ ឧទាហរណ៍ បរិយាកាសរៀនមេត្រីមិនត្រឹមតែផ្តល់ឱកាសឲ្យកុមារចូលរួមក្នុងសកម្មភាព ដែលប្រើប្រាស់វិធីសាស្ត្របង្រៀនថ្មី។ ប៉ុណ្ណោះទេ ប៉ុន្តែក៏ជាបរិយាកាសមួយសម្រាប់ឲ្យមាតាបិតា និងសហគមន៍ចូលរួមយ៉ាងសកម្ម ដើម្បីជួយកុមារឲ្យចូលរៀន និងជួយឲ្យសាលាដំណើរការផងដែរ។

- "ថ្នាក់រៀន" គឺនិយាយសំដៅដល់ទីកន្លែងពិតប្រាកដមួយ ដែលកុមារទាំងអស់មកជួបជុំគ្នាដើម្បីរៀន ដោយមានជំនួយពីគ្រូ។ ថ្នាក់រៀនរួមមាន ថ្នាក់រៀនក្នុងប្រព័ន្ធក្នុងសាលារដ្ឋ ថ្នាក់រៀនក្រៅផ្លូវការសម្រាប់កុមារពលកម្ម រៀនក្រោមដើមឈើ ថ្នាក់រៀននៅមជ្ឈមណ្ឌលយុវជនសំរាប់កុមាររស់តាមចិញ្ចើមថ្នល់ និងថ្នាក់រៀនតាមផ្ទះជាបណ្តោះអាសន្ន ឬជាអចិន្ត្រៃ ដោយសារកុមាររៀននៅតាមបរិយាកាសផ្សេង។

- "គ្រូបង្រៀន ឬគ្រូ" ជាមនុស្សដែលដឹកនាំកុមារឲ្យរៀនក្នុងបរិយាកាសរៀនក្រៅប្រព័ន្ធ ឬក្នុងប្រព័ន្ធ។

- "សិស្ស" "អ្នករៀន" ឬ "កូនសិស្ស" គឺសំដៅដល់ អ្នករៀនដែលបានចូលរៀនក្នុងប្រព័ន្ធ ឬក្រៅប្រព័ន្ធ។ ពាក្យទាំងនេះប្រើផ្លាស់ប្តូរគ្នាក្នុងកម្រងសៀវភៅនេះ។

- "កុមារពិការ"រួមមានកុមារទាំងឡាយណាដែលពិការរាងកាយ ពិការសតិ និងពិការបញ្ញា និងកុមារទាំងឡាយណាដែលស្ថិតក្នុងស្ថានភាពពិការផ្សេង។ កុមារទាំងនេះ គិតទាំងកុមារពិការពីកំណើត ទាំងរាងកាយ និងបញ្ញា ឬកុមារពិការដោយសារជំងឺ គ្រោះថ្នាក់ ឬដោយសារហេតុផលផ្សេង។ទៀត។ ពិការអាចឲ្យឧទាហរណ៍ ដូចជាកុមារមានបញ្ហាភ្នែក ស្តាប់ ឬមានបញ្ហាធ្វើចលនាសារពាង្គកាយ ឬអវយវៈណាមួយ។ កុមារទាំងនេះអាចជាកុមារដែលរៀនឡាយ ហើយត្រូវការរៀនតាមវិធីផ្សេងពីកុមារដទៃ។ នៅប្រទេសជាច្រើន មិនមែនកុមារទាំងអស់ទេ ដែលរកឃើញថា ពិការ ប៉ុន្តែមានតម្រូវការការអប់រំពិសេស ហើយកុមារទាំងអស់ដែលរកឃើញថាមានតម្រូវការអប់រំពិសេស ក៏មិនពិការទាំងអស់ដែរ។ កុមារទាំងពីរក្រុមនេះមិនដូចគ្នាទេ។ កុមារពិការអាចមានសមត្ថភាពរៀន និងមានសិទ្ធិចូលរៀននៅសាលា ដូចកុមារដទៃដែរ ប៉ុន្តែកុមារទាំងនេះមិនត្រូវបានបញ្ចូលឲ្យរៀនក្នុងសាលាទេ ជាពិសេស នៅប្រទេសជាច្រើននៅតំបន់អាស៊ីប៉ាស៊ីភិច។

- "សិស្ស ដែលមានតម្រូវការរៀនពិសេស ឬតម្រូវការអប់រំពិសេស" ជាសិស្សដែលទាមទារការយកចិត្តទុកដាក់ជួយក្នុងពេលរៀន។ នៅប្រទេសភាគច្រើន ការយកចិត្តទុកដាក់បែបនេះ មានផ្តល់ឲ្យសិស្ស ទាំងក្នុងសាលា ឬថ្នាក់រៀនពិសេស និងសាលា ឬថ្នាក់រៀនធម្មតា។ ប្រទេសជាច្រើនបានកំណត់ប្រភេទក្រុមសិស្សបែបនេះថា ជា"ក្រុមដែលមានតម្រូវការអប់រំពិសេស" ដែលខុសពីសិស្សធម្មតា។ ពេលប្រើពាក្យនេះក្នុងកម្រងឯកសារនេះ យើងក៏ទទួលស្គាល់នូវការកំណត់ប្រភេទសិស្សបែបនេះដែរ។ ប៉ុន្តែ សេចក្តីសន្និដ្ឋានមិនបានទាញថា មានភាពខុសគ្នាក្នុងការអប់រំជាក់ស្តែង រវាងសិស្សដែលមានតម្រូវការរៀនពិសេស ឬមានតម្រូវការអប់រំពិសេស និងសិស្សធម្មតាឡើយ។

- "ភេទ" និយាយសំដៅទៅលើភាពខុសគ្នារវាងបុរស និងស្ត្រីដោយសំអាងលើជីវៈ។

- "យេនឌ័រ" និយាយសំដៅដល់តួនាទីក្នុងសង្គម ដែលបុរស និងស្ត្រីធ្វើដាច់ដោយឡែកពីគ្នាក្នុងស្ថានភាពសង្គមណាមួយ។ ឧទាហរណ៍ "បុរសជាមេគ្រួសារ" ហើយ"ស្ត្រីត្រូវមើលថែរក្សាកូន"។ តួនាទីយេនឌ័រគឺ សង្គមជាអ្នកបង្កើត ហើយផ្សព្វផ្សាយពីជំនាន់មួយទៅជំនាន់មួយ ដែលយូរៗទៅក្លាយទៅជាវប្បធម៌របស់សង្គម។ ដោយសារយេនឌ័រជាខ្លឹមសារនៃការរៀនក្នុងសង្គម (ឧទាហរណ៍ រៀនក្នុងគ្រួសារ និងក្នុងសាលា) ដូច្នេះ អ្វីទាំងអស់ដែលទាក់ទងនឹងយេនឌ័រគឺ អាចផ្លាស់ ប្តូរបាន ហើយអាចធានាឲ្យមានសមភាព និងសមធម៌សម្រាប់ ទាំងបុរស និងស្ត្រីបានផងដែរ។ ម្យ៉ាងវិញទៀត យើងក៏ផ្លាស់ប្តូរតួនាទីរបស់ស្ត្រីដែលធ្លាប់តែថា "ស្ត្រីត្រូវមើលថែរក្សាកូន" ឲ្យទៅជា"ស្ត្រីជាមេគ្រួសារ" ហើយប្តូរពីទម្លាប់ដែលថា "បុរសជាមេគ្រួសារ" ឲ្យទៅជា "បុរសត្រូវថែរក្សាកូន" ហើយអាចប្តូរបានថា បុរសនិងស្ត្រី ជាមេគ្រួសារ និងត្រូវថែរក្សាកូន"។

- "គ្រួសារ"មានន័យថា ជាកោសិកាសង្គមដ៏សំខាន់មួយ ដែលចិញ្ចឹមបីបាច់ថែរក្សាកុមារ ហើយ"សហគមន៍" ជាក្រុមសង្គមធំមួយ ដែលកុមារ និងគ្រួសាររស់នៅក្រោមដំបូលរបស់វា។

កំណត់សម្គាល់សម្រាប់អ្នកបកប្រែ និងអ្នកកែសម្រួល

កម្រងសៀវភៅនេះសេរសេរជាភាសាដើម គឺ អង់គ្លេស ប៉ុន្តែ ដើម្បីឲ្យកម្រងសៀវភៅនេះប្រើយ៉ាងទូលំទូលាយ ចាំបាច់ត្រូវបកប្រែឲ្យបានច្រើនភាសា ហើយកែសម្រួលឲ្យស្របតាមបរិបទប្រទេស ដែលប្រើភាសាបកប្រែនោះ។ សម្រាប់អ្នកបកប្រែ ឬអ្នកកែសម្រួលកម្រងសៀវភៅនេះ ចូរចងចាំចំណុចសំខាន់ៗដូចខាងក្រោម :

ទម្រង់ សូរស័ព្ទ និងវាក្យស័ព្ទ

កម្រងសៀវភៅនេះសរសេរជាលក្ខណៈសាមញ្ញ និងមានមេត្រីភាពសម្រាប់អ្នកអាន។ ហេតុដូច្នេះ កម្រងសៀវភៅនេះ សរសេរជាទម្រង់សន្ទនាសាមញ្ញ និងភាសាប្រើក្នុងជីវភាពរស់នៅធម្មតា គឺមានទម្រង់ដូចជានិយាយដ៏សាមញ្ញជាមួយគ្រូបង្រៀនម្នាក់ មិនមែនសរសេរជាទម្រង់ពិបាកយល់ និងផ្លូវការទេ។ អ្នកបកប្រែ ក៏អាចប្រើភាសាជាទម្រង់បែបនេះដែរ សូមកុំប្រើភាសាសរសេរបែបផ្លូវការ និងស្មុគស្មាញពេក។

កម្រងសៀវភៅនេះសរសេរក្នុងសូរស័ព្ទវិជ្ជមាន និងទាក់អារម្មណ៍អ្នកអាន។ យើងចង់ទាក់ទាញអារម្មណ៍គ្រូបង្រៀន និងអ្នកអានផ្សេង។ទៀតឲ្យកាន់តែចង់រៀនបន្តមទៀតពីកម្រងសៀវភៅនេះ។ យើងមិនសរសេរក្នុងសូរស័ព្ទត្រង់ថា កន្លែងនេះខុស ឬត្រូវទេ ហើយកន្លែងនេះគួរធ្វើ និងកន្លែងនេះមិនគួរធ្វើទេ។ ដូច្នេះយើងសូមឲ្យអ្នកបកប្រែប្រើសូរស័ព្ទ បែបនេះក្នុងការបកប្រែកម្រងសៀវភៅនេះ។

ទោះជាកម្រងសៀវភៅនេះសរសេរច្បាប់ដើមជាភាសាអង់គ្លេសក្តី យើងក៏បានយកទៅសាកល្បងនៅក្នុងសិក្ខាសាលាតំបន់បីលើករួចហើយដែរ (នៅចាំគីស្តាន ភីលីពីន និងថៃ)។ ការសាកល្បងនេះរៀបចំឡើងក្នុងគោលបំណងសិក្សាថា តើអ្នកដែលមានភាសាកំណើតមិនមែនអង់គ្លេសអាចយល់កម្រងសៀវភៅនេះឬទេ។ ដើម្បីឲ្យកាន់តែងាយយល់ ក្នុងកម្រងសៀវភៅនេះ យើងប្រើពាក្យយ៉ាងសាមញ្ញ។ យើងមិនមានបំណងប្រើពាក្យពិបាកទេ។ ពាក្យពិបាកមួយចំនួនប្រហែលជាងាយស្រួលសម្រាប់អ្នកជំនាញមួយចំនួន ប៉ុន្តែអាចពិបាកយល់សម្រាប់អ្នកផ្សេង។ ប៉ុន្តែ ពាក្យពិសេសមួយចំនួនអាចពិបាកបកប្រែ។ ឧទាហរណ៍ ពាក្យ "យេនឌ័រ" ប្រហែលជាមិនមានក្នុងភាសាខ្លះទេ ប៉ុន្តែត្រូវបកពាក្យនេះឲ្យត្រូវតាមន័យរបស់ពាក្យ។ បើអ្នកយល់ថា ពាក្យខ្លះពិបាកបកប្រែ និងពាក្យបកប្រែជាភាសាកំណើតរបស់អ្នក សូមជួបជាមួយអ្នកជំនាញ និងអង្គការជំនាញ ដែលបានប្រើពាក្យនេះរួចហើយ។ ឧទាហរណ៍ ពាក្យ"យេនឌ័រ" ជាពាក្យមួយដែលមិនត្រឹមតែប្រើក្នុងវិស័យអប់រំប៉ុណ្ណោះទេ ប៉ុន្តែក៏ប្រើក្នុងកម្មវិធីសុខភាពបន្តពូជ និងប្រជាសាស្ត្រផងដែរ ហើយក៏ប្រើក្នុងសិទ្ធិមនុស្សផងដែរ។ បើអ្នកអប់រំមិនទាន់បកប្រែពាក្យនេះទេ (ឬបកប្រែហើយតែមិនត្រូវ) សូមទៅជួបជាមួយអង្គការជាតិ ឬអង្គការអន្តរជាតិដែលបានបកប្រែពាក្យនេះ។

បរិបទ និងខ្លឹមសារ

យើងបានព្យាយាមប្រើករណីសិក្សា និងបទពិសោធមកពីប្រទេសជាច្រើនទាំងនៅអាស៊ី និងក្រៅអាស៊ី។ ប៉ុន្តែករណីសិក្សាទាំងនេះ អាចខុសពីបរិបទក្នុងប្រទេសរបស់អ្នក។ ឧទាហរណ៍ គ្រូបង្រៀនចង់ឃើញករណីសិក្សាក្នុងប្រទេស ព្រោះគ្រូបង្រៀនទាំងអស់យល់ថា ករណីសិក្សាក្នុងប្រទេសអាចងាយយល់ជាង។ ក្នុងករណីបែបនេះ អ្នកត្រូវរកករណីសិក្សាក្នុងប្រទេសមកជំនួសករណីសិក្សាដែលមានក្នុងកម្រងសៀវភៅនេះ។ ប៉ុន្តែ ត្រូវចាំថា ករណីសិក្សាទាំងនោះត្រូវស្របតាមខ្លឹមសារពាក់ព័ន្ធក្នុងអត្ថបទ។

ជាទូទៅ ខ្លឹមសារក្នុងកម្រងសៀវភៅនេះ ត្រូវមានអត្ថន័យស្របតាមបរិបទក្នុងសហគមន៍របស់អ្នក។ ឧទាហរណ៍ ត្រូវបញ្ចូលកុមារដែលនៅក្រៅសាលា ដែលមានសរសេរក្នុងកម្រងសៀវភៅលេខ៣។ ឧទាហរណ៍ ត្រូវផ្តល់ករណីសិក្សាជាក់ស្តែងអំពី "យេនឌ័រ" ដើម្បីជួយអ្នកអានឲ្យងាយយល់អំពីខ្លឹមសារក្នុងកម្រងសៀវភៅ។ សូមកែប្រែខ្លឹមសារក្នុងកម្រងសៀវភៅឲ្យស្របតាមបរិបទរបស់សហគមន៍របស់អ្នក។

លើសនេះទៀត ខ្លឹមសារក្នុងកម្រងសៀវភៅនេះ ច្រើនពាក់ព័ន្ធនឹងការពិតរបស់សាលាក្នុងប្រទេសរបស់អ្នក។ ឧទាហរណ៍នៅប្រទេសដែលមានកម្មវិធីបង្រៀនថ្នាក់ក្បួប អ្នកត្រូវកែប្រែសកម្មភាពឲ្យស្របតាមបរិបទក្នុងស្ថានភាពនោះ។

ក្នុងការកែសម្រួលសកម្មភាព វិធីសាស្ត្រ និងករណីសិក្សាក្នុងកម្រងសៀវភៅនេះឲ្យស្របតាមបរិបទក្នុងសហគមន៍ ស្ថានភាពសាលារៀន ត្រូវសហការជាមួយគ្រូបង្រៀនដែលធ្លាប់បានចូលរួមក្នុងសកម្មភាពសាលារៀនកុមារមេត្រី ឬថ្នាក់រៀនកុមារមេត្រី។ គ្រូទាំងនោះអាចជួយអ្នកក្នុងការកំណត់រកសកម្មភាព វិធីសាស្ត្រ ឬករណីសិក្សា (ឲ្យកាន់តែសមស្រប) ផ្សេង។ទៀត បន្ថែមទៅលើអ្វីដែលមានស្រាប់ក្នុងគោលនីមួយ។ និងកម្រងសៀវភៅនីមួយ។។ អ្នកអាចដកសកម្មភាព ឬករណីសិក្សាណាមួយចេញពីកម្រងសៀវភៅនេះ បើអ្នកមានសកម្មភាព ឬករណីសិក្សា ដែលសមស្របសម្រាប់បរិបទសហគមន៍ ឬសាលារៀនរបស់អ្នក។

ជាទីបញ្ចប់ កញ្ចប់កម្រងសៀវភៅនេះត្រូវតែជាប់បានយូរ ហើយងាយស្រួលប្រើ (ឧទាហរណ៍ ងាយយកទៅថតចម្លង កម្រងសៀវភៅនីមួយ។ត្រូវដាច់ពីគ្នា ដៀសវាងចង់ក្រងជាសៀវភៅមួយក្បាលធំ។ អ្នកគួរពិគ្រោះយោបល់ជាមួយគ្រូបង្រៀន ដើម្បីសួរយោបល់ថា តើគ្រូបង្រៀនចង់បានកម្រងសៀវភៅក្នុងរូបរាងបែបណា?

ការបោះពុម្ពលើកទី ១ : ឆ្នាំ ២០១៦

កម្រងសៀវភៅលេខ : ១

ប្រែក្លាយឱ្យទៅជាបរិយាកាសរៀនមេត្រី ដោយបញ្ចូលគ្រប់សមាសភាព

បោះពុម្ពផ្សាយដោយ ក្រសួងអប់រំ យុវជន និងកីឡា ដែលមានការគាំទ្រពីអង្គការយូណេស្កូ



បរិយាកាសរៀនមេត្រី
ដោយបញ្ចូលគ្រប់សមាសភាព

UNESCO

សេចក្តីណែនាំអំពីគោល

កម្រងសៀវភៅលេខ ១ ពណ៌នាអំពីបរិយាកាសរៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព និងអំពីសារប្រយោជន៍នៃបរិយាកាសរៀនមេត្រី សម្រាប់គ្រូបង្រៀន កុមារ មាតាបិតា និងសម្រាប់សហគមន៍។ កម្រងសៀវភៅនេះ ជួយអ្នកឲ្យចេះរិះរកវិធីប្រែក្លាយសាលារបស់អ្នកឱ្យទៅជាសាលារៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព និងរកចំណុចដែលត្រូវកែលំអ ក្នុងសាលារៀនរបស់អ្នកផងដែរ។ កម្រងសៀវភៅនេះ ក៏ផ្តល់គំនិតគួរពិចារណាអំពីវិធីធ្វើដែនការ ដើម្បីកែលំអសាលារៀន និងអំពីវិធីតាមដាន និងវាយតម្លៃការរីកចម្រើនរបស់សាលារៀនផងដែរ។

គោល

គោល ១.១ តើបរិយាកាសរៀនមេត្រីជាអ្វី? ហេតុអ្វីបានជាមានសារៈសំខាន់? ៣

តើពាក្យ "ដាក់បញ្ចូលគ្នាគ្រប់សមាសភាព និងរៀនមេត្រីមានន័យយ៉ាងដូចម្តេច? ៣

តើកត្តាសំខាន់ៗរបស់បរិយាកាសរៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាពមានអ្វីខ្លះ? ៨

តើបរិយាកាសរៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាពផ្តល់ផលប្រយោជន៍អ្វីខ្លះ? ១២

គោល ១.២ តើសាលារបស់យើងកំពុងស្ថិតក្នុងស្ថានភាពណា? ១៨

តើសាលារបស់យើងបានក្លាយជាសាលាដែលមានបរិយាកាសរៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាពហើយឬនៅ? ១៨

តើសាលារបស់យើងអាចក្លាយទៅជាសាលាដែលមានបរិយាកាសរៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាពដោយរបៀបណា? ២៥

វិធីកែប្រែ និងជានានិរន្តរភាពនៃការកែប្រែនេះ ២៧

គោល ១.៣ ជំហានអនុវត្ត ដើម្បីប្រែក្លាយឱ្យទៅជាបរិយាកាសរៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព ៣១

ជំហានធ្វើដែនការ ដើម្បីប្រែក្លាយឱ្យទៅជាបរិយាកាសរៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព ៣១

វិធីតាមដានការរីកចម្រើនរបស់យើង ៣៦

គោល ១.៤ តើយើងបានរៀនពីបទពិសោធកន្លងមកអ្វីខ្លះ?..... ៣៩



គោល ១.១
តើបរិយាកាសរៀនមេត្រីដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាពជាអ្វី? ហើយហេតុអ្វីបានជាមានសារៈសំខាន់?

ការអប់រំដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាពនិយាយអំពី ការកែប្រែជាក់ស្តែង ដែលអាចជួយកុមារដែលមានជីវប្រវត្តិ និងសមត្ថភាពខុសគេ និងកុមារប្រភេទផ្សេងៗទៀតឲ្យមានឱកាសចូលរៀន និងរៀនបានជោគជ័យក្នុងថ្នាក់រៀន និងក្នុងសាលារៀន។ ការដាក់បញ្ចូលគ្នាគ្រប់សមាសភាពនេះ មិនត្រឹមតែផ្តល់ផលប្រយោជន៍ សម្រាប់កុមារដែលអ្នកអប់រំ តែងហៅថា កុមារដែលមានតម្រូវការអប់រំពិសេស ប៉ុន្តែថែមទាំងផ្តល់ផលប្រយោជន៍ដល់កុមារ មាតាបិតា គ្រូបង្រៀន អ្នករដ្ឋបាលសាលា និងមនុស្សក្នុងសហគមន៍គ្រប់រូប។ ដែលធ្វើការជាមួយសាលារៀនផងដែរ។

តើពាក្យថា "ការដាក់បញ្ចូលគ្នាគ្រប់សមាសភាព និងរៀនមេត្រីមានន័យយ៉ាងដូចម្តេច?

តើការអប់រំដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាពជាអ្វី?

អស់រយៈពេលជាច្រើនឆ្នាំមកហើយ ពាក្យ "ដាក់បញ្ចូលគ្នាគ្រប់សមាសភាព" មានន័យថា "ដាក់បញ្ចូលកុមារពិការឱ្យចូលរៀនក្នុងថ្នាក់រៀន"ធម្មតា"ជាមួយកុមារមិនពិការ។ ក្នុងកម្រងសៀវភៅនេះ ពាក្យ"ដាក់បញ្ចូលគ្នាគ្រប់សមាសភាព"មានន័យច្រើនលើសពីន័យខាងលើនេះច្រើនណាស់។

ពាក្យ"ដាក់បញ្ចូលគ្នាគ្រប់សមាសភាព"គឺបានរាប់បញ្ចូលទាំងកុមារពិការ ដូចជា កុមារដែលមានបញ្ហាក្នុងការមើល ឬស្តាប់ កុមារដែលមិនអាចដើរបាន ឬកុមារដែលរៀនយឺត។ ប៉ុន្តែ ពាក្យ"ដាក់បញ្ចូលគ្នាគ្រប់សមាសភាព" ក៏មានន័យថា បញ្ចូលកុមារទាំងអស់ដែលត្រូវគេចោះបង់ចោល និងមិនគិតគូរឱ្យចូលរៀនក្នុងសាលា។ កុមារទាំងនេះអាចនិយាយភាសាដែលសិស្សក្នុងថ្នាក់ទាំងអស់មិនប្រើ អាចប្រឈមមុខនឹងការចោះបង់ចោលសាលា ដោយសារឈឺ ហេវហត់ពេក និងរៀនខ្សោយពេក ហើយអាចជាកុមារដែលកាន់សាសនាខុសពីអ្នកដទៃរៀនក្នុងសាលា។ កុមារទាំងនេះអាចជាកុមារីដែលមានផ្ទៃពោះ កុមាររងគ្រោះដោយសារមេរោគអេដស៍/ជំងឺអេដស៍ អាចជាកុមារី និងកុមារាដែលគ្មានឱកាសចូលរៀន ជាពិសេស កុមារពលកម្មតាមផ្លូវ តាមការដ្ឋាន ឬអាចជាកូនជនអន្តោប្រវេសន៍ ហើយអាចជាកុមារដែលមានការងារធ្វើដោយមានប្រាក់កំរៃ ដើម្បីជួយបន្ទុកគ្រួសារ។ ពាក្យ"ដាក់បញ្ចូលគ្នាគ្រប់សមាសភាព"មានន័យថា ក្នុងតួនាទីជាគ្រូបង្រៀន យើងត្រូវមានការទទួលខុសត្រូវក្នុងការស្វែងរកជំនួយគាំទ្រ (ពីអាជ្ញាធរ ពីសាលារៀន ពីសហគមន៍ ពីគ្រួសារ ពីកុមារ ពីស្តាប់ងអប់រំ ពីសេវាសុខាភិបាល ពីអ្នកដឹកនាំ និងពីប្រភពផ្សេងទៀត) ដើម្បីកំណត់ និងស្វែងរកកុមារគ្រប់ប្រភេទឱ្យចូលសាលារៀន ហើយបង្រៀនកុមារទាំងអស់នោះ។

លើសនេះទៀត ក្នុងសហគមន៍មួយចំនួន កុមារទាំងអស់បានចុះឈ្មោះចូលរៀននៅសាលារៀហើយ ប៉ុន្តែកុមារទាំងនោះត្រូវគេទាត់ចោលមិនឱ្យចូលរៀននៅសាលា និងមិនឱ្យរៀនក្នុងថ្នាក់។ កុមារប្រភេទនេះអាចជា :

- មានភាសាកំណើត ដែលមិនប្រើក្នុងសៀវភៅសិក្សា។
- កុមារដែលមិនធ្លាប់មានឱកាសចូលរួមក្នុងសកម្មភាពអ្វី។
- កុមារដែលមិនធ្លាប់មានឱកាសរួមវិភាគទានអ្វីសោះ។
- កុមារដែលមិនមានក្តារ ឬមិនមានសៀវភៅ ឬកុមារដែលមិនអាចស្តាប់គ្រូឮ។
- កុមារដែលរៀនខ្សោយ និងកុមារមិនមានអ្នកណាយកចិត្តទុកដាក់ជួយ។

កុមារទាំងអស់នេះអាចអង្គុយនៅជួរក្រោយ ហើយមិនយូរប៉ុន្មាន អាចបោះបង់ចោលសាលា។ ក្នុងតួនាទីជាគ្រូបង្រៀន យើងត្រូវទទួលខុសត្រូវបង្កើតបរិយាកាសរៀនមួយដែលកុមារទាំងអស់ អាចរៀនបាន ចង់រៀន និងមានអារម្មណ៍ចូលរួមក្នុងសកម្មភាពថ្នាក់រៀន និងសាលារៀន។

តើបរិយាកាសរៀនមេត្រីជាអ្វី?

ជាងដប់ឆ្នាំកន្លងមកនេះ មានសាលាជាច្រើនបានខិតខំប្រែក្លាយខ្លួនឱ្យទៅជាសាលា"កុមារមេត្រី"។ "សាលាកុមារមេត្រី" ជាសាលាដែលកុមារទាំងអស់មានសិទ្ធិរៀនរហូតអស់សក្តានុភាព ក្នុងបរិយាកាសមួយដែលមានសុវត្ថិភាព និងមានមេត្រីភាព។ គោលបំណងរបស់សាលាកុមារមេត្រី សំដៅបំផុសការចូលរៀន និងសកម្មភាពរៀនរបស់កុមារក្នុងសាលា ជាជាងគ្រាន់តែយកចិត្តទុកដាក់តែលើការបង្រៀនមុខវិជ្ជា និងការប្រឡង។ ការប្រែក្លាយឱ្យទៅជា "សាលាកុមារមេត្រី" មានសារៈសំខាន់ណាស់ ប៉ុន្តែមិនធានាឱ្យមានលក្ខណៈពេញលេញគ្រប់ជ្រុងជ្រោយជាសាលាកុមារមារមេត្រីទេ។

កុមារមកសាលាដើម្បីរៀន ប៉ុន្តែក្នុងតួនាទីជាគ្រូបង្រៀន យើងក៏ត្រូវរៀនដែរ។ យើងរៀនអ្វីដែលថ្មីនៅជុំវិញខ្លួនយើង ដើម្បីបង្រៀនសិស្ស។ យើងរៀនដើម្បីបង្រៀនឱ្យកាន់តែមានប្រសិទ្ធភាព និងឱ្យសិស្សកាន់តែចូលចិត្ត។ ដូច្នេះ សិស្សទាំងអស់ ទីងរៀនអំពីរៀនអាន និងគណិត ហើយយើងជាគ្រូ ក៏រៀនអំពីអ្វីដែលថ្មីពីសិស្សរបស់យើងដែរ។ កម្រងសៀវភៅនេះ ជាជំហានមួយសម្រាប់ណែនាំឱ្យអ្នកអនុវត្តតាម។

បរិយាកាស"រៀនមេត្រី"ជា"បរិយាកាសកុមារមេត្រី" និងជា"បរិយាកាសគ្រូមេត្រី"។ បរិយាកាសនេះពន្យល់អំពីសារៈសំខាន់នៃការរៀនសូត្ររួមគ្នារវាងគ្រូ និងសិស្ស ដែលអាចចាត់ទុកជាសហគមន៍រៀនសូត្រមួយ។ បរិយាកាសនេះប្រមូលផ្តុំកុមារឱ្យនៅកណ្តាលវង្វង់នៃការរៀនសូត្រ ហើយចលនាឱ្យសិស្សបានចូលរៀនយ៉ាងសកម្មថែមទៀតផង។ បរិយាកាសនេះបំពេញតម្រូវការ និងចំណង់ចំណូលចិត្តរបស់គ្រូ។ ដូច្នេះ យើងជាគ្រូបង្រៀន អាចផ្តល់ការអប់រំដល់សិស្សរបស់យើងឱ្យកាន់តែមានប្រសិទ្ធភាព និងគុណភាពល្អបំផុត តាមដែលយើងអាចធ្វើបាន។



សកម្មភាពអនុវត្ត : ស្វែងយល់អំពីថ្នាក់រៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព

ថ្នាក់រៀនទាំងពីរខាងក្រោម តើអ្នកគិតថា ថ្នាក់មួយណាមានបរិយាកាសរៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព?

ថ្នាក់ "ក"

មានកុមារចំនួនសែសិបនាក់កំពុងអង្គុយនៅតាមតុឈើក្នុងថ្នាក់រៀនមួយ ដោយម្នាក់ៗមានកាន់ខ្មៅដៃ សៀវភៅ និងប៊ិច។ អ្នកគ្រូម្នាក់កំពុងចម្លងអត្ថបទមួយពីសៀវភៅសិស្សថ្នាក់ទី៣ ដាក់ក្តារខៀន។ អ្នកគ្រូកំពុងធ្វើតជួរចម្លងតាមសៀវភៅកុំឱ្យខុស។ ក្មេងប្រុសអង្គុយនៅម្ខាង ប៉ែកខាងស្តាំនៃបន្ទប់ ហើយចម្លងតាមក្តារខៀនចូលសៀវភៅ។ កុមារីអង្គុយនៅម្ខាង ប៉ែកខាងឆ្វេងនៃបន្ទប់ កំពុងរង់ចាំអ្នកគ្រូរំកិលខ្លួនបន្តិច ដើម្បីមើលអក្សរលើក្តារខៀនឃើញ ហើយចម្លងចូលសៀវភៅ។ កំពុងសរសេរបណ្តើរ អ្នកគ្រូស្រែកសួរសិស្សបណ្តើរថា "តើប្អូនៗទាំងអស់គ្នាបានចម្លងតាមក្តារខៀនចូលសៀវភៅគ្រប់គ្នាហើយឬនៅ?" សិស្សទាំងអស់ឆ្លើយថា "ហើយៗ អ្នកគ្រូ។"

ថ្នាក់ "ខ"

មានកុមារពីរក្រុមកំពុងអង្គុយជ្រាលកម្រាលជាវង្វង់ពីរ។ ក្រុមទាំងពីរមានសិស្សប្រុស និងសិស្សស្រីអង្គុយរួមគ្នា។ អ្នកគ្រូថ្នាក់ទី៣នេះ កំពុងបង្រៀនសិស្សអំពីទម្រង់ និងរាង។ កុមារមួយក្រុមពិភាក្សាគ្នាអំពីរាងវង្វង់ និងរាងមូល។ អ្នកគ្រូបានបង្ហាញសិស្សនូវវត្ថុរាងវង្វង់ និងរាងមូលមួយចំនួន ដែលសិស្សជាអ្នកយកមកពីផ្ទះ។ សិស្សក្នុងក្រុមនេះ កាន់វត្ថុទាំងនេះក្នុងដៃ ហើយអ្នកគ្រូឱ្យសិស្សគិតរកវត្ថុអ្វីដែលសិស្សស្គាល់ ហើយមានរាងមូល ឬរាងវង្វង់។ ក្នុងក្រុមមួយទៀត សិស្សខ្លះកាន់ក្រដាសកាសែតរមូរមានរាងទ្រវែងដូចដំបង និងមានកាន់លេខផងដែរ។ អ្នកគ្រូហៅលេខ ហើយសិស្សណាកាន់លេខដែលអ្នកគ្រូហៅត្រូវយកក្រដាសកាសែតរមូររបស់គេទៅដាក់ចំកណ្តាលវង្វង់ ហើយបង្កើតជារាងការេ។ ពេលអ្នកគ្រូហៅលេខ ស្រាប់តែមានសិស្សម្នាក់ដែលមានបញ្ហាក្នុងការស្តាប់ យកក្រដាសកាសែតរមូររបស់ខ្លួន ទៅកណ្តាលវង្វង់ ហើយបង្កើតជារាងត្រីកោណ ហើយញញឹមយ៉ាងស្រស់ដាក់អ្នកគ្រូ។ អ្នកគ្រូក៏ញញឹមដាក់វិញ ហើយនិយាយថា "ល្អណាស់" ដោយបែរមុខចំសិស្សនោះ ដើម្បីឱ្យសិស្សនោះមើលឃើញមាត់របស់អ្នកគ្រូ។ ចំណែកម្តាយម្នាក់ដែលស្ម័គ្រចិត្តធ្វើជាជំនួយការរបស់អ្នកគ្រូអស់ពេលមួយសប្តាហ៍មកហើយនោះ បានចាប់ពកុមារនោះ រួចបែរទៅជួយកុមារម្នាក់ទៀត ដែលច្រលំមិនដឹងដាក់កាសែតរមូររបស់ខ្លួននៅកន្លែងណា ដើម្បីបង្កើតជារាងថ្មីទៀត។

៦ ប្រែក្លាយឱ្យទៅជាបរិយាកាសរៀនកុមារមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព

ចូរឆ្លើយសំណួរខាងក្រោម :

- តើថ្នាក់មួយណា ក្នុងចំណោមថ្នាក់ទាំងពីរ អ្នកជឿថា ជាថ្នាក់រៀនកុមារមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព?
- តើមានអ្វីជាសំអាង ដែលថា ថ្នាក់នោះជាថ្នាក់រៀនកុមារមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព? ចូររកហេតុផលឱ្យបានច្បាស់លាស់។

  ១. _____

  ២. _____

  ៣. _____

  ៤. _____

  ៥. _____

ប្រៀបធៀបសំណៅសរសេររបស់អ្នកជាមួយសំណេររបស់មិត្តភក្តិ។ តើមូលហេតុមួយណាដូចគ្នាជាមួយមូលហេតុដែលអ្នករកឃើញ? ហើយមូលហេតុមួយណាខុសពីមូលហេតុដែលអ្នករកឃើញ? អ្នកប្រហែលជាមានចម្លើយផ្សេង។

ចម្លើយមួយចំនួនរបស់អ្នកប្រហែលជាមាន ដូចជា ការអង្គុយរបស់សិស្ស សម្ភារបង្រៀនដែលសិស្សក្នុងថ្នាក់ប្រើ និងការទំនាក់ទំនងគ្នារវាងសិស្ស និងសិស្ស ហើយរវាងសិស្ស និងគ្រូ ក្នុងថ្នាក់។ កត្តាទាំងនេះបង្ហាញពីភាពខុសគ្នារវាងថ្នាក់ទាំងពីរ។ ថ្នាក់ទាំងពីរច្រាប់យើងអំពីបរិយាកាសរបស់ថ្នាក់រៀន។ តារាងខាងក្រោមបង្ហាញពីភាពខុសគ្នារវាងថ្នាក់រៀនបែបបុរាណ និងថ្នាក់រៀនកុមារមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព។ អ្នកក៏អាចគិតរកកត្តាផ្សេងៗទៀតបានដែរ។ កត្តាសំខាន់ ជាពិសេសគឺ "ទំនាក់ទំនង"។ ក្នុងថ្នាក់រៀនដែលដាក់បញ្ចូលគ្នាគ្រប់សមាសភាព យើងត្រូវបង្កើតទំនាក់ទំនងឱ្យជិតស្និទ្ធជាមួយសិស្ស ហើយយកចិត្តទុកដាក់ជាមួយសិស្សឱ្យកាន់តែច្រើន។ ដូច្នេះ សិស្សទាំងអស់នឹងមានអារម្មណ៍ថា បានរៀនច្រើនពីគ្រូ។

កត្តាបង្ហាញអំពីថ្នាក់រៀនមេត្រីដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព

	ថ្នាក់រៀនបែបបុរាណ	ថ្នាក់បរិយាកាសរៀនមេត្រី ដោយ-ដាក់បញ្ចូលគ្នាគ្រប់សមាសភាព
ទំនាក់ទំនង	ចម្ងាយទំនាក់ទំនង (គ្រូឆ្លើយទៅសិស្ស ដោយបែរខ្នង) មានមេត្រីភាព និង មានអារម្មណ៍កក់ក្តៅ។	គ្រូអង្គុយជាមួយសិស្ស ហើយញញឹម ដាក់សិស្សដែលមានបញ្ហាក្នុងការ ស្តាប់។ មានអ្នកជំនួយការគ្រូម្នាក់ ដែលជាមាតា ឬបិតាសិស្ស។
អ្នកណាក្នុង ថ្នាក់ខ្លះ?	គ្រូ និងសិស្សមានសមត្ថភាព ប្រហាក់ប្រហែលគ្នា។	គ្រូបង្រៀនសិស្សដែលមានជីវប្រវត្តិ និង សមត្ថភាពខុសគេ និងអ្នកផ្សេងទៀត ដូចជា អ្នកជំនួយការគ្រូ ដែលជាមាតា ឬបិតារបស់សិស្ស។
ការអង្គុយ របស់សិស្ស	ការអង្គុយរបស់សិស្សក្នុងថ្នាក់គឺ ដូចគ្នាទាំងអស់ (សិស្សទាំងអស់ ត្រូវអង្គុយលើកៅអី ដែលមាន តុឈើតំរៀបជាជួរ ហើយសិស្សស្រី អង្គុយម្ខាង ហើយសិស្សប្រុសអង្គុយ ម្ខាងនៃបន្ទប់)។	ការរៀបឱ្យសិស្សអង្គុយក្នុងលក្ខណៈ ខុសគ្នា។ សិស្សស្រី និងសិស្សប្រុស អង្គុយជាមួយគ្នា អាចអង្គុយលើកម្រាល ជារាងវង្វង់ ឬអាចអង្គុយនៅតុជាមួយគ្នា រវាងសិស្សស្រី និងសិស្សប្រុស។
សម្ភារៀន និងបង្រៀន	សៀវភៅសិស្ស សៀវភៅសរសេរ និងការខៀនសម្រាប់គ្រូ។	មានសម្ភារច្រើនបែប ច្រើនសណ្ឋាន តាមមុខវិជ្ជានីមួយ។ ដូចជា សម្ភារ បង្រៀនគណិត ធ្វើពីក្រដាសកាតសែត ឬផ្ទាំងរូបភាព ឬគំនូរតុកកំប្លែង សម្រាប់បង្រៀនភាសា។
ធនធាន	គ្រូបង្រៀនត្រូវបង្រៀនសិស្ស ដោយមិនចាំបាច់ប្រើសម្ភារឧបទេស។	គ្រូរៀបចំកិច្ចតែងការបង្រៀនមុន មួយថ្ងៃ។ គ្រូឱ្យសិស្សចូលរួមយក សម្ភារៀនមកពីផ្ទះ ហើយសម្ភារ ទាំងនេះមិនត្រូវចំណាយលុយច្រើន។
ការវាយតម្លៃ	រៀនត្រូវតែមានការប្រលងសរសេរ។	ការវាយតម្លៃលទ្ធផលសិក្សារបស់សិស្ស អង្កេត និងដាក់កិច្ចការផ្ទះឱ្យសិស្សធ្វើ ជាប់ជាប្រចាំ (អានកម្រងសៀវភៅ លេខ៥)។



សកម្មភាពឆ្លុះបញ្ចាំង : តើយើងស្ថិតក្នុងស្ថានភាពបែបណា?

គិតពិចារណាអំពីកត្តាល្អ ។របស់ថ្នាក់រៀនកុមារមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព ដែលបានបង្ហាញក្នុងតារាងខាងលើ ហើយសួរខ្លួនឯងនូវសំណួរដូចខាងក្រោម :

- *តើខ្ញុំកំពុងបង្រៀនក្នុងថ្នាក់ប្រភេទណា?*
- *តើខ្ញុំអាចផ្លាស់ប្តូរអ្វីខ្លះ ដើម្បីប្រែក្លាយថ្នាក់របស់ខ្ញុំឱ្យទៅជាថ្នាក់រៀនកុមារមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព?*
- *តើខ្ញុំអាចធ្វើឱ្យមេរៀនដែលខ្ញុំបង្រៀនកាន់តែចាប់អារម្មណ៍ដល់សិស្សដោយរបៀបណា ដើម្បីឱ្យសិស្សរបស់ខ្ញុំ កាន់តែមានអារម្មណ៍ចង់រៀនបន្តែមទៀត?*
- *តើខ្ញុំអាចរៀបចំថ្នាក់រៀនរបស់ខ្ញុំរបៀបណា ដើម្បីឱ្យសិស្សទាំងអស់អាចរៀនបានទាំងអស់គ្នា?*
- *តើអ្នកណាអាចជួយខ្ញុំក្នុងការបង្កើតបរិយាកាសរៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព (ឧទាហរណ៍ នាយកសាលា គ្រូផ្សេងទៀត សិស្ស មាតាបិតា និងអ្នកដឹកនាំសហគមន៍)?*

តើកត្តាសំខាន់ៗរបស់បរិយាកាសរៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាពមានអ្វីខ្លះ?

កុមារទាំងអស់មានសិទ្ធិចូលរៀន ដូចមានចែងក្នុងអនុសញ្ញាស្តីពីសិទ្ធិកុមារ ដែលរដ្ឋាភិបាលគ្រប់ប្រទេសទាំងអស់ បានចុះហត្ថលេខា។ លើសពីនេះទៀត កុមារអាចរៀនដោយមិនប្រកាន់លក្ខណៈសាវាង្គកាយបញ្ញា ស្ថានភាពសង្គម ភាសា និងស្ថានភាពផ្សេងៗទៀតឡើយ។ កុមារទាំងនេះ អាចជា កុមារពិការ កុមារតាមចិញ្ចើមថ្នល់ កុមារពលកម្ម កូនប្រជាជនរស់នៅតំបន់ដាច់ស្រយាល កូនជនជាតិភាគតិចដែលមានភាសា និងវប្បធម៌ខុសគេ កុមារងាយគ្រោះដោយសារមេរោគអេដស៍/ជំងឺអេដស៍ និងកុមារមកពីគ្រួសារក្រីក្រជួបការលំបាក និងគ្មានឱកាស។[1]

ដោយសារមានភាពខុសគ្នាច្រើនបែបនេះ កុមារត្រូវការរៀនតាមវិធីផ្សេងៗគ្នាជាច្រើន មិនមែនរៀនគ្រាន់តែចម្លងមេរៀន តាមការខៀនចូលសៀវភៅប៉ុណ្ណោះទេ។ ចម្លងមេរៀនតាមការខៀនចូលសៀវភៅជាវិធីរៀនមួយដែលមិនសូវមានប្រសិទ្ធភាពទេ។ យើងនឹងរៀនច្រើនទៀតអំពីវិធីរៀនក្នុងកម្រងសៀវភៅលេខ៤ ដែលនិយាយលំអិតអំពីការបង្កើតថ្នាក់រៀនដែលមានបរិយាកាសរៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព។

---

[1] UNESCO (1994) The Framework for Action on Special Needs Education, p. 6.

បង្រៀនកុមារដែលមានប្រវត្តិ និងសមត្ថភាពខុសគេ ជាការលំបាកមួយ ព្រោះយើងត្រូវយល់អំពីវិធីបង្រៀនកុមារប្រភេទនេះ។ យើងមិនមែនកើតមក ចេះសព្វគ្រប់នូវវិធីបង្រៀនបែបនេះទេ ហើយយើងក៏មិនអាចរៀនទូវអ្វីទាំងអស់ដែលយើងត្រូវរៀនក្នុងវគ្គបណ្តុះបណ្តាលគ្រូដែរ។ យើងត្រូវការរៀនតាមរយៈការអង្កេត និងពិភាក្សាជាមួយគ្រូដែលមានបទពិសោធ តាមរយៈការចូលរៀនក្នុងសិក្ខាសាលា តាមរយៈការអានសៀវភៅ និងតាមរយៈការស្រាវជ្រាវឯកសារផ្សេងៗ ដូចជាកម្រងសៀវភៅនេះជាដើម ហើយបន្ទាប់មកយើងត្រូវយកចំណេះដឹងរបស់យើងទៅអនុវត្តក្នុងថ្នាក់រៀន។ បរិយាកាសរៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព មានសារៈសំខាន់ណាស់ មិនត្រឹមតែសម្រាប់បណ្តុះបណ្តាលកូនៗរបស់យើងទេ ប៉ុន្តែសម្រាប់អភិវឌ្ឍជំនាញរបស់យើងជាគ្រូបង្រៀនផងដែរ។

ក្នុងបរិយាកាសរៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព មនុស្សគ្រប់ៗរូប ត្រូវចូលរួមចែករំលែក នូវទស្សនទីសំយអំពីវិធីដែលកុមាររៀន និងកុមារធ្វើការ។ មនុស្សគ្រប់ៗរូប ជឿថា ការអប់រំត្រូវតែដាក់បញ្ចូលគ្នាគ្រប់សមាសភាព មានសមភាពយេនឌ័រ(ក្មេងស្រីត្រូវមានសិទ្ធិ និងឱកាសស្មើគ្នាជាមួយក្មេងប្រុស) ហើយមិនរើសអើង ស្របតាមវប្បធម៌ ទំនៀមទម្លាប់ ហើយពាក់ព័ន្ធនឹងជីវភាពរស់នៅប្រចាំថ្ងៃរបស់កុមារ និងរបស់គ្រួសារកុមារ។ គ្រូបង្រៀន អ្នករដ្ឋបាលសាលា និងសិស្ស ចេះគោរព និងទទួលស្គាល់ភាសា វប្បធម៌ ជីវប្រវត្តិ និងសមត្ថភាពផ្សេងៗគ្នារបស់កុមារទាំងអស់។

បរិយាកាសរៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព បង្រៀនកុមារអំពីបំណិនជីវិត និងជីវភាពប្រកបដោយសុខភាព។ ដូច្នេះ កុមារនឹងមានសមត្ថភាពសម្រេចចិត្តបានត្រឹមត្រូវ ហើយចេះការពារខ្លួនកុំឱ្យកើតជំងឺ និងគ្រោះថ្នាក់។ លើសនេះទៀត បរិយាកាសរៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព មិនមានការរំលោភបំពានកុមារ គ្មានរំពាត់ និងគ្មានទណ្ឌកម្មឡើយ។

បរិយាកាសរៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព ចលនាឱ្យគ្រូបង្រៀន និងអ្នករដ្ឋបាលសាលា កុមារ គ្រួសារ និងសហគមន៍ ចេះជួយកុមារឱ្យរៀនទាំងក្នុងថ្នាក់រៀន និងក្រៅថ្នាក់រៀន។ ក្នុងថ្នាក់រៀនមិនត្រឹមតែគ្រូបង្រៀនទេ កុមារក៏ទទួលខុសត្រូវចំពោះការរៀនសូត្ររបស់ខ្លួនដែរ ហើយក៏ចូលរួមយ៉ាងសកម្មក្នុងសកម្មភាពរៀនសូត្រផងដែរ។ ការរៀនសូត្រ ត្រូវតែពាក់ព័ន្ធនឹងអ្វីដែលសិស្សចង់ចេះ សម្រាប់ប្រើប្រាស់ក្នុងជីវភាពប្រចាំថ្ងៃ និងអ្វីដែលមានតម្លៃសម្រាប់ជីវភាពប្រចាំថ្ងៃផងដែរ។

បរិយាកាសរៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាពក៏សិក្សាអំពីតម្រូវការ និងចំណង់ចំណូលចិត្តរបស់យើងជាគ្រូបង្រៀនផងដែរ។ បរិយាកាសរៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព ផ្តល់ឱកាសឱ្យយើងរៀនអំពីវិធីបង្រៀនឱ្យកាន់តែមានប្រសិទ្ធភាព ផ្តល់ធនធានកាន់តែច្រើនសម្រាប់ឱ្យយើងយកទៅបង្រៀន ហើយក៏ជួយឱ្យយើងទទួលបានជោគជ័យ និងទទួលបានការអបអរសាទរ និងទទួលបានការពេញចិត្តពីអ្នកដទៃផងដែរ។



សកម្មភាពអនុវត្ត : តើបរិយាកាសរៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាពជាអ្វី?

ពិភាក្សាជាមួយសហការីរបស់អ្នក ដើម្បីរកកត្តាសំខាន់ៗរបស់បរិយាកាសរៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព ក្នុងថ្នាក់រៀន សាលារៀន ឬទីកន្លែងមួយដែលកុមារអាចរៀនបាន។

- *រកការខ្វៀនដើម្បីសរសេរ (ឬក្រដាសផ្ទាំងធំៗ)*
- *នៅក្រៅវង្វង់នេះ ចូរឱ្យសហការីរបស់អ្នកសរសេរកត្តាសំខាន់ៗមួយឬពីររបស់បរិយាកាសរៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព។*
- *ប្រៀបធៀបក្រាហ្វិករបស់អ្នកជាមួយនឹងក្រាហ្វិកនៅទំព័របន្ទាប់។ តើមានកត្តាណាខ្លះដែលខ្វះខាត?*
- *បន្ទាប់មកសួរខ្លួនឯងថា តើកត្តាអ្វីខ្លះដែលថ្នាក់រៀនរបស់យើង ឬសាលារបស់យើងមានរួចហើយ? តើយើងត្រូវធ្វើអ្វីបន្តទៀតដើម្បីកែលំអ? តើយើងកែលំអសាលា ឬថ្នាក់រៀនរបស់យើងឱ្យក្លាយទៅជាសាលាឬថ្នាក់រៀនដែលមានបរិយាកាសរៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាពដោយរបៀបណា? ចូរសរសេរគំនិតរបស់អ្នកក្នុងតារាងខាងក្រោម :*

កត្តាសំខាន់ៗរបស់បរិយាកាសរៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព ដែលយើងរកឃើញមាន :

_____

_____

_____

កត្តាសំខាន់ៗរបស់បរិយាកាសរៀនមេត្រីដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាពដែលត្រូវការកែលំអ និង វិធីកែលំអមាន :

_____

_____

កត្តាសំខាន់ៗរបស់បរិយាកាសរៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព មាន :



ចំណុចគួរចងចាំ : កែប្រែពីសាលាបែបបុរាណ ឬថ្នាក់រៀនបែបបុរាណឱ្យទៅជាថ្នាក់រៀន ឬសាលារៀនដែលមានបរិយាកាសរៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព ត្រូវចំណាយពេលវេលាយូរ មិនអាចធ្វើមួយថ្ងៃបានទេ។ ការកែប្រែនេះត្រូវការពេលវេលា និងកិច្ចសហការច្រើនណាស់។ ការកែប្រែនេះ ក៏ផ្តល់ផលប្រយោជន៍ច្រើនដល់យើងជាគ្រូបង្រៀន ដល់កូនៗរបស់យើង ដល់គ្រួសាររបស់សិស្ស និងដល់សហគមន៍ទាំងមូលផងដែរ។

តើបរិយាកាសរៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព ផ្តល់ផលប្រយោជន៍អ្វីខ្លះ?



សកម្មភាពឆ្លុះបញ្ចាំង

ចូរអានករណីសិក្សាខាងក្រោមជាក្រុម ឬម្នាក់ឯង។

សាលារៀននៅភូមិមួយរបស់ប្រទេសប៉ាពួញូហ្គីនី

នៅឆ្នាំ ១៩៨០ មាតាបិតាមកពីសហគមន៍មួយចំនួននៅខេត្តភាគខាងកើត នៃប្រទេសប៉ាពួញូហ្គីនី បានទាមទារឱ្យផ្តល់ការអប់រំសម្រាប់កូនៗពាក់ព័ន្ធនឹងជីវភាពពិតរបស់សហគមន៍។ មាតាបិតាចង់បានការអប់រំមួយដែលបង្រៀនកុមារអំពីតម្លៃរបស់ភូមិ ឱ្យស្គាល់តម្លៃនៃជីវិត តម្លៃវប្បធម៌ និងភាសា ហើយបង្រៀនកុមារអំពីអត្តសញ្ញាណរបស់សហគមន៍។ អាជ្ញាធរខេត្ត សាកលវិទ្យាល័យ និងអង្គការក្រៅរដ្ឋាភិបាលបានរួមគ្នា បង្កើតសាលាមត្តេយ្យភូមិមួយ ឈ្មោះតុកប្លេស។ សាលានេះទទួលកុមារអាយុពី៦–៨ ឆ្នាំឱ្យចូលរៀនភាសាប្រើប្រាស់ក្នុងសហគមន៍ ក្នុងកម្មវិធីអប់រំក្រៅប្រព័ន្ធមួយ។

សាលាតុកប្លេសបានប្រើប្រាស់សម្ភារ ដែលមានស្រាប់ក្នុងសហគមន៍ ហើយចំណាយថវិកាតិច។ គ្រូអាចបង្រៀនសិស្សដោយងាយស្រួល និងមិនចំណាយថវិកាខ្ពស់ថែមទៀតផង។ ប្រជាជនក្នុងសហគមន៍រួមគ្នាសរសេររឿងនិទាន ជាភាសាក្នុងស្រុក ដើម្បីឱ្យកុមារៀន។ រឿងនិទាននិយាយអំពីប្រពៃណី វប្បធម៌ រឿងព្រេង ចម្រៀង ឬកំណាព្យ។ សិស្សក៏សរសេររឿងតាមបទពិសោធជាក់ស្តែង ហើយចងក្រងជាសៀវភៅដែលប្រើធនធានក្នុងស្រុក និងមានគំនូរក្នុងសៀវភៅថែមទៀតផង។ សៀវភៅនេះត្រូវបានបញ្ចូលទៅក្នុងបណ្ណាល័យ ហើយឱ្យសិស្សអានជាក្រុម ក្នុងម៉ោងរៀនអាន។ សិស្សក៏យករឿងនិទានទាំងនោះមកសម្តែង និងពិភាក្សាក្នុងថ្នាក់ថែមទៀតផង។

កុមារដែលចេញពីសាលាតុកប្លេស មានចំណេះដឹង និងឱ្យតម្លៃលើវប្បធម៌របស់សហគមន៍ និងកាន់តែមានសមត្ថភាពប្រើប្រាស់ភាសាកំណើតរបស់ខ្លួនថែមទៀតផង។ កុមារកាន់តែសប្បាយចិត្ត មានទំនុកចិត្តលើខ្លួនឯង ហើយកាន់តែមានចិត្តចង់រៀនថែមទៀត។ កុមារមានសំណួរកាន់តែច្រើនដើម្បីសួរ។ កុមាររៀនកាន់តែពូកែ នៅពេលបានចូលរៀននៅសាលាចំណេះទូទៅក្នុងប្រព័ន្ធ។

គ្រូបង្រៀនតែងប្រើការចងចាំរបស់ខ្លួនអំពីអារម្មណ៍ ដែលធ្លាប់តែច្រឡំ និងភ័យខ្លាច ដូចកាលពីខ្លួនចូលសាលាពីដំបូង ហើយបាននិយាយទៅកាន់សិស្សក្នុងភាសាមួយដែលសិស្សមិនយល់។ គ្រូបង្រៀនភាគច្រើនជឿថា សិស្សមិនដូចបញ្ហាដូចគ្រូទេ។ គ្រូបង្រៀនមួយចំនួនមានអារម្មណ៍ប្លែក។ច្រើន។ ម្យ៉ាងទៀត គ្រូបង្រៀនច្រើនមានអារម្មណ៍ថា គ្រូផ្ទាល់គ្រប់គ្រងសិស្ស នៅពេលគ្រូចេះឱនលំទោន និងមិនសូវសកម្ម។ ម្យ៉ាងវិញទៀត គ្រូមានចិត្តសប្បាយរីករាយ ព្រោះថា សិស្សរៀនចាប់ចេះ នៅពេលបង្រៀនខ្លឹមសារថ្មី។

ការប្រើភាសាក្នុងស្រុកនៅសាលាតុកប្លេស ប្រទេសប៉ាពួញូហ្គីនី អាចធានាថា រក្សាបានទូវភាពសម្បូរបែបនៃវប្បធម៌ និងភាសាជាមិនខាន។

- Dutcher N (2001) Expanding Educational Opportunity in Linguistically Diverse Societies. Center for Applied Linguistics: Washington, DC.
and http:// www.literacyonline.org/explorer/index.html
*Summer Institute for Linguistics

ឥឡូវនេះ ចូរវិភាគស្ថានភាពសាលាមត្តេយ្យមួយឈ្មោះថា វែលតុកប្លេស។ តើអ្នកគិតថា កុមារ គ្រូបង្រៀន មាតាបិតាសិស្ស និងសហគមន៍ទទួលផលប្រយោជន៍ពីបរិយាកាសរៀនមេត្រី ដោយដាក់បញ្ចូលគ្នា គ្រប់សមាសភាពដោយរបៀបណា? ចូរសរសេរផលប្រយោជន៍ទាំងនោះក្នុងតារាងខាងក្រោម :

ផលប្រយោជន៍សម្រាប់កុមារ

១. _____

២. _____

៣. _____

ផលប្រយោជន៍សម្រាប់គ្រូបង្រៀន

១. _____

២. _____

៣. _____

ផលប្រយោជន៍សម្រាប់មាតាបិតាសិស្ស

១. _____

២. _____

៣. _____

ផលប្រយោជន៍សម្រាប់សហគមន៍

១. _____

២. _____

៣. _____

ប្រៀបធៀបផលប្រយោជន៍ដែលអ្នករកឃើញជាមួយអ្នកដទៃ បន្ទាប់មក អានផលប្រយោជន៍ខាងក្រោមទាំងអស់គ្នា ។ តើអ្នករកឃើញផលប្រយោជន៍ចំនួនប៉ុន្មាន? តើអ្នកបានរៀនទូវគំនិតថ្មីៗ និងផលប្រយោជន៍ថ្មីៗដែរឬទេ?

ផលប្រយោជន៍សម្រាប់កុមារ

តាមរយៈបរិយាកាសរៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព កុមារមានទំនុកចិត្តលើខ្លួនឯង មានស្វ័យម្ចាស់ការ និងចេះគោរពខ្លួនឯង។ កុមារជឿជាក់លើខ្លួនឯង និងមានមោទនភាពចំពោះជោគជ័យដែលកុមារទទួលបាន។ កុមារបានរៀនអំពីវិធីរៀនដោយឯកភាជ្ឈទាំងក្នុងសាលា និងក្រៅសាលា។ ឧទាហរណ៍ កុមាររៀនអំពីវិធីសួរសំណួរល្អ។ កុមាររៀនស្វែងយល់ ហើយអនុវត្តអ្វីដែលបានរៀននៅសាលា ក្នុងជីវភាពរស់នៅប្រចាំថ្ងៃ ដូចជាក្នុងពេលលេងកំសាន្ត និងក្នុងពេលធ្វើការផ្ទះ។ កុមាររៀនអំពីទំនាក់ទំនងយ៉ាងសកម្ម និងដោយសប្បាយរីករាយជាមួយមិត្តរួមថ្នាក់ និងជាមួយគ្រូបង្រៀន។ កុមារនឹងរីករាយលេងកំសាន្ត ជាមួយអ្នកដទៃដែលមានជីវប្រវត្តិ និងសមត្ថភាពខុសពីអ្នកដទៃ។ កុមារចេះសម្របសម្រួលខ្លួនតាមកាលៈទេសៈ។ កុមារទាំងអស់រៀនរួមគ្នា ហើយចេះឱ្យតម្លៃទៅលើទំនាក់ទំនងដែលកុមារបានបង្កើតឡើង ដោយមិនប្រកាន់ភាពខុសគ្នានៃជីវប្រវត្តិ ឬសមត្ថភាពឡើយ។

កុមារនឹងកាន់តែមានជំនាញប្តែប្រឌិត ហើយជំនាញនេះនឹងជួយឱ្យកុមាររៀនកាន់តែបានជោគជ័យ។ កុមារនឹងចេះឱ្យតម្លៃភាសាកំណើត វប្បធម៌ និងប្រពៃណីរបស់ខ្លួន ហើយចាត់ទុកខ្លួនឯងថា អ្វីដែលខ្លួនមានខុសគេ គឺជា "លក្ខណៈពិសេស"។

តាមរយៈបរិយាកាសរៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព កុមារនឹងអភិវឌ្ឍជំនាញទំនាក់ទំនង ត្រឹមលក្ខណៈសម្រាប់ជីវិត។ កុមារនឹងទទួលបានផលប្រយោជន៍ ចេះគោរពខ្លួនឯង និងចេះគោរពនិងឱ្យតម្លៃអ្នកដទៃ។

ផលប្រយោជន៍សម្រាប់គ្រូបង្រៀន

គ្រូបង្រៀនក៏ទទួលផលប្រយោជន៍ដ៏សំខាន់ពីការងារបង្រៀនរបស់ខ្លួនក្នុងបរិយាកាសរៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាពដែរ។ គ្រូបង្រៀននឹងមានឱកាសកាន់តែច្រើនថែមទៀត ដើម្បីរៀនវិធីថ្មី។ ក្នុងការបង្រៀនសិស្សមកពីគ្រប់មជ្ឈដ្ឋានផងដែរ។ គ្រូបង្រៀននឹងទទួលបានចំណេះដឹងថ្មី។ ដូចជាវិធីផ្សេង។ ដែលសិស្សរៀន និងវិធីបង្រៀនថ្មី។។ គ្រូនឹងរកឃើញវិធីជម្នះរាល់ការលំបាកនេះ ហើយរៀបចំឥរិយាបថវិជ្ជមានចំពោះកុមារ និងក្នុងស្ថានភាពលំបាក។ ការបង្រៀននឹងក្លាយទៅជាការសប្បាយរីករាយ មិនមែនជាការងារតឹងរ៉ឹង និងការងារលំបាកនោះទេ។

គ្រូបង្រៀននឹងមានឱកាសកាន់តែច្រើនថែមទៀត ដើម្បីស្វែងយល់អំពីគំនិតថ្មី។ តាមរយៈទំនាក់ទំនងជាមួយអ្នកដទៃ ទាំងក្នុងសាលា និងក្រៅសាលា ដូចជា ក្នុងសាលាកម្រង ឬបណ្តាញគ្រូបង្រៀន។ ដោយបានអនុវត្តនូវគំនិតថ្មីៗទាំងនេះ គ្រូបង្រៀននឹងចលនាឱ្យសិស្សកាន់តែចូលចិត្តរៀន កាន់តែមានគំនិតប្តែប្រឌិត និងយកចិត្តទុកដាក់ក្នុងការរៀនសូត្រ ហេតុដូច្នេះ កុមារ និងមាតាបិតាអាចផ្តល់ យោបល់តែលំអដល់គ្រូបង្រៀនវិញ ហើយគ្រូបង្រៀននឹងទទួលបានការគាំទ្រពីសហគមន៍កាន់តែច្រើន ហើយ នឹងទទួលបានរង្វាន់ និងការលើកទឹកចិត្តដោយសារការងារល្អនេះ។

គ្រូបង្រៀននឹងពេញចិត្តការងារដែលខ្លួនធ្វើ ហើយមានអារម្មណ៍ថា ទទួលបានជោគជ័យច្រើនដោយសារកុមារទាំងអស់បានចូលរៀនក្នុងសាលា។ ចូរចាំថា "កុមារទាំងអស់ទទួលបានជោគជ័យក្នុងការរៀនសូត្រ" មិនមែនមានន័យថា កុមារទាំងអស់បានប្រលងជាប់ទាំងអស់ទេ។ ប៉ុន្តែការជោគជ័យនេះ មានន័យថា យើងទទួលស្គាល់ភាពខុសគ្នារបស់កុមារ និងវិធីផ្សេងៗដែលកុមារៀន ព្រមទាំងវិធីដែលកុមារទទួលបានជោគជ័យក្នុងការរៀនសូត្រ។ ឧទាហរណ៍ : កុមារអាចមានសមត្ថភាពពន្យល់គ្រូ និងពន្យល់មិត្តរួមថ្នាក់លើខ្លឹមសារអ្វីមួយបានយ៉ាងល្អ។ ក្នុងន័យនេះ កុមារមិនត្រឹមតែរង់ចាំឆ្លើយសំណួរក្នុងពេលប្រលងនោះទេ។

ក្នុងសាលាដែលមានបរិយាកាសរៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព គ្រូបង្រៀន នឹងមានអ្នកស្មើគ្រែចិត្តជួយធ្វើការក្នុងថ្នាក់។ អ្នកស្មើគ្រែចិត្តទាំងនេះនឹងជួយកាត់បន្ថយបន្ទុកការងាររបស់គ្រូ។ ក្រៅមការណែនាំរបស់គ្រូ អ្នកស្មើគ្រែចិត្តនឹងចង់ជួយថែមទៀត នៅពេលដែលបានដឹងថា វិធីសាស្ត្ររៀន និងបង្រៀនក្នុងថ្នាក់មានសារៈសំខាន់សម្រាប់ជីវភាពរស់នៅរបស់កុមារ និងរបស់គ្រួសារ។

ផលប្រយោជន៍សម្រាប់មាតាបិតា

តាមរយៈបរិយាកាសរៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព មាតាបិតា និងយល់កាន់តែច្បាស់ថែមទៀត អំពីវិធីសាស្ត្រដែលកូនៗរៀននៅសាលា។ មាតាបិតា នឹងចូលរួមកាន់តែសកម្ម ហើយមានអារម្មណ៍ថា ការជួយកូនចៅក្នុងសាលាជាការសំខាន់។ នៅពេលគ្រូបង្រៀនសុំឱ្យមាតាបិតាផ្តល់យោបល់មួយចំនួនអំពីកូនៗរបស់គាត់ មាតាបិតា នឹងមានអារម្មណ៍ថា នឹងមានតម្លៃណាស់ ហើយមានអារម្មណ៍ថាខ្លួនជាដៃគូដ៏សំខាន់ និងស្មើភាពជាមួយគ្រូបង្រៀនក្នុងការផ្តល់ឱកាសរៀនសូត្រដ៏មានគុណភាពសម្រាប់កូនៗ។ មាតាបិតា ក៏នឹងរៀនអំពីវិធីដោះស្រាយបញ្ហាជាមួយកូនៗនៅផ្ទះ ដោយប្រើវិធីដែលគ្រូបង្រៀនបានប្រើនៅសាលា។ មាតាបិតា ក៏នឹងរៀនអំពីវិធីទំនាក់ទំនងជាមួយអ្នកដទៃ ក្នុងសហគមន៍ ហើយអាចស្វែងយល់ និងជួយដោះស្រាយបញ្ហាគ្នាទៅវិញទៅមក។ សំខាន់ជាងនេះទៀត មាតាបិតាដឹងថា កូនៗរបស់គាត់ និងកុមារទាំងអស់បានទទួលការអប់រំប្រកបដោយគុណភាព។

ផលប្រយោជន៍សម្រាប់សហគមន៍

បរិយាកាសរៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព ក៏ផ្តល់ផលប្រយោជន៍ច្រើនដល់សហគមន៍ដែរ។ សហគមន៍ នឹងមានមោទនភាពដោយសារ កុមារកាន់តែច្រើនបានចូលរៀននៅសាលា។ សហគមន៍នឹងយល់ថា "អ្នកដឹកនាំសហគមន៍ ក្នុងពេលអនាគត" កំពុងទទួលបានការអប់រំ ដើម្បីឱ្យចូលរួមក្នុងសកម្មភាពសង្គមកាន់តែសកម្ម។ សហគមន៍ មើលឃើញថា បញ្ហាសង្គម ដូចជា ឧក្រិដ្ឋកម្មតូចតាច ឬបញ្ហាយុវវ័យ នឹងអាចកាត់បន្ថយបាន។ សមាជិកសហគមន៍ទាំងអស់នឹងចូលរួមកាន់តែសកម្មក្នុងសកម្មភាពរបស់សាលារៀន ហើយបង្កើតទំនាក់ទំនងកាន់តែល្អរវាងសាលា និងសហគមន៍។

១៦ ប្រែក្លាយឱ្យទៅជាបរិយាកាសរៀនកុមារមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព



សកម្មភាពអនុវត្ត : កាតព្វកិច្ចដែលត្រូវប្រែក្លាយឱ្យទៅជាបរិយាកាសរៀនមេត្រី ដោយ-ដាក់បញ្ចូលគ្នាគ្រប់សមាសភាព

ដោយសារផលប្រយោជន៍ទាំងអស់ខាងលើ ហេតុអ្វីបានជាសាលាទាំងអស់ មិនបង្កើតបរិយាកាសរៀនមេត្រីដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព? ខាងក្រោម ជាការាងខ្លីមួយ បង្ហាញពីឧបសគ្គារាំងសាលាមួយចំនួនមិនឱ្យក្លាយទៅជាសាលាដែលមានបរិយាកាសរៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព។ សម្រាប់ឧបសគ្គនីមួយ។ ត្រូវរកមធ្យោបាយដោះស្រាយឲ្យបាន។

១. ការកែប្រែទាមទារថាមពល និងចន្លះច្រើន។ ប្រសិនបើគ្រូបង្រៀនមានការទទួលខុសត្រូវច្រើន ឬមានការកិច្ចរដ្ឋបាលនៅសាលាច្រើន ដូចជា ចូលរួមប្រជុំញឹកញាប់ពេក គ្រូបង្រៀននឹងមានអារម្មណ៍ថារវល់ខ្លាំង គ្មានពេលវេលា ឬ គ្មានកម្លាំងក្នុងការកែប្រែបរិយាកាសសាលាទេ។

វិធីជម្នះឧបសគ្គនេះ

ក. _____

ខ. _____

គ. _____

២. គ្រូបង្រៀនមិនយល់អំពីបរិយាកាសរៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព ឬគ្រូបង្រៀនគិតថាគ្មានធនធានគ្រប់គ្រាន់សម្រាប់ប្រើច្រាស់ក្នុងការកែប្រែសាលាឱ្យទៅជាសាលាដែលមានបរិយាកាសរៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាពទេ។

វិធីជម្នះឧបសគ្គនេះ

ក. _____

ខ. _____

គ. _____

៣. មាតាបិតា ហើយសូម្បីតែគ្រូបង្រៀន ក៏មិនយល់អំពីផលប្រយោជន៍របស់បរិយាកាសរៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាពដែរ ហើយព្រួយបារម្ភថា ការដាក់បញ្ចូលកុមារគ្រប់ប្រភេទឱ្យចូលរៀនក្នុងសាលាអាចប៉ះពាល់ដល់កុមារធម្មតាដទៃទៀត។

វិធីជម្នះឧបសគ្គនេះ :

ក. _____

ខ. _____

គ. _____

រៀនសូត្រពីបទពិសោធកន្លងមក : ការដាក់បញ្ចូលកុមារពិការឱ្យចូលរៀន

យើងបានរកឃើញថា កុមារមានមនុស្សធម៌ និងស្មោះត្រង់ជាងមនុស្សចាស់។ ក្នុងអំឡុងពេល ៤ឆ្នាំ កន្លងទៅនេះ មិនមានអ្នកណាសួរសំណួរដល់កុមារ ដូចជា "តើមិត្តភក្តិរបស់ខ្ញុំមានបញ្ហាអ្វី?" ឬ "ហេតុអ្វីបានជាមិត្តភក្តិរបស់ខ្ញុំ មានចរិតបែបនេះ?" យើងមិនដែលឃើញកុមារណាមិនចង់លេងចូលកុមារដទៃនោះទេ។ នៅពេលមានមិត្តពិការម្នាក់ទទួលបានពិន្ទុល្អ ថ្នាក់ទាំងមូលត្រូវស្ងៀមស្ងាត់ ហើយក្រោយពីមិត្តពិការនោះ ឆ្លើយសំណួរត្រូវ ក៏មានសម្លេងទះដៃអបអរសាទរ។

មនុស្សគ្រប់រូបសប្បាយរីករាយនឹងជោគជ័យនេះ។ មិត្តភក្តិមិនមែនខុសគ្នាគ្រប់បែបយ៉ាងនោះទេ។ មិត្តភក្តិទៅហែលទឹកជាមួយគ្នា ទៅដើរកំសាន្តជាមួយគ្នា ចូលរួមពិធីជប់លៀងជាមួយគ្នា ហើយចូលរួមខួបកំណើតមិត្តភក្តិជាមួយគ្នា។ ខ្ញុំអាចនិយាយបានថា បើក្នុងថ្នាក់មួយគ្មានសិស្សពិការចូលរៀនជាមួយទេ សិស្សទាំងអស់នឹងមានចរិតផ្សេង។ ជួនកាល កុមារពិការត្រូវគេសើចចំអកឡកឡើយ រុញច្រាន និងសម្លឹងសម្លក់។ សំណាងដែរ នៅពេលមានអំពើបែបនេះកើតឡើង ស្ទាប់តែមានប្រតិកម្មពីមិត្តរួមថ្នាក់របស់កុមារពិការភ្លាម ហើយមិត្តរួមថ្នាក់ការពារមិត្តភក្តិរបស់គេ។ សំខាន់ជាងនេះទៀត មាតាបិតាទាំងអស់ទទួលស្គាល់កុមារពិការបែបនេះ។ នៅដើមឆ្នាំ រៀនថ្នាក់ទីមួយ មាតាបិតាមួយចំនួន សម្គាល់មើលកុមារពិការ ហើយច្រើនដកខ្លួនឆ្ងាយពីកុមារពិការទាំងនោះ។ មាតាបិតាបែបនោះ តែងសួរខ្លួនឯងថា "ហេតុអ្វីក៏អញឱ្យកូនអញ អង្គុយជាប់កុមារបែបនេះ?" "កុមារបែបនេះនឹងរំខានការរៀនសូត្ររបស់កូន?" សំណាងដែរ ប្រតិកម្មនេះកើតឡើងតែក្នុងរយៈពេលខ្លី មួយខែ ឬពីរខែប៉ុណ្ណោះ។ នៅពេលមាតាបិតាដឹងថាកូនៗទទួលស្គាល់ និងរាប់អានកុមារបែបនោះ ពួកគាត់ក៏ចាប់ផ្តើមជួយកុមារពិការទាំងនោះ។ ពួកគាត់ជួយស្លៀកពាក់ឱ្យ រៀបចំការាបឱ្យ និងជូនទៅផ្ទះជាដើម។ មាតាបិតារបស់កុមារផ្សេងទៀតចង់ឱ្យខ្ញុំចាត់ចែងការប្រជុំមួយជាមួយមាតាបិតា។ ក្នុងពេលប្រជុំនោះ ពួកគាត់ចង់ឱ្យខ្ញុំពន្យល់អំពីអត្តន័យនៃពិការភាព។ ខ្ញុំអាចទាញសេចក្តីសន្និដ្ឋានដ៏សាមញ្ញថា ក្នុងរយៈពេលមិនយូរប៉ុន្មាន ទាំងមាតាបិតា ទាំងសិស្សផ្សេងទៀតបានផ្លាស់ប្តូរគំនិត ហើយថ្នាក់រៀនបានដំណើរការយ៉ាងល្អ ហើយកុមារពិការបានក្លាយជាកុមារដែលគួរឱ្យស្រលាញ់បំផុតក្នុងថ្នាក់រៀន។

- "Including Children with Disabilities, an interview with Katica Dukovska Muratovska."
http://www.unicef.org/teachers/forum/0100.htm



គោល ១.២
តើយើងកំពុងស្ថិតនៅកន្លែងណា?

តើសាលារបស់យើងបានក្លាយជាសាលាដែលមានបរិយាកាសរៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាពហើយឬនៅ?

សាលាជាច្រើនប្រែហែលជាកំពុងដំណើរការល្អ ក្នុងការប្រែក្លាយខ្លួនឱ្យទៅជាសាលារៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព ហើយសាលាទាំងនោះមើលឃើញអំពីសារប្រយោជន៍របស់បរិយាកាសរៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព សម្រាប់គ្រូ សម្រាប់កុមារ សម្រាប់មាតាបិតា និងសម្រាប់សហគមន៍ ។ ក្នុងដំណើរការប្រែក្លាយទៅជាសាលារៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព ជំហានទីមួយ ត្រូវសិក្សាវិភាគអំពីកត្តានៃបរិយាកាសរៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព ដែលសាលារបស់អ្នកមានរួចហើយ។ ដូច្នេះ អ្នកនឹងដឹងថា គួរចាប់ផ្តើមអនុវត្តជំហានណាបន្ត ដើម្បីប្រែក្លាយទៅជាសាលាដែលមានបរិយាកាសរៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព។

តារាងខាងក្រោមជួយអ្នកក្នុងការវាយតម្លៃសាលារបស់អ្នក។ បំពេញតារាងនេះ ដោយស្មោះត្រង់។ គូសសញ្ញា (X) នៅមុខសកម្មភាពណា ដែលសាលារបស់អ្នកបានអនុវត្តរួចហើយ។ កុំព្រួយបារម្ភថា មានសកម្មភាពច្រើនដែលអ្នកមិនបានគូស។ ក្នុងកម្រងសៀវភៅទាំងអស់នេះ យើងអាចគូសសកម្មភាពទាំងនេះជាមួយគ្នា។ ក្រោយពីសហការីរបស់អ្នក និងអ្នក បានវាយតម្លៃចប់សព្វគ្រប់ហើយ អ្នកនឹងមានព័ត៌មានដែលអាចចាប់ផ្តើមធ្វើផែនការកែប្រែសាលារបស់អ្នកឱ្យទៅជាសាលារៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព។ ក្នុងគោលបន្ទាប់ទៀត អ្នកនឹងរៀនអំពីវិធីកែប្រែនេះ។



សកម្មភាពអនុវត្ត : ការវាយតម្លៃអំពីបរិយាកាសរៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាពដោយខ្លួនឯង

តើសាលារបស់អ្នកបានធ្វើអ្វីខ្លះ ដើម្បីប្រែក្លាយទៅជាបរិយាកាសរៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព។

គោលនយោបាយសាលា និងការគាំទ្រផ្នែករដ្ឋបាល

សាលារបស់អ្នក

_____ មានបេសកកម្ម និងទស្សនវិស័យ ព្រមទាំងគោលនយោបាយនិយាយអំពីការអប់រំកុមារមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព គិតទាំងគោលនយោបាយប្រឆាំងនឹងការរើសអើងផងដែរ។

_____ មានបញ្ជីសរុបកុមារគ្រប់អាយុចូលរៀននៅសាលា នៅទូទាំងសហគមន៍ ទាំងកុមារដែលបានចូលរៀន និងកុមារមិនបានចូលរៀន។

_____ អនុវត្តយុទ្ធនាការបំផុសចលនាឱ្យមាតាបិតាចុះឈ្មោះកូនចូលរៀន ក្នុងន័យថា កុមារ **ទាំងអស់** ត្រូវតែចុះឈ្មោះចូលរៀន ហើយសាលាស្វាគមន៍កុមារទាំងអស់ឱ្យចូលរៀន។

_____ មានឯកសារ ឬធនធានផ្សេងរបស់ក្រសួងអប់រំ សម្រាប់បម្រើការអប់រំ ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព គឺសម្រាប់កុមារដែលមានជីវប្រវត្តិ និងសមត្ថភាពខុសគេ។

_____ ស្វែងរក និងរកឱ្យស្គាល់អង្គការដែលមានជំនាញ ក្រុមអ្នកតស៊ូមតិ និងអង្គការមានមូលដ្ឋាននៅសហគមន៍ដែលមានធនធានសម្រាប់ឧបត្ថម្ភការអប់រំ ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព។

_____ បង្ហាញកត្តានានាដែលថា អ្នករដ្ឋបាលសាលា និងគ្រូបង្រៀនយល់អំពីសារៈសំខាន់របស់ការអប់រំដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព។

_____ បានបង្កើតតារាងមួយនិយាយអំពីឧបសគ្គដែលរារាំងសាលាមិនឱ្យប្រែក្លាយទៅជាសាលាដែលមានបរិយាកាសរៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព និងតារាងមួយនិយាយអំពីវិធីជម្នះរាល់ឧបសគ្គទាំងអស់នេះ។

_____ ដឹងថា មានគោលនយោបាយ កំពុងតែប្រែគោលនយោបាយ និងកំពុងអនុវត្តគោលនយោបាយដូចជាការយកថ្លៃសាលា និងកាលវិភាគប្រចាំថ្ងៃរបស់សាលាដែលកំពុងរារាំងកុមារី និងកុមារាមួយចំនួនមិនឱ្យមានឱកាសទទួលការអប់រំប្រកបដោយគុណភាព។

_____ ផ្តល់សិទ្ធិឱ្យគ្រូបង្រៀនបង្កើតវិធីសាស្ត្របង្រៀនថ្មី។ ដើម្បីបង្រៀនសិស្ស។

_____ បង្កើតទំនាក់ទំនងល្អជាមួយសហគមន៍ ឆ្លើយតបនឹងតម្រូវការរបស់សហគមន៍ ហើយផ្តល់ឱកាសផ្លាស់ប្តូរទស្សនៈ និងគំនិតជាមួយសហគមន៍ អំពីការកែប្រែវិជ្ជមាន និងអំពីការអនុវត្តកម្មវិធីអប់រំដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព។

_____ ឆ្លើយតបនឹងតម្រូវការរបស់បុគ្គលិក និងរបស់សាលា និងមិនកេងប្រវ័ញ្ច រកផលចំណេញ។

_____ មានយន្តការគាំទ្រ យន្តការដឹកនាំច្បាស់លាស់ និងមានយន្តការតាមដាន ដែលមានប្រសិទ្ធភាព ដែលមនុស្សគ្រប់រូបបានរៀន ហើយបានចងក្រងជាឯកសារអំពីការអនុវត្តការអប់រំដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព និងអំពីការសម្រេចចិត្តសម្រាប់ពេលអនាគត។

បរិយាកាសសាលា

សាលារបស់អ្នក

_____ មានបរិក្ខារដែលអាចប្រើដើម្បីបំពេញតម្រូវការរបស់សិស្ស ដូចជា មានបង្គន់ដាច់សម្រាប់កុមារី និងមានផ្លូវដើរជាជម្រាល (មិនមានជណ្តើរ) សម្រាប់កុមារពិការសារពាង្គកាយ។

_____ មានបរិយាកាសកក់ក្តៅ មានសុខភាព និងអនាម័យល្អ។

_____ មានទឹកស្អាតប្រើ ហើយប្រសិនបើមានលក់ចំណីអាហារក្នុងសាលា ត្រូវតែជាចំណីដែលមានសុខភាព និងមានជីវជាតិ។

_____ មានបុគ្គលិកធ្វើការក្នុងសាលាដែលមានប្រវត្តិផ្សេងៗគ្នា (ទាំងស្ត្រី និងបុរស ជនជាតិ ភាគតិច ជនពិការ និងអ្នកកាន់សាសនាផ្សេង និងអ្នកដែលមានភាសាកំណើតផ្សេង និងមានស្ថានភាពសេដ្ឋកិច្ចខុសៗគ្នា)។

_____ មានបុគ្គលិក ដូចជា អ្នកពិគ្រោះការ និងគ្រូបង្រៀន ដែលចេះពីរភាសា ដែលអាចជួយកុមារ ដែលមានតម្រូវការអប់រំពិសេស។

_____ មានច្បាប់ និងវិធានការដែលអាចជួយគ្រូទាំងអស់ ជួយបុគ្គលិកសាលា ជួយមាតាបិតា និង កុមារឱ្យសហការគ្នា ដើម្បីបំពេញតម្រូវការអប់រំពិសេសរបស់កុមារមួយចំនួន។

_____ ធ្វើការជាក្រុម ដោយសហការគ្នារវាងគ្រូ និងសិស្ស។

_____ មានទំនាក់ទំនងជាមួយអាជ្ញាធរ និងស្ថាប័នសុខភាពដែលអាចជួយពិនិត្យសុខភាពរបស់កុមារឱ្យបានទៀងទាត់។

ជំនាញ ចំណេះដឹង និងឥរិយាបថរបស់គ្រូបង្រៀន

គ្រូបង្រៀន

_____ អាចពន្យល់អំពីអត្ថន័យរបស់ពាក្យ "ការរៀនមេត្រី" "ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព" ហើយអាចរកឧទាហរណ៍អំពីបរិយាកាសរៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព។

_____ ជឿជាក់ថា កុមារទាំងអស់ ទាំងកុមារី កូនអ្នកក្រីក្រ កូនអ្នកមាន កូនជនជាតិភាគតិច និងកុមារពិការ ពិតជាមានសមត្ថភាពរៀនដូចកុមារដទៃទៀតដែរ។

_____ ចូលរួមក្នុងសកម្មភាពស្វែងរកកុមារគ្រប់អាយុចូលសាលា តែមិនបានចូលរៀន ហើយចូលរួមធានាថា កុមារទាំងនោះមានឱកាសទទួលការអប់រំ។

_____ ស្គាល់អំពីជំងឺដែលអាចបង្កឱ្យកុមារពិការទាំងរាងកាយ និងបញ្ញា ហើយអាចជួយកុមារដែលមិនមានសុខភាពល្អ ឱ្យទៅជាកុមារដែលមានសុខភាពល្អវិញ។

_____ បានពិនិត្យសុខភាពជាប្រចាំ ដូចបុគ្គលិកដទៃទៀត ដែលធ្វើការក្នុងសាលា។

_____ មានជំនឿខ្ពស់ថា កុមារទាំងអស់មានសមត្ថភាពរៀន ហើយអាចបំផុសឱ្យកុមាររៀនរហូតចប់ថ្នាក់

_____ ដឹងថា មានធនធានសម្រាប់ប្រើប្រាស់ដើម្បីជួយកុមារដែលមានតម្រូវការអប់រំពិសេស។

_____ អាចស្គាល់អ្វីដែលជាទម្លាប់មានភាពលំអៀងយេនឌ័រ ក្នុងការបង្រៀន និងក្នុងឯកសាររៀន និងបង្រៀនក្នុងសាលា ហើយមានសមត្ថភាពកាត់បន្ថយទម្លាប់លំអៀងបែបនេះ។

_____ មានសមត្ថភាពបង្រៀនសិស្សឱ្យចេះលុបបំបាត់ភាពលំអៀង ដែលមានក្នុងសៀវភៅមេរៀន។

_____ មានសមត្ថភាពកែប្រែកម្មវិធីសិក្សា មេរៀន និងសកម្មភាពសិស្សក្នុងសាលា ដើម្បីឱ្យស្របតាមប្រវត្តិ និងសមត្ថភាពរបស់កុមារ។

_____ ប្រើប្រាស់ខ្លឹមសារមេរៀន ភាសា និងវិធីបង្រៀន ដែលអាចដឹកនាំសិស្សឱ្យរៀនកាន់តែប្រសើរ។

_____ មានសមត្ថភាពវាយតម្លៃការរៀនសូត្ររបស់សិស្ស ដោយស្របតាមសមត្ថភាព និងតម្រូវការរបស់សិស្ស។

_____ ចេះឆ្លុះបញ្ចាំងពីសមត្ថភាពរបស់ខ្លួន និងត្រៀមខ្លួនដើម្បីរៀន កែប្រែ និងដកបទពិសោធ និង–ផ្លាស់ប្តូរបទពិសោធជាមួយអ្នកដទៃ។

_____ មានសមត្ថភាពធ្វើការជាក្រុម។

អភិវឌ្ឍសមត្ថភាពគ្រូបង្រៀន

គ្រូបង្រៀន .....

_____ ចូលរួមក្នុងសិក្ខាសាលា ឬវគ្គផ្សេងៗអំពីថ្នាក់រៀន និងសាលារៀនដែលមានបរិយាកាសរៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព និងទទួលការបណ្តុះបណ្តាលបន្ត ដើម្បីអភិវឌ្ឍជំនាញ វិជ្ជាជីវៈឱ្យដល់កម្រិតឧត្តម។

២២ ប្រែក្លាយឱ្យទៅជាបរិយាកាសរៀនកុមារមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព

_____ ត្រូវធ្វើបទបង្ហាញពន្យល់ដល់គ្រួដទៃ មាតាបិតា និងសហគមន៍អំពីថ្នាក់រៀន ដែលមានបរិយាកាសរៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព។

_____ ទទួលការគាំទ្រជាបន្តបន្ទាប់ ដើម្បីបង្កើនការយល់ដឹងអំពីខ្លឹមសារមេរៀន ដែលត្រូវបង្រៀន (ដូចជា គណិតវិទ្យា)។

_____ ទទួលការគាំទ្រជាបន្តបន្ទាប់ដើម្បីរៀបរៀងសម្ភារៈរៀន និងបង្រៀន ទាក់ទងនឹងបរិយាកាសរៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព។

_____ ទទួលការគាំទ្រជាបន្តបន្ទាប់ពីអ្នករដ្ឋបាលសាលា តាមរយៈការអង្កេតជាប្រចាំ និងតាមរយៈជែនការគ្រប់គ្រងសាលា។

_____ ត្រូវមានបន្ទប់ ឬកន្លែងធ្វើការ ដែលអាចរៀបចំឯកសារបង្រៀន និងចែករំលែកចំណេះដឹងជាមួយអ្នកដទៃ។

_____ អាចធ្វើដំណើរទៅទស្សនកិច្ចសាលាផ្សេង ដែលមានបរិយាកាសរៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព។

សិស្ស

_____ កុមារទាំងអស់ក្នុងសហគមន៍ដែលគ្រប់អាយុចូលរៀន បានចូលរៀននៅសាលាជាប្រចាំ។

_____ សិស្សទាំងអស់ត្រូវមានសៀវភៅអាន និងឯកសាររៀនបន្ថែម ដែលអាចបម្រើតម្រូវការរៀនសូត្ររបស់សិស្ស។

_____ សិស្សទាំងអស់ត្រូវទទួលបានព័ត៌មានអំពីការវាយតម្លៃលើការសិក្សា ដូច្នេះ សិស្សអាចមើលឃើញចំណុចខ្លាយដែលត្រូវកែលំអ។

_____ កុមារដែលមានប្រវត្តិ និងសមត្ថភាពខុសគេ មានសិទ្ធិដូចកុមារដទៃក្នុងការរៀនសូត្រ ហើយមានសិទ្ធិនិយាយស្តីក្នុងថ្នាក់រៀន និងក្នុងសាលារៀន។

_____ កុមារទាំងអស់ នឹងត្រូវទទួលការយកចិត្តទុកដាក់តាមដាន ប្រសិនបើកុមារទាំងនោះមិនបានចូលរៀនទៀងទាត់។

_____ កុមារទាំងអស់មានឱកាសស្មើភាពគ្នា ក្នុងការចូលរួមក្នុងសកម្មភាពរបស់សាលា។

_____ សិស្សទាំងអស់ត្រូវចូលរួមជួយរៀបរៀងច្បាប់ និងវិន័យក្នុងថ្នាក់ និងច្បាប់ និងវិន័យសាលា ដោយមិន ប្រកាន់អ្វីទាំងអស់ មិនរើសអើង មិនមានអំពើហិង្សា និងមិនមានការរំលោភបំពាន។

ខ្លឹមសារមេរៀន និងការវាយតម្លៃការសិក្សា

_____ កម្មវិធីសិក្សាត្រូវទន់ភ្លន់ និងអនុញ្ញាតឱ្យគ្រូប្រើប្រាស់វិធីសាស្ត្របង្រៀនផ្សេង។ និងវិធីសាស្ត្ររៀន របស់សិស្សប្លែក។ ដូចជាការពិភាក្សាតាមក្រុម ឬការសម្តែងជាដើម។

_____ ខ្លឹមសារក្នុងកម្មវិធីសិក្សា ត្រូវតែពាក់ព័ន្ធនឹងជីវភាពប្រចាំថ្ងៃ និងបទពិសោធរបស់កុមារ ទាំងអស់ក្នុងសាលា ដោយមិនប្រកាន់ប្រវត្តិ ឬសមត្ថភាពឡើយ។

_____ កម្មវិធីសិក្សាត្រូវមានបញ្ចូលជំនាញអក្ខរកម្ម លេខនព្វន្ត និងបំណិនជីវិតសម្រាប់គ្រប់មុខវិជ្ជា។

_____ គ្រូបង្រៀនត្រូវប្រើធនធាន ដែលមានស្រាប់ក្នុងសហគមន៍ សម្រាប់ជួយកុមារឱ្យរៀន។

_____ សម្ភារៈរៀន និងបង្រៀនក្នុងកម្មវិធីសិក្សាត្រូវតែមានរូបភាព ឧទាហរណ៍ និងព័ត៌មានអំពី មនុស្សគ្រប់ប្រភេទ ទាំងកុមារី និងស្ត្រី ជនជាតិភាគតិច ប្រជាជនស្ថិតក្នុងស្ថានភាពសេដ្ឋកិច្ច ផ្សេងៗគ្នា និងជនពិការផងដែរ។

_____ កម្មវិធីសិក្សាត្រូវបម្រើតម្រូវការរៀនសូត្ររបស់កុមារគ្រប់ប្រភេទ ជាពិសេសកុមារពិការ។

_____ កុមារ ដែលមានការលំបាកក្នុងការរៀនសូត្រ ត្រូវមានឱកាសរំលឹកមេរៀន និងបំប៉នបន្ថែម ឬ ទទួលបានការបង្រៀនបន្ថែមម៉ោង។

_____ កម្មវិធីសិក្សា និងសម្ភារៈរៀន និងបង្រៀនត្រូវតែរៀបរៀងជាភាសាដែលកុមារប្រើប្រចាំថ្ងៃ ទាំងក្នុងសាលា និងក្រៅសាលា។

_____ កម្មវិធីសិក្សាត្រូវតែប្រែតរិយាបថរបស់សិស្ស ដូចជា ឱ្យសិស្សចេះគោរព យោគយល់គ្នា ហើយ ទទួលស្គាល់ និងឱ្យតម្លៃវប្បធម៌របស់ខ្លួន និងវប្បធម៌របស់អ្នកដទៃ។

_____ គ្រូបង្រៀនត្រូវមានឯកសារគំរូសម្រាប់វាយតម្លៃចំណេះដឹង បំណិន និងតរិយាបថរបស់សិស្ស គឺមិនប្រើប្រាស់តែការប្រលងមួយមុខឡើយ។

២៤ ប្រែក្លាយឱ្យទៅជាបរិយាកាសរៀនកុមារមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព

មុខវិជ្ជាពិសេស/សកម្មភាពបន្ថែម

_____ កុមារពិការត្រូវមានឱកាសលេងកំសាន្ត និងមានឱកាសអភិវឌ្ឍសមត្ថភាពផងដែរ។

_____ កុមារីត្រូវមានឱកាសចូលរៀន និងឱកាសលេងកំសាន្ត (ដូចជាលេងបាល់ទាត់ ដូចក្មេងប្រុសដែរ) និងបានចូលរួមក្នុងសកម្មភាពបន្ថែមក្នុងសាលា ដូចកុមារាដែរ។

_____ កុមារទាំងអស់ត្រូវមានឱកាសអាន សរសេរ និងរៀន ដោយប្រើភាសាកំណើតរបស់ខ្លួន។

_____ សាលាត្រូវឱ្យតម្លៃកុមារដែលកាន់សាសនាផ្សេងៗគ្នា កុមារគួរមានឱកាសរៀនអំពីទំនៀមទម្លាប់ និងសាសនាដទៃ តាមពេលវេលាសមស្រប។

សហគមន៍

_____ មាតាបិតា និងសហគមន៍ត្រូវដឹង និងយល់អំពីបរិយាកាសរៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព និងមានសមត្ថភាពជួយសាលាឱ្យក្លាយទៅជាសាលាដែលមានបរិយាកាសរៀនមេត្រីដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព។

_____ សហគមន៍ត្រូវចេះជួយសាលារៀន ក្នុងការរកកុមារទាំងអស់ដែលមិនបានចូលរៀន និងបញ្ជូនកុមារទាំងនោះឱ្យចូលរៀននៅសាលា។

_____ មាតាបិតា និងសហគមន៍ត្រូវចូលរួមឧបត្ថម្ភ ជាគំនិត និងជាធនធាន ដើម្បីអនុវត្តកម្មវិធីបរិយាកាសរៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព។

_____ មាតាបិតាត្រូវទទួលព័ត៌មានពីសាលា រៀនអំពីការចូលរៀនរបស់កូនៗ និងអំពីលទ្ធផលសិក្សារបស់កូនៗ។

តារាងស្វ័យវាយតម្លៃ នឹងជួយអ្នក និងសហការីរបស់អ្នកឱ្យចេះធ្វើដែនការ និងបង្កើតបរិយាកាសរៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព ក្នុងសាលារបស់អ្នក។ គោលបន្ទាប់បង្ហាញអំពីវិធីបង្កើតបរិយាកាសរៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព។ ដូច្នេះ សូមកុំភ្លេចអានតារាងស្វ័យវាយតម្លៃនេះ ហើយចងចាំតារាងនេះផង។ ការអនុវត្តកម្មវិធីបង្កើតបរិយាកាសរៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព ជាសកម្មភាពមួយដែលត្រូវអនុវត្តជាបន្តបន្ទាប់ និងចំណាយពេលយូរណាស់។ អ្នក សហការី មាតាបិតា និងសហគមន៍ ពិតជាចង់អានតារាងស្វ័យវាយតម្លៃនេះគ្រប់ពេល ដើម្បីតាមដានការអនុវត្ត និងពិនិត្យការរីកចម្រើនឈានទៅប្រែក្លាយសាលា ឱ្យទៅជាបរិយាកាសរៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព។

តើសាលារបស់យើងអាចក្លាយទៅជាសាលាដែលមានបរិយាកាសរៀនមេត្រីដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាពដោយរបៀបណា?

តើអ្នកអាចឆ្លើយនឹងសំណួររបស់គ្រូបង្រៀនម្នាក់មកពីសាលាផ្សេងយ៉ាងដូចម្តេចដែលគាត់បានសួរថា "តើយើងត្រូវធ្វើអ្វីខ្លះ ដើម្បីប្រែក្លាយសាលាមួយឱ្យទៅជាសាលាដែលមានបរិយាកាសរៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព? ការអាន និងពិភាក្សាអត្ថបទខាងក្រោម អាចជួយអ្នកឱ្យឆ្លើយនឹងសំណួរខាងលើបានជាមិនខាន។



សកម្មភាពអនុវត្ត : ប្រែក្លាយសាលាមួយនៅប្រទេសថៃឱ្យទៅជាសាលាដែលមានបរិយាកាសរៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព

នៅឆ្នាំ ១៩៥០ សាលាឈ្មោះមានច្រាសាទវិទ្យា បានសាងសង់នៅជាយក្រុងបាងកក មិនឆ្ងាយប៉ុន្មានពីតំបន់ដែលមានអគារខ្ពស់ៗ និងតំបន់អនាធិបតេយ្យ។ គោលបំណងរបស់សាលានេះ គឺប្រមូលកុមារទាំងអស់ឱ្យចូលសាលា មិនប្រកាន់ថា កូនអ្នកមាន ឬកូនអ្នកក្រឡើយ។ នៅឆ្នាំ ១៩៨៦ នាយិកា បានចាប់ផ្តើមអនុវត្តវិធីសាស្ត្របង្រៀនសិស្សគោលមជ្ឈមណ្ឌលក្នុងសាលានេះ។ នាយិការូបនោះ បានអនុញ្ញាតឱ្យគ្រូទាំងអស់ចូលរួមសិក្ខាសាលារយៈពេលបួនថ្ងៃ ដឹកនាំដោយអ្នកឯកទេសអប់រំម្នាក់ ដែលមានបទពិសោធយូរឆ្នាំក្នុងវិធីសាស្ត្រៀន និងបង្រៀនសិស្សគោលមជ្ឈមណ្ឌល។ សិក្ខាសាលានេះ មានការចូលរួមយ៉ាងសកម្មពីសំណាក់សិក្ខាកាមទាំងអស់។ គោលបំណងរបស់សិក្ខាសាលានេះគឺ សំដៅលើកកម្ពស់ ប្រសិទ្ធភាពរៀន និងបង្រៀនក្នុងថ្នាក់។ គ្រូជាច្រើននាក់មានការចាប់អារម្មណ៍នឹងវិធីសាស្ត្របង្រៀនបែបសកម្មនេះ។ លោកគ្រូអ្នកគ្រូបានចាប់ផ្តើមបង្កើតឯកសារបន្ថែម និងព្យាយាមប្រើវិធីថ្មីៗ ក្នុងថ្នាក់។ អ្នកគ្រូនាយិកាបានចាត់ទុកថា ការត្រួតពិនិត្យ ជាការកិច្ចដ៏ចំបង ហើយអ្នកគ្រូនាយិកា បានបំផុសឱ្យគ្រូចេះអង្កេត និងចែករំលែកបទពិសោធ និងចំណេះដឹងក្នុងចំណោមគ្រូទាំងអស់។ ការចែករំលែកបទពិសោធ និងចំណេះដឹងនេះ នឹងបង្កើតគំនិតច្នៃប្រឌិតថ្មីៗ។ ហើយជួយគ្រូឱ្យកាន់តែទុកចិត្តលើសមត្ថភាពផ្ទាល់ខ្លួន។ គ្រូបង្រៀនបានចាប់ផ្តើមចែករំលែកបទពិសោធគ្នាទៅវិញទៅមក តាមរយៈសិក្ខាសាលា។ គ្រូបង្រៀននៅសាលានេះ បានទៅទស្សនកិច្ចសិក្សានៅសាលាផ្សេង ដើម្បីរៀនអំពីវិធីថ្មីៗ។ ហើយអញ្ជើញគ្រូមកពីសាលាផ្សេង ទូទាំងប្រទេសថៃមកមើលសាលានេះផងដែរ។

សាលាមានច្រាសាទវិទ្យាបានព្យាយាមប្រើធនធានដែលមានក្នុងសហគមន៍ ហើយស្វែងរកធនធានថ្មីៗ ដើម្បីអភិវឌ្ឍសាលានេះបន្ថែមទៀត។ ទាំងអ្នកគ្រូនាយិកា និងអ្នកគ្រូ លោកគ្រូបានរួមគ្នា សរសេរអំពីបេសកកម្ម ទស្សនវិស័យ និងវប្បធម៌របស់សាលាទាក់ទងនឹងបរិយាកាសរៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាពដែលអនុវត្តតាមទំនៀមទម្លាប់ ប្រពៃណី និងសាសនាព្រះពុទ្ធ។ ឧទាហរណ៍ គ្រូ និងសិស្សត្រូវចំណាយពេលធ្វើសមាធិ និងឆ្លុះបញ្ចាំងលើខ្លួនឯង។

២៦ ប្រែក្លាយឱ្យទៅជាបរិយាកាសរៀនកុមារមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព

គោលបំណងមួយរបស់សាលាមានច្បាសាទវិទ្យា គឺសំដៅបង្ហាញឱ្យសង្គមថៃយល់ថា កុមារទាំងអស់ពិតជាមានសមត្ថភាពរៀនដូចៗគ្នាទាំងអស់។ នៅទសវត្សរ៍ ១៩៩០ អ្នកគ្រូនាយិកា គណៈកម្មការមាតាបិតាសិស្ស និងគ្រូបង្រៀន បានប្រមូលព័ត៌មានអំពីវិធីរកកុមារទាំងអស់ក្នុងសហគមន៍ឱ្យមកចូលរៀននៅសាលា។ ទាំងអស់គ្នាបានចាប់ផ្តើមចុះឈ្មោះ កុមារគ្រប់ប្រភេទ ដូចជា កុមារថ្លង់ កុមារដែលរពឹសខុសគេ និងកុមារឡោយបញ្ជាឱ្យចូលរៀនក្នុងសាលា។ មុននឹងចាប់ផ្តើមចុះឈ្មោះកុមារទាំងអស់នេះឱ្យចូលរៀន លោកគ្រូអ្នកគ្រូត្រូវទទួលបានការបណ្តុះបណ្តាលពិសេសអំពីវិធីសាស្ត្របង្រៀនកុមារទាំងនេះក្នុងថ្នាក់រៀន។ លោកគ្រូអ្នកគ្រូបានមើលឃើញ និងជឿជាក់ថា ក្នុងបរិយាកាសរៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព កុមារទាំងអស់ គឺគ្រប់ៗគ្នាទទួលបានជលប្រយោជន៍ទាំងអស់គ្នា។ នៅពេលដ្លវជាតិមួយត្រូវសង់នៅមុខសាលារៀនមានច្បាសាទវិទ្យា សាលាបានហៅកុមារ ដែលជាកម្មករធ្វើការនៅការដ្ឋានសាង់សង់ដ្លវមកចូលរៀន លេង និងរៀនជាមួយកុមារទាំងអស់ដែលរៀនក្នុងសាលា។ មាតាបិតាបានផ្តល់សំលៀកបំពាក់ឯកសណ្ឋានឱ្យកុមារធ្វើការទាំងនោះ សាលាមិនយកថ្លៃចំណាយអ្វីទាំងអស់។

ការផ្លាស់ប្តូរក្នុងសាលា គឺ ទាំងវិធីសាស្ត្ររៀន និងបង្រៀនសិស្សគោលមជ្ឈមណ្ឌល និងដោយដាក់បញ្ចូលគ្នាកុមារគ្រប់សមាសភាពឱ្យចូលរៀនក្នុងសាលា ត្រូវបានអនុវត្តជាបណ្តើរៗអស់រយៈពេលជាច្រើនឆ្នាំ។ អ្នកគ្រូនាយិកាបានដឹងថា គ្រប់គ្នាត្រូវការពេលវេលា ដើម្បីប្តូរពីប្រើវិធីចាស់ទៅប្រើវិធីថ្មី។ រៀងរាល់បី ឬប្រាំឆ្នាំ សាលាសរសេរធម្មនុញ្ញថ្មីមួយដែលយកចិត្តទុកដាក់លើអាទិភាពរៀនសូត្ររបស់កុមារទាំងអស់។ មនុស្សគ្រប់ៗរូបក្នុងសាលាចូលរួមសរសេរធម្មនុញ្ញនោះ។ សាលាបានប្រើប្រាស់ វិធីមួយហៅថា វិធីសាស្ត្រសហការ ដើម្បីផ្លាស់ប្តូរ "មនុស្សគ្រប់រូបចូលរួម មនុស្សគ្រប់រូបជាអ្នករៀន"។

ក្រោយពីបានអានករណីសិក្សាមួយខាងលើនេះ តើសាលាមានច្បាសាទវិទ្យាបានចាត់វិធានការអ្វីខ្លះដើម្បីប្រែក្លាយ ទៅជាបរិយាកាសរៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព? ចូរសរសេរវិធានការសំខាន់ៗ មួយចំនួន ហើយរំលែកចម្លើយ របស់អ្នកជាមួយសហការីផ្សេងៗទៀត។

១. _____

២. _____

៣. _____



សកម្មភាពឆ្លុះបញ្ចាំង : តើយើងកំពុងស្ថិតក្នុងស្ថានភាពបែបណា?

ចូរវិភាគ និងឆ្លុះបញ្ចាំងអំពីការផ្លាស់ប្តូរទាំងឡាយដែលបានកើតឡើងក្នុងសាលារបស់អ្នក ដែលអ្នកអាចយកទៅប្រើដើម្បីប្រែក្លាយទៅជាបរិយាកាសរៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព។

រំលឹក មើលកត្តាវិជ្ជមាន ដែលមានការផ្លាស់ប្តូរក្នុងថ្នាក់រៀនរបស់អ្នក ក្នុងសាលា ឬក្នុងសហគមន៍។ ចូរសរសេរវិធានការ ឬកត្តាសំខាន់នានាដែលអ្នក ឬអ្នកដទៃអនុវត្តសម្រេចបានជោគជ័យក្នុងការកែប្រែនេះ។

១. _____

២. _____

៣. _____

វិធីកែប្រែ និងធានានិរន្តរភាពនៃការកែប្រែនេះ

កត្តាខាងក្រោម មានសារៈសំខាន់សម្រាប់ធានាឱ្យមានការកែប្រែប្រកបដោយនិរន្តរភាពក្នុង សាលា។ តើវិធានការ ឬកត្តាខាងក្រោមអ្វីខ្លះ ស្របគ្នានឹងវិធានការ ឬកត្តាដែលអ្នកបានសរសេរខាងលើ? ចូរពិភាក្សាអំពីកត្តា ឬវិធានការដែលខុសគ្នា ជាមួយសហការីរបស់អ្នក ហើយតើអ្នកអាចយកកត្តា ឬវិធានការទាំងនោះទៅអនុវត្តក្នុងសាលារបស់អ្នកយ៉ាងដូចម្តេច?

១. ការដឹកនាំសម្រាប់ការកែប្រែនេះមានសារៈសំខាន់ណាស់។ ប្រសិនជាគ្មានការដឹកនាំទេ ក៏គ្មានការកែប្រែដែរ។ អ្នកដឹកនាំត្រូវតែជាមនុស្សណាម្នាក់ដែលមានមានតួនាទីដឹកនាំ ដូចជា ប្រធានគ្រូបង្រៀន ឬគ្រូបង្រៀនដែលមានចំណាប់អារម្មណ៍ និងប្តេជ្ញាប្តូរផ្តាច់ក្នុងការកែប្រែនេះ។ អ្នកនោះនឹងក្លាយទៅជា "ភ្នាក់ងារកែប្រែ" ជាអ្នកទទួលខុសត្រូវលើការងារទូទៅរបស់សាលា គ្រប់គ្រង និងដឹកនាំក្នុងការកែប្រែនេះ។

២. សិក្ខាសាលា និងឱកាសរៀនបន្ថែម សម្រាប់គ្រូបង្រៀនដែលសកម្ម និងចូលរួមអនុវត្តសកម្មភាពជាក់ស្តែង ដើម្បីធានាឱ្យមាននិរន្តរភាពនៃការផ្លាស់ប្តូរនេះ។ ឧទាហរណ៍ ចាប់ផ្តើមដោយបង្កើតទិវាអភិវឌ្ឍបុគ្គលិក ដោយអនុញ្ញាតឱ្យគ្រូបង្រៀនផ្លាស់ប្តូរបទពិសោធអំពីវិធីសាស្ត្របង្រៀនសិស្សគោលមជ្ឈមណ្ឌល ហើយផ្តល់ឱកាសឱ្យគ្រូបង្រៀនពិភាក្សាគ្នាជាសាធារណៈអំពីបញ្ហា និងកង្វល់អំពីបរិយាកាសរៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព។ បំផុសលោកគ្រូអ្នកគ្រូឱ្យអង្កេតការអនុវត្តរបស់គ្រូៗគ្នាឯង ហើយផ្តល់យោបល់តែលំអ។ ដោយសារកុមារទាំងអស់មានតម្រូវការខុសៗគ្នា ហើយបានចុះឈ្មោះចូលរៀន នៅសាលាមានច្រាសាទវិទ្យាតែមួយ ត្រូវរៀបចំសិក្ខាសាលាបន្ថែមដើម្បីបង្រៀនគ្រូឱ្យ (ក) យល់អំពីវិធីសាស្ត្ររៀនរបស់សិស្សទាំងអស់នេះ (ខ) រៀនអំពីវិធីបង្រៀនថ្មី។ និង (គ) កំណត់រកកត្តាដែលត្រូវកែប្រែក្នុងសាលា ដើម្បីជួយកុមារឱ្យរៀនកាន់តែល្អប្រសើរ។ ត្រូវធានាយកចំណេះដឹងល្អៗទទួលបានពីសិក្ខាសាលាមកអនុវត្ត រកតម្រូវការដើម្បីកែប្រែវិធីសាស្ត្ររៀន និងបង្រៀន និងផ្តល់គំនិតយោបល់សម្រាប់រៀបចំសិក្ខាសាលាវគ្គក្រោយៗទៀត។

៣. លើកកម្ពស់ការរៀន និងបង្រៀនក្នុងថ្នាក់ ជាការយកចិត្តទុកដាក់លើការប្រែក្លាយសាលាឱ្យទៅជាបរិយាកាសរៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព។ ចូរចាំថា សាលា ជាថ្នាក់រៀនមួយ។ ដោយសារសាលាតំណាងឱ្យបរិយាកាសទូទៅ អ្នក និងថ្នាក់រៀនរបស់អ្នក ត្រូវតែជិតស្និទ្ធ និងមានមេត្រីភាពជាមួយកុមារទាំងអស់។ អ្នកត្រូវជួបជាមួយសិស្សញឹកញាប់ ធ្វើការជាមួយសិស្សកាន់តែស្និទ្ធស្នាល ហើយវិធីបង្រៀន ត្រូវតែជួយដំរុញការរៀនសូត្ររបស់សិស្សឱ្យទទួលបានជោគជ័យ។

៤. ព័ត៌មានប្រមូលបានក្នុងសាលា និងសហគមន៍ ក៏ដូចជាព័ត៌មានអំពីបរិយាកាសរៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព ត្រូវតែយកទៅប្រើដើម្បីធ្វើសេចក្តីសម្រេចចិត្តឱ្យបានត្រឹមត្រូវ។ យើងត្រូវពិនិត្យមើល ប្រើវិធីប្រមូលព័ត៌មាន និងវិភាគព័ត៌មានមួយចំនួនក្នុងកម្រងសៀវភៅនេះ។

៥. ធនធាន ត្រូវប្រមូល និងប្រើឱ្យមានប្រសិទ្ធភាពបំផុត។ ទាំងគ្រួសារ និងសហគមន៍ គឺមានសារៈសំខាន់មិនអាចខ្វះបាន ដូចយើងបានរៀនរួចហើយ ក្នុងកម្រងសៀវភៅលេខ២ អំពីវិធីធ្វើការជាមួយគ្រួសារ និងសហគមន៍ ដើម្បីបង្កើតបរិយាកាសរៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព។

៦. **ផែនការមានសារៈសំខាន់មិនអាចខ្វះបាន** : ផែនការរយៈពេលវែង (៣ ទៅ ៥ ឆ្នាំ) ដែលទន់ភ្លន់ងាយបត់បែន អាចប្រើជាគោលការណ៍ណែនាំ ដើម្បីកែប្រែមួយជំហានម្តងៗ។ ផែនការផ្តល់ពេលវេលាឱ្យគ្រូបង្រៀន បុគ្គលិកសាលា និងសហគមន៍ ដើម្បីកែប្រែពីការអនុវត្តបែបចាស់បុរាណ មករកការអនុវត្តបែបថ្មី។ គ្រូបង្រៀន និងមាតាបិតា គួរចូលរួមក្នុងការបង្កើតគោលដៅ និងទិសដៅក្នុងផែនការ។ ប្រសិនបើមានការចូលរួមពីមនុស្សកាន់តែច្រើន និងសកម្ម តាំងពីដំបូង ផែនការនឹងកាន់តែល្អប្រសើរ ។

៧. **វិធីសាស្ត្រសហការ និងធ្វើការជាក្រុម** ក្នុងដំណើរការកែប្រែ ជាតម្រូវការចាំបាច់។ "មនុស្សគ្រប់រូបចូលរួម មនុស្សគ្រប់រូបជាអ្នករៀន ហើយគ្រប់ៗគ្នាសុទ្ធតែជាអ្នកឈ្នះ។" វិធីសាស្ត្រនេះបំផុសឱ្យមានគំនិតច្នៃប្រឌិតច្រើន និងឱ្យមនុស្សគ្រប់គ្នាមានទំនុកចិត្ត ចែករំលែកការកិច្ច និងការទទួលខុសត្រូវបានល្អ។

៨. **បេសកកម្ម ទស្សនវិស័យ និងវប្បធម៌**របស់សាលា ត្រូវសរសេរឱ្យល្អត្រឹមត្រូវ ដោយបង្ហាញអំពីកត្តាសំខាន់ៗរបស់បរិយាកាសរៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព ដូចបានពិភាក្សាក្នុងគោលដំបូង ក្នុងកម្រងសៀវភៅលេខ ១។ មនុស្សគ្រប់រូប ទាំងគ្រូ អ្នករដ្ឋបាលសាលា កុមារ មាតាបិតា និងអ្នកដឹកនាំសហគមន៍ ត្រូវចូលរួមក្នុងសកម្មភាពសរសេរបេសកកម្ម និងទស្សនវិស័យរបស់សាលា។

៩. **ទំនាក់ទំនងបន្ត**ជាមួយមាតាបិតា និងអ្នកដឹកនាំសហគមន៍ គឺមានសារៈសំខាន់ ដើម្បីបង្កើតភាពទុកចិត្ត និងជានាថា កុមារទាំងអស់បានចូលរៀនក្នុងសាលា ហើយរៀនតាមសមត្ថភាពរបស់ខ្លួន ហើយលើកកម្ពស់ជំនឿរបស់សហគមន៍ ឱ្យទទួលយកសាលាជាកម្មសិទ្ធិរបស់សហគមន៍ ហើយឱ្យសហគមន៍ និងសាលាចែករំលែកធនធានគ្នាទៅវិញទៅមកសម្រាប់ប្រើប្រាស់។



សកម្មភាពអនុវត្ត : ដោះស្រាយបញ្ហាជំទាស់

មិនមែនមនុស្សគ្រប់រូបមានបំណងចង់ផ្តាស់ប្តូរទាំងអស់ទេ។ មនុស្សមួយចំនួនជំទាស់នឹងគំនិតឱ្យផ្តាស់ប្តូរទម្លាប់ និងការអនុវត្ត ដែលបានធ្វើជាយូរឆ្នាំមកហើយ។ ចូរពិភាក្សាជាមួយសហការីរបស់អ្នក អំពីមូលហេតុមួយចំនួនដែលសាលាផ្សេង ឬសាលារបស់អ្នកជួលជំទាស់នឹងគំនិតកែប្រែឱ្យទៅជាសាលាដែលមានបរិយាកាសរៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព។ ចូរសរសេរគំនិតជំទាស់ទាំងនេះ។ តើមានវិធានការអ្វី ដើម្បីដោះស្រាយបញ្ហាជំទាស់ទាំងអស់នេះ?

១. គំនិតជំទាស់ : _____

វិធានការដោះស្រាយបញ្ហាជំទាស់នេះ : _____

_____

២. គំនិតជំទាស់ : _____

វិធានការដោះស្រាយបញ្ហាជំទាស់នេះ : _____

_____

៣. គំនិតជំទាស់ : _____

វិធានការដោះស្រាយបញ្ហាជំទាស់នេះ : _____

_____

៤. គំនិតជំទាស់ : _____

វិធានការដោះស្រាយបញ្ហាជំទាស់នេះ : _____

_____

៥. គំនិតជំទាស់ : _____

វិធានការដោះស្រាយបញ្ហាជំទាស់នេះ : _____

_____



គោល ១.៣
ជំហានអនុវត្តដើម្បីប្រែក្លាយឱ្យទៅជាបរិយាកាសរៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព

ជំហានធ្វើផែនការដើម្បីប្រែក្លាយឱ្យទៅជាបរិយាកាសរៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព

ក្រោយពីបានវាយតម្លៃអំពីស្ថានភាពសាលារបស់អ្នក ដើម្បីកែប្រែឱ្យក្លាយទៅជាបរិយាកាសរៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព និងក្រោយពីបានទទួលស្គាល់វិធានការកែប្រែទាំងនេះ អ្នកត្រូវសម្រេចចិត្តអនុវត្តជំហានបន្តបន្ទាប់ ដើម្បីបង្កើតបរិយាកាសរៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព ក្នុងថ្នាក់រៀន ឬក្នុងសាលារៀនទាំងមូល។ ខាងក្រោមជាអនុសាសន៍មួយចំនួន ស្តីពីជំហានក្នុងការធ្វើផែនការ និងអនុវត្តបរិយាកាសរៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព។ ជំហានទាំងនេះមិនមែនតម្រូវឱ្យអនុវត្តតាមលំដាប់នោះទេ។ ជំហានទាំងនេះ អាចជាកត្តា ឬវិធានការដែលអ្នកអាចប្រើក្នុងថ្នាក់រៀន និងក្នុងសាលារៀន ដើម្បីប្រែក្លាយទៅជាបរិយាកាសរៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព។ អ្នកអាចរកឃើញជំហានផ្សេងៗទៀត ស្របតាមពេលវេលា និងស្ថានភាពរបស់អ្នក។ អ្នកក៏អាចរកវិធានការផ្សេងទៀត ដើម្បីសម្រេចជំហានទីមួយៗផងដែរ។ ប៉ុន្តែកត្តាសំខាន់បំផុត គឺត្រូវមានឥរិយាបថវិជ្ជមានក្នុងការកែប្រែ និងបង្កើតបរិយាកាសរៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព។

ជំហានទី១ : បង្កើតក្រុមការងារបរិយាកាសរៀនមេត្រីដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព

រកមនុស្សដែលកាន់តួនាទីធ្វើផែនការ និងអនុវត្តបរិយាកាសរៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព ហើយបង្កើតក្រុមសម្របសម្រួលការងារមួយ

មនុស្សទាំងអស់នេះ នឹងបង្កើតជាក្រុមការងារបរិយាកាសរៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព។ ក្រុមនេះត្រូវមានសមាសភាព ដូចជា គ្រូបង្រៀន ប្រធានក្រុមបច្ចេកទេស មាតាបិតា ឬអាចបញ្ចូលអ្នកផ្សេងទៀត។ ក្រុមសម្របសម្រួល ត្រូវមានសមាសភាព ដូចជា គ្រូបង្រៀន អ្នករដ្ឋបាលសាលា និងបុគ្គលិកសាលាផ្សេងៗទៀត អ្នកជំនាញអប់រំ ភ្នាក់ងារសុខភាព និងប្រជាជនក្រីក្រជួបការលំបាក ជនពិការ សិស្សធំៗ មាតាបិតា សមាជិកសហគមន៍ និងអង្គការដែលធ្វើការក្នុងសហគមន៍។

ជំហានទី ២ : កំណត់រកតម្រូវការ

តើប្រជាជនបានដឹង និងយល់អំពីអ្វីខ្លះ ហើយប្រជាជនត្រូវយល់ដឹងអំពីអ្វីខ្លះ?

១. **ស្វែងយល់អំពីចំណេះដឹងរបស់ក្រុមសម្របសម្រួល :** *តើសមាជិកក្រុមការងារ បរិយាកាសរៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាពបានដឹងអំពីកត្តាសំខាន់ៗ និងសារប្រយោជន៍របស់បរិយាកាសរៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាពអ្វីខ្លះ? តើអ្នក និងក្រុមការងារនេះ ត្រូវរៀនអំពីអ្វីបន្ថែមទៀត ហើយតើមនុស្សគ្រប់រូបរៀនអំពីបរិយាកាសរៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាពដោយរបៀបណា (ឧទាហរណ៍ អញ្ជើញអ្នកជំនាញឱ្យនិយាយ ជួបជាមួយអ្នកជំនាញ និងទៅអាននៅមណ្ឌលឯកសារជាដើម)?*

២. **ស្វែងយល់អំពីចំណេះដឹងរបស់សិស្ស បុគ្គលិក មាតាបិតា អាណាព្យាបាល និងរបស់សមាជិកសហគមន៍ :** *នៅពេលក្រុមសម្របសម្រួលស្គាល់ច្បាស់ អំពីបរិយាកាសរៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព ជ្រើសរើសសំណួរដែលត្រូវសួរអ្នកដទៃ។ សកម្មភាពនេះ ត្រូវសម្ភាស និងជួបពិភាក្សាជាក្រុម ឬត្រូវរៀបចំកម្រងសំណួរដែលត្រូវចុះសួរ។*

រៀនអំពីសាលា និងអំពីកុមារក្នុងសហគមន៍

១. **ពិនិត្យ ឬបំពេញតារាងស្វ័យវាយតម្លៃ អំពីបរិយាកាសរៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព** *មានបង្ហាញក្នុងគោលដំបូងនិយាយអំពី "តើយើងស្ថិតក្នុងស្ថានភាពបែបណា?" សរសេរក្នុងតារាងមួយ អំពីការងារដែលសាលារបស់អ្នកបានធ្វើរួចហើយ និងការងារដែលត្រូវធ្វើបន្តដើម្បីប្រែក្លាយទៅជាសាលាដែលមានបរិយាកាសរៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព។*

២. **ស្វែងរកឱ្យឃើញកុមារក្នុងសហគមន៍ ដែលមិនបានចូលសាលារៀន :** *គោលសម្រាប់អនុវត្តសកម្មភាពនេះ មានបង្ហាញច្បាស់ក្នុងកម្រងសៀវភៅលេខ៣ ស្តីពី "ប្រមូលកុមារទាំងអស់ឱ្យចូលរៀនក្នុងសាលា"។*

៣. **កំណត់រកតម្រូវការរៀនសូត្ររបស់សិស្សក្នុងថ្នាក់ និងរបស់កុមារដែលគេមិនគិតគូរអើពើក្នុងសហគមន៍ :** *សមាជិកក្រុមស្វែងយល់អំពីតម្រូវការ ឱ្យបានច្រើនតាមដែលអាចរកបាន ដើម្បីធ្វើការសម្រាប់ថ្នាក់រៀន និងសម្រាប់សាលារៀនឱ្យបានល្អ ដោយដាក់បញ្ចូលកុមារគ្រប់សមាសភាពឲ្យចូលរៀន។ ក្រុមការងារត្រូវវាយតម្លៃអំពីតម្រូវការរៀនសូត្ររបស់សិស្ស ប្រសិនបើមិនធ្លាប់បានធ្វើពីមុនទេ។ មាតាបិតាអាចជួយផ្តល់ព័ត៌មានអំពីកូនៗ និងកុមារក្នុងភូមិផងដែរ។*

---

2 The steps in this section were adapted from The All Children Belong Project, www.uni.edu/coe/inclusion/decision_making/planning_steps.html, and from Booth T, Ainscow M, et al. (2000) Index for Inclusion: Developing learning and participation in schools (Bristol, CSIE).

๔. **ស្វែងរកធនធានដែលអាចប្រើបានក្នុងសាលារៀន និងក្នុងសហគមន៍** : *សរសេរតម្រូវការរបស់កុមារ និងសេវាទាំងអស់សម្រាប់បម្រើកុមារដែលមានប្រវត្តិ និងតម្រូវការខុសគេក្នុងតារាងមួយ។ សេវាទាំងនេះ អាចជាសេវារបស់រដ្ឋ របស់អង្គការក្រៅរដ្ឋាភិបាល ក្លឹនិក និងភ្នាក់ងារឯកជន។*

๕. **ពណ៌នាអំពីកម្មវិធីអប់រំថ្មីៗ និងបរិយាកាសសាលា** : *ការពណ៌នានេះត្រូវនិយាយឱ្យច្បាស់។ អំពីបរិក្ខាគ្រឿងសង្ហារឹម និងសម្ភារ ដែលមានក្នុងសាលា និងប្រើការបាន។ តើកុមារទាំងអស់អាចប្រើប្រាស់បរិក្ខាគ្រឿងសង្ហារឹម និងសម្ភារទាំងនេះបានដែរឬទេ? បើប្រើមិនបាន តើធ្វើដូចម្តេចដើម្បីឱ្យកុមារប្រើបាន?*

๖. **ស្វែងរក និងពណ៌នាអំពីសកម្មភាពរៀន និងបង្រៀនក្នុងថ្នាក់** : *ចុះមើលថ្នាក់រៀន ហើយពិពណ៌នាអំពីសកម្មភាពជាក់ស្តែងរបស់គ្រូ និងសិស្សក្នុងថ្នាក់រៀន។ តើថ្នាក់រៀនដែលអ្នកចុះមើលទាំងនោះមានបរិយាកាសរៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាពដែរឬទេ? តើហេតុអ្វី?*

វិភាគព័ត៌មាននេះ : *ពណ៌នាអំពីការកែប្រែដែលត្រូវតែធ្វើឱ្យបាន ដើម្បីប្រែក្លាយថ្នាក់រៀនឱ្យទៅជាថ្នាក់ដែលមានបរិយាកាសរៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព។ ពិចារណាអំពីទំហំថ្នាក់រៀន វិធីសាស្ត្ររៀន និងបង្រៀន បែបបទនៃការបង្រៀន ទំនាក់ទំនងរវាងគ្រូ និងសិស្ស អ្នកជំនួយការក្នុងថ្នាក់ និងសម្ភារប្រើក្នុងថ្នាក់។*

ប្រមូលព័ត៌មានបន្ថែម : *ព័ត៌មានដែលអ្នកប្រមូលបាន អាចជួយជាគំនិតក្នុងការបង្កើតសំណួរថ្មីៗ ដើម្បីសួរកព័ត៌មានបន្ថែម។ ប្រមូលព័ត៌មានបន្ថែមដើម្បីធ្វើសេចក្តីសម្រេចចិត្តឱ្យបានត្រឹមត្រូវ តាមព័ត៌មានដែលពាក់ព័ន្ធ គឺមិនយកតែទស្សនៈ ឬគំនិតផ្ទាល់ខ្លួនទេ។*

ជំហានទី៣ : បង្កើតទស្សនវិស័យ

ពណ៌នាអំពីបរិយាកាសក្នុងថ្នាក់រៀនដែលអ្នកចង់បាន ឬ"ថ្នាក់រៀនក្នុងសុបិនរបស់អ្នក"៖ នៅពេលដែលអ្នក និងសិស្សរបស់អ្នកដើរក្នុងថ្នាក់ តើអ្នកមើលឃើញសកម្មភាពយ៉ាងដូចម្តេច? តើថ្នាក់រៀនត្រូវការគ្រឿងសង្ហារឹមប្រភេទណា? តើគ្រូបង្រៀនត្រូវធ្វើអ្វីខ្លះ? តើសិស្សត្រូវធ្វើអ្វីខ្លះ? តើនៅលើជញ្ជាំង គួរដាក់តាំងអ្វីខ្លះ? ត្រូវគិតអំពីកុមារា និងកុមារីដែលមិននិយាយភាសាដូចសិស្សដទៃ កុមារដែលមានបញ្ហាមើលស្តាប់ និងបញ្ហាខ្សោយ និងកុមារដែលមានប្រវត្តិ សាសនា និងសមត្ថភាពខុសគេ គឺត្រូវគិតអំពីកុមារគ្រប់សមាសភាព។ ប្រសិនបើកុមារគ្រប់អាយុចូលរៀនទាំងអស់ បានចូលរៀនក្នុងសាលា តើតម្រូវការរៀនសូត្ររបស់កុមារទាំងអស់នោះមានអ្វីខ្លះ? ហើយតើយើងអាចបំពេញតម្រូវការទាំងនោះដោយរបៀបណា? ចូរសរសេរខ្លឹមសារទស្សនវិស័យរបស់អ្នកឱ្យច្បាស់លាស់ អំពី"ថ្នាក់រៀនក្នុងសុបិនរបស់អ្នក"។ ទស្សនវិស័យនេះនឹងត្រូវប្រើជាគោលដៅរបស់អ្នក ដើម្បីប្រែក្លាយថ្នាក់រៀនឱ្យទៅជាថ្នាក់ដែលមានបរិយាកាសរៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព។

បន្ទាប់ទៀត ពណ៌នាអំពីកម្មវិធីអប់រំ និងបរិយាកាសសាលា ដែលអ្នកចង់បាន ។ ពិចារណាអំពីធនធានដែលបានពណ៌នាខាងលើ។ តើអ្នកត្រូវការជំនួយគាំទ្រអ្វីខ្លះពីសហគមន៍ ពីអាជ្ញាធរមូលដ្ឋាន និងពីមន្ត្រីអប់រំ? តើអ្នកអាចទៅរកជំនួយគាំទ្រទាំងនេះដោយរបៀបណា? អ្នកណានឹងជួយផ្សព្វផ្សាយរកជំនួយគាំទ្រនេះ ដោយរបៀបណា? តើកុមារអាចចូលរួមដោយរបៀបណា? ចូរសរសេរអំពីសកម្មភាពដែលឆ្លើយនឹងសំណួរនេះក្នុងតារាងមួយ។ សកម្មភាពទាំងនេះនឹងជួយអ្នកក្នុងការសរសេរអំពី"ទស្សនវិស័យ"របស់អ្នក។

ជំហានទី ៤ : ធ្វើផែនការអភិវឌ្ឍន៍សាលា ដែលមានបរិយាកាសរៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព

ជាការចាំបាច់ ត្រូវបង្កើតារាងកម្មវិធីសកម្មភាព ដើម្បីបង្កើត និងអនុវត្តកម្មវិធីបរិយាកាសរៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព អ្នកត្រូវពណ៌នាឱ្យលំអិតអំពីការកែប្រែដែលត្រូវធ្វើឱ្យបាន ហើយកំណត់ពេលវេលាអនុវត្តសកម្មភាពកែប្រែទាំងនោះ ឱ្យច្បាស់លាស់។ អ្នកក៏ត្រូវសរសេរអំពីសម្ភារ និងសេវា អំពីអ្នកទទួលខុសត្រូវផ្តល់សេវា និងធនធានដែលត្រូវការក្នុងតារាងមួយឱ្យបានច្បាស់លាស់។ កម្មវិធីសកម្មភាពត្រូវដាក់កាលបរិច្ឆេទឱ្យច្បាស់លាស់ សម្រាប់អនុវត្តសកម្មភាពកែប្រែទាំងនេះ។ ក្នុងកម្មវិធីសកម្មភាពនេះ ត្រូវសរសេរឱ្យច្បាស់អំពីគោលដៅ ហើយកម្មវិធីសកម្មភាពនេះត្រូវតែទន់ភ្លន់ងាយបត់បែន ដើម្បីសមស្រប តាមតម្រូវការ និងលក្ខខណ្ឌផ្សេង។។

ផ្តល់ធនធានបន្ថែមតាមតម្រូវការ : រៀបចំតារាងតម្រូវការបន្ថែមឱ្យហើយស្រេច (ដូចជា ថវិកាសម្រាប់រៀបរៀងសម្ភារឧបទេស ប្រព័ន្ធរៀនស្វ័យសិក្សាតាមក្រម ឬបង្កើតគណៈកម្មាធិការគ្រូ និងមាតាបិតាដើម្បីស្វែងរកធនធានបន្ថែម)។

គិតគូរអំពីចិត្ត គំនិតរបស់មនុស្ស : ការអភិវឌ្ឍវិស័យអប់រំ ដែលបំផុសឱ្យសិស្សចូលរៀន និងប្រឹងរៀនមានពីរវិធានការ គឺ តាមរយៈការវិភាគលំអិត ផែនការលំអិត និងតាមរយៈការកែប្រែចិត្តគំនិតរបស់មនុស្ស។ អ្នកអាចប្រើតារាងស្វ័យវាយតម្លៃ និងគោលការណ៍ណែនាំទាំងនេះ ដើម្បីធ្វើវិភាគលំអិត។ តើអ្នកត្រូវធ្វើអ្វីខ្លះ ដើម្បីកែប្រែចិត្តគំនិតរបស់មនុស្ស? ឧទាហរណ៍ ចាប់ផ្តើមបង្កើនការចូលរួមរបស់មាតាបិតា និងសហគមន៍ក្នុងសកម្មភាពថ្នាក់រៀន។ ការចូលរួមនេះនឹងជួយឱ្យមាតាបិតា និងសហគមន៍រៀនអំពីសារប្រយោជន៍របស់បរិយាកាសរៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព ហើយមាតាបិតា និងសហគមន៍ អាចជួយអ្នកក្នុងការបង្រៀន និងជួយសិស្សក្នុងការរៀនឱ្យកាន់តែប្រសើរឡើងផងដែរ។ កម្រងសៀវភៅលេខ២ "ធ្វើការជាមួយគ្រួសារ និងសហគមន៍ ដើម្បីបង្កើតបរិយាកាសរៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព" ជួយជាគំនិតបន្ថែមទៀត ដែលអ្នកអាចយកមកសាកល្បងបាន។

ជំហានទី ៥ : អនុវត្តផែនការរបស់អ្នក

ផ្តល់ជំនួយបច្ចេកទេសដល់បុគ្គលិកតាមតម្រូវការ។ តើត្រូវការជំនួយបច្ចេកទេស ដូចជា រៀបចំសិក្ខាសាលាស្តីអំពីប្រធានបទពិសេស។ ដែលឲ្យអ្នកមានបទពិសោធមកនិយាយដែរឬទេ? តើត្រូវការជំនួយបច្ចេកទេសបែបណា ហើយអ្នកណាអ្នកផ្តល់ឱ្យ? តើត្រូវអនុវត្តផែនការនេះដោយរបៀបណា ហើយត្រូវផ្តល់ជំនួយបច្ចេកទេសចំនួនប៉ុន្មាន?

បណ្តុះបណ្តាលបុគ្គលិកបម្រើការនៅសាលា (ទាំងបុគ្គលិកបង្រៀន និងបុគ្គលិកមិនបង្រៀន) ហើយបណ្តុះបណ្តាលសិស្សផងដែរ ប្រសិនបើត្រូវការចាំបាច់។ ប្រធានបទបណ្តុះបណ្តាល រួមមាន សិទ្ធិកុមារ និងផលប្រយោជន៍របស់សិទ្ធិកុមារសម្រាប់ការអប់រំ វិសមភាពយេនឌ័រ និងសមធម៌យេនឌ័រ ភាពខុសគ្នា និងភាពស្រដៀងគ្នានៃវប្បធម៌ និងភាសា ការយល់ដឹងអំពីពិការភាព អំពីការគាំពារ និងថែទាំ អំពីការទទួលខុសត្រូវរបស់បុគ្គលិក និងអំពីវិធីសាស្ត្របង្រៀនថ្មីៗ។ល។

បំផុសចលនាឱ្យមាតាបិតាចូលរួម។ ក្រុមការងារធ្វើផែនការត្រូវបង្កើតប្រព័ន្ធទំនាក់ទំនងរវាងមាតាបិតា និងគ្រូបង្រៀន។ តើអ្នកណាជាអ្នកទទួលខុសត្រូវទំនាក់ទំនងជាប្រចាំជាមួយមាតាបិតា? យោបល់របស់មាតាបិតាគួរយកមកពិចារណា និងដាក់បញ្ចូលក្នុងផែនការ និងក្នុងសកម្មភាពអនុវត្តផងដែរ។

ធ្វើផែនការមួយដើម្បីដោះស្រាយបញ្ហាជំទាស់។ នៅសាលាមានច្រាសទឹកឡា អ្នកគ្រូនាយិកាអនុញ្ញាតឱ្យគ្រូកែប្រែបរិយាកាសក្នុងសាលាដើម្បីឱ្យងាយស្រួលអនុវត្ត។ គ្រូភាគច្រើនអនុវត្តវិធីសាស្ត្រសិស្សគោលមជ្ឈមណ្ឌល ប៉ុន្តែគ្រូមួយចំនួនមិនអាចអនុវត្តបាន។ មាតាបិតាភាគច្រើនគាំទ្រការសម្រេចចិត្តរបស់សាលាដើម្បីដាក់បញ្ចូលគ្នាគ្រប់សមាសភាព ប៉ុន្តែមួយចំនួនបារម្ភអំពីចំនួនកុមារពិការដែលចុះឈ្មោះចូលរៀននៅសាលា។ មាតាបិតាទាំងនេះមិនចង់ឱ្យសាលាមានឈ្មោះថា "សាលាសម្រាប់កុមារពិការ ឬសម្រាប់កុមារដែលមានតម្រូវការអប់រំពិសេស"នោះទេ។ សាលាបានដោះស្រាយបញ្ហានេះដោយកំណត់ភាគរយច្បាស់លាស់។ ប្រើព័ត៌មានទទួលបានពីសកម្មភាពទូវគោល១.១ (សកម្មភាពស្តីពីភាតព្វកិច្ចដើម្បីប្រែក្លាយទៅជាបរិយាកាសរៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព) ដើម្បីកំណត់រកបញ្ហាជំទាស់ដែលអាចកើតមាន និងកំណត់រកវិធានការដោះស្រាយបញ្ហាជំទាស់ទាំងនេះ។

ជំហានទី៦ : វាយតម្លៃផែនការរបស់អ្នក និងអបអរការជោគជ័យរបស់អ្នក

តាមដានការវិភាគចម្រើន និងកែសម្រួលផែនការរបស់អ្នក ប្រសិនបើចាំបាច់ : ក្រុមការងារបង្កើតបរិយាកាសរៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព ជាធនធានដែលត្រូវប្រើពេញមួយឆ្នាំសិក្សា ដូចជា រៀបចំកម្មវិធីប្រជុំ តាមដានការងារ។ សម្រេចរកវិធីតាមដាន ហើយរកមនុស្សដែលទទួលខុសត្រូវការងារនេះ។ អង្កេតអំពីដំណើរការសកម្មភាពរបស់កម្មវិធីដែលកំពុងអនុវត្ត។ ពិនិត្យមើលថា តើជំនួយគាំទ្រគ្រប់គ្រាន់ ឬ ត្រូវការបន្ថែមទៀតដែរឬទេ ឬក៏ត្រូវលុបចោល?

អបអរចំពោះជោគជ័យរបស់អ្នក : ការកែប្រែបានជោគជ័យក្នុងកម្មវិធីអប់រំ ជាពិសេស កម្មវិធីដែលបានវិនិយោគធនធានមនុស្ស និងធនធានសម្ភារ។ យើងត្រូវអបអរសាទរចំពោះជោគជ័យរបស់យើង។ សង្ឃឹមថា អ្នកនឹងអនុញ្ញាតឱ្យសហគមន៍ចូលរួមក្នុងគ្រប់ជំហានទាំងអស់ ហើយអញ្ជើញសហគមន៍ឱ្យចូលរួមក្នុងកម្មវិធីអបអរសាទរការជោគជ័យក្នុងសាលារបស់អ្នក ក្នុងពិធីបុណ្យអ្វីមួយ ឬក្នុងឱកាស "បើកបវេសនកាល"។ ក្នុងឱកាសបើកបវេសនកាល គួរអញ្ជើញមាតាបិតាសិស្ស សមាជិកសហគមន៍ និងមន្ត្រីអប់រំឱ្យចូលរួមជង។ ក្នុងឱកាសនោះ ត្រូវតាំងពិព័រណ៍រាល់ការងារសម្រេចបានរបស់កុមារ និងសម្ភារបង្រៀនថ្មីៗដែលគ្រូផលិតបាន។ គ្រូបង្រៀនត្រូវបង្ហាញជំនាញថ្មី។ និងវិធីសាស្ត្របង្រៀនថ្មី។ ហើយកុមារពិការត្រូវធ្វើសកម្មភាពបង្ហាញអំពីលទ្ធផលដែលគេទទួលបានពីការសិក្សា។

វិធីតាមដានការរីកចម្រើនរបស់យើង

តើយើងបានកែប្រែអ្វីខ្លះឱ្យមានភាពខុសពីមុន? តើថ្នាក់រៀន និងសាលារៀនរបស់យើងបានក្លាយទៅជាបរិយាកាសរៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាពហើយឬនៅ? ដើម្បីរកឱ្យឃើញថា អ្នកបានបង្កើតបរិយាកាសរៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាពបានជោគជ័យ អ្នកត្រូវសួរសំណួរពីរ :

១. តើយើងបានបង្កើតបរិយាកាសរៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព តាមបំណងរបស់យើង ដែរឬទេ? (តើយើងអាចកែលំអអ្វីដែលយើងបានធ្វើកន្លងមកឱ្យបានល្អប្រសើរជាងមុនដោយរបៀបណា?)

២. តើយើងបានកែប្រែអ្វីខ្លះឱ្យមានភាពខុសពីមុន ជាពិសេសការលើកកម្ពស់លទ្ធផលនៃការរៀនសូត្ររបស់សិស្ស?

អ្នកអាចវាយតម្លៃដំណើរការសកម្មភាពលេខ (១) និងលទ្ធផលលេខ (២) របស់បរិយាកាសរៀនមេត្រីដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព ជាលក្ខណៈផ្លូវការ និងក្រៅផ្លូវការ។ អ្នក និងអ្នកដទៃក្នុងសាលា អាចវាយតម្លៃជាលក្ខណៈក្រៅផ្លូវការ ហើយយកព័ត៌មានដែលប្រមូលបានពីការវាយតម្លៃនេះទៅប្រើ ដើម្បីកែប្រែកម្មវិធី។ លើសពីការវាយតម្លៃក្រៅផ្លូវការ យើងត្រូវទុកចិត្តលើអ្នកក្រៅឱ្យវាយតម្លៃកម្មវិធីរបស់យើងជាប្រចាំជាលក្ខណៈផ្លូវការដង់ដែរ។ ការវាយតម្លៃបែបនេះ ជាចំណែកមួយក្នុងការបង្កើនការទុកចិត្តលើសកម្មភាពរបស់សាលារៀន ឬអាចចាត់ទុកជាសកម្មភាពមើលសាលាដោយ "ភ្នែកមនុស្សថ្មី"។ នៅសាលាមានថ្ងៃសាទរទិទ្យាក្នុងឱកាសបើកបវេសនកាល ឱ្យមាតាបិតាបំពេញកម្រងសំណួរវាយតម្លៃបរិក្ខាររបស់សាលា សមិទ្ធផលរបស់សាលា និងលទ្ធផលរៀនសូត្ររបស់សិស្ស ហើយឱ្យមាតាបិតា ផ្តល់អនុសាសន៍ដើម្បីកែលំអ។ ប្រសិនបើអនុវត្តបានបែបនេះ អ្នកនឹងទទួលបានគំនិតល្អជាច្រើន។ ចូរចាំថា កុមារក៏ជាអ្នកត្រួតពិនិត្យ និងជាអ្នកវាយតម្លៃដ៏មានប្រសិទ្ធភាពដែរ ហេតុដូច្នេះ យើងត្រូវតែសួរកុមារដង់ដែរ។

៣៦ ប្រែក្លាយឱ្យទៅជាបរិយាកាសរៀនកុមារមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព

តារាង់ស្វ័យវាយតម្លៃអំពីបរិយាកាសរៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព ដែលបង្ហាញជូននៅខាងដើមនៃកម្រងសៀវភៅនេះ អាចយកមកប្រើជាគោលសម្រាប់តាមដាន ដូច្នេះ អ្នកអាចមើលឃើញការរីកចម្រើនរបស់សាលា ដើម្បីក្លាយជាបរិយាកាសរៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព ក្នុងអំឡុងពេលពេញមួយឆ្នាំសិក្សា ពីរឆ្នាំ បីឆ្នាំ ច្រើនឆ្នាំ ឬមួយទស្សវត្សរ៍ ឬលើសពីមួយទស្សវត្សរ៍។

បន្ថែមលើតារាង់ស្វ័យវាយតម្លៃនេះ អ្នកអាចប្រើវិធានថ្នាំងខាងក្រោម ដើម្បីប្រមូលព័ត៌មានអំពីលទ្ធផលទាក់ទងនឹងការប្រែក្លាយសាលាឱ្យទៅជាសាលាដែលមានបរិយាកាសរៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព។

១. ការកត់ត្រាទុកជាឯកសារ និងក្នុងកំណត់ហេតុ : អ្នក និងសហការី គ្រូបង្រៀន អាចកត់ត្រាក្នុងកំណត់ហេតុប្រចាំខែអំពីជោគជ័យដែលអ្នកទទួលបានក្នុងការបង្កើតបរិយាកាសរៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព។ ការកត់ត្រានេះត្រូវកត់បញ្ចូលទាំងសកម្មភាព និងការប្រជុំក្នុងសាលា និងក្នុងសហគមន៍។ ប្រធានថ្នាក់ និងសិស្សដទៃទៀត ក៏ត្រូវកត់ត្រាកំណត់ហេតុជាប្រចាំ អំពីសកម្មភាព និងព្រឹត្តិការណ៍ដែលបានកើតឡើង ហើយយកអ្វីដែលបានកត់ត្រាមកពិភាក្សាជាមួយគ្រូ និងជាមួយថ្នាក់រៀនទាំងមូលជារៀងរាល់ខែ។ អ្នកដឹកនាំសហគមន៍ ឬមាតាបិតា ក៏ត្រូវចុះពិនិត្យសាលា ឱ្យបានជាប្រចាំ និងកត់ត្រាទុកជាកំណត់ហេតុផងដែរ។

២. និយាយជាមួយអ្នកដទៃ : សកម្មភាពភាគច្រើនគឺ អនុវត្តក្រៅផ្លូវការ នៅពេលកម្មវិធីបង្កើតបរិយាកាសរៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាពរបស់អ្នកកំពុងដំណើរការ។ ប៉ុន្តែជួនកាលអ្នកត្រូវរៀបជែនការឱ្យច្បាស់លាស់ ដើម្បីរៀបចំពិធីអ្វីមួយ ប្រសិនបើយើងចង់បានចម្លើយពីអ្នកដទៃ។ អ្នកអាចអនុវត្តសកម្មភាពនេះ ដោយប្រើកម្រងសំណួរ និងកត់ត្រាចម្លើយ។ ពិភាក្សាជាមួយកុមារ មាតាបិតា និងគ្រូបង្រៀនផ្សេង។ទៀត ជាក្រុម ឬជាបុគ្គល។ ចាំបាច់អ្នកក៏ត្រូវសួរសំណួរដែលអាចប្រមូលព័ត៌មាន និងទស្សន:ជាច្រើន គឺ មិនមែនចម្លើយតាមការសន្និដ្ឋានរបស់មនុស្ស ថាជាចម្លើយដែលអ្នកចង់បាននោះទេ។

៣. វាយតម្លៃចំណេះដឹង និងជំនាញតាមរយៈការសរសេរតែងសេចក្តី ឬអត្ថបទខ្លី: តើគ្រូផ្សេងទៀត និងអ្នកដឹងអំពីប្រភេទសិស្ស ក្នុងសាលាមានច្រើនសមាសភាពដែរឬទេ? អ្នកប្រហែលជាចង់ឱ្យគ្រូបង្រៀនផ្សេងទៀតសរសេរអត្ថបទខ្លីអំពីអ្វីដែលគេបានដឹង ហើយឱ្យគ្រូបង្រៀនសរសេរសំណួរក្នុងតារាង់មួយ សួរអំពីអ្វីដែលគេចង់ស្វែងយល់បន្ថែម។ សកម្មភាពនេះ ក៏ល្អសម្រាប់សិស្សផងដែរ។

៤. អង្កេត : តើយើងគួរអង្កេតមើលអ្នកណាខ្លះ និងមើលអ្វីខ្លះ? ប្រធានក្រុមបច្ចេកទេសត្រូវអង្កេតការបង្រៀនរបស់គ្រូក្នុងថ្នាក់ ព្រោះការបង្រៀននេះជាផ្នែកមួយនៃការអភិវឌ្ឍសមត្ថភាពជំនាញរបស់គ្រូ។ (កត់ត្រានូវការអង្កេតរបស់ប្រធានក្រុមបច្ចេកទេសនៅតាមថ្នាក់រៀន និងអំពីខ្លឹមសារនៃការពិភាក្សាក្នុងពេលចុះអង្កេត)។ ការអង្កេតដោយគ្រូគ្នាឯងក៏មានសារៈសំខាន់ សម្រាប់ការបង្រៀនជាក្រុមផងដែរ។

គ្រូបង្រៀននៅថ្នាក់មួយ អាចអង្កេតសកម្មភាពរបស់សិស្សនៅថ្នាក់ផ្សេង។ទៀតដែរ។ កត់ត្រាលទ្ធផលនៃការអង្កេត និងយោបល់ដែលទទួលបានពីការអង្កេតជាដែរ ហើយយកលទ្ធផលនៃការអង្កេតនេះ ទៅពិភាក្សាជាប្រចាំជាមួយគ្រូបង្រៀនផ្សេង។ទៀត និងជាមួយប្រធានក្រុមបច្ចេកទេស។

សូមមើលអគារ និងបរិស្ថានជុំវិញខ្លួនជាដែរ។ តើសកម្មភាពបង្កើតបរិយាកាសរៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាពរបស់អ្នក ចូលរួមចំណែកដល់ការកែប្រែមុខមាត់របស់សាលាដែរឬទេ? "តើមានជួបឧបសគ្គដែរឬទេ? តើបង្គន់របស់កុមារា និងបង្គន់របស់កុមារីនៅកន្លែងខុសគ្នាដែរឬទេ? តើកុមារា និងកុមារី គ្រប់ប្រភេទមានឱកាសស្មើភាពគ្នា លេងនៅទីធ្លាលេងកំសាន្តដែរឬទេ?

អង្កេតលើការកែប្រែនៃអត្តចរិត និងឥរិយាបថរបស់សិស្ស។ តើសិស្សក្នុងថ្នាក់ចេះជួយគ្នាប្រសើរជាងមុនដែរឬទេ?

៥. ឯកសារ : សិក្សា និងវិភាគឯកសារផ្សេង។របស់សាលា ដូចជាព្រឹត្តិបត្រ សំបុត្រសរសេរទៅមាតាបិតាសិស្ស របាយការណ៍បូកសរុបលទ្ធផល កិច្ចតែងការបង្រៀន និងកម្មវិធីសិក្សាលំអិតតាមមុខវិជ្ជា។ តើលិខិតផ្លូវការផ្ញើជូនទៅមាតាបិតាសិស្ស និងសហគមន៍ ឆ្លុះបញ្ចាំងអំពីបរិយាកាសរៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព តាមដែលអ្នកចង់បានដែរឬទេ?



គោល ១.៤
តើយើងបានរៀនពីបទពិសោធអ្វីខ្លះកន្លងមក?

អ្នកបានរៀនចប់កម្រងសៀវភៅលេខ១នេះរួចហើយ ប៉ុន្តែអ្នកត្រូវអនុវត្តសកម្មភាពមួយទៀត។ យើងអាចចាប់ផ្តើមស្វែងយល់ និងរំលឹកឡើងវិញ តើអ្នកបានរៀនអ្វីខ្លះអំពីបរិយាកាសរៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព ក្នុងកម្រងសៀវភៅនេះ? តើអ្នកអាចបំពេញលំហាត់ខាងក្រោមនេះបានដែរឬទេ?

១. តើបរិយាកាសរៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាពជាអ្វី? ចូរពន្យល់អត្ថន័យនៃបរិយាកាសរៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព ហើយតើបរិយាកាសរៀនមេត្រីដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព ក្នុងថ្នាក់រៀនមានលក្ខណៈដូចម្តេច (និយាយអំពីរបៀបអង្គុយ សម្ភារៈរៀន និងបង្រៀន និងទំនាក់ទំនងក្នុងថ្នាក់រៀន)។

២. សរសេរកត្តាសំខាន់ៗចំនួនប្រាំរបស់បរិយាកាសរៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព។

៣. សរសេរសារប្រយោជន៍របស់បរិយាកាសរៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាពឱ្យបានពីរសម្រាប់ក្រុមនីមួយ។ ដូចជា សម្រាប់កុមារ គ្រូបង្រៀន មាតាបិតា និងសម្រាប់សមាជិកសហគមន៍។

៤. ហេតុអ្វីបានជាក្នុងក្រុមនីមួយ។ មានអ្នកជំទាស់ចំពោះការប្រែក្លាយឱ្យទៅជាបរិយាកាសរៀនមេត្រីដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព?

៥. ចូរសរសេរជំហានសំខាន់ៗក្នុងការកែប្រែក្នុងសាលាទូទៅ និងពណ៌នាអំពីជំហាននីមួយៗក្នុងការកែប្រែក្នុងសាលារបស់អ្នកផ្ទាល់។

៦. តើជំហានសំខាន់ទាំងប្រាំក្នុងការធ្វើដែនការកម្មវិធីសម្រាប់បង្កើតបរិយាកាសរៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាពមានអ្វីខ្លះ? តើសាលារបស់អ្នកបានកែប្រែក្នុងជំហានមួយណា? តើអ្នកបានធ្វើអ្វីខ្លះ ដើម្បីប្រែក្លាយសាលារបស់អ្នកឱ្យទៅជាបរិយាកាសរៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព? ដោយសារការងារនេះជាសកម្មភាពអនុវត្តជាបន្តបន្ទាប់ តើអ្នកត្រូវធ្វើអ្វីបន្តទៀត?

បង្កើតបរិយាកាសរៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព ជាផ្លូវដ៏ល្អមួយដែលត្រូវធ្វើដំណើរ។ តាមពិត ប្រសិនបើចង់ធានាសម្រេចគោលដៅអប់រំសម្រាប់ទាំងអស់គ្នា មានតែបង្កើតបរិយាកាសរៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាពទេ ជាផ្លូវល្អនាំទៅរកការសម្រេចនេះ។ ការបង្កើតបរិយាកាសនេះ ទាមទារការប្តេជ្ញាចិត្ត ការខិតខំប្រឹងប្រែង និងចន្លះនយោបាយបើកចំហ។ ប្រសិនបើបង្កើតបរិយាកាសរៀនមេត្រីដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាពបាន យើងនឹងសប្បាយរីករាយគ្រប់ៗគ្នា ដោយបានឃើញកុមារទាំងអស់ ទិតខំរៀនសូត្រ កុមារដែលរៀនក្នុងសាលា បានទទួលចំណេះដឹងថ្មីៗពីកុមារដែលចូលរៀនថ្មី ដែលធ្លាប់តែគេមិនគិតគូរ ហើយកុមារដែលគេមិនគិតគូរពីមុន នឹងបានចូលសាលារៀនព្រមទាំងសប្បាយរីកជាមួយនឹងការរៀនសូត្រក្នុងសាលាជាមិនខាន។

កម្រងសៀវភៅនេះបានជួយអ្នកឱ្យគិតពិចារណាអំពីសកម្មភាពនានាដែលសាលារបស់អ្នកបានអនុវត្តរួចហើយ ដើម្បីប្រែក្លាយទៅជាបរិយាកាសរៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព ហើយក៏បានជួយជាគំនិត ដើម្បីធ្វើឱ្យសាលារបស់អ្នកកាន់តែមានបរិយាកាសរៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាពថែមទៀត។ សូមសួរខ្លួនឯងថា **"តើខ្ញុំអាចកែប្រែអ្វីខ្លះក្នុងថ្នាក់រៀន និងក្នុងសាលារៀនរបស់ខ្ញុំ? ចូរសរសេរគោលដៅផ្ទាល់ខ្លួនបី ហើយប្រៀបធៀប និងពិភាក្សាជាមួយសហការីរបស់អ្នក។ មួយ ឬ ពីរសប្តាហ៍ក្រោយ ចូរពិនិត្យមើលថា តើអ្នកមានការរីកចម្រើនដោយរបៀបណា?**

តើអ្នកអាចរៀនបន្ថែមនៅកន្លែងណា?

ការចោះពុម្ពផ្សាយខាងក្រោម និងវេបសាយ (Web sites) គឺជាធនធានដ៏មានតម្លៃ ជាដែរសម្រាប់លើក ទឹកចិត្តឱ្យមានទូទំនាក់ទំនង កាន់តែជិតស្និទ្ធថែមទៀតរវាងសាលារៀន គ្រួសារ និងសហគមន៍។

ឯកសារយោង

Booth T, Ainscow M, Black-Hawkins K, Vaughan M and Shaw L. (2000) Index for Inclusion: Developing Learning and Participation in Schools. Bristol: Centre for Studies on Inclusive Education.

Dutcher N. (2001) Expanding Educational Opportunity in Linguistically Diverse Societies. Center for Applied Linguistics: Washington, DC.

Pijl SJ, Meijer CJW, and Hegarty S. (Eds.) (1997) Inclusive Education: A Global Agenda. London: Routledge.

Slavin RE, Madden NA, Dolan LJ and Wasik BA. (1996) Every Child, Every School: Success for All. Newbury Park, California: Corwin.

UNESCO (2001) Open File on Inclusive Education: Support Materials for Managers and Administrators. Paris.

UNESCO (1993) Teacher Education Resource Pack: Special Needs in the Classroom. Paris.

UNESCO (2000) One School for All Children. EFA 2000 Bulletin. Paris.
United Nations (1989) Convention on the Rights of the Child. Adopted and opened for signature, ratification and accession by General Assembly resolution 44/25 of 20 November 1989, entry into force 2 September 1990, in accordance with article 49.

Web sites

Centre for Studies on Inclusive Education (CSIE).
http://www.inclusion.uwe.ac.uk

Enabling Education Network (EENET).
http://www.eenet.org.uk

International Labour Organization.
http://www.ilo.org

Organisation for Economic Co-operation and Development.
http//www.oecd.org/els/education

UNESCO. http://www.unesco.org/education

UNESCO/Inclusive Education.
http://www.unesco.org/education/sne

UNICEF.
http://www.unicef.org

UNICEF Teachers Talking About Learning.
http://www.unicef.org/teachers

World Bank.
http://www.worldbank.org

World Health Organization (WHO).
http://www.who.int/home-page

Many national governments have Web sites that provide information on their inclusive education policies and activities. An easy way to access government sites through the Internet is through 'Governments on the Web' at
http://www.gksoft.com/govt/en

ឯកសារយុទ្ធសាស្ត្រ ស្តីពីការអប់រំកុមារតូចតាចដែលងាយរងគ្រោះ ក្នុងបរិការណ៍ជំងឺរាតត្បាតកូវីដ-១៩

កម្រងសៀវភៅលេខ : ២

ធ្វើការជាមួយគ្រួសារ និងសហគមន៍ ដើម្បីបង្កើតបរិយាកាសរៀនមេត្រី ដោយបញ្ចូលគ្រប់សមាសភាព



បរិយាកាសរៀនមេត្រី
ដោយបញ្ចូលគ្រប់សមាសភាព

UNESCO

សេចក្តីណែនាំអំពីគោល

កម្រងសៀវភៅលេខ២ ពណ៌នាអំពីវិធីដែលអ្នកអាចជួយមាតាបិតា និងសមាជិកសហគមន៍ ព្រមទាំងអង្គការនានាឱ្យចូលរួមអភិវឌ្ឍ និងបង្កើតបរិយាកាសរៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព។ កម្រងសៀវភៅនេះណែនាំអំពីវិធីចលនាសហគមន៍ឱ្យចូលរួមក្នុងសកម្មភាពសាលា និងចលនាសិស្សឱ្យចូលរួមក្នុងសកម្មភាពសហគមន៍វិញ។ សៀវភៅនេះក៏ណែនាំវិធីដែលបាន និងកំពុងអនុវត្តកន្លងមក ហើយក៏ផ្តល់នូវគំនិត និងយោបល់អំពីវិធីចលនា និងបំផុសគ្រួសារ និងសហគមន៍ឱ្យចូលរួមកាន់តែសកម្មក្នុងការលើកកម្ពស់ និងអភិវឌ្ឍបរិយាកាសរៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាពផងដែរ ។

គោល

គោល ២.១ ទំនាក់ទំនងរវាងគ្រូបង្រៀន មាតាបិតា និងសហគមន៍ក្នុងបរិយាកាសរៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព ---------- ៣

តើនរណាជាសហគមន៍ ឬសហគមន៍ជាអ្វី?---------- ៣

ហេតុអ្វីបានជាយើងចលនាឱ្យសហគមន៍ចូលរួម? ---------- ៤

តើយើងមានតួនាទី និងការទទួលខុសត្រូវអ្វីខ្លះ? ---------- ៨

គោល ២.២ ព័ត៌មាន និងការគាំទ្រមតិឱ្យមានបរិយាកាសរៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាពនៅតាមគ្រួសារ និងតាមសហគមន៍ ---------- ១១

ការបង្កើតទំនាក់ទំនងជាមួយគ្រួសារ និងសហគមន៍ ---------- ១១

រក្សាការច្រាស្រ៉ៃយទាក់ទងគ្នាជាប្រចាំ ---------- ១៣

ជំរុញការគាំទ្រមតិឱ្យមានបរិយាកាសរៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព ---------- ១៩

គោល ២.៣ សហគមន៍ និងកម្មវិធីសិក្សា ---------- ២២

សហគមន៍ក្នុងថ្នាក់រៀន ---------- ២២

ថ្នាក់រៀន និងសហគមន៍ ---------- ២៥

គោល ២.៤ តើយើងបានរៀនបទពិសោធអ្វីខ្លះនាពេលកន្លងមក? ---------- ២៧

គោល ២.១



ទំនាក់ទំនងរវាងគ្រូ មាតាបិតា និងសហគមន៍ក្នុងបរិយាកាសរៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព

តើនរណាជាសហគមន៍ ឬសហគមន៍ជាអ្វី?

សហគមន៍រួមមានមាតាបិតា និងអាណាព្យាបាលរបស់សិស្ស សមាជិកផ្សេងៗក្នុងគ្រួសារ និងប្រជាជនរស់នៅជិតខាងសាលា។ សហគមន៍គិតទាំងគ្រូបង្រៀនដែលចូលនិវត្តន៍ លោកតា លោកយាយ និងមនុស្សគ្រប់ៗរូប ដែលរស់ក្នុងតំបន់ក្បែរសាលា។ ប្រសិនបើសាលានៅទីប្រជុំជន សហគមន៍នៅទីប្រជុំជនអាចខុសពីសហគមន៍ជនបទ។ សហគមន៍ទីប្រជុំជនអាចមានអ្នកជំនួញ អ្នកលក់ដូរ មន្ត្រីរាជការ និងអ្នកដទៃទៀត។ មនុស្សទាំងនោះ អាចរួមចំណែកយ៉ាងធំធេង ក្នុងការលើកកម្ពស់ការរៀនសូត្ររបស់កុមារឱ្យមានបរិយាកាសរៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព។

ក្នុងបរិយាកាសរៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព យើងត្រូវទទួលខុសត្រូវបង្កើតបរិយាកាសមួយដើម្បីឱ្យកុមារគ្រប់រូប ទាំងស្រី និងប្រុស អាចរៀនបានដូចគ្នា និងមានអារម្មណ៍ចូលរៀនក្នុងបរិយាកាស"រៀនមេត្រី"។ មាតាបិតា និងសមាជិកសហគមន៍ មានការងារសំខាន់ក្នុងការគាំទ្រការអភិវឌ្ឍបរិយាកាសរៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព ក្នុងសាលា និងក្នុងថ្នាក់រៀនរបស់យើង។ ឧទាហរណ៍ មាតាបិតា និងសមាជិកសហគមន៍ ត្រូវធ្វើការជាមួយយើង ដើម្បីធានាកុមារឱ្យឃើញកុមារមិនបានចូលរៀនក្នុងសហគមន៍ ដើម្បីប្រមូលកុមារទាំងនោះឱ្យចុះឈ្មោះចូលរៀន និងបន្តការសិក្សាឲ្យបានវែងឆ្ងាយ។

គួរឱ្យសោកស្តាយបំផុត ទោះបីជាដឹងថា ការចូលរួមរបស់សហគមន៍ក្នុងការអភិវឌ្ឍបរិយាកាសរៀនមេត្រីដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព មានសារៈសំខាន់យ៉ាងណាក៏ដោយ ក៏យើងឃើញថា ការអនុវត្តជាក់ស្តែង សហគមន៍ និងសាលារៀននៅតែឋិតនៅឆ្ងាយពីគ្នា។ បញ្ហានេះប្រែហែលជាកើតឡើង ដោយសារមូលហេតុច្រើនយ៉ាង។ ប្រែហែលជាដោយសារពេលវេលារបស់សាលា និងពេលវេលារបស់មាតាបិតាមិនត្រូវគ្នា ឬមិនស្របគ្នា ជាពិសេសពេលមាតាបិតា (មាតាបិតា មេម៉ាយ ឬពោះម៉ាយ) មិនមានពេលចូលរួមក្នុងសកម្មភាពសាលា ព្រោះជាប់រវល់ការងារចិញ្ចឹមជីវិត។ ជួនកាលយើងជាគ្រូ ត្រូវបានចាត់តាំងឱ្យទៅធ្វើការនៅសាលាដែលយើងមិនសូវស្គាល់។ យើងជាគ្រូមិនរស់ក្នុងសហគមន៍ដែលយើងបង្រៀន ហើយជួនកាល យើងត្រូវស្នាក់នៅសាលា ហើយចុងសប្តាហ៍ យើងត្រូវទៅផ្ទះជួបជុំគ្រួសារនៅភូមិឆ្ងាយ។ ដោយសារហេតុផលទាំងនេះ និងហេតុផលផ្សេងៗទៀត ការច្រាស្រ៉ៃយទាក់ទងគ្នា ត្រូវកើតឡើងតាមផ្លូវតែមួយគត គឺ ពីសាលាទៅឪពុកម្តាយ ឬពីសាលាទៅសហគមន៍ ហើយការច្រាស្រ៉ៃយទាក់ទងពីមាតាបិតាទៅសាលា ឬពីសហគមន៍ទៅសាលាកម្រកើតឡើងណាស់។

សហគមន៍បានចូលរួមជាមួយសាលាឬទេ?

អ្នកអប់រំនៅចេណៃ ប្រទេសឥណ្ឌាបានចាប់អារម្មណ៍លើពាក្យមួយប្រយោគថា "សហគមន៍ទាំងអស់បានចូលរួមជាមួយសាលារៀន"។ ទោះបីជាអ្នកអប់រំទាំងនោះមើលឃើញខ្លួនឯងថា ជាផ្នែកមួយរបស់សហគមន៍ក៏ដោយ ក៏អ្នកអប់រំទាំងនោះមិនសូវទំនាក់ទំនងជិតស្និទ្ធជាមួយប្រជាជន និងអង្គការដទៃទៀតក្នុងសហគមន៍ដែរ។ ទំនាក់ទំនងដែលអ្នកអប់រំទាំងនោះមានគឺ តែជាមួយស្ថាប័នអប់រំផ្សេងៗទៀតប៉ុណ្ណោះ។ អ្នកអប់រំមានអារម្មណ៍ឯកោនៅឆ្ងាយពីជីវភាពរស់នៅក្នុងសហគមន៍។ អ្នកអប់រំមិនដឹងអំពីអ្នកដទៃឡើយ ហើយអ្នកដទៃក៏មិនបានដឹងអំពីអ្នកអប់រំដែរ ហើយក៏មិនដឹងអ្វីដែលអ្នកអប់រំបានធ្វើដែរ។ ជាទូទៅ អ្នកអប់រំចង់ធ្វើការជាមួយអ្នករៀនសូត្រ និងមាតាបិតា ដើម្បីទទួលបានគំនិតអំពីសាលារៀនណាស់។ ហេតុដូចនេះ អ្នកអប់រំចាប់ផ្តើមធ្វើការជាមួយមាតាបិតាជាក្រុមតូច។ ដើម្បីលើកទឹកចិត្តឱ្យមានការពិភាក្សាកាន់តែសកម្មថែមទៀតជាមួយគ្រូបង្រៀន។ អ្នកអប់រំក៏បានអញ្ជើញសមាជិកសហគមន៍ក្នុងស្រុកមកសាលារៀនដើម្បីបង្កបរិយាកាសទំនាក់ទំនងជាមួយអ្នកសិក្សាផងដែរ។

- Booth T and Black-Hawkins K. (2001) Developing Learning and Participation in Countries of the South: The Role of an Index for Inclusion. UNESCO: Paris.

ហេតុអ្វីបានជាយើងចលនាឱ្យសហគមន៍ចូលរួម?

សហគមន៍ជាបរិបទរួមមួយដែលកុមារត្រូវរស់នៅ និងរៀនសូត្រ និងអនុវត្តអ្វីដែលយើងបានបង្រៀន។ តម្លៃ និងការចូលរួមរបស់គ្រួសារ អ្នកដឹកនាំសហគមន៍ និងសមាជិកសហគមន៍ មានសារៈសំខាន់យ៉ាងខ្លាំងដើម្បីធានាឱ្យកុមារទាំងអស់បានចូលសាលារៀន ហើយជួយកុមារឱ្យរៀនបានជោគជ័យ។ ឧទាហរណ៍ ប្រសិនបើគ្រួសារ និងសហគមន៍ឱ្យតម្លៃលើការអប់រំដែលយើងផ្តល់ (ព្រមទាំងឱ្យតម្លៃលើយើងដែល ជាគ្រូ) កុមារនឹងឱ្យតម្លៃផងដែរទៅលើឱកាសរៀនសូត្ររបស់ពួកគេផងដែរ។ កត្តានេះនឹងជំរុញកុមារឱ្យគោរពយើង និងគោរពមិត្តរួមថ្នាក់ ជាពិសេសអ្នកដែលមានប្រវត្តិ និងសមត្ថភាពខុសគេ ព្រមទាំងបំផុសកុមារឱ្យអនុវត្តការរៀនសូត្រក្នុងជីវភាពប្រចាំថ្ងៃរបស់ពួកគេផងដែរ។

សហគមន៍ផ្តល់ផងដែរនូវព័ត៌មាន និងចំណេះដឹងដ៏មានប្រយោជន៍ ដែលយើងអាចប្រើសម្រាប់កែលំអការបង្រៀនរបស់យើង និងជំរុញការរៀនសូត្ររបស់កុមារ។ ឧទាហរណ៍ យើងអាចបញ្ចូលរឿង ឬចម្រៀងប្រពៃណីផ្សេងៗ ទៅក្នុងមេរៀនភាសារបស់យើង ឬយើងប្រើបច្ចេកទេសផ្សេងៗគ្នាក្នុងការដាំដើមឈើក្នុងស្រុក ឬចិញ្ចឹមសត្វតាមមេរៀនវិទ្យាសាស្ត្ររៀននៅសាលា។

លើសពីនេះទៀត ប្រសិនបើយើងចង់ប្រមូលផ្តុំធនធានដែលចាំបាច់ ដើម្បីកែលំអការរៀនសូត្ររបស់កុមារទាំងអស់ ដើម្បីកែលំអគុណភាពសាលារបស់យើង និងដើម្បីសម្រេចបានការផ្លាស់ប្តូរស្ថិតស្ថេរ និងជាប់លាប់ **ចាំបាច់ យើងត្រូវតែធ្វើការរួមគ្នា។** សាលារៀននៅហ្វីលីពីនដែលបានចូលរួមក្នុងការកែទម្រង់វិស័យអប់រំបានធ្វើការកត់សម្គាល់ដូចខាងក្រោម :

អន្តរាគមន៍ដាច់តែឯង និងដំណោះស្រាយយ៉ាងរហ័សនឹងមិនសម្រេចបានជោគជ័យឡើយ។ ចាំបាច់ត្រូវមានការទាក់ទងគ្នារវាងអន្តរាគមន៍ និងវិធីសាស្ត្រផ្សេងៗគ្នា ដែលមានគ្រូបង្រៀន អ្នកគ្រប់គ្រងសាលា និងអ្នកសង្កេត អ្នកឃ្លាំមើល មាតាបិតា និងសមាជិកសហគមន៍ ព្រមទាំងកុមារត្រូវចូលរួមក្នុងដំណើរការនៃការផ្លាស់ប្តូរនេះ (ដែលធ្វើឱ្យមានភាពខុសគ្នាដ៏ជាប់លាប់)។

- Feny de los Angeles-Bautista with Marissa J. Pascual, Marjorie S. Javier, Lillian Mercado-Carreon and Cristina H. Abad. (2001). Reinventing Philippine Education: Building Schools Filipino Children Deserve. The Ford Foundation, Philippines.

សហគមន៍គឺជាធនធានមួយដ៏មានតម្លៃសម្រាប់សាលារៀន ដែលបានចាប់ផ្តើមអភិវឌ្ឍបរិយាកាសរៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព។ សាលារៀនអង្គការ BRAC នៅប្រទេសបង់ក្លាដេសគឺជាឧទាហរណ៍។

គំរូដំបូងនៃការតស៊ូមតិសហគមន៍ដើម្បីបង្កើតឱ្យមានបរិយាកាសរៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព

ក្នុងឆ្នាំ ១៩៧៩ សាលារៀនរបស់អង្គការ BRAC លើកដំបូងបានបើកនៅប្រទេសបង់ក្លាដេសដោយឆ្លើយតបតាមសំណើរបស់ស្ត្រីរៀនក្នុងថ្នាក់ អក្ខរកម្មមួយដែលចង់ឱ្យមានការអប់រំជាមូលដ្ឋានសម្រាប់កូនៗ។ ពាក្យ BRAC មានន័យថា "គណៈកម្មការអភិវឌ្ឍជនបទបង់ក្លាដេស"។ BRAC ជាអង្គការក្រៅរដ្ឋាភិបាលមួយ ដែលបានចូលរួមជាមួយគណៈកម្មការជនបទបង់ក្លាដេស បានជួយស្ត្រីជាម្តាយបង្កើតគណៈកម្មការសាលាមួយស្វែងរកកន្លែងសម្រាប់សង់សាលារៀន រកគ្រូបង្រៀន និងគ្រប់គ្រងសាលារៀន។

អង្គការ BRAC បានកំណត់អត្តសញ្ញាណកុមារក្រីក្រ ជាពិសេសកុមារី ដោយធ្វើអង្កេតតាមគ្រួសារ។ សាលារៀនត្រូវចុះឈ្មោះចូលរៀនភាគច្រើនជាកុមារី មានកម្មវិធីសិក្សាច្បាស់លាស់ មានការបង្រៀនដែលផ្តោតទៅលើកុមារ និងលុបចោលការដាក់ទណ្ឌកម្មលើរូបកាយ។ ពេលគឺសិស្សរៀនចប់កម្មវិធីអប់រំជាមូលដ្ឋានរបស់ BRAC សិស្សទាំងនោះអាចចូលរៀនបន្តទៀតនៅសាលារដ្ឋ។ កុមារជាច្រើនរៀនបានជោគជ័យយ៉ាងគាប់ប្រសើរ។

ជាធម្មតា បុគ្គលិកសិក្សាគឺជាប្រជាជនដែលរស់ក្នុងសហគមន៍ ហើយរក្សាទូទៅទាក់ទងយ៉ាងខ្ពស់ជាមួយមាតាបិតា។ មាតាបិតាកំណត់ពេលវេលាជាក់លាក់សម្រាប់កម្មវិធីសាលា និងអាចផ្លាស់ប្តូរម៉ោងពេលក្នុងអំឡុងពេលនៃឆ្នាំសិក្សា ដើម្បីឱ្យស្របតាមរដូវកសិកម្ម និងវិស្សមកាល។ មាតាបិតាត្រួតពិនិត្យក្រៅផ្លូវការ និងតាមដានចំនួនអវត្តមានរបស់គ្រូបង្រៀនដែលមានកំរិតតិចបំផុត។ សាលានីមួយៗមានគណៈកម្មការគ្រប់គ្រងសាលាមួយ ដែលមានសមាសភាពមាតា ឬបិតាចំនួនបីរូប អ្នកដឹកនាំសហគមន៍មួយរូប និងគ្រូបង្រៀន។ ពួកគេត្រូវទទួលខុសត្រូវរួមគ្នាក្នុងការគ្រប់គ្រងសាលា។

បុគ្គលិករបស់អង្គការ BRAC រៀបចំការជួបប្រជុំជារៀងរាល់ខែសម្រាប់មាតាបិតា និងគ្រូបង្រៀន តាមពេលវេលាសមស្របសម្រាប់មាតាបិតាសិស្ស។ ស្ត្រីជាច្រើនបានចូលរួមការប្រជុំ ដោយហេតុថា ការប្រជុំត្រូវធ្វើឡើងនៅពេលថ្ងៃ។ សុច្ឆន្ទាការចង្អុលបង្ហាញពីគុណភាពរបស់អង្គការ BRAC កំណត់ថា មាតាបិតាយ៉ាងតិច ៣០% ចូលរួមរាល់ការប្រជុំ។ តាមការដាក់ស្នែង កុមារប្រហែល ៨០% មានវត្តមានរបស់មាតាបិតាបានចូលរួមការប្រជុំ។ មាតាបិតាអាចសំដែងចេញនូវការព្រួយបារម្ភរបស់ខ្លួនអំពីបញ្ហាសាលារៀន តែអង្គការ BRAC បានលើកបង្ហាញបញ្ហាកង្វល់ដ៏ចំបងទាក់ទងនឹងថ្លៃឈ្នួលសាលា ថ្លៃចំណាយផ្សេងៗ ចំងាយផ្លូវ វិនិយ និងការរៀបចំកម្មវិធីសិក្សា ជាហេតុធ្វើឱ្យមានការមិនពេញចិត្តតិចតួចណាស់។

- Adapted from Rugh A and Bossert H. (1998) Involving Communities: Participation in the Delivery of Education Programs. Washington, DC: Creative Associates International, Inc.



សកម្មភាពឆ្លុះបញ្ចាំង : តើសហគមន៍គាំទ្រឱ្យមានបរិយាកាសរៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់ សមាសភាពដោយរបៀបណា?

តើសហគមន៍ចូលរួមក្នុងការអភិវឌ្ឍបរិយាកាសរៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាពនៅតាមសាលារបស់អង្គការ BRAC ដោយរបៀបណា?

១. _____

២. _____

៣. _____

តើសហគមន៍របស់អ្នកបានជួយសាលារបស់អ្នកដោយរបៀបណា ដើម្បីរក្សាបរិយាកាសរៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព?

១. _____

២. _____

៣. _____

តើមានមធ្យោបាយអ្វីផ្សេងទៀតដែរឬទេ ដែលសហគមន៍របស់អ្នកបានជួយសាលារបស់អ្នកឱ្យរក្សាបរិយាកាសរៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព?

១. _____

២. _____

៣. _____

តើ **អ្នកណា** ក្នុងសហគមន៍របស់អ្នក អាចធ្វើជាអ្នកដឹកនាំ ដើម្បីបង្កើត និងរក្សាបរិយាកាសរៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាពឲ្យមាននិរន្តរភាព?

១. _____

២. _____

៣. _____

តើអ្នកអាចធ្វើអ្វីខ្លះ ដើម្បីលើកទឹកចិត្តសហគមន៍របស់អ្នកឱ្យជួយរក្សាបរិយាកាសរៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាពក្នុងសាលារបស់អ្នក?

១. _____

២. _____

៣. _____

តើយើងមានតួនាទី និងការទទួលខុសត្រូវអ្វីខ្លះ?

ជាគ្រូបង្រៀន តើយើងមានតួនាទី និងការទទួលខុសត្រូវអ្វីខ្លះដើម្បីធ្វើការជាមួយមាតាបិតា និងសមាជិកសហគមន៍ដើម្បីឱ្យពួកគាត់ជួយគាំទ្រឱ្យមានបរិយាកាសរៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព?

គ្រូបង្រៀនទាំងអស់ត្រូវមានការទទួលខុសត្រូវ ដូចខាងក្រោម :

១. ទាក់ទងជាប្រក្រតីនៅតាមផ្ទះ មានន័យថា ជាមួយមាតាបិតា ឬអាណាព្យាបាលអំពីការរីកចម្រើនក្នុងការរៀនសូត្រ និងការទទួលបានសមិទ្ធិផលរបស់កូនៗ។

២. ធ្វើការជាមួយអ្នកដឹកនាំសហគមន៍ ដើម្បីរកឱ្យឃើញថា កុមារណាខ្លះមិនបានចូលសាលា ហេតុអ្វីបានជាមិនបានចូលសាលា និងត្រូវរិះរកមធ្យោបាយផ្សេងៗ ដើម្បីនាំកុមារទាំងនោះចូលសាលា។

៣. ត្រូវពន្យល់មាតាបិតារបស់សិស្សក្នុងថ្នាក់ឱ្យយល់អំពីតម្លៃ និងគោលបំណងនៃបរិយាកាសរៀនមេត្រីដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព។

៤. ត្រូវរៀបចំណែនាំសិស្សឱ្យទាក់ទងជាមួយសហគមន៍ ដែលជាផ្នែកមួយនៃកម្មវិធីសិក្សា ដូចជារៀបចំធ្វើដំណើរទៅកន្លែងផ្សេងៗ ឬរៀបចំព្រឹត្តិការណ៍ និងសកម្មភាពពិសេសនានា។

៥. ត្រូវអញ្ជើញមាតាបិតា និងសមាជិកសហគមន៍ឱ្យចូលរួមក្នុងសកម្មភាពថ្នាក់រៀន។

គ្រូបង្រៀនខ្លះត្រូវទទួលខុសត្រូវជាងដៃទៀត :

៦. បំពេញការងារជាមួយគ្រូដទៃទៀត និងជាមួយនាយកសាលា ដើម្បីផ្តល់ព័ត៌មានអំពីបរិយាកាសរៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាពដល់មាតាបិតាសិស្ស អង្គការ សមាគម (គណៈកម្មការគ្រប់គ្រងសាលា គណៈកម្មការអប់រំភូមិ សមាគមគ្រូបង្រៀន និងមាតាបិតា)

៧. លើកទឹកចិត្ត និងធ្វើការជាមួយមាតាបិតាដែលជាអ្នកគាំទ្រឱ្យមានបរិយាកាសរៀនមេត្រីដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាពជាមួយមាតាបិតាដទៃទៀត និងក្នុងសហគមន៍។



សកម្មភាពអនុវត្ត : តើយើងអាចធ្វើការជាមួយសហគមន៍ដោយរបៀបណា?

យើងអាចចាប់ផ្តើមដោយការស្រង់សកម្មភាពសាលានីមួយ។ ដែលអ្នកស្គាល់ដែលមានការចូលរួមជាមួយគ្រួសារ និងសហគមន៍ ដូចជា ការធ្វើទស្សនកិច្ចនៅតាមកន្លែងនានា ការជួបប្រជុំរវាងគ្រូ និងមាតាបិតា ការដើរដង្ហែរជាក្បួន ហើយដែលអាចនាំឱ្យគ្រូបង្រៀន កុមារ គ្រួសារកុមារ និងសហគមន៍ជួបជុំគ្នាបាន[1]។ នៅជាប់សកម្មភាពនីមួយ។ ចូរសរសេរ:

- *តើអ្នកបានចូលរួមក្នុងសកម្មភាពនេះឬទេ? ប្រសិនបើបានចូលរួម តើបានធ្វើជាអ្វី? (ដូចជា "ធ្វើជាអ្នករៀបចំសកម្មភាព "ឬ"ជាអ្នកទទួលភ្ញៀវ")។*
- *លទ្ធផលវិជ្ជមានដែលបានទទួលពីសកម្មភាពនេះ។*
- *លទ្ធផលអវិជ្ជមាន ឬមិនរំពឹងទុក ដែលបានកើតមាន ហើយលទ្ធផលទាំងនេះអាចបញ្ឈៀសបានឬទេនៅពេលអនាគត? (ឧទាហរណ៍ មានមាតាបិតាតិចតួចបានចូលរួម ដែលបញ្ហានេះអាចជម្នះបានដោយការប្រកាសជាមុន)។ ព្រឹត្តិការណ៍មួយធ្វើជាច្រើនដងប្រសើរជាងធ្វើតែមួយដង។*

ចូរគូរបន្ទាត់នៅក្រោមសកម្មភាពទាំងអស់ដែលអ្នកគិតថា មានសារៈសំខាន់បំផុត។ ចូរគូររង្វង់សកម្មភាពទាំងអស់ដែលទាក់ទងផ្ទាល់ជាមួយថ្នាក់រៀន ឬទាក់ទងនឹងការបង្រៀនរបស់អ្នក។ តើសកម្មភាពណាខ្លះដែលអ្នកបានគូរបន្ទាត់ពីក្រោម ហើយសកម្មភាពណាខ្លះដែលបានគូររង្វង់? ចំពោះសកម្មភាព ដែលបានគូរបន្ទាត់ពីក្រោម ចូរគិតពិចារណាអំពីរបៀបណាមួយ ដែលអ្នកអាចបញ្ចូលសកម្មភាពទាំងនេះទៅក្នុងសកម្មភាពថ្នាក់រៀនរបស់អ្នក។

ចូរអ្នកសួរខ្លួនឯងថា តើសកម្មភាពណាខ្លះមានសារៈសំខាន់បំផុតក្នុងការធ្វើឱ្យថ្នាក់រៀនរបស់អ្នកមានបរិយាកាសរៀនមេត្រី? សកម្មភាពណាខ្លះជាព្រឹត្តិការណ៍ដ៏ល្អ ដើម្បីជំរុញគ្រួសារនានា និងសហគមន៍ឱ្យមានការយល់ដឹងប្រសើរឡើងថែមទៀត នូវបរិយាកាសរៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព?

ចូរសង្កេតយ៉ាងខ្លីអំពីទំនាក់ទំនងដែលមានការអភិវឌ្ឍរវាងអ្នក សាលារបស់អ្នក និងសហគមន៍ដោយសារលទ្ធផលនៃសកម្មភាពនីមួយៗ។ ឧទាហរណ៍ ដោយមានការរៀបចំការជួបប្រជុំរវាងគ្រូបង្រៀន និងមាតាបិតានៅដើមឆ្នាំសិក្សា ខ្ញុំបានអភិវឌ្ឍការយល់ដឹងកាន់តែប្រសើរឡើងអំពីគ្រួសារសិស្ស ហើយមាតាបិតាសិស្ស កាន់តែច្រើនថែមទៀតកំពុងតែស្ម័គ្រចិត្តជួយដល់សកម្មភាពថ្នាក់រៀន។

---

[1] This activity was adapted from The Multigrade Teacher's Handbook (1994) Bureau of Elementary Education, Department of Education, Culture and Sports in cooperation with UNICEF Philippines, and UNICEF at http://www.unicef.org/teachers/environment/families.htm

ជាទីបញ្ចប់ ចូរមើលម្តងទៀតអំពីទំនាក់ទំនង និងសកម្មភាពវិជ្ជមាន រវាងសាលារបស់អ្នក និងសហគមន៍ បន្ទាប់មកចូររកមធ្យោបាយផ្សេង។ ដើម្បីពង្រីកសកម្មភាព និងទំនាក់ទំនងទាំងនេះឲ្យធំទូលាយ។ ឧទាហរណ៍ រៀបចំទិវាបវេសនកាលនៅដើមឆ្នាំ និងចុងឆ្នាំនីមួយៗ ជាជាងរៀបចំឱ្យមានតែម្តងក្នុងមួយឆ្នាំ។ ទិវាបវេសនកាលនៅដើមឆ្នាំ អាចផ្តោតលើអ្វីមួយដែលកុមារនឹងត្រូវរៀន និងលើរបៀប ឬវិធីណាខ្លះដែលគ្រួសារទាំងឡាយអាចជួយបាន ចំណែកទិវាវិស្សមកាលនៅចុងឆ្នាំ អាចបង្ហាញអំពីលទ្ធផលការងាររបស់កុមារ និងសមិទ្ធិផលរបស់មនុស្សគ្រប់ៗរូប ដែលបានខិតខំធ្វើការរួមគ្នា និងបានបង្កើតបរិយាកាសរៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព។

គោលទី ២.២



ព័ត៌មាន និងការគាំទ្រមតិឱ្យមានបរិយាកាសរៀនមេត្រីដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព តាមគ្រួសារ និងក្នុងសហគមន៍

ដើម្បីអន្តរាគមន៍ក្នុងវិស័យអប់រំឲ្យមានឥទ្ធិពលពិតប្រាកដ សហគមន៍ត្រូវគាំទ្រអន្តរាគមន៍ទាំងអស់ឱ្យបានពេញលេញ និងចូលរួមយ៉ាងសកម្ម ក្នុងសកម្មភាពអន្តរាគមន៍ទាំងអស់។ ដើម្បីឱ្យសហគមន៍ចូលរួមយ៉ាងសកម្ម ត្រូវបង្កើតទំនាក់ទំនងជាមួយសហគមន៍ ផ្តល់ព័ត៌មាន និងបំផុសសហគមន៍ឱ្យធ្វើសកម្មភាព។

ការបង្កើតទំនាក់ទំនងជាមួយគ្រួសារ និងសហគមន៍

ការទទួលខុសត្រូវសំខាន់បំផុតមួយរបស់យើងជាគ្រូបង្រៀនគឺត្រូវបើកចំហបណ្តាញទំនាក់ទំនងចំពោះគ្រួសារ និងសមាជិកសហគមន៍ដទៃទៀត។ កុមាររៀនសូត្រកាន់តែប្រសើរឡើង ពេលដែលមាតាបិតា និងសមាជិកគ្រួសារដទៃទៀត មានការចាប់អារម្មណ៍ និងចូលរួមសកម្មភាពជាមួយសាលា និងការអប់រំ។ ពេលដែលយើងឱ្យគ្រួសារទាំងឡាយចូលរួមក្នុងសកម្មភាពសិក្សា យើងបង្កើនសក្តានុភាពសម្រាប់ការសិក្សាក្នុងថ្នាក់របស់យើង ហើយយើងបង្កើតការគាំទ្រសម្រាប់ការបង្រៀនរបស់យើង តាមវិធីសាស្ត្រជាច្រើន។ ហេតុដូច្នេះហើយ ការបង្កើតទំនាក់ទំនងជាមួយគ្រួសាររបស់កុមារ និងជាមួយសមាជិកសហគមន៍ មានសារៈសំខាន់យ៉ាងខ្លាំងដល់ការបង្កើតបរិយាកាសរៀនមេត្រី[2]។

មានមធ្យោបាយប្រកបដោយប្រសិទ្ធភាពជាច្រើន ដើម្បីចាប់ផ្តើមធ្វើទំនាក់ទំនងជាមួយគ្រួសារកុមាររបស់យើង។ ខាងក្រោមនេះ ជាបញ្ជីស្តីពីមធ្យោបាយមួយចំនួនសម្រាប់ទំនាក់ទំនង។ ចូរសាកល្បងប្រើវិធីសាស្ត្រណាមួយដែលអ្នកចូលចិត្តបំផុត និងងាយស្រួលក្នុងការអនុវត្ត ហើយបន្ទាប់មកចូរសាកល្បងប្រើវិធីសាស្ត្រដទៃទៀតដូចខាងក្រោម :

- រៀបចំការជួបប្រជុំជាមួយគ្រួសារ និងក្រុមសហគមន៍ ណែនាំឱ្យប្រជាជនស្គាល់អ្នក រៀបរាប់ពីវត្ថុបំណងនៃការបង្រៀន និងការរៀនសូត្ររបស់កុមារ រៀបរាប់អំពីភាពខុសគ្នាជាច្រើនក្នុងថ្នាក់ដែលមានបរិយាកាសរៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព ព្រមទាំងពិភាក្សាអំពីមធ្យោបាយផ្សេង។ ដែលគ្រួសារ និងសមាជិកសហគមន៍អាចចូលរួមក្នុងសកម្មភាពថ្នាក់រៀន។

- រៀបចំកម្មវិធីពិភាក្សាក្រៅផ្លូវការជាមួយមាតាបិតាសិស្សមួយដង ឬពីរដង ក្នុងមួយឆ្នាំដើម្បីវាយតម្លៃការសិក្សារបស់កុមារ។។ បង្ហាញមាតាបិតាសិស្សនូវគំរូលទ្ធផលការងារសិក្សារបស់កុមារ។

---

2 This section and activity were adapted fromThe Multigrade Teacher's Handbook (1994) Bureau of Elementary Education, Department of Education, Culture and Sports in cooperation with UNICEF Philippines, and UNICEF at http://www.unicef.org/teachers/environment/families.htm

និយាយបញ្ជាក់អំពីទេពកោសល្យ និងសមិទ្ធិផលវិជ្ជមានរបស់កុមារម្នាក់ៗ ព្រមទាំងនិយាយអំពីរបៀបដែលកុមារម្នាក់ៗរៀនសូត្រកាន់តែប្រសើរឡើង ប្រសិនបើកុមារអាចជម្នះឧបសគ្គបាន។

- បញ្ជូនលទ្ធផលរៀនសូត្ររបស់សិស្សទៅតាមលំនៅឋាន ដើម្បីបង្ហាញមាតាបិតាសិស្សឱ្យដឹងថាតើកូនរបស់ខ្លួនរៀនបានល្អកំរិតណា។ សុំយោបល់មាតាបិតាសិស្សអំពីការរៀនសូត្ររបស់កូនៗ ព្រមទាំងសួរមាតាបិតាសិស្សថា តើបន្ទាប់មកពួកគាត់គិតថាកូនៗរបស់គាត់គួររៀនអំពីអ្វីបន្តែម។

- លើកទឹកចិត្តកុមារឱ្យនិយាយអំពីអ្វីដែលពួកគេយល់ដឹងនៅផ្ទះ ហើយប្រើចំណេះដឹងនេះក្នុងមេរៀនដែលអ្នកបង្រៀន។ និយាយច្រាប់មាតាបិតាសិស្សផងដែរថា អ្វីៗដែលកុមារកំពុងរៀនក្នុងថ្នាក់គឺទាក់ទងនឹងជីវភាពរស់នៅរបស់កុមារនៅតាមផ្ទះ។ និយាយឱ្យដាយទៅគឺថា ត្រូវបង្ហាញថាតើកុមារអាចប្រើ ឬកំពុងប្រើចំណេះដឹងយកពីផ្ទះ មកចែករំលែកក្នុងថ្នាក់ដោយរបៀបណា។

- រៀបចំធ្វើទស្សនកិច្ចដល់ទីកន្លែងសហគមន៍ ឬស្នើសុំឱ្យកុមារសម្ភាសសួរមាតាបិតា ឬជីដូនជីតាអំពីកុមារភាពកាលពីគាត់នៅក្មេងដែលរស់នៅក្នុងសហគមន៍ ហើយបន្ទាប់មក ត្រូវឱ្យកុមារសរសេររឿងរ៉ាវ ឬតែងសេចក្តីទាំងឡាយអំពី "ជីវភាពរស់នៅក្នុងសហគមន៍នាអតីតកាល"។

- លើកទឹកចិត្តសមាជិកគ្រួសារឱ្យចូលរួមក្នុងសកម្មភាពថ្នាក់រៀន ហើយអញ្ជើញជំនាញការសហគមន៍ ដើម្បីមកចែករំលែកចំណេះដឹងជាមួយសិស្សក្នុងថ្នាក់រៀន។



សកម្មភាពអនុវត្ត : ការបង្កើតទំនាក់ទំនងជាមួយគ្រួសារ និងសហគមន៍

ចូរចាប់ផ្តើមដោយធ្វើការសង្ខេបនូវវិធី ឬរបៀបផ្សេងៗ ដែលនៅពេលថ្មីៗនេះ អ្នកបានទំនាក់ទំនងជាមួយគ្រួសារកុមារ និងសហគមន៍។ តើអ្នកបានធ្វើទំនាក់ទំនងលើកដំបូងជាមួយពួកគេដោយរបៀបណា ហើយតើមាតាបិតា និងសហសគមន៍ បានចូលរួមក្នុងសកម្មភាពរៀនសូត្ររបស់កុមារក្នុងកំរិតណា?

ចូរត្រឡប់មើលម្តងទៀតនូវវិធី ឬរបៀបផ្សេងៗគ្នា ដែលបានរៀបរាប់ខាងលើ ស្តីពីការបង្កើតទំនាក់ទំនងជាមួយគ្រួសារ និងសហគមន៍។ ជ្រើសរើសវិធីខុសៗគ្នាទាំងនេះចំនួនពីរ ឬបី (ឬច្រើនជាងនេះ) រួចកត់ត្រាវិធីដែលបានជ្រើសរើសទាំងនេះ ហើយបន្ទាប់មក នៅក្រោមវិធីនីមួយៗ ចូរធ្វើការកត់សម្គាល់ដូចតទៅនេះ :

- សម្ភារអ្វីខ្លះដែលអ្នកគួររៀបចំ (ប្រសិនបើមាន)។

- វិធី ឬរបៀបផ្សេងៗដែលអ្នកនឹងត្រូវប្រើ ដើម្បីទាក់ទងជាមួយគ្រួសារ និងសមាជិកសហគមន៍

- *កាលបរិច្ឆេទ និងពេលវេលានៃសកម្មភាព ព្រមទាំងកាលបរិច្ឆេទដែលមានការទាក់ទងជាទៃទៀត ដូចជា ឱកាសពិសេសផ្សេងៗ។*

បន្ទាប់មក ចូរសម្រេចថា តើវិធីខុសៗគ្នាទាំងនេះអាចភ្ជាប់គ្នាបានឬទេ។ ឧទាហរណ៍ អ្នកចង់ប្រជុំជាក្រុមមួយនៅដើមឆ្នាំ ឬក្នុងឆ្នាំសិក្សា។ នៅកិច្ចប្រជុំនេះ អ្នកអាចលើកទឹកចិត្ត ឬជ្រើសរើសសមាជិកគ្រួសារធ្វើជាជំនួយការថ្នាក់រៀន ហើយស្នើសុំជំនាញការ អ្នកស្ម័គ្រចិត្តរបស់សហគមន៍ឱ្យផ្តល់សុន្ទរកថាពិសេសៗដល់កុមារ។

ចូរសរសេរកាលបរិច្ឆេទចាប់ផ្តើម ព្រមទាំងពេលវេលា និងហេតុការណ៍ដែលទាក់ទងជាទៃទៀត នៅលើប្រតិទិន ឬសៀវភៅកាលបរិច្ឆេទរបស់អ្នក ដើម្បីឱ្យអ្នកអាចបង្កើត "ផែនការទំនាក់ទំនងជាមួយសហគមន៍និងគ្រួសារ" យ៉ាងសាមញ្ញមួយ។

រក្សាការច្រាស្រំយទាក់ទងគ្នាជាប្រចាំ

ការផ្តល់ព័ត៌មានដល់មាតាបិតាអំពីការរីកចម្រើនរបស់កូន

ក្នុងបរិយាកាសរៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព គ្រូបង្រៀនចាំបាច់ត្រូវធ្វើទំនាក់ទំនងជាមួយមាតាបិតាជាប្រចាំអំពីកូនៗដែលរៀនក្នុងថ្នាក់។ យើងអាចទៅជួបមាតាបិតាសិស្សនៅតាមផ្ទះ ផ្ញើលិខិតវាយតម្លៃការរីកចម្រើនរបស់កុមារទៅលំនៅឋានតាមរយៈ កុមារផ្ទាល់ ឬអញ្ជើញមាតាបិតាមកសាលាជួបយើង។ ហេតុដូចនេះហើយ ជាការសំខាន់ត្រូវបង្កើតបរិយាកាសស្វាគមន៍មួយនៅសាលាដើម្បីទទួលមាតាបិតា និងសមាជិកសហគមន៍ទាំងអស់។

ការជួបប្រជុំជាមួយមាតាបិតា ឬអាណាព្យាបាលនៅដើមឆ្នាំមានសារៈសំខាន់ណាស់ដើម្បីឱ្យគ្រូបង្រៀន និងមាតាបិតាអាចធ្វើការអភិវឌ្ឍ ទំនាក់ទំនង និងភាពជាដៃគូមួយសម្រាប់ការរៀនសូត្ររបស់កុមារ។ ទោះជាយ៉ាងណាក្តី ប្រសិនបើមាតាបិតាគិតថា ការសួរសុខទុក្ខរបស់យើង នៅតាមផ្ទះ ឬការអញ្ជើញមាតាបិតាទៅសាលា នឹងអាចកើតមានឡើងតែនៅពេលកុមារណាម្នាក់កំពុងទទួលពិន័យ អ្នកត្រូវបញ្ជាក់ឱ្យបានច្បាស់នៅគ្រាដំបូងនៃការទៅសួរសុខទុក្ខរបស់អ្នក ឬក្នុងការអញ្ជើញមាតាបិតាដោយនិយាយថា ការសន្ទនានេះមានលក្ខណៈខុសៗពីគ្នា។ ចូរច្រាប់ពួកគាត់ថា អ្នកចង់ដឹងព័ត៌មានទាក់ទងនឹងកុមារពីពួកគាត់ ដើម្បីអាចជួយអ្នកក្នុងការបង្រៀនកុមារ ឱ្យកាន់តែមានប្រសិទ្ធភាពថែមទៀត។ ចូរច្រាប់ពួកគាត់ផងដែរថា អ្នកចង់ជំរាបច្រាប់ពួកគាត់អំពីជំនាញប្រសព្វរបស់កូនពួកគាត់ ដើម្បីឱ្យពួកគាត់អាចជួយកុមារពេលនៅផ្ទះ និងជួយពង្រឹងបន្ថែមទៀតនូវអ្វីដែលកុមារកំពុងរៀននៅសាលា។

ការប្រាស្រ័យទាក់ទងរវាងគ្រូបង្រៀន និងលំនៅឋានរបស់សិស្ស

នៅសាលារៀនកុមារមេត្រីនៅប្រទេសថៃ មាតាបិតា និងសមាជិកសហគមន៍បានឆ្លើយសំណួរមួយនេះនៅលើទម្រង់វាយតម្លៃ "តើអ្វីទៅដែលមានសារៈសំខាន់បំផុតសម្រាប់សាលារៀនយើង ហើយហេតុអ្វី?" ចំណុចមួយដែលបានឆ្លើយថាជាចំណុចមានអាទិភាពខ្ពស់នោះគឺ ការប្រាស្រ័យទាក់ទងរវាងគ្រូបង្រៀន និងលំនៅឋានរបស់សិស្ស។ ពួកគេបាននិយាយថា "គ្រូបង្រៀន និងមាតាបិតារបស់សិស្សគ្រប់រូបត្រូវធ្វើការណាត់ជួបគ្នានៅរាល់វគ្គសិក្សានីមួយៗ ដើម្បីពិគ្រោះពិភាក្សាអំពីអាកប្បកិរិយា និងការរៀនសូត្ររបស់សិស្ស។ បញ្ហានេះមានសារៈសំខាន់ណាស់ ដោយហេតុថា វាអាចផ្តល់ការណែនាំសម្រាប់ដោះស្រាយបញ្ហាក្នុងចំណោមសមាជិកគណៈកម្មការសាលា សមាជិកសហគមន៍សំខាន់ៗ និងសាលារៀន។ វាក៏អាចបង្កើនការជូនព័ត៌មាន និងការប្រាស្រ័យទាក់ទងពីសាលារៀនទៅសហគមន៍ ហើយវាអាចបង្កើតនូវស្មារតីយោគយល់គ្នារវាងមាតាបិតាសិស្ស និងគ្រូបង្រៀន"។

- Hopkins J and Chaimuangdee K. (2000) School Self-Assessment: Participatory Learning and Action for Child-Friendly Schools. Chiang Mai, Thailand: The Life Skills Development Foundation, in collaboration with the UNICEF Office for Thailand, Bangkok.

ការផ្តល់ព័ត៌មានជាប្រចាំដល់មាតាបិតាសិស្សអំពីការរីកចម្រើនក្នុងការសិក្សារបស់កូនៗពួកគាត់មានសារៈសំខាន់ណាស់។ នេះមានន័យថា ការប្រើវិធីសាស្ត្រវាយតម្លៃដែលអាចជួយគ្រូបង្រៀន សិស្ស ព្រមទាំងជួយមាតាបិតាឱ្យដឹងថា តើជំនាញណាខ្លះដែលកុមារណាម្នាក់មានការរីកចម្រើនផ្នែកអក្សរ គិតលេខ បំណិនជីវិត និងមុខវិជ្ជាផ្សេងៗទៀត។ មាតាបិតាត្រូវការដឹងនូវអ្វីដែលកូនគាត់រៀនបានពូកែ និងអ្វីដែលកូនត្រូវការរៀនបន្តែមទៀត។ មធ្យោបាយមួយក្នុងចំណោមមធ្យោបាយជាច្រើន ដែលត្រូវប្រើដើម្បីដោះស្រាយបញ្ហានេះគឺតារាងពណ៌ ដែលមានប្រសិទ្ធភាពជាពិសេសចំពោះមាតាបិតា ដែលមិនចេះអក្សរ។ ឧទាហរណ៍ក្នុងតារាងទី១ ពណ៌មួយទាក់ទងនឹងជំនាញដែលត្រូវការសម្រាប់រៀនគណិតវិទ្យាថ្នាក់ទី៣។

តារាងទី ១. តារាងពណ៌ស្តីពីខ្លឹមសារ និងកិច្ចការគណិតវិទ្យាថ្នាក់ទី៣

កំរិត	*(៨ លើ ១០ ត្រឹមត្រូវ ត្រូវបន្តទៅកំរិតបន្ទាប់)*
ក្រហម	• *តម្លៃរូបិយវត្ថុ (រហូតដល់ ១០០)* • *ការសរសេរលេខ* • *ការដកលេខ (លេខមួយខ្ទង់) ការបូកលេខ (ចំនួនលេខមួយខ្ទង់ និងពីរខ្ទង់)*
ទឹកក្រូច	• *លេខគូ (បូក និងដក)* • *ការចែក (ចំនួនលេខមួយខ្ទង់)* • *ការអានបញ្ហាគណិតវិទ្យា*
លឿង	• *ការគុណលេខ* • *ការដក និងបូកចំនួនលេខពីរខ្ទង់* • *ការវាស់វែង (ចំងាយ និងមាឌ)*
បៃតង	• *ការកំណត់លេខរហូតដល់ ៣០០* • *ការដក និងបូកដោយរៀបដាក់ជាក្រមឡើងវិញ* • *ការដកចំនួនលេខពីរខ្ទង់ និងបីខ្ទង់* • *ការកំណត់ចំនួនលេខបីខ្ទង់*
ខៀវ	• *ការគុណលេខ (ចំនួនលេខមួយខ្ទង់ និងពីរខ្ទង់)* • *ការចែក (ចំនួនលេខមួយខ្ទង់ និងពីរខ្ទង់)* • *ការអានបញ្ហាពាក្យ*
ស្វាយ	• *ការគុណលេខ (ចំនួនលេខពីរខ្ទង់ និងបីខ្ទង់)* • *ការវាស់វែង (ចំងាយ និងវត្ថុរាវ)* • *ការអានបញ្ហាពាក្យ*

Adapted from duPlessis J. (2003) Rainbow Charts and C-O-C-O-N-U-T-S: Teacher Development for Continuous Assessment in Malawi Classrooms. Washington, DC: American Institutes for Research.

ដោយប្រើតារាងទី១ បន្ទាប់មកត្រូវបង្កើត "តារាងពណ៌ឥន្ទធនូ" ដើម្បីបង្ហាញពីការវិភាគចម្រើនរបស់កុមារ និងជានាឱ្យគ្រូបង្រៀន សិស្ស និងមាតាបិតាអាចត្រួតពិនិត្យរួមគ្នាពីការរៀនសូត្ររបស់កុមារ។ ក្នុងតារាងពណ៌ឥន្ទធនូ (តារាង ទី២) កុមារម្នាក់ៗមានរូបសញ្ញា "មុខវិភាយ" ដោយមានដាក់ឈ្មោះរបស់ខ្លួនលើរូបសញ្ញានោះ។ នៅពេលដែលពួកគេកែលំអជំនាញគណិតវិទ្យារបស់ពួកគេ ដូចបានចង្អុលបង្ហាញក្នុងតារាងពណ៌ រូបសញ្ញារបស់ពួកគេត្រូវផ្លាស់ទៅរកពណ៌ដែលត្រូវគ្នាជាមួយកំរិតជំនាញរបស់ខ្លួន។ ប្រសិនបើគ្រូសង្កេតឃើញថា កុមារមួយចំនួនស្ថិតក្នុងកំរិតណាមួយយូរពេក គ្រូអាចរកវិធីផ្សេង។ ដើម្បីជួយកុមារឱ្យយល់ដឹងអំពីអ្វីដែលចាំបាច់ ដើម្បីឆ្ពោះទៅរកកំរិតបន្ទាប់។

តារាងទី២ : តារាងពណ៌ឥន្ទធនូ ស្តីពីការរីកចម្រើនរបស់សិស្ស



ទោះជាគ្រូបង្រៀនប្រើតារាងពណ៌ឥន្ទធនូ ឬបញ្ជីស្តីពីជំនាញ ឬ បំណុស្តីពីរបាយការណ៍ការរីកចម្រើនរបស់សិស្សដើម្បីផ្ញើទៅតាមលំនៅឋាន ការជូនព័ត៌មានដល់មាតាបិតាអំពីការរីកចម្រើនរបស់កុមារមានសារៈសំខាន់ យ៉ាងខ្លាំងក្នុងការបង្កើតការទាក់ទងរវាងសាលា និងមាតាបិតាសិស្ស។

ការផ្តល់ព័ត៌មានដល់មាតាបិតាអំពីបរិយាកាសរៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព

ក្នុងការនិយាយជាមួយមាតាបិតា ឬអាណាព្យាលរបស់កុមារ ជាការសំខាន់អ្នកត្រូវពន្យល់ថា សាលា និងថ្នាក់រៀនរបស់អ្នកក្លាយទៅជាសាលា និងថ្នាក់ដែលមានបរិយាកាសរៀនមេត្រីដោយរបៀបណា។ អ្នកអាចត្រូវការកូនសៀវភៅឃោសនាព័ត៌មានរបស់សាលា ឬលិខិតស្នាមដែលចុះហត្ថលេខាដោយនាយកសាលាដើម្បីជួយពន្យល់អំពីអ្វីដែលអ្នកកំពុងតែព្យាយាមធ្វើ។ អ្នកត្រូវពន្យល់ផងដែរថា "តាមរយៈការរៀនមេត្រី" យើងចង់និយាយថា មនុស្សគ្រប់រូប (គ្រូបង្រៀន មាតាបិតា និងសមាជិកសហគមន៍) នឹងអាចជួយឱ្យកុមារទំរៀនសូត្រ ហើយនឹងរៀនជាមួយកុមារផងដែរ។ អ្នកអាចបង្ហាញពួកគេនូវលទ្ធផលការសិក្សាមួយចំនួនរបស់កូនៗពួកគេ ហើយចូររៀបរាប់អ្វីដែលកុមារធ្វើក្នុងបរិយាកាសរៀនសូត្រដ៏រស់រវើក និងផ្តោតលើកុមារដែលខុសគ្នាពីសាលាដែលពួកគាត់ បងប្អូនគាត់ ឬកូនច្បងគាត់ចូលរៀន។ អ្នកត្រូវពន្យល់ដោយប្រយ័ត្ននូវអ្វីដែលអ្នកចង់និយាយចំពោះឃ្លា "ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព" ព្រោះយើងបានរៀនរួចហើយក្នុងកម្រងសៀវភៅលេខ១ ក្នុងគោលនេះ ហើយប្រើករណីសិក្សាមួយចំនួនជាឧទាហរណ៍ ដើម្បីបង្ហាញថា បរិយាកាសរៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាពអាចផ្តល់ផលប្រយោជន៍យ៉ាងណាខ្លះដល់កុមារ **ទាំងអស់**។



សកម្មភាពអនុវត្ត : លេងល្បែងតាមការចូលចិត្ត

ពេលជួបមាតាបិតាសិស្ស អ្នកអាចពន្យល់ឱ្យយល់អត្ថន័យនៃឃ្លា "ដាក់បញ្ចូលគ្នានូវអ្វីដែលគេបោះបង់ចោល ឬ មិនគិតគូរ" ឬ"ដាក់បញ្ចូលគ្នាគ្រប់សមាសភាព"។ សកម្មភាពដ៏ថ្លៃថ្លាមួយសម្រាប់អនុវត្តខ្លឹមសារនេះ គឺ "លេងជាមួយមនុស្សដែលយើងចូលចិត្ត"។

ក្នុងសកម្មភាពនេះ ចូររៀបចំគ្រឿងពាក់ជាសញ្ញាដែលមានពីរពណ៌ខុសគ្នា (ដូចជា ពណ៌ក្រហម និងពណ៌ខៀវ) សម្រាប់មនុស្សពាក់ភ្ជាប់នឹងខោអាវពួកគេ ដោយប្រើបង់ស្អិត ឬម្ជុលខ្លាស់។ មនុស្សម្នាក់ៗគួរមានគ្រឿងពាក់ជាសញ្ញាមួយ ដោយត្រូវផ្តល់ពណ៌ក្រហមខ្លះទៅនារី ហើយខ្លះទៀតទៅបុរស។ ចូរពន្យល់ថា ក្នុងសកម្មភាពនេះ អ្នកខ្លះនឹងត្រូវបានគេផ្តល់សិទ្ធិពេញលេញ ហើយអ្នកខ្លះទៀតនឹងត្រូវបានគេច្រានចោល។

ចូរច្រាប់មនុស្សដែលមានគ្រឿងពាក់ពណ៌ក្រហមឱ្យអង្គុយនៅផ្នែកខាងក្រោយនៃបន្ទប់ ឬមួយចំហៀងនៃបន្ទប់។ បន្ទាប់មក ចូរបន្តការសន្ទនាជីវភាពមួយជាមួយមនុស្ស ដែលមានគ្រឿងពាក់ពណ៌ខៀវ។ ចូរកុំយកចិត្តទុកដាក់ក្រុមមនុស្ស ដែលមានគ្រឿងពាក់ពណ៌ក្រហម។ ចូរក្រឡេកមើលក្រុមពាក់គ្រឿងសញ្ញាពណ៌ក្រហមម្តងម្កាល ហើយច្រាប់ពួកគេអង្គុយឱ្យស្ងៀមស្ងាត់ ឬឱ្យឈប់រញ៉េរញ៉ៃ ឬញញឹម។ ចូរបន្តនិយាយជាមួយក្រុមដែលពាក់គ្រឿងសញ្ញាពណ៌ខៀវ។ បន្តសកម្មភាពដូចនេះរយៈពេល ៥ ទៅ ១០ នាទី។ អ្នកក៏អាចសុំមនុស្សណាម្នាក់ដែលពាក់គ្រឿងសញ្ញាពណ៌ខៀវឱ្យច្រាប់ក្រុមដែលពាក់គ្រឿងសញ្ញាពណ៌ក្រហមឱ្យស្ងៀមស្ងាត់។ ក្រោយពីចប់រយៈពេល ១០ នាទី ចូរច្រាប់អ្នករាល់គ្នាឱ្យដោះគ្រឿងសញ្ញាចេញ ហើយអង្គុយជុំគ្នាឡើងវិញ។ សួរសំណួរទាំងនេះ :

- តើអ្នកដែលពាក់គ្រឿងសញ្ញាពណ៌ខៀវមានអារម្មណ៍ដូចម្តេច? តើអ្នកដែលពាក់គ្រឿងសញ្ញាពណ៌ក្រហមមានអារម្មណ៍ដូចម្តេច? ប្រសិនបើអ្នកកំពុងពាក់គ្រឿងសញ្ញាពណ៌ក្រហម តើអ្នកចង់ពាក់ពណ៌ខៀវឬទេ? តើអ្នកអាចធ្វើអ្វីខ្លះដើម្បីទទួលបានគ្រឿងសញ្ញាពណ៌ខៀវ? តើមានន័យដូចម្តេចចំពោះការដែលគេច្រានចោល? តើអ្នកណាជាមនុស្សដែលគេបានច្រានចោល? តើអ្នកណាគឺជាឬអាចជាមនុស្សដែលងាយនឹងទទួលរងការឈឺចាប់បំផុត?

ចូរចងចាំថា បុគ្គលទាំងឡាយដែលត្រូវបានគេច្រានចោលមិនយកចិត្តទុកដាក់ (ដូចជា ជនពិការរូបកាយ) អាចមានអារម្មណ៍កាន់តែអៀនខ្មាស អាម៉ាស់មុខ ឬទទួលរងទុក្ខទោសថែមទៀត ដោយការមានកូនពិការម្នាក់។ ពួកគេកំពុងតែត្រូវបានគេច្រានចោលមិនអើពើទ្វេដង។ លើសពីនេះទៀត អ្នកដែលងាយទទួលរងការឈឺចាប់បំផុត គឺជាកុមារពិការ ក្រីក្រ កូនជនជាតិភាគតិច ហើយមិនចេះនិយាយភាសារបស់ប្រទេសដែលខ្លួនរស់នៅ ហើយជាពិសេសជាកុមារី។ កុមារទាំងនេះអាចត្រូវបានច្រានចោល ដោយមានហេតុផលជាច្រើនទៅពេលដំណាលគ្នា (ឧទាហរណ៍ កុមារីជនជាតិភាគតិច ពិការ ក្រខ្សត់ ហើយ មិនយល់នូវអ្វីដែលគេកំពុងនិយាយក្នុងថ្នាក់រៀន)។ ទោះជាយ៉ាងណាក៏ដោយ កុមារទាំងនេះជាប្រភេទកុមារដែលយើងត្រូវស្វែងរក ដើម្បីរាប់បញ្ចូលពួកគេទៅក្នុងបរិយាកាសរៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព។

ឥឡូវនេះ ចូរអនុវត្តមេរៀនខាងលើ ដោយធ្វើការពន្យល់ឱ្យបានច្បាស់នូវអ្វី ដែលយើងចង់និយាយ ចំពោះឃ្លា "ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព" និងឃ្លា "បរិយាកាសរៀនមេត្រី"។ ចូរពិភាក្សាអំពីផលប្រយោជន៍នៃឃ្លា "រៀនមេត្រី ដោយបញ្ចូលគ្រប់សមាសភាព" និងពិភាក្សាថាតើ "បរិយាកាសរៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព" អាចបង្កើតឡើងតាមរយៈភាពជាដៃគូរវាងគ្រូបង្រៀន និង-មាតាបិតាសិស្សដោយរបៀបណា។

គំនិត : គេអាចប្រើសកម្មភាពនេះដដែរ ដើម្បីជួយកុមារឱ្យយល់ដឹងនូវអ្វីដែលមានន័យថា "ដែលត្រូវគេច្រានចោលមិនអើពើ" ហើយយល់ថា ហេតុអ្វីបានជាចាំបាច់ត្រូវឱ្យតម្លៃលើប្រវត្តិ និងសមត្ថភាពផ្សេងៗគ្នារបស់កុមារ។

ការផ្តល់ព័ត៌មានដល់សហគមន៍អំពីបរិយាកាសរៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព

ក្រៅពីការជជែកពិភាក្សាជាមួយមាតាបិតា គ្រូបង្រៀនខ្លះអាចធ្វើការជាមួយនាយកសាលា និងក្រុមការងារបរិយាកាសរៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាពរបស់សាលា ឬគណៈកម្មការសម្របសម្រួល ដើម្បីពន្យល់អំពីការវិវត្តចម្រើននៃបរិយាកាសរៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព ដល់ក្រុមធំៗជាច្រើន រាប់បញ្ចូលទាំងសមាជិកសហគមន៍។ ប្រសិនបើអ្នកជាមនុស្សម្នាក់ក្នុងចំណោមមនុស្សទាំងនេះ អ្នកអាចពន្យល់អំពីបរិយាកាសរៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព ដោយអនុវត្តតាមមធ្យោបាយមួយចំនួន ដូចខាងក្រោម :

១. ចោះពុម្ពព័ត៌មាន : ចូររៀបចំសៀវភៅយោសនាអំពីសាលារៀន ឬ លិខិតជូនដំណឹង ដើម្បីចែកចាយ។ ចូរអញ្ជើញអ្នកកាសែតក្នុងស្រុកឱ្យមកទស្សនាសាលារៀន និងលើកទឹកចិត្តសារព័ត៌មានក្នុងស្រុកឱ្យសរសេរអំពីបរិយាកាសរៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព។ ចូរបង្ហាញអ្នកកាសែតទាំងនោះអំពីផលប្រយោជន៍នៃសាលារៀន ដែលមានបរិយាកាសរៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព ហើយពន្យល់អំពីផែនការរបស់សាលាដែលមានបំណងផ្តល់ការអប់រំប្រកបដោយគុណភាពសម្រាប់កុមារទាំងអស់។

២. សេចក្តីប្រកាសជាសាធារណៈតាមវិទ្យុ និងទូរទស្សន៍ : នៅតាមសាលារៀន ប្រើវិទ្យុ និងទូរទស្សន៍ដើម្បីបង្ហាញ និងច្រាប់មាតាបិតាអំពីតម្រូវការសម្រាប់ការរៀនសូត្ររបស់កុមារ។

៣. ការជួបប្រជុំក្រុម ឬសហគមន៍ : ចូររៀបចំផែនការ ដើម្បីធ្វើសិក្ខាសាលា ឬវគ្គបណ្តុះបណ្តាលដែលមានរយៈពេលពីមួយថ្ងៃទៅបីថ្ងៃ។ សិក្ខាសាលា ឬវគ្គបណ្តុះបណ្តាលនេះអាចជួយណែនាំមនុស្សថ្មី។ ទាំងឡាយឱ្យស្គាល់ពីសាលារៀន ជាពិសេសសម្រាប់គ្រួសារ ដែលមានកូនមិនទាន់ចូលរៀន។ សិក្ខាសាលា ឬវគ្គបណ្តុះបណ្តាលនេះអាចជួយពន្យល់អំពីបេសកកម្មរបស់សាលារៀនក្នុងការអប់រំដល់កុមារទាំងអស់ ហើយអាចពន្យល់អំពីបរិយាកាសរៀនសូត្រ ដែលមានការចូលរួមយ៉ាងសកម្មរបស់សាលា។ ជាការសំខាន់ដដែរ ដោយបានស្តាប់ និងឆ្លើយសំណួរ និង

បញ្ហាកង្វល់របស់មាតាបិតាក្នុងអំឡុងពេលជួបប្រជុំគ្នានៅលើកដំបូង និងនៅពេលក្រោយបន្ត បន្ទាប់ ព្រមទាំងបានទទួលនូវគំនិតពីពួកគាត់ស្តីពីបញ្ហាថាតើគុណភាពនៃការអប់រំនៅសាលារបស់អ្នកអាចកែរលំអប្រសើរថែមទៀត ដោយរបៀបណា។

៤. ចលនាឱ្យសេវាសង្គមចូលរួម : ដោយហេតុថាសេវាសង្គមអាចចូលរួមក្នុងសាលារបស់អ្នកក្នុងខណៈដែលសាលានេះមានការចូលរួមគ្រប់សមាសភាពកាន់តែច្រើនឡើង ចូរបន្តការទាក់ទងជាមួយសេវាសង្គមទាំងនេះជាផ្នែកមួយនៃយុទ្ធសាស្ត្រដ៏សំខាន់របស់អ្នក។ សេវាសង្គមទាំងនេះអាចផ្តល់ធនធានសំខាន់ៗ និងជួយការពារសិទ្ធិកុមារ។

៥. ការភ្ជាប់ (បណ្តាញ) ជាមួយសាលារៀនដទៃទៀត : នៅប្រទេសខ្លះ សាលារៀនចំនួនបីជាអប្បបរមាត្រូវធ្វើការរួមគ្នា ដើម្បីគាំទ្រគ្នាទៅវិញទៅមក ក្នុងការដាក់បញ្ចូលគ្នាគ្រប់សមាសភាពឱ្យបានច្រើនថែមទៀត។ គ្រូបង្រៀនចែករំលែកគំនិតស្តីពីវិធីសាស្ត្រនានា ដែលគេកំពុងប្រើ ឬ មធ្យោបាយផ្សេង។ ដែលគេកំពុងចលនាសមាជិកសហគមន៍ឱ្យចូលរួមក្នុងសកម្មភាពថ្នាក់រៀន។ គេរៀបចំធ្វើសិក្ខាសាលានៅសាលារៀន ដើម្បីបង្កើនចំណេះដឹងថ្មីៗថែមទៀត ដល់គ្រូបង្រៀន។ គេរៀបចំបង្កើតព្រឹត្តិការណ៍សហគមន៍រួមគ្នា ដើម្បីទាំកុមារទាំងអស់ឱ្យចូលរៀននៅសាលា ឬ ធ្វើដំណើរទៅកន្លែងផ្សេងៗរួមគ្នា ដើម្បីឱ្យកុមារអាចរៀនសូត្រពីសហគមន៍ផ្សេង។

ជំរុញការគាំទ្រមតិឱ្យមានបរិយាកាសរៀនមេត្រី ដោយបញ្ចូលគ្រប់សមាសភាព

មាតាបិតាជាអ្នកតស៊ូមតិ

មាតាបិតាជាអ្នកតស៊ូមតិឱ្យមានការផ្លាស់ប្តូរ : ក្នុងសហគមន៍ខ្លះ មាតាបិតាផ្ទាល់គឺជាអ្នកតស៊ូមតិឱ្យបង្កើតបរិយាកាសរៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាពនៅតាមសាលាមុនគ្រូបង្រៀន និង នាយកសាលាទៅទៀត។ ឧទាហរណ៍ នៅខេត្តភាគខាងជើងនៃប្រទេសប៉ាពួញូហ្គីនី មាតាបិតាទាមទារឱ្យកូនរៀនភាសាជាតិនៅសាលា។ សាលាខេត្តបានធ្វើការជាមួយ សាកលវិទ្យាល័យ និងអង្គការក្រៅរដ្ឋាភិបាលដើម្បីផ្តល់ការអប់រំដែលមានការចំណាយតិចក្នុងការរៀនភាសាជាតិសម្រាប់កុមារ។ នៅតាមសាលារបស់អង្គការ BRAC នៃប្រទេសបង់ក្លាដេស មាតាបានស្នើសុំឱ្យមានការអប់រំមូលដ្ឋានសម្រាប់កូនស្រី-ប្រុសដែលត្រូវបានច្រានចេញពីសាលារៀន ដោយសារតែការចំណាយខ្ពស់ និងចំងាយផ្លូវឆ្ងាយ។

មាតាបិតាជាអ្នកប្រឆាំងនឹងការផ្លាស់ប្តូរ : ក្នុងសហគមន៍ដទៃទៀត មាតាបិតាប្រឆាំងជំទាស់នឹងការផ្លាស់ប្តូរ។ មាតាបិតាខ្លះ ដែលបានឆ្លុះបញ្ចាំងឱ្យឃើញតម្លៃសង្គម អាចមិនចង់ឱ្យកុមារ ដែលមានលក្ខណៈខុសពីកូនរបស់ខ្លួន ចូលរៀនសាលា ជាមួយកូនរបស់ខ្លួន។ ជាពិសេសមនុស្សទាំងនេះគួរតែជាគោលដៅសម្រាប់សកម្មភាពតស៊ូមតិដែលនឹងត្រូវពិភាក្សាខាងក្រោម។

មាតាបិតាជាអ្នកចូលរួមដែលមានឆន្ទៈក្នុងការផ្លាស់ប្តូរ : ក្នុងសហគមន៍ខ្លះទៀត មាតាបិតាអាចមានឆន្ទៈចូលរួមជាមួយសាលា ប្រសិនបើអ្នកស្នើសុំពួកគាត់ ហើយប្រសិនបើអ្នកពន្យល់ពួកគាត់ឱ្យយល់

អំពីបរិយាកាសរៀនមេត្រីដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព។ ប្រសិនបើមាតាបិតាមិនដែលបានចូលរួម ជាទម្លាប់កន្លងមកក្នុងការអប់រំកូន ពួកគាត់ពិតជាត្រូវការការអញ្ជើញ ស្វាគមន៍យ៉ាងកក់ក្តៅ និងត្រូវការការអញ្ជើញសារជាថ្មីម្តងទៀតដើម្បីឱ្យចូលរួម។

យុទ្ធសាស្ត្រតស៊ូមតិ

ការតស៊ូមតិមានន័យពាក់ព័ន្ធនឹងការអប់រំ ការផ្សព្វផ្សាយ ការទទួលបាននូវការគាំទ្រ និងការធ្វើឱ្យអ្នកដទៃយកចំណេះដែលគេចេះទៅប្រាប់ និងផ្សព្វផ្សាយដល់អ្នកផ្សេងទៀត។ តើមាតាបិតា និងសមាជិកសហគមន៍អាចក្លាយទៅជាអ្នកតស៊ូមតិ ដើម្បីធានាឱ្យមានបរិយាកាសរៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាពក្នុងសាលាដោយរបៀបណា?

១. លើកទឹកចិត្តមាតាបិតាឱ្យនិយាយប្រាប់អ្នកដទៃទៀតអំពីសាលាដែលមានបរិយាកាសរៀនមេត្រីដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាពរបស់អ្នក : អ្នកតស៊ូមតិជាមាតាបិតាអាចប្រើព័ត៌មានដូចគ្នានឹងព័ត៌មានដែលអ្នកបានបង្រៀនពួកគាត់អំពីបរិយាកាសរៀនមេត្រីដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព ដូចជាសៀវភៅឃោសនា លិខិតជូនដំណឹង ឬកិច្ចការសិស្ស។ មាតាបិតាជាអ្នកតស៊ូមតិនេះ អាចនិយាយមានប្រសិទ្ធភាព ជាពិសេសក្នុងការនិយាយជាមួយមាតាបិតាដែលជំទាស់នឹងការផ្លាស់ប្តូរ ហើយពន្យល់អំពីតម្លៃនៃពហុភាព និងនានាភាពក្នុងសាលារៀន និងថ្នាក់រៀន តាមរយៈបទពិសោធផ្ទាល់របស់ពួកគាត់ ឬបទពិសោធរបស់អ្នកដទៃ និងក្នុងការធ្វើឱ្យមាតាបិតាដែលជំទាស់នឹងការផ្លាស់ប្តូរយល់ច្បាស់ថា ការអប់រំដែលមានគុណភាពត្រូវនាំមុខគេ ក្នុងសាលាដែលមានបរិយាកាសរៀនមេត្រីដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព។

២. ចលនាឱ្យមាតាបិតាចូលរួមក្នុងសកម្មភាពថ្នាក់រៀន ដើម្បីជួយកុមារដែលជាទម្លាប់គេច្រានចោល : ពេលដែលមាតាបិតាមើលឃើញថា ពួកគាត់មានការស្វាគមន៍ក្នុងសាលា រៀននិងថ្នាក់រៀន ពួកគាត់អាចស្ម័គ្រចិត្តមកចូលរួមសកម្មភាពសាលាញឹកញាប់ និងមកជួយអ្នក។ ប្រសិនបើពួកគាត់មិនមកសាលាទេ រៀបចំគំរោងការងារសម្រាប់មាតាបិតា ហើយអញ្ជើញពួកគាត់ឱ្យមកជួយអ្នក។ ឧទាហរណ៍ មាតាបិតា ឬសមាជិកសហគមន៍អាចធ្វើជាអ្នកស្ម័គ្រចិត្តក្នុងការបង្រៀនភាសា ឬសម្រាប់ជួយកុមារពិការ។ ពួកគាត់អាចអានឱ្យកុមារស្តាប់ និងស្តាប់កុមារអាន។ ពួកគាត់អាចសង្កេតឃ្លាំមើលសកម្មភាពក្រុមផងដែរ ហើយឱ្យគ្រូបង្រៀនធ្វើការដោយសេរីជាមួយកុមារ ឬក្រុមតូចៗដែលត្រូវយកចិត្តទុកដាក់បន្ថែម។ យើងនឹងរកមធ្យោបាយផ្សេងៗទៀតដើម្បីចលនាឱ្យមាតាបិតា និងសហគមន៍ចូលរួមក្នុងឯកសារគោលបន្ទាប់។

៣. ចលនាឱ្យមាតាបិតាចូលរួមក្នុងសកម្មភាពស្វែងរកកុមារ សម្រាប់កុមារមិនទាន់ចូលសាលាដែលត្រូវគេច្រានចោលជាទម្លាប់ : ឧទាហរណ៍ រៀបចំពិធីតាំងសមិទ្ធិផលដើម្បីចុះឈ្មោះចូលរៀននៅសាលា មុនចាប់ផ្តើមឆ្នាំសិក្សា ដើម្បីទាក់ទាញគ្រួសារទាំងអស់ ពីសហគមន៍ឱ្យចូលរួម បន្ទាប់មក ចុះឈ្មោះកុមារទាំងអស់ឱ្យចូលរៀន។ អ្នកជំនួញ និងក្រុមហ៊ុនពាណិជ្ជកម្មក្នុងស្រុក អាចចូលរួមវិភាគទានទូវអំណោយតូចតាច ដែលនឹងត្រូវផ្តល់ឱ្យជាសន្លឹកឆ្នោត ហើយ

មាតាបិតា និងគ្រូបង្រៀនអាចផ្តល់អំណោយជាអាហារពិសេស និងរៀបចំបង្កើតល្បែងកំសាន្ត ផ្សេង។ ហើយការច្រៀង-រាំ ក៏អាចរាប់បញ្ចូលផងដែរ។ សកម្មភាពទាំងអស់ត្រូវផ្តោតលើសារៈសំខាន់នៃការអប់រំប្រកបដោយគុណភាព និងមធ្យោបាយនានាដែលសាលារៀន និងសហគមន៍អាចធ្វើការរួមគ្នាដើម្បីអប់រំកុមារទាំងអស់។ ពីធីចុះឈ្មោះនៅសាលាមួយនៅប្រទេសហ្គាតាម៉ាឡា ដែលមានតូកកំប្លែង អាហារពិសេស និងល្បែងកំសាន្ត បានចុះឈ្មោះកុមារជាច្រើនដែលធ្វើឱ្យសាលាមិនអាចទទួលកុមារថ្មីៗទាំងអស់បាន ហើយបានចាប់ផ្តើមរៀបចំដែនការសាងសង់អគារសាលាថ្មីមួយខ្នងទៀត។ យើងអាចឃើញគំនិតដទៃៗទៀតជាច្រើនក្នុងការចលនាឱ្យមាតាបិតា និងសហគមន៍ចូលរួមក្នុងសកម្មភាព ស្វែងរកកុមារក្នុងកម្រងសៀវភៅនេះ ដើម្បីនាំកុមារចូលរៀននៅសាលា។

៤. ការភ្ជាប់សហគមន៍គ្រប់គ្រងសាលាជាមួយបរិយាកាសរៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព : សមាគមគ្រូបង្រៀន និងមាតាបិតាសិស្ស ឬ គណៈកម្មការគ្រប់គ្រងសាលាជាមធ្យោបាយក្នុងការចលនាមាតាបិតាឱ្យចូលរួមក្នុងទំនាក់ទំនងដ៏យូរអង្វែងមួយជាមួយសាលារៀន។ សមាគម និងគណៈកម្មការនេះជួយផ្តល់នូវការសង្កេតឃ្លាំមើលនៅតាមកន្លែង ព្រមទាំងផ្តល់នូវគុណភាព និងការទទួលខុសត្រូវកាន់តែប្រសើរឡើង។

គណៈកម្មការអប់រំភូមិ

កម្មវិធីតស៊ូមតិសហគមន៍ក្នុងរដ្ឋមួយរបស់ប៉ាគីស្ថានឈ្មោះ Balochistan បានគាំទ្រឱ្យបង្កើតគណៈកម្មការអប់រំភូមិរបស់ស្ត្រី។ នៅពេលបច្ចុប្បន្ននេះ ក្រុមទាំងនេះមានសមាជិកជាង ១000 នាក់។ ក្រុមនីមួយៗមានសមាជិក ៥នាក់ ដោយយកគំរូតាមគណៈកម្មការអប់រំរបស់បុរស។ មានការលំបាកជាច្រើនដើម្បីធ្វើសមាហរណកម្មភេទឱ្យទៅជាគណៈកម្មការតែមួយក្នុងវិស័យជាច្រើនដែលមានការអភិរក្ស។ ទោះជាយ៉ាងណាក្តី ស្ត្រីត្រូវបានបង្ហាញថា មានលក្ខណៈល្អប្រសើរជាងបុរសក្នុងការទ្រទ្រង់ការចូលរៀនរបស់កុមារ និង សកម្មភាពប្រចាំថ្ងៃដទៃទៀត នៅតាមសាលាកុមារីទាំងអស់។

សម្រាប់ព័ត៌មានបន្ថែមស្តីពីកម្មវិធីនេះ ចូរមើលក្នុង http://www.worldbank.org ហើយចែករក "Balochistan."

៥. ការច្រាស្រ័យទាក់ទងតាមរយៈការទៅលេងលំនៅឋាន : ការទាក់ទងជាមួយគ្រួសារដែលកូនៗពួកគេត្រូវបានច្រានចោល ជាទម្លាប់មិនមានការងាយស្រួលឡើយ។ មធ្យោបាយមួយដើម្បីផ្តល់ព័ត៌មានអំពីបរិយាកាសរៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាពគឺ ត្រូវឱ្យសាលាស្នើសុំអ្នកណាម្នាក់ដែលបីតក្នុងក្រុមដែលគេច្រានចោល ដូចជាកុមារពិការ ឬជនជាតិភាគតិច ឱ្យធ្វើជាមនុស្សទំនាក់ទំនងសម្រាប់សាលារៀន។ ការជួបប្រជុំជាក្រុមជាមួយមនុស្សនោះ ឬការទៅលេងនៅតាមផ្ទះ អាចមានប្រសិទ្ធភាពក្នុងការពន្យល់អំពីមធ្យោបាយរបស់សាលាដើម្បីបង្កើតបរិយាកាសរៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព។



គោលទី ២.៣
សហគមន៍ និងកម្មវិធីសិក្សា

សហគមន៍ក្នុងថ្នាក់រៀន

ការចូលរួមវិភាគទានរបស់មាតាបិតា និងសហគមន៍មានសារៈសំខាន់ណាស់ក្នុងការអភិវឌ្ឍបរិយាកាសរៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព។ ការចូលរួមវិភាគទានជាហិរញ្ញវត្ថុ ឬជាសម្ភារ ជាមធ្យោបាយដាក់ស្តែង ដែមាតាបិតាអាចផ្តត់ផ្តង់គាំទ្រដល់ការរៀនសូត្ររបស់កុមារ។ ឧទាហរណ៍ អង្គការ សហគមន៍ សមាគមគ្រូបង្រៀន និងមាតាបិតា និងគណៈកម្មការគ្រប់គ្រងសាលា ជារឿយៗចូលរួមជួយកែលំអសម្ភារឧបទេសរបស់សាលា។ បញ្ហានេះមានសារៈសំខាន់ណាស់ ជាពិសេសសម្រាប់សាលារៀនណាដែលមានឧបសគ្គផ្សេងៗមិនឱ្យកុមារពិការរាងកាយចូលអគារសិក្សារួច។ ប្រសិនបើមានកាំជណ្តើរ សមាជិកសហគមន៍អាចជួយដាក់ផ្លូវជំរាលជំនួសកាំជណ្តើរ។ នៅតាមបណ្តាប្រទេសជាច្រើន អង្គការសហគមន៍ក៏ធ្វើសកម្មភាព ក្នុងការកែលំអការផ្តត់ផ្តង់ទឹក និងអនាម័យរបស់សាលាផងដែរ។ ប្រសិនបើគ្មានបង្គន់ដាច់ដោយឡែកសម្រាប់កុមារី ពួកគេត្រូវសង់បង្គន់សម្រាប់កុមារី។

> មាតាបិតាក្នុងសហគមន៍មួយនៅប្រទេសម៉ាឡាវីបានដឹងថា គ្រូបង្រៀនគ្មានកន្លែងសុវត្ថិភាពដើម្បីរក្សាទុកសម្ភារៀនសូត្រ ដែលគ្រូបានរៀបរៀងដើម្បីទាក់ទាញសិស្សឱ្យចូលរួមក្នុងការរៀនសូត្រ។ ឃើញបែបនេះ សហគមន៍បានទិញទ្វារសម្រាប់ដាក់តាមបន្ទប់រៀន និងតាមការិយាល័យនាយកសាលា។ មាតាបិតា ក្នុងសហគមន៍នោះ និងសហគមន៍ចំនួន ២០ ផ្សេងទៀតក្នុងសង្កាត់តែមួយចាប់ផ្តើមផ្តល់ប្រអប់ចាស់។ ស្បែកជើងកៅស៊ូ និងសម្ភារផ្សេងៗទៀតសម្រាប់ឱ្យគ្រូបង្រៀនធ្វើជាសម្ភារសិក្សា ដើម្បីប្រើជាមួយសិស្សក្នុងថ្នាក់រៀនសម្រាប់រៀនអក្សរ និងគណិតវិទ្យា។ គ្រូបង្រៀនម្នាក់បានកត់សម្គាល់ថា បទពិសោធនៃការចូលរួមរបស់មាតាបិតាជាមួយសាលាក្នុងការរៀបរៀងកម្មវិធីសិក្សាកំពុងតែរួមចំណែកក្នុងការបង្កើនសមិទ្ធិផលរៀនសូត្រ និងជីវជម្ពុះរបស់កុមារនៅសាលា។
>
> - Miske SJ. (2003) Proud Pioneers: Improving Teaching and Learning in Malawi through Continuous Assessment. Washington, DC: American Institutes for Research.

នៅប្រទេសហ្វីលីពីន អ្នកអប់រំម្នាក់បានរាយការណ៍ថា គេបានខិតខំប្រឹងប្រែងជាខ្លាំង ដើម្បីធ្វើឱ្យមាតាបិតាមានអារម្មណ៍ថា ពួកគាត់ជាផ្នែកមួយនៃសាលារៀន និងធ្វើឱ្យសិស្សមានអារម្មណ៍ថា ជាផ្នែកមួយនៃសហគមន៍។ មាតាបិតាបានជួយសាងសង់មជ្ឈមណ្ឌលធនធានសិក្សាដែលអាចធ្វើជាបណ្ណាល័យមួយមានសៀវភៅចំនួន១០០ក្បាល ឧបត្ថម្ភដោយអង្គការ UNICEF ចំណែកសម្ភារសិក្សាត្រូវបានបង្កើតដោយគ្រូបង្រៀន និងសិស្ស ឬឧបត្ថម្ភដោយអង្គការមិនមែនរដ្ឋាភិបាល។ សិស្សក៏បានជួយជលិតគ្រឿងសង្ហារិមផ្សេង។ទៀតបន្ថែម ដូចជាធ្នើរសៀវភៅនៅបណ្ណាល័យ។

Feny de los Angeles-Bautista with Marissa J. Pascual, Marjorie S. Javier, Lillian Mercado-Carreon and Cristina H. Abad. (2001). Reinventing Philippine Education: Building Schools Filipino Children Deserve. The Ford Foundation, Manila.

យើងបានកត់សម្គាល់ក្នុងគោលចុងក្រោយថា មធ្យោបាយមួយដើម្បីចលនាឱ្យមាតាបិតាចូលរួមដោយផ្ទាល់គឺត្រូវអញ្ជើញពួកគាត់មកកាន់ថ្នាក់រៀន។ មានមធ្យោបាយជាច្រើន ដែលមាតាបិតា ជីដូនជីតា និង អាណាព្យាបាលអាចចូលរួមក្នុងការអប់រំសិស្ស ដែលនឹងអាចរួមចំណែកដល់ការធ្វើឱ្យមានបរិយាកាសរៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាពរបស់ថ្នាក់រៀន។ ខាងក្រោមនេះគឺជាគំនិតខ្លះៗ ទុកគ្រាន់ពិចារណា។

- មាតាបិតា ឬសមាជិកគ្រួសារដទៃទៀតអាចស្ម័គ្រចិត្តជួយគ្រូបង្រៀនអំពីសកម្មភាពថ្នាក់រៀន ដូចជា ការអាន ឬរៀបចំសម្ភារសិក្សា ដើម្បីជួយសកម្មភាពក្រៅកម្មវិធីសិក្សា ដូចជាកីឡា ឬការធ្វើដំណើរតាមកន្លែងផ្សេង។ ឬជួយរៀបចំបង្កើត សកម្មភាពពិសេស។ ដូចជាពិធីបុណ្យផ្សេង។។

- មាតាបិតាអាចធ្វើជាវាគ្មិនដែលជាភ្ញៀវក្នុងថ្នាក់រៀន ដែលចែករំលែកព័ត៌មានស្តីពីការងារ និងពិភពការងាររបស់ពួកគេ។ ពួកគេអាចនិយាយអំពីការអប់រំដែលបានរួមចំណែកដោយរបៀបណាមួយចំពោះជំនាញការងាររបស់ពួកគេ។ មាតាបិតា ដែលមិនចេះអក្សរអាចនិយាយអំពីប្រវត្តិសហគមន៍ ចែករំលែករឿងនិទានផ្សេង។ ឬបង្ហាញអំពីរបៀបធ្វើសិប្បកម្មប្រពៃណី។

- ពួកគេអាចពាក់ព័ន្ធ និងចូលរួមក្នុងជំនួបប្រជុំសមាគមគ្រូបង្រៀន និងមាតាបិតា និងកិច្ចប្រជុំរបស់សាលាដទៃទៀត ដែលនឹងត្រូវគេផ្តល់ព័ត៌មានជូន ព្រមទាំងចូលរួមព្រឹត្តិការណ៍ថ្នាក់រៀនពិសេស។។ នៅព្រឹត្តិការណ៍ទាំងនេះ ពួកគេអាចជួបជាមួយគ្រូបង្រៀនអាចយល់ដឹងអំពីកម្មវិធីសិក្សារបស់សាលា និងអំពីរបៀបក្នុងការចូលរួមក្នុងសកម្មភាពផ្សេង។។

- ពួកគេអាចផ្តល់អំណោយជាសម្ភារចាំបាច់នានាដល់សាលារៀន ឬជួយស្វែងរកវិភាគទានហិរញ្ញវត្ថុពីអ្នកដទៃទៀត ដើម្បីឆ្លើយតបតាមតម្រូវការរបស់សាលារៀន និងថ្នាក់រៀន។

- ពួកគេអាចឈានទៅរកមាតាបិតាដទៃទៀត ដែលមានកូនមិនទាន់ចូលសាលា ឬកំពុងគិតដល់ការបោះបង់ការសិក្សា ដើម្បីលើកទឹកចិត្តកុមារទាំងនោះឱ្យបំពេញចប់ការអប់រំរបស់ខ្លួន។
- ពួកគេអាចចូលរួមក្នុងការប្រឹងប្រែង ដើម្បីរក្សាសាលា ឬមជ្ឈមណ្ឌលគាំពារកុមារឱ្យមានសុវត្ថិភាព និង អនាម័យ។
- ពួកគេអាចជួយសាលារៀនរៀបចំពិធីបើកបវេសនកាល។ នៅថ្ងៃនោះ មាតាបិតា សមាជិកសហគមន៍ និងមន្ត្រីផ្សេងៗត្រូវបានអញ្ជើញចូលរួមនៅសាលារៀន។ ការងារតំណាងរបស់សិស្សទាំងអស់ត្រូវបានដាក់តាំងបង្ហាញ រួមជាមួយសម្ភារសិក្សាថ្មីៗ។ គ្រូបង្រៀនបង្ហាញពីជំនាញថ្មីៗរបស់ខ្លួនក្នុងការវាយតម្លៃ និងការបង្រៀន។ កុមារដែលមានប្រវត្តិ និងសមត្ថភាពផ្សេងៗគ្នា ទាំងអស់បង្ហាញពីអ្វីដែលពួកគេបានរៀន។
- មាតាបិតា និងសមាជិកគ្រួសាររបស់សហគមន៍អាចជួយវាយតម្លៃសមិទ្ធផលនៃការរៀនសូត្ររបស់កុមារ។ ពួកគេអាចដាក់ពិន្ទុលើលំហាត់ធ្វើនៅផ្ទះរបស់សិស្ស ហើយដូច្នេះបានផ្តល់នូវទិន្នន័យរបស់ខ្លួនទៅក្នុងការរៀនសូត្ររបស់កូន។
- អ្នករៀនចប់ការសិក្សាដោយជោគជ័យ និងមាតាបិតាដែលមានការលះបង់អាចធ្វើជាអ្នកដើរតួគំរូជាពិសេសអ្នកដែលមានសមត្ថភាព និងប្រវត្តិខ្សោយ។ ចូររៀបចំទិវាស្តីពីមុខរបរអាជីពរៀងរាល់ឆ្នាំ។ អញ្ជើញបុរស និងស្ត្រីទាំងនេះឱ្យមកពិភាក្សាអំពីមុខរបររបស់ខ្លួន និងអំពីរបៀបណាមួយសម្រាប់ឱ្យកុមារា និងកុមារីរៀបចំមុខរបរទាំងនោះ។

ស្ត្រីគំរូ

នៅតាមសាលារៀន ដែលគ្មានគ្រូបង្រៀនជាស្ត្រី ស្ត្រីក្នុងសហគមន៍អាចចូលរួមក្នុងកម្មវិធីស្ត្រីគំរូបាន។ មាតាបិតា ឬបងប្អូនញាតិមិត្តរបស់សិស្ស ព្រមទាំងឥស្សរជនសាសនា អ្នកសិល្បៈល្បី។ អតីតយុវល្បី។ ឬអ្នកនយោបាយល្បីៗក្នុងសហគមន៍ ជាធម្មតា មានឆន្ទៈចូលរួមជាមួយសាលារៀន ឬថ្នាក់រៀន ដែលព្យាយាមផ្តល់ឱកាសឱ្យកុមារីចូលរួមក្នុងកម្មវិធីស្ត្រីគំរូ។

ប្រសិនបើស្ត្រីក្នុងសហគមន៍អាចដើរតួនាទីជាគំរូបាន ចូរអញ្ជើញពួកគាត់ឱ្យមកសាលាជាច្រើនដងក្នុងអំឡុងពេលឆ្នាំសិក្សា។ ចូរស្នើសុំពួកគាត់ថ្លែងបង្ហាញអំពីរបៀបរបបដែលពួកគាត់បានធ្វើការសម្រាប់បុរស និងជាមួយបុរសស្ត្រីទាំងឡាយ និងថ្លែងអំពីតួនាទីយេនឌ័រដែលមានឥទ្ធិពល ដោយរបៀបណាខ្លះលើជំពើស ជ័យជម្នះ និងបរាជ័យរបស់ពួកគាត់។ ក្រៅពីការថ្លែងសុន្ទរកថា សុំឱ្យគាត់ពន្យល់បង្ហាញពីការងាររបស់ពួកគាត់ និងការពិគ្រោះ ពិភាក្សាជាមួយសិស្ស ពួកគាត់អាចជួយដឹកនាំ និងផ្តល់យោបល់ស្តីពីតួនាទីគំរូជាមួយសិស្សទាំងអស់។

ចូរឱ្យគ្រូបង្រៀនជាស្ត្រីម្នាក់ ឬសិស្សស្រីមួយក្រុម ដែលរៀនបានជោគជ័យរហូតដល់ថ្នាក់ទី ៦ ឬទី១១ ទៅទស្សនាតាមសាលានៅជនបទ ដែលជាធម្មតាមានកុមារីចោះបង់ចោលការសិក្សានៅត្រឹមថ្នាក់ទី៥ ឬមុនថ្នាក់ទី៥។ កុមារីទាំងអស់គួរជួបជុំរួមគ្នា ដើម្បីដឹងអំពីអ្វីដែលកុមារីត្រូវការធ្វើ ត្រូវការបន្តការសិក្សា ឬរៀនឱ្យបានពូកែក្នុងសាលា។ ចូរឱ្យគ្រូជាស្ត្រី ដែលចុះទៅទស្សនាតាមសាលា និងកុមារីដែលមានអាយុច្រើនជួបប្រជុំរួមគ្នាជាមួយមាតាបិតា ដើម្បីពិភាក្សាអំពីមធ្យោបាយច្បាស់លាស់ ដើម្បីជួយកុមារីទាំងឡាយឱ្យបន្តការសិក្សា និងបំពេញឱ្យចប់ការអប់រំរបស់ខ្លួន។

- The Gender-Fair Teacher (2003) UNICEF/Eritrea

ថ្នាក់រៀន និងសហគមន៍

ក្រៅពីការអញ្ជើញមាតាបិតា និងសមាជិកសហគមន៍ឱ្យមកសាលាដែលមានបរិយាកាសរៀនមេត្រីដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព កម្មវិធីសិក្សាដែលមានការទាក់ទងមួយទាមទារឱ្យកុមារស្ថិតក្នុងសហគមន៍ និងរៀនឱ្យបាន ច្រើនអំពីប្រធានបទផ្សេងៗ។

ឧទាហរណ៍ :

- កុមារអាចស្វែងរកអត្ថបទផ្សេងៗ ឬទទួលព័ត៌មានពីផ្ទះ ឬសហគមន៍របស់ខ្លួន ដែលទាក់ទងនឹងមេរៀនណាមួយនៅសាលារៀន។
- កុមារអាចសួរសម្តាសមាតាបិតា ឬជីដូនជីតាអំពីវិធីកុមារភាពរបស់ខ្លួន។
- ពួកគេអាចស្វែងរកវត្ថុជាតិ ឬសម្ភារដទៃទៀត ដែលទាក់ទងនឹងមេរៀនណាមួយ។
- ពួកគេអាចនាំសម្ភារផ្សេងៗ (ដូចជា ក្រដាសកាតុងដែលប្រើរួច) ដែលគ្រូបង្រៀនអាចប្រើដើម្បីធ្វើជាសម្ភារសិក្សា និងបង្រៀន។
- កុមារអាចចូលរួមក្នុងការតុបតែងថ្នាក់រៀនឡើងវិញ ឬក្នុងការវាយតម្លៃ និងកែរលំអទីធ្លា សាលា ដើម្បីឱ្យមាន បរិយាកាសរៀនមេត្រីរបស់កុមារ (ជាពិសេស សម្រាប់កុមារពិការ) មានសុវត្ថិភាព (កាត់បន្ថយជម្លោះ) និងងាយយល់ពីបញ្ហាយេនឌ័រ ការកែរលំអទីធ្លាសាលាអាចនាំឱ្យផ្លែបន្ទប់មានលក្ខណៈកាន់តែស្រឡះឡើងជង់ដែរ[3]។
- កុមារអាចជួយរៀបចំសហគមន៍ខ្លួន និងជួយស្វែងរកកុមារដែលមិនទាន់ចូលសាលា ដែលពួកគេគួរតែត្រូវចូលរៀន។

[3] UNICEF. Children as Community Researchers. http://www.unicef.org/teachers

- កុមារអាចចូលរួមក្នុងសកម្មភាពសេវាកម្មរបស់សហគមន៍។ ក្នុងគំរោងការងារស្តីពីកុមារនៅប្រទេសថៃ កុមារបានស្ម័គ្រចិត្តជាប្រចាំក្នុងការចោសសំអាតផ្ទះសំបែងរបស់មនុស្សចាស់ជរាដែលកំពុងរស់នៅម្នាក់ឯង។ នៅពេលល្ងាច ពួកគេទទួលទានអាហាររួមគ្នា ហើយមនុស្សចាស់ជរាបាននិយាយអំពីប្រវត្តិ និងវប្បធម៌របស់សហគមន៍។ ទោះបីជាពួកគេមានអាយុផ្សេងគ្នាក៏ដោយ ក៏ពួកគេម្នាក់ៗបានអភិវឌ្ឍទំនាក់ទំនងកាន់តែជិតស្និទ្ធ និង អនុវត្តនូវការផ្តល់ការគាំពារកាន់តែប្រសើរឡើង។ ជាងនេះទៀត កុមារក៏បានថែរក្សា ស្អាតបាតនូវផ្លូវថ្នល់ និងផ្លូវលំនានាក្នុងសហគមន៍ ដើម្បីបញ្ចៀសការគ្រោះថ្នាក់ផ្សេង។[3]។

សកម្មភាពថ្នាក់រៀនដែលផ្តោតទៅលើសហគមន៍ : មានមធ្យោបាយផ្សេង។ទៀតជាច្រើនដែលសិស្សអាចរៀនពីសហគមន៍របស់ខ្លួន និងអាចរួមចំណែកក្នុងសកម្មភាពរបស់សហគមន៍។ ឧទាហរណ៍ នៅប្រទេសថៃភាគខាងជើង សិស្សថ្នាក់ទី ៥ មួយក្រុមបានសិក្សាអំពីបរិស្ថានសហគមន៍សម្រាប់ការរៀនមុខវិជ្ជាវិទ្យាសាស្ត្រក្នុងអំឡុងពេលនៃឆ្នាំសិក្សា។ ពួកគេបានចង់ក្រងជាឯកសារនូវសញ្ញានៃការបំផ្លិចបំផ្លាញព្រៃឈើ ហើយបានសួរសម្ភាសសមាជិកសហគមន៍អំពីប្រវត្តិព្រៃឈើក្នុងសហគមន៍។ ពួកគេបានពិភាក្សាជង់ដែរអំពីវិធីក្នុងការដាំដើមឈើក្នុងសហគមន៍។ នៅចុងឆ្នាំ សិស្សទាំងនោះបានបង្ហាញការសិក្សារបស់ពួកគេដល់មាតាបិតា។ ជាការពិត មាតាបិតាទាំងអស់នេះបានរៀនអំពីសហគមន៍ពីសិស្សទាំងនោះ។ ពួកគេចាប់អារម្មណ៍ចំពោះអ្វី ដែលសិស្សបានរៀន និងវិធី ផ្សេង។ ដែលសិស្សបានបង្ហាញព័ត៌មាន។ មាតាបិតា និងសិស្សបានរួមដៃគ្នាស្វែង រកដំណោះស្រាយចំពោះបញ្ហាបរិស្ថានក្នុងសហគមន៍។

ការចូលរួមរបស់សិស្សនៅរាល់កិច្ចប្រជុំ : សិស្សអាចពង្រីកបទពិសោធពិភពលោកផ្ទាល់របស់ខ្លួនដោយការចូលរួមនៅរាល់ការជួបប្រជុំរវាងសាលា និងមាតាបិតា ឬការប្រជុំរបស់សហគមន៍ ឬព្រឹត្តិការណ៍ដទៃទៀត។ អ្នកអាចសំដែងការដើរតួការប្រជុំជាមុនសិនជាមួយសិស្សក្នុងថ្នាក់រៀន និងហ្វឹកហាត់ពេលដែលពួកគេនឹងចូលរួមការប្រជុំ។ សិស្សអាចរៀបចំបង្កើតសកម្មភាព និងគំរោងការងារពីមេរៀនក្នុងថ្នាក់របស់ខ្លួន ហើយបង្ហាញសកម្មភាព និងគំរោងទាំងនោះក្នុងពិធីតាំងសមិទ្ធិផល របស់សិស្ស ឬសិស្សមួយក្រុមតូចអាចបង្ហាញរឿងល្ខោន ចម្រៀង ឬ កំណាព្យ។ ក្នុងសកម្មភាពបែបនេះ សិស្សពន្យល់មាតាបិតា ឬអាណាព្យាបាលអំពីអ្វីដែលបានរៀននៅសាលា។ កត្តានេះបានធ្វើឱ្យការច្រាស្រ៊ែយទាក់ទងរវាងសាលា និងមាតាបិតា កាន់តែល្អឡើង ហើយបានជំរុញឱ្យកុមារអនុវត្តអ្វីដែលខ្លួនបានរៀននៅសាលា។

ក្នុងការរៀបចំការជួបប្រជុំរវាងសាលា និងមាតាបិតាស្តីពីការសិក្សារបស់សិស្ស ជាការចាំបាច់ត្រូវយកចិត្តទុកដាក់ ជាពិសេសចំពោះភាសាណាមួយ ឬភាសាផ្សេង។ដែលនឹងត្រូវប្រើក្នុងការប្រជុំ។ សិស្ស និងគ្រូបង្រៀនត្រូវការសម្រេចចិត្តថា តើពួកគេនឹងច្រាស្រ៊ែយទាក់ទងដោយរបៀបណាជាមួយមាតាបិតាដែលមិននិយាយភាសារួមមួយ ឬដែលមានបញ្ហាការស្តាប់។

---

[4] For more ideas on children's participation, see http://www.inmu.mahidol.ac.th/CHILD



គោលទី ២.៤
តើយើងបានរៀនពីបទពិសោធអ្វីខ្លះកន្លងមក?

កម្រងសៀវភៅនេះបានផ្តល់ឱ្យអ្នកនូវគោលជាច្រើន ដែលអ្នកអាចប្រើដើម្បីចលនាគ្រួសារសិស្ស និងសហគមន៍ឱ្យចូលរួមក្នុងបរិយាកាសរៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព។ តើអ្នកអាចធ្វើកិច្ចការខាង ក្រោមនេះបានឬទេ?

១. ចូរដាក់ជាបញ្ជីនូវការទទួលខុសត្រូវរបស់គ្រូដែលមានបរិយាកាសរៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព ទាក់ទងនឹងសហគមន៍។

២. តើមានមធ្យោបាយអ្វីខ្លះ ដែលអ្នកអាចផ្តល់ព័ត៌មានដល់មាតាបិតាអំពីទេព្យកោសល្យ និងជំនាញរៀនសូត្ររបស់កូនពួកគាត់?

៣. ចូរដាក់ជាបញ្ជីនូវមធ្យោបាយចំនួនពីរ ដែលមាតា និងបិតាអាចជួយ ដើម្បីរាប់បញ្ចូលកុមារដែលធ្លាប់ត្រូវគេច្រានចោល (ក) ក្នុងសាលារៀន (ខ) នៅក្រៅសាលារៀន។

៤. ចូរផ្តល់ឈ្មោះមធ្យោបាយជាច្រើន ដែលសហគមន៍ " ចូលក្នុងថ្នាក់រៀន "។

៥. ចូរដាក់ជាបញ្ជីនូវមធ្យោបាយជាច្រើន ដែលសិស្សអាចចូលរួមក្នុងសហគមន៍របស់ខ្លួន ឬប្រើសម្ភារបានពីផ្ទះ ឬមានស្រាប់ក្នុងសហគមន៍។

ការចលនាឱ្យសហគមន៍ចូលរួមគឺជាកត្តាសំខាន់សម្រាប់ការទទួលជ័យជម្នះនៃបរិយាកាសរៀនមេត្រីដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព។ មានមធ្យោបាយជាច្រើន ដែលអ្នកអាចរៀបចំសិស្សឱ្យចូលរួមក្នុងការរៀនសូត្រក្នុងសហគមន៍ និងជាមួយបរិយាកាសក្នុងស្រុក។ ក៏មានមធ្យោបាយជាច្រើនផងដែរ ដែលគ្រូអាចធ្វើការជាមួយមាតាបិតា ឬអាណាព្យាបាលសិស្ស ដើម្បីផ្តល់ព័ត៌មានដល់ពួកគេ អំពីបរិយាកាសរៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព និងលើកទឹកចិត្តពួកគេឱ្យធ្វើជាអ្នកតស៊ូមតិសម្រាប់សាលារៀនក្នុងសហគមន៍។ សៀវភៅនេះបានដាក់ជាតារាងនូវគំនិតជាច្រើនសម្រាប់បញ្ហានេះ។ ឥឡូវនេះចូរសួរខ្លួនអ្នកថា "តើខ្ញុំអាចធ្វើអ្វីដើម្បីចាប់ផ្តើមធ្វើការឱ្យកាន់តែជិតស្និទ្ធថែមទៀតជាមួយគ្រួសារកុមារ និងសហគមន៍?" ចូររកគោលដៅផ្ទាល់ខ្លួនចំនួនបី ហើយប្រៀបធៀប និងពិភាក្សាគោលដៅទាំងនេះជាមួយសហការី សិស្ស និងគ្រួសារសិស្ស។ បានរយៈពេលពីមួយទៅពីរសប្តាហ៍ ប្រៀបធៀបមើលថា តើអ្នកកំពុងតែមានការរីកចម្រើនដោយរបៀបណា ហើយតើអ្នកអាចចាត់វិធានការបន្ថែមអ្វីខ្លះទៀត?

តើអ្នកអាចរៀនបន្ថែមនៅកន្លែងណា?

ការបោះពុម្ពផ្សាយខាងក្រោម និងវេបសាយ (Web sites) គឺជាធនធានដ៏មានតម្លៃផងដែរសម្រាប់លើកទឹកចិត្តឱ្យមានទូទៅទំនាក់ទំនង កាន់តែជិតស្និទ្ធថែមទៀតរវាងសាលារៀន គ្រួសារ និងសហគមន៍។

ឯកសារយោង

Bureau of Elementary Education, Department of Education, Culture and Sports in cooperation with UNICEF Philippines (1994) The Multigrade Teacher's Handbook, Manila.

duPlessis J. (2003) Rainbow Charts and C-O-C-O-N-U-T-S: Teacher Development for Continuous Assessment in Malawi Classrooms. Washington, DC: American Institutes for Research.

Miske SJ. (2003) Proud Pioneers: Improving Teaching and Learning in Malawi through Continuous Assessment. Washington, DC: American Institutes for Research.

Rugh A and Bossert H. (1998) Involving communities: Participation in the delivery of education programs. Washington, DC: Creative Associates International, Inc.

The Gender-Fair Teacher (2003) UNICEF/Eritrea.

Web Sites

Children as Community Researchers. This is an excellent publication for promoting children's learning through the community. It can be downloaded at: http://www.unicef.org/teachers/researchers/index.html or http://www.unicef.org/teachers/researchers/childresearch.pdf

Children's Integrated Learning and Development Project. http://www.inmu.mahidol.ac.th/CHILD

Community School Alliances. http://www.edc.org/CSA

Supporting Home-School Collaboration by Sandra L. Christenson. http://www.cyfc.umn.edu/schoolage/resources/supporting.html

UNICEF Teachers Talking about Learning. http://www.unicef.org/teachers/environment/commun.htm. This excellent Web site offers information on: learning and the community; teachers and communities; involving families in learning; communities helping schools; community life; and tips for improving schools.

អក្សរសិល្ប៍សម្រាប់កុមារ : ៣

កម្រងសៀវភៅលេខ : ៣

ប្រមូលកុមារទាំងអស់ឱ្យចូលរៀនទៅក្នុងសាលា

អក្សរសិល្ប៍សម្រាប់កុមារ ដែលផលិតឡើងដោយមជ្ឈមណ្ឌលសិក្សាសម្រាប់សាលារៀន



បរិយាកាសអ្នកចៃន្តី
ដោយបញ្ជូលគ្រប់សមាសភាព

UNESCO

សេចក្តីណែនាំអំពីគោល

កម្រងសៀវភៅលេខ៣នេះនឹងជួយអ្នក និងសហការីរបស់អ្នកឱ្យយល់ដឹងអំពីឧបសគ្គនានាដែលរារាំងមិនឱ្យកុមារមានឱកាសបានចូលរៀន និងវិធានការនានាដើម្បីធានាឱ្យកុមារទាំងនោះបានចូលរៀន? កម្រងសៀវភៅនេះត្រូវលើកយកបញ្ហា និងវិធីសាស្ត្រទាំងនេះ មកបង្ហាញមួយដំណាក់កាល។។ កម្រងសៀវភៅនេះក៏មានបង្ហាញអំពីវិធីសាស្ត្រធ្វើឱ្យកុមារដែលពុំធ្លាប់មានឱកាសចូលរៀនបានចូលរៀនវិញដែរ។ វិធីសាស្ត្រទាំងនេះ ត្រូវបានលោកគ្រូ អ្នកគ្រូនៅជុំវិញពិភពលោកប្រើប្រាស់បានជោគជ័យរួចហើយ។ បន្ទាប់ពីបានសិក្សាកម្រងសៀវភៅនេះ អ្នកនឹងអាចនិយាយជាមួយលោកគ្រូ អ្នកគ្រូដទៃទៀត សមាជិកគ្រួសារ សហគមន៍ និងសិស្សអំពីកត្តានានា ដែលរារាំងកុមារមិនឱ្យមានឱកាសចូលរៀន។ អ្នកអាចកត់សម្គាល់ ពីទីកន្លែងដែលកុមារ រស់នៅ ហេតុផលដែលកុមារមិនបានចូលរៀន និងវិធានការដែលត្រូវអនុវត្ត ដើម្បីធានាឱ្យកុមារទាំងអស់បានចូលរៀន ។

គោល

គោល ៣.១ តើអ្នកណាខ្លះប្រហែលជាមិនបានចូលរៀន? ---------- ៣

ការលាតត្រដាងឧបសគ្គារារាំងមិនឱ្យកុមារបានចូលរៀន ---------- ៣

ការវាយតម្លៃដោយខ្លួនឯងចំពោះការសិក្សាដែលមានបញ្ហូលគ្រប់សមាសភាព --------- ១១

គោល ៣.២ រកកុមារដែលមិនបានចូលរៀនក្នុងសាលា និងហេតុផលដែលជម្រុញឱ្យកុមារនៅក្រៅសាលា ---------- ១៣

ការកំណត់ដែនទីព័ត៌មានសាលា–សហគមន៍ ---------- ១៣

ការចូលរួមរបស់កុមារនៅក្នុងការកំណត់ដែនទីព័ត៌មានសហគមន៍ ---------- ១៥

ការស្វែងរកមូលហេតុដែលធ្វើឱ្យកុមារមិនបានចូលរៀន ---------- ១៩

គោល ៣.៣ វិធានការដែលត្រូវធ្វើដើម្បីប្រមូលកុមារឱ្យបានចូលរៀន ---------- ២៧

ជែនការសកម្មភាព ---------- ២៧

គំនិតសម្រាប់អនុវត្តសកម្មភាព ---------- ៣០

គាល ៣.៤ តើយើងបានរៀនពីបទពិសោធកន្លងមកអ្វីខ្លះ? ---------- ៤០



គោល ៣.១
តើអ្នកណាខ្លះប្រហែលជាមិនបានចូលរៀន?

ដំណាក់កាលសំខាន់មួយ ក្នុងការបង្កើតបរិយាកាសសិក្សាសម្រាប់អ្នកទាំងអស់គ្នា និងមានបញ្ហូលគ្រួសារ សហគមន៍នៅក្នុងដំណើរការនេះ គឺការស្វែងរកកុមារនៅក្នុងសហគមន៍ដែលមិនបានចូលរៀន។ តើអ្នកធ្លាប់បានគិតថា សិស្សអាចមានបងប្អូនប្រុស ឬបងប្អូនស្រីមិនបានចូលសាលារៀនឬទេ? ប្រសិនបើយើងពិតជាចង់ឱ្យកុមារទាំងនោះបានចូលរៀននៅក្នុងសាលា និងថ្នាក់រៀនសម្រាប់ទាំងអស់គ្នា ចូរយើងនាំគ្នាទិតខំនាំកុមារទាំងនោះឱ្យចូលរៀន និងបង្កលក្ខណៈឱ្យកុមារទាំងនោះបានរៀនរហូតចប់ ដោយជ្រើមជ្រែងឱ្យកុមារទាំងនោះ ទទួលបានចំណេះដឹង និងជំនាញ ដែលពួកគេត្រូវការចាំបាច់នៅក្នុងជីវិត។ ធ្វើដូច្នេះបានជាដំបូង យើងត្រូវដឹងពីមូលហេតុ ដែលបណ្តាលឱ្យកុមារទាំងនោះនៅក្រៅសាលា។

ការលាតត្រដាងឧបសគ្គរារាំងមិនឱ្យកុមារបានចូលរៀន

ចូរអានករណីសិក្សាមួយខាងក្រោមដោយខ្លួនឯង ឬអានខ្លាំងៗឱ្យមិត្តរួមថ្នាក់ស្តាប់។

កុមារទីប មានអាយុ១២ឆ្នាំ។ ជារៀងរាល់ព្រឹក ទោះក្តៅស្ទើរឆេះ ឬត្រជាក់ដូចទឹកកក កុមារទីបតែងដើរត្រាច់ចរពាសពេញសហគមន៍ ដើម្បីរកច្រាក់ចិញ្ចឹមជីវិត និងសន្សំខ្លះសម្រាប់ការសិក្សា។ ជួនកាលទីបជួយរៀបចំ និងសម្អាតហាងលក់ទំនិញក្នុងសហគមន៍ ឬលាងចានតាមហាងគុយទាវ។ ប្រសិនបើគ្មានការងារធ្វើទេ ទីបតើសសំបកដប និងសំបកកំប៉ុងយកទៅលក់ឱ្យហាងអេតចាយមួយក្នុងភូមិ។ នៅពេលមានវេលាបុណ្យទានក្នុងសហគមន៍ ជួនកាលទីបសុំលុយពីអ្នកដែលមកធ្វើបុណ្យក្នុងវត្ត ក្នុងសហគមន៍។ នៅថ្ងៃដែលមានសំណាង ទីបអាចរកបានពី១ទៅ១.៥ដុល្លា។ នៅថ្ងៃដែលគ្មានសំណាង ទីបរកមិនបានកន្លះដុល្លាផង។ ក្នុងការរកច្រាក់នេះ ទីបតែងនិយាយាថា ពេលគេឱ្យច្រាក់មកខ្ញុំ ហើយឱ្យខ្ញុំធ្វើអ្វី ខ្ញុំធ្វើភ្លាម។ ទីបធ្លាប់បានចូលរៀនដែរ តែពេលនេះ ទីបចង់បានច្រាក់ជាង៏ការរៀនសូត្រ។



សកម្មភាពអនុវត្ត : កំណត់រកឧបសគ្គរារាំងកុមារមិនឱ្យចូលរៀននៅក្នុងសាលាដែលមានបញ្ហូលគ្រប់សមាសភាព

ប្រសិនបើអ្នកធ្វើការជាមួយសហការីផ្សេងទៀត ចូរបែងចែកជា ២ ឬ ៤ ក្រុម។ ប្រសិនបើអ្នកធ្វើការតែម្នាក់ឯង ចូរសាកល្បងសកម្មភាពខាងក្រោមនេះដោយម្នាក់ឯង។

- ទីមួយ ម្នាក់ៗត្រូវគិតដោយស្ងៀមស្ងាត់រៀងៗខ្លួនអំពីហេតុផលមួយចំនួន ដែលទីបមិនបានចូលរៀន។ ម្នាក់ៗគួរកត់ត្រានូវគំនិតរបស់ខ្លួនទុក ដើម្បីជាជំនួយក្នុងការប្រើប្រាស់នៅពេលក្រោយ។ គួរចំណាយពេលប្រហែល ៥ នាទី សម្រាប់ធ្វើលំហាត់សកម្មភាពនេះ។

- បរិយាកាសសិក្សារបស់កុមារត្រូវមានបញ្ចូលសាលា គ្រួសារ និងសហគមន៍ឱ្យចូលរួម។ សាលាបែបនេះ ក៏មានបញ្ចូលទាំងកុមារផងដែរ។ មានន័យថា តើកុមារចង់ទៅរៀនឬមិនចង់? បន្ទាប់មកទៀត បែងចែកបរិយាកាសសិក្សានីមួយៗ ទៅឱ្យក្រុមនីមួយៗ។ ក្រុមមួយតំណាងសាលា ក្រុមមួយទៀតតំណាងគ្រួសារ ក្រុមមួយទៀតតំណាងសហគមន៍ និងក្រុមចុងក្រោយគឺ កុមារ (ទីប)។ បើអ្នកមានតែ ២ ក្រុម ក្រុមនីមួយៗត្រូវទទួលខុសត្រូវលើបរិយាកាសសិក្សា។ ប្រសិនបើអ្នកមានតែម្នាក់ឯង អ្នកត្រូវធ្វើទាំងអស់។

- ចែកផ្ទាំងក្រដាសធំៗសម្រាប់សរសេរឱ្យទៅក្រុមនីមួយៗ។ មួយក្រុមមួយសន្លឹក ហើយបន្ទាប់មកឱ្យពួកក្រុមនីមួយៗសរសេរបរិយាកាសសិក្សាដែលគេបានរើសនៅផ្នែកខាងលើនៃក្រដាស។

- ពិភាក្សានៅក្នុងក្រុមរបស់អ្នកអំពីឧបសគ្គនានាដែលមាននៅក្នុងបរិយាកាសសិក្សាដែលអ្នកជ្រើសរើស ដែលជាមូលហេតុធ្វើឱ្យទីបមិនបានចូលរៀន។ កត់ត្រាឧបសគ្គទាំងអស់នេះនៅលើក្រដាស ដែលបានចែកជូន បន្ទាប់មកអានខ្លឹមសារខាងក្រោមនេះ។

ហេតុផលមួយចំនួនដែលរារាំងកុមារមិនឱ្យចូលរៀន

កុមារទីប (កុមារ)

អត្តចរិតកុមារ និងបរិយាកាសជុំវិញកុមារមានឥទ្ធិពលលើការចូលរៀន ឬចង់ចូលរៀនរបស់កុមារ បើមិនទាំងអស់ ក៏ដោយផ្នែកដែរ។ ឧទាហរណ៍ ពន្លឺស្រស់បំព្រង និងក្តីសង្ឃឹមរកច្រាក់ ជំរុញកុមារឱ្យចាកចេញពីភូមិកំណើតទៅកាន់ទីក្រុងធំៗ ជាជាងទៅសាលារៀន។ ខាងក្រោមនេះ ជាហេតុផលខ្លះៗទាក់ទងនឹងកុមារដែលមិនបានចូលរៀន។ **តើមានកត្តាទាក់ទងនឹងកុមារក្នុងសហគមន៍ ប្រទេស ឬវប្បធម៌ដែលអាចប៉ះពាល់ដល់ការចូលរៀនរបស់កុមារឬទេ?**

ភាពគ្មានផ្ទះសំបែង និងតម្រូវការធ្វើការ : យើងឃើញកុមារក្នុងសភាពបែបនេះជារៀងរាល់ថ្ងៃ ជាពិសេស ប្រសិនបើយើងរស់ក្នុងទីក្រុងធំៗ ប៉ុន្តែយើងស្ទើរតែមិនចាប់អារម្មណ៍ កុមារតាមចិញ្ចើមផ្លូវទាល់តែសោះ ប្រសិនបើកុមារទាំងនោះមិនបានសុំច្រាក់ពីយើងទេ។ "តាមដងផ្លូវ" គឺជាផ្ទះ និងប្រភពជីវិតរបស់កុមារទាំងនោះ។ មានកុមារប្រហែល១០០លាននាក់ ដែលរស់នៅតាមដងផ្លូវនៅទូទាំងពិភពលោក។

កុមារទាំងនោះជាកុមារដែលធ្វើការ ហើយជាទូទៅ កុមារទាំងនោះឈប់រៀន ហើយគ្មានផ្ទះសំបែងរស់នៅទេ។ កុមារអនាថាទាំងនេះងាយរងនឹងការកេងប្រវ័ញ្ចណាស់ ព្រោះកុមារទាំងនោះ ពុំមានគ្រួសារ សហគមន៍ ឬសាលាគាំពារ និងថែទាំទេ។ មិនមែនសុទ្ធតែកុមារដែលរស់នៅតាមដងផ្លូវទាំងនោះ គ្មានគ្រួសារនោះទេ។ កុមារខ្លះ ដូចជា ទីប ធ្វើការនៅតាមផ្លូវដើម្បីរកប្រាក់ ហើយបន្ទាប់មក វិលទៅរកគ្រួសារវិញនៅពេលយប់។ នេះជាករណីសម្រាប់កុមារដែលពុំឃើញតម្លៃអប់រំ ពុំចូលចិត្តសាលា ឬកុមារនោះធំពេក មិនហ៊ានចូលរៀន ឬជួបការលំបាកដោយទំនាស់នយោបាយ ដែលបញ្ហាជីវភាពរស់នៅមានសារៈសំខាន់ជាងការសិក្សា។ កុមារអនាថាទាំងនោះ មានទំនាក់ទំនងតិចតួច ឬគ្មានទំនាក់ទំនងទាល់តែសោះជាមួយគ្រួសារ។ លើសពីនេះទៀត កុមារទាំងនោះត្រូវទទួលរងការធ្វើបាបទាំងរាងកាយ និងផ្លូវភេទ នៅផ្ទះ ដែលជាហេតុធ្វើឱ្យកុមារត្រូវរត់ចេញពីផ្ទះ ហើយមករស់នៅតាមចិញ្ចើមផ្លូវ ជាកន្លែងដែលកុមារត្រូវទទួលរងអំពើដូចគ្នា។

ជំងឺ និងការអត់ឃ្លាន : កុមារមិនអាចរៀនបានល្អទេ ប្រសិនបើគេមានជំងឺជាអចិន្ត្រៃយ៍ ឃ្លាន ហើយហូបចុកមិនបានគ្រប់គ្រាន់។ កុមារតែងអវត្តមានញឹកញាប់ ហើយត្រូវបានគេចាត់ទុកថា ជាអ្នករៀនសូត្រដែលមានការចេះដឹងយឺត ឬរៀនខ្សោយ។ ប្រសិនបើកុមារនោះមិនបានទទួលការយកចិត្តទុកដាក់តាមត្រូវការទេ កុមារអាចមានអារម្មណ៍ថា ពួកគេមិនមែនជាមិត្តរួមថ្នាក់ទេ ហើយពួកគេអាចនឹងឈប់រៀនដោយសារហេតុផលនេះ។ ផលអាក្រក់នៃជំងឺ ឬការខ្វះខាតអាហារមានជីវជាតិអាចមានផលប៉ះពាល់យូរអង្វែង ប្រសិនបើ ជំងឺ ឬការខ្វះអាហារនេះបណ្តាលឱ្យកុមារពិការខាងផ្លូវកាយ និងបញ្ញា។

ការចុះបញ្ជីកំណើត : នៅក្នុងប្រទេសមួយចំនួន ប្រសិនបើកុមារដូចជា ទីប ពុំមានភស្តុតាងបញ្ជាក់ថា បានចុះបញ្ជីកំណើតរួចហើយទេ កុមារនោះមិនអាចចូលរៀនបានទេ ឬបានចូលរៀនត្រឹមតែប៉ុន្មានឆ្នាំប៉ុណ្ណោះ។ ប្រការនេះធ្វើឱ្យប៉ះពាល់ដល់ក្មេងស្រីយ៉ាងខ្លាំង ព្រោះកំណើតរបស់ក្មេងស្រីមិនត្រូវបានចុះបញ្ជីត្រឹមត្រូវទេ ហើយការខ្វះសំបុត្រកំណើតនេះ ធ្វើឱ្យកុមារីមិនបានចូលរៀន ឬមិនបានប្រលងបញ្ចប់ការសិក្សា។ ការខ្វះសំបុត្រកំណើតច្រើនមានចំពោះជនភៀសខ្លួន ជនជាតិភាគតិច និង ជនផ្លាស់ទីលំនៅ។

ខ្លាចអំពើហិង្សា : ការខ្លាចមានអំពើហិង្សាពេលធ្វើដំណើរទៅសាលា នៅសាលា អាចបន្លាចកុមារឱ្យគេចពីសាលា។ ក្មេងប្រុសទទួលការវាយដំ ចំណែកកុមារីអាចទទួលការរំលោភផ្លូវភេទ និងការបំពានផ្លូវភេទតាមរូបភាពផ្សេងទៀត។ សម្រាប់អ្នកដែលជាជនរងគ្រោះ វាធ្វើឱ្យមានការប៉ះពាល់ដល់កិត្តិយសយ៉ាងខ្លាំង។ ទីបអាចជាជនរងគ្រោះបែបនេះ ដែលជាហេតុធ្វើឱ្យទីបលែងទៅសាលាតទៅទៀត។

ពិការភាព និងតម្រូវការពិសេស : កុមារភាគច្រើនដែលពិការ និងមានតម្រូវការពិសេសមិនបានចូលរៀនទេ ជាពិសេសនៅពេលដែលសាលា និងប្រព័ន្ធអប់រំរបស់យើងពុំមានគោលនយោបាយ ឬកម្មវិធីបញ្ចូលកុមារពិការសមត្ថភាពសិក្សាដូចជា ពិការរាងកាយ និងស្មារតី។ ក្រមនេះ ជាកុមារដែលយើងតែងគិតគូរនៅពេលយើងនិយាយពី "ការអប់រំដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព"។ ក្រមនេះជាកុមារដែលមិនធ្លាប់ចូលរៀនសោះ ដោយសារតែឥរិយាបថ ឬជំនឿអវិជ្ជមានដែលថា កុមារប្រភេទនេះមិនអាចចូលរៀនបាន។ ឪពុកម្តាយ ឬសមាជិកសហគមន៍ក៏មិនដឹងដែរថា កុមារទាំងនេះមានសិទ្ធិទទួលការអប់រំ និងត្រូវតែចូលរៀន។ សូម្បីតែសម្ភារទ្រទ្រង់នៅសាលា (ជណ្តើរ) អាចជាការរារាំងកុមារទាំងនេះ

មិនឱ្យចូលសាលាបានដែរ។ កុមារទាំងនេះ ក៏ជាអ្នកដែលចោះបង់ការសិក្សាមុនគេ ដោយសារតែមានសិស្ស ក្នុងថ្នាក់ច្រើនពេក ហើយគ្រូមិនអាចចំណាយពេលឱ្យបានគ្រប់គ្រាន់តាមតម្រូវការពិសេសរបស់កុមារពិការ។ លើសពីនេះទៀត ខ្វីមសារមេរៀន វិធីសាស្ត្របង្រៀន និងសូម្បីតែ "ភាសា" ក្នុងការបង្រៀន (និយាយបង្ហាញ) មិនសមស្របសម្រាប់កុមារពិការ និងកុមារដែលមានតម្រូវការពិសេស។

ការមានផ្ទៃពោះ : នៅប្រទេស និងសហគមន៍មួយចំនួន កុមារីដែលមានផ្ទៃពោះត្រូវបញ្ឈប់ពីសាលាដោយសារខ្លាចថា "ការមានផ្ទៃពោះ" បែបនេះ អាចជំរុញឱ្យអ្នកដទៃទៀតដៀមដាម ឬបៀតបៀនផ្លូវភេទ។ សូម្បីតែកុមារដែលជាជនរងគ្រោះដោយសារគេរំលោភ ការមានផ្ទៃពោះរបស់នាង អាចនាំភាពអាម៉ាស់មកឱ្យគ្រួសារ។ ជាយថាហេតុ សមាជិកក្នុងគ្រួសារ អាចនឹងបញ្ឈប់ទំនាក់ទំនងជាមួយនាង ហើយពួកគេពុំឃើញមានហេតុផលណាទៀតដែលត្រូវឱ្យនាងទៅរៀននោះទេ។

បរិយាកាសគ្រួសារ

គ្រួសារ និងសហគមន៍ត្រូវតែជាអ្នកទីមួយក្នុងការថែទាំ និងការពារកុមារ ដើម្បីយល់ដឹងពីបញ្ហាទាំងឡាយដែលកុមារកំពុងតែជួបប្រទះ និងចាត់វិធានការដើម្បីដោះស្រាយបញ្ហាទាំងអស់នេះតាមរបៀបសមស្រប។ នៅប្រទេសជាច្រើន តាមបទពិសោធរបស់អ្នកដែលធ្វើការជាមួយកុមារដែលបានចោះបង់ចោលការសិក្សា វិធានការដែលមានប្រសិទ្ធភាពជាងគេដើម្បីទប់ស្កាត់ការចោះបង់ការសិក្សារបស់កុមារ គឺគ្រួសារ និងសហគមន៍ដែលមានការរីកចម្រើន និងយកចិត្តទុកដាក់ចំពោះកុមារឱ្យបានដឹតដល់។ ទាំងក្រោមជាហេតុផលមួយចំនួនទាក់ទងនឹងគ្រួសារ និងសហគមន៍ដែលអាចមានឥទ្ធិពលលើការចូលរៀនរបស់កុមារ។

តើមានកត្តាគ្រួសារ សហគមន៍ ឬវប្បធម៌អ្វីខ្លះដែលប៉ះពាល់ដល់ការចូលរៀនរបស់កុមារ?

ភាពក្រីក្រ និងផលប្រយោជន៍ជាក់ស្តែងទទួលបានពីការអប់រំ : ភាពក្រីក្រជាញឹកញាប់ កំណត់ការចូលរៀន ឬមិនចូលរៀនរបស់កុមារ។ ផ្ទុយទៅវិញ បើកុមារមិនបានចូលរៀន កុមារនឹងមិនអាចរកប្រាក់ចំណូលឱ្យបានគ្រប់គ្រាន់ តែផ្ទុយទៅវិញ ការមិនបានចូលរៀនបង្កើតឱ្យមានភាពក្រីក្រក្នុងសហគមន៍។ ដោយសារតែបន្ទុកខាងប្រាក់កាស ឪពុកម្តាយក្រីក្រមានការលំបាក សូម្បីតែតម្រូវការចាំបាច់មួយចំនួនសម្រាប់ការសិក្សារបស់កូន ក៏មិនអាចរកបានផង។ ដូច្នេះ កុមារ ដូចជា ទីបត្រូវតែជួយរកស៊ីចិញ្ចឹមគ្រួសារដោយការលះបង់ការសិក្សា និងអនាគតរបស់ខ្លួន។ ស្ថានភាពបែបនេះកើតមាន ជាពិសេសនៅពេលដែលគ្រួសារលែងគិតថា ការសិក្សាមានសារប្រយោជន៍សម្រាប់ការរស់នៅប្រចាំថ្ងៃរបស់គេ។ ដូច្នេះ ពួកគេមិនយល់ឃើញថា តើហេតុអ្វីបានជាកូនរបស់គេត្រូវទៅរៀននោះទេ។ ឪពុកម្តាយ ក៏អាចគិតដែរថា កូនរបស់គេទទួលការអប់រំដែលពុំមានគុណភាព និងថា ជំនាញទាំងឡាយដែលកូនរៀនពីបទពិសោធការងារជាក់ស្តែងមានសារៈសំខាន់ជាងខ្វីមសារមេរៀននៅសាលាចំណេះទូទៅ។

ទំនាស់ : ឪពុកម្តាយមួយចំនួនដែលតែងមានជម្លោះរឿងច្រាក់កាស និងបញ្ហាផ្សេងទៀត អាចនាំឱ្យមានអំពើហិង្សា ដែលជាញឹកញាប់ ធ្វើឱ្យកុមារអវត្តមានពីសាលា ឬជំរុញកុមារដូចជា ទីប ឱ្យរត់គេចពីផ្ទះ និងគេចសាលា។

ការខ្វះការគាំពារ និងថែទាំ : ដោយសារតម្រូវការច្រាក់កាស ឪពុកម្តាយត្រូវបង្ខំចិត្តផ្លាស់ទីលំនៅពីស្រុកកំណើតរយៈពេលខ្លី ឬយូរ។ ជាយថាហេតុ ពួកគេអាចដាក់កុមារដូចជា ទីប នៅក្រោមការថែទាំរបស់ជីដូនជីតា ឬអ្នកដទៃទៀតដែលពុំមានចំណេះដឹង មិនមានធនធាន និងពុំបានយកចិត្តទុកដាក់ឱ្យបានគ្រប់គ្រាន់ចំពោះកុមារ។ អាណាព្យាបាលទាំងនេះ ពុំសូវឱ្យតម្លៃលើការសិក្សាទេ នៅពេលដែលគេត្រូវការច្រាក់ដោយខានមិនបាននោះ។

ការរើសអើង និងការលែងត្រូវការ ដោយសារតែមេរោគអេដស៍/ជំងឺអេដស៍ : កុមារដែលឪពុកម្តាយស្លាប់ចោលដោយសារអេដស៍ មានឱកាសរៀនសូត្រតិចជាងអ្នកមានឪពុកម្តាយ។ នៅប្រទេសមួយចំនួន កុមារ ជាពិសេសកុមារី – ត្រូវបានគេដកចេញពីសាលា ឱ្យមកមើលថែទាំបងប្អូន ឬអ្នកជំងឺ ឬរកច្រាក់ដើម្បីផ្គត់ផ្គង់គ្រួសារ។ ក្នុងករណីខ្លះទៀត កុមារទាំងនេះត្រូវបានគេចាត់ទុកថាជា "អ្នកចម្លងជំងឺ" ដូច្នេះទាំងសហគមន៍ ទាំងគ្រូបង្រៀន បង្ខំឱ្យកុមារឈប់រៀន ហើយក៏អាចនិយាយបានថា ទីប ឬ សមាជិកគ្រួសាររបស់ទីបជាអ្នកមានមេរោគអេដស៍/ជំងឺអេដស៍។

បរិយាកាសហគមន៍

ការរើសអើងយេនឌ័រ : ជំនឿបុរាណអំពីឋានៈ និងតួនាទីរបស់បុរស និងស្ត្រី អាចរារាំងការចូលរៀនរបស់កុមារី។ នៅសហគមន៍ដែលស្ត្រីត្រូវបានគេចាត់ទុកថា មានឋានៈទាបជាងបុរស កុមារីត្រូវនៅផ្ទះធ្វើការងារផ្ទះ និងមិនបានចូលរៀន។ ស្ថានភាពនេះកាន់តែធ្ងន់ធ្ងរថែមទៀត ដោយការអនុវត្តប្រពៃណីទម្លាប់ដែលតម្រូវឱ្យកុមារីរៀបការតាំងពីវ័យក្មេង ហើយចាកចេញពីផ្ទះទៅរស់នៅខាងប្តី។ នេះជាការខាតបង់របស់គ្រួសារខាងស្រី ដែលជាហេតុធ្វើឱ្យឪពុកម្តាយមិនបញ្ជូនកូនស្រីទៅសាលារៀន។ ទីបអាចជាក្មេងដែលរត់គេចពីស្ថានភាពបែបនេះ ក៏អាចថាបាន ។

ភាពខុសគ្នាខាងវប្បធម៌ និងប្រពៃណីមូលដ្ឋាន : កុមារដែលមកពីគ្រួសារដែលខុសពីសហគមន៍យ៉ាងហោចណាស់ ក៏ខុសភាសា សាសនា វណ្ណៈ និងកត្តាផ្សេងៗទៀតខាងវប្បធម៌ ត្រូវបានគេបដិសេធមិនឱ្យចូលរៀន។ ជួនកាលពួកគេបានចូលរៀនក្នុងប្រព័ន្ធអប់រំដែលមានស្តង់ដារសម្ភារសិក្សាដែលគ្មានគុណភាព ការបង្រៀនដែលគ្មានគុណភាព និងមានឱកាសចូលរៀននៅឧត្តមសិក្សាតិចតួច បើប្រៀបធៀបនឹងកុមារក្នុងសហគមន៍ដទៃទៀត។ លើសនេះទៀត ក្នុងសហគមន៍មួយចំនួនមានទម្លាប់ថា ការប្រឹងធ្វើការតាំងពីក្មេងដោយមិនចាំបាច់រៀនអ្វីដែលមានគុណភាពនោះទេ ក៏មានអនាគតល្អដែរ។ ទម្លាប់បែបនេះចេះតែបន្ត ពីជំនាន់មួយទៅជំនាន់មួយទៀត ដែលបង្កើតឱ្យមានវដ្តនៃភាពក្រីក្រ និងអនក្ខរភាព។ ទីបអាចជាសមាជិកគ្រួសារមួយដែលមានស្ថានភាពបែបនេះ។

ឥរិយាបថអវិជ្ជមាន : ឥរិយាបថអវិជ្ជមានចំពោះកុមារ ដែលមានសមត្ថភាព និងប្រវត្តិខុសគេ ជាឧបសគ្គតែមួយធំជាង់គេបង្អស់ក្នុងការរារាំងកុមារមិនឱ្យចូលរៀន។ ឥរិយាបថអវិជ្ជមាន អាចឃើញ មាននៅគ្រប់កម្រិតទាំងអស់ : ឪពុកម្តាយ សមាជិកសហគមន៍ សាលា និងលោកគ្រូ អ្នកគ្រូ មន្ត្រីរដ្ឋាភិបាល និងក្នុងចំណោមកុមារជួបការលំបាកក៏មានដែរ ។ ការភ័យខ្លាច បំរាម ការអៀនខ្មាស ការមិនយកចិត្តទុកដាក់ និងព័ត៌មានមិនត្រឹមត្រូវ និងកត្តាផ្សេងៗជាច្រើនទៀត អាចធ្វើឱ្យមានឥរិយាបថអវិជ្ជមានចំពោះកុមារ និងស្ថានភាពរបស់កុមារ។ សូម្បីតែគ្រួសាររបស់កុមារទាំងនេះ អាចមើលឃើញតម្លៃរបស់កុមារទាបជង់ដែរ ទើបជំរុញឲ្យកុមារគេចចេញពីទំនាក់ទំនងសង្គម ហើយក្លាយជាសមាជិកសហគមន៍ដែលគេមើលមិនឃើញ។ ស្ថានភាពបែបនេះអាចធ្វើឱ្យកុមារគេចចេញពីសាលាដោយខ្លួនឯង ទោះបីជាកុមារទាំងនោះមានសិទ្ធិ និងតម្រូវការ ដូចកុមារដទៃទៀតក៏ដោយ។ ទីបអាចជាជនរង់គ្រោះដោយសារតែឥរិយាបថអវិជ្ជមានបែបនេះ។

បរិយាកាសសាលា

បេសកកម្មរបស់សាលាគឺផ្តល់ការអប់រំប្រកបដោយប្រសិទ្ធភាពដល់កុមារគ្រប់ៗរូប ដោយផ្តល់ឱ្យកុមារនូវបំណិនជីវិត។ ប្រវត្តិសាស្ត្របង្ហាញថា សាលារបស់យើងមិនទាន់បានទទួលធនធានគ្រប់គ្រាន់ ដើម្បីអប់រំកុមារា និងកុមារី ដែលមានតម្រូវការ និងសមត្ថភាពខុសគេនៅឡើយទេ។ ការៈទេស:គ្រួសារ និងសហគមន៍អាចជាកត្តាជំរុញកុមារឱ្យនៅក្រៅសាលា។ ការពង្រឹងតែគ្រួសារ និងសហគមន៍ មិនអាចនិយាយថាគ្រប់គ្រាន់ធ្វើឱ្យសាលារបស់យើងមានបរិយាកាសដាក់បញ្ចូលគ្នាគ្រប់សមាសភាពទេ។ កត្តាជាច្រើនទៀតអាចមានក្នុងសាលារបស់យើងតែម្តង ដែលមិនលើកទឹកចិត្តកុមារឱ្យមករៀន ឬនៅរៀន ឱ្យចប់ភូមិសិក្សា។ ទីប អាចជាកុមារដែលរង់គ្រោះដោយសារកត្តាសាលារៀន។ អ្នក និងសហការីរបស់អ្នក មានតួនាទីសំខាន់ដែលត្រូវបំពេញ។ អ្នកអាចជួយផ្លាស់ប្តូរសាលារបស់អ្នក ឱ្យទៅជាកន្លែងមួយដែលកុមារគ្រប់ៗរូប អាចមករៀនបាន។ ខាង់ក្រោមនេះ ជាហេតុផលមួយចំនួនដែលកុមារមិនបានមករៀន ដោយសារសាលាមិនអំណោយផល។ **តើកត្តាសាលារៀនអ្វីខ្លះ អាចប៉ះពាល់ដល់ការចូលរៀន របស់កុមារ?**

តម្លៃចំណាយ (ផ្ទាល់ និងចំណាយក្រោមតុ) : សម្រាប់គ្រួសារក្រីក្រជាច្រើន ថ្លៃសាលា ថ្លៃប្រលង ថ្លៃវិភាគទានសាលា វិភាគទានសមាគមមាតាបិតាសិស្ស និងការចំណាយលើសៀវភៅ ប៊ិច ខ្មៅដៃ សំលៀកបំពាក់ឯកសណ្ឋានសាលា និងការចំណាយធ្វើដំណើរ អាចរារាំងកុមារ ដូចជា ទីបមិនឱ្យចូលរៀន។

ទីតាំងសាលា : នៅតាមតំបន់ជនបទ ប្រសិនបើសាលាស្ថិតនៅឆ្ងាយពីទីប្រជុំជនសហគមន៍ កុមារដូចជាទីប អាចនៅជុះដែលជាកន្លែងមានសុវត្ថិភាពជាង់ធ្វើដំណើរទៅសាលាដែលនៅឆ្ងាយពីផ្ទះ។ ទីតាំងសាលាមានឥទ្ធិពលខ្លាំងណាស់ចំពោះក្មេងស្រី។ ចម្ងាយពីផ្ទះទៅសាលាឆ្ងាយ អាចធ្វើឱ្យឪពុកម្តាយមិនបញ្ជូនកូនស្រីទៅសាលា ដោយព្រួយបារម្ភពីសុវត្ថិភាពរបស់កូន។ កុមារពិការក៏មិនអាចចូលរៀនបានដែរ ប្រសិនបើ ពុំមានការផ្តល់មធ្យោបាយធ្វើដំណើរឱ្យបានត្រឹមត្រូវ។

ពេលវេលារៀននៅសាលា : ទិបចង់រៀននៅផ្ទើយ ប៉ុន្តែមិនអាចទៅរៀនបាន ក្នុងពេលវេលាធម្មតារបស់សាលា។ ការវិភាគ និងប្រតិទិនសាលាមិនស៊ីចង្វាក់នឹងពេលម៉ោងធ្វើការរបស់ទិប ដែលជាហេតុធ្វើឱ្យ "ទិបមិនអាចរៀនជង រកច្រាក់ជង"។ លើសពីនេះទៀត ក្មេងស្រីត្រូវឈប់រៀន ព្រោះការទៅរៀនធ្វើឱ្យប៉ះពាល់ដល់ប្រយោជន៍ និងការងារផ្ទះសំបែង ដូចជាការដាំស្ល និងមើលថែទាំប្អូនតូច។។

សម្ភាររូបវន្ត : ដោយសារសាលារបស់យើងពុំមានសម្ភាររូបវន្តគ្រប់គ្រាន់ អាចជាមូលហេតុមួយធ្វើឱ្យកុមារមួយចំនួនមិនបានចូលរៀន។ ឧទាហរណ៍ ការខ្វះខាតបង្គន់អនាម័យដាច់ដោយឡែកសម្រាប់កុមារា និងកុមារី ជាពិសេសពេលកុមារីមានរដូវ អាចជំរុញឱ្យកុមារីមិនមករៀន។ លើសពីនេះទៀត ការខ្វះសម្ភាររូបវន្ត ធ្វើឱ្យប៉ះពាល់កុមារពិការយ៉ាងខ្លាំង។ នរណាទៅដឹង ប្រហែលជាទិប ជាកុមារពិការ។

ការរៀបចំត្រឹមត្រូវរបស់គ្រូ : ហេតុផលមួយក្នុងចំណោមហេតុផលទាំងឡាយដែលកុមារមានប្រវត្តិ និងសមត្ថភាពខុសគេ មិនបានចូលរៀនគឺទាក់ទងនឹងការរៀបចំមិនបានត្រឹមត្រូវរបស់សាលា និងលោកគ្រូ អ្នកគ្រូក្នុងការបង្រៀន។ លោកគ្រូ អ្នកគ្រូ មិនដឹងថា ត្រូវបង្រៀនកុមារទាំងនោះដោយរបៀបណា ព្រោះថាគ្រូទាំងនោះមិនបានទទួលការបណ្តុះបណ្តាលឱ្យបានត្រឹមត្រូវ ពុំមានគំនិត និងព័ត៌មានចាំបាច់ដែលត្រូវប្រើដើម្បីជួយកុមារទាំងនោះឱ្យរៀនបានត្រឹមត្រូវ។ ជាយថាហេតុ ទោះបីជាកុមារទាំងនោះមកសាលាក៏ដោយ ក៏ពួកគេបានទទួលការយកចិត្តទុកដាក់តិច ការអប់រំដែលពុំមានគុណភាព បើធៀបនឹងកុមារដទៃទៀត។

ចំនួនសិស្សក្នុងថ្នាក់ ធនធាន និងបន្ទុកការងារ : ចំនួនសិស្សក្នុងថ្នាក់ច្រើន ជាបញ្ហាទូទៅនៅប្រទេសជាច្រើន។ ចំនួនសិស្សក្នុងថ្នាក់ច្រើន ជាឧបសគ្គក្នុងការដាក់បញ្ចូលសិស្សគ្រប់សមាសភាពឱ្យបានចូលរៀន។ នៅប្រទេសអភិវឌ្ឍចំនួនសិស្ស ៣០ នាក់ ក្នុងមួយថ្នាក់ ត្រូវបានគេចាត់ទុកថា ជាចំនួនដ៏ច្រើន ហើយនៅប្រទេសកំពុងអភិវឌ្ឍ ចំនួនសិស្សពី ៦០ – ១០០ នាក់ ជារឿងធម្មតា។ គ្រូនៅប្រទេសកំពុងអភិវឌ្ឍន៍ត្រូវទទួលបន្ទុកការងារធ្ងន់ធ្ងរ ជាញឹកញាប់មិនសូវសប្បាយចិត្តទេ។ ជាការពិតណាស់ គ្រូគ្រប់រូបចង់បង្រៀនថ្នាក់ដែលមានសិស្សតិច ស្រួលគ្រប់គ្រង និងមានធនធានគ្រប់គ្រាន់ រួមបញ្ចូលទាំងសម្ភារ និងម៉ោងបង្រៀន។ ប៉ុន្តែចំនួនសិស្សក្នុងថ្នាក់មិនមែនជាកត្តាសារវន្តសម្រាប់ធ្វើឱ្យការសិក្សាដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាពបរាជ័យនោះទេ ប្រសិនបើ **ឥរិយាបថ**របស់អ្នកពាក់ព័ន្ធទាំងអស់**វិជ្ជមាន និងស្វាគមន៍**។ មានឧទាហរណ៍ជាច្រើនដែលកុមារមានប្រវត្តិ និងសមត្ថភាពខុសគេ ត្រូវបានគេបញ្ចូលដោយជោគជ័យក្នុងថ្នាក់ដែលមានសិស្សច្រើននាក់។ ការវិភាគខាងក្រោម បង្ហាញឧបសគ្គខាងឥរិយាបថក្នុងការសិក្សា ដោយដាក់បញ្ចូលគ្រប់សមាសភាព ជាឧបសគ្គធំ បើប្រៀបធៀបនឹងកត្តាផ្សេងទៀត ដូចជាធនធានជាដើម។

ការសិក្សាដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព ទោះបីជាសិស្សក្នុងថ្នាក់រៀនមានច្រើនជាង ១១៥ នាក់ក៏ដោយ

នៅឆ្នាំ ១៩៩៤ ការសិក្សាស្រាវជ្រាវមួយត្រូវបានធ្វើឡើងនៅក្នុងសាលា ២ នៅប្រទេសឆ្លេសូតូ។ សាលាទាំងពីរនេះ គឺជាគម្រោងអប់រំបញ្ចូលគ្រប់សមាសភាពសាកល្បងរបស់ក្រសួងអប់រំ។ សាលាមួយស្ថិតនៅជិតទីក្រុងម៉ាសេរូ ក្នុងមួយថ្នាក់ៗមានសិស្សជាមធ្យម ៥០ នាក់ មានប្រវត្តិថា បានបញ្ចូលសិស្សពិការរាងកាយឱ្យបានចូលរៀន។ សាលាមួយទៀតស្ថិតនៅតំបន់ភ្នំ ដែលត្រូវបើកឡានចំនួន ៨ ម៉ោងពីទីក្រុងទើបទៅដល់។ ថ្នាក់មួយក្នុងចំណោមថ្នាក់នានានៅក្នុងសាលានេះមានសិស្សស្រីប្រុសចំនួន ១១៥ នាក់។

គ្រូនៅក្នុងសាលាទី ១ មានឥរិយាបថអវិជ្ជមានចំពោះកម្មវិធីបញ្ចូលគ្រប់សមាសភាពចាប់តាំងពីដំបូងមកម្លេះ។ សាលានេះមានឈ្មោះល្បី ហើយពួកគេបារម្ភថា កម្មវិធីនេះនឹងតម្រូវឱ្យគ្រូចំណាយពេលច្រើនសម្រាប់ "អ្នករៀនយឺត" គ្រូចាត់ទុកថា នេះគឺជាការដាក់ទំងន់បន្ថែមមកឱ្យគ្រូជាអ្នកទទួលខុសត្រូវ។

គ្រូនៅសាលាតំបន់ភ្នំ មានការលើកទឹកចិត្តយ៉ាងខ្លាំង ដែលជាហេតុធ្វើឱ្យគ្រូទាំងនោះចំណាយពេលសំរាកថ្ងៃត្រង់ ពេលចុងសប្តាហ៍ និងពេលល្ងាច ដើម្បីជួយបង្រៀនបន្ថែមដល់កុមារដែលត្រូវការជំនួយ ទៅសួរសុខទុក្ខគ្រួសារសិស្សដល់ផ្ទះ និងជួយយកកុមារទៅមន្ទីរពេទ្យពេលត្រូវការ។ ប្រការដែលថា មានសិស្សច្រើនលើសលប់នៅក្នុងថ្នាក់មិនមែនជាឧបសគ្គក្នុងការអប់រំដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាពនោះទេ។ គ្រូអាចដោះស្រាយចំនួនសិស្សនៅក្នុងថ្នាក់តាមរបៀបមួយដែលអាចធ្វើបាន ប៉ុន្តែពេលសួរពីគំនិតរបស់គាត់ គាត់និយាយថា ការពិតគាត់ក៏ត្រូវការបង្រៀនថ្នាក់ដែលមានសិស្សពី ៥០ – ៥៥ នាក់ដែរ។

Schools for All Save the Children.
www.eenet.org.uk/bibliog/scuk/schools_for_all.shtml

ការវាយតម្លៃដោយខ្លួនឯងចំពោះការសិក្សា ដែលបញ្ចូលគ្រប់សមាសភាព

សង្ខេបអំពីឧបសគ្គរារាំងដល់ការរៀនសូត្រ ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព

- កុមារ : ភាពគ្មានផ្ទះសំបែង និងតម្រូវការធ្វើការ ជំងឺ និងភាពអត់ឃ្លាន ការចុះបញ្ជីកំណើត អំពើហិង្សា ការមានផ្ទៃពោះ
- គ្រួសារ : ភាពក្រីក្រ ទំនាស់ ការខ្វះការគាំពារ និងវប្បធម៌ មេរោគអេដស៍/ជំងឺអេដស៍
- សហគមន៍ : ការរើសអើងយេនឌ័រ ភាពខុសគ្នាខាងវប្បធម៌ និងទម្លាប់ ឥរិយាបថអវិជ្ជមាន
- សាលារៀន : តម្លៃចំណាយ ទីតាំងសាលា ពេលវេលារៀននៅសាលា សម្ភារបន្ថែម ការរៀបចំត្រឹមត្រូវរបស់គ្រូ ចំនួនសិស្សនៅក្នុងថ្នាក់ ធនធាន និងបន្ទុកការងារ។

តើមានឧបសគ្គអ្វីខ្លះដែលអ្នកបានកត់ទុកក្នុងតារាង និងពិភាក្សាគ្នាក្នុងសកម្មភាពលើកមុន និងអានឯកសារនានាលើកមុនដែរឬទេ?

បង្កើត "តារាងមេ" មួយ ហើយសរសេរឧបសគ្គទាំងឡាយដែលអ្នកបានដឹង អាន និងពិភាក្សាដូចមានបង្ហាញខាងលើ។



សកម្មភាពអនុវត្ត : ឧបសគ្គ និងឱកាស

- *អ្នកគ្រប់គ្នាគួរតែបិទភ្នែក ហើយស្រមៃថា ពួកគេគឺជាទីប ឬក៏កុមារណាម្នាក់ទៀតដែលមិនបានចូលរៀន។ ត្រូវកំណត់ឈ្មោះ អាយុ និងភេទដោយខ្លួនឯង កន្លែងរស់នៅ និងរស់នៅជាមួយអ្នកណា ស្ថានភាពរស់នៅ (ដូចជាទីប ឬយ៉ាងណា)។*

- *គិតអំពី**ឱកាស**ណាដែលអ្នកអាចចូលរៀនបាន (ឧទាហរណ៍ ប្រសិនបើសាលានៅក្បែរ) និងអ្វីដែលជា**ឧបសគ្គ**។ អ្នកអាចពិនិត្យមើលតារាងខាងលើ ឬតារាងដែលអ្នកបានរៀបចំ អំពីឧបសគ្គការពារកុមារមិនឱ្យមានឱកាសចូលរៀន។*

- *នៅលើក្រដាសដ៏ធំមួយ គូរវង្វង់ ៤ ដែលវង្វង់នីមួយៗជាន់គ្នាតាមលំដាប់។ វង្វង់ដែលតូចជាងគេបង្អស់នៅខាងក្នុងគេបង្អស់តំណាងឱ្យកុមារ វង្វង់នៅក្រៅបន្ទាប់តំណាងឱ្យគ្រួសារ វង្វង់បន្ទាប់ទៀតតំណាងឱ្យសហគមន៍ និងវង្វង់ធំជាងគេនៅក្រៅគេបង្អស់តំណាងឱ្យសាលា។ ចូរគូរវង្វង់រួចដាក់ឈ្មោះឱ្យបានត្រឹមត្រូវ។*

- *ចូរប្រើប្រាស់ពណ៌ផ្សេង ឬពុម្ពអក្សរផ្សេង ដើម្បីបង្ហាញពីឱកាស និងឧបសគ្គ។ អ្នកគ្រប់គ្នាត្រូវកត់ត្រាគំនិត របស់គេលើវង្វង់ទាំងអស់ (កុមារ គ្រួសារ សហគមន៍ និងសាលា)។ ចូរធ្វើការងារនេះជាមួយគ្នាជាក្រុម (មិនមែនធ្វើតែម្នាក់ឯងទេ)។ ទោះបីជាមានអ្នកណាម្នាក់សរសេរពីគំនិតអ្វីមួយហើយក៏ដោយ ក៏អ្នកអាចសរសេរម្តងទៀតដែរ ប្រសិនបើអ្នក មានគំនិតដូចគ្នា។*

- *បន្ទាប់ពីអ្នកគ្រប់គ្នាបានបញ្ចប់ ចូរពិនិត្យមើលតារាងដែលអ្នកទើបតែបង្កើត។ តើមានឱកាសច្រើនជាងឧបសគ្គ ឬឧបសគ្គច្រើនជាងឱកាស? តើមានឧបសគ្គច្រើនជាង ដែលអ្នកបានគិតទុកឬទេ? ឧបសគ្គទាំងនេះ គឺជាកត្តាប្រឈមមុខ ដែលត្រូវដោះស្រាយ ដើម្បីជួយកុមារដូចជា ទីប ឱ្យបានចូលរៀន។*

- *តើអ្វីជាឧបសគ្គរួមទាក់ទងនឹងកម្រិតនីមួយៗ (តើឱកាសអ្វីខ្លះដែលត្រូវបានគេកត់ត្រា ញឹកញាប់ជាងគេ)? តើនេះជាឱកាសពិតប្រាកដឬទេ? នៅពេលនេះ តើឱកាសទាំងនោះមានដែរឬទេសម្រាប់កុមារដែលមានប្រវត្តិ និងសមត្ថភាពខុសគេនៅសហគមន៍? ឬវាគ្រាន់តែជាអ្វីដែលអ្នកគិតថា ជាឱកាសដែលគួរមាននៅថ្ងៃក្រោយ? ប្រសិនបើវាគ្រាន់តែជាឱកាសដែលអ្នកចង់ឱ្យមានអ្នកត្រូវតែធ្វើសកម្មភាព ដើម្បីឱ្យឱកាសបែបនេះកើតមានឡើងពិតៗ។ ការធ្វើឱ្យមាន*

ឱកាសបែបនេះ ជាទស្សនវិស័យដែលអ្នកចង់សម្រេចឱ្យបានដើម្បីលុបបំបាត់ឧបសគ្គរារាំងកុមារមិនឱ្យចូលរៀននៅក្នុងសាលាដែលមានដាក់បញ្ចូលគ្នាគ្រប់សមាសភាព។

- តើឱកាស និងឧបសគ្គមាននៅគ្រប់កម្រិតស្មើគ្នាឬទេ? ឬផ្តុំគ្នានៅកម្រិតណាមួយច្រើនជាងកម្រិតណាមួយទៀត (ឧបសគ្គច្រើនមានក្នុងគ្រួសារ ហើយឱកាសច្រើនមានក្នុងសាលាឬយ៉ាងណា) លទ្ធផលនេះជួយអ្នកឱ្យដឹងថា ត្រូវមានជែនការអាទិភាពនៅកម្រិតមួយណា ដើម្បីជម្នះគ្រប់ឧបសគ្គទាំងអស់។

- តើមានឱកាស និងឧបសគ្គណាដែលត្រូវបានគេកត់ត្រាច្រើនដងជាងគេ ក្នុងកម្រិតនីមួយៗ? រកឱកាសបែបនេះឃើញ ជាចំណុចចាប់ផ្តើមនៃសកម្មភាពដោះស្រាយបញ្ហា។

- តើមានឧបសគ្គណាមួយដែលមាននៅគ្រប់កម្រិតឬទេ (ដូចជា តារិយាបថអវិជ្ជមាន អាចមានដូចជា ទម្លាប់អវិជ្ជមានរបស់គ្រូ គ្រួសារ និងសហគមន៍)? ប្រសិនបើមាន ត្រូវពិភាក្សារួមគ្នា ដើម្បីជម្នះឧបសគ្គទាំងនេះឱ្យបាន។



គោល ៣.២

រកកុមារដែលមិនចូលរៀនក្នុងសាលា និង មូលហេតុដែលជំរុញឱ្យកុមារនៅក្រៅសាលា

ឯកសារគោលខាងដើមជួយយើងឱ្យស្វែងយល់ពីហេតុផលដែលបណ្តាលឱ្យកុមារមួយចំនួនមិនបានចូលរៀន។ សំណួរដែលត្រូវឆ្លើយពេលនេះគឺថា "ឧបសគ្គមួយណាក្នុងចំណោមឧបសគ្គនានាដែលកើតមានក្នុងសាលា ឬសហគមន៍របស់ខ្ញុំធ្វើឱ្យកុមារនៅក្រៅសាលា?" ដើម្បីឆ្លើយសំណួរនេះ ជាដំបូង យើងត្រូវដឹងថា តើកុមារណាខ្លះក្នុងសហគមន៍មិនបានចូលរៀន? ហើយបន្ទាប់មក ទើបយើងស្វែងយល់ពីហេតុផលដែលបណ្តាលឱ្យកុមារទាំងនោះមិនបានចូលរៀន។ បន្ទាប់ពីយើងទទួលបានព័ត៌មានបែបនេះរួចហើយ យើងអាចចាប់ផ្តើមរៀបចំផែនការ និងអនុវត្តសកម្មភាពដើម្បីធានាឱ្យកុមារទាំងនេះបានចូលរៀន។

ការកំណត់ផែនទីព័ត៌មានសាលា-សហគមន៍

វិធីសាស្ត្រដែលមានប្រសិទ្ធភាពមួយ ដែលប្រើប្រាស់យ៉ាងទូលំទូលាយដើម្បីកំណត់រកកុមារដែលមិនបានចូលរៀនគឺការកំណត់ផែនទីព័ត៌មានសាលា-សហគមន៍។ ដូចជាការកំណត់ផែនទីដែរ ផែនទីព័ត៌មានសហគមន៍នេះ បង្ហាញពីទីតាំងភូមិសាស្ត្ររបស់សហគមន៍និមួយ ៗ។ ជាពិសេសជាងនេះទៀត ការកំណត់ផែនទីព័ត៌មានក៏មានបញ្ចូលចំនួនគ្រួសារនៅក្នុងសហគមន៍ ចំនួនកុមារ និងអាយុរបស់មនុស្សម្នាក់ ៗនៅក្នុងគ្រួសារនីមួយ ៗ ហើយរកហេតុផលថា តើកុមារដែលគ្រប់អាយុបានចូលរៀន ឬមិនបាន។ អ្នកអាចរៀបចំឯកសារផែនទីព័ត៌មានរបៀបនេះដោយដំណាក់កាលដូចខាងក្រោម។

១. ស្វែងរកជំនួយពីគណៈកម្មាធិការសហគមន៍ ឬអ្នកស្ម័គ្រចិត្ត ក៏ដូចជាគ្រូបង្រៀនដទៃទៀតនៅក្នុងសាលារបស់អ្នក។ នេះគឺជាសកម្មភាពដ៏ប្រសើរដើម្បីជំរុញ "ឱ្យមានការចូលរួមទាំងអស់គ្នា" ដោយមានបុគ្គលិកគ្រប់គ្នា (គ្រូបង្រៀនទាំងអស់ ជំនួយការ អ្នកមើលថែទាំកុមារ) បានចូលរួម។ ប៉ុន្តែ មិនត្រូវភ្លេចទេថា មានសមាជិកសហគមន៍ជាច្រើនទៀត ដែលអាចជួយប្រមូលព័ត៌មានដែលអ្នកត្រូវការ ដើម្បីបង្កើតផែនទីព័ត៌មានសហគមន៍។ អ្នកទាំងនោះមាន ដូចជាភ្នាក់ងារអភិវឌ្ឍសហគមន៍ អ្នកស្ម័គ្រចិត្ត ព្រឹទ្ធាចារ្យនៅក្នុងសហគមន៍ អ្នកដឹកនាំសាសនា សមាជិកសមាគមមាតាបិតាសិស្ស និងកុមារ។ (យើងនឹងនិយាយពីការចូលរួមរបស់កុមារនៅពេលក្រោយ)។ ដំណាក់កាលនេះនឹងជួយយើងឱ្យកសាងទំនាក់ទំនងកាន់តែរឹងមាំរវាងសាលា និងសហគមន៍ ដែលសាលាត្រូវផ្តល់សេវាសិក្សារៀនសូត្រដល់សិស្ស។ ការបង្កើតទំនាក់ទំនងនេះ ក៏អាចជួយសាលារបស់អ្នកឱ្យទទួលបានធនធានសហគមន៍ សម្រាប់កម្មវិធីអនុវត្តសកម្មភាព (ជាពិសេស មាន

សារៈសំខាន់ណាស់សម្រាប់សាលាដែលខ្វះធនធាន)។ សកម្មភាពបែបនេះក៏បង្ហាញថា សហគមន៍ជាម្ចាស់កម្មសិទ្ធិលើដែនទីព័ត៌មានសហគមន៍ និងកម្មវិធីសិក្សា ដែលបញ្ចូលគ្រប់សមាសភាពដែលកើតចេញពីដំណើរការធ្វើដែនការ និងដែនទីព័ត៌មានសហគមន៍បែបនេះ។

២. រៀបចំការប្រជុំណែនាំមួយសម្រាប់អ្នកស្ម័គ្រចិត្តជួយប្រមូលព័ត៌មាន និងជួយរៀបចំដែនទីព័ត៌មានសហគមន៍។ និយាយច្រាប់ពួកគេអំពីហេតុផលដែលថា កុមារទាំងអស់ត្រូវតែមានឱកាសចូលរៀនដូចៗគ្នា ច្រាប់អំពីផលប្រយោជន៍នៃការដាក់កុមារគ្រប់ប្រភេទ និងមានសមត្ថភាពចំរុះឱ្យរៀនជាមួយគ្នា និងច្រាប់អំពីពីសារៈសំខាន់នៃដែនទីព័ត៌មានសហគមន៍សម្រាប់ស្វែងរកកុមារដែលមិនបានចូលរៀន ហើយ ត្រូវធ្វើយ៉ាងណានាំកុមារឱ្យចូលរៀន និងសប្បាយជាមួយការសិក្សា។

៣. នៅក្នុងពេលប្រជុំណែនាំនោះ ឬពេលប្រជុំលើកក្រោយ។ទៀត រៀបចំដែនទីសហគមន៍មួយឱ្យបាន។ សហគមន៍ខ្លះប្រហែលជាមានដែនទីរួចហើយ ហើយសហគមន៍មួយចំនួនទៀតមិនមានទេ។ កំណត់សម្គាល់ព្រំប្រទល់សំខាន់ៗ (ផ្លូវថ្នល់ ប្រភពទឹក កន្លែងសំខាន់ៗ ដូចជា មណ្ឌលសុខភាពភូមិ កន្លែងគោរពបូជាសាសនា។ ល។ និងផ្ទះទាំងអស់នៅក្នុងសហគមន៍។

៤. បន្ទាប់មកទៀត ធ្វើអង្កេតគ្រួសារមួយ ដើម្បីកំណត់ចំនួនសមាជិកក្នុងគ្រួសារដោយមាន កត់ត្រាភេទ អាយុ និងកម្រិតវប្បធម៌នៃសមាជិកគ្រួសារ។ ព័ត៌មានអំពីកម្រិតអប់រំរបស់កុមារអាចជួយអ្នកក្នុងការកំណត់គោលដៅរបស់កុមារដែលមិនបានចូលរៀននៅសាលា ហើយព័ត៌មានបែបនេះសម្រាប់មនុស្សពេញវ័យអាចបញ្ជាក់ថា តើឪពុកម្តាយណាខ្លះ ដែលបានទទួលផលប្រយោជន៍ពីកម្មវិធីអក្ខរកម្ម។ នៅប្រទេសឥណ្ឌា និងប៉េណាំង (អាប្រ៊ិកខាង់លិច) កម្មវិធីបែបនេះមានសារៈសំខាន់ណាស់ ព្រោះកម្មវិធីបែបនេះជួយឱ្យឪពុកម្តាយយល់ដឹងពីសារៈសំខាន់នៃការសិក្សាសម្រាប់ខ្លួនគេ និងកូន។ (ជាពិសេសកូនស្រី)។ ការអង្កេតគ្រួសារអាចធ្វើបានតាមរបៀបខុសៗគ្នាច្រើនយ៉ាងណាស់ ដូចជាការទៅសាកសួរដល់ផ្ទះ (ដែលអាចប្រើដើម្បីលើកទឹកចិត្តឪពុកម្តាយឱ្យបញ្ជូនកូនទៅសាលារៀន) ការសម្ភាសជាមួយអ្នកដែលមានចំណេះដឹងទូលំទូលាយ (អាចជា កុមារក៏បាន) ឬប្រើច្រាស់ឯកសារដែលមានស្រាប់។ នៅប្រទេសថៃ ព័ត៌មានជំរឿនតាមភូមិ ត្រូវបានគេប្រើច្រាស់ដើម្បី កត់សម្គាល់សមាជិកក្នុងគ្រួសារ និងអាយុ ហើយបន្ទាប់មកយកទៅប្រៀបធៀប ជាមួយនឹងឯកសារចុះឈ្មោះចូលរៀន ដើម្បីដឹងថា តើកុមារណាដែលមិនបានចូលរៀន។

៥. នៅពេលដែលព័ត៌មានទាំងអស់ត្រូវប្រមូលរួចហើយ រៀបចំដែនទីសហគមន៍ចុងក្រោយដោយបង្ហាញពីចំនួនគ្រួសារ សមាជិកក្នុងគ្រួសារ អាយុ និងកម្រិតវប្បធម៌។ បន្ទាប់មក ផ្សព្វផ្សាយដែនទីព័ត៌មានសហគមន៍នេះជាមួយអ្នកដឹកនាំសហគមន៍ ដើម្បីកំណត់ថា តើកុមារណាខ្លះ ដែលមិនបានចូលរៀន និងពិភាក្សារកហេតុផលមួយចំនួនដែលគ្រួសារទាំងនេះមិនបានបញ្ជូនកូនទៅរៀន។ ដោយមានព័ត៌មានទាំងនេះ យើងអាចកសាងដែនការសម្រាប់ធ្វើសកម្មភាពបាន។

កំណត់ផែនទីព័ត៌មានសហគមន៍របស់គម្រោង Lok Jumbish (LJ) នៅក្នុងខេត្ត Rajasthan, ប្រទេសឥណ្ឌា

គម្រោង **LJ** *ក៏ជាគរមនុស្សមួយក្រុមមានប្រុសមានស្រីដែលសុទ្ធតែជាអ្នកមានការប្តេជ្ញាចិត្តខ្ពស់ ហើយជ្រើសរើសដោយសហគមន៍។ បន្ទាប់ពីការបណ្តុះបណ្តាលរួច ពួកគេបានរៀបចំការអង្កេតមួយ ដោយកត់ត្រាកម្រិតវប្បធម៌របស់សមាជិកគ្រួសារគ្រប់រូបនៅក្នុងគ្រួសារនីមួយ។។ ផែនទីព័ត៌មានសហគមន៍ត្រូវបានរៀបចំដោយបង្ហាញពីកម្រិតវប្បធម៌របស់សមាជិកគ្រប់រូបនៅក្នុងសហគមន៍។ ភូមិទាំងមូលនាំគ្នាវិភាគពីហេតុផលដែលកុមារមិនបានចូលរៀន។ នៅកន្លែងជាច្រើន ទោះបីជាមានសាលាហើយក៏ដោយ ក៏សាលាទាំងនោះមិនអាចដំណើរការបានល្អដែរដោយសារការខ្វះគ្រូ និងធនធានចាំបាច់មួយចំនួន។ កុមារីមិនបានចូលរៀនទេ ពីព្រោះឪពុកម្តាយមិនអនុញ្ញាតឱ្យកូនស្រីធ្វើដំណើរផ្លូវឆ្ងាយទៅ សាលា។ សាលាភាគច្រើនមានតែគ្រូប្រុសប៉ុណ្ណោះ។ ដើម្បីជាការឆ្លើយតប ក្រុមតំណាងភូមិ ក្រុមស្ត្រី និង គ្រូបង្រៀនមូលដ្ឋានចាប់ផ្តើមអនុវត្តនូវសកម្មភាពប្លែកគ្នាជាច្រើន ដូចជា ត្រួតពិនិត្យការចុះឈ្មោះ ចូលរៀន និងការគង់វង្សរៀនរហូតចប់ថ្នាក់ ចាប់ផ្តើមមជ្ឈមណ្ឌលអប់រំក្រៅប្រព័ន្ធ ជួសជុល ឬសង់អគារ សិក្ខាប្ទី កម្មវិធី សុខភាពសិក្សា និងវេទិកាសម្រាប់កុមារីជំទង់។ ចំណែកការអប់រំក្នុងប្រព័ន្ធ ការកែលំអ រួមមាន ការបណ្តុះបណ្តាលគ្រូអំពីខ្លឹមសារ និងទឹកចិត្តបង្រៀន ការរៀបចំសៀវភៅ រៀបចំកិច្ចតែងការបង្រៀនឱ្យបានត្រឹមត្រូវ និងផ្គត់ផ្គង់ធនធាន និងសម្ភារៈរៀន និងបង្រៀនដែលមានគុណភាពនៅក្នុងតំបន់ដែលកំពុងតែអនុវត្តគម្រោង។ គម្រោង* **LJ** *ក៏បានបង្កើតឱ្យមាន ជាបណ្តាញការងារនៃមជ្ឈមណ្ឌលអប់រំក្រៅប្រព័ន្ធ ដោយជ្រើសរើសអ្នកចេះដឹងនៅក្នុងមូលដ្ឋានធ្វើជាគ្រូ។*

ប្រភព **: Mathur R. (2000) Taking Flight. Education for All Innovation Series No. 14. UNESCO Principal Regional Office for Asia and the Pacific, Bangkok.z**

ការចូលរួមរបស់កុមារនៅក្នុងការកំណត់ផែនទីព័ត៌មានសហគមន៍

ដំណើរការកំណត់ព័ត៌មានសហគមន៍គឺជាសកម្មភាព"ពីសហគមន៍ទៅកុមារ"។ និយាយម្យ៉ាងទៀត តើយើងត្រូវប្រើប្រាស់សហគមន៍ដោយរបៀបណាដើម្បីរកកុមារដែលមិនបានចូលរៀន។ តាមពិត សកម្មភាពកំណត់ព័ត៌មានសហគមន៍អាចធ្វើបានដោយវិធី "កុមារជាមួយកុមារ"។ កុមារទាំងអស់អាចកំណត់ព័ត៌មានសហគមន៍ ដោយកត់សម្គាល់កុមារណាខ្លះដែលបានចូលរៀន និងកុមារណាខ្លះដែលមិនបានចូលរៀន។[1]

[1]This section including the process of creating the map were adapted from "Children as Community Researchers," UNICEF Web site: Teachers Talking about Learning: www.unicef.org/teachers/researchers/basemap.htm. Readers are strongly encouraged to access this Web site, see examples of children's maps, and learn more!

សកម្មភាពកំណត់ព័ត៌មានសហគមន៍ដោយប្រើកុមារគឺជាសកម្មភាព ដែលមានប្រសិទ្ធភាពក្នុងការប្រែមែប្រមូលកុមារឱ្យបានចូលរៀន។ ពួកគេជាអ្នកនាំមុខក្នុងការកត់សម្គាល់កុមារដែលមិនបានមកសាលា និងជួយជំរុញឪពុកម្តាយកុមារទាំងនោះឱ្យបញ្ជូនកូនទៅរៀន។ ឧទាហរណ៍ គម្រោងកុមារនៅប្រទេសថៃ កុមារដែលមានអាយុ ៤-៦ ឆ្នាំ ធ្វើការជាមួយគ្នាដើម្បីគូរផែនទីសហគមន៍នៅជុំវិញសាលា ហើយរកមើលថាតើកុមារណារស់នៅក្នុងគ្រួសារមួយណា ហើយកុមារនោះបានចូលរៀន ឬមិនបាន។ បុគ្គលិកក្នុងគម្រោងម្នាក់បានកត់សម្គាល់ថា "ប្រសិនបើអ្នកអាចរកក្មេងបីនាក់ដែលជឿថា កុមារម្នាក់នេះរស់នៅក្នុងផ្ទះនេះ ពេលនោះការសន្និដ្ឋានបែបនេះ គឺពិតជាត្រឹមត្រូវហើយ"។ ពួកគេអាចធ្វើជាអ្នកដឹកនាំក្នុងការកំណត់ព័ត៌មានសហគមន៍។ ពួកគេអាចរកទិន្នន័យ ដែលមានតម្លៃអំពីសហគមន៍របស់គេល្អជាងដែលគេអាចរំពឹងទុកទៅទៀត។

វិធីសាស្ត្រមួយដើម្បីចាប់ផ្តើមគឺឱ្យកុមារគូរផែនទីរបស់សហគមន៍ ដែលនឹងជួយកុមារក្នុងការសម្រេចថា តើព័ត៌មានអ្វីខ្លះដែលត្រូវដាក់នៅក្នុងផែនទីនោះ។ លទ្ធភាពក្នុងការគូរផែនទីឱ្យបានត្រឹមត្រូវគឺអាស្រ័យលើ អាយុកុមារ។ ប្រសិនបើស្មាដៃ និងរបៀបគូរដែលខុសគ្នារបស់កុមារត្រូវបានគេទទួលយក កុមារគ្រប់អាយុទាំងអស់នឹងអាចគូរបានផែនទីសហគមន៍ដែលមានលក្ខណៈរួមមួយ។

ប្រសិនបើសហគមន៍មិនទាន់មានផែនទីទេ គួររៀបចំផែនទីមួយដោយចាប់ផ្តើមពីបន្តិចបន្តួចទៅ។ ជាទូទៅ ផែនទីសហគមន៍គួរតែគូរលើក្រដាសឱ្យបានធំបន្តិចដើម្បីឱ្យកុមារអាចដៅចំណុចផ្ទះរបស់គេ និងផ្ទះមិត្តភក្តិ។ ផែនទីនេះគឺជាការចូលរួមចំណែកដ៏ធំធេងរបស់កុមារសម្រាប់អភិវឌ្ឍសហគមន៍។ ការរៀបចំផែនទីគឺធ្វើឡើងដោយរបៀបដូចខាងក្រោម :

១. ចាប់ផ្តើមដោយឱ្យក្មេងមកជួបជុំគ្នា ហើយកត់ត្រានូវទីកន្លែងសំខាន់នៅក្នុងសហគមន៍ (ដូចជា សាលា វត្តអារាម លំនៅឋាន មណ្ឌលសុខភាព ហាងទំនិញ។ល។) ហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗ (ដូចជា ផ្លូវថ្នល់ ភ្នំ ទន្លេ) និងទីកន្លែងផ្សេងទៀត ដែលប្រជាជននៅក្នុងសហគមន៍តែងជួបជុំគ្នា (ដូចជាវាលស្រែ ត្រពាំង អណ្តូងទឹករួមជាដើម)។

២. កាត់ក្រដាសកាតុងជាច្រើនបំណែក ហើយគូរទីកន្លែងសំខាន់ៗដែលបានរៀបរាប់ខាងដើម នៅលើចំរៀកក្រដាសទាំងនោះ។ ប្រសិនបើគ្មានក្រដាសទេ គេអាចប្រើសម្ភារផ្សេងទៀត ដូចជា បន្ទះក្តារដុំថ្ម ដុំឈើ ខ្សែ ជាដើមដើម្បីសម្គាល់ទីតាំងទាំងនោះ។ ប៉ុន្តែត្រូវធ្វើយ៉ាងណាឱ្យសិស្សចាំឱ្យច្បាស់ថាវត្ថុអ្វីតំណាងឱ្យទីតាំងអ្វី (ឧទាហរណ៍ ថ្មតំណាងឱ្យភ្នំជាដើម)។

៣. ឱ្យកុមារនិយាយប្រាប់ថាតើក្នុងចំណោមទីតាំងទាំងអស់ ទីតាំងមួយណាសំខាន់ជាងគេនៅក្នុងសហគមន៍ ដូចជា សាលាជាដើម។ ឱ្យកុមារដាក់សញ្ញាពិសេសនៅលើរបស់ដែលសំខាន់ជាងគេ។ ធ្វើយ៉ាងណាឱ្យមានលក្ខណៈលេចធ្លោជាងទីតាំងដទៃទៀត។ វាគឺជា "ចំណុចបង្គោល" (កន្លែងដែលសមាជិកគ្រប់រូបអាចធ្វើជាកន្លែងចំណាំសម្រាប់រកកន្លែងផ្សេងទៀតក្នុងសហគមន៍)។

៤. ដាក់កំណាត់ ក្រដាសកាតុងក្រាស់ ឬបន្ទះក្តារនៅលើដី ឱ្យកុមារទាំងអស់មកនៅជុំវិញរបស់ដែលដាក់លើដីនោះ ហើយឱ្យកុមារដៅ "ចំណុចបង្គោលនៅលើទីតាំងទាំងនោះ" (ដូចជាសាលា) ដូច្នេះកុមារអាចសម្គាល់ទីតាំងដែលត្រូវដាក់ផ្ទះរបស់គេ។ ឧទាហរណ៍ ប្រសិនបើសាលានៅក្បែរផ្ទះ ឬនៅកណ្តាលសហគមន៍ ដៅឱ្យចំកន្លែងនោះ។ ប្រសិនបើនៅឆ្ងាយ ដាក់វាលើជាយកំណាត់ ឬបន្ទះឈើនោះដើម្បីបង្ហាញថា វាមិននៅកណ្តាលសហគមន៍ ឬក្បែរផ្ទះប្រជាជនទេ។

៥. ឱ្យកុមារសម្គាល់ទីតាំងផ្សេងទៀតនៅក្នុងសហគមន៍។ គូរ ឬដាក់សញ្ញាសម្គាល់ទីតាំងកន្លែងទាំងអស់នោះ ដោយមានដាក់ព្រិដែនសម្រាប់កន្លែងនីមួយៗផងដែរ។

៦. ទាំងអស់គ្នាត្រូវកំណត់ភូមិសាស្ត្រសំខាន់ៗរបស់សហគមន៍ (ដូចជា ផ្លូវ វាលស្រែ ភ្នំ ទន្លេ) ហើយដាក់បន្ថែមនៅក្នុងដែនទី។ កុមារទាំងអស់ត្រូវឯកភាពគ្នាពីទីតាំងរបស់ភូមិសាស្ត្រទាំងអស់នេះ។ ឱ្យកុមារដើរជុំវិញដែនទីនេះ ដើម្បីពិនិត្យមើលឱ្យបានច្បាស់។ ប្រសិនបើកុមារបានរៀបចំដែនទីដោយខ្លួនឯងផ្ទាល់ ឱ្យកុមារផ្ទៀងផ្ទាត់ជាមួយនឹងដែនទីដែលធ្វើរួមគ្នានេះផង។

៧. ពេលដែលកុមារទាំងអស់យល់ស្របពីអគារ ទីតាំងភូមិសាស្ត្រ និងកន្លែងសំខាន់ផ្សេងៗទៀតនៅក្នុងសហគមន៍ដែលបានកំណត់នៅលើកំណាត់ ឬបន្ទះក្តារ ហើយឱ្យកុមារយកថ្មាំ ឬ ហ្វឺតមកគូរតាមកន្លែងដែលបានដាក់សម្គាល់នោះដើម្បីឱ្យទីតាំងដែលបានកំណត់នោះស្ថិតនៅជាអចិន្ត្រៃយ៍នៅលើកំណាត់ ឬបន្ទះឈើនោះ។

៨. ដែនទីនេះគឺជាដែនទីរបស់សិស្សទាំងអស់គ្នា ដូច្នេះ ត្រូវមានភាពសំបូរបែប ដោយទីតាំងសំខាន់ៗអាចដាក់បន្ថែមបាននៅពេលសិស្សនឹកឃើញ។ ដើម្បីធ្វើដែនទីឱ្យមានលក្ខណៈពេញលេញ និងកំណត់រកកុមារដែលនៅក្រៅសាលាឱ្យឃើញ កុមារត្រូវប្រើចំរៀកក្រដាសតូចៗដាក់លើដែនទីនោះ។ ក្រដាសតូចៗទាំងនោះតំណាងឱ្យខ្លឹមសារលំអិតផ្សេងទៀត។ ខ្លឹមសារទាំងនោះមាន :

- ◆ ផ្ទះរបស់កុមារទាំងអស់នៅក្នុងសហគមន៍ អាយុរបស់កុមារទាំងអស់ និងថាតើកុមារនោះ បានចូលរៀន ឬមិនបាន។
- ◆ ផ្ទះរបស់មនុស្សដែលមានសារៈសំខាន់ដល់គ្រួសាររបស់កុមារ។
- ◆ ទីកន្លែងដែលកុមារជួបជុំគ្នាលេង។
- ◆ កន្លែងដែលកុមារមិនគួរទៅ ដូចជាកន្លែងដែលអាចមានអំពើហិង្សា ឬល្បែងការ
- ◆ កន្លែងដែលកុមារចូលចិត្ត និងមិនចូលចិត្ត
- ◆ កន្លែងដែលកុមារអាចទៅតែម្នាក់ឯង ទៅជាមួយឪពុកម្តាយ បងប្អូន មិត្តភក្តិ និងមនុស្សពេញវ័យផ្សេងទៀត។

៩. ផ្លូវធ្វើដំណើរ (ជាពិសេសផ្លូវដែលគេធ្វើដំណើរទៅ និងមកសាលា) និងមធ្យោបាយធ្វើដំណើរ (ដូចជា ដើរ កង់ ឬយានដំនិះផ្សេងទៀត)។ នាំកូនដើរជុំវិញសហគមន៍ដើម្បីឱ្យកូនយល់ដឹងពីសហគមន៍ឱ្យបានកាន់តែច្បាស់ ហើយបំពេញព័ត៌មាននៅក្នុងដែនទីឱ្យបានកាន់តែត្រឹមត្រូវ។ នៅពេលកំពុងដើរជុំវិញសហគមន៍ ឬនៅពេលជួបប្រជុំគ្នានៅទីកន្លែងនានាត្រូវឱ្យមានការចូលរួមរបស់មនុស្សចាស់ដើម្បីនិយាយជាមួយកុមារ ហើយធ្វើការកែតម្រូវដែនទីឡើងវិញ។ ធ្វើបែបនេះដើម្បីឱ្យមានការចូលរួមរបស់មនុស្សចាស់ ដើម្បីស្វែងរកកុមារដែលមិនបានចូលរៀន និងបង្កើតឱ្យមានការគាំទ្រសម្រាប់ការអនុវត្តកម្មវិធី។

បន្ទាប់ពីដែនទីត្រូវបានរៀបចំហើយ សិស្សរបស់អ្នកអាចសម្គាល់ឃើញកុមារនៅក្នុងសហគមន៍ ដែលមិនបានចូលរៀន និងដឹងថាតើកុមារទាំងអស់នោះមកពីគ្រួសារមួយណា។ កូនរបស់អ្នកធ្វើការជាមួយគ្រួឪពុកម្តាយ អ្នកដឹកនាំសហគមន៍ អាចជួយលើកទឹកចិត្តឪពុកម្តាយនៅក្នុងសហគមន៍ឱ្យបញ្ជូនកូនទៅសាលា។ នៅប្រទេសនេប៉ាល់ នៅក្នុងគម្រោងនៃប្រព័ន្ធគ្រប់គ្រងព័ត៌មានអប់រំសហគមន៍ ដែលទទួលការឧបត្ថម្ភដោយអង្គការសង្គ្រោះកុមារអង់គ្លេស កុមារដើរទៅតាមគ្រួសារ ដែលមានកុមារមិនបានចូលរៀន។ ពួកគេនិយាយជាមួយឪពុកម្តាយកុមារទាំងនោះពីការលំបាកដែលគាត់ជួបប្រទះ និងវិធីដោះស្រាយដើម្បីឱ្យកុមារទាំងនោះចូលរៀន។

ដែនទីព័ត៌មានសហគមន៍ត្រូវតែកែតម្រូវជារឿយៗ។ ដើម្បីឱ្យការកត់សម្គាល់រកកុមារដែលមិនបានចូលរៀនកាន់តែមានប្រសិទ្ធភាព។ ការកែតម្រូវដែនទីជាបន្តបន្ទាប់បែបនេះ វានឹងក្លាយទៅជាទម្លាប់ ហើយពេលនោះការរៀបចំព័ត៌មានសហគមន៍នឹងក្លាយទៅជាផ្នែកមួយនៃកម្មវិធីសិក្សារបស់កុមារ។ ជាពិសេសទៀតដែនទីត្រូវដាក់នៅទីកន្លែងដែលសហគមន៍ងាយមើលឃើញ ដូចជា នៅមណ្ឌលព័ត៌មានសហគមន៍ ឬកន្លែង

ជួបប្រជុំនានា ដើម្បីឱ្យមនុស្សពេញវ័យទាំងនោះមានយោបល់ជួយកែតម្រូវ។ ដែនទីនេះអាចជួយដល់ដំណើរការនៃការប្រែមែប្រមូលកុមារឱ្យបានចូលរៀន។ នៅក្នុងតំបន់អនាធិបតេយ្យប៉ែកខាងជើងភាគខាងកើតនៃប្រទេសថៃ មេភូមិប្រើប្រាស់ការស្ទាបស្ទង់មតិ និង ដែនទីព័ត៌មានសហគមន៍ដើម្បីរកកុមារដែលមិនបានចូលរៀន ព្រោះពួកគេពុំមានចុះបញ្ជីកំណើត។ មេភូមិទាំងនោះត្រូវទៅដល់ផ្ទះកុមារ ហើយជួនកាលទៀតត្រូវទៅដល់សាលាស្រុក ឬសាលាខេត្តដើម្បីជួយដល់ដំណើរការចុះឈ្មោះកុមារទាំងនោះនៅក្នុងបញ្ជីកំណើតដើម្បីឱ្យពួកគេបានចូលរៀន។

ការស្វែងរកមូលហេតុដែលធ្វើឱ្យកុមារមិនបានចូលរៀន

ធ្វើការងារជាមួយសហការី ឬកូនសិស្សរបស់អ្នក អ្នកអាចកត់សម្គាល់ឃើញកុមារដែលមិនបានចូលរៀននៅក្នុងសាលានៅក្នុងសហគមន៍របស់អ្នក ហើយអ្នកក៏អាចប្រមូលបានព័ត៌មានមួយចំនួនដែលធ្វើឱ្យកុមារទាំងនោះ មិនបានចូលរៀន។ សំណួរសំខាន់ៗមួយចំនួនដែលអ្នកត្រូវឆ្លើយមានដូចខាងក្រោមនេះ : តើកុមារដែលមិនបានចូលរៀនស្ថិតក្នុងស្ថានភាពលំបាកអ្វីខ្លះ បើប្រៀបធៀបទៅនឹងកុមារដែលបានចូលរៀន?

ដូចដែលយើងបានរៀននៅខាងដើមរួចហើយ កត្តាដែលធ្វើឱ្យកុមារមិនបានចូលរៀនខ្លះអាចមើលឃើញ ដូចជា ពិការរូបកាយ និងគ្មានបញ្ជា។ កត្តាខ្លះទៀតមើលមិនឃើញ ដូចជា ការយកចិត្តទុកដាក់មិនបានជិតដល់ ការខ្វះការថែទាំ និងគាំពារ ការខ្វះអាហារទ្រទ្រង់សុខភាព និងកត្តាមួយចំនួនទៀតដែលត្រូវបានគេទទួលស្គាល់ជាទូទៅ ដូចជា តួនាទីយែនឌ័រ ឬការទទួលខុសត្រូវរបស់កុមារក្នុងគ្រួសារ។



សកម្មភាពអនុវត្ត : កំណត់ប្រវត្តិរូបរបស់កុមារ

ប្រវត្តិរូបរបស់កុមារ ជាឧបករណ៍សំខាន់ដើម្បីជានាឱ្យមានការអប់រំដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាពក្នុងថ្នាក់រៀន។ វិធីនេះត្រូវបានប្រើនៅបណ្តាប្រទេសជាច្រើន ដូចជា អាហ្វ្រិក អាមេរិកណ្តាល អាស៊ីខាងត្បូង និងអាស៊ីកណ្តាល។ ប្រវត្តិរូបកុមារអាច :

- ជួយគ្រូក្នុងការកត់សម្គាល់ហេតុផលដែលកុមារមិនបានរៀន ឬហេតុផលដែលធ្វើឱ្យកុមារងាយបោះបង់ការសិក្សា។
- បង្ហាញពីភាពខុសប្លែកគ្នារបស់កុមារនៅក្នុងសហគមន៍។ លក្ខណៈខុសគ្នារបស់កុមារ រួមមានស្ថានភាពរបស់កុមារ គ្រួសារ និងការលំបាកដែលកុមារប្រឈមមុខ។
- ជួយបង្កើតកម្មវិធី ដើម្បីជម្នះរាល់ឧបសគ្គ ដែលធ្វើឱ្យកុមារមិនបានចូលរៀន។

ប្រវត្តិរូបរបស់កុមារបានរៀបចំ និងប្រើនៅប្រទេសថៃ នៅក្នុងប្រព័ន្ធគ្រប់គ្រងព័ត៌មានសាលា និងនៅប្រទេសភីលីពីនប្រើជាប្រព័ន្ធសម្រាប់តាមដានការរៀនសូត្ររបស់សិស្ស (STS)។ ប្រព័ន្ធទាំងពីរជួយបង្កើតប្រព័ន្ធសាលាកុមារមេត្រី។ នៅបង់ក្លាដែស និងប្រទេសមួយចំនួនទៀតនៅអាស៊ីកណ្តាល និងអាស៊ីខាងត្បូង ប្រវត្តិរបស់កុមារត្រូវបានប្រើជាប្រពន្ធ័ព័ត៌មានគ្រប់គ្រងមណ្ឌលអប់រំកុមារតាមសហគមន៍ (C-EMIS)។ អ្នកដឹកនាំសហគមន៍ប្រមូលព័ត៌មាន និងទិន្នន័យអំពីកុមារនៅតាមគ្រួសារនៅក្នុងសហគមន៍។ អ្នកដឹកនាំសហគមន៍កំណត់អត្តសញ្ញាណកុមារដែលជិតគ្រប់អាយុ ឬគ្រប់អាយុចូលរៀន ហើយណែនាំគ្រួសារឱ្យបញ្ជូនកូនទៅសាលារៀន។ ដោយប្រើវិធីនេះ ប្រើប្រព័ន្ធ (C-EMIS) និង (STS) នៅតាមសហគមន៍ (មិនត្រឹមតែនៅតាមសាលាប៉ុណ្ណោះទេ)។ ប្រើវិធីនេះអាចកំណត់អត្តសញ្ញាណកុមារនៅក្រៅសាលា និងកុមាររៀននៅសាលា ហើយក៏អាចកំណត់អត្តសញ្ញាណកុមាររៀនខ្សោយផងដែរ។ ដើម្បីបង្កើតប្រវត្តិរូបរបស់កុមារណាម្នាក់ត្រូវអនុវត្តតាមវិធីខាងក្រោម :

១. យោងតាមព័ត៌មានដែនទីសហគមន៍ ចុះបញ្ជីកុមារគ្រប់រូបដែលមិនបានចូលរៀន។

២. ផ្លាស់ប្តូរយោបល់ជាមួយសហការីរបស់អ្នក ឬជាមួយអ្នកដែលបានជួយរៀបចំដែនទីព័ត៌មានសហគមន៍អំពីឧបសគ្គដែលធ្វើឱ្យកុមារមិនបានចូលរៀន។ អ្នកអាចមើលកត្តានានា ដែលអ្នកបានកត់ត្រាទុកកាលពីមុន ហើយបែងចែកកត្តាទាំងនេះទៅតាមក្រុមនីមួយៗដូចជា សាលា សហគមន៍ គ្រួសារ និងកុមារ។ អ្នកត្រូវចាំថា មូលហេតុខ្លះអាចបណ្តាលមកពីកត្តារួមគ្នា។ កត្តាខ្លះមិនមែនជាមូលហេតុផ្ទាល់ ដែលធ្វើឱ្យកុមារមិនបានចូលរៀន តែអ្នកក៏ត្រូវតែពិនិត្យមើលឱ្យច្បាស់អំពីមូលហេតុផងដែរ។

៣. បន្ទាប់មក ប្រើច្រាស់កត្តាទាំងនេះ ដើម្បីបង្កើតសំណួរ ដែលពេលអ្នកឆ្លើយអាចធ្វើឱ្យអ្នកយល់ដឹងពីមូលហេតុដែលធ្វើឱ្យកុមារមិនបានចូលរៀន។ ខាងក្រោមនេះគឺជាសំណួរគំរូមួយចំនួនដែលបានប្រើរួចហើយនៅប្រទេសភីលីពីន និងថៃ ដើម្បីស្វែងយល់អំពីស្ថានភាពកុមាររៀនពូកែតែមានប្រវត្តិ និងសមត្ថភាពខុសៗគ្នា[2]។ សំណួរទាំងអស់នេះត្រូវបានរៀបចំ ដើម្បីលាតត្រដាងបង្ហាញឱ្យឃើញច្បាស់អំពីឧបសគ្គនានាដែលបានពិភាក្សាពីខាងដើម និងមានឥទ្ធិពលលើការចូលរៀន ឬមិនចូលរៀន និងការចោះបង់ចោលការសិក្សារបស់កុមារ។ **អ្នកអាចបង្កើតតារាងសំណួររបស់អ្នក ដោយផ្អែកលើមូលហេតុដែលអ្នកមាននៅក្នុងសហគមន៍របស់អ្នក**។

---

[2] Examples of the Child Profile from other countries such as El Salvador and Uganda can be found in: Toolkit for Assessing and Promoting Equity in the Classroom, produced by Wendy Rimer et al. Edited by Marta S. Maldonado and Angela Aldave. Creative Associates International Inc., USAID/EGAT/WID, Washington DC. 2003.

ឧបសគ្គ : ភាពខុសគ្នាខាងវប្បធម៌ និងទំនៀមទម្លាប់មូលដ្ឋាន

- តើកុមារជាជនជាតិអ្វី ឬមកពីក្រុមជនជាតិភាគតិចណា?
- តើកុមារកាន់សាសនាអ្វី?

ឧបសគ្គ : ការរើសអើងយេនឌ័រ

- តើកុមារមានភេទអ្វី?
- តើកុមារមានអាយុប៉ុន្មានឆ្នាំ?

ឧបសគ្គ : ការចុះបញ្ជីកំណើត

- តើកុមារមានសំបុត្រកំណើតឬទេ?

ឧបសគ្គ : ពេលធ្វើការ និងពេលសិក្សា (តម្រូវការធ្វើការ)

- តើកុមារមានធ្វើការដើម្បីរកប្រាក់ចំណូលឬទេ?

ឧបសគ្គ : ឥរិយាបថអវិជ្ជមាន ខ្លាចមានអំពើហិង្សា

- បើកុមារធ្លាប់ចូលរៀនដែរ តើការសិក្សារបស់កុមារយ៉ាងណាដែរ?
- បើកុមារធ្លាប់ចូលរៀនដែរ តើវត្តមានរបស់កុមារយ៉ាងណាដែរ?
- បើកុមារធ្លាប់ចូលរៀនដែរ តើកុមារឧស្សាហ៍ចោះបង់ការសិក្សាឬទេ?

ឧបសគ្គ : ជំងឺ និងការហត់ហែវ មេរោគអេដស៍/ជំងឺអេដស៍ ការមានផ្ទៃពោះ

- តើកុមារមានសុខភាព និងការហូបចុកបែបណាដែរ?

ឧបសគ្គ : បរិក្ខារសាលា និងទីតាំងសាលា

- តើពិការភាពអាចរារាំងកុមារមិនឱ្យទៅសាលាបានដោយសារតែសាលាពុំមានបរិក្ខារសម្រាប់សិស្សពិការប្រើឬយ៉ាងណា?
- តើផ្ទះរបស់កុមារនៅឆ្ងាយពីសាលាឬទេ? (ចម្ងាយផ្លូវ និងរយៈពេលធ្វើដំណើរ)

ឧបសគ្គ : ការគាំពារ និងថែទាំ ទំនាស់

- តើឪពុកម្តាយរបស់កុមារមានអាយុប៉ុន្មានឆ្នាំ?
- តើកុមារមានទាំងឪពុកទាំងម្តាយឬទេ? ឬមានតែឪពុក ឬតែម្តាយ ឬគ្មានទាំងឪពុកទាំងម្តាយ?

- តើឪពុកម្តាយរបស់កុមារមានកម្រិតវប្បធម៌ត្រឹមកម្រិតណាដែរ?
- តើមានសមាជិកនៅក្នុងគ្រួសារណាដែលធ្លាប់ចោះបង់ការសិក្សាឬទេ? មូលហេតុអ្វី?
- តើឪពុកម្តាយកុមារនៅតែរស់នៅជាមួយគ្នាឬទេ?
- តើកុមាររស់នៅជាមួយអ្នកណា?
- តើមានក្មេងប៉ុន្មាននាក់ដែលមិនទាន់គ្រប់អាយុចូលរៀននៅក្នុងគ្រួសារ?
- តើអ្នកណាជាអ្នកមើលថែទាំកុមារតូចៗមិនទាន់ចូលរៀនទាំងនោះ?
- តើឪពុក ឬម្តាយធ្លាប់ចាកចេញពីផ្ទះដើម្បីទៅរកការងារធ្វើនៅទីឆ្ងាយឬទេ?

ឧបសគ្គ : ភាពក្រីក្រ និងផលប្រយោជន៍ពិតប្រាកដទទួលបានពីការអប់រំ និងការចំណាយលើការសិក្សា

- តើឪពុក ឬម្តាយរបស់កុមារមានមុខរបរពិតប្រាកដអ្វី?
- តើឪពុក ឬម្តាយកុមារមានមុខរបរបន្ថែមអ្វី? (ប្រសិនបើមាន)
- តើគ្រួសារមានដីសម្រាប់រកប្រាក់ចំណូលឬទេ? ប្រសិនបើមាន តើមានដីទំហំប៉ុន្មាន?
- តើកុមារមានជួលដីសម្រាប់រកប្រាក់ចំណូលឬទេ? បើមាន តើជួលដីទំហំប៉ុន្មានដែរ?
- តើប្រាក់ចំណូលជាមធ្យមរបស់គ្រួសារមានចំនួនប៉ុន្មានក្នុងមួយខែ?
- តើគ្រួសារមានខ្ចីប្រាក់គេរកស៊ីទេ? បើមាន តើខ្ចីគេប៉ុន្មាន ហើយខ្ចីពេលណាដែរ? (មានរដូវខ្លះខ្ចីគេ ហើយរដូវខ្លះមិនខ្ចីគេ)
- តើមានមនុស្សប៉ុន្មាននាក់រស់នៅក្នុងផ្ទះ?
- តើមានសមាជិកណាម្នាក់ក្នុងគ្រួសារជាសមាជិកនៅក្នុងក្រុមអភិវឌ្ឍសហគមន៍ឬទេ?

៤. រៀបចំកម្រងសំណួរដើម្បីប្រមូលចំលើយសម្រាប់សំណួរទាំងអស់នេះ។ កម្រងសំណួរអាចជាសំណួរទាំងអស់ខាងលើ ដែលចំលើយសម្រាប់សំណួរទាំងអស់អាចប្រើប្រាស់ដើម្បីបង្កើតជាប្រវត្តិកុមារ។ ប្រវត្តិកុមារអាចចង់ក្រងម្យ៉ាងទៀតតាមបែបផ្លូវការជាងនេះ ដូចដែលបង្ហាញនៅផ្នែកខាងក្រោយនៃកម្រងសៀវភៅនេះ។ នៅពេលដែលកម្រងសំណួរត្រូវរៀបចំហើយ កម្រងសំណួរអាច (ក) ផ្ញើរទៅតាមផ្ទះ ដើម្បីឱ្យគ្រួសារនីមួយៗបំពេញ ហើយផ្ញើរត្រឡប់មកសាលា ឬប្រធានសហគមន៍វិញ (ខ) គ្រូជាអ្នកបំពេញ នៅពេលគ្រូដើរទៅតាមគ្រួសារនីមួយៗ (គ) គ្រូបំពេញដោយសាកសួរព័ត៌មានតាមរយៈសិស្ស ឬតាមរយៈឪពុកម្តាយ នៅពេលឪពុកម្តាយមកទទួលកូនពីសាលាវិញ។

៥. បន្ទាប់ពីបានបំពេញកម្រងសំណួរ និងផ្ញើរមកវិញហើយ បង្កើតជាករណីសិក្សាសម្រាប់កុមារម្នាក់ៗ ដោយប្រើប្រាស់ចំលើយសម្រាប់សំណួរខាងលើ។ ខាងក្រោមនេះគឺជាករណីសិក្សាគំរូមួយ។ ករណីសិក្សានេះនឹងជួយអ្នកឱ្យកត់សម្គាល់ ភ្ជាប់ទំនាក់ទំនង និងវិភាគកត្តានានា ដែលរារាំងកុមារមិនឱ្យទៅសាលារៀន ឬប៉ះពាល់ដល់ការសិក្សារបស់កុមារ។

អាយ ជាជនជាតិភាគតិចមោង រស់នៅតំបន់ខាងជើងនៃប្រទេសថៃ។ គេប៉ាន់ស្មានថា នាងមានអាយុប្រហែល៩ឆ្នាំ ប៉ុន្តែពុំមានសំបុត្រកំណើតបញ្ជាក់ច្បាស់លាស់ទេ។ ឪពុករបស់នាងស្លាប់ហើយ។ ម្តាយរបស់នាងមានអាយុ៣០ឆ្នាំ ហើយពុំទាន់រៀបការម្តងទៀតទេ។ ម្តាយរបស់អាយ មិនចេះអក្សរទេ។ មុខរបរសំខាន់របស់គាត់គឺ ការធ្វើស្រែលើដែដីតូចមួយនៅតំបន់ខ្ពង់រាប។ ជីដូនរបស់អាយជាអ្នកមើលការខុសត្រូវអាយ និងប្អូនប្រុសរបស់នាងដែលមានអាយុ៥ឆ្នាំ និងមិនទាន់ចូលរៀននៅលាលាមត្តេយ្យទេ។ គ្រួសារអាយមានជីវភាពក្រីក្រណាស់។ ម្តាយអាយរកប្រាក់ចំណូលមិនបាន៥០០បាតជង់ក្នុងមួយខែ។ នៅរដូវធ្វើស្រែមិនបាន ម្តាយអាយទៅធ្វើពលករនៅទីក្រុងបាងកក។ គ្មានសមាជិកណាម្នាក់ក្នុងគ្រួសារអាយ ជាសមាជិកក្នុងក្រុមអភិវឌ្ឍន៍សហគមន៍ទេ ហើយពុំបានទទួលផលពីធនធានសហគមន៍ទេ។ អាយរៀនដល់ថ្នាក់ទី ៣ មិនទាន់ចប់ផង ហើយក៏ឈប់រៀនទៅ។ ម្តាយរបស់អាយ មិនអាចរកប្រាក់ទិញសំលៀកបំពាក់ឯកសណ្ឋានរបស់សាលា ក៏ដូចជាប្រាក់សម្រាប់មធ្យោបាយធ្វើដំណើរពីផ្ទះទៅសាលា ដែលឋិតនៅចម្ងាយ២៥គីឡូម៉ែត្រ ពីផ្ទះរបស់នាង។ កាលពីនាងនៅរៀន នាងអវត្តមានចំនួនពាក់កណ្តាល គឺបណ្តាលមកពីនាងឈឺ និងពាក់កណ្តាលទៀត គឺគ្រាន់តែជាលេសប៉ុណ្ណោះ។ នាងច្រើនតែមានជំងឺរលាកផ្លូវដង្ហើម។

៦. បន្ទាប់ពីបញ្ចប់ករណីសិក្សានីមួយៗ ចូរពិនិត្យមើលករណីនីមួយៗ ដោយយកចិត្តទុកដាក់ដើម្បីឱ្យដឹងថា កត្តាអ្វីខ្លះដែលធ្វើឱ្យប៉ះពាល់ដល់ឱកាសចូលរៀន និងការរៀនសូត្ររបស់កុមារ។ គូសបន្ទាត់ពីក្រោមកត្តាទាំងនោះដើម្បីឱ្យងាយមើល និងប្រៀបធៀប។ សម្រាប់ករណីរបស់អាយ កត្តាទាំងនេះអាចបណ្តាលមកពីភាពខុសគ្នាខាងវប្បធម៌ ការខ្វះបញ្ជីកំណើត ភាពក្រីក្រ ការខ្វះការគាំពារ និងថែទាំ ការខ្វះការទទួលធនធានសហគមន៍ បញ្ហាសុខភាព និងការខ្វះអាហារបរិភោគ។

៧. បន្ទាប់មកប្រៀបធៀបកត្តាផ្សេងៗរបស់កុមារនីមួយៗ។ កត្តាមួយណាដែលជាកត្តាទូទៅជាងគេ? ប្រើប្រាស់កត្តាមួយនេះជាការចាប់ផ្តើមដើម្បីរៀបចំផែនការសកម្មភាពដើម្បីដោះស្រាយមូលហេតុនានាដែលរារាំងកុមារមិនឱ្យចូលរៀន។ កម្រងសៀវភៅក្រោយៗទៀតនៅក្នុងកម្រងសៀវភៅនេះបង្ហាញអំពីរបៀបរៀបចំផែនការសម្រាប់ការងារនេះ។

២៤ ប្រមូលកុមារទាំងអស់ឱ្យចូលរៀនក្នុងសាលា

គំរូកម្រងសំណួរប្រវត្តិរបស់កុមារ

១. ឈ្មោះកុមារ_____ ភេទ _____ អាយុ _____
អាសយដ្ឋាន _____
សញ្ជាតិ _____ ជនជាតិភាគតិច _____ សាសនា _____
ថ្ងៃខែឆ្នាំកំណើត _____ ទីកន្លែងកំណើត _____
បញ្ជីកំណើត: មាន___ មិនមាន___ (គូស)

២. ឈ្មោះឪពុក _____ អាយុ _____ នៅរស់ ___ ស្លាប់ ____

៣. ឈ្មោះម្តាយ _____ អាយុ _____ នៅរស់ ___ ស្លាប់ ____

៤. ស្ថានភាពឪពុកម្តាយ (គូសរង្វង់): នៅជាមួយគ្នា មេម៉ាយ/ពោះម៉ាយ
លែងលះគ្នា រស់នៅបែកគ្នា

៥. តើកុមាររស់នៅជាមួយអ្នកណា? (គូសរង្វង់): ឪពុកម្តាយ ម្តាយ
ឪពុក អ្នកផ្សេង (សូមបញ្ជាក់)

៦. កត់ត្រាសមាជិកគ្រួសារទាំងអស់ដែលរស់នៅក្នុងគ្រួសារជាមួយកុមារ។ (ចូរបំពេញព័ត៌មាននៅក្នុងតារាងខាងក្រោម)

សមាជិកគ្រួសារ	ភេទ		អាយុ	កម្រិតវប្បធម៌ (ថ្នាក់ខ្ពស់បំផុត) តាមកម្រិតសិក្សានីមួយៗ						ត្រូវជាអ្វីនឹងកុមារ	មុខរបរ (បញ្ជាក់)	
ឈ្មោះ	ប	ស		១	២	៣	៤	៥	៦			

ចំណាំ : ១: ពុំបានរៀនសូត្រជាផ្លូវការទេ ២: បានរៀននៅក្នុងសាលាក្រៅប្រព័ន្ធ
៣: រៀនដល់ថ្នាក់មត្តេយ្យ ៤: រៀនដល់ថ្នាក់បឋម
៥: រៀនដល់ថ្នាក់មធ្យមសិក្សា ៦: រៀនដល់ថ្នាក់មហាវិទ្យាល័យ

៧. តើឪពុកម្តាយរបស់កុមារធ្លាប់ផ្លាស់ទីលំនៅទៅកន្លែងផ្សេងឬទេ? (គូសរង្វង់លើ"បាទ/ចាស" ឬ "ទេ" តាមព័ត៌មានសមស្របខាងក្រោម។

ឪពុក ផ្លាស់ពេលណា _____ (សូមបញ្ជាក់ ខែ និងឆ្នាំ) _____
បាទ ធ្លាប់ផ្លាស់ទៅ: ទីក្រុង/ខេត្ត _____; ប្រទេស_____
រយៈពេលប៉ុន្មាន _____ (ចំនួន ខែ និង ឆ្នាំ)
ទេ

ម្តាយ ផ្លាស់ពេលណា (សូមបញ្ជាក់ ខែ និងឆ្នាំ)
ចាស ធ្លាប់ផ្លាស់ទៅ: ទីក្រុង/ខេត្ត _____: ប្រទេស_____
រយៈពេលប៉ុន្មាន _____ (ចំនួន ខែ និង ឆ្នាំ)
ទេ
ទាំងគ្រួសារ ផ្លាស់ពេលណា (សូមបញ្ជាក់ ខែ និងឆ្នាំ)
ចាស/បាទ ធ្លាប់ផ្លាស់ទៅ: ទីក្រុង/ខេត្ត _____: ប្រទេស_____
រយៈពេលប៉ុន្មាន _____ (ចំនួន ខែ និង ឆ្នាំ)

៨. ថ្លាក់ចំណូលក្នុងគ្រួសារប្រចាំខែ (សូមគូសរង្វង់)

តិចជាង ១០០០ បាត
ពី ១០០០ ទៅ ២៥០០ បាត
ពី ២៥០១ ទៅ ៥០០០ បាត
ពី ៥០០១ ទៅ ៨០០០ បាត
ពី ៨០០១ ទៅ ១០០០០ បាត
លើសពី ១០០០០ បាត

៩. អ្នកមើលថែទាំ គាំពារកុមារគ្រប់អាយុចូលរៀនមត្តេយ្យ

តើក្នុងគ្រួសារ មានក្មេងដែលគ្រប់អាយុចូលរៀនមត្តេយ្យចំនួនប៉ុន្មាននាក់ តែមិនចូលរៀន?
តើអ្នកណាជាអ្នកមើលថែទាំ គាំពារកុមារទាំងនោះនៅពេលថ្ងៃ?
ឪពុក ឬម្តាយ_____ បងប្អូន (សូមបញ្ជាក់) _____
នៅមណ្ឌលថែទាំគាំពារកុមាររបស់សហគមន៍ ___ ជួលមនុស្សឱ្យមើលថែទាំគាំពារ ___
អ្នកផ្សេងទៀត(សូមបញ្ជាក់) _____

១០. មានផ្ទះ/ដី

តើគ្រួសាររបស់កុមារមានដីសម្រាប់រកថ្លាក់ចំណូលឬទេ? (មិនគិតដីផ្ទះទេ)
បើមាន : ដីខ្លួនឯង _____ (ចំនួនហិចតា)
ដីជួល_____ (ចំនួនហិចតា)
ដីគ្រួសារ _____ (ចំនួនហិចតា)
មិនមានទេ : _____
ផ្សេងទៀត (សូមបញ្ជាក់)

តើគ្រួសារកុមារមានផ្ទះឬទេ?
មាន_____ មិនមាន_____
បើមាន : ផ្ទះខ្លួនឯង_____ ផ្ទះជួល_____
ប្រភេទផ្ទះ (សូមបញ្ជាក់) _____

១១. ចម្ងាយ និងមធ្យោបាយធ្វើដំណើរពីផ្ទះទៅសាលា

តើសាលានៅចម្ងាយប៉ុន្មានគីឡូម៉ែត្រពីផ្ទះរបស់កុមារ? (សូមបញ្ជាក់ចម្ងាយ) _____
រយៈពេលធ្វើដំណើរពីផ្ទះទៅសាលា (សូមបញ្ជាក់ចំនួនម៉ោង _____ នាទី _____)

តើកុមារធ្វើដំណើរទៅសាលាដោយមធ្យោបាយអ្វី? សូមគូសរង្វង់

ដើរ រថយន្ត ម៉ូតូ

កង់ តាក់ស៊ី/ម៉ូតូឌុប ឡានក្រែង

ផ្សេងទៀត (សូមបញ្ជាក់)

១២. តើមានអ្នកណាម្នាក់នៅក្នុងគ្រួសារដែលចោះបង់ការសិក្សាចោលឬទេ? _____មាន _____មិនមាន

បើមាន (បញ្ជាក់មូលហេតុ) _____

១៣. តើកុមារធ្លាប់បានរៀនឬទេ? ___បាន ___មិនបាន: បើបាន រៀនរយៈពេលប៉ុន្មាន _____

១៤. តើកុមារធ្លាប់ចោះបង់ចោលការសិក្សាឬទេ? _____ដែល _____មិនធ្លាប់:

បើធ្លាប់ រយៈពេល _____

បើធ្លាប់ ដោយសារហេតុផលអ្វី _____

១៥. តើមានសមាជិកក្នុងគ្រួសារជាសមាជិកក្នុងក្រុមអភិវឌ្ឍសហគមន៍ឬទេ?_____មាន_____មិនមាន

បើមាន សូមបញ្ជាក់ឈ្មោះក្រុមអភិវឌ្ឍសហគមន៍នោះ _____

១៦. តើកុមារអាចមានប្រភពណាជួយទំនុកបំរុងថ្លៃកាសសម្រាប់ការរៀនសូត្រឬទេ?

_____មាន _____មិនមាន

ប្រសិនបើមាន សូមបញ្ជាក់ឈ្មោះប្រភព _____

១៧. បើកុមារធ្លាប់បានចូលរៀន តើកុមារអវត្តមានញឹកញាប់ទេ?_____ញឹកញាប់ _____មិនញឹកញាប់

បើញឹកញាប់ ហេតុអ្វី? _____

១៨. បើកុមារដែលបានរៀន តើកុមារប្រលង់ធ្លាក់ញឹកញាប់ទេក្នុងមុខវិជ្ជាសិក្សាទាំងអស់?

មិនដែល _____

ប្រហែល ២៥% _____

២៦ - ៥០% _____

ច្រើនជា ៥០% _____

១៩. តើកុមារមានរោគក្រិនឬទេ (តូច ឬទាបជាងអាយុ _____មាន _____មិនមាន

២០. តើកុមារបានទទួលទានអាហារថ្ងៃត្រង់ដែលសាលារៀបចំឱ្យឬទេ? _____បាន _____មិនបាន

តើកុមារបានទទួលទានអាហារថ្ងៃត្រង់នេះទៀងទាត់ទេ? _____ទៀងទាត់ _____មិនទៀងទាត់

២១. តើកុមារពិការដែរឬទេ? បើពិការ សូមបញ្ជាក់ _____

_____

២២. តើកុមារមានជំងឺប្រចាំកាយឬទេ?

បើមាន សូមបញ្ជាក់ _____ ឬ

តើព័ត៌មាននេះត្រូវរក្សាជាការសម្ងាត់ទេ _____សម្ងាត់



គោល ៣.៣
វិធានការដែលត្រូវអនុវត្តដើម្បីប្រមូលកុមារឱ្យបានចូលរៀន

ដោយហេតុថា ឥឡូវនេះ យើងបានរកឃើញកុមារដែលមិនបានចូលរៀន និងហេតុផលមួយចំនួនដែលធ្វើឱ្យកុមារនៅក្រៅសាលា យើងអាចរៀបចំផែនការមួយចំនួនដើម្បីជានាឱ្យកុមារទាំងនោះបានចូលរៀន។ កម្រងសៀវភៅនេះចាប់ផ្តើមរៀបរាប់ដំណើរការរៀបចំផែនការសកម្មភាព (ម្យ៉ាងទៀតថា ផែនការមីក្រូ) និងគំនិតមួយចំនួនដែលអ្នកអាចសាកល្បងធ្វើសកម្មភាព ឬកែសម្រួលសម្រាប់សាលាតាមសហគមន៍។

ផែនការសកម្មភាព

ក្នុងគោលខាងដើម យើងប្រើច្បាស់ផែនទីព័ត៌មានសហគមន៍ដើម្បីស្វែងរកកុមារដែលមិនបានចូលរៀន។ យើងរៀបចំផែនទី ដោយមានការចូលរួមពីសមាជិកសហគមន៍ ឬសិស្ស និងការចែករំលែកព័ត៌មានជាមួយមនុស្សដទៃទៀត។ យើងក៏បានប្រមូលព័ត៌មានអំពីកុមារម្នាក់ៗ ដែលមិនបានចូលរៀន រៀបចំព័ត៌មានប្រវត្តិកុមារ និងកត់សម្គាល់ឧបសគ្គនានាដែលរារាំងកុមារមិនឱ្យចូលរៀន។ ពេលនេះ យើងត្រូវចាប់ផ្តើមធ្វើសកម្មភាពដើម្បីជម្នះឧបសគ្គទាំងនេះ។ ដើម្បីធ្វើបែបនេះ អ្នកអាចធ្វើតាមដំណាក់កាលខាងក្រោមដើម្បីកសាងផែនការសកម្មភាពដែលមានប្រសិទ្ធភាព[3]។ ដំណាក់កាលនេះមានលក្ខណៈប្រហាក់ប្រហែលនឹងដំណាក់កាលនៅក្នុងកម្រងសៀវភៅលេខ ១ ស្តីពីដំណាក់កាលរៀបចំបរិយាកាសរៀនមេត្រី ដោយបញ្ចូលគ្រប់សមាសភាពដែរ។ ឯកសារគោលខាងក្រោមនេះត្រូវបានកែសម្រួលសម្រាប់ចាប់ផ្តើមអនុវត្តជាលក់នៅក្នុងសាលា ដើម្បីលុបបំបាត់ឧបសគ្គទាំងនេះ និងធ្វើឱ្យកុមារទាំងអស់មានឱកាសចូលរៀន។

១. ចងក្រងជាក្រុមជាមួយមនុស្សដែលអាចជួយអ្នក ដើម្បីវិភាគព័ត៌មានដែលអ្នកបានប្រមូលតាមរយៈផែនទីព័ត៌មានសហគមន៍ និងរៀបចំផែនការសកម្មភាពសមរម្យ។ អ្នកទាំងនេះអាចជួយរៀបចំផែនការបរិយាកាសរៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព ដែលបានរៀបរាប់ក្នុងកម្រងសៀវភៅលេខ២ ឬអ្នកដែលបានចូលរួមយ៉ាងសកម្ម ក្នុងការរៀបចំផែនទីព័ត៌មានសហគមន៍។ ម្យ៉ាងវិញទៀត អ្នកអាចបង្កើនសមាជិកក្រុម ដោយដាក់បញ្ចូលគ្នាអ្នកដែលអាចជួយរៀបចំផែនការសកម្មភាព និងអនុវត្តសកម្មភាពដូចមានចែងក្នុងផែនការ។

---

[3] Adapted from: Toolkit for Assessing and Promoting Equity in the Classroom, produced by Wendy Rimer et al. Edited by Marta S. Maldonado and Angela Aldave. Creative Associates International Inc., USAID/EGAT/WID, Washington DC. 2003.

២. បែងចែកសមាជិកក្នុងក្រុមទៅតាមតួនាទី និងចំណង់ចំណូលចិត្ត ឧទាហរណ៍ គ្រូបង្រៀន សមាជិកសមាគម មេដឹកនាំសហគមន៍ សិស្ស និងអ្នកមកពីផ្នែកឯកជនដទៃទៀត។

៣. បន្ទាប់មកទៀត ក្រុមនីមួយ ៗត្រូវបញ្ចេញទស្សនៈទាក់ទងនឹងសកម្មភាពដែលពួកគេត្រូវបំពេញជាក្រុមដើម្បីប្រមូលកុមារទាំងអស់នោះឱ្យបានចូលរៀន។ ក្រុមនីមួយ ៗត្រូវពិចារណារកការលំបាកពេលអនុវត្តសកម្មភាពទាំងនេះ។ តើកត្តាអ្វីខ្លះអាចជួយជម្រុញការអនុវត្តសកម្មភាពទាំងនេះឱ្យបានជោគជ័យ? តើកត្តាអ្វីខ្លះជាឧបសគ្គារាំងការអនុវត្តសកម្មភាពទាំងនេះ? តើត្រូវចៀសវាងឧបសគ្គទាំងនេះដោយរបៀបណា? ដើម្បីចៀសវាងការរៀបចំដែនការដែលនាំមកនូវបរាជ័យអ្នកត្រូវពិចារណារកឧបសគ្គនានាឱ្យបានច្រើន និងត្រឹមត្រូវ។

៤. នៅពេលដែលក្រុមនីមួយ ៗសម្រេចពីសកម្មភាពដែលត្រូវបំពេញដើម្បីឱ្យកុមារទាំងនោះបានចូលរៀន ក្រុមនីមួយ ៗត្រូវមកជួបជុំគ្នាដើម្បីផ្លាស់ប្តូរគំនិត និងបទពិសោធ។ ធ្វើការជាមួយគ្នាដើម្បីកត់សម្គាល់សកម្មភាព ដែលអាចអនុវត្តជាក់ស្តែងដោយពិចារណាលើបញ្ហាដូចខាងក្រោម និងបញ្ហាផ្សេងទៀតដែលអ្នកគិតថាសមស្រប។

ក. តើសកម្មភាពមួយណាដែលមានឥទ្ធិពលលើកុមារខ្លាំងជាងគេ ឬសកម្មភាពមួយណាគួរមានអាទិភាពខ្ពស់ជាងគេនៅក្នុងស្ថានភាពជាក់ស្តែងរបស់អ្នក? អ្នកអាចចាប់ផ្តើមបែងចែកសកម្មភាពទៅតាមអាទិភាពដែលត្រូវបំពេញ។

ខ. តើមានសកម្មភាពណាដែលមានលក្ខណៈប្រហាក់ប្រហែលគ្នា ដែលអាចដាក់បញ្ចូលគ្នារវាងក្រុមនីមួ ៗឬទេ? ធ្វើជាមួយគ្នាកត់សម្គាល់ដែនការប្រហាក់ប្រហែលគ្នា ដើម្បីពង្រឹងការខិតខំប្រឹងប្រែងសន្សំសំចៃធនធាន និងបង្កើនសក្តានុភាពដើម្បីជោគជ័យ។

គ. តើសកម្មភាពមួយណាដែលមានសក្តានុពលភាពបានជោគជ័យខ្ពស់ ហើយគួរចាប់ផ្តើមមុនគេ? យុទ្ធសាស្ត្រដ៏ល្អបំផុតគឺការចាប់ផ្តើមសកម្មភាពដ៏សាមញ្ញ ។ ដើម្បីទទួលបានជោគជ័យ និងជាបន្តបន្ទាប់រំកិលទៅរកសកម្មភាពដែលលំបាក។ និយាយរួម បំពេញសកម្មភាពណាដែលងាយទទួលបានជោគជ័យជាបន្តបន្ទាប់។ ឧទាហរណ៍ យើងគួរចាប់ផ្តើមដោយធ្វើឱ្យសាលាមានលក្ខណៈងាយស្រួលសម្រាប់កុមារពិការបានចូលរៀនសិន ហើយ បន្ទាប់មកចាំគិតពីសកម្មភាពលំបាក។ ដូចជាការកែប្រែភរិយាបថអវិជ្ជមាននានាចំពោះកុមារពិការនៅក្នុងថ្នាក់រៀន។

ឃ. តើសកម្មភាពមួយណាដែលអាចអនុវត្តបានដោយប្រើប្រាស់ធនធានដែលមានស្រាប់? សកម្មភាពមួយណាដែលទាមទារឱ្យមានជំនួយពីខាងក្រៅ? ដើម្បីទទួលបានជំនួយខាងក្រៅ ជាញឹកញាប់យើងត្រូវបង្ហាញអ្នកដែលនឹងជួយយើងថា អ្នកប្រឹងអស់លទ្ធភាព និងប្រើប្រាស់ធនធានដែលអ្នកមានជាមុនសិន។ ដូច្នេះ ចូរចាប់ផ្តើមជាមួយនឹងអ្វីដែលអ្នកមាន មុននឹង-ចាប់ផ្តើមសកម្មភាពដែលអ្នកត្រូវការជំនួយពីខាងក្រៅ។

៥. បន្ទាប់មក អ្នកទាំងអស់គ្នាត្រូវធ្វើជាមួយគ្នាដើម្បីរៀបចំផែនការសកម្មភាព ដែលយើងបានសម្រេចខាងដើម។ ផែនការសកម្មភាពនេះត្រូវមានចំណុចដូចខាងក្រោម។

ក. គោលបំណងដែលអ្នកចង់សម្រេច ឧទាហរណ៍ បង្កើនការចូលរៀនរបស់កុមារដែលមានប្រវត្តិនិងសមត្ថភាពខុសគេ។

ខ. យុទ្ធសាស្ត្រ ឬវិធីសាស្ត្រដែលចាំបាច់ដើម្បីបំពេញសកម្មភាព ឧទាហរណ៍ ជួបប្រជុំជាមួយឪពុកម្តាយកុមារដែលមានប្រវត្តិ និងសមត្ថភាពខុសគេ ដើម្បីស្វែងយល់ពីតម្រូវការខុសគ្នារបស់កុមារ។ បន្ទាប់មកជួបជាមួយគណៈគ្រប់គ្រងសាលា និងគ្រូដើម្បីពិនិត្យមើលសម្ភារសាលា និងសកម្មភាពនានាដែលត្រូវបំពេញដើម្បីធ្វើឱ្យសាលាមានលក្ខណៈអំណោយផល និងទាក់ទាញអារម្មណ៍។

គ. សកម្មភាព និងពេលវេលាជាក់ស្តែង ដូចបានរៀបរាប់ខាងលើ។

ឃ. ក្រមគោលដៅនីមួយៗមានទំនាក់ទំនង (ឧទាហរណ៍ ឪពុកម្តាយរបស់កុមារដែលមានប្រវត្តិនិងសមត្ថភាពខុសគេ និងកុមារទាំងនេះតែម្តង) និងអ្នកដែលទាក់ទងនឹងការអនុវត្តសកម្មភាពនេះ (បុគ្គលិករដ្ឋបាលសាលា គ្រូ សមាជិកសមាគមមាតាបិតាសិស្សសិស្សៗល។

ង. តើអ្នកត្រូវការធនធានអ្វី និងតើអ្នកត្រូវធ្វើយ៉ាងណាដើម្បីបានធនធាននោះ?

ច. តើលក្ខណៈវិនិច្ឆ័យអ្វីខ្លះដែលអ្នកត្រូវប្រើដើម្បីវាយតម្លៃថា តើសកម្មភាពរបស់អ្នកទទួលបានជោគជ័យ ឬមិនបាន (ឧទាហរណ៍ ចំនួនកុមារទាំងអស់បានចូលរៀន ឬមិនបាន)?

៦. ប្រសិនបើក្រមជាច្រើនត្រូវធ្វើសកម្មភាពខុសគ្នា ក្រមទាំងនោះត្រូវជួបប្រជុំគ្នាឱ្យបានទៀងទាត់ដើម្បីផ្លាស់ប្តូរគំនិត និងបទពិសោធ។ ការប្រជុំនេះអាចផ្តល់ឱកាស ឬរកលទ្ធភាពអនុវត្តសកម្មភាពរួមគ្នា។

៧. ផ្តល់ឱកាសឱ្យក្រុមទាំងអស់ពិនិត្យមើលសកម្មភាពដែលបានអនុវត្តកន្លងមក ដើម្បីឱ្យក្រុមទាំងអស់ដឹងថា អ្វីបានអនុវត្តហើយ អ្វីដែលកំពុងអនុវត្ត និងអ្វីដែលត្រូវធ្វើបន្ត និងដើម្បីឱ្យក្រុមទាំងអស់វាយតម្លៃពីជោគជ័យរបស់ក្រុម (អ្វីដែលដំណើរការល្អ និងអ្វីដែលដំណើរការមិនបានល្អ)។ ប្រើប្រាស់ព័ត៌មាននេះដើម្បីសម្រេចថា តើត្រូវបន្តសកម្មភាពដូចដែលបានកំណត់ក្នុងផែនការ ឬត្រូវធ្វើការកែតម្រូវសកម្មភាពខ្លះ នៅក្នុងផែនការ។ ចូរអនុវត្តតាមសេចក្តីសម្រេចចុងក្រោយនេះ។

គំនិតសម្រាប់អនុវត្តសកម្មភាព

ផ្នែកនេះនិយាយពី **"អ្នកបង្កើតគំនិត"** និងពិនិត្យមើលដោយត្រួសៗពីឧបសគ្គសំខាន់ៗមួយចំនួនដើម្បីផ្តល់ការអប់រំដែលមានគ្រប់សមាសភាព ដែលយើងបានពិភាក្សាខាងដើមជារឿយៗ។ បន្ទាប់មកយើងនឹងបង្ហាញគំនិតមួយចំនួនដើម្បីជម្នះឧបសគ្គទាំងនេះ ដោយផ្អែកលើបទពិសោធរបស់សាលា និងសហគមន៍ ដែលបានខិតខំដើម្បីជំរុញឱ្យមានការសិក្សាដែលមានបញ្ហូលគ្រប់សមាសភាព។ នេះគឺជាគំនិតដែលអ្នកគួរពិចារណា ពង្រីកបន្ថែម ដោយផ្អែកលើស្ថានភាពរបស់អ្នក។ អ្នកក៏អាចប្រើជាចំណុចចាប់ផ្តើមធ្វើសកម្មភាពដែរ។

បរិយាកាសកុមារ

សំបុត្រកំណើត : កុមារដែលមិនមានសំបុត្រកំណើតប្រហែលជាមិនបានចូលរៀនទេ ជួនកាលកុមារទាំងនោះអាចចូលរៀនបានដែរ តែមិនបានចប់គ្រប់ភូមិសិក្សាទេ។ តើយើងត្រូវធ្វើដូចម្តេចដើម្បីជួយកុមារដែលស្ថិតនៅក្នុងស្ថានភាពបែបនេះ?

- សហការជាមួយសហគមន៍ និងរដ្ឋអំណាចមូលដ្ឋានដើម្បីធ្វើ "យុទ្ធនាការចុះបញ្ជីកំណើត" ដើម្បីឱ្យកុមារទាំងអស់មានសំបុត្រកំណើតត្រឹមត្រូវ។

- ទំនាក់ទំនងជាមួយមណ្ឌលសុខភាពសហគមន៍ និងមន្ទីរពេទ្យ ដើម្បីសហការគ្នារៀបចំយុទ្ធសាស្ត្រលើកទឹកចិត្តឪពុកម្តាយឱ្យចុះបញ្ជីកំណើតកូនក្រោយសំរាល។

ការវើសអើង និងការប្រមាថមើលងាយដោយសារមានផ្ទុកមេរោគអេដស៍/ជំងឺអេដស៍ : កុមារដែលមានផ្ទុកមេរោគអេដស៍/ជំងឺអេដស៍ឬសមាជិកគ្រួសារមានផ្ទុកមេរោគអេដស៍/ជំងឺអេដស៍មិនបានចូលរៀនទេ បើបានក៏មានចំនួនតិចតួច ហើយរៀនមិនបានជាប់លាប់ដែរ។ កុមារទាំងនោះត្រូវមើលថែទាំអ្នកជំងឺ ឬ ត្រូវសាលាបញ្ឈប់ ដោយការវើសអើងភ័យខ្លាចកុមារចម្លងជំងឺ។ តើយើងត្រូវធ្វើយ៉ាងណាដើម្បីជួយកុមារទាំងអស់នេះ?

- សហការជាមួយអង្គការអេដស៍នៅមូលដ្ឋានដើម្បីរៀបចំសិក្ខាសាលាក្នុងសាលា ឬ សហគមន៍ដើម្បីលើកកម្ពស់ការយល់ដឹងពីជំងឺអេដស៍ និងការឆ្លងជំងឺអេដស៍។

- ពិភាក្សាអំពីតម្រូវការ និងការព្រួយបារម្ភរបស់ឪពុកម្តាយ ដែលកូនមិនមានផ្ទុកមេរោគអេដស៍/ជំងឺអេដស៍ និងអំពីការរៀនសូត្ររបស់កុមារ មិនមានផ្ទុកមេរោគអេដស៍/ជំងឺអេដស៍ជាមួយកុមារដែលមានជំងឺអេដស៍ នៅពេលត្រូវរៀនថ្នាក់ជាមួយគ្នា។
- អភិវឌ្ឍ និងពង្រឹងគោលនយោបាយសុខភាពសិក្សា ដោយស្វាគមន៍កុមារដែលមានផ្ទុកមេរោគអេដស៍/ជំងឺអេដស៍ឱ្យចូលរៀនដូចកុមារដទៃទៀតដែរ ដោយគិតពីតម្រូវការ និងការពារកុមារទាំងនោះឱ្យរួចផុតពីការមើលងាយ ការរើសអើង និងអំពើហិង្សា។
- រៀបចំឱ្យមានក្រុមពិគ្រោះយោបល់ ដូចបង្ហាញជូនក្នុងករណីសិក្សាខាងក្រោម។

ខ្លាចមានអំពើហិង្សា : *កុមារមិនទៅរៀនទេ ប្រសិនបើគេខ្លាចមានអំពើហិង្សា។ តើយើងត្រូវធ្វើយ៉ាងណាដើម្បីឱ្យយើងស្គាល់ស្ថានភាពសាលាកាន់តែច្បាស់?*

- សហការជាមួយកុមារ និងសមាជិកសហគមន៍នានា ដើម្បីរៀបចំផែនទីព័ត៌មានពីទីកន្លែងដែលអាចមានអំពើហិង្សា ដូចជានៅទីធ្លាសាលា នៅពេលធ្វើដំណើរទៅសាលា និងត្រឡប់មកវិញ។ *(ពិភាក្សាស៊ីជម្រៅនៅក្នុងកម្រងសៀវភៅលេខ ៦ ស្តីពីការកសាងបរិយាកាសសិក្សា ដែលមានជាសុកភាព និងសុវត្ថិភាព)*។
- សហការជាមួយថ្នាក់ដឹកនាំសហគមន៍ និងឪពុកម្តាយដើម្បីបង្កើតសកម្មភាព "ការឃ្លាំមើលកុមារ" ដែលអ្នកទទួលខុសត្រូវដូចជាគ្រូ ឪពុកម្តាយ និងសមាជិកក្នុងសហគមន៍ឃ្លាំមើលទីកន្លែងដែលអាចនឹងមានអំពើហិង្សា ទាំងនៅក្នុង និងក្រៅសាលា។ សកម្មភាពនេះអាចរួមបញ្ចូលទាំងនាំកុមារទៅដល់កន្លែងសុវត្ថិភាព ប្រសិនបើចាំបាច់។

ជំងឺ និងភាពអត់ឃ្លាន : *កុមារដែលមានជំងឺ ឬអត់ឃ្លាន រៀនមិនបានល្អទេ។ តើមានសកម្មភាពអ្វីខ្លះដែលយើងត្រូវធ្វើដើម្បីជួយកុមារទាំងនេះ (* **ចំណាំ :** *សកម្មភាពបន្ថែមទៀតមានពិភាក្សានៅក្នុងកម្រងសៀវភៅលេខ ៦)?*

- រៀបចំឱ្យមានកម្មវិធីអាហារសម្រាប់ការសិក្សានៅក្នុងសាលា។ កម្មវិធីនេះត្រូវផ្តល់អាហារដែលមានជីវជាតិឱ្យបានទៀងទាត់ ដូចជាពេលបាយថ្ងៃត្រង់ ឬអាហារសម្រន់។ កម្មវិធីនេះអាចមានសារៈសំខាន់ណាស់សម្រាប់កុមារី។
- សហការជាមួយនឹងអ្នកផ្តល់សេវាសុខភាពនៅក្នុងសហគមន៍ ដែលផ្តល់សេវានានា ដូចជាដើម្បីជួយលើកកម្ពស់សុខភាពរបស់សិស្ស ក៏ដូចជាការហូបចុកដែលមានសុខភាពដែរ។

មេរៀនដែលបានមកពីបទពិសោធ : គម្រោងមេរោគអេដស៍/ជំងឺអេដស៍ស្រុកធិកា

FAWE របស់កិនយ៉ា **(FAWEK)** ជ្រើសរើសស្រុកធិកា ពីព្រោះកុមារ ១៧ ភាគរយនៅបឋមសិក្សា និង២២ភាគរយនៅមធ្យមសិក្សាមានជួកមេរោគអេដស៍។ **FAWEK** កំណត់យកកុមារនៅបឋមសិក្សាដែលឈានចូលវ័យជំទង់ (១០-១៣ឆ្នាំ) ដោយមានគោលបំណងរៀបចំឱ្យមានក្លឹបពិគ្រោះយោបល់។ ក្លឹបនេះនឹងក្លាយជាកន្លែងដែលកុមារា កុមារី អាចទទួលចំណេះដឹងមូលដ្ឋាន បំណិន និងអាកប្បកិរិយាអំពីការរួមភេទរបស់យុវវ័យ បញ្ហាសុខភាពបន្តពូជ និងកាមរោគ រួមទាំងអេដស៍ផងដែរ។ គម្រោងក៏បានបញ្ចូលសិស្សវិទ្យាល័យផងដែរ ដើម្បីឱ្យសិស្សទាំងនោះចៀសវាងការរួមភេទគ្មានសុវត្ថិភាព និងក្លាយជាមនុស្សល្អ ដោយហ៊ានិយាយបដិសេធថា "**ទេ**" ចំពោះការរួមភេទដែលអាកប្បកិរិយាបែបនេះជាយុទ្ធសាស្ត្រដ៏មានប្រសិទ្ធភាពដើម្បីចៀសវាងការចម្លងអេដស៍។

សិក្ខាសាលាមួយត្រូវបានរៀបចំឡើងដោយមានការចូលរួមពីលោកគ្រូ អ្នកគ្រូចំនួន៦៤នាក់ មកពីសាលាបឋមសិក្សាចំនួន៣២។ គ្រូទាំងនោះនឹងធ្វើជាអ្នកពិគ្រោះយោបល់ក្នុងក្លឹបមួយ ក្នុងសាលាដោយផ្តល់ការណែនាំ និងពិគ្រោះយោបល់ដល់សិស្ស។ តាមរយៈសិក្ខាសាលាដែលមានការចូលរួមយ៉ាងកុះករលោកគ្រូអ្នកគ្រូបានទទួលចំណេះដឹង បំណិន និងឥរិយាបថទាក់ទងនឹងការពិគ្រោះយោបល់អំពីមេរោគអេដស៍/ជំងឺអេដស៍។ លើសពីនេះទៀត លោកគ្រូ អ្នកគ្រូក៏ទទួលបានឯកសារគ្រប់គ្រាន់សម្រាប់ធ្វើការនៅតាមសាលាផងដែរ។

សិស្ស៦៤នាក់មកពីសាលាបឋមសិក្សាចំនួន៣២ ដោយសារសាលាមួយ មានសិស្សប្រុសម្នាក់ សិស្សស្រីម្នាក់ ហើយមានគ្រូម្នាក់អមដំណើរ មកចូលរួមក្នុងសិក្ខាសាលារយៈពេល២ថ្ងៃ។ គ្រូជាអ្នកដឹកនាំក្នុងការពិគ្រោះយោបល់ក្នុងក្លឹប និងសិស្សទាំង២នាក់ ជាអ្នកដឹកនាំក្លឹប។ ការតាំងពិព័រណ៍ស្តីពីមេរោគអេដស៍/ជំងឺអេដស៍ ខ្សែវីដេអូខ្នាតខ្លីមានចំណងជើងថា "**Bush Fire**" បទឧទ្ទេសជាពាក្យកាព្យរបស់សិស្ស និងពាក្យពេចន៍ជាប្រយោគខ្លី ៗស្តីពីជំងឺអេដស៍ ត្រូវបានប្រើប្រាស់ជាជំនួយក្នុងការបណ្តុះបណ្តាលក្នុងសិក្ខាសាលា។ សិស្សទាំងប្រុស ទាំងស្រីចំនួន ៦៤នាក់ដែលបានទទួលការបណ្តុះបណ្តាលជាអ្នកពិគ្រោះយោបល់ ដូចគ្រូដែរ បានចាប់ផ្តើមយុទ្ធនាការស្វែងយល់អំពីអេដស៍ក្នុងទ្រង់ទ្រាយកាន់តែធំ ដោយចាប់ផ្តើមពីសាលា។ សិស្សទាំងនោះប្រើប្រាស់ ចំរៀង កំណាព្យ ល្ខោន ការពិភាក្សា ការសំដែង និងការពិគ្រោះយោបល់តាមគ្រប់រូបភាព។ សាលានីមួយ ៗក្នុងចំណោមសាលាទាំង ៣២ មានសិស្សស្រីជាមធ្យមចំនួន ២៥០នាក់។ ដូច្នេះ គម្រោងនេះអាចផ្សព្វផ្សាយដល់កុមារីចំនួន ៨០០០ នាក់ និងគ្រូចំនួន ៨០០ នាក់។ ការពិគ្រោះយោបល់នេះធ្វើឡើងនៅពេលមានការជួបជុំនៅសាលា ការជួបប្រជុំជាមួយឪពុកម្តាយ ដោយការរៀបចំជាបទឧទ្ទេសផ្សេង ៗ។ លទ្ធផលដូចនេះបានផ្សព្វផ្សាយចេញក្រៅសាលាទៅទៀត។ ឥឡូវនេះខ្លឹមសារដែលគេបានប្រើប្រាស់ត្រូវបានគេយកទៅផ្សព្វផ្សាយ នៅតាមវិហារ ទីផ្សារ និងកន្លែងសាធារណៈផ្សេងទៀតនៅក្នុងសហគមន៍។

ប្រភព : - **HIV/AIDS and Girls' Education: The FAWE Kenya Experience. Forum for African Women Educationalists. Nairobi, Kenya. www.fawe.org**

ការមានផ្ទៃពោះ : នៅក្នុងប្រទេស និងសហគមន៍ខ្លះ កុមារីដែលមានផ្ទៃពោះមិនអនុញ្ញាតឱ្យចូលរៀនទេ ទោះបីជាពួកគេមានសិទ្ធិទទួលការអប់រំក៏ដោយ។ ជំហានដំបូងដើម្បីធានាថា សិទ្ធិនេះត្រូវបានទទួលស្គាល់គឺការបង្កើតគោលនយោបាយសុខភាពសិក្សា ដែលធានាឱ្យកុមារីដែលមានផ្ទៃពោះ និងមានកូនបានចូលរៀនជាធម្មតា។ ដំណាក់ការនៃការរៀបចំគោលនយោបាយនេះមានពិភាក្សានៅក្នុងកម្រងសៀវភៅលេខ១។

បរិយាកាសគ្រួសារ

ភាពក្រីក្រ : ការអប់រំជួយកាត់បន្ថយភាពក្រីក្រ តែភាពក្រីក្រគឺជាឧបសគ្គរារាំងមិនឱ្យកុមារជាច្រើនបានទទួលការអប់រំ។ ដោយបុព្វហេតុចម្បងនៃភាពក្រីក្រ គឺសេដ្ឋកិច្ច យុទ្ធសាស្ត្រជ័យមានប្រសិទ្ធភាពដើម្បីធានាឱ្យកុមារបានចូលរៀនត្រូវពឹងផ្អែកលើការឧបត្ថម្ភខាងសេដ្ឋកិច្ចដល់កុមារ និងគ្រួសារ។

នៅប្រទេសថៃ កម្មវិធីកុមារមេត្រីប្រើប្រាស់ព័ត៌មានអំពីលទ្ធផលនៃការសិក្សា និង ជីវប្រវត្តិរបស់កុមារ ដើម្បីកត់សម្គាល់កុមារដែលរៀនខ្សោយ និងត្រូវបោះបង់ការសិក្សា។ គេបានកត់សម្គាល់ឃើញថា កុមារទាំងនេះ ច្រើនមកពីគ្រួសារដែលមានប្រាក់កាសតិចតួច ហើយឱ្យតម្លៃលើការងាររបស់កុមារខ្ពស់ជាងតម្លៃនៃការសិក្សា។ កុមារទាំងនេះចង់បានការបណ្តុះបណ្តាលជំនាញ ដូចជា ត្បាញ ដេរ ចម្លាក់ឈើ ជលិតកម្មកសិកម្ម កុំព្យូទ័រ។ល។ ជំនាញទាំងនេះអាចបង្កើនប្រាក់ចំណូលប្រចាំគ្រួសារ នៅពេលដែលកុមារកំពុងរៀនផង និងធ្វើការផង។ កុមារមួយចំនួននៅប្រទេសថៃ កម្មវិធីកុមារមេត្រី ប្រើប្រាស់ព័ត៌មានអំពីលទ្ធផលនៃការសិក្សារបស់កុមារ និងជីវប្រវត្តិរបស់កុមារ ដើម្បីកត់សម្គាល់កុមារដែលរៀនខ្សោយ ដែលអាចបោះបង់ការសិក្សា។ កុមារមួយចំនួន ក្នុងចំណោមកុមារទាំងនេះ បានទទួលរង្វាន់ថ្នាក់ជាតិដោយសារស្នាដៃល្អ។ នៅសាលាមួយចំនួន សមាជិកគ្រួសាររបស់កុមារទាំងនេះ អាចធ្វើជា"គ្រូ" បង្រៀនកុមារអំពីជំនាញប្រចាំត្រកូល ដូចជា របៀបជ្រលក់ពណ៌អំបោះ និងការត្បាញហូលជាដើម។ ការចូលរួមរបស់ឪពុកម្តាយក្នុងការអប់រំបែបនេះ អាចបង្កើនគុណប្រយោជន៍របស់សាលា ក្នុងក្រសែភ្នែករបស់ឪពុកម្តាយ តាមរយៈការកែលំអជីវភាព និងការថែរក្សាសម្បត្តិវប្បធម៌បុរាណ។ វាក៏អាចបង្កើនទំនាក់ទំនងរវាងឪពុកម្តាយ និងកូនអំពីអនាគតនៃការសិក្សារបស់កូនដែលអាចជួយគ្រួសារបានវិញនៅពេលក្រោយ។
តើយុទ្ធសាស្ត្រប្រហាក់ប្រហែលគ្នាបែបនេះ អាចបញ្ចូលក្នុងកម្មវិធីសិក្សាក្នុងសាលាអ្នកបានឬទេ?

អត្ថប្រយោជន៍នៃការអប់រំ : ជាញឹកញាប់ គ្រួសារក្រីក្រមិនអាចផ្គត់ផ្គង់គ្រួសារបានទេ។ សូម្បីតែសម្ភារមូលដ្ឋានប្រើប្រាស់ក្នុងផ្ទះក៏គ្មានផង។ ដូច្នេះ កុមារភាគច្រើនក្លាយជាអ្នកជួយរកប្រាក់ចំណូលឱ្យគ្រួសារដោយលះបង់ពេលវេលានៃការសិក្សា។ ស្ថានភាពបែបនេះមានកាន់តែច្បាស់នៅពេលដែលឪពុកម្តាយរបស់កុមារ និងកុមារខ្លួនឯង មើលឃើញការអប់រំមិនអាចមានអត្ថប្រយោជន៍សម្រាប់ការរស់នៅប្រចាំថ្ងៃ។ ដូច្នេះ កុមារទាំងនេះមិនផ្តល់អត្ថប្រយោជន៍ដល់ការអប់រំទេ។ ពេលនោះ កុមារទាំងនោះនឹងមិនមានហេតុផលអ្វីដែលត្រូវទៅរៀនទេ។ តើយើងអាចធ្វើអ្វីខ្លះដើម្បីជួយកុមារទាំងអស់នេះ?

- ឱ្យកុមារជើរមើលសកម្មភាព "សេដ្ឋកិច្ចសហគមន៍" ហើយបង្ហាញថាសកម្មភាពទាំងនេះគឺជាអ្វីដែលគេអាចរៀនពីកម្មវិធីសិក្សាពីសាលា។ ដូច្នេះសាលាមានតួនាទីសំខាន់ណាស់សម្រាប់ជីវភាពប្រចាំថ្ងៃរបស់គេ។

- លើកទឹកចិត្តឪពុកម្តាយ និងសមាជិកសហគមន៍ឱ្យធ្វើជា "គ្រូជំនួយការ" នៅក្នុងថ្នាក់រៀនដើម្បីឱ្យពួកគាត់អាចចែករំលែកបទពិសោធ និងចំណេះដឹងប្រចាំមូលដ្ឋាន និង ពន្យល់ពីសារៈសំខាន់នៃបទពិសោធ និងចំណេះដឹងប្រចាំមូលដ្ឋានក្នុងជីវភាពរស់នៅ និងណែនាំពីទំនាក់ទំនងរបស់វាទៅនឹងអ្វី ដែលកំពុងបង្រៀននៅក្នុងថ្នាក់។

ការខ្វះការគាំពារ និងថែទាំ : ទោះបីជាអ្នកដែលមើលការខុសត្រូវដល់កុមារដែលប្រសើរបំផុតគឺជាឪពុកម្តាយក៏ដោយ ក៏កុមារទាំងអស់មិនមានសំណាងបែបនេះទេ ជាពិសេសពេលដែលឪពុកម្តាយត្រូវទៅធ្វើការ។ នៅក្នុងករណីបែបនេះ កុមារទាំងនេះនឹងត្រូវទទួលការមើលថែទាំដោយមនុស្សផ្សេងទៀតដែលមិនមានចំណេះដឹងគ្រប់គ្រាន់ពីការមើលថែទាំ និងគាំពារកុមារ និងមិនសូវយកចិត្តទុកដាក់ចំពោះកុមារ។ តើយើងមានវិធានការអ្វីខ្លះដើម្បីជួយកុមារទាំងអស់នេះ?

- នៅថ្ងៃពិសេស។ អញ្ជើញអ្នកមើលថែទាំកុមារទៅសាលា។ បង្ហាញច្បាប់គេពីស្នាដៃកុមារ និងផ្តល់ការណែនាំស្តីពីការលើកកម្ពស់សុខភាព និងសុខុមាលភាពកុមារតាមរយៈការថែទាំ។

- លើកទឹកចិត្តឱ្យមានសិក្ខាសាលាស្តីពី "អ្នកមើលថែទាំកុមារគឺជាគ្រូ" ដើម្បីពិភាក្សាពីការវិវត្តរបស់កុមារ និងពីវិធីលើកកម្ពស់ការមើលថែទាំ និងគាំពារកុមារ។

- ប្រមូលឯកសារស្តីពីការមើលថែទាំកុមារពីភ្នាក់ងាររដ្ឋាភិបាល និងក្រៅរដ្ឋាភិបាល។ ជ្រើរ្រាស់ឯកសារទាំងនោះនៅក្នុងមណ្ឌលសុខភាព និងកម្មវិធីអប់រំជីវិតគ្រួសារជាមួយកុមារ ហើយចែកជូនឯកសារទាំងនោះទៅតាមគ្រួសារដើម្បីឱ្យសមាជិកគ្រួសារអាន និងស្វែងយល់ទាំងអស់គ្នា។

បរិយាកាសសហគមន៍

ការរើសអើងយេនឌ័រ : ក្នុងសង្គមមួយចំនួន ប្រសិនបើត្រូវសម្រេចថា តើត្រូវឱ្យក្មេងប្រុសឬក្មេងស្រីទៅរៀន គេតែងតែជ្រើសរើសក្មេងប្រុសឱ្យទៅរៀន។ ក្មេងស្រីត្រូវទុកឱ្យនៅចាំផ្ទះ មើលថែទាំប្អូនតូច។ ឬធ្វើការផ្ទះ។ តើយើងត្រូវធ្វើយ៉ាងណាដើម្បីលើកទឹកចិត្តក្មេងស្រីឱ្យបានចូលរៀនដែរ?

- ពិនិត្យការរៀនសូត្រ និងប្រមូលព័ត៌មានរបស់ក្មេងស្រីដែលមិនបានចូលរៀន (ដូចជា តាមរយៈការចង់ក្រងប្រវត្តិរូបកុមារជាដើម)។
- ជំរុញអ្នកដឹកនាំសហគមន៍ (ជាពិសេសខាងសាសនា) ឱ្យលើកទឹកចិត្តក្មេងស្រីឱ្យទៅរៀន តាមរយៈការចូលរួមនៅក្នុងគណៈកម្មាធិការអប់រំសហគមន៍ ឬសមាគមមាតាបិតាសិស្ស។ ផ្តល់ព័ត៌មានដល់គ្រួសារទូទៅឱ្យគេយល់ដឹងពីអត្ថប្រយោជន៍នៃការអប់រំក្មេងស្រី។
- ត្រូវបង្ហាញឱ្យឃើញពីទំនាក់ទំនងរវាងមេរៀន រៀននៅសាលាជាមួយនឹងសកម្មភាពប្រចាំថ្ងៃរបស់កុមារ និងគ្រួសារដើម្បីលើកទឹកចិត្តឪពុកម្តាយឱ្យបញ្ជូនកូនស្រីទៅរៀនដូចកូនប្រុស។
- ជួយគាំទ្រឪពុកម្តាយដើម្បីឱ្យគេអាចផ្តល់ឱកាស និងការពារកូនរបស់គេទាំងស្រី ទាំងប្រុសឱ្យបានស្មើគ្នា។
- ពិភាក្សាជាមួយឪពុកម្តាយដើម្បីឱ្យរៀបចំយ៉ាងណាធ្វើឱ្យពេលវេលាដែលក្មេងស្រីត្រូវធ្វើការងារផ្ទះនិងពេលទៅរៀនមិនជាន់ពេលវេលាគ្នា។ ការធ្វើបែបនេះនឹងជួយឱ្យក្មេងស្រីទៅរៀន បានទៀងទាត់។
- ពិនិត្យមើលថាតើសាលាអាចរៀបចំពេលវេលាយ៉ាងណាឱ្យសមស្របសម្រាប់ក្មេងស្រី ដែលមានការងារត្រូវបំពេញច្រើនបានចូលរៀនផង។ ពិភាក្សាជាមួយនឹងអង្គការមូលដ្ឋាន ដើម្បីរៀបចំសកម្មភាពសហគមន៍ ដូចជាការមើលថែទាំកុមារ (ជំនួសក្មេងស្រី) ដើម្បីធ្វើឱ្យក្មេងស្រីមានឱកាសបានចូលរៀន។
- កត់សម្គាល់ និងគាំទ្រការដោះស្រាយជាក់ស្តែងតាមមូលដ្ឋាន ដូចជា ផ្តល់ការអប់រំក្រៅប្រព័ន្ធដែលមានគុណភាពតាមផ្ទះសម្រាប់ក្មេងស្រីដែលគ្មានឱកាសបានចូលរៀននៅសាលា។
- លើកទឹកចិត្តឱ្យមានកម្មវិធីជំនួយឧត្តម្ភសម្រាប់ក្មេងស្រី ដូចជា អាហារូបករណ៍បន្តិចបន្តួច ប្រាក់ឧបត្ថម្ភ កម្មវិធីអាហារ និងជំនួយពីសាលាដូចជាបញ្ហាសំលៀកបំពាក់ជាដើម។

ភាពខុសគ្នានៃវប្បធម៌ និងទំនៀមទម្លាប់មូលដ្ឋាន : ការអប់រំដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព ត្រូវមានលើកទឹកចិត្តឱ្យមានភាពខុសគ្នាទាំងវប្បធម៌ និងទំនៀមទម្លាប់មូលដ្ឋានរបស់សិស្ស។ សម្រាប់កុមារ ដែលនិយាយភាសាផ្សេង ឬមានវប្បធម៌ផ្សេង យើងត្រូវយកចិត្តទុកដាក់លើ :

- សហការជាមួយឪពុកម្តាយ និងសមាជិកសហគមន៍ ដើម្បីកែសម្រួលមេរៀន និងឯកសារៀន និងបង្រៀនដើម្បីឱ្យស្របតាមវប្បធម៌ និងភាសាផ្សេងគ្នានៅក្នុងសហគមន៍។ ធ្វើបែបនេះ នឹងជួយធានាឱ្យមានឯកសារដែលមានខ្លឹមសារដើមពិតប្រាកដ និងមានប្រយោជន៍ដល់សហគមន៍ ដែលជាហេតុធ្វើឱ្យឪពុកម្តាយចង់បញ្ជូនកូនទៅសាលារៀន។ វិធីដែលត្រូវបញ្ចូលវប្បធម៌ និងទំនៀមទម្លាប់មូលដ្ឋានក្នុងកម្មវិធីសិក្សាមាននិយាយលំអិតក្នុងកម្រងសៀវភៅលេខ ៤។

- ប្រើប្រាស់រឿងតាមមូលដ្ឋាន ប្រវត្តិសាស្ត្រចាំមាត់តៗគ្នា រឿងព្រេងនិទាន កំណាព្យ ចំរៀង ដើម្បីរៀបចំមេរៀនសម្រាប់បង្រៀន។
- សម្រាប់កុមារដែលមិនចេះនិយាយភាសាដែលគ្រូប្រើសម្រាប់បង្រៀន ត្រូវឱ្យគ្រូដែលចេះនិយាយពីរភាសាបង្រៀន ឬគ្រូដែលចេះនិយាយភាសាកុមារ (សមាជិកគ្រួសារ ឬ សមាជិកក្នុងសហគមន៍) រៀបចំកម្មវិធីសិក្សាសមស្រួមមួយសម្រាប់កុមារដោយប្រើប្រាស់ភាសាដែលកុមារចេះ។

បរិយាកាសាលា

ការចំណាយ : សម្រាប់គ្រួសារក្រីក្រជាច្រើន ការចំណាយផ្ទាល់ ឬប្រយោលក្នុងការបញ្ជូនកូនទៅសាលារៀន តែងហួសពីសមត្ថភាពរកចំណូលរបស់គ្រួសារ។ តើយើងអាចធ្វើអ្វីខ្លះដើម្បីជួយកុមារដែលមកពីគ្រួសារក្រីក្របែបនេះ?

- ពិភាក្សាជាមួយរដ្ឋបាលសាលា ឪពុកម្តាយ និងសមាជិកសហគមន៍អំពីការចំណាយដោយផ្ទាល់ និងចំណាយដោយប្រយោល ដែលជាកត្តាធ្វើឱ្យកុមារមិនបានចូលរៀន។
- រកវិធីកាត់បន្ថយ ឬលុបបំបាត់ការចំណាយទាំងនេះ ឧទាហរណ៍តាមរយៈកម្មវិធីឧបត្ថម្ភ ដូចជាអាហារូបករណ៍បន្តិចបន្តួច អាហារ និងការគាំទ្រតាមរូបភាពផ្សេងៗរបស់សាលា ដូចជាសំលៀកបំពាក់ តាមរយៈអំណោយសប្បុរសជនរបស់អង្គការនៅតាមមូលដ្ឋាន ។

ទីតាំង : នៅតាមតំបន់ជនបទ ប្រសិនបើសាលាស្ថិតនៅដាច់ឆ្ងាយពីសហគមន៍ ឪពុកម្តាយមិនចង់ឱ្យកូនទៅសាលារៀនទេ។ តើមានវិធានការអ្វីខ្លះដើម្បីជួយកុមារទាំងអស់នេះ?

- រកមើលកុមារដែលរស់នៅឆ្ងាយពីសាលា តាមរយៈការធ្វើដែនទីព័ត៌មានសហគមន៍ ការកត់ត្រាជីវប្រវត្តិកុមារជាដើម។
- សហការជាមួយឪពុកម្តាយ និងសមាជិកសហគមន៍ដើម្បីរកវិធីឱ្យកុមារទាំងនេះបានទៅសាលា និងត្រឡប់មកពីសាលាវិញដោយសុវត្ថិភាព។

កាលវិភាគសាលា : កុមារខ្លះចង់រៀនដូចកុមារដទៃទៀតដែរ។ ប៉ុន្តែដោយសារកាលវិភាគសាលាជាន់នឹងពេលវេលាដែលកុមារត្រូវធ្វើការ កុមារទាំងនេះមិនអាចរៀនផងរកប្រាក់ផងបានទេ។ លើសពីនេះទៀត កុមារី ក៏ដូចជាកុមារាដែរនឹងត្រូវបោះបង់ការសិក្សានៅពេលដែលពេលវេលានៃការសិក្សាជាន់គ្នានឹងពេលវេលាធ្វើការរកប្រាក់ចំណូល ឬធ្វើការផ្ទះ។ តើគេអាចធ្វើអ្វីខ្លះដើម្បីជួយកុមារទាំងអស់នេះ?

- ពិនិត្យមើលលទ្ធភាពនៃការរៀបចំកាលវិភាគទន់ភ្លន់មួយ ដើម្បីសម្រួលតាមពេលវេលារបស់កុមារដែលត្រូវធ្វើការ។

- និយាយជាមួយសេវាសង្គមមូលដ្ឋាន និងអង្គការមនុស្សធម៌នានាដើម្បីឱ្យដឹងថា តើអង្គការមានរៀបចំកម្មវិធីសម្រាប់កុមារដែលធ្វើការ ឬរស់តាមទីសាធារណៈឬអត់ និងពីលទ្ធភាពនៃការបង្កើតឱ្យមានកម្មវិធីបែបនេះសម្រាប់កុមារ ប្រសិនបើអង្គការទាំងនោះមិនទាន់មាននៅឡើយ។ កម្មវិធីនេះត្រូវរៀបចំឡើងបន្ទាប់ពីកុមារធ្វើការហើយ ដូចជានៅពេលល្ងាច ឬចុងសប្តាហ៍ ដើម្បីឱ្យកុមារដែលបានរៀននៅសាលាមានពេលបង្រៀនមិត្តភក្តិរួមអាយុរបស់កុមារ ដែលមិនមានឱកាសបានចូលរៀននៅក្នុងសាលា។

បរិក្ខារសាលា : ការខ្វះខាតសម្ភារនៅសាលាជាមូលហេតុមួយដែលធ្វើឱ្យកុមារមិនទៅរៀន។ ដូច្នេះយើងត្រូវគិតពីការកែប្រែសាលាទាំងបរិយាកាស និងសម្ភារដើម្បីឱ្យកុមារគ្រប់សមាសភាពបានចូលរៀន។ ឧទាហរណ៍ បើកុមារពិការមិនអាចឡើងទៅរៀននៅក្នុងបន្ទប់ជាន់ទី ២ ដំណោះស្រាយគឺត្រូវដូរថ្នាក់នោះមកជាន់ទីមួយ និងឱ្យថ្នាក់នៅជាន់ទី១ ឡើងទៅជាន់ទី២វិញ។ តើសកម្មភាពមួយចំនួនដែលអាចអនុវត្តបាន ដើម្បីជួយកុមារទាំងនេះមានអ្វីខ្លះ?

- សហការជាមួយគ្រួសារ និងមេដឹកនាំសហគមន៍ដើម្បីកសាងប្រព័ន្ធផ្គត់ផ្គង់ទឹក និងបង្គន់ដាច់ដោយឡែកសម្រាប់ក្មេងប្រុស និងក្មេងស្រី (ចូរមើលកម្រងសៀវភៅលេខ ៥)។

- ពិនិត្យឱ្យបានច្បាស់ពីតម្រូវការសម្ភារ និងចំណូលចិត្តរបស់កុមារដែលមានប្រវត្តិ និងសមត្ថភាពខុសគេ។ ពិនិត្យរកលទ្ធភាពដែលសាលាអាចធ្វើបានដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់កុមារទាំងនេះ។

ការរៀបចំមេរៀនរបស់គ្រូ : ជាញឹកញាប់គ្រូមួយចំនួនមិនចង់បញ្ចូលសិស្សដែលមានប្រវត្តិខុសគេ និងសិស្សពិការឱ្យរៀននៅក្នុងសាលាទេ ព្រោះគ្រូមិនដឹងថា ត្រូវបង្រៀនកុមារទាំងនោះដោយរបៀបណា។ តើយើងត្រូវធ្វើយ៉ាងណា ដើម្បីជួយគ្រូ និងកុមារទាំងនេះ?

- រកមើលកុមារណាខ្លះមិនបានចូលរៀន ហើយបណ្តាលមកពីមូលហេតុអ្វី? តើកុមារទាំងនោះមានប្រវត្តិ និងសមត្ថភាពកម្រិតណា? តើកុមារមានតម្រូវការសិក្សាពិសេសអ្វីខ្លះ?

- ទំនាក់ទំនងជាមួយភ្នាក់ងារអប់រំរបស់រដ្ឋាភិបាល អង្គការក្រៅរដ្ឋាភិបាលមូលដ្ឋាន វិទ្យាស្ថានបណ្តុះបណ្តាលគ្រូ អង្គការជំនួយមនុស្សធម៌មូលដ្ឋាន ឬភ្នាក់ងារអន្តរជាតិដែលធ្វើការដើម្បីពង្រឹងការអប់រំនៅក្នុងប្រទេស។ សួរអង្គការទាំងនោះមើលថា តើអង្គការទាំងនោះស្គាល់គ្រូ ឬអ្នកជំនាញដែលមានបទពិសោធបង្រៀនកុមារដែលមានប្រវត្តិ និងសមត្ថភាពខុសៗគ្នា ដូចជាសិស្សរបស់អ្នក។

- ទាក់ទងគ្រូទាំងនោះ និងសុំឱ្យអ្នក ឬសហការីរបស់អ្នកទៅមើលវិធីបង្រៀនកុមារ ដែលមានតម្រូវការពិសេសនៅសាលារបស់គ្រូទាំងនោះ។ ប្រសិនបើអ្នកមិនអាចទៅធ្វើទស្សនកិច្ចសិក្សានៅសាលានោះដោយហេតុថា ការចំណាយខ្ពស់ពេក សុំឱ្យគេផ្ញើរឯកសារដែលអ្នកអាចប្រើសម្រាប់បង្រៀន ដូចជាគំរូកិច្ចតែងការបង្រៀន វិធីសាស្ត្របង្រៀន ឬគំរូសម្ភារបង្រៀន ដែលអ្នកអាចប្រើប្រាស់ ឬធ្វើតាម។

- នៅពេលមានធនធានហើយ សុំឱ្យគ្រូទាំងនោះមកទស្សនកិច្ចសិក្សានៅសាលារបស់អ្នកដើម្បីឱ្យគេផ្តល់ដំបូន្មាន និងនិយាយជាមួយប្រធានរដ្ឋបាល និងគ្រូដទៃទៀតដើម្បីស្វែងយល់ពីតម្លៃនៃការអប់រំដែលមានសមត្ថភាពខុសគ្នា និងមានពិការភាព។

- **សេចក្តីបន្ថែម :** កុំទាន់អស់សង្ឃឹម។ បង្កើតបណ្តាញការងារ និងរក្សាទំនាក់ទំនងល្អជាមួយគ្រូនានាដែលបង្រៀនកុមារពិការ និងមានសមត្ថភាពខុសគេ។ ចូររក្សាទំនាក់ទំនងជាមួយគ្រូទាំងនោះឱ្យបានជាប់លាប់។

សកម្មភាពដែលគ្រូអាចធ្វើដើម្បីបង្កើនឱកាសឱ្យកុមារពិការអាចចូលរៀន និងរៀនបានលទ្ធផលល្អ

១. កុមារពិការពិបាកធ្វើដំណើរទៅសាលាណាស់។ ញ្ជាយោមរៀបចំមធ្យោបាយធ្វើដំណើរទៅសាលាសម្រាប់ក្មេងពិការទាំងនេះ។ ចំណែកនៅសាលាវិញ ត្រូវធ្វើជណ្តើរជម្រាល ឬបង្កាន់ដៃជណ្តើរមានលក្ខណៈសមស្របសម្រាប់កុមារពិការធ្វើដំណើរ។

២. ពេលឃើញកុមារពិការមកកាន់សាលានៅថ្ងៃដំបូង ចូរអ្នកនិយាយជាមួយអ្នកដែលនាំកុមារមក ដើម្បីឱ្យដឹងពីកន្លែងពិការរបស់កុមារ និងពន្យល់ប្រាប់កុមារទាំងនោះថា កុមារអាចធ្វើអ្វីបានគ្រប់បែបយ៉ាង ដូចកុមារដទៃទៀតដែរ ទោះបីជាកុមារពិការក៏ដោយ។ សួរនាំអំពីការលំបាកនានាដែលកុមារពិការជួបប្រទះ ក្នុងការរស់នៅ។

៣. ពេលកុមារមករៀន សួរសុខទុក្ខកុមារ និងសួរសុខទុក្ខគ្រួសាររបស់កុមារដល់ផ្ទះ ម្តងម្កាលដើម្បីនិយាយប្រាប់ឪពុកម្តាយអំពីអ្វីដែលអ្នកធ្វើ ដើម្បីជួយកុមារឱ្យរៀនទៅសាលា។ សួរពីគម្រោងការទៅថ្ងៃអនាគតរបស់កុមារ។ រកវិធីដែលអ្នកអាចជួយគ្រួសារនេះឱ្យបានល្អប្រសើរ។

៤. សាកសួរឪពុកម្តាយមើលថា តើកុមារត្រូវលេបថ្នាំពេទ្យនៅសាលាឬអត់។

៥. ប្រសិនបើអ្នកពុំមានពេលគ្រប់គ្រាន់ដើម្បីយកចិត្តទុកដាក់លើកុមារ តាមដែលកុមារត្រូវការសុំសាលា ឬសហគមន៍ឱ្យរកជំនួយការម្នាក់។ ជំនួយការនេះអាចមានពេលវេលាគ្រប់គ្រាន់សម្រាប់កុមារពិការនៅពេលដែលគ្រូកំពុងបង្រៀន។

៦. គ្រូត្រូវរៀបចំឱ្យកុមារពិការអង្គុយកន្លែងសមរម្យដើម្បីឱ្យគេអាចស្តាប់ឮ និងមើលឃើញ ពេលកំពុងបង្រៀន។ សរសេរឱ្យបានច្បាស់ដើម្បីឱ្យកុមារយល់នូវអ្វីដែលអ្នកកំពុងនិយាយ។

៧. តាមដានមើលថា តើកុមារ និងឪពុកម្តាយរបស់កុមារមានបញ្ហាដោយសារតែការចូលរៀនរបស់កុមារឬយ៉ាងណា។ សួរយោបល់ឪពុកម្តាយថា តើកុមារដទៃទៀតបានជួយកូនរបស់គាត់ និងធ្វើល្អជាមួយកូនគាត់ដែរឬទេ។

*ប្រភព : **UNICEF. http://www.unicef.org/teachers/protection/access.htm***



គោល ៣.៤
តើយើងបានរៀនអ្វីខ្លះ?

ឧបសគ្គរារាំងមិនឱ្យការអប់រំគ្រប់សមាសភាពបានសម្រេច អាចមើលឃើញខ្លះ ដូចជាពិការភាពហើយកត្តាមើលមិនឃើញ ដូចជា ការថែទាំ និងគាំពារមិនដិតដល់ ឬការខ្វះអាហារូបត្ថម្ភ និងកត្តាផ្សេង។ ទៀតដែលប៉ះពាល់ដល់ការសិក្សា និងការទៅសាលារបស់កុមារ ហើយជួនកាលត្រូវធ្វើតាមទម្លាប់ចាស់បុរាណ ដូចជា ឥរិយាបថចាស់គំរិល ទម្លាប់យេនឌ័រ ឬទំនៀមទម្លាប់ប្រពៃណី និងភូតាទិ និងការទទួលខុសត្រូវរបស់កូនៗក្នុងគ្រួសារ។

កុមារអាចត្រូវគេបដិសេធមិនឱ្យចូលរៀនដោយហេតុផលប្រទាក់ក្រឡាគ្នាជាច្រើន ហើយយើងប្រហែលជាមិនបានគិតថា មានហេតុផលទាំងនោះទេ។ ឧទាហរណ៍ ទំនៀមទម្លាប់វប្បធម៌បង្ហាញថា កុមារដែលរស់នៅសហគមន៍ជនបទ ត្រូវធ្វើការតាំងពីកុមារភាពម្ល៉េះ ដោយមិនចាំបាច់ទៅរៀនអ្វីទេ។ ស្ថានភាពបែបនេះកាន់តែត្រឹមត្រូវទៅទៀតសម្រាប់គ្រួសារក្រីក្រ ព្រោះគ្រួសារក្រីក្រមិនអាចមានច្រាក់ចំណាយសម្រាប់ឱ្យកូនទៅរៀនទេ ហើយគ្រួសារក្រីក្រមិនសូវគិតថា ការអប់រំនឹងមានប្រយោជន៍សម្រាប់កូនទៅថ្ងៃអនាគតទេ។

ឧបសគ្គរារាំងមិនឱ្យកុមារគ្រប់សមាសភាពបានចូលរៀនមាននៅគ្រប់កន្លែងទាំងអស់ ឧទាហរណ៍ នៅពេលដែលសាលាមិនបានផ្តល់ការអប់រំដែលគួរជាទីទាក់ទាញ ពេញចិត្ត និងមានគុណភាព ដើម្បីឆ្លើយតបនឹងតម្រូវការរបស់កុមារ។ កុមារអាចបោះបង់ចោលការសិក្សានៅពេលណាមួយ ជាពិសេស ប្រសិនបើកុមារមានដើមកំណើតជាជនជាតិភាគតិច ហើយគ្រូតែងបង្ហាញពីការលំបាកក្នុងការបង្រៀនដែរ។

កុមារម្នាក់អាចជួបការលំបាកច្រើនបែបច្រើនជំពូកណាស់ ដែលមិនអនុញ្ញាតឱ្យកុមារចូលរៀន។ ឧទាហរណ៍ មានឯកសារជាច្រើននិយាយអំពី "ការរើសអើងទ្វេដង" ឬ "ការរើសអើងច្រើនដង" ដែលកុមារីពិការជួបប្រទះ ឬកុមារីដែលត្រូវមើលថែរទាំមនុស្សក្នុងគ្រួសារដែលមានមេរោគអេដស៍/ជំងឺអេដស៍។ ក្នុងវប្បធម៌ខ្លះ កុមារីត្រូវជួបការរើសអើងតាំងពីកំណើត មានអាយុកាលមធ្យមរស់តិចជាងកុមារា និងទទួលបានការអប់រំតិចតួចប៉ុណ្ណោះ។ គេអាចចាត់ទុកកុមារទាំងនេះថា ជាបន្ទុកបន្ថែម ឬការអស់សង្ឃឹមរបស់គ្រួសារ ហើយសិទ្ធិរបស់កុមារីទាំងនេះមិនត្រូវបានលើកកម្ពស់ និងគោរពឱ្យបានត្រឹមត្រូវទេ។ បញ្ហាទាំងនេះកាន់តែធ្ងន់ធ្ងរទៅទៀត ប្រសិនបើកុមារទាំងនេះគឺជាកុមារអនាថា កុមារធ្វើការ កូនជនជាតិភាគតិច។

ក្នុងករណីទាំងអស់នេះ ត្រូវខិតខំប្រឹងប្រែងយ៉ាងពិសេសដើម្បីស្វែងរកកុមារទាំងនេះ ហើយសកម្មភាពជាច្រើនត្រូវធ្វើឡើងដំណាលគ្នាដើម្បីឱ្យកុមារទាំងនេះបានចូលរៀន។

ដំណាក់កាលដំបូងដែលត្រូវធ្វើដើម្បីឱ្យកុមារគ្រប់សមាសភាពបានចូលរៀនគឺ ការស្វែងរកឱ្យឃើញថា តើកុមារណាខ្លះដែលមិនបានចូលសាលារៀន។ ការកំណត់ព័ត៌មានសហគមន៍គឺជាវិធីសាស្ត្រមានប្រសិទ្ធភាព សម្រាប់ស្វែងរកកុមារទាំងអស់នេះ។ ការកំណត់ព័ត៌មានសហគមន៍នេះជាសកម្មភាពសាលា–សហគមន៍ (សហគមន៍ជាអ្នកស្វែងរកកុមារ) ឬសកម្មភាពថ្នាក់រៀន (កុមារជាអ្នកស្វែងរកកុមារ)។

ដើម្បីស្វែងយល់ពីមូលហេតុដែលកុមារមិនបានចូលរៀន យើងត្រូវប្រើវិធីកុមារគោលមជ្ឈមណ្ឌល។ យើងត្រូវស្គាល់កត្តារបស់កុមារម្នាក់ៗ គ្រួសារ សហគមន៍ និងសាលារៀន ហើយត្រូវដឹងថា តើកត្តាណាមួយដែលរារាំងកុមារមិនឱ្យចូលរៀន។ កត្តាទាំងនេះ គឺជាចំណុចចាប់ផ្តើមសម្រាប់ការកែប្រែ និងបង្កើតបរិយាកាសសាលាដែលមានការចូលរៀនដោយកុមារមកពីគ្រប់សមាសភាព។

គោលនីមួយៗក្នុងកម្រងសៀវភៅនេះក៏បានណែនាំអ្នកឱ្យរៀបចំធ្វើជែនការសកម្មភាពសម្រាប់កាត់បន្ថយឧបសគ្គនានាដែលរារាំងដល់ការរៀនសូត្ររបស់កុមារ មកពីគ្រប់សមាសភាពនៅក្នុងសាលា និងក្នុងសហគមន៍។ ដើម្បីចាប់ផ្តើមដំណើរការនេះ ចូរអាន និងពិចារណាសំណួរខាងក្រោម ហើយយល់ស្របលើសកម្មភាពជាក់ស្តែងដែលអ្នក និងសហការីរបស់អ្នក អាចអនុវត្តបានក្នុងស្ថានភាពរៀងៗខ្លួន។

- តើអ្នករៀនបានចំណេះដឹងអ្វីខ្លះហើយពីកម្រងសៀវភៅនេះ?
- តើខ្លឹមសារអ្វីដែលជាខ្លឹមសារចម្បងក្នុងបរិបទនៃតម្រូវការរបស់អ្នក?
- តើឧបសគ្គចម្បងរារាំងមិនឱ្យមានការចូលរៀនរបស់កុមារគ្រប់សមាសភាពមានអ្វីខ្លះនៅក្នុងស្ថានភាពនៃសាលារបស់អ្នក?
- តើការលំបាកអ្វីខ្លះដែលអ្នក និងក្រុមរបស់អ្នកកំពុងជួបប្រទះ?
- តើអ្នកត្រូវធ្វើអ្វីខ្លះដើម្បីជម្នះរាល់ការលំបាកទាំងនោះ?
- តើអ្នកត្រូវប្រើសូចនាករអ្វីខ្លះដើម្បីវាស់វែងពីលទ្ធផលការងារ និងជោគជ័យរបស់អ្នក?
- តើមានគម្រោងសកម្មភាពអ្វីខ្លះសម្រាប់ឆ្នាំសិក្សាក្រោយ?
- តើអ្នកនឹងវាយតម្លៃពីការរីកចម្រើនរបស់អ្នកនៅពេលណា និងដោយវិធីណា?
- ជែនការ និងសកម្មភាពទាំងនេះ នឹងជួយអ្នកឱ្យរៀបចំថ្នាក់រៀនមួយដែលបង្កលក្ខណៈឱ្យមានការចូលរៀន ដោយកុមារមកពីគ្រប់សមាសភាព។ នេះគឺជាប្រធានបទក្នុងកម្រងសៀវភៅលេខ ៤ និងលេខ ៥។

តើអ្នកអាចអានឯកសារបន្ថែមនៅឯណា?

ខាងក្រោមនេះ ជាឯកសារបោះពុម្ព និងវិបសាយដែលមានឯកសារសំខាន់ៗទាក់ទងនឹងការពុះពារ ដើម្បីធានាឱ្យកុមារទាំងអស់បានចូលរៀន។

ឯកសារយោង

Govinda R. (1999) Reaching the Unreached through Participatory Planning: School Mapping in Lok Jumbish, India. Paris: International Institute for Educational Planning/UNESCO.

Hart R. (1997) Children's Participation: The Theory and Practice of Involving Young Citizens in Community Development and Environmental Care. New York: UNICEF and London: Earthscan.

Mathur R. (2000) Taking Flight. Education for All Innovation Series No. 14. Bangkok: UNESCO Principal Regional Office for Asia and the Pacific.

Rimer W et al. (2003) Toolkit for Assessing and Promoting Equity in the Classroom, Edited by Marta S. Maldonado and Angela Aldave. Washington DC: Creative Associates International Inc., USAID/EGAT/WID.

Staff Development Division, Bureau of Elementary Education, Department of Education, Philippines, and UNICEF. (2002) Student Tracking System Facilitator's Manual. (A good source for learning about how to develop child profiles.)

UNESCO (2003) Sharing a World of Difference: The Earth's Linguistic, Cultural and Biological Diversity. Paris.

Volpi E. (2002) Street Children: Promising Practices and Approaches. WBI Working Papers. Washington, DC: The International Bank for Reconstruction and Development/The World Bank.

Web Sites

Barriers to Girls' Education: Strategies and Interventions. UNICEF Teachers Talking About Learning.
http://www.unicef.org/teachers/girls_ed/barriers_02.htm

Child Protection. UNICEF. http://www.unicef.org/protection/index_bigpicture.html

Children as Community Researchers: Creating a Community Base Map. UNICEF. http://www.unicef.org/teachers/researchers/index.html or http://www.unicef.org/teachers/researchers/childresearch.pdf

Equity in the Classroom, A Semi-Annual Newsletter, August 2000. Creative Associates International, Inc. This newsletter gives valuable insights and case studies on the challenges of bilingual education and strategies for teaching linguistically diverse learners. It can be accessed at: http://www.caii.net/EIC/Resources/eicnewsJuneweb.pdf

Gender in Education: Promoting Gender Equality in Education. UNESCO Asia and Pacific Regional Bureau for Education, Bangkok, Thailand.
http://www.unescobkk.org/gender

HIV/AIDS and Policies Affecting Children.
http://www.hri.ca/children/aids/factsheet_detail.htm

Leslie J and Jamison DT. Health and nutrition considerations in education planning. 1. Educational consequences of health problems among school-age children. http://www.unu.edu/Unupress/food/8F123e/8F123E03.htm

Save the Children (UK). Schools for All.
www.eenet.org.uk/bibliog/scuk/schools_for_all.shtml

UNICEF Teachers Talking About Learning.
http://unicef.org/teachers

កម្រងសៀវភៅលេខ : ៤

បង្កើតថ្នាក់រៀនកុមារមេត្រី ដោយបញ្ចូលគ្រប់សមាសភាព

កម្រងសៀវភៅលេខ : ៤

បង្កើតថ្នាក់រៀនកុមារមេត្រី ដោយបញ្ចូលគ្រប់សមាសភាព



បរិយាកាសរៀនមេត្រី
ដោយបញ្ចូលគ្រប់សមាសភាព

UNESCO

សេចក្តីណែនាំអំពីគោល

កម្រងសៀវភៅនេះនឹងជួយអ្នកឲ្យយល់ថា តើគំនិតនៃការសិក្សាបានផ្លាស់ប្តូរដោយរបៀបណាលើរយៈពេលមួយ នៅពេលដែលថ្នាក់របស់យើងផ្តោតលើកុមារ។ កម្រងសៀវភៅនេះផ្តល់ដល់អ្នកនូវគោល និងគំនិតជាច្រើន ស្តីពីរបៀបធ្វើការជាមួយកុមារដែលមានប្រវត្តិ និងសមត្ថភាពផ្សេងគ្នាដែលបានរៀនក្នុងថ្នាក់របស់អ្នក ព្រមទាំងអំពីរបៀបធ្វើឱ្យការសិក្សាមានខ្លឹមសារសម្រាប់សិស្សទាំងអស់គ្នា។

គោល

គោល ៤.១ ការសិក្សាអំពីសកម្មភាពរៀន និងអ្នករៀន ---------- ៣

ការរៀន និងការបង្រៀន ---------- ៣

វិធីរៀនរបស់កុមារ ---------- ៥

គោល ៤.២ ដំណោះស្រាយបញ្ហានានាភាពនៅក្នុងថ្នាក់រៀន ---------- ១៧

ការវាយតម្លៃ និងការលើកទឹកចិត្តឱ្យមាននានាភាពក្នុងថ្នាក់រៀន ---------- ១៧

ប្រើប្រាស់វិធីគិតពិចារណា រៀន និងស្វែងយល់នៅក្នុងថ្នាក់រៀនផ្សេងៗគ្នា---------- ១៩

បញ្ហាប្រឈមមុខអំពីនានាភាព ---------- ២១

ភាពលំអៀងក្នុងកម្មវិធីសិក្សា និងសម្ភារសិក្សា ---------- ២៩

យេនឌ័រ និងការបង្រៀន ---------- ៣៥

នានាភាព និងពិការភាព ---------- ៣៦

មេរោគអេដស៍/ជំងឺអេដស៍ និងការរើសអើង ---------- ៤៤

គោល ៤.៣ ធ្វើឱ្យការសិក្សាមានខ្លឹមសារសម្រាប់ទាំងអស់គ្នា ---------- ៤៦

ការរៀនសម្រាប់បម្រើជីវភាពរស់នៅ ---------- ៤៦

ការបង្កើតបរិយាកាសរៀនមេត្រី សម្រាប់ការសិក្សាដែលអត្ថន័យមានខ្លឹមសារ ---------- ៤៨

ការបង្កើតបទពិសោធសិក្សាដើម្បីស្វែងយល់អំពីបញ្ហាយេនឌ័រ ---------- ៥០

សកម្មភាពរៀនដែលសកម្ម និងមានការចូលរួម ---------- ៥៥

បង្រៀនគណិតវិទ្យា វិទ្យាសាស្ត្រ និងភាសាឲ្យមានអត្ថន័យខ្លឹមសារសម្រាប់ទាំងអស់គ្នា -- ៥៩

គាល ៤.៤ តើយើងបានរៀនពីបទពិសោធអ្វីខ្លះនាពេលកន្លងមក? ---------- ៧៥



គោល ៤.១
ការសិក្សាអំពីសកម្មភាពរៀន និងអ្នករៀន

ការរៀន និងការបង្រៀន

នៅក្នុងសេចក្តីផ្តើមនៃគោលនេះ យើងបាននិយាយថា "បញ្ចូលគ្រប់សមាសភាព" មានន័យថា ការរាប់បញ្ចូល មិនត្រឹមតែកុមារពិការក្នុងថ្នាក់រៀនប៉ុណ្ណោះទេ តែថែមទាំងកុមារទាំងអស់ដែលមានប្រវត្តិ និងសមត្ថភាពខុសគេ។ ជាការពិត ការនាំកុមារទាំងអស់នេះឲ្យចូលរៀនក្នុងថ្នាក់របស់យើង គឺមានត្រឹមតែពាក់កណ្តាលនៃបញ្ហាដែលត្រូវដោះស្រាយប៉ុណ្ណោះ។ ពាក់កណ្តាលទៀត គឺការឆ្លើយតបតម្រូវការសិក្សាផ្សេងៗគ្នារបស់កុមារទាំងអស់ និងការផ្តល់ការយកចិត្តទុកដាក់ពិសេសចំពោះកុមារទាំងឡាយដែលត្រូវបានច្រានចេញពីថ្នាក់រៀន ឬមិនឲ្យចូលរួម និង/ឬ ចូលរៀនក្នុងថ្នាក់។

ថ្នាក់រៀនរបស់យើងមានលក្ខណៈផ្សេងៗគ្នាអំពីប្រភេទកុមារដែលយើងបង្រៀន និងវិធីដែលកុមារៀន។ ការស្រាវជ្រាវថ្មីៗ បានច្បាស់យើងថា កុមារៀនសូត្រក្នុងវិធីផ្សេងៗគ្នា ដោយសារកត្តាតំណពូជ បទពិសោធ បរិយាកាស ឬចរិយាសម្បត្តិរបស់កុមារ។ ហេតុដូច្នេះហើយ យើងត្រូវការប្រើសកម្មភាព និងវិធីសាស្ត្របង្រៀនផ្សេងៗគ្នា ដើម្បីឆ្លើយតបតាមតម្រូវការរៀនសូត្រផ្សេងៗគ្នារបស់កុមារ។

គំនិតដំបូងមួយនេះអាចបង្កការព្រួយបារម្ភ និងការភ័យខ្លាច។ គ្រូបង្រៀនជាច្រើនអាចកំពុងធ្វើការក្នុងថ្នាក់រៀនយ៉ាងធំ ហើយអាចឆ្ងល់ថា "តើខ្ញុំអាចប្រើវិធីសាស្ត្របង្រៀនផ្សេងៗគ្នាដោយរបៀបណាដើម្បីបំពេញតាមតម្រូវការរបស់កុមារម្នាក់ៗ នៅពេលដែលខ្ញុំមានកុមារផ្សេងៗគ្នាចំនួន៥០នាក់ក្នុងថ្នាក់រៀនខ្ញុំ?"។ ជាការពិត នេះជាមូលហេតុមួយដែលធ្វើឱ្យគ្រូបង្រៀនខ្លះរកមធ្យោបាយដោះទាល់ ដោយប្រើ "វិធីរៀនដោយទន្ទេញចាំមាត់"។ យើងនិយាយពីត៏មានដដែលៗម្តងហើយម្តងទៀត ហើយឱ្យកុមារថាតាមយើងម្តងហើយម្តងទៀត ដោយសង្ឃឹមថា កុមារនឹងអាចចងចាំបាន។ វិធីនេះអាចជាវិធីមួយដែលងាយស្រួលសម្រាប់គ្រប់គ្រងកុមារច្រើននាក់ក្នុងថ្នាក់រៀន និងមានលក្ខណៈទៀងត្រង់ តែវិធីនេះអាចធ្វើឱ្យយើង និងកុមារមានការធុញទ្រាន់ច្រើន។ ក្នុងរយៈពេលមិនយូរប៉ុន្មាន យើងនឹងគ្មានការចូលចិត្ត ឬការប្រឹងប្រែងក្នុងការបង្រៀន ហើយជាក់ស្តែង កុមារគ្មានការចូលចិត្ត ឬការប្រលងប្រណាំងក្នុងការរៀនសោះឡើយ។

ដើម្បីផ្លាស់ប្តូរស្ថានភាពនេះ យើងត្រូវការរៀនអំពីវិធីបង្រៀនថ្មី។ និងប្រើវិធីទាំងនេះជាប្រចាំជាមួយកុមារទាំងអស់។ បន្ទាប់មក កុមារនឹងចូលចិត្តវិធីផ្សេងៗគ្នាដែលពួកគេរៀន ហើយកុមារទាំងអស់នឹងមានអារម្មណ៍ចង់រៀន។ គ្រូបង្រៀនខ្លះបានប្រើរួចជាស្រេចហើយនូវវិធីសាស្ត្របង្រៀនផ្សេងៗ ហើយពួកគេយល់ឃើញថា ការបង្រៀនកាន់តែផ្តល់ផលល្អថែមទៀត។

អ្នកស្រី Shikha Chanda ជាគ្រូបង្រៀនម្នាក់នៅសាលាបឋមសិក្សារដ្ឋ Kanchijhuli នៃស្រុក Mymenshingh ដែលស្ថិតនៅចម្ងាយប្រហែល១២០គ.ម ពីទីក្រុង Dhaka រដ្ឋធានីនៃប្រទេសបង់ក្លាដេស។ គាត់បានបង្រៀននៅទីនោះអស់រយៈពេលជាច្រើនឆ្នាំមកហើយ ប៉ុន្តែនៅពេលថ្មីៗនេះ គាត់មានការភ្ញាក់ផ្អើលជាខ្លាំងដោយបានឃើញការរីកចម្រើនរបស់សិស្សរបស់គាត់ នៅពេលពួកគេដើរជាជួរចូលក្នុងថ្នាក់រៀនរាល់ព្រឹក។ សិស្សរបស់គាត់មានអាយុពី៦-១០ឆ្នាំ។ គាត់បានរៀនសូត្រអំពីរបៀបរៀន និងបង្រៀនក្នុងគម្រោង IDEAL និងបានព្យាយាមអនុវត្តចំណេះដឹងថ្មីរបស់គាត់ស្តីពីវិធីសាស្ត្រថ្មីៗ ដើម្បីដោះស្រាយបញ្ហារៀនសូត្រក្នុងថ្នាក់រៀន។ គាត់ភ្ញាក់ផ្អើល និងរីករាយដោយសារលទ្ធផលរៀនសូត្រដែលសិស្សរបស់គាត់ទទួលបាន។

"គម្រោង IDEAL បានបណ្តុះបណ្តាលខ្ញុំអំពីវិធីសាស្ត្ររៀន និងបង្រៀនថ្មីនេះ ហើយខ្ញុំបានកត់សម្គាល់ឃើញភាពខុសគ្នាភ្លាមៗ។ ពីមុន សិស្សខ្ញុំមានភាពស្ពឹកច្រអូស ហើយងាយធុញទ្រាន់ចំពោះការបង្រៀនដែលគ្មានការផ្លាស់ប្តូរ និងការធ្វើដដែលៗនៃមេរៀន។ ឥឡូវនេះ ពួកគេមើលទៅមានភាពរវៃសរវែ ហើយហ៊ាននិយាយស្តី និងមិនមានការខ្មាសអៀនទៀតឡើយ "។

Multiple Ways of Teaching and Learning in Bangladesh. http://www.unicef.org/teachers/forum/0301.htm



សកម្មភាពឆ្លុះបញ្ចាំង : តើគេបានបង្រៀនអ្នកដោយរបៀបណា?

ចូរគិតអំពីរបៀបដែលគេបានបង្រៀនអ្នកនៅក្នុងសាលា និងរបៀបដែលគេបានបង្រៀនអ្នកដើម្បីបង្រៀន។ ចូរសរសេរពីអារម្មណ៍ របស់អ្នកអំពីវិធីសាស្ត្រទាំងនេះ។

	វិធីសាស្ត្របង្រៀន ដែលបានប្រើ	**សេចក្តីពន្យល់ តើវិធីសាស្ត្រទាំងនេះ ជាវិធីសាស្ត្រដឹកនាំដោយគ្រូ (ដូចជា ការឱ្យទន្ទេញចាំមាត់) ឬសិស្សគោលមជ្ឈមណ្ឌល?**
ពេលអ្នកនៅសាលា		
ពេលបណ្តុះបណ្តាលគ្រូ		

តើវិធីសាស្ត្របង្រៀនណាខ្លះក្នុងចំណោមវិធីសាស្ត្រទាំងនេះជួយអ្នករៀនឲ្យបានល្អបំផុត? តើអ្នកកំពុងប្រើវិធីសាស្ត្រទាំងនេះក្នុងថ្នាក់រៀនរបស់អ្នកឬទេ? តើសិស្សរបស់អ្នក ឆ្លើយតបដូចម្តេចចំពោះវិធីសាស្ត្រទាំងនេះ? តើពួកគេកំពុងរៀនយ៉ាងសកម្ម និងយ៉ាងរីករាយ ឬក៏គ្រាន់តែអង្គុយស្ងៀមស្ងាត់ចាំស្តាប់អ្នក? តើសិស្សប្រែលង និងឆ្លើយសំណួរបានល្អយ៉ាងណាដែរ?

វិធីរៀនរបស់កុមារ

គ្មានកុមារណាម្នាក់ "រៀនខ្សោយឡើយ"។ ដោយត្រូវបានផ្តល់លក្ខខណ្ឌត្រឹមត្រូវ កុមារទាំងអស់ កុមារី និងកុមារា អាចរៀនដោយមានប្រសិទ្ធភាព ជាពិសេសនៅពេលពួកគេ "រៀនជង និងអនុវត្តជង"។

សម្រាប់ពួកយើងភាគច្រើន យើងរៀនបានល្អបំផុត ដោយ "រៀនជង និងអនុវត្តជង" មានន័យថាតាមរយៈការធ្វើសកម្មភាពពិតប្រាកដ និងការទទួលបានបទពិសោធ។ នេះគឺជាអ្វីពិតប្រាកដ ដែលយើងចង់និយាយ នៅពេលយើងនិយាយពី "ការរៀនយ៉ាងសកម្ម" "ការចូលរួមរបស់កុមារក្នុងការរៀនសូត្រ" ឬ "ការរៀនសូត្រដោយមានការចូលរួម"។ វានឹងជំរុញកុមាររៀនពីព័ត៌មានថ្មីៗតាមរយៈសកម្មភាព និងវិធីសាស្ត្របង្រៀនផ្សេងៗ។ សកម្មភាពទាំងនេះ ជារឿយៗ ត្រូវបានផ្សារភ្ជាប់ទៅនឹងបទពិសោធអនុវត្តរបស់កុមារក្នុងជីវភាពប្រចាំថ្ងៃ។ ការផ្សារភ្ជាប់នេះជួយកុមារឱ្យយល់ និងចងចាំអ្វីដែលពួកគេកំពុងរៀន ហើយបន្ទាប់មកប្រើអ្វីដែលពួកគេបានរៀនជាបន្តបន្ទាប់ក្នុងជីវិតប្រចាំថ្ងៃ។

តើមធ្យោបាយផ្សេងៗអ្វីខ្លះដែលកុមាររៀន? ការដឹងមធ្យោបាយផ្សេងៗទាំងនេះនឹងជួយយើងអភិវឌ្ឍសកម្មភាពរៀនសូត្រដែលកាន់តែមានខ្លឹមសារល្អឡើងសម្រាប់កុមារ និងសម្រាប់យើង ហើយជាពិសេសជួយកុមារទាំងឡាយដែលត្រូវបានច្រានចេញមិនឲ្យចូលរៀនដោយសារប្រពៃណី យើងចង់រក្សាកុមារទាំងនោះឲ្យរៀនក្នុងថ្នាក់រៀនកុមារមេត្រី ដោយបញ្ចូលគ្រប់សមាសភាពរបស់យើង។

ការរៀនដោយប្រើញាណ : ចក្ខុវិញ្ញាណ សោតវិញ្ញាណ និងកាយវិញ្ញាណ

តើសិស្សរបស់អ្នកនឹងធ្វើអ្វី នៅពេលពួកគេចូលដល់ក្នុងថ្នាក់ភ្លាមនៅពេលព្រឹក? សង្ឃឹមថា កុមារនឹងសំឡឹងមើលអ្នក (ចក្ខុ) និងស្តាប់អ្នក (សម្លេង) ព្រមទាំងមើលអ្វីដែលអ្នក និងអ្នកដទៃទៀតកំពុងធ្វើ (ចលនា)។ សិស្សកំពុងរៀន។

ញាណទាំងបីនេះ–ចក្ខុវិញ្ញាណ សោតវិញ្ញាណ និងចលនា– ជាញាណសំខាន់ក្នុងការជួយកុមារឱ្យរៀន។ កុមារពិការ អាចរៀនក្នុងវិធីដូចគ្នានឹងកុមារធម្មតាដែរ។ ទោះបីជាយ៉ាងណាក្តី សម្រាប់កុមារកុមារមានញាណមួយក្នុងចំណោមញាណទាំងបី (សោតវិញ្ញាណ ចក្ខុវិញ្ញាណ ឬកាយវិញ្ញាណ) ចុះខ្សោយ ឬបាត់បង់សមត្ថភាព ហើយកុមារទាំងនេះអាចរៀនក្នុងល្បឿនមួយយឺតជាងមិត្តភក្តិដែលមិនពិការ។

រយៈពេលជាច្រើនឆ្នាំ យើងបានដឹងថា កុមារ៣០% រៀនដោគជ័យនៅពេលពួកគេឮអ្វីមួយ ៣៣% នៅពេលពួកគេឃើញអ្វីមួយ និង ៣៧%តាមរយៈសកម្មភាពផ្ទាល់។ ដូចជាសុភាសិតមួយនិយាយថា "ខ្ញុំស្តាប់ឮ ហើយខ្ញុំភ្លេច ខ្ញុំឃើញ ហើយខ្ញុំចងចាំ ខ្ញុំបានធ្វើផ្ទាល់ដៃ ហើយខ្ញុំយល់" ចំណុចនេះមានសារៈសំខាន់ណាស់! ប្រសិនបើយើងគ្រាន់តែបង្រៀនកុមារដោយឱ្យពួកគេស្តាប់យើង ដូច្នេះមានសិស្សប្រហែលមួយភាគបីប៉ុណ្ណោះ ដែលនឹងរៀនចេះអ្វីដែលយើងបង្រៀនឲ្យស្តាប់។ ស្ថានភាពនេះ អាចកើតមាននៅពេលយើងគ្រាន់តែឲ្យកុមារសរសេរអ្វីមួយក្នុងសៀវភៅរបស់ពួកគេ ជាការចប់ប៉ុណ្ណោះ។

អ្នកគ្រូ Shikha ក្នុងប្រទេសបង់ក្លាដេសយល់ថា កុមារផ្សេងៗគ្នារៀនដោយរបៀបផ្សេងៗគ្នា ដូច្នេះគាត់បានផ្លាស់ប្តូរការបង្រៀនរបស់គាត់ "យើងមិនប្រើតែវិធីសាស្ត្រដឹស និងក្តារខៀនឡើយ។ ការបង្រៀនតាមរយៈចម្រៀង របាំ សូត្រកំណាព្យ និងការសម្តែងមានភាពសប្បាយច្រើន ហើយមានលក្ខណៈងាយស្រួល ពីព្រោះកុមារបានផ្តោតអារម្មណ៍ពិតប្រាកដ និងមានអារម្មណ៍ថា ពួកគេកំពុងរៀនតាមរយៈសកម្មភាពសប្បាយរីករាយ"។

សម្រាប់គ្រូបង្រៀន បញ្ហានេះមានន័យថា នៅពេលយើងកំពុងរៀបចំកិច្ចតែងការបង្រៀន យើងត្រូវការរៀបចំប្រើសម្ភារឧបទេសផ្សេងៗ (ផ្ទាំងរូបភាពធំ។ គំនូរ។ល។) ត្រូវការប្រើញាណ សម្រាប់ការពិភាក្សា (ចក្ខុវិញ្ញាណ និងការស្តាប់) និងផ្តល់ឱកាសឱ្យកុមារធ្វើចលនាក្នុងទម្រង់ណាមួយ (ឧទាហរណ៍ សម្តែងល្បែងសិក្សា ឬរបាំដែលទាក់ទងនឹងវប្បធម៌ផ្សេងៗដែលអ្នកអាចរៀបចំក្នុងថ្នាក់រៀន)។

ចូរចាំថា កុមារខ្លះអាចមានបញ្ហាពិបាកមើល ឬស្តាប់ ហើយមិនអាចចងចាំបាន ដូចកុមារដទៃទៀតឡើយ។ ចូរសួរខ្លួនអ្នកថា តើសកម្មភាពអ្វីខ្លះនឹងទាក់ទងជាមួយកុមារទាំងនោះ ហើយក្នុងឋានៈជាគ្រូ បង្រៀនខ្ញុំអាចសម្រួលសកម្មភាពនានាឱ្យជាប់ទាក់ទងគ្នាដោយរបៀបណា ដើម្បីឱ្យសិស្សទាំងអស់អាចរៀនបាន?

វិធីរៀនបែបចម្រុះ

យើងដឹងថា កុមារខ្លះរៀនបានល្អបំផុតតាមរយៈការអាន និងការកត់ត្រា កុមារដទៃទៀត តាមរយៈការសិក្សា សម្ភារជាក់ស្តែង ហើយមានកុមារខ្លះទៀតតាមរយៈការធ្វើចលនារាងកាយ (របាំ កីឡា) ឬ សកម្មភាពតន្ត្រី។ កុមារខ្លះចូលចិត្តធ្វើការលើបញ្ហានានា ចំណែកខ្លះទៀតចូលចិត្តធ្វើការរួមគ្នាជាមួយសិស្សដទៃ ដើម្បីស្វែងរកដំណោះស្រាយ។ ដូច្នេះ កុមាររៀនតាមវិធីផ្សេងៗជាច្រើន។

ប្រសិនបើយើងអាចអង្កេតមើល ឬរកឃើញមធ្យោបាយជាច្រើនដើម្បីឱ្យកុមារក្នុងថ្នាក់ដែលបញ្ចូលគ្រប់សមាសភាពរបស់យើងរៀន យើងអាចជួយកុមារទាំងអស់ឱ្យរៀនកាន់តែប្រសើរ ហើយយើងនឹងទទួលបានការពេញចិត្តកាន់តែច្រើនថែមទៀត ពីការបង្រៀនរបស់យើង។

អ្នកគ្រូ Shikha មកពីប្រទេសបង់ក្លាដេស បានកត់សម្គាល់ថា មុនពេលគាត់ចាប់ផ្តើមផ្លាស់ប្តូរវិធីសាស្ត្របង្រៀន សិស្សអវត្តមានច្រើន តែឥឡូវនេះ ចំនួនសិស្សបានកើនឡើង កុមារកាន់តែច្រើនថែមទៀតបានចូលរៀនជាប្រចាំ។ "ឥឡូវនេះ កុមារចង់មកសាលារៀន។ មុនពេលមានប្រព័ន្ធថ្មី គ្រូបង្រៀនចូលក្នុងថ្នាក់ ហើយច្រាប់កុមារឱ្យបន្តការអានសៀវភៅក្នុងថ្នាក់ ហើយគោលបំណងរបស់យើង គឺត្រូវឱ្យសិស្សរាល់គ្នាក្នុងថ្នាក់ ស្ងៀមស្ងាត់ និងខំព្យាយាមសិក្សា។ ឥឡូវនេះ ការបង្រៀនភាគច្រើនបំផុតគឺតាមរយៈបច្ចេកទេសដែលមានការចូលរួម និងការសិក្សាដោយផ្អែកលើសកម្មភាពអនុវត្តផ្ទាល់"។

ការរៀនសូត្រយ៉ាងសកម្ម និងមានការចូលរួមរបស់សិស្ស អាចប្រើមធ្យោបាយជាច្រើនដែលជួយកុមារក្នុងការរៀន។ មធ្យោបាយចំនួន ៧ ដែលជួយកុមារឱ្យរៀន មានដូចខាងក្រោម :

- **មធ្យោបាយផ្ទាល់មាត់ ឬភាសាវិទ្យា** សម្រាប់កុមារខ្លះដែលគិត និងរៀនតាមរយៈពាក្យ និយាយឬសរសេរ ការចងចាំ និងតាមរយៈការរំលឹកឡើងវិញ។
- **មធ្យោបាយគណិតវិទ្យា ឬមធ្យោបាយតក្កវិទ្យា** សម្រាប់កុមារខ្លះដែលអាចគិត និងរៀនតាមរយៈការរកហេតុផល និងការគណនា។ កុមារអាចប្រើលេខដោយងាយស្រួល ចេះលេខប្រភាគ និងអាចវាស់វែងបានច្បាស់លាស់។
- **មធ្យោបាយលំហ ឬមើលឃើញនឹងភ្នែក** សម្រាប់កុមារខ្លះដែលចូលចិត្តសិល្បៈ ដូចជា គំនូរឬរូបចម្លាក់។ ពួកគេអាចមើលដែនទី តារាង និងដ្យាក្រាមដោយងាយស្រួល។
- **មធ្យោបាយដោយរាងកាយ ឬចលនា** សម្រាប់កុមារខ្លះដែលរៀនតាមរយៈចលនារាងកាយល្បែង និងការសម្តែង។
- **មធ្យោបាយតន្ត្រី ឬចង្វាក់ភ្លេង** សម្រាប់កុមារខ្លះដែលរៀនបានល្អបំផុតតាមរយៈសម្លេង ចង្វាក់ពាក្យចួន និងការបន្ទរសម្លេងតាម។
- **មធ្យោបាយអន្តរបុគ្គល** សម្រាប់កុមារខ្លះរៀនជាក្រុម ។ល។ យ៉ាងងាយ តាមរយៈការងារដែលមានកិច្ចសហការគ្នា។ ពួកគេចូលចិត្តសកម្មភាពជាក្រុម ពួកគេយល់ដោយងាយពីស្ថានភាពសង្គម ហើយពួកគេអាចអភិវឌ្ឍទំនាក់ទំនងជាមួយអ្នកដទៃបានយ៉ាងងាយស្រួល។
- **មធ្យោបាយចរិយាផ្ទាល់ខ្លួន** សម្រាប់កុមារខ្លះ ដែលរៀនបានល្អតាមរយៈការផ្តោតអារម្មណ៍ផ្ទាល់ខ្លួន និងការឆ្លុះបញ្ចាំងខ្លួនឯង។ ពួកគេអាចធ្វើការម្នាក់ឯងបានស្រួល ដឹងពីអារម្មណ៍ផ្ទាល់ខ្លួន និងដឹងពីចំណុចខ្លាំង និងចំណុចខ្សោយផ្ទាល់ខ្លួន។

៨ បង្កើតថ្នាក់រៀនកុមារមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព

នៅពេលកុមាររៀន កុមារអាចប្រើមធ្យោបាយទាំងនេះដើម្បីងាយយល់ និងងាយចងចាំ។ អាស្រ័យហេតុនេះហើយ ចាំបាច់ គ្រូត្រូវប្រើវិធីសាស្ត្របង្រៀនផ្សេង។ ដោយបូកបញ្ចូគ្នា នូវមធ្យោបាយសិក្សាទាំងនេះ។

អ្នកគ្រូ Shikha បានព្យាយាមអនុវត្តការយល់ដឹងរបស់គាត់ស្តីពីមធ្យោបាយសិក្សាចម្រុះ :

"ពីប្រធានបទនៃមេរៀន និងអ្វីដែលកុមារត្រូវការរៀន ខ្ញុំគិតពិចារណាអំពីមធ្យោបាយទាំង៧ សម្រាប់ការសិក្សា ហើយបានព្យាយាមបង្កើតសកម្មភាពនានាជុំវិញមធ្យោបាយទាំងនេះ ដែលទាក់ទងនឹងប្រធានបទ។ ឧទាហរណ៍ ប្រធានបទក្នុងថ្នាក់សិក្សាសង្គមរបស់ខ្ញុំពាក់ព័ន្ធនឹងរដូវ និងផ្លែឈើតាមរដូវ។ កុមារ និងខ្ញុំ បានសរសេរកំណាព្យស្តីពីផ្លែឈើ ចំណែកកុមារខ្លះបានរចនា និងបង្កើតរបាំងមុខជារូបផ្លែឈើដែលមានពណ៌ស្រស់ៗ។ កុមារម្នាក់ៗបានជ្រើសរើសផ្លែឈើដែលខ្លួនពេញចិត្ត ពាក់របាំងមុខ ហើយលេងសម្តែងតួផ្លែឈើ។ កុមារធ្វើការជាក្រុម ហើយអាន និង សរសេរឈ្មោះផ្លែឈើខ្លះផងដែរ។

វិធីសាស្ត្រស្រដៀងគ្នាមួយត្រូវបានប្រើសម្រាប់ប្រធានបទ "មុខរបរក្នុងសហគមន៍"។ កុមារផ្តល់ឈ្មោះមុខរបរផ្សេង។ គិតស្រមៃ និងសម្តែងរឿងអំពីមុខរបរអ្វីមួយដែលពួកគេចង់ធ្វើ ចង់ពិភាក្សាអំពីមុខរបរទាំងនោះជាក្រុម។ និងអានរឿងអំពីមុខរបរ។ ខ្ញុំតែងលាយបញ្ចូលជំនាញភាសាក្នុងមេរៀនសិក្សាសង្គម។ ខ្ញុំនៅតែសាកល្បងអ្វីផ្សេង។ ហើយត្រូវការធ្វើឱ្យសហគមន៍ក្នុងស្រុករបស់យើងយល់ថា ការសិក្សាក្នុងថ្នាក់រៀនមិនត្រូវបានរឹតបន្តឹងឡើយ"។

យើងត្រូវរៀបរៀងកិច្ចតែងការបង្រៀន និងគ្រប់គ្រងថ្នាក់រៀនតាមវិធីនានា ដើម្បីធានាឱ្យមានការសិក្សាដ៏សកម្ម និងប្រកបដោយប្រសិទ្ធភាព សម្រាប់កុមារទាំងអស់។ យើងនឹងរៀនថែមទៀត អំពីកិច្ចតែងការបង្រៀនក្នុងកម្រងសៀវភៅក្រោយ ស្តីពីការគ្រប់គ្រងថ្នាក់រៀនកុមារមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព។ ប៉ុន្តែ អ្នកគ្រូ Shikha បានយល់ដឹងអំពីសារៈសំខាន់នៃកិច្ចតែងការបង្រៀនយ៉ាងច្បាស់។

"ដោយគ្មានមន្ទិលសង្ស័យ កិច្ចតែងការបង្រៀនគឺត្រូវចំណាយពេលវេលានៅពេលឥឡូវនេះ ប៉ុន្តែវាផ្តល់ការកំសាន្ត និងការប្រកួតប្រជែង ចំពោះការច្នៃប្រឌិតរបស់ខ្ញុំ។ ជួនកាល វាមានការលំបាកជងដែរ ក្នុងការទទួលបាននូវប្រភេទធនធានត្រឹមត្រូវដែលខ្ញុំត្រូវការ ប៉ុន្តែខ្ញុំបានឱ្យកុមារចូលរួមរៀបចំកិច្ចតែងការបង្រៀន។ ដោយដឹងអ្វីដែលត្រូវការ កុមារនាំយកសម្ភារផ្សេងៗពីផ្ទះ។ យើងក៏បានអភិវឌ្ឍសម្ភាររួមគ្នាក្នុងថ្នាក់ ដូចជារបាំងមុខសម្រាប់ការសម្តែង ឧបករណ៍សម្រាប់មុខរបរផ្សេងៗ ល្បែង និងកំណាព្យ។"



សកម្មភាពឆ្លុះបញ្ចាំង : ការកែលំអមេរៀនរបស់អ្នក

- ចូរជ្រើសរើសមេរៀនមួយដែលអ្នកចូលចិត្តបង្រៀន ប៉ុន្តែសិស្សរបស់អ្នកអនុវត្តមិនសម្រេចតាមការរំពឹងទុករបស់អ្នកទេ។ ជម្រើសផ្សេងពីនេះ ចូរជ្រើសរើសមេរៀនមួយដែលអ្នកចង់បង្រៀនឱ្យមានភាពកាន់តែរីករាយផ្ទៀង។
- តើចំណុចសំខាន់ៗ (ព័ត៌មាន) អ្វីខ្លះទៅ ដែលអ្នកចង់ឱ្យកុមាររៀន?
- តើវិធីសាស្ត្រអ្វីទៅដែលអ្នកប្រើ ដើម្បីទំនាក់ទំនងព័ត៌មានទាំងនេះ? ហេតុអ្វីបានជាអ្នកគិតថាវិធីសាស្ត្រទាំងនេះមិនអាចអនុវត្តបានល្អ? ឧទាហរណ៍ តើកុមារនឹងប្រឹមធ្យោបាយសិក្សាតែមួយប៉ណ្ណោះឬយ៉ាងណា?
- តើសកម្មភាពផ្សេងគ្នាអ្វីខ្លះទៅដែលអ្នកអាចប្រើក្នុងការបង្រៀន ដើម្បីឱ្យកុមារអាចប្រើញាណ (ចក្ខុវិញ្ញាណ សោតវិញ្ញាណ កាយវិញ្ញាណ) ក្នុងការសិក្សា? តើមធ្យោបាយសិក្សាផ្សេងៗអ្វីខ្លះដែលត្រូវប្រើ? (ចូរអានគំនិតរបស់អ្នកគ្រូ Shika)។
- តើអ្នកអាចបញ្ចូលសកម្មភាពទាំងនេះទៅក្នុងកិច្ចតែងការបង្រៀនរបស់អ្នក ដោយរបៀបណា?
- តើកុមាររបស់អ្នកអាចរួមចំណែកដោយរបៀបណា ក្នុងកិច្ចតែងការបង្រៀន ជាពិសេស កុមារមិនបានចូលរួមក្នុងថ្នាក់ ឬកុមារដែលមានប្រវត្តិ និងសមត្ថភាពខុសគេ?
- ចូរសាកល្បងមេរៀន! ប្រសិនបើអ្នកមានអារម្មណ៍ស្រួលក្នុងការធ្វើដូច្នេះ ចូរសួរសិស្សរបស់អ្នកថាតើពួកគេចូលចិត្តមេរៀននេះឬទេ? តើសកម្មភាពអ្វីខ្លះដែលពួកគេចូលចិត្តបំផុត? តើអ្នកអាចប្រើសកម្មភាពទាំងនេះ ដើម្បីបង្រៀនមេរៀនដទៃទៀតឬទេ?

ឧបសគ្គចំពោះការសិក្សា

តើអ្នកអាចចាំកុមារម្នាក់ក្នុងថ្នាក់ណាមួយរបស់អ្នក ដែលជាធម្មតា មានលក្ខណៈទុយម៉ុយ មិនចង់ចូលរួម ហើយមិនដែលលើកដៃក្នុងថ្នាក់ និងរៀនមិនបានពូកែដែរឬទេ? មូលហេតុមួយសម្រាប់អាកប្បកិរិយាកុមារនេះអាចមកពីកុមារនេះ មានការគោរពខ្លួនឯងទាបពេក ឬមិនឲ្យតម្លៃខ្លួនឯង។ កុមារនេះមិនមានជំនឿជឿជាក់ចំពោះសមត្ថភាពរបស់ខ្លួន ឬអាចគិតថា ខ្លួនមិនមែនជាសមាជិកក្នុងថ្នាក់រៀនដែលមានតម្លៃម្នាក់ឡើយ។ ការសិក្សាបានបង្ហាញឱ្យឃើញទំនាក់ទំនងដ៏ជិតស្និទ្ធមួយរវាងរបៀបដែលកុមារមើលឃើញខ្លួនឯង

និង៍សកម្មភាពរៀនសូត្រដោយខ្លួនឯង៍។ គេយល់ឃើញថា កុមារម្នាក់ដែលមានការគោរពខ្លួនឯង៍ទាប ដោយសារតែចម្លើយត្រលប់អវិជ្ជមាន (ការទិតៀន) នៅពេលមិនយូរ កុមារនោះ យល់តែម្នាក់ឯង៍ថា ការដែលប្រសើរ គឺមិនចាំបាច់ព្យាយាមរៀនអ្វីឡើយ។ ប្រសិនជារៀនទៅ វាមិនជាប់ដដែល ខ្ញុំនឹង៍ឈប់រៀនហើយ។



សកម្មភាពអនុវត្ត : តម្លៃនៃការគោរពខ្លួនឯង

ចូរយកក្រដាសមួយសន្លឹក ហើយគូររូបមុខមនុស្សមួយ។ មុខនេះ ជាមុខរបស់កុមារម្នាក់ក្នុង៍ចំណោមសិស្សរបស់អ្នក។ ចូរគិតអំពីអ្វី ៗដែលមនុស្សពេញវ័យអាចនិយាយទៅកាន់កុមារនេះ ដែលធ្វើឱ្យកុមារនេះមានអារម្មណ៍មិនល្អអំពីខ្លួនឯង៍។ សម្រាប់ឧទាហរណ៍នីមួយ ៗដែលអ្នកអាចគិតដល់ ឬអង្កេតមើលក្នុង៍មួយសប្តាហ៍ ចូរហែកក្រដាសនោះចោល។



ត្រូវប្រើសំដីទាំង៍នេះ បី ឬបួនដង៍ដើម្បីធ្វើឱ្យកុមារអស់មានអារម្មណ៍គោរពខ្លួនឯង៍។

(កំណត់សម្គាល់ : អ្នកអាចធ្វើសកម្មភាពនេះ ជាមួយកុមារ ដើម្បីជួយពួកគេឲ្យយល់ពីអារម្មណ៍របស់អ្នកដទៃ និង៍យល់ថា សកម្មភាពរបស់ពួកគេប៉ះពាល់អារម្មណ៍ទាំង៍នោះដោយរបៀបណា)។

ពេលយើង៍ឮសំដីអវិជ្ជមានដែលបានប្រើចំពោះកុមារ យើង៍ត្រូវប្តូរវាទៅជាសំដីវិជ្ជមានវិញ។ ឧទាហរណ៍ សំដីអវិជ្ជមាន "ឯង៍នេះល្ងង់ណាស់។ មើលនែ៎ តើចម្លើយខុសប៉ុន្មាន?" អាចប្តូរទៅជា "ចូរជ្លៀង៍ចម្លើយ តើអ្នកឆ្លើយត្រូវប៉ុន្មាន? លើកក្រោយគួរធ្វើឱ្យត្រូវច្រើនជាង៍នេះ។ អ្វីដែលបានជួយអ្នកឱ្យចង៍ចាំគឺចម្លើយណាដែលអ្នកបានធ្វើត្រូវ?"។

មុនពេលកុមារចូលរួមពេញលេញក្នុង៍ការរៀនសូត្រ កុមារត្រូវការជឿថា ពួកគេមានសមត្ថភាពចូលរៀន។ កុមារនឹង៍លើកកម្ពស់ការគោរពខ្លួនឯង៍ និង៍អត្តសញ្ញាណរបស់ខ្លួននៅពេលពួកគេធំធាត់ឡើង៍

ហើយមនុស្សពេញវ័យនឹងដើរតួនាទីជាវិធីមាំក្នុងការធំធាត់របស់កុមារ។ កុមារអាចខូចអារម្មណ៍បាននៅពេលភេទ ប្រវត្តិ ជនជាតិភាគតិច ឬសមត្ថភាពពួកគេមិនត្រូវបានផ្តល់តម្លៃ ឬត្រូវបានប្រើដើម្បីធ្វើឱ្យពួកគេមានអារម្មណ៍ថាអន់ខ្សោយ ឬ គ្មានសមត្ថភាព។

យើងមិនអាចផ្តល់ដល់កុមារនូវការគោរពខ្លួនឯងដែលមានលក្ខណៈវិជ្ជមានឡើយ ប៉ុន្តែយើងអាចផ្តល់បរិយាកាស និងលក្ខខណ្ឌ ត្រឹមត្រូវសម្រាប់ការគោរពនេះដើម្បីអភិវឌ្ឍ។ កុមារទាំងអស់គួរ :

- មានអារម្មណ៍ថា ពួកគេ និងការរួមចំណែករបស់ពួកគេត្រូវបានផ្តល់តម្លៃ
- មានអារម្មណ៍ថា មានសុវត្ថិភាព (ទាំងរាងកាយ និងអារម្មណ៍) នៅក្នុងបរិយាកាសរៀនសូត្រ
- មានអារម្មណ៍ថា គំនិតពួកគេមានតម្លៃថ្លៃថ្លា

និយាយឱ្យងាយគឺថា គួរផ្តល់តម្លៃដល់កុមារថា ពួកគេជាអ្នកណា។ កុមារគួរមានអារម្មណសុវត្ថិភាពអាចសម្តែងចេញទស្សនៈរបស់ខ្លួន និងទទួលជោគជ័យក្នុងការសិក្សារបស់ខ្លួន។ កត្តានេះជួយកុមារឱ្យចូលចិត្តរៀនសូត្រ ហើយគ្រូបង្រៀនអាចធ្វើឱ្យមានការចូលចិត្ត នេះតាមរយៈការបង្កើតថ្នាក់រៀនមួយដែលសប្បាយរីករាយថែមទៀត។ ថ្នាក់រៀនបែបនេះគឺជាថ្នាក់រៀនមួយដែលជំរុញឱ្យមានការគោរពខ្លួនឯងរបស់កុមារតាមរយៈការសរសើរ ជាថ្នាក់ដែលលើកទឹកចិត្តការរៀបជាក្រុម ។ដែលមានភាពរាក់ទាក់ និងសហការគ្នា និងជាកន្លែង ដែលកុមារមានអារម្មណ៍ទទួលជោគជ័យ និងមានការសប្បាយរីករាយក្នុងការរៀនអ្វី ។ដែលថ្មី។



សកម្មភាពអនុវត្ត : ការកែលំអការគោរពខ្លួនឯង

សកម្មភាពនេះអាចធ្វើជាមួយគ្រូ សិស្ស មាតាបិតា ឬសមាជិកសហគមន៍ដទៃទៀត។

- ចូរចែកផ្ទាំងក្រដាសធំមួយ ឬផ្ទៃសរសេរសមរម្យណាមួយជាបីខ្នងស្មើគ្នា។
- នៅខ្នងខាងឆ្វេងដៃ ចូរសរសេរជាបញ្ជីរនូវស្ថានភាពនានាក្នុងថ្នាក់រៀន ឬសាលារបស់អ្នក ដែលសិស្សអាចមានអារម្មណ៍ថា ត្រូវមិនបានផ្តល់តម្លៃ និងមានសុវត្ថិភាព ។
- នៅខ្នងកណ្តាលនៅជាប់ស្ថានភាពនីមួយ។ ចូរស្រង់ជាបញ្ជីមូលហេតុដែលអ្នកគិតថា បរិយាកាស ឬមនុស្សខាងក្រៅធ្វើឱ្យកុមារមានអារម្មណ៍ដូច្នេះ។
- នៅខ្នងខាងស្តាំដៃ ចូរស្រង់ជាបញ្ជីនូវអ្វីដែលអាចផ្លាស់ប្តូរបាន ដើម្បីឱ្យកុមារមានអារម្មណ៍ថាត្រូវបានផ្តល់តម្លៃ មានសុវត្ថិភាព និងស្ថិតក្នុងស្ថានភាពដូចកុមារដទៃដែរ ហើយស្រង់ជាបញ្ជីថា តើការផ្លាស់ប្តូរទាំងនេះអាចកើតមានដោយរបៀបណា?

ចូរប្រើសកម្មភាពនេះជាចំណុចចាប់ផ្តើមសម្រាប់ការអភិវឌ្ឍផែនការសកម្មភាព ដើម្បីកែលំអការគោរពខ្លួនឯង និងការសិក្សារបស់កុមារ ក្នុងថ្នាក់សាលា និងក្នុងសហគមន៍។

កុមារបង្កើតចំណេះដឹង និងអត្ថន័យផ្ទាល់របស់ខ្លួនយ៉ាងសកម្ម

កុមាររៀនដោយការភ្ជាប់ព័ត៌មានថ្មីៗជាមួយព័ត៌មានដែលគេបានដឹងរួចហើយ។ ការចេះដឹងបែបនេះមានឈ្មោះថា សំណង់ខួរក្បាល។ ការជជែកគ្នា និងការសួរសំណួររួមគ្នា (ទំនាក់ទំនងសង្គម) អាចកែលំអការរៀន ដូច្នេះ ហើយការងារជាក្រុម និងជាគូមានសារៈសំខាន់យ៉ាងខ្លាំង។

តួនាទីរបស់យើងជាគ្រូបង្រៀន គឺមិនមែនចាក់បញ្ចូលព័ត៌មានទៅក្នុងខួរក្បាលរបស់កុមារឡើយ នេះជាការមិនត្រឹមត្រូវឡើយ ដោយទុកឱ្យសិស្សស្វែងរកអ្វីផ្សេងៗដោយខ្លួនឯង។ យើងគួរស្វែងរកមធ្យោបាយគាំទ្រការសិក្សាយ៉ាងសកម្ម ដោយប្រើព័ត៌មានដែលកុមារដឹងមុនរួចជាស្រេច (ការរៀនមុនៗរបស់កុមារ)។

កុមារអាចយឺតយ៉ាវក្នុងការសម្របខ្លួនទៅនឹងការសិក្សានៅសាលា ហើយកុមារមិនដឹងថានឹងត្រូវនិយាយអ្វី នៅពេលគ្រូសួរសំណួរមួយឡើយ។ ក្នុងករណីនេះ អ្នកត្រូវបង្កើតទំនាក់ទំនងដ៏ល្អមួយជាមួយកុមារ ដើម្បីស្វែងយល់ថា កុមារអាចរៀនបានល្អដោយរបៀបណា។ ឧទាហរណ៍ តើការងារធម្មតាៗអ្វីខ្លះដែលកុមារនេះអាចធ្វើបាន? តើអក្សរអ្វីខ្លះក្នុងឈ្មោះដែលកុមារនោះចេះចាំបាន ហើយអាចសរសេរតាមបានត្រឹមត្រូវ? តើកុមារនោះចេះលេខអ្វីខ្លះ ហើយអាចប្រើវត្ថុផ្សេងៗក្នុងថ្នាក់រៀនដើម្បីរាប់ចំនួនបានឬទេ? តើវត្ថុពិសេសៗអ្វីខ្លះដែលកុមារនេះចូលចិត្ត ហើយអាចនិយាយអំពីវត្ថុនោះជាមួយគ្រូបង្រៀន ជាមួយកុមារម្នាក់ទៀត ឬជាមួយតុក្កតាធម្មតាមួយក្នុងថ្នាក់? តើកុមារនេះចេះច្រៀង ឬលេងល្បែងកំសាន្តផ្សេងៗឬទេ?

លើសពីនេះទៀត តើយើងអាចធ្វើទំនាក់ទំនងរវាងសាលាជាមួយផ្ទះ និងសហគមន៍របស់កុមារដោយរបៀបណា?



សកម្មភាពអនុវត្ត : ការភ្ជាប់ទំនាក់ទំនងរវាងផ្ទះ និងថ្នាក់រៀន

ក្នុងតារាងខាងក្រោម ចូរសរសេរសកម្មភាពនានាដែលសិស្សរបស់អ្នកបានរៀននៅផ្ទះ ហើយដែលពួកគេអាចប្រើក្នុងថ្នាក់រៀន។

តើអ្នកអាចបញ្ចូលព័ត៌មានទាំងនេះក្នុងកិច្ចតែងការបង្រៀនរបស់អ្នកដោយរបៀបណា? តើអ្នកអាចអនុញ្ញាតឱ្យសិស្សចូលរួមក្នុងការរៀបចំកិច្ចតែងការបង្រៀនដោយរបៀបណា?

ឈ្មោះសិស្ស	តើសិស្សនេះបានរៀនអ្វីខ្លះនៅផ្ទះ?	តើការចេះដឹងនៅផ្ទះនេះអាចយកមកប្រើនៅសាលាឬទេ?

គ្មានកុមារណាម្នាក់មកសាលា ដោយមិនបានរៀនអ្វីសោះនៅផ្ទះ ឬនៅសហមន៍នោះឡើយ។ ទោះជាក្នុងសាលា ឬក្រៅសាលាក្តី កុមារឆ្លើយតបចំពោះស្ថានភាពថ្មីៗក្នុងវិធីផ្សេងៗគ្នាជាច្រើន។ វិធីខ្លះនឹងមានប្រយោជន៍នៅសាលារៀន ចំណែកខ្លះទៀតអាចមិនមានប្រយោជន៍សោះឡើយ ហើយនេះជាការទទួលខុសត្រូវរបស់យើងក្នុងការរកឱ្យឃើញថា កុមារចេះអ្វី ហើយជំនាញអ្វីខ្លះដែលកុមារបានរៀនរួចហើយ។ បន្ទាប់មក ដោយផ្អែកលើចំណេះដឹង និងជំនាញទាំងនេះ យើងអាចបង្កើតការបង្រៀនអ្វីដែលថ្មីៗដល់កុមារ។ ប៉ុន្តែដើម្បីធ្វើដូច្នេះបាន យើងត្រូវអង្កេតមើលកុមាររបស់យើងឱ្យបានកៀក និងអង្កេតមើលរបៀបណាមួយដែលកុមារៀនពីគំនិត បំណិន ជំនាញ និងតម្លៃថ្មីៗ។ ក្នុងករណីជាច្រើន បទពិសោធរបស់កុមារីខុសឆ្ងាយពីបទពិសោធរបស់កុមារា។

នៅសាលារៀន កុមាររបស់យើងត្រូវប្រឈមជាមួយការកិច្ចជាច្រើនដែលអាចខុសគ្នាច្រើន ពីការកិច្ចនិងបញ្ហានានាដែលពួកគេត្រូវដោះស្រាយ ក្នុងអំឡុងពេលរៀន។ កុមារខ្លះអាចមិនធ្លាប់កាន់ខ្មៅដៃពីមុនឡើយ កុមារខ្លះអាចមិនធ្លាប់ឃើញសៀវភៅឡើយ កុមារខ្លះទៀតអាចមិនធ្លាប់និយាយភាសាដែលអ្នក និងមិត្តរួមថ្នាក់និយាយឡើយ។ ហេតុដូច្នេះ ជាការសំខាន់ ត្រូវបង្កើតទំនាក់ទំនងជាច្រើន រវាងអ្វីដែលកុមារបានដឹង និងចេះធ្វើបានល្អ ជាមួយនឹងភារកិច្ចថ្មីៗដែលថ្នាក់រៀន និងមេរៀនរបស់អ្នកជាគ្រូធ្វើ។ តើបញ្ហានេះអាចត្រូវបានដោះស្រាយដោយរបៀបណា?



សកម្មភាពអនុវត្ត : ការបង្កើតទំនាក់ទំនងសម្រាប់អ្នកសិក្សា

នៅកម្រិតអប់រំមូលដ្ឋាន សាលារៀនត្រូវរំពឹងថា នឹងបង្រៀនកុមារឱ្យចេះអំពីរបៀបអាន និងប្រើលេខ។ នៅពេលកុមារមកសាលារៀន និងនៅថ្ងៃចូលរៀនដំបូង តើសកម្មភាពធម្មតាអ្វីខ្លះដែលអ្នកអាចធ្វើបាន ដើម្បីឱ្យកុមារទាំងនោះទទួលជោគជ័យក្នុងការរៀនអាន និងប្រើលេខ? ខាងក្រោម ជាឧទាហរណ៍ខ្លះ។ តើអ្នកអាចគិតឃើញឧទាហរណ៍ខ្លះទៀតបានដែរឬទេ?

- ចូរដាក់ស្លាកលើវត្ថុនានាជាមួយកុមារជុំវិញបន្ទប់ដោយមានឈ្មោះដែលយើងផ្តល់ឱ្យវត្ថុទាំងនេះ (ជាភាសាមួយ ឬភាសា នានាដែលកុមារប្រើ) ឧទាហរណ៍ តុប៊ុយរ៉ូ កៅអី ឈ្មោះរបស់កុមារលើតុក្តារខៀន លេខផ្សេងៗ ដែលដាក់ជាក្រុមជាមួយ វត្ថុផ្សេងៗ។ល។ តើកុមារណាខ្លះអាចធ្វើទំនាក់ទំនងវត្ថុទាំងនេះជាមួយពាក្យទាំងឡាយដែលប្រើជំនួសឱ្យវត្ថុទាំងនេះ?

- អ្នកត្រូវច្រាប់កុមារម្នាក់ៗយ៉ាងហោចណាស់នូវអ្វីមួយដែលពួកគេធ្វើបានល្អ។

- ចូរសរសេរពាក្យនានារបស់ចម្រៀងមួយបទដែលកុមារចេះ ឬអាចរៀនយ៉ាងរហ័ស។ ពិនិត្យមើលតើអ្នកណាអាចទាយពាក្យណាខ្លះបាន។ ពាក្យថ្មីៗអាចត្រូវបានណែនាំឱ្យស្គាល់នៅក្នុងបទចម្រៀងដែលកុមារបានចេះចាំច្បាស់។ ការច្រៀង ជាផ្នែកសំខាន់មួយនៃការសិក្សា ព្រោះវាជួយការដកដង្ហើមរបស់កុមារ បង្កើតវាក្យសព្ទ ចង្វាក់ និងពាក្យចុងចួន និងលើកកម្ពស់សាមគ្គីភាពក្នុងថ្នាក់។

- ចូរផ្តល់ការណែនាំឱ្យបានច្បាស់លាស់ក្នុងថ្នាក់រៀន។ ចូររៀបចំឱ្យកុមារអាយុច្រើនជួយកុមារអាយុក្មេងជាង ដើម្បីយល់អំពីការណែនាំផ្សេងៗដែលអ្នកបានផ្តល់ឲ្យ។

អ្នកអាចមានកុមារណាម្នាក់ដែលមករៀនក្នុងថ្នាក់របស់អ្នក ហើយមិនចេះនិយាយភាសានៅក្នុងថ្នាក់។ ក្នុងករណីនេះ ជាការសំខាន់បំផុតគឺត្រូវរកឱ្យឃើញថា កុមារនេះចេះធ្វើអ្វីខ្លះ។ ជាការមានប្រយោជន៍ប្រសិនបើអ្នកអាចនិយាយជាមួយកុមារម្នាក់ៗ ដោយប្រើឈ្មោះរបស់កុមារជាភាសាកំណើត។ ប្រសិនបើមិនអាចធ្វើបាន ចូររកកុមារដទៃទៀត ឬអ្នកដទៃនៅក្នុងសហគមន៍ ដែលអាចជួយអ្នកធ្វើការច្រាស្រ៊ែយទាក់ទងនិងបង្កើតទំនាក់ទំនងរវាងភាសារបស់កុមារនោះ និងសកម្មភាពថ្នាក់រៀនរបស់អ្នក។ ឧទាហរណ៍ តើអ្នកអាចប្រើចម្រៀងជាភាសាកំណើតរបស់កុមារ ដើម្បីបង្រៀនពាក្យថ្មីៗសម្រាប់ភាសាបង្រៀនក្នុងថ្នាក់របស់អ្នកឬទេ?។ ពាក្យទាំងឡាយ ក្នុងបទចម្រៀងដែលកុមារបានចេះក្នុងភាសាផ្ទាល់របស់ខ្លួន អាចជំនួសបន្តិចម្តងៗដោយពាក្យភាសារៀនក្នុងថ្នាក់។ តើអ្នកអាចប្រើចម្រៀងនេះ ដើម្បីបង្រៀនកុមារទាំងអស់អំពីតម្លៃនៃភាសាផ្សេងៗគ្នាឬទេ?

ដោយបង្កើតការកិច្ចធម្មតាដែលកុមារអាចសម្រេចបានដោយជោគជ័យ ហើយជាពិសេសនៅដើមឆ្នាំសិក្សា កុមារដែលទុយមុយ ទីបំផុតក៏នឹងអាចមានការចាប់ផ្តើមបានល្អផងដែរ។ ពួកគេនឹងមានជំនឿទុកចិត្តថា សាលារៀនគឺជាកន្លែងដ៏ល្អមួយ គឺជាកន្លែងដែលពួកគេមានអារម្មណ៍សុវត្ថិភាព និងជាកន្លែងសម្រាប់ស្រាវជ្រាវ និងរៀនសូត្រ និងជាបរិយាកាសរៀនកុមារមេត្រី។

ចូរចងចាំ: មុនពេលចាប់ផ្តើមប្រធានបទថ្មីមួយ អ្នកត្រូវសួរកុមារទាំងអស់ថា ពួកគេបានដឹងអ្វីខ្លះអំពីប្រធានបទនោះ។ ការសួរសំណួរនេះនឹងជួយកុមារឱ្យមានទំនាក់ទំនងជាមួយប្រធានបទ ប្រសិនបើវាជាប្រធានបទមួយដែលពួកគេធ្លាប់ដឹងពីមុនមក ហើយនឹងជួយកុមារឱ្យយល់ និងរៀនបានកាន់តែរហ័ស។ កុមារអាចទទួលបានចំណេះដឹងជាច្រើននៅក្រៅថ្នាក់រៀន ដូចជា នៅផ្ទះ ឬនៅសហគមន៍។ ព័ត៌មាននេះនឹងជួយ

ដំបូន្មានសម្រាប់ការបង្រៀន និងការរៀន

- មេរៀនត្រូវការរៀបចំដោយប្រើ "គំនិតធំៗ" ជាជាងផ្នែកផ្សេងៗនៃព័ត៌មានដែលមិនជាប់ទាក់ទងគ្នា។ ក្នុងរបៀបនេះ កុមារមានជំហ្រមួយដែលនៅពីក្រោមជំហ្រនោះពួកគេអាចតម្រូវព័ត៌មានថ្មីៗជាមួយអ្វីដែលគេបានដឹងរួចហើយ។ គំនិតធំមួយអាចជាអ្វីមួយដូចជា "ទឹកមានសារៈសំខាន់ចំពោះជីវិត" ហើយប្រធានបទអាចជា "ថ្ងៃនេះ យើងនឹងរៀនវិធីរក្សាទឹកឱ្យមានអនាម័យ"។
- យើងត្រូវការពិចារណាអំពីតម្រូវការអភិវឌ្ឍរបស់កុមារ។ កុមារខ្លះត្រូវការពេលច្រើនថែមទៀតជាងកុមារដទៃទៀត សម្រាប់ទទួលបានការវិកចម្រើន។
- យើងត្រូវការធ្វើជាអ្នកសម្របសម្រួលការសិក្សា ហើយទទួលស្គាល់ចរិតលក្ខណៈមិនដូចគ្នារបស់អ្នកសិក្សារបស់យើង។ បរិយាកាសរៀន គួរគាំទ្រអ្នកសិក្សាទាំងអស់។
- សិស្សត្រូវការពិភាក្សារួមគ្នាជាមួយគ្រូបង្រៀន និងជាមួយគ្នាទៅវិញទៅមកក្នុងអំឡុងពេលធ្វើសកម្មភាពផ្សេងៗ ទាំងសកម្មភាពជាបុគ្គល និងជាក្រុម។
- យើងត្រូវការរៀបចំសកម្មភាពផ្សេងៗដែលលើកទឹកចិត្តកុមារទាំងអស់ធ្វើការជាក្រុមការងារ ដូចជាធ្វើការជាគូ ឬជាក្រុមតូចៗលើកិច្ចការអ្វីមួយ។
- សិស្សត្រូវយល់ថា កម្មវិធីសិក្សាមានប្រយោជន៍ចំពោះពួកគេ ត្រូវបានលើកទឹកចិត្តឱ្យសួរសំណួរ និងពិចារណាព័ត៌មាន ហើយនិងយល់ពីខ្លឹមសារផ្ទាល់ខ្លួន។
- យើងត្រូវសួរសំណួរល្អ។ ដើម្បីឱ្យសិស្សពន្យល់ពីគំនិតពួកគេ។ ក្រៅពីការសួរសំណួរដែលទាមទារនូវចម្លើយ"បាទ/ចាស"ឬ"ទេ" យើងត្រូវការសួរសំណួរមិនកំណត់ផងដែរដើម្បីឱ្យសិស្សសម្តែងចេញទស្សនៈ គំនិត និងយោបល់របស់ខ្លួន ឧទាហរណ៍ សំណួរដែលបញ្ចប់ ដោយ "តើអ្នកគិតយ៉ាងដូចម្តេចដែរ?"។
- សំណួរដែលគ្រូបានសួរ និងការពិភាក្សាដ៏សកម្មរវាងសិស្សនឹងជួយជំរុញកុមារធ្វើការស្រាវជ្រាវរកព័ត៌មាន។ ការទាក់ទងជាមួយអ្នកដទៃ ការទទួលព័ត៌មានថ្មីៗ និងការឆ្លុះបញ្ចាំងលើគំនិតនានា ជួយកុមារបង្កើតចំណេះដឹងថ្មីៗ។

យើងជ្រាវរកឃ្លាប់អ្វីដែលកុមារបានដឹងក្នុងជីវភាពប្រចាំថ្ងៃ ទៅនឹងអ្វីដែលជាចំណេះដឹងថ្មីៗដែលយើងកំពុងបង្រៀន។ ជាងនេះទៀត កុមារខ្លះអាចជា "អ្នកជំនាញ" លើប្រធានបទមួយចំនួន ដូចជា ការនេសាទត្រី ឬការដាំបន្លែ ហើយកុមារទាំងនេះគួរទទួលបានឱកាសដើម្បីបង្ហាញចំណេះដឹងរបស់ខ្លួនសម្រាប់ជាផលប្រយោជន៍ដល់ថ្នាក់រៀនទាំងមូល។

លើសពីនេះទៀត កុមារនឹងរៀនកាន់តែប្រសើរឡើង តាមរយៈការរៀនដែលមានកិច្ចសហការ ("យើងអាចធ្វើការងាររួមគ្នា") ជាជាងមធ្យោបាយសិក្ខានានាដែលមានលក្ខណៈប្រកួតប្រជែង ("ខ្ញុំពូកែខាងកិច្ចការនេះជាងអ្នក ពីព្រោះអ្នក .....")។ ប្រសិនបើរៀបចំបានល្អ ការងារជាក្រុមតូចៗអាចលើកទឹកចិត្តកុមារឱ្យធ្វើការ និងរៀនរួមគ្នា។ ទំនាក់ទំនងនេះមានសារៈសំខាន់ណាស់ ជាពិសេស នៅពេលក្រុមនីមួយៗមានសមាសភាពទាំងកុមារា និងកុមារី ឬនៅពេលក្រុមនីមួយៗមានកុមារដែលមានប្រវត្តិ និងសមត្ថភាពខុសគេ។ ជាងនេះទៀត ការសិក្ខាដែលមានកិច្ចសហការគ្នាអាចកែលំអវិនិយក្នុងថ្នាក់ ពីព្រោះកុមារទាំងអស់កំពុងធ្វើការរួមគ្នា ជាជាងកំពុងទទួលការរំខាន។ ការរៀនបែបនេះអាចផ្តល់ឱ្យយើងនូវពេលវេលាដើម្បីធ្វើការគាំទ្រកុមារម្នាក់ៗ ឬក្រុមពិភាក្សាតូចៗ។



គោល ៤.២
ដំណោះស្រាយបញ្ហានានាភាពក្នុងថ្នាក់រៀន

ការវាយតម្លៃ និងការលើកទឹកចិត្តឱ្យមាននានាភាពក្នុងថ្នាក់រៀន

ថ្នាក់រៀនទាំងអស់មានលក្ខណៈផ្សេងៗគ្នាពីព្រោះកុមារទាំងអស់មានលក្ខណៈពិសេសរបស់ខ្លួន។ ថ្នាក់រៀនដែលមាននានាភាពអាចមានផលប្រយោជន៍វិជ្ជមានសម្រាប់អ្នកសិក្សាទាំងអស់។ កុមារមានបទពិសោធ ជំនាញ ចំណេះដឹង និងកិរិយាមារយាទផ្សេងៗគ្នា។ កុមារទាំងអស់អាចរួមចំណែក និងនាំគ្រឿងផ្សំមួយចំនួនសម្រាប់ដាក់ក្នុង "ស៊ុប" នៃការសិក្សា។ គ្រូបង្រៀនធ្វើជាអ្នកសម្របសម្រួលម្នាក់ដែលផ្តល់បរិយាកាស និងឱកាសត្រឹមត្រូវសម្រាប់កុមារទាំងអស់ ដើម្បីរៀនឱ្យបានសកម្ម។

កុមារ (ហើយជួនកាល មនុស្សពេញវ័យ) ត្រូវការដឹងថា នានាភាព ជាអំណោយមួយមិនមែនជាការទទួលខុសត្រូវឡើយ។ ក្នុងកម្រងសៀវភៅទី២ ក្នុងគោល ២.២ យើងបានរៀនសកម្មភាពមួយហៅថា "ការលេងជាមួយវត្ថុដែលចូលចិត្ត" ជាសកម្មភាពមួយអាចឱ្យមាតាបិតា និងកុមារដឹងថា វាមាននិយមដូចម្តេចនៅពេលដែលត្រូវបានគេច្រានចោលមិនអើពើ និងដឹងថា ហេតុអ្វីបានជាការបញ្ចូលគ្រប់សមាសភាពមានសារៈសំខាន់សម្រាប់មនុស្សគ្រប់ៗរូប។ សកម្មភាពស្រដៀងគ្នានេះដែរ ដូចបង្ហាញខាងក្រោម អាចជួយកុមារ និងមាតាបិតាឱ្យយល់ពីតម្លៃនៃនានាភាព។



សកម្មភាពអនុវត្ត : ការផ្តល់អំណោយ-ការស្គាល់គ្នាទៅវិញទៅមក

គ្រូបង្រៀនអាចជូនអំណោយ ទទួលស្វាគមន៍គ្នានៅពេលជួបគ្នាលើកដំបូង។ គ្រូបង្រៀន អាចប្រើសកម្មភាពនេះ ជាមួយកូនសិស្សពេលជួបគ្នាលើកដំបូងនៅដើមឆ្នាំ។ សកម្មភាពនេះក៏អាចប្រើបាននៅពេលជួបប្រជុំគ្នាជាលើកដំបូង រវាងសមាគមគ្រូបង្រៀន និងសមាគមមាតាបិតា។

សម្រាប់សកម្មភាពនេះ អ្នកចូលរួមទាំងឡាយត្រូវធ្វើការជាគូៗ។ ពួកគេសួរគ្នាទៅវិញទៅមកនូវសំណួរគ្មានកំណត់ ដើម្បីរកឱ្យឃើញថា តើលក្ខណៈសម្បត្តិពិសេសអ្វីខ្លះដែលមនុស្សម្នាក់ៗមាន ហើយអាចផ្តល់ប្រយោជន៍ដល់ក្រុមទាំងមូលបាន។ សេចក្តីថ្លែងការណ៍ចុងក្រោយគួរសរសេរនៅលើ "បំណុំអំណោយ" តូចមួយ ហើយបញ្ជាក់អ្វីមួយដូចខាងក្រោម :

"ឈ្មោះរបស់មិត្តខ្ញុំគឺ .....ហើយគាត់បាននាំមកនូវអំណោយភាពអត់ធ្មត់"។

"ឈ្មោះរបស់មិត្តខ្ញុំគឺ .....ហើយនាងបាននាំមកនូវអំណោយដែលមានលក្ខណៈកំប្លែង"។

បន្ទាប់មក គូនីមួយៗនៃអ្នកចូលរួមផ្លាស់ប្តូរវេនគ្នា បង្ហាញជំនាញគ្នាទៅវិញទៅមក ដល់ក្រុមទាំងមូល។ ពួកគេគួរនិយាយអំពីវិធីដែលជំនាញទាំងនេះ អាចផ្តល់ប្រយោជន៍ដល់អ្នករាល់គ្នា។ គ្រូបង្រៀន ឬអ្នកសម្របសម្រួល គួរតុបតែងប្រអប់មួយសម្រាប់ឱ្យអ្នកចូលរួមម្នាក់ៗដាក់បំណុំរំណោយរបស់ខ្លួនទៅក្នុងប្រអប់ បន្ទាប់ពីបានបង្ហាញ "រង្វាន់ដែលមិត្តភក្តិឱ្យ" ឱ្យក្រុមទាំងមូលមើល។

សកម្មភាពនេះអាចបង្ហាញឱ្យឃើញតម្លៃវិការសម្រាប់ឱ្យគ្រូបង្រៀនវាយតម្លៃកុមារទាំងអស់នៅក្នុងថ្នាក់ ហើយបង្ហាញថា លក្ខណសម្បត្តិផ្ទាល់ខ្លួនជាច្រើនមិនអាចមើលឃើញ ដោយអង្កេតមើលធម្មតាបានឡើយ។ ការទទួលខុសត្រូវរបស់យើង គឺត្រូវកោសផ្ទៃខាងក្រៅចេញ ហើយរកឱ្យឃើញនូវលក្ខណៈពិសេសមួយដែលកុមារម្នាក់ៗមាន។ បន្ទាប់មក យើងអាចបង្កើតបទពិសោធសិក្សាដើម្បីប្រើ និងអភិវឌ្ឍលក្ខណសម្បត្តិទាំងនេះឱ្យបាន។



សកម្មភាពអនុវត្ត : ទំគំរូខាងក្រោម. ចាប់ផ្តើមស្គាល់គ្នាទៅវិញទៅមក និងការរៀនសូត្រពីគ្នាទៅវិញទៅមក

ក្នុងសកម្មភាពនេះ អ្នកចូលរួមត្រូវរៀបជាគូៗធ្វើការជាមួយគ្នា និងស្នើសុំឱ្យគិតអំពីទេពកោសល្យ ចំណាប់អារម្មណ៍ ឬការងារកំសាន្តរបស់ខ្លួន។ បន្ទាប់មក ពួកគេរៀបរាប់ដល់ដៃគូរបស់ខ្លួន នូវទិដ្ឋភាពមួយចំនួននៃការចាប់អារម្មណ៍របស់ខ្លួន និងបង្រៀនអ្វីមួយដែលដៃគូនោះមិនដឹង។ ប្រសិនបើអាចធ្វើបាន អ្នកចូលរួមម្នាក់ៗគួរមានក្រដាសលឿងមួយសន្លឹកដើម្បីសរសេរ។ ដំបូង ពួកគេគួរស្តាប់ដៃគូរបស់ខ្លួន បន្ទាប់មកសរសេរទេពកោសល្យ ឬជំនាញនៅផ្នែកខាងលើ រួចសរសេរឈ្មោះដៃគូរបស់ខ្លួន និងអ្វីផ្សេងៗដែលពួកគេបានរៀនពីជំនាញនោះ។ ឧទាហរណ៍ :

ជំនាញ : ចាប់ត្រី

ចាន់ ម៉ូស៊ីញ៉ូ
អ្វីដែលខ្ញុំបានរៀន .....
រកត្រីនៅពេលយប់ ទើបរកបានច្រើន
ទឹកស្ងប់ស្ងាត់ទើបល្អ ដើម្បីងាយស្រួលចាប់ត្រី
រង់ចាំដល់ខែពេញបូណ៌មី
ប្រភេទត្រីផ្សេង ត្រូវប្រើនុយផ្សេង

បន្ទាប់ពីដៃគូបានបញ្ចប់ការនិយាយអំពីចំណាប់អារម្មណ៍របស់ខ្លួន ហើយដោយផ្អែកលើពេលវេលាដែលមាន អ្នកសម្របសម្រួលអាចស្នើសុំអ្នកស្ម័គ្រចិត្តម្នាក់ឡើងមកផ្នែកខាងមុខបន្ទប់។ បន្ទាប់មក

អ្នកចូលរួម អាចសួរ៥ សំណួរ ដើម្បីញ្ជាយាមរកឱ្យឃើញពីទេពកោសល្យរបស់ដៃគូខ្លួន។ ជម្រើសផ្សេងទៀត គឺថា អ្នកស្ម័គ្រចិត្តអាចធ្វើសកម្មភាពបង្ហាញពីទេពកោសល្យរបស់ដៃគូ ហើយអ្នកដទៃទៀតអាចទាយថា វាជាអ្វី? បន្ទាប់មក ក្រដាសពណ៌លឿងត្រូវបានប្រមូលផ្តុំដាក់ជាក្រុម។នៅលើបន្ទះក្តារមួយ ដូចជា ជំនាញថែសួន ដាក់មួយក្រុម ជំនាញសិល្បៈដាក់មួយក្រុម ឬជំនាញកីឡាដាក់មួយក្រុម។

តើយើងអាចរៀនអ្វីពីសកម្មភាពទាំងនេះ?

នៅប្រទេស ទីម័រខាងកើត គ្រូបង្រៀនបានពិពណ៌នាថា :

- ◆ យើងបានរៀនស្តាប់គ្នាទៅវិញទៅមក។
- ◆ យើងចាប់ផ្តើមស្គាល់គ្នាទៅវិញទៅមកប្រសើរឡើង។
- ◆ យើងបានរៀនច្រៀស្រ័យទាក់ទងប្រសើរឡើង ទាំងការប្រើដោយមាត់ទទេ និងការមិនប្រើមាត់។
- ◆ យើងគឺជាក្រុមការងារមួយដ៏ល្អដែលមានទេពកោសល្យជាច្រើន។
- ◆ យើងបានរៀនសួរសំណួរគ្នានកំណត់។
- ◆ យើងបានរៀនពីគ្នាទៅវិញទៅមក។

អ្នកសម្របសម្រួលអាចនិយាយថា មេរៀនមួយដ៏សំខាន់ គឺ **យើងអាចមើលឃើញថា អ្នករាល់គ្នាមានទេពកោសល្យមួយ ហើយយើងអាចប្រើទេពកោសល្យទាំងនេះនៅក្នុងការងាររបស់យើងជាគ្រូបង្រៀន និងជាអ្នករៀន។**

គ្រូបង្រៀនត្រូវគិតថា កុមារម្នាក់ៗនាំអ្វីមួយដែលមានលក្ខណៈវិជ្ជមានមកតាមខ្លួន ដែលធ្វើឱ្យពួកគេអាចចូលរួមចំណែកបាន។ ទោះជាយ៉ាងណាក្តី គ្រូបង្រៀនត្រូវរកលក្ខណៈអវិជ្ជមានឱ្យឃើញ។ កុមារអាចធ្វើជាគ្រូបង្រៀន ផងដែរ ហើយអាចរៀនពីគ្នាទៅវិញទៅមក។

ប្រើប្រាស់វិធីគិតពិចារណា រៀន និងស្វែងយល់ក្នុងថ្នាក់រៀនផ្សេងៗគ្នា

នៅក្នុងគោលមុន យើងបានដឹងថា **កុមាររៀនដោយវិធីផ្សេងៗគ្នា និងក្នុងកម្រិតខុសៗគ្នា** មានន័យថា មាននានាភាពក្នុងការរៀន។ ហេតុដូច្នេះ ក្នុងឋានៈជាគ្រូបង្រៀន យើងត្រូវចេះច្នៃប្រឌិតវិធីរៀនផ្សេងៗ ដោយប្រើវិធីសាស្ត្របង្រៀនខុសៗគ្នា។ ដូច្នេះ កុមារទាំងអស់អាចយល់ព័ត៌មាន និងខ្លឹមសារដែល យើងបង្រៀន ហើយអាចរៀនក្នុងវិធីដ៏មានខ្លឹមសារ ជាពិសេសកុមារដែលមានប្រវត្តិ និងសមត្ថភាពខុសគេ។

ភាពផ្សេងៗនៃសកម្មភាពរៀន និងបង្រៀននៅក្នុងថ្នាក់រៀនមានចាប់ពីការទន្ទេញចាំមាត់ និងការបន្ថូរសម្លេង រហូតដល់ការដោះស្រាយបញ្ហា និង ការគិតដោយមានលក្ខណៈច្នៃប្រឌិត។

ការទន្ទេញចាំមាត់ ការវិភាគ ធ្វើសំយោគ រកដំណោះស្រាយបញ្ហា

ក្នុងថ្នាក់រៀន យើងអាចស្វែងរកវិធីនានា ដើម្បីបង្ហាញអំពីនានាភាពនៃសកម្មភាពទាំងនេះ។ ឧទាហរណ៍ យើងអាច :

- **ប្រើវត្ថុផ្សេងៗ ដើម្បីបង្រៀនគណិតវិទ្យា** ដែលបញ្ចូលក្នុងជំនាញម៉ាស៊ីនរបស់កុមារ និងការយល់ដោយឱ្យសិស្សឃើញជាក់ស្តែងនឹងភ្នែក។
- **ឱ្យកុមារនិយាយ (ឬសរសេរ) ពីគំនិត និងរបៀបគិតគណិតវិទ្យា** ដែលផ្សារភ្ជាប់ការគិតដោយមាត់ ជាមួយនឹងការយល់គំនិតគណិតវិទ្យាច្បាស់លាស់។
- **ឱ្យសិស្សគូររូបភាពពណ៌នាអំពីរឿងនានាដែលគ្រូអានឱ្យសិស្សស្តាប់** ដែលភ្ជាប់ការគិតជាក់ស្តែងរបស់សិស្សទៅនឹង ពាក្យ និងព្រឹត្តិការណ៍នៅក្នុងរឿង។
- **ណែនាំកុមារឱ្យធ្វើផែនទីតំបន់ជុំវិញសាលារៀន** ដែលភ្ជាប់បទពិសោធស្តីពីចលនាក្នុងលំហជាមួយនឹងគំនិតគណិតវិទ្យាជាក់ស្តែង។ នៅពេលកុមារពិនិត្យស្ទាបស្ទង់មើលនៅក្នុងសហគមន៍ រកឃើញបញ្ហានានាក្នុងសហគមន៍ និងប្រើជំនាញសហការគ្នាដោះស្រាយបញ្ហាទាំងនេះ សិស្សកំពុងរៀនវិធីអនុវត្តអ្វីដែលបានរៀននៅសាលា។ ក្រៅពីការអប់រំដ៏ល្អ ដំណើរការនេះជួយសហគមន៍ឱ្យយល់ពីការងាររបស់សាលា និងបំផុសឱ្យសហគមន៍គាំទ្រការងាររបស់គ្រូបង្រៀនថែមទៀត (ចូរមើលកម្រងសៀវភៅលេខ ៣ និងលេខ ៦)។

ដើម្បីឱ្យថ្នាក់រៀនរបស់អ្នកមានបញ្ចូលគ្រប់សមាសភាព អ្នកត្រូវធានាថា កម្មវិធីសិក្សាអាចអនុវត្តបាន ហើយទាក់ទងនឹងតម្រូវការរបស់កុមារ (ខ្លឹមសារបង្រៀន) វិធីដែលអ្នកបង្រៀន វិធីដែលកុមាររៀនល្អបំផុត (ដំណើរការ) និងរបៀបណាមួយដែលទាក់ទងនឹងបរិយាកាសដែលកុមារកំពុងរស់នៅ និងកំពុងរៀន។

យើងត្រូវពិចារណាផងដែរចំពោះកុមារដែលមានបញ្ហាក្នុងការសិក្សា ឬបង្ហាញភាពអាក់រអួលក្នុងការសិក្សា។ តើយើងកំពុងរៀបចំកម្មវិធីសិក្សាដែលមានលក្ខណៈស្តង់ដាមួយសម្រាប់កុមារដែលមានបញ្ហាក្នុងការសិក្សា ដូចជាកុមារដែលខ្សោយបញ្ញា រៀនមិនសូវយល់ និងមើលមិនឃើញច្បាស់? តើកម្មវិធីសិក្សានេះអាចប្រើសម្រាប់កុមារទាំងនេះ និងកុមារដទៃៗទៀតបានឬទេ? តើយើងដំណើរការកម្មវិធីសិក្សានេះដោយរបៀបណា?



សកម្មភាពអនុវត្ត : ការអង្កេតមើលនានាភាព

១. សរសេរអំពីកុមារនៅក្នុងថ្នាក់របស់អ្នកដែលមានចំណុចខ្លាំងច្បាស់លាស់ក្នុងមុខវិជ្ជាជាក់លាក់ណាមួយ ដូចជា មុខវិជ្ជាគណិតវិទ្យា ជំនាញសរសេរ ជំនាញពិភាក្សា។ល។ ចូររៀបរាប់ថា តើចំណុចខ្លាំងទាំងនេះ ត្រូវបានបង្ហាញនៅក្នុងថ្នាក់ដូចម្តេច?

២. សរសេរអំពីកុមារដែលមានទេពកោសល្យដទៃៗទៀត ដែលអាចទាក់ទងដោយប្រយោល ជាមួយការសិក្សាក្នុងថ្នាក់រៀន។ តើកុមារម្នាក់ជាអ្នកធ្វើគំរូដ៏ល្អឬ? តើកុមារម្នាក់ទៀតបង្ហាញកិច្ចសហការគ្នាល្អផ្នែកកីឡា និងការលេងល្បែងឬ? តើកុមារម្នាក់ទៀតមានជំនាញសង្គម រៀនពូកែឬ? ឧទាហរណ៍ កុមារដែលមានលក្ខណៈមិនប្រក្រតីតែងតែមានជំនាញសង្គមពូកែ។

៣. ឥឡូវនេះ ចូរគូសវង្វង់មួយនៅលើទំព័រតំណាងឱ្យកុមារសេសសល់ដទៃទៀតនៅក្នុងថ្នាក់ ដែលអ្នកមិនទាន់បានភ្ជាប់ជាមួយនឹងទេពកោសល្យ ឬជំនាញពិសេសនៅឡើយ។ នៅសប្តាហ៍ក្រោយ ចូរអង្កេតមើលកុមារទាំងនេះដោយយកចិត្តទុកដាក់។ ប្រសិនបើអ្នកកត់សម្គាល់ឃើញថា កុមារណាម្នាក់ក្នុងចំណោមកុមារទាំងនេះចូលចិត្តសកម្មភាពជាក់លាក់ណាមួយ ចូរកត់សកម្មភាពនោះទុក។ តើសកម្មភាពនោះ ឬវិធីដែលកុមារអនុវត្តសកម្មភាពនោះឆ្លុះបញ្ចាំងពីវិធីរៀនរបស់កុមារនោះឬទេ? តើវិធីរៀនទាំងនេះអាចបញ្ចូលទៅក្នុងមេរៀនរបស់អ្នកដូចម្តេច?

ក្នុងការអង្កេត និងដោះស្រាយបញ្ហានានាភាព យើងត្រូវរកឱ្យឃើញថា យើងអាចបង្កើតប្រការអ្វីខ្លះមានន័យថា មធ្យោបាយវិជ្ជមានដែលអាចជួយកុមារក្នុងការរៀន ជាពិសេសកុមារដែលមានបញ្ហាក្នុងការសិក្សា។ យើងមិនគួរផ្តោតលើអ្វីដែលយើងត្រូវ "លះបង់" (សម្បទាន) ដូចជា ពេលវេលាទេ ប៉ុន្តែយើងត្រូវផ្តោតលើប្រយោជន៍សិក្សាសម្រាប់កុមារ។ ឧទាហរណ៍ តើយើងអាចសុំឱ្យកុមារម្នាក់ទៀតអានឱ្យកុមារដែលមានបញ្ហាក្នុងការស្តាប់ ហើយសរសេរឱ្យកុមារនោះដងបានឬទេ? នៅពេលជាមួយគ្នានេះដែរ តើយើងអាចរកឃើញជំនាញសំខាន់អ្វីខ្លះដែលកុមារកំពុងមានបញ្ហាម្នាក់នេះ ហើយតើដៃគូរបស់កុមារនោះ អាចរៀនជំនាញទាំងនេះយ៉ាងដូចម្តេច? និយាយឱ្យងាយ យើងត្រូវបង្កើតទំនាក់ទំនងមួយដែលកុមារទាំងពីរអាចរួមចំណែកជួយគ្នាទៅវិញទៅមកក្នុងការសិក្សា។

បញ្ហាប្រឈមមុខអំពីនានាភាព

ការមានកុមារផ្សេងៗដែលមានប្រវត្តិ និងសមត្ថភាពខុសគ្នាក្នុងថ្នាក់រៀនមួយដែលដាក់បញ្ចូលគ្នាគ្រប់សមាសភាព តែងមានបញ្ហាដែលត្រូវប្រឈមច្រើនណាស់។ យើងត្រូវពិចារណាថា កុមារម្នាក់ៗ ត្រូវការរៀនអ្វី ហើយរៀនដូចម្តេចដើម្បីបានពូកែ។ យើងត្រូវរកឱ្យឃើញវិធី ដើម្បីឱ្យកុមារទាំងអស់ចង់រៀនរួមគ្នាដោយ រីករាយ។ បញ្ហាប្រឈមចំនួនបី ដែលអាចរារាំងកុមារមិនឱ្យរៀនជាមួយគ្នាគឺ ការសម្គុតគំរាម

ភាពលំអៀង និងការរើសអើង។ ការរៀនវិធីដោះស្រាយបញ្ហាប្រឈមទាំងនេះនៅក្នុងថ្នាក់រៀនដែលបញ្ចូលគ្រប់សមាសភាព គឺជាការងារដ៏សំខាន់បំផុតមួយ ដែលគ្រូបង្រៀនត្រូវធ្វើឱ្យបាន។

ការសម្លុតគំរាម

ការសម្លុតគំរាម គឺជាទម្រង់មួយនៃភាពហិង្សា។ ក្នុងកម្រងសៀវភៅទី ៦ ស្តីពីការបង្កើតបរិយាកាសសាលាល្អ និងមានការគាំពារ យើងនឹងរៀន ទម្រង់ដទៃៗទៀតនៃភាពហិង្សាដែលអាចកើតមាននៅក្នុងសាលាមួយ វិធីបង្ហាញភាពហិង្សានៅក្នុងសាលា និងវិធីដើម្បីអភិវឌ្ឍគោលនយោបាយ និងសកម្មភាពសាលាដ៏មានប្រសិទ្ធភាពប្រឆាំងនឹងភាពហិង្សា។ នៅក្នុងសៀវភៅនេះ យើងនឹងផ្តោតជាពិសេសលើការសម្លុត គំរាមដោយហេតុថា ការគំរាមកំហែង និងការភ័យខ្លាចអាចរារាំងកុមារមិនឱ្យរៀននៅក្នុងថ្នាក់ដែលមានបរិយាកាសរៀនមេត្រី ដោយ បញ្ចូលគ្រប់សមាសភាពរបស់យើង។

ពេលយើងគិតអំពីការសម្លុតគំរាម ជាធម្មតា យើងគិតដល់កុមារម្នាក់ ឬកុមារមួយក្រុម (អ្នកប្រព្រឹត្តល្មើស) ដែលគំរាមកំហែងកុមារម្នាក់ ទៀត (ជនរងគ្រោះ) ញឹកញាប់ ពីព្រោះជនរងគ្រោះ មានលក្ខណៈផ្សេង ដោយរបៀបណាមួយ។ ពួកគេអាចរៀនគ្រាន់បើជាងអ្នកប្រព្រឹត្តល្មើស (ពួកគេទទួលបានកម្រិតល្អជាង) ពួកគេអាចមកពីក្រុមដែលមានវប្បធម៌ខុសគ្នាមួយ ដូចជា ការមានសាសនាផ្សេងគ្នា ឬពួកគេអាចជា អ្នកក្រ។ អាកប្បកិរិយារបស់មនុស្សពេញវ័យ និងគ្រូបង្រៀន មិនមែនរបស់កុមារ អាចចាត់ទុកថា ជាការសម្លុតគំរាម ផងដែរ។ ការ សម្លុតគំរាមមានច្រើនប្រភេទ ឧទាហរណ៍ :

- ការសម្លុតគំរាមលើរូបកាយ ដូចជា ត្រូវបានវាយដោយអ្នកមានអាយុប្រហាក់ប្រហែលគ្នាដោយគ្រួ ឬអាណាព្យាបាល។
- ការសម្លុតគំរាមផ្នែកបញ្ញា នៅពេលដែលគំនិតរបស់កុមារមិនត្រូវបានយកចិត្តទុកដាក់ ឬមិនឱ្យតម្លៃ។
- ការសម្លុតគំរាមផ្លូវចិត្ត ដោយសារមានការគោរពខ្លួនឯងតិចតួច ហេតុការគួរឱ្យអាម៉ាស់នៅសាលា ឬ ការដកយកការទ្វាន់ទ្វីញដែលអាចទាក់ទងនឹងការគំរាមកំហែងខាងបញ្ញា។
- ការសម្លុតគំរាមដោយមាត់ ដូចជា ការហៅឈ្មោះ ការនិយាយបញ្ឆើ ការលេងសើចដដែលៗ សំដីប្រកាន់ពូជសាសន៍។
- ការសម្លុតគំរាមដោយប្រយោល ដូចជា ការផ្សព្វផ្សាយពាក្យចចាមអារ៉ាម ការច្រានឧរណាម្នាក់ចេញពីក្រុម។
- ការសម្លុតគំរាមផ្នែកវប្បធម៌/សង្គម ដែលកើតចេញពីភាពលំអៀង ឬការរើសអើង ដោយសារតែភាពខុសគ្នាក្នុងថ្នាក់ ក្រុមជនជាតិភាគតិច វណ្ណៈ ភេទ។ល។

ជាធម្មតា ការសម្តែតគំរាមគឺជាទម្រង់មួយនៃអាកប្បកិរិយាកំរោលដែលធ្វើឱ្យគេឈឺចាប់ និង-មានចេតនា។ ជួនកាលអំពើនេះអាចបន្ត កើតមានជាច្រើនសប្តាហ៍ ច្រើនខែ ឬច្រើនឆ្នាំ។ ប្រសិនបើមិនមានជំនួយទេ អំពើនេះអាចបង្កការលំបាកក្នុងការការពារខ្លួន សម្រាប់អ្នកទាំងឡាយដែលត្រូវគេសម្តែតគំរាម។

ក្នុងសង្គមជាច្រើន ជារឿយ។ អ្នកដែលមានលក្ខណៈខុសពីគេតែងត្រូវបានសម្តែតគំរាម។ ភាពខុសពីគេរបស់ពួកគេអាចដោយសារបញ្ហា ភេទ ជនជាតិភាគតិច ភាពពិការ ឬចរិតលក្ខណៈផ្ទាល់ខ្លួនដទៃទៀត។ ទោះជាកុមារាតែងតែពាក់ព័ន្ធនឹងសកម្មភាពសម្តែតគំរាមលើរូបកាយក៏ដោយ កុមារីអាចប្រើទម្រង់នៃការសម្តែតគំរាមដែលមានលក្ខណៈប្រយោល និងវៃឆ្លាតជាង ដូចជា ការនិយាយដង្ហួជន្លេញ ហើយកុមារីអាចសម្តែតគំរាមជាក្រុម។ ជាជាងម្នាក់ៗ។

ជារឿយ។ កុមារដែលត្រូវបានគេសម្តែតគំរាមមិនសារភាពថា ខ្លួនគេកំពុងត្រូវបានសម្តែតគំរាមឡើយ ពីព្រោះពួកគេភ័យខ្លាចថា សកម្មភាពសម្តែតគំរាមនឹងកាន់តែកើនឡើង។ សម្រាប់កុមារដែលកំពុងត្រូវបានរំលោភបំពានដោយមនុស្សពេញវ័យណាម្នាក់ ពួកគេអាច មិនមានបំណងសារភាពអំពីការសម្តែតនេះឡើយ ពីព្រោះពួកគេភ័យខ្លាចមនុស្សពេញវ័យនោះ ឬមនុស្សពេញវ័យជាទូទៅ។

សម្រាប់គ្រូបង្រៀន វាមានការពិបាកក្នុងការដោះស្រាយបញ្ហាការសម្តែតគំរាម ពីព្រោះការសម្តែតគំរាមតែងកើតមាននៅខាងក្រៅ ថ្នាក់រៀន ដូចជា នៅតាមផ្លូវទៅសាលា ឬ នៅកន្លែងលេងកំសាន្ត។ ទោះជាយ៉ាងនេះក្តី លទ្ធផលនៃការគំរាមកំហែង តែងតែមានឥទ្ធិពលលើ ការសិក្សារបស់កុមារដែលទទួលរងការរំលោភបំពាននៅក្នុងថ្នាក់របស់យើង។

គ្រូបង្រៀនត្រូវមានវិធានការលើការសម្តែតគំរាមឱ្យបានច្បាស់ដប្រជា ហើយយើងត្រូវស្វែងរកមធ្យោបាយនានា ដើម្បីដឹងពីទំហំនៃការសម្តែតគំរាមក្នុងថ្នាក់។ ការអង្កេតមើល ជាជំនាញមួយដ៏សំខាន់សម្រាប់គ្រូបង្រៀន ហើយយើងត្រូវអង្កេតមើលកុមារ ក្នុងអំឡុងពេលលេង ព្រមទាំងក្នុងថ្នាក់រៀន។ កុមារដែលតែងតែនៅម្នាក់ឯង ដែលមានមិត្តភក្តិតិចតួច ឬដែលមានលក្ខណៈខុសពីគេនៅក្នុងរបៀបណាមួយ អាចជាគោលដៅសម្រាប់ការសម្តែតគំរាម។ សញ្ញានៃការសម្តែតគំរាមអាចមាន :

- កុមារដែលចាត់បង់ជំនឿជឿជាក់ភ្លាម។។
- កុមារដែលគេចពីការទាក់ទងដោយក្រែសែភ្នែក និងមានភាពស្ងប់ស្ងាត់ជាប់រហូត។
- កុមារដែលទទួលលទ្ធផលមិនបានល្អ ប៉ុន្តែដែលពីមុនរៀនបានពូកែ។
- កុមារដែលចូលសាលាមិនទៀងទាត់ ឬឈឺក្បាល ឬឈឺពោះដោយគ្មានហេតុផល។

ការពិភាក្សាជាមួយមាតាបិតា និងអាណាព្យាបាលដទៃទៀតមានភាពចាំបាច់ជាខ្លាំង ប៉ុន្តែយើងគួរត្រៀមខ្លួនសម្រាប់ការផ្លាស់ប្តូរផ្សេង។នៃអាកប្បកិរិយាកុមារ។ យើងគួរកត់សម្គាល់ផ្ទាល់របស់យើង ដើម្បីរកឱ្យឃើញការផ្លាស់ប្តូរអាកប្បកិរិយារបស់កុមារ ដែលអាចឆ្លុះបញ្ចាំងឱ្យឃើញនូវការសម្តែតគំរាម។

គេអាចធ្វើការស្ទាបស្ទង់ផងដែរដើម្បីទទួលបានរូបភាពមួយស្តីពីទំនាក់ទំនងនៅក្នុងថ្នាក់ ឬសាលា។ បញ្ជីសំណួរចំនួនពីរត្រូវបានបង្ហាញខាងក្រោម។ បញ្ជីសំណួរទី ១ គឺជាបញ្ជីពិនិត្យពីអាកប្បកិរិយាសម្ភុតគំរាម។ បញ្ជីទី ២ គឺជាបញ្ជីសំណួរដែលមានលក្ខណៈកាន់តែទូលំទូលាយឡើង ដើម្បីប្រមូលចម្លើយអំពីទំនាក់ទំនងនៅក្នុង និងជុំវិញសាលា និងថ្នាក់រៀនរបស់យើង[1]។ អ្នកអាចស្នើសិស្សរបស់អ្នកបំពេញ បញ្ជីសំណួរដោយអានាមិក (គ្មានឈ្មោះ)។

១. ការកើតមាននូវការសម្ភុតគំរាម

	មិនបានកើតឡើង	បានកើតឡើងម្តង	បានកើតឡើងច្រើនដង
ខ្ញុំត្រូវគេរុញ គេទាត់ ឬវាយដំដោយចេតនា។			
កុមារដទៃទៀតបាននិយាយដើមខ្ញុំអាក្រក់។។			
របស់របរខ្ញុំត្រូវគេដណ្តើមយក។			
ខ្ញុំត្រូវបានគេនិយាយ បញ្ឆើមើលងាយ ព្រោះខ្ញុំមានលក្ខណៈខុសពីកុមារដទៃ។			
ខ្ញុំត្រូវគេនិយាយបញ្ឆើដោយមូលហេតុផ្សេង។ទៀត។			
មានគេសើចចំអកឡកឡឺយ និងដេរប្រមាថខ្ញុំ			

[1] These checklists have been adapted from checklists originally designed by Tiny Arora and published in "Tackling Bullying in Your School: A Practical Handbook for Teachers," S. Sharp and PK Smith, editors. Routledge. 1994.

២. បញ្ជីសំណួរទំនាក់ទំនង

ខ្ញុំគឺជាកុមារ ..... ខ្ញុំគឺជាកុមារី .....

អាយុ ..... រៀនថ្នាក់ .....

នៅសាលាក្នុងសប្តាហ៍នេះ មានកុមារម្នាក់ :	មិនបានកើតឡើង	បានកើតឡើងម្តង	បានកើតឡើងច្រើនដង
គេមានចេតនាមិនឱ្យខ្ញុំលេងចូល			
មានគេម្នាក់អាក្រក់ចំពោះខ្ញុំក្នុងរបៀបណាមួយ។			
បាននិយាយបញ្ឆៅខ្ញុំដែលធ្វើឱ្យខ្ញុំមិនចូលចិត្ត			
បាននិយាយល្អជាមួយខ្ញុំ			
បានទាត់ខ្ញុំ			
បានឱ្យរង្វាន់មួយដល់ខ្ញុំ			
បាននិយាយអាក្រក់ដាក់ខ្ញុំព្រោះខុសគេ			
បាននិយាយគំរាមវាយខ្ញុំ			
បានគំរាមទារលុយពីខ្ញុំ			
បានបន្លាចខ្ញុំ			
ឈប់ឱ្យខ្ញុំលេងចូល			
និយាយចំអកដាក់ខ្ញុំ ហើយសើចមើលងាយខ្ញុំ			
បង្ខំខ្ញុំឱ្យវាយធ្វើបាបអ្នកផ្សេង			

នៅសាលាក្នុងសប្តាហ៍នេះ មានកុមារម្នាក់ :	មិនបានកើតឡើង	បានកើតឡើងម្តង	បានកើតឡើងច្រើនដង
ករខ្ញុំ ហើយបង្កបញ្ហាដល់ខ្ញុំ			
ជួយកាន់របស់របរឱ្យខ្ញុំ			
ជួយធ្វើកិច្ចការខ្ញុំ			
ចំអកឡកឡើយ និងធ្វើត្រាប់តាមដំណើរបស់ខ្ញុំ			
មើលងាយខ្ញុំព្រោះពណ៌សម្បុរខ្ញុំខុសគេ			
បានលេងចូលខ្ញុំ			
បានបំបែក កំទេចរបស់របរបស់ខ្ញុំ			

បន្ទាប់ពីវិភាគលទ្ធផលបញ្ជីសំណួររួចមក យើងអាចរកឃើញកុមារទាំងឡាយដែលចង់និយាយថាពួកគេគំពុងត្រូវបានគេសម្តុត គំរាម និងកុមារទាំងឡាយដែលទំនងជាអ្នកសម្តុតគំរាមគេ។ ទោះជាយ៉ាងណាក្តី ចូរប្រយត្ន័។ កុមារខ្លះអាចជាជនរងគ្រោះដោយការសម្តុត គំរាម ប៉ុន្តែពួកគេអាចមិនមានចេតនាសារភាពវាសូម្បីតែនៅក្នុងបញ្ជីសំណួរនេះ។ ដោយហេតុថា បញ្ជីសំណួរមានលក្ខណៈអានាមិក យ៉ាងហោចណាស់វានឹងអាចជួយអ្នកឲ្យយល់បានទូទៅបំរែនៃការសម្តុតគំរាមនៅក្នុងថ្នាក់របស់អ្នក។ ពីព័ត៌មាននេះ អ្នកអាចចាប់ផ្តើមរៀបចំសកម្មភាពបន្ថែមទៀតជាមួយគ្រូបង្រៀន មាតាបិតា អាណាព្យាបាល និងកុមារ។

សកម្មភាពដោះស្រាយការសម្តុត គំរាម ប្រមាថ មើលងាយ

ដើម្បីកាត់បន្ថយការសម្តុតគំរាម គ្រូបង្រៀនត្រូវធ្វើសកម្មភាពផ្សេងៗមួយចំនួន ដូចជា :

- ធ្វើលំហាត់ប្រាណដើម្បីជួយកុមារលំហែអារម្មណ៍ និងបន្ថយភាពតានតឹងក្នុងចិត្ត
- បង្កើនការសិក្សាដែលមានកិច្ចសហការក្នុងថ្នាក់ (កុមារជួយគ្នាទៅវិញទៅមកក្នុងការសិក្សា)
- កែលំអអំណះអំណាងរបស់កុមារ ដោយផ្តល់សិទ្ធិបន្ថែមដល់កុមារ ដូចជាអនុញ្ញាតឱ្យកុមារបង្កើតវិន័យក្នុងថ្នាក់រៀន ហើយឱ្យកុមារទទួលខុសត្រូវនៅក្នុងគណៈកម្មាធិការសិស្ស។

- បង្កើនការទទួលខុសត្រូវនៅក្នុងថ្នាក់ ដោយការបង្កើតគណៈកម្មាធិការសិស្ស និងធ្វើការកាន់តែជិតស្និទ្ធជាមួយ មាតាបិតា និងសហគមន៍។
- អភិវឌ្ឍយុទ្ធសាស្ត្រទំនាក់ទំនងពីកុមារម្នាក់ទៅកុមារម្នាក់ ដើម្បីដោះស្រាយជំលោះ
- ឱ្យកុមារកឱ្យឃើញនូវវិធានការវិន័យដែលកុមារទាំងអស់គួរប្រើ ដើម្បីទប់ទល់ជាមួយកុមារដែលចូលចិត្តមើលងាយ សម្លុត និងគំរាមគេ

នៅក្នុងកម្មវិធីសិក្សា គ្រូបង្រៀនអាចដឹកនាំការសម្តែងដូចជា ល្ខោន ឬអាយ៉ង ដើម្បីរកឱ្យឃើញទំហំនៃការសម្លុតគំរាម និងដើមហេតុ ហើយរកដំណោះស្រាយ បើកើតមាននៅក្រៅសាលា។ ឧទាហរណ៍ គ្រូបង្រៀននៅប្រទេស Guyana បានធ្វើអាយ៉ង ហើយបានសរសេររឿងខ្លី។ ឱ្យសិស្សសម្តែងដើម្បីពន្យល់បង្ហាញពីទិដ្ឋភាពនៃការសម្លុតគំរាម និងប្រកាន់ជាតិសាសន៍។ គ្រូទាំងនោះបានចាត់វិធានការ ដើម្បីជួយកុមារដែលទទួលរងការសម្លុតគំរាម និងប្រកាន់ជាតិសាសន៍។

កិច្ចពិភាក្សា ឬការជជែកវែកញែកស្តីពីបញ្ហាពិបាក។អាចត្រូវធ្វើឡើងស្របជាមួយការសម្តែងរឿង ឬការសម្តែងតួ ដើម្បីឱ្យកុមារសាកល្បងរបៀបនិយាយ "បដិសេធ" ដោយជឿជាក់ ព្រមទាំងរកភាសាត្រឹមត្រូវដើម្បីប្រើប្រចាំងនឹងអ្នកសម្លុតគំរាម និងអ្នករំលោភបំពានគេ។

ភាពលំអៀង និង ការរើសអើង

ជារឿយ។ ដើមហេតុនៃការសម្លុតគំរាមគឺជាភាពលំអៀង (អាកប្បកិរិយា ឬយោបល់ដែលអយុត្តិធម៌ចំពោះមនុស្ស) និងការរើសអើង (ភាពខុសគ្នាដែលអយុត្តិធម៌រវាងក្រុមមនុស្សប្រចាំងនឹងក្រុមមនុស្សផ្សេងទៀត។ មធ្យោបាយមួយ ដើម្បីយល់ថា ភាពលំអៀង និងការរើសអើងប្រព្រឹត្តដូចម្តេចនៅក្នុងថ្នាក់រៀន និងនៅក្នុងសាលារៀន គឺប្រើបទពិសោធផ្ទាល់របស់យើងទាំងអស់គ្នា។



សកម្មភាពអនុវត្ត : ការយល់ពីការរើសអើង

សកម្មភាពនេះអាចធ្វើជាមួយគ្រូបង្រៀន មាតាបិតា ឬកុមារដែលមានអាយុច្រើន។ គោលបំណងគឺត្រូវលើកកម្ពស់ការយល់ដឹងអំពីរបៀប និងទម្រង់ផ្សេងៗនៃភាពលំអៀង និងការរើសអើង ក្នុងសាលារៀនអាចប៉ះពាល់ដល់បុគ្គលម្នាក់ៗ។ លើសពីនេះទៀត សកម្មភាពនេះចលនាបំផុសមនុស្សឱ្យចេះឆ្លុះបញ្ចាំង និងរកឱ្យឃើញភាពលំអៀង និងការរើសអើងដែលគ្រប់គ្នាជួបប្រទះ។

២៨ បង្កើតថ្នាក់រៀនកុមារមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព

យើងអាចបង្កើតបានមេរៀនជាច្រើន ដោយគ្រាន់តែប្រើប្រាស់សកម្មភាពខាងលើនេះ ឧទាហរណ៍ :

- អ្នករាល់គ្នាអាចជាជនរងគ្រោះដោយការជិះជាន់ និងជាអ្នកជិះជាន់គេ។
- បុគ្គលម្នាក់ៗទទួលស្គាល់ថា ភាពលំអៀង និងការរើសអើងបានសំដៅលើរូបពួកគេ សូម្បីនៅអាយុក្មេងក៏ដោយ។

សេចក្តីណែនាំ : ពេលវេលាដែលត្រូវការសម្រាប់សកម្មភាពនេះអាស្រ័យលើទំហំថ្នាក់រៀន ឬក្រុមអ្នកចូលរួម។ ចូរផ្តល់ពេល ១០ នាទី សម្រាប់សិស្សម្នាក់ៗ ឬក្រុមនីមួយៗ។

ចូរបែងចែកអ្នកចូលរួមជាក្រុមៗដែលមានគ្នា ៥ ឬ ៦ នាក់។ ឱ្យពួកគេចែករំលែករឿងណាមួយ ស្តីពីពេលដែលពួកគេបានឃើញភាពលំអៀង ឬការរើសអើងដែលមាននៅក្នុងបរិយាកាសសាលា។ ពាក្យណែនាំនិងគោលការណ៍មួយចំនួនទីងផ្តល់ជាជំនួយដ៏មានប្រយោជន៍។

១. ការអនុវត្តការរើសអើង ឬភាពលំអៀងមិនចាំបាច់មានចេតនាឡើយ។

២. បទពិសោធអាចទាក់ទិននឹងសិស្ស គ្រូ អ្នកគ្រប់គ្រងរដ្ឋបាល ឬបរិយាកាសទូទៅក្នុងសាលា។

៣. បញ្ជាក់ថា សិស្សអាចគិតអំពីកម្មវិធីសិក្សា វិធីសាស្ត្របង្រៀន សម្ភារអប់រំ ទំនាក់ទំនង ឬទិដ្ឋភាពផ្សេងៗទៀតនៅក្នុងបរិយាកាសសាលា។

៤. រំលឹកសិស្សថា អត្តសញ្ញាណមានទិដ្ឋភាពចម្រុះ។ ជាធម្មតា សិស្សគិតភ្លាមៗអំពីពូជសាន៍ ឬជនជាតិភាគតិច នៅក្នុងសកម្មភាពនេះ។ ចូរព្យាយាមណែនាំសិស្សឱ្យមើលឃើញទិដ្ឋភាពផ្សេងទៀតអំពីការរើសអើង ឬភាពលំអៀង ដូចជា ការជឿថា កុមារីមិនពូកែខាងផ្នែកវិទ្យាសាស្ត្រ ឬជឿថាកុមារដែលពិការមិនអាចលេងកីឡាបាន។

៥. ចុងក្រោយ ចូរលើកជាយោបល់ថា បទពិសោធរបស់ពួកគេអាចជាបទពិសោធដែលត្រូវគេធ្វើបាប ឬបទពិសោធជាអ្នកធ្វើបាបគេ។ អ្នកចូលរួមមួយចំនួនតូចនឹងជ្រើសរើសយកបទពិសោធជាអ្នកធ្វើបាបគេ ប៉ុន្តែបើមាននរណាម្នាក់ជ្រើសរើសយកបទពិសោធនេះ នោះអ្នកនឹងមានពេលគ្រប់គ្រាន់ដើម្បីឆ្លុះបញ្ចាំងការពិត។

ចូរផ្តល់ពេល ៥ នាទី សម្រាប់អ្នកចូលរួមនីមួយៗចែករំលែករឿងរបស់ខ្លួន ហើយបើចាំបាច់ចូរផ្តល់ពេល ៥ នាទីទៀតសម្រាប់ពួកគេឆ្លើយសំណួរស្តីពីបទពិសោធរបស់ខ្លួន។ វាមានសារៈសំខាន់ដែលបានរៀនអំពីបទពិសោធរបស់អ្នករាល់គ្នា និងដែលបានទាញការសន្និដ្ឋានថា ហេតុការផ្សេងៗបានធ្វើឱ្យអ្នកចូលរួមមានអារម្មណ៍ដូចម្តេច នៅពេលកើតមានឡើង។ អ្នកអាចសួរបុគ្គលម្នាក់ៗថា បទពិសោធ

ពួកគេបានប៉ះពាល់ដល់កិរិយាមារយាទ និងការអនុវត្តរបស់ពួកគេដូចម្តេច ឬសួរពីគំនិតផ្ទាល់ពួកគេថា តើអាចបញ្ចៀសស្ថានភាពនេះដោយរបៀបណា?

នៅពេលអ្នករាល់គ្នាមានឱកាសនិយាយរឿងរួចហើយ អ្នកអាចសួរសំណួរជាច្រើន ដើម្បីចាប់ផ្តើមកិច្ច ពិភាក្សាអំពីភាពលំអៀង និងការរើសអើងនៅក្នុងថ្នាក់រៀន និងសាលារៀន។

១. តើអ្នកមានអារម្មណ៍ដូចម្តេចអំពីការចែករំលែករឿងផ្ទាល់ខ្លួនរបស់អ្នកស្តីពីភាពលំអៀង និង ការរើសអើង?

២. តើអ្វីមួយដែលអ្នកបានរៀនពីបទពិសោធរបស់អ្នក ឬពីរឿងរបស់អ្នកណាម្នាក់ ដែលអាចនាំអ្នក ធ្វើអ្វីមួយផ្សេងៗគ្នា ក្នុងការបង្រៀនផ្ទាល់ និងការរស់នៅប្រចាំថ្ងៃ?

៣. តើការទាក់ទងគ្នាអ្វីខ្លះដែលអ្នកបានឃើញនៅក្នុងចំណោមរឿងទាំងនេះ? តើមានភាពមិនផ្លាស់ប្តូរ ណាមួយដែល អ្នកយល់ថាគួរឱ្យចាប់អារម្មណ៍ឬទេ?

៤. តើអ្នកណាមានការពិចារកក្នុងការចាំហេតុការណ៍ណាមួយ ឬក្នុងការបញ្ជាក់ថា នៅពេលណាដែល ពួកគេបានចាំជាលើកដំបូងនូវភាពលំអៀង ឬការរើសអើងក្នុងនៅសាលា? ប្រសិនបើមែន តើហេតុអ្វី?

៥. តើរឿងរបស់អ្នកដទៃធ្វើឱ្យអ្នកនឹកឃើញដល់ហេតុការណ៍បន្ថែមទៀតនៅក្នុងបទពិសោធផ្ទាល់ របស់អ្នកឬទេ?

ភាពលំអៀងក្នុងកម្មវិធីសិក្សា និងសម្ភារសិក្សា

ភាពលំអៀង និងការរើសអើងអាចត្រូវបានឆ្លុះបញ្ចាំងដោយអចេតនានៅក្នុងកម្មវិធីសិក្សា និង សម្ភារសិក្សា។ នេះជាករណីដែលកើតមាន ជាពិសេសសម្រាប់កុមារី កុមារដែលផ្លុកមេរោគអេដស៍ ព្រមទាំងកុមារដទៃទៀតដែលមានប្រវត្តិ និងសមត្ថភាពខុសគេ។ ឧទាហរណ៍ កុមារដែលកំពុងរស់នៅ ឬ ធ្វើការតាមដងវអាចត្រូវបានពណ៌នានៅក្នុងសៀវភៅរបស់សាលា ឬសៀវភៅរឿងផ្សេងៗថា ជាអ្នក លួចខ្ទេះ ហោចៅ ឬជាចោរ ហើយកុមារដែលកំពុងធ្វើការងារអាចត្រូវបានពណ៌នាថា ជាអ្នកក្រ ទោះបីជាពួកគេអាច មានចំណុចខ្លាំងៗ ចំណុចល្អ ដូចជា ជំនាញសង្គម និងជំនាញក្នុងការរស់នៅល្អក៏ដោយ។ ប្រសិនបើសម្ភារ កម្មវិធីសិក្សារបស់យើងរាប់បញ្ចូលកុមារដែលមានប្រវត្តិ និងសមត្ថភាពខុសៗគេ ពួកគេងាយនឹងរងឥទ្ធិពល ពីភាពខុសគ្នារបស់កុមារផ្សេងៗ។ និងក្នុងកាលៈទេសៈផ្សេងគ្នា។ ពួកគេក៏នឹងទាក់ទងច្រើនថែមទៀតជាមួយ ការរៀនសូត្ររបស់កុមារផងដែរ។

ស្ថានភាពដូចគ្នាទាក់ទងនឹងសម្ភារនានាដែលរាប់បញ្ចូលកុមារី។ ដូចយើងបានរៀននៅក្នុងសៀវភៅទី ៣ រួចហើយ តួនាទីសង្គម ដែលបានផ្តល់ចំពោះស្ត្រី និងបុរស "តួនាទីយេនឌ័រ) អាចខុសគ្នានៅក្នុងសង្គម។ ជំនឿជាប្រពៃណីស្តីពីស្ថានភាព និងតួនាទីរបស់បុរសប្រចាំងនឹងស្ត្រី អាចរឹតបន្តឹងកុមារីក្នុងការចូលសាលា។ ក្នុងសហគមន៍ដែលស្ត្រីត្រូវបានជឿថា មានលក្ខណៈអន់ខ្សោយជាងបុរស កុមារីតែងតែត្រូវរក្សានៅផ្ទះ ដើម្បីធ្វើការងារផ្ទះ និងមិនឱ្យចូលសាលាឡើយ។ តួនាទី ជំនឿ និងសកម្មភាពបែបនេះ ដែលរើសអើងចំពោះកុមារី អាចត្រូវឆ្លុះបញ្ចាំងឱ្យឃើញនៅក្នុងសម្ភារបង្រៀនដែលយើងកំពុងប្រើផងដែរ។ នៅពេលកុមារីឃើញខ្លួនគេបង្ហាញក្នុងសៀវភៅមេរៀនថា ជាមនុស្សចាំតែធ្វើតាមគេ ហើយកុមារាជាមនុស្សសកម្ម និងធ្វើការងារផ្សេង។ កុមារីអាចគិតថា ពួកគេគួរជាមនុស្សចាំតែធ្វើតាមគេដែរ។ បញ្ហានេះតែងនាំឱ្យមានការអនុវត្តមិនបានល្អក្នុងការសិក្សា ជាពិសេសក្នុងមុខវិជ្ជាគណិតវិទ្យា និងវិទ្យាសាស្ត្រ ឬពាក់ព័ន្ធនឹងការអង្កេតវិទ្យាសាស្ត្រ ព្រោះការអង្កេតនេះអាចត្រូវបានចាត់ទុកជា "សកម្មភាពរបស់កុមារ"។

ហេតុដូច្នេះហើយ សមភាពនៅក្នុងការរៀបចំកម្មវិធីសិក្សាមានសារៈសំខាន់ណាស់សម្រាប់ធានាឱ្យមានការរាប់បញ្ចូលគ្រប់សមាសភាពនៅក្នុងថ្នាក់រៀន។ សម្ភារបង្រៀនដែលយើងប្រើ បានបញ្ចូលគ្រប់សមាសភាពនៅពេលសម្ភារទាំងនោះបាន :

- រាប់បញ្ចូកុមារទាំងអស់ សូម្បីកុមារដែលមានប្រវត្តិ និងសមត្ថភាពខុសគេក៏ដោយ។
- ទាក់ទងនឹងសមត្ថភាព និងតម្រូវការរបស់កុមារ។
- សមស្របតាមទំនៀមទម្លាប់ និងវប្បធម៌។
- ផ្តល់តម្លៃឱ្យនានាភាពរបស់សង្គម (ឧទាហរណ៍ នានាភាពនៃសេដ្ឋកិច្ច សង្គមកិច្ច គ្រួសារក្រីក្រ អាចជាគ្រួសារដ៏ល្អសម្រាប់កុមារ ពួកគេអាចមានដំណោះស្រាយបញ្ហាដែលមានលក្ខណៈច្នៃប្រឌិត ហើយអាចពណ៌នាថា ជា គ្រួសារមានគំនិតច្នៃប្រឌិត)។
- មានប្រយោជន៍ចំពោះជីវភាពរស់នៅរបស់ពួកគេនៅពេលអនាគត។
- រាប់បញ្ចូលមនុស្សប្រុស និងស្រី ក្នុងតួនាទីផ្សេង។។
- ប្រើភាសាសមរម្យដែលរួមបញ្ចូលទាំងទិដ្ឋភាពស្មើភាពគ្នាផងដែរ។

តើអ្នកអាចវាយតម្លៃបានទេថា តើសម្ភារដែលអ្នកកំពុងប្រើបានឆ្លុះបញ្ចាំងពីបញ្ហាយេនឌ័រ និងបញ្ហារបស់ជនជាតិភាគតិចដោយរបៀបណា?

១. ពិនិត្យមើលរូបគំនូរលំអ : ចូរស្វែងរក លក្ខណៈគំរូ មានន័យថា រូបភាព ឬគំនិតស្តីពីមនុស្សដែលត្រូវបានគេរក្សាទុក និងព្រមទទួលយក ទោះបីជា គំនិត ឬរូបភាពទាំងនោះអាចមិនពិតក៏ដោយ (ដូចជា បុរសត្រូវបាន គិតថា ជា "មេគ្រួសារ" ហើយស្ត្រីត្រូវមើលថែរក្សាកូន)។ ក្នុង

រូបភាពលំអនានា តើមនុស្សនៅក្នុងក្រុមវប្បធម៌មួយ ឬបុរសគឺជាតួអង្គដែលមានឥទ្ធិពលគ្របដណ្តប់លើនារីឬទេ? តើអ្នកណាកំពុងធ្វើអ្វី? តើកុមារពិការគឺជាអ្នកដែលចាំតែធ្វើតាមគេ ឬតើមានការចូលរួមដែរ ដូចជាការលេងបាល់ជាមួយអ្នកដទៃ? តើអ្នកដទៃស្វាគមន៍កុមារពិការឬទេ?

២. ពិនិត្យមើលដំណើររឿង : *តើបញ្ហាត្រូវបានបង្ហាញ ផ្តើម និងដោះស្រាយនៅក្នុងរឿងដោយរបៀបណា? តើដំណើររឿងបានលើកទឹកចិត្តឱ្យមានការព្រមទទួលយកដោយមិនប្រែកែក ឬការតស៊ូយ៉ាងសកម្មរបស់តួអង្គ "ក្រុមជនជាតិភាគតិច" (ដូចជាកុលសម្ព័ន្ធ មនុស្សពិការ)? តើជីវជម្មៈរបស់កុមារី និងស្ត្រីត្រូវផ្តែកលើគំនិតផ្តួចផ្តើម និងបញ្ហារបស់ពួកគេផ្ទាល់ ឬដោយសារ "សំរស់ស្រស់ស្អាត" របស់នារី? តើគេអាចនិយាយរឿង ដដែលៗបានឬទេ ប្រសិនបើសកម្មភាព ឬតួនាទីផ្សេងៗដែលបានផ្តល់ដល់បុរស និងស្ត្រីនៅក្នុងរឿងនោះ ត្រូវបានគេធ្វើបញ្ច្រាស់វិញឬទេ?*

៣. ពិនិត្យមើលរបៀបរស់នៅ : *ប្រសិនបើរូបគំនូរលំអ និងអត្ថបទក្បាយាមពាណិនាអំពីវប្បធម៌មួយផ្សេងទៀត តើវាបានធ្វើឱ្យមានលក្ខណៈសាមញ្ញ ឬផ្តល់ការយល់ដឹងពិតប្រាកដអំពីរបៀបរស់នៅផ្សេងៗឬទេ?*

៤. ពិនិត្យមើលទំនាក់ទំនង : *តើអ្នកណាមានអំណាច? តើអ្នកណាជាអ្នកសម្រេចចិត្ត? តើមុខងាររបស់ស្ត្រីស្ថិតក្នុងតួនាទីគាំទ្រដ៏សំខាន់ ឬនៅក្រោមបង្គាប់គេ?*

៥. កត់សម្គាល់វីរបុរស : *ជាធម្មតា តើវីរបុរសមកពីក្រុមវប្បធម៌ជាក់លាក់ឬ? តើមនុស្សពិការមិនអាចជាវីរបុរសទេឬ? តើស្ត្រីមិនអាចជាវីរនារីបានឬទេ?*

៦. ពិចារណាពីឥទ្ធិពលលើរូបភាពបង្ហាញពីខ្លួនឯងរបស់កុមារ : *តើមានសំណួរពារណាមួយឬទេដែលអាចកម្រិតសេចក្តីថ្លាថ្នាររបស់កុមារ? បញ្ហានេះអាចប៉ះពាល់ដល់ការយល់ដឹងរបស់កុមារ។ តើមានអ្វីកើតឡើងចំពោះរូបភាពបង្ហាញខ្លួនឯងរបស់កុមារី ពេលដែលកុមារីបានដឹងដោយការអានថា កុមារាអនុវត្តសកម្មភាពដែលសំខាន់ៗ និងក្លាហាន ប៉ុន្តែកុមារីមិនអាចអនុវត្តសកម្មភាពដូច្នេះ?*[2]

មធ្យោបាយមួយសម្រាប់ចាប់ផ្តើមពិនិត្យមើលបញ្ហាទាំងនេះ គឺត្រូវប្រើតារាងពិនិត្យខាងក្រោមដើម្បីវាយតម្លៃសម្ភារសិក្សារបស់អ្នកអំពីសមភាព និងការបញ្ចូលគ្រប់សមាសភាព។

---

[2] Excerpted from: Swanson HL. (1999). Instructional components that predict treatment outcomes for students with learning disabilities: Support for a combined strategy and direct instruction model. Learning Disabilities Research and Practice, 14 (3), 129-140.

តារាងពិនិត្យសម្រាប់វាយតម្លៃសមភាពក្នុងសម្ភារសិក្សា

លក្ខណៈវិនិច្ឆ័យ	ខ្លឹមសារ		រូបភាពលំអ	
	ឯកភាព	មិនឯកភាព	ឯកភាព	មិនឯកភាព
តើតួនាទីរបស់កុមារា និងកុមារីមានតុល្យភាពឬទេ (ដូចជា វេជ្ជបណ្ឌិត គ្រូបង្រៀន កសិករ ពាណិជ្ជករ)?				
តើប្រភេទសកម្មភាពសម្រាប់កុមារា និងកុមារីស្មើភាពគ្នាឬទេ (ដូចជា សកម្មភាពកីឡា ការអាន ការជជែកគ្នា ធ្វើកិច្ចការសាលា)?				
តើទាំងកុមារា និងកុមារីមានអាកប្បកិរិយាប្រហាក់ប្រហែលគ្នាឬទេ (ដូចជា សកម្ម ចេះជួយគ្នា វីកវាយខ្លាំងក្លា ស្ងាបនា)?				
តើកុមារីដណ្តើមយកតួនាទីជាអ្នកដឹកនាំម្តងម្កាលឬទេ?				
តើកុមារីត្រូវបានបង្ហាញថា ជាមនុស្សមានជំនឿជាក់និងអាច ធ្វើការសម្រេចចិត្តបានឬ?				
តើកុមារីធ្វើសកម្មភាព" វៃឆ្លាត" ដូចកុមារដែឬ?				
តើកុមារីត្រូវបានរាប់បញ្ចូលក្នុងសកម្មភាពខាងក្រៅៗ ច្រើនដូចកុមារាឬទេ?				
តើកុមារី និងកុមារាកំពុងចូលរួមដោះស្រាយបញ្ហាក្នុងអត្ថបទដែរឬទេ?				
តើកុមារី និងកុមារាកំពុងធ្វើការរួមគ្នាក្នុងរបៀបមួយដែលសមស្របតាមវប្បធម៌ដែរឬទេ?				
តើប្រធានបទគួរឱ្យចាប់អារម្មណ៍ឬទេចំពោះកុមារស្ថិតក្នុងក្រុមជនជាតិភាគតិច?				
តើប្រធានបទគួរឱ្យចាប់អារម្មណ៍ចំពោះកុមារី ឬទេ?				
តើមានតុល្យភាពយេនឌ័រ ឬទេ នៅក្នុងរឿងនានាស្តីពីសត្វ?				
តើស្ត្រីត្រូវបានរៀបរាប់នៅក្នុងប្រវត្តិសាស្ត្រឬទេ?				

លក្ខណៈវិនិច្ឆ័យ	ខ្លឹមសារ		រូបភាពលំអ	
	ឯកភាព	មិនឯកភាព	ឯកភាព	មិនឯកភាព
តើស្ត្រីត្រូវបានរាប់បញ្ចូលក្នុងអក្សរសាស្ត្រ និងសិល្បៈឬទេ?				
តើជនជាតិភាគតិចត្រូវបានរាប់បញ្ចូលក្នុងប្រវត្តិសាស្ត្រ អក្សរសាស្ត្រ និងសិល្បៈឬទេ?				
តើភាសាបានរាប់បញ្ចូលកុមារី (ឬពាក្យផ្សេង។ ដូចជា "គាត់" ឬ "របស់គាត់" ដែលជាធម្មតាត្រូវបានប្រើ) ឬទេ?				
តើភាសាមានលក្ខណៈសមរម្យសម្រាប់ប្រើក្នុងសហគមន៍ឬទេ?				
តើភាសាបានលើកទឹកចិត្តកុមារា និងកុមារីជនជាតិភាគតិចឱ្យចាប់អារម្មណ៍អត្ថបទមេរៀនឬទេ?				
តើពាក្យនានាមិនរើសអើងចំពោះជនជាតិភាគតិចឬកុមារីទេឬ?				

សៀវភៅគួរឆ្លុះបញ្ចាំងនានាភាពនៃតួនាទីយេនឌ័រ ប្រវត្តិ ពូជសាសន៍ និងវប្បធម៌ តម្រូវការ និងសមត្ថភាពពិសេស មុខរបរ អាយុ គ្រួសារ (ឧទាហរណ៍ មានតែម្តាយ ឬមានតែឪពុក។

ប្រសិនបើមានការជ្រើសរើសតិចតួចនៅក្នុងសៀវភៅដែលមានក្នុងសាលារបស់អ្នក យើងត្រូវ "កែ" អ្វីដែលយើងមាន និង បន្ថែមព័ត៌មានពិស្តារដែលមិនមានក្នុងអត្ថបទ។ អ្នក សហសេវិករបស់អ្នក និងកុមារអាចគូររូបលំអបន្ថែមលើសៀវភៅនានា ដើម្បីធ្វើឱ្យសៀវភៅទាំងនោះមានតុល្យភាពស្តីពីតួនាទីស្ត្រី ក្រុមជនជាតិភាគតិច និងអ្នកដទៃទៀតដែលមានប្រវត្តិ និងសមត្ថភាពខុសគេ។



សកម្មភាពអនុវត្ត : ការវាយតម្លៃអំពីសមភាពក្នុងសម្ភារៀន និងបង្រៀន

ឥឡូវនេះ យើងបានរៀនរួចហើយនូវអ្វីដែលត្រូវស្វែងរក ចូរយកសៀវភៅសិស្សមួយក្បាលមកអាន ហើយព្យាយាមវិភាគអត្ថបទក្នុងសៀវភៅនោះ ដោយប្រើរាល់ចំណុចដែលបានរៀបរាប់ខាងលើ។ សកម្មភាពនេះអាចល្អសម្រាប់គ្រូបង្រៀនយកមកអនុវត្តតាម។ លើសនេះទៀត នៅពេលពន្យល់ពីគំនិតរួចហើយ កុមារ

អាយុច្រើនអាចជួយវិភាគអត្ថបទក្នុងសៀវភៅនេះ ហើយផ្តល់អនុសាសន៍ស្តីពីវិធីកែសម្រួលសៀវភៅនេះ ដើម្បី បញ្ចូលឱ្យបានគ្រប់សមាសភាព។ មាតាបិតា ឬអាណាព្យាបាលអាចជួយផ្តល់យោបល់គួររួបលំអថ្មី។ ដើម្បី បន្ថែមទៅលើអ្វីដែលអ្នក និងសិស្សបានធ្វើកែសម្រួលរួចហើយ ហើយជួយកែលំអភាពលំអៀងមួយចំនួន ដែលមាននៅក្នុងសៀវភៅនេះ ដោយប្រើព័ត៌មាន និងឧទាហរណ៍ទាក់ទងនឹង ទំនៀមទម្លាប់វប្បធម៌ក្នុងស្រុក។ ចូរប្រើតារាងខាងក្រោម ដើម្បីជួយដល់ការវិភាគរបស់អ្នក។

បញ្ហាដែលត្រូវវិភាគ	មានអ្វីជាភស្តុតាង? នៅទំព័រមួយណា?	គួរធ្វើអ្វីដើម្បីកែលំអសៀវភៅ	ត្រូវការជំនួយឬទេ
ពិនិត្យគំនូរលំអ			
ពិនិត្យដំណើររឿង			
ពិនិត្យរបៀបរស់នៅ			
ពិនិត្យមើលទំនាក់ទំនង			
កត់សម្គាល់នូវភាវៈបុរស			
ពិចារណាលទ្ធផលស្តីពីការឆ្លុះបញ្ចាំងរូបភាពខ្លួនឯងរបស់កុមារ			
នានាភាពនៃចរិតលក្ខណៈ			
ភាសា			

យេនឌ័រ និងការបង្រៀន

គ្រូបង្រៀន និងសាលារៀនអាចបង្កប់ឱ្យអនុវត្តដោយអចេតនានូវលក្ខណៈគំរូយេនឌ័រ។ យើងអាច :

- *អំពាវនាវកុមារាឆ្លើយសំណួរឱ្យបានញឹកញាប់ជាងយើងអំពាវនាវកុមារី។*
- *ចាត់តាំងការងារថែរក្សាផ្ទះដល់កុមារី និងការងារប្រើឧបករណ៍ដល់កុមារា។*
- *ផ្តល់រង្វាន់កុមារាសម្រាប់ចម្លើយត្រឹមត្រូវ ហើយមិនសរសើរកុមារី។*
- *ទិតៀនកុមារីសម្រាប់ចម្លើយមិនត្រឹមត្រូវ។*
- *ផ្តល់ការទទួលខុសត្រូវដល់កុមារា ច្រើនជាងកុមារី (ដូចជា ធ្វើជាប្រធានថ្នាក់ ឬប្រធានក្រុម)។*
- *ប្រើសៀវភៅអត្ថបទ និងសម្ភារសិក្សាផ្សេងទៀតដែលជំរុញមានគំរូយេនឌ័រមិនល្អ និងគ្រោះថ្នាក់។*

ជាងនេះទៀត គ្រូបង្រៀនជាច្រើនអាចមិនបានដឹងពេញលេញថា ពួកគេបានប្រព្រឹត្តទៅលើកុមារី និងកុមារាផ្សេងពីគ្នា។ ជាគ្រូបង្រៀន យើងត្រូវមានការទទួលខុសត្រូវច្បាស់លាស់ ដើម្បីបង្កើតឱកាសសម្រាប់ កុមារទាំងអស់ កុមារី និងកុមារា រៀនឱ្យបានអស់ពីសមត្ថភាព។

ចូរចាំថា មិនមែនជាការចាំបាច់ឡើយក្នុងការប្រឆាំងជំទាស់នឹងគំនិតដែលជាគោលការណ៍គ្រឹះរបស់វប្បធម៌ ឬសហគមន៍មួយ។ ទោះជាយ៉ាងណាក្តី ជាការចាំបាច់ត្រូវយល់ពីរបៀបដែលគំនិតទាំងនេះអាចមានឥទ្ធិពលលើការអនុវត្តការបង្រៀនរបស់យើង និងឱកាស សិក្សាដែលកុមារទាំងអស់គួរមាន។



សកម្មភាពអនុវត្ត : សមធម៌យេនឌ័រ

ទោះជាធ្វើការម្នាក់ឯង ឬជាសកម្មភាពថ្នាក់រៀនក្តី ចូរធ្វើការស្ទាបស្ទង់ខ្លួនមួយ ដើម្បីទទួលបានការយល់អំពីសាលា និងសហគមន៍ជាល់របស់អ្នក។ នៅក្នុងតារាងខាងក្រោម ចូរសរសេរការងារទាំងឡាយដែលកុមារា និងកុមារីធ្វើនៅផ្ទះ ឬសហគមន៍ក្នុងស្រុក (ដូចជា ការយួរទឹក ការចម្អិនអាហារ ការថែរក្សាកុមារដទៃទៀត ឬការថែទាំសត្វ) និងការងារទាំងឡាយដែលគ្រូណែនាំកុមារឱ្យធ្វើនៅក្នុងសាលា (ដូចជា ការបោសសំរាម ការប្តូរតុ)។ តើការងារដែលយើងបានឱ្យកុមារា និងកុមារីធ្វើនៅសាលាដូចគ្នានឹងការងារនៅផ្ទះ ឬនៅសហគមន៍ឬទេ? តើ ការងារទាំងនេះឆ្លុះបញ្ចាំងពីជំនឿជាប្រពៃណីអំពីតួនាទីរបស់បុរស និងស្ត្រី ឬទេ? តើការងារទាំងនេះបានបញ្ឈប់កុមារីមិនឱ្យធ្វើសកម្មភាពនានាដែលពួកគេអាចធ្វើបានយ៉ាងពេញលេញឬ?

ទាក់ទងនឹងការស្ទាបស្ទង់របស់អ្នក តើសកម្មភាពអ្វីដែលអ្នក និងសិស្សរបស់អ្នកអាចធ្វើដើម្បីជានាឱ្យកុមារទាំងអស់មានឱកាស រៀនអំពីវិធីធ្វើការងារជាក់លាក់ណាមួយ នឹងយកការទទួលខុសត្រូវ។

តើសកម្មភាពអ្វីដែលអ្នក និងសិស្សរបស់អ្នកអាចធ្វើនៅក្នុងសាលា និងសហគមន៍ ដើម្បីលើកទឹកចិត្តបុគ្គលិកសាលា និងសមាជិកសហគមន៍ ក្នុងការឱ្យកុមារទាំងអស់ចូលរួមឱ្យបានស្មើគ្នា និងដើម្បីរួមចំណែកចំពោះការអភិវឌ្ឍសហគមន៍របស់គេ សាលារបស់គេ និងខ្លួនគេផ្ទាល់។

	កុមារា	កុមារី	យោបល់
ផ្ទះ ឬ សហគមន៍			
សាលារៀន			

នានាភាព និងពិការភាព

យុទ្ធសាស្ត្រសម្រាប់សិស្សពិការ[3]

នៅពេលយើងកំពុងបង្កើតថ្នាក់រៀនដែលបញ្ចូលគ្រប់សមាសភាព និងកំពុងព្យាយាមរាប់បញ្ចូលកុមារដែលមានសមត្ថភាពខុសគេ យើងត្រូវការយុទ្ធសាស្ត្រនានា ដើម្បីជួយកុមារទាំងនេះរៀនឱ្យបានពេញលេញបំផុត។ យុទ្ធសាស្ត្រទាំងនេះមានមួយចំនួនដូចខាងក្រោម :

- **ភាពបន្តបណ្តាក់គ្នា:** *បែងចែកការកិច្ច ហើយផ្តល់ការណែនាំមួយជំហានម្តងៗ។*
- **ធ្វើដដែលៗ និងចម្លើយត្រលប់ :** *ចូរប្រើលំហាត់សាកល្បងប្រចាំថ្ងៃស្តីពីជំនាញ ជាការអនុវត្តដដែលៗ ចម្លើយត្រលប់ប្រចាំថ្ងៃ។*
- **ចាប់ផ្តើមពីផ្នែកតូចៗ ហើយស្មាបនា :** *ចែកជំនាញដែលជាគោលដៅមួយទៅជាផ្នែក ឬអាកប្បកិរិយាតូចៗ ហើយបន្ទាប់មក បង្កើតផ្នែកផ្សេងៗទាំងនោះទៅជាផ្នែកទាំងមូលមួយ។*
- **កាត់បន្ថយភាពលំបាក :** *ការកិច្ចបន្តបន្ទាប់គ្នាពីងាយស្រួលទៅលំបាក ហើយដោយគ្រាន់តែផ្តល់តម្រុយចាំបាច់ ប៉ុណ្ណោះ។*
- **ការសួរសំណួរ :** *សួរសំណួរដែលទាក់ទងនឹងដំណើរការ ("របៀបយ៉ាងម៉េចដើម្បី") ឬ សំណួរទាក់ទងនឹងខ្លឹមសារ ("តើអ្វីជា")។*

---

[3] This section on "Children Who Have Difficulty Seeing" was adapted from: Baily D, Hawes H and Bonati B. (1994) Child-to-Child: A Resource Book. Part 2: The Child-to-Child Activity Sheets. London: The Child-to-Child Trust.

- **ក្រាហ្វិក :** *សង្កត់ធ្ងន់លើរូបភាពនានា ឬតំណាងគំនូរនានា។*
- **ការណែនាំក្រុម :** *ការណែនាំកើតមាននៅក្នុងក្រុមសិស្សតូចមួយ ហើយអាចណែនាំដោយគ្រូ។*
- **ការបន្ថែមការចូលរួមរបស់គ្រូ និងអ្នកមានវ័យប្រហាក់ប្រហែលគ្នា :** *ប្រើកិច្ចការសាលាសម្រាប់ធ្វើនៅផ្ទះ មាតាបិតា ឬអ្នកដទៃទៀត ដើម្បីជួយក្នុងការណែនាំ។*

ជាងនេះទៀត អ្នកអាចលើកទឹកចិត្តកុមារដទៃទៀតឱ្យយកការទទួលខុសត្រូវមិត្តរួមថ្នាក់ដែលពិការដោយការដាក់ជាគូៗនូវកុមារពិការម្នាក់ៗជាមួយកុមារដែលមិនពិការ។ ស្នើដៃគូឱ្យជួយការកិច្ចសំខាន់ៗ។ ឧទាហរណ៍ ទៅកន្លែងដែលកុមារពិការចង់ទៅបង្គន់ បរិភោគ ជាដើម។ ស្នើដៃគូជួយកុមារធ្វើសកម្មភាពនានាដូចជាការធ្វើដំណើរទស្សនកិច្ចដល់កន្លែង ឬលេងល្បែងជាក្រុមការងារ។ ពន្យល់ដល់ដៃគូថា ពួកគេត្រូវការពារកុមារពិការកុំឱ្យមានគ្រោះថ្នាក់ដោយសំដី ឬរូបកាយ និងច្រាប់ពួកគេនូវវិធីដ៏ល្អបំផុតដើម្បីធ្វើដូច្នេះ។

ចូរនិយាយច្រាប់សិស្សរបស់អ្នកអំពីភាពពិការផ្សេងៗគ្នា ជាពិសេស ភាពពិការមួយដែលពួកគេអាចឃើញចំពោះកុមារនៅក្នុងសាលា ឬនៅសហគមន៍។ មធ្យោបាយមួយដើម្បីនិយាយពីបញ្ហានេះគឺត្រូវស្នើមនុស្សពេញវ័យម្នាក់ដែលពិការឱ្យមកថ្នាក់របស់អ្នក ហើយ និយាយជាមួយកុមារ។

ចូរពន្យល់ដល់កុមារថា ភាពពិការគឺបណ្តាលមកពីជំងឺ គ្រោះថ្នាក់ ឬហ្សែន។ ឧទាហរណ៍ អ្នកអាចពន្យល់ថា ជំងឺឆ្លងនៅក្នុងភ្នែក ឬត្រចៀក អាចបង្កឱ្យមានបញ្ហាក្នុងការឃើញ ឬឮ។

ដើម្បីជួយកុមារដែលមិនពិការឱ្យព្រមទទួលរាប់រកកុមារពិការ ចូរនិយាយរឿងច្រាប់ពួកគេ ដោយពណ៌នា អំពីអ្វីដែលមនុស្ស ពិការអាចធ្វើបាន។

កុមារដែលមានបញ្ហាក្នុងការមើល

រកឱ្យឃើញកុមារដែលមិនអាចមើលឃើញច្បាស់

កុមារខ្លះមិនអាចមើលឃើញច្បាស់ដូចកុមារដទៃទៀតឡើយ។ ប្រសិនបើរកឃើញបញ្ហានេះបានរហ័ស យើងអាចធ្វើសកម្មភាពជាច្រើនដើម្បីជម្នះបញ្ហានេះ។ ជាងនេះទៀត កុមារដែលទទួលរងការឈឺចាប់បំផុតនោះ គឺកុមារដែលមានប្រវត្តិ និងសមត្ថភាពខុសគេ ព្រោះការមើលមិនឃើញច្បាស់ ជាសត្រូវ និងជាស្ថានភាពលំបាកដែលមិនត្រូវបានគេយកចិត្តទុកដាក់។ កុមារប្រភេទនេះ អាចទទួលរងគ្រោះថ្នាក់កាន់តែខ្លាំងដោយការជន្លជន្លេញលេង ការយាយី និងការសម្លុតគំរាម។ ដូច្នេះ ជាការសំខាន់ត្រូវដឹងថា តើកុមារអាចមើលឃើញច្បាស់តាំងពីក្មេងឬទេ។ មានមធ្យោបាយខុសៗគ្នាដើម្បីដឹងពីបញ្ហានេះ។ កុមារដទៃទៀត អាចជួយរកឃើញថា តើកុមារណាម្នាក់មើលឃើញច្បាស់ឬ មិនច្បាស់ និងរៀនអំពីវិធីជួយកុមារប្រភេទនោះ។

សញ្ញាខ្លះស្តីពីកុមារដែលមិនអាចមើលឃើញច្បាស់ គឺនៅពេលដែលកុមារ:[3]

- ប៉ះទង្គិចជាមួយវត្ថុណាមួយដោយងាយ។
- មានការលំបាកក្នុងការអានអ្វីមួយដែលនៅជិត ឬនៅឆ្ងាយ។
- មានការលំបាកក្នុងការសរសេរឱ្យត្រង់ជួរ។
- មានការលំបាកក្នុងការដោតអំបោះចូលម្ជុល។
- កាន់សៀវភៅកៀកទៅនឹងមុខរបស់ខ្លួន នៅពេលអាន និងអាចមានចេញទឹកភ្នែក។
- អាចត្អូញត្អែរពីការឈឺក្បាល ឬរមាស់ភ្នែក។
- មិនអាចចាប់បាល់បាននៅពេលកំពុងលេង។
- ស្លៀកពាក់សម្លៀកបំពាក់បញ្ច្រាស។
- រៀបចំវត្ថុអ្វីមួយមិនត្រឹមត្រូវ។
- នាំយកមកនូវវត្ថុដែលមិនត្រឹមត្រូវ ពេលស្នើឱ្យនាំយកវត្ថុអ្វីមួយ។

ការពិនិត្យចក្ខុវិញ្ញាណរបស់កុមារ

ការរកឃើញយ៉ាងរហ័សនូវកុមារដែលមិនអាចមើលឃើញ គឺមានសារៈសំខាន់យ៉ាងខ្លាំងក្នុងការជួយកុមារឱ្យរៀន និងស្ថិតនៅក្នុងសាលា។ មានបច្ចេកទេសធម្មតាៗជាច្រើនដែលអ្នក និងសិស្សរបស់អ្នកអាចធ្វើបាន ដើម្បីរកឃើញកុមារទាំងនេះ ដូចជាឧទាហរណ៍ខាងក្រោម :

ការអភិវឌ្ឍដោយមើលភ្នែកធម្មតា

ជំហានទី ១. ចូរធ្វើក្រដាសស្តង់ស៊ីលមួយដែលមានរៀងអក្សរ "E" ចំនួន ៦ អក្សរមួយស្ថិតនៅកម្ពស់៦ស.ម ហើយអក្សរដទៃទៀតស្ថិតនៅកម្ពស់៤,៥ស.ម ៣ស.ម ១,៥សម ០,៥ស.ម និង ០,២៥ស.ម។ វាមានសារៈសំខាន់យ៉ាងខ្លាំងក្នុងការផ្តល់រូបសញ្ញានត្រឹមត្រូវដល់តួអក្សរនីមួយៗ។ "ជើង" អក្សរ "E" នីមួយៗគួរមានទំហំដូចគ្នា ហើយផ្ទៃលំហនីមួយៗដែលនៅចន្លោះជើងអក្សរ "E" គួរមានទំហំដូចគ្នា។

ជំហានទី ២. ដោយប្រើក្រដាស្តង់សីលនេះ ឬក្រដាសស្តង់ស៊ីលផ្សេងទៀត ចូរស្នើកុមារម្នាក់ៗធ្វើអក្សរ "E" មួយដែលមានរង្វាស់ត្រឹមត្រូវ ហើយលាបពណ៌ខ្មៅ។

---

[4] Adapted from: Baily D, Hawes H and Bonati B. (1994) Child-to-Child: A Resource Book. Part 2: The Child-to-Child Activity Sheets. London: The Child-to-Child Trust.

ជំហានទី ៣. យកការបិទអក្សរ "E" នីមួយៗ ទៅលើបន្ទះក្តារពណ៌សធំមួយ ឬលើក្រដាសកាតុងធ្ងន់មួយផ្ទាំង។ តារាងគួរមើលទៅដូចជា តារាងខាងក្រោម។

ជំហានទី ៤. ចូរឱ្យកុមារសោកល្បងគ្នាទៅវិញទៅមក។ ចូរព្យួរតារាងនៅកន្លែងដែលមានពន្លឺគ្រប់គ្រាន់។ ចូរគូសខ្សែមួយនៅលើដីចម្ងាយ៦ម៉ែត្រ ពីតារាង។ កុមារដែលនឹងត្រូវសាកល្បងឈរនៅខាងក្រោយខ្សែនេះ ហើយកាន់ក្រដាសកាតុងអក្សរ "E"ធំមួយ។ ត្រូវសាកល្បងភ្នែកនីមួយៗដាច់ពីគ្នាដោយភ្នែកម្ខាងត្រូវគ្របបិទដោយប្រយ័ត្ន។ កុមារម្នាក់ទៀតចង្អុរទៅអក្សរនានានៅលើតារាង។ ដំបូង កុមារគួរចង្អុលទៅអក្សរដែលធំ។ ហើយបន្ទាប់មកទៅអក្សរដែលកាន់តែតូចទៅៗ។ **កុមារដែលកំពុងត្រូវគេសាកល្បងត្រូវកាន់អក្សរ "E" របស់ខ្លួនក្នុងទិសដៅដូចគ្នានឹងទិសដៅនៃអក្សរដែលកុមារម្នាក់ទៀតកំពុងចង្អុល។**

ជំហានទី ៥. ពេលកុមារដឹងរបៀបក្នុងការសាកល្បង ចូរជួយពួកគេគិតអំពីមធ្យោបាយនានាក្នុងការផ្តល់ការសាកល្បងដល់កុមារតូចៗ ជាពិសេសកុមារដែលនឹងត្រូវចូលរៀននៅពេលឆាប់ៗខាងមុខ។ នៅសាលា កុមារនៅថ្នាក់ខ្ពស់ៗអាចធ្វើការសាកល្បងការមើលឃើញរបស់កុមារនៅថ្នាក់ទាបៗជាង។ ត្រូវពិគ្រោះជជែកដែរជាមួយបុគ្គលិកសុខាភិបាលក្នុងស្រុក និងអ្នកឯកទេសខាងភ្នែក ដើម្បីពិនិត្យមើលថាតើមានសកម្មភាពសាកល្បងភ្នែកស្រដៀងគ្នាណាមួយត្រូវបានអភិវឌ្ឍដើម្បីតម្រូវតាមភាសាក្នុងស្រុក និងវប្បធម៌របស់អ្នកឬទេ។

ជួយកុមារដែលមើលឃើញមិនច្បាស់

ពេលកុមារណាម្នាក់មានបញ្ហាក្នុងការមើលមកសាលានៅពេលលើកដំបូង ត្រូវជួបកុមារនោះ និងមាតាបិតាតែឯង។ ត្រូវឱ្យកុមារដឹងថា អ្នកជាអ្នកណា ដោយការនិយាយជាមួយកុមារ ហើយពន្យល់ពីអ្វីដែលអ្នកកំពុងធ្វើ។ ត្រូវឱ្យកុមារស្ងាបប៉ះអ្នក។

បន្ទាប់មក ត្រូវណែនាំកុមារនោះឱ្យស្គាល់មិត្តរួមថ្នាក់របស់ខ្លួន។ ត្រូវពន្យល់ថា កុមារនេះទៅសាលារៀនដូចកុមារផ្សេង។ទៀតដែរ ហើយកុមារនេះអាចធ្វើអ្វីផ្សេង។ ដោយប្រើញាណផ្សេង។របស់ខ្លួន ដូចជាការប៉ះ ការស្តាប់ និងការហិតក្លិន។ ចូរសំណូមពរថា នៅពេលដែលកុមារនេះអាចត្រូវការជំនួយខ្លះក្នុងភារកិច្ចជាក់លាក់ណាមួយ ពួកគេទាំងអស់អាចរៀនពីគ្នាទៅវិញទៅមក។

ត្រូវណែនាំមិត្តរួមថ្នាក់ឱ្យស្គាល់កុមារនេះ។ ប្រសិនបើកុមារមិនអាចមើលឃើញមិត្តរួមថ្នាក់ ត្រូវច្រាប់ឈ្មោះសិស្សចំនួន។ ចូរឱ្យកុមារនេះនិយាយជាមួយកុមារទាំងនោះរហូតដល់កុមារចង់ចាំសម្លេង និងឈ្មោះ។ ចូរឱ្យកុមារនោះប៉ះពួកគេ។ បន្ទាប់មក ត្រូវច្រាប់កុមារនេះពីឈ្មោះរបស់កុមារដទៃទៀត ដូច្នេះ កុមារចាប់ផ្តើមស្គាល់កុមារទាំងអស់ក្នុងថ្នាក់។

កុមារដែលមានបញ្ហាការមើល ជាធម្មតា មិនដឹងថាមនុស្សបានមកក្បែរខ្លួននៅពេលណាឡើយ ពីព្រោះពួកគេមើលមិនឃើញ។ ពួកគេអាចឃើញនរណាណាម្នាក់ដែលគេបានជួបឡើយ។ នៅពេលអ្នកនៅជាមួយកុមារដែលមិនអាចមើលឃើញច្បាស់ ចូរនិយាយជាមួយ កុមារនោះ ដើម្បីឱ្យកុមារដឹងថាអ្នកនៅទីនោះ។ ចូរច្រាប់កុមារទាំងឡាយក្នុងថ្នាក់ និងក្នុងសាលារបស់អ្នកឱ្យធ្វើដូចអ្នកដែរ។

ចូរសរសេរនៅលើក្តារខៀនដោយប្រើអក្សរធំ។ ចូរបង្រៀនកុមារដទៃទៀតឱ្យសរសេរដូច្នេះផងដែរ។ ចូរអានការណែនាំនានា ចូរកុំគិតថា អ្នករាល់គ្នាអាចអានអក្សរលើក្តារខៀនបានគ្រប់គ្នា។ ចូរបញ្ជាក់ឱ្យច្បាស់នូវអ្វីដែលត្រូវបានពិពណ៌នាលើសម្ភារជំនួយដាក់ស្តែង (ដូចជា "នៅខាងឆ្វេងដៃគឺជា.....")។ ចូរឱ្យកុមារប៉ះសម្ភារជំនួយក្នុងការបង្រៀនទាំងនេះ បើកុមារមិនអាចមើលឃើញ។ ឧទាហរណ៍ ផែនទីអាចជាគម្រោងប្លង់ដែលប្រើដោយខ្សែ។ កុមារម្នាក់ៗដែលមានបញ្ហាក្នុងការមើលត្រូវការ "អ្នកអានម្នាក់" ដើម្បីជួយ។ អ្នកអាននោះត្រូវអាន និងពន្យល់ពីសៀវភៅនានាដល់កុមារនោះ និងជួយកុមារនោះក្នុងការរៀន។ អ្នកអាននោះអាចជាមិត្តរួមថ្នាក់ កុមារម្នាក់ ដែលមានអាយុច្រើនជាង មិត្តភក្តិ ឬគ្រូបង្រៀនដែលជាអ្នកស្ម័គ្រចិត្ត។

កុមារដែលអាចមើលឃើញផ្នែកខ្លះៗអាចរៀនអាន និងសរសេរក្នុងរបៀបដូចគ្នានឹងកុមារដទៃទៀតរៀនដែរ។ ដំបូង ចូរបង្រៀន កុមារនោះសរសេរដោយប្រើដីសនៅលើក្តារ។ ចូរភ្ជាប់ផ្នែកផ្សេង។នៃខ្សែកាត់តាមក្តារឆ្នូតនោះ ដើម្បីឱ្យកុមារអាចស្ទាប និងប្រើវាជាខ្សែសម្រាប់ណែនាំនៅពេលកំពុងសរសេរ។ នៅពេលកុមារចាប់ផ្តើមសរសេរលើក្រដាស ចូរភ្ជាប់ខ្សែក្នុងរបៀបដូចគ្នានេះដែរលើបំណែកឈើមួយ។ ចូរបង្រៀនកុមារនោះដាក់ក្រដាសនៅពីក្រោមខ្សែទាំងនោះ។

កុមារដែលមានបញ្ហាពិបាកក្នុងការស្តាប់ ឬនិយាយ

កុមារដែលមានបញ្ហាលំបាកក្នុងការស្តាប់ ឬនិយាយ ជារឿយ។ មិនធ្វើការច្រាស្រ៍យទាក់ទងគ្នាឡើយ ឬពួកគេធ្វើការច្រាស្រ៍យទាក់ទងគ្នាមិន បានល្អឡើយ។ នេះគឺព្រោះថា យើងប្រើការស្តាប់ និងការនិយាយជាច្រើនដង។ ទោះជាយើងប្រើវិធីផ្សេង។ដើម្បីច្រាស្រ៍យទាក់ទងក៏ដោយ។

ការរកឃើញកុមារដែលមិនអាចស្តាប់ឮច្បាស់

សញ្ញាដែលអាចប្រាប់យើងថា តើកុមារណាម្នាក់កំពុងមានបញ្ហាលំបាកក្នុងការស្តាប់ មានមួយចំនួនដូចខាងក្រោម[4] :

- កុមារមិនយកចិត្តទុកដាក់ពីសម្លេង ឬភាពអ៊ូអែផ្សើយ ប្រសិនបើកុមារនោះមិនដឹងថា សម្លេងទាំងនោះមកពីណា។
- កុមារហាក់ដូចជាមិនស្តាប់បង្គាប់ ឬជាមនុស្សចុងក្រោយដែលស្តាប់តាមបញ្ជា ឬសំណើរអ្វីមួយ។
- ត្រចៀកកុមារនោះមានជំងឺឆ្លង ឬវត្តុរាវ ឬខ្ទុះហូរចេញមកក្រៅ។
- កុមារសំឡឹងមើលបបូរមាត់អ្នកដទៃ នៅពេលពួកគេកំពុងនិយាយ។
- កុមារងាកក្បាលក្នុងទិសដៅមួយដើម្បីស្តាប់។
- កុមារនិយាយខ្លាំងៗ ហើយមិនច្បាស់។
- ជួនកាល កុមារហាក់ដូចជាស្ងប់ស្ងាត់ ហើយមានអាកប្បកិរិយាច្រលើសបើស និងចង់នៅម្នាក់ឯង។
- កុមារមិនអាចរៀនក្នុងថ្នាក់បានពូកែឡើយ។

ការច្រាស្រំយទាក់ទងជាមួយកុមារដែលមានបញ្ហាពិបាកក្នុងការស្តាប់

កុមារខ្លះដែលកើតមកស្តាប់មិនលើអាចមិនរៀននិយាយ។ ពួកគេគួរត្រូវបានបង្រៀននូវវិធីផ្សេងៗ ដើម្បីបញ្ចេញនូវគំនិត តម្រូវការ និងអារម្មណ៍របស់ខ្លួន ដូចជា ផ្នែកសិល្បៈ ឬតាមរយៈចលនា និងកាយវិការ។ ប្រសិនបើកុមារម្នាក់នៅក្នុងថ្នាក់របស់អ្នកមិនអាចស្តាប់ឮ ឬនិយាយ ចូរប្រើវិធីសាស្ត្រទំនាក់ទំនងផ្សេងៗ ជាមួយកុមារនេះ ដូចជា ការនិយាយ ប្រើដៃ មុខ ឬចលនាដង្ហុង ឬការសរសេរ។ ចូរបង្រៀនកុមារដទៃទៀតឱ្យប្រើវិធីសាស្ត្រផ្សេង។ ដើម្បីទំនាក់ទំនងជាមួយកុមារនោះ។

មុនពេលនិយាយជាមួយកុមារនោះ ចូរឱ្យកុមារនោះយកចិត្តទុកដាក់ ដូច្នេះកុមារនោះនឹងដឹងថា អ្នកកំពុងនិយាយ។ ត្រូវប្រាកដថា កុមារនោះអាចមើលឃើញអ្នកច្បាស់ ហើយត្រូវឈរចំកន្លែងភ្លឺ។

ជួនកាល កុមារដែលមានបញ្ហាក្នុងការស្តាប់ ឬនិយាយមានអារម្មណ៍ឆេវឆាវ។ ពួកគេអាចយកចិត្តទុកដាក់ ឬពួកគេអាចមិនស្តាប់ ដោយយកចិត្តទុកដាក់ចំពោះអ្វីដែលគេកំពុងនិយាយ។ ចូរអង្កេតមើលកុមារទាំងនោះដោយយកចិត្តទុកដាក់។ ប្រសិនបើកុមារទាំងនោះ មិនសូវយកចិត្តទុកដាក់ទេនោះ ត្រូវស្វែងរកវិធី

---

4 Adapted from: Baily D, Hawes H and Bonati B. (1994) Child-to-Child: A Resource Book. Part 2: The Child-to-Child Activity Sheets. London: The Child-to-Child Trust.

5 http://www.avert.org/children.htm

ផ្សេងទៀត ដើម្បីធ្វើឱ្យពួកគេចាប់អារម្មណ៍ចំពោះអ្វីដែលអ្នកកំពុងនិយាយ។ ឧទាហរណ៍ អ្នក និងកុមារត្រូវអង្គុយជារង្វង់ ដើម្បីឱ្យអ្នករាល់គ្នាឃើញមុខគ្នាទៅវិញទៅមក។ ការធ្វើដូច្នេះនឹងជួយដល់ការស្តាប់ និងការយល់។ ចូរ ប្រើតំរុយជាក់ស្តែង ដូចជា រូបភាព វត្ថុ ឬពាក្យគន្លឹះ ដើម្បីណែនាំបង្ហាញមេរៀន។

កុមារខ្លះដែលមានបញ្ហាការស្តាប់អាចពូកាន់តែច្បាស់ ប្រសិនបើអ្នកដទៃនិយាយកៀកត្រចៀកខ្លួន។ ត្រូវរកឱ្យឃើញថា តើវិធីនេះ អាចជួយកុមារដែលអ្នកបង្រៀនឬទេ។ ប្រសិនបើដូច្នេះ ត្រូវនិយាយឱ្យកៀកត្រចៀកកុមារ នៅពេលអ្នកធ្វើការច្រាស្រ៊ុយទាក់ទងជាមួយ កុមារនោះ។ ចូរច្រាប់កុមារដទៃឱ្យធ្វើដូចអ្នក។

នៅពេលអ្នកទំនាក់ទំនងជាមួយកុមារ អ្នកត្រូវផ្តល់ពេលឱ្យកុមារស្តាប់ និងគិត។ ប្រសិនបើកុមារនោះឆ្លើយដោយការបញ្ចេញសម្តេងពាក្យមិនត្រឹមត្រូវ ត្រូវនិយាយពាក្យទាំងនោះត្រឹមត្រូវឡើងវិញ និងដោយយឺត។ ដើម្បីឱ្យកុមារព្យាយាមនិយាយ។ ត្រូវច្រាកដថា កុមារនោះអាចឃើញមុខរបស់អ្នក នៅពេលអ្នកនិយាយពាក្យទាំងនោះត្រឹមត្រូវ។

នៅពេលអ្នកនិយាយ ត្រូវធ្វើចលនាផ្នែកផ្សេងៗនៃដងខ្លួន ដើម្បីធ្វើឱ្យកាន់តែយល់ច្បាស់នូវអ្វីដែលអ្នកនិយាយ ចំពោះកុមារដែល មានបញ្ហាក្នុងការស្តាប់។ អ្នកត្រូវប្រើដៃរបស់អ្នកជាដែរនៅពេលអ្នកនិយាយ។ ឧទាហរណ៍ អ្នកអាចប្រើដៃរបស់អ្នកដើម្បីបង្ហាញពីទំហំ វត្ថុនានា។

ត្រូវប្រើចលនា និងទឹកមុខឱ្យបានញឹកញាប់នៅពេលអ្នកនៅជាមួយកុមារដែលមានបញ្ហាក្នុងការស្តាប់។ កុមារនោះនឹងដឹងថា សកម្មភាពទាំងនេះមានន័យដូចម្តេច។ ត្រូវបង្រៀនកុមារដទៃទៀតឱ្យប្រើទឹកមុខ និងចលនា ដើម្បីច្រាស្រ៊ុយទាក់ទងជាមួយកុមារដែល មានបញ្ហាការស្តាប់។

ត្រូវព្យាយាមយល់ពីវិធីផ្សេងៗដែលកុមារនោះសម្តែងចេញ។ ត្រូវបន្តប្រើវិធីសាស្ត្រទំនាក់ទំនងផ្សេងៗជាមួយកុមារនោះជាដែរ ដើម្បីធ្វើឱ្យកុមារយល់ពីអ្វីដែលអ្នកចង់បាន។

កុមារដែលអាចពូពាក្យខ្លះៗគួរត្រូវបង្រៀនឱ្យចេះនិយាយ។ កុមារខ្លះរៀននិយាយបានច្បាស់ កុមារខ្លះទៀតព្យាយាមនិយាយ តែបានជោគជ័យត្រឹមបញ្ចេញសម្តេងដែលគេអាចយល់បានប៉ុណ្ណោះ។ អ្នកអាចទទួលជំនួយមួយចំនួនក្នុងការអភិវឌ្ឍជំនាញភាសាសញ្ញាពីអង្គការក្រៅរដ្ឋាភិបាល មូលនិធិនានា ឬស្ថាប័នដែលមានឯកទេសខាងការជួយផ្នែកសោតវិញ្ញាណដែលចុះឡាយ។

ប្រសិនបើជំនួយផ្នែកសោតវិញ្ញាណត្រូវបានប្រើ ត្រូវដឹងថា ជំនួយទាំងនេះនឹងពង្រីកកម្លាំងសម្តេងទាំងអស់ រួមទាំងសម្តេងថ្លង់ ជុំវិញផងដែរ។ វាអាចជាការពិបាកផងដែរ ក្នុងការញែកសម្តេងឱ្យដាច់ពីគ្នា ប្រសិនបើមនុស្សជាច្រើននិយាយនៅពេលដំណាលគ្នា។ ត្រូវលើក ទឹកចិត្តកុមារដែលមានបញ្ហាសោតវិញ្ញាណឱ្យអង្គុយជាមួយមិត្តភក្តិម្នាក់ដែលអាចកត់ត្រាសម្រាប់កុមារនោះ ដើម្បីឱ្យកុមារនោះអាចផ្តោតលើការមើលបបូរមាត់អាន។



សកម្មភាពអនុវត្ត : លេងល្បែង និងលំហាត់ច្រាណ

ល្បែង និងលំហាត់ច្រាណអាចជាឱកាសដ៏ល្អ ដើម្បីបង្កើតថ្នាក់រៀនដែលបញ្ចូលគ្រប់សមាសភាព។ ត្រូវព្យាយាមណែនាំសកម្មភាពណាមួយ ដែលកុមារចូលចិត្ត ដូចជាសកម្មភាពដូចខាងក្រោម :

លំហាត់ច្រាណអាចជួយកុមារទាំងអស់ឱ្យមានសុខភាពល្អ។ នៅពេលអ្នករៀបចំបង្កើតរយៈពេលហាត់ច្រាណសម្រាប់ថ្នាក់របស់អ្នក ត្រូវច្រាកដថា កុមារដែលមានប្រវត្តិ និងសមត្ថភាពខុសៗគ្នាអាចចូលរួមឱ្យបានច្រើនដែលអាចធ្វើទៅបាន។ កុមារខ្លះមិនអាចលេងល្បែងបានសកម្មឡើយ។ ត្រូវបញ្ចូលល្បែងនានាសម្រាប់ពួកគេ ដែលអាចលេង បានដោយមានការប្រឹង ប្រែងតិចតួច ឬដែលត្រូវបានលេងដោយការអង្គុយ។ ដើម្បីធ្វើឱ្យកុមារដែលមិនអាចមើលឃើញលេងល្បែងបាល់បាន ត្រូវដាក់កណ្តឹងមួយនៅខាងក្នុង ឬនៅផ្នែកខាងក្រៅបាល់ ដើម្បីឱ្យកុមារអាចឮសូរសម្លេងនៅពេលបាល់មានចលនា។

កុមារភាគច្រើនចូលចិត្តតន្ត្រី ទោះជាពួកគេមិនអាចកម្រើក ឬច្រៀងបាន ដោយសារពិការភាព។ កុមារដែលមានបញ្ហាក្នុងការសិក្សាចូលចិត្តតន្ត្រី។ សូម្បីកុមារដែលមានការពិបាកក្នុងការស្តាប់អាចចូលចិត្តតន្ត្រីដែរ ជាពិសេស ប្រសិនបើវាមានចង្វាក់មួយដែលគេអាចឃើញ តាមរយៈចលនាដងខ្លួន (ដូចជារបាំ) ឬ ប្រសិនបើឧបករណ៍ដែលប្រើសម្រាប់ប្រគំតន្ត្រីបញ្ចេញនូវរំញ័រចង្វាក់ដែលពួកគេមានអារម្មណ៍ដឹង។

ឧទាហរណ៍ស្តីពីល្បែងនានា



ល្បែងទី ១. រៀនដោយការមើល

កុមារម្នាក់បិទត្រចៀករបស់ខ្លួនដោយប្រើម្រាមដៃ។ កុមារម្នាក់ទៀតនិយាយរឿងកំប្លែងមួយច្រាប់ដល់ក្រុម។

បន្ទាប់មក កុមារម្នាក់ធ្វើជា "គ្រូ"។ "គ្រូ" ស្នើសុំឱ្យកុមារម្នាក់ៗឆ្លើយសំណួរអំពីរឿងនោះ។

នៅពេល "គ្រូ" បានបញ្ចប់ការសួរសំណួរ គ្រូសុំឱ្យកុមារដែលបិទត្រចៀក បើកត្រចៀក ហើយស្តាប់។ "គ្រូ" សុំឱ្យកុមារនោះច្រាប់ក្រុមនូវអ្វីដែល ខ្លួនមានអារម្មណ៍ ដែលមិនអាចឮរឿងបានច្បាស់។ កុមារនោះត្រូវពន្យល់នូវអ្វីដែលកុមារនោះអាចយល់តាមរយៈការមើលមុខ និងកាយវិការរបស់គ្រូ និងកុមារដទៃទៀត។

កុមារដែលអាចនិយាយរឿងបានភាគច្រើនពីការមើលមុខ និងកាយវិការនឹងត្រូវឈ្នះល្បែងនេះ។ កុមាម្នាក់ៗគួរមានឱកាសបិទត្រចៀក។ ការធ្វើដូច្នេះនឹងជួយកុមារយល់អំពីបញ្ហានានារបស់កុមារដែលមានបញ្ហាក្នុងការស្តាប់។ បន្ទាប់មក ពួកគេនឹងយល់អំពីបញ្ហា របស់កុមារនោះ។

ល្បែងទី ២. រៀនដោយការស្តាប



កុមារម្នាក់ត្រូវគ្របបាំងភ្នែករបស់ខ្លួន ហើយឈរនៅចំកណ្តាលវង្វង់នៃកុមារដទៃទៀត។

កុមារម្នាក់ៗ ដែលពីទ្ធជារង្វង់ជើរសំដៅកុមារដែលគ្របបាំងភ្នែក។ កុមារដែលបាំងមុខនេះរបស់កុមារម្នាក់ៗ។ ហើយព្យាយាមទាយថា កុមារម្នាក់ៗ នេះជានរណា។ ត្រូវផ្តល់ពេលឱ្យតែ ១ នាទី ប៉ុណ្ណោះ ដើម្បីទាយឈ្មោះកុមារម្នាក់ៗ។

កុមារ ដែលអាចចង់ចាំមុខរបស់មិត្តភក្តិខ្លួនបានច្រើនជាង់គេនឹងឈ្នះល្បែងនេះ។

កុមារម្នាក់ៗគួរមានឱកាសបិទភ្នែករបស់ខ្លួន។ ការធ្វើដូច្នេះនឹងជួយកុមារឱ្យយល់ពីបញ្ហានានារបស់កុមារដែលមានបញ្ហាក្នុងការមើល។

មេរោគអេដស៍/ជំងឺអេដស៍ និងការរើសអើង

នៅក្នុងពិភពលោកនាពេលបច្ចុប្បន្ន ចំនួនកុមារចេះតែកើនឡើងបានឆ្លងរោគ អេដស៍/ជំងឺអេដស៍តាំងពីកំណើតពីម្តាយដែលមានផ្ទុកមេរោគ។ កុមារដទៃទៀតត្រូវគេរើសអើង ឬត្រូវច្រានចេញពីសាលាពីព្រោះពួកគេរស់នៅក្នុងគ្រួសារដែលមានសមាជិកណាម្នាក់មានមេរោគអេដស៍/ជំងឺអេដស៍។ លទ្ធផលមួយទៀតរបស់មេរោគអេដស៍/ជំងឺអេដស៍គឺថា កុមារជាច្រើនអ្នកអាចបាត់បង់មាតាបិតាដោយសារជំងឺអេដស៍ ហើយកុមារទាំងនេះកំពុងរស់នៅជាមួយជីដូនជីតា ឬបងប្អូនដទៃទៀត ឬរស់នៅតាមដងផ្លូវ។

បញ្ហាចម្បងពីរប្រឈមមុខចំពោះគ្រូបង្រៀនក្នុងការលើកបង្ហាញមេរោគអេដស៍/ជំងឺអេដស៍ក្នុងថ្នាក់រៀនរបស់ខ្លួន។ បញ្ហាទី ១ គឺ បញ្ហាការអនុវត្តផ្នែកសុខភាព ដែលត្រូវធ្វើការទាក់ទងជាមួយកុមារមានផ្ទុកមេរោគអេដស៍/ជំងឺអេដស៍។ ដើម្បីធ្វើដូច្នេះ អ្នកត្រូវការទទួលបានការផ្តល់ព័ត៌មានឱ្យបានច្បាស់អំពីជំងឺឆ្លងទាំងអស់ ដើម្បីឱ្យអ្នកអាចនិយាយអំពីជំងឺអេដស៍ដែលទាក់ទងនឹងកុមារទាំងនោះ។ អ្នកអាចនិយាយជាមួយបុគ្គលិកសុខាភិបាលក្នុងស្រុក និងទទួលបានព័ត៌មានថ្មីៗ ជាពិសេសព័ត៌មានស្តីពីការកើតមានជាទូទៅនៃជំងឺឆ្លងទាំងអស់នៅក្នុងតំបន់របស់អ្នក ព្រមទាំងជំងឺអេដស៍ផងដែរ។ អ្នកអាចទទួលបានផងដែរនូវសម្ភារ

ព័ត៌មានសំខាន់ៗស្តីពីមេរោគអេដស៍/ជំងឺអេដស៍ ដើម្បីឱ្យអ្នកអាចចែករំលែកជាមួយសហការី និងសិស្ស របស់អ្នក។ ការចែករំលែកព័ត៌មាននេះអាចជួយកែលំអការយល់ខុសណាមួយអំពីជំងឺនេះ និងអ្នកទាំងឡាយ ដែលបានឆ្លងជំងឺនេះ។ ក្នុងផ្នែកអនុវត្តន៍ អ្នករាល់គ្នានៅក្នុងសាលារបស់អ្នកត្រូវចូលរួមថែរក្សាសាលារៀនឱ្យ ទៅជាកន្លែងមានអនាម័យ និងមានសុខភាពល្អសម្រាប់កុមារ។ ការផ្តល់ស្រោមដៃកៅស៊ូ និងថ្នាំក្លរ មាន ភាពចាំបាច់យ៉ាងខ្លាំងដើម្បីសំអាតឈាម ការកូតចង្អែរ និងលាមក។

បញ្ហាទី ២ គឺវិធីឆ្លើយសំណួររបស់កុមារស្តីពីមេរោគអេដស៍/ជំងឺអេដស៍ ដោយរាប់បញ្ចូលបញ្ហា ស្តីពីការរួមភេទ សុខភាពផ្លូវភេទ និងជំងឺ។ អ្នកនឹងមានអារម្មណ៍កាន់តែងាយស្រួលក្នុងការនិយាយជាមួយកុមារ ប្រសិនបើអ្នកបានគិតជាមុនអំពីសំណួរខ្លះៗដែលអាចនាំឱ្យមានការពិភាក្សា។ ឧទាហរណ៍ "តើមនុស្សកើត ជំងឺអេដស៍ដោយរបៀបណា?" ហើយ "ស្រោមអនាម័យគឺជាអ្វី?"។

នៅពេលកុមារម្នាក់សួរសំណួរមួយដល់អ្នក ចូរព្យាយាម :

- **ស្តាប់** ដោយយកចិត្តទុកដាក់។
- **ទទួលយក** អ្វីដែលពួកគេនិយាយ។
- ឆ្លើយ **តាមកម្រិតរបស់ពួកគេ** ហើយ។
- ត្រូវមានលក្ខណៈ **ស្មោះត្រង់** ដែលអាចធ្វើបាន[5]។

ប្រសិនបើអ្នកមិនដឹងចម្លើយចំពោះសំណួររបស់កុមារ ចូរកុំខ្លាចនិយាយថា អ្នកត្រូវការពេលដើម្បី ស្វែងរកចម្លើយត្រឹមត្រូវ។ ប្រសិនបើអ្នក ជាគ្រូនៅក្នុងសាលាមួយដែលមានកុមារផ្ទុកមេរោគអេដស៍/ជំងឺ អេដស៍ សូមអានកម្រងសៀវភៅទី ៦ នៅក្នុងកញ្ចប់គោលនេះ ដោយយកចិត្តទុកដាក់។ វាមានសំណូមពរ និង សកម្មភាពជាច្រើនសម្រាប់បង្រៀនអ្នក កុមាររបស់អ្នក និងសហការីរបស់អ្នកអំពីជំនាញសំខាន់ៗដើម្បីយល់ ពីមេរោគអេដស៍/ជំងឺអេដស៍ ព្រមទាំងវិធីនានាដែលអ្នកអាចបង្រៀនកុមារអំពីវិធីទប់ស្កាត់ការឆ្លងរាលដាល។

---

5 http://www.avert.org/children.htm



គោល ៤.៣
ធ្វើឱ្យការសិក្សាមានអត្ថន័យខ្លឹមសារ សម្រាប់ទាំងអស់គ្នា

ការរៀនសម្រាប់បម្រើជីវភាពរស់នៅ

នៅផ្នែកដំបូងនៃកញ្ចប់គោលនេះ យើងបានរៀនរួចហើយថា ឧបសគ្គដែលមានសក្តានុភាពមួយចំពោះការរៀនដែលបញ្ចូលគ្រប់សមាសភាព និងការនាំកុមារទាំងអស់ឱ្យចូលសាលាគឺ "តម្លៃនៃការអប់រំ"។ ម្យ៉ាងទៀត មាតាបិតា និងកុមារមិនអាចមើលឃើញថា ព័ត៌មានដែលបានរៀននៅសាលាមានខ្លឹមសារសម្រាប់ជីវភាពរស់នៅប្រចាំថ្ងៃរបស់ពួកគេទេ។ សម្រាប់មាតាបិតាដែលពឹងផ្អែកលើកូនរបស់ខ្លួន ដើម្បីរកច្រាក់ចំណូល ហើយសូម្បីតែកុមារផ្ទាល់អាចមានអារម្មណ៍ថា "ការរៀនធ្វើការ" មានសារៈសំខាន់ជាងការចូលរៀននៅសាលា។

សូម្បីកុមារដែលមិនត្រូវការរកច្រាក់ចំណូលគាំទ្រគ្រួសាររបស់ខ្លួន ពួកគេក៏អាចមានអារម្មណ៍ធុញទ្រាន់ក្នុងថ្នាក់រៀនដែរ ប្រសិនបើ ពួកគេមិនឃើញការទាក់ទងគ្នារវាងអ្វីដែលពួកគេកំពុងរៀន និងពួកគេនឹងក្លាយទៅជាអ្វីនៅពេលអនាគត។ ហេតុដូច្នេះ ពួកគេមិនអាចឱ្យតម្លៃសាលាឡើយ និងមិនអាចចូលរៀនជាប្រចាំបានឡើយ ប្រសិនបើមិនឃើញទំនាក់ទំនងអ្វីសោះរវាងការរៀនសូត្រ និងជីវភាពរស់នៅ។

អាស្រ័យហេតុនេះ បញ្ហាប្រឈមរបស់យើងគឺត្រូវបង្កើតបរិយាកាសរៀនមេត្រីមួយ ជាបរិយាកាសមួយដែលជំរុញកុមាររៀន ដោយការភ្ជាប់អ្វីដែលពួកគេកំពុងរៀន ជាមួយនឹងផលប្រយោជន៍របស់ពួកគេ និងជីវភាពរស់នៅប្រចាំថ្ងៃរបស់ពួកគេ។ ទំនាក់ទំនងនេះ មានសារៈសំខាន់ណាស់ ពីព្រោះនៅពេលអ្នកបង្រៀនកុមាររបស់អ្នក នៅក្នុងចិត្តរបស់ពួកគេ ពួកគេកំពុងព្យាយាមភ្ជាប់អ្វីដែលពួកគេកំពុងរៀននៅពេលនេះជាមួយអ្វីដែលពួកគេបានរៀនរួចហើយក្នុងជីវភាពរស់នៅ។ តើយើងអាចបង្កើតទំនាក់ទំនងនេះដូចម្តេច? ចូរមើលឧទាហរណ៍ស្តីពីករណីមួយ។

*ក្នុងខណៈកំពុងបើកបរតាមផ្លូវក្នុងស្រុក**Manatuto** (ប្រទេសទីម័រខាងកើត) កុមារី ៣ នាក់ព្យាយាមបញ្ឈប់យានយន្តរបស់យើង ដោយការគ្រវីខ្សែដែលមានត្រីតូចៗ។ យើងឈប់។ កុមារអាយុពី ៨–១០ ឆ្នាំ សុះសាមកលក់ត្រីដែលពួកគេរកបានដោយតម្លៃពីរឬបីសេន។ នៅម៉ោងប្រហែល ១១ ព្រឹកថ្ងៃសុក្រ។ មិនមែនជាថ្ងៃឈប់សម្រាកបុណ្យជាតិឡើយ។ តើកុមារីទាំងនេះគួរនៅក្នុងសាលាឬ? សំណួរគឺ "តើពួកគេគួរចេញពីសាលាឬទេ"។ ពួកគេកំពុងរៀនយ៉ាងសកម្ម កំពុងរៀនដោយការអនុវត្ត កំពុងជួយគ្រួសារ ដោយទំរាំតែជាតិប្លែតែអ៊ីនដ៏សំខាន់ ឬរកច្រាក់បន្តិចបន្តួចឱ្យគ្រួសារ ប្រសិនបើពួកគេអាចលក់ត្រីបាន។*

អ្នកអង្កេតឃ្លាំមើលស្រុកម្នាក់ ដែលកំពុងស្ថិតក្នុងយានយន្តដែរបានទាកចិត្តដែលថា កុមារីមិននៅក្នុងសាលា ប៉ុន្តែគាត់បានពន្យល់ថា ប្រសិនបើពួកគេនៅសាលារៀន ពួកគេអាចកំពុងរៀនភាសាបរទេសមួយ (ព្រោះភាសាកំណើតរបស់ខ្លួនមិនត្រូវបានបង្រៀននៅក្នុងសាលាឡើយ)។ សាលានានាមានសៀវភៅនិងសម្ភារសិក្សាតិចតួចណាស់ ដូច្នេះ កុមារត្រូវចំណាយពេលយ៉ាងច្រើនស្តាប់គ្រូ ឬចម្លងពីក្តារខៀន។ សៀវភៅ ដែលគ្រូអាចប្រើត្រូវបានបោះពុម្ពជាភាសាព័រទុយហ្គាល់។

*គាត់បានបន្តនិយាយថា គ្រូបង្រៀនជាច្រើនមិនបានទទួលការបណ្តុះបណ្តាលទេ ហើយដោយហេតុថាគ្មានផ្ទះសម្រាប់គ្រូបង្រៀន ពួកគេមិនរស់នៅក្នុងតំបន់នេះឡើយ។ គ្រូបង្រៀនអាចមិនដឹងថា កុមារបានចំណាយពេលវេលារបស់ខ្លួនដើម្បីលេងនៅលើឆ្នេរខ្សាច់ និងនេសាទត្រី។ សៀវភៅមេរៀននានាក៏បានបញ្ចូលខ្ទាហារណ៍ស្តីពីសកម្មភាពនានា ដូចជាការនេសាទត្រីនៅប្រទេសព័រទុយហ្គាល់ ជាដាច់នៅក្នុងស្រុក **Manatuto** ហើយជាធម្មតា មានតែកុមារាប៉ុណ្ណោះដែលត្រូវបានបង្ហាញថាកំពុងនេសាទត្រី ចំណែកកុមារីកំពុងចំអិនអាហារ។ អ្នកអង្កេត ឃ្លាំមើលស្រុកបាននិយាយថា ពួកគេកំពុងព្យាយាមធ្វើឱ្យមានបំលាស់ប្តូរ-នានា ដើម្បីធ្វើឱ្យសាលាមានបរិយាកាស "មេត្រី" ទាំងចំពោះកុមារា និងកុមារី ប៉ុន្តែវាមានការលំបាកណាស់ ហើយត្រូវការពេលវេលាផងដែរ។*

ប្រសិនបើគ្រូបង្រៀននៅក្នុងស្រុក **Manatuto** បានដឹងពីកុមារបានប្រសើរឡើង ហើយបានដឹងពីបរិយាកាសរស់នៅរបស់កុមារ ប្រហែល ជាពួកគេអាចសម្រួលកម្មវិធីសិក្សាដោយរាប់បញ្ចូលឱ្យបានច្រើនថែមទៀតនូវប្រធានបទ និងខ្ទាហារណ៍ក្នុងស្រុក។ ពួកគេអាចស្នើមាតាបិតា កុមារមួយចំនួនមកពន្យល់ពីវិធីនេសាទរបស់ខ្លួន ហើយមាតាបិតាកុមារអាចនាំមកនូវសំណាញ់ និងសម្ភារដទៃទៀតដែលពួកគេប្រើ។ កុមារអាចទៅផ្ទះ ហើយគូររូបត្រីផ្សេងៗដែលចាប់បានក្នុងស្រុក និងធ្វើផ្ទាំងបដាសម្រាប់ដាក់លើជញ្ជាំងថ្នាក់រៀន។ កុមារអាចថ្លឹងទម្ងន់ និងវាស់ប្រវែងត្រី ហើយធ្វើក្រាហ្វិកមួយដែលបង្ហាញពីទំហំត្រីផ្សេងៗ ដែលចាប់បាន។ តាមរយៈសកម្មភាពទាំងនេះ និងសកម្មភាពសិក្សាសកម្មដទៃទៀត កុមារនឹងត្រូវបានជំរុញបន្ថែមទៀតឱ្យមកសាលារៀន ហើយការរៀនសូត្ររបស់ពួកគេនឹងកាន់តែមានខ្លឹមសារឡើងសម្រាប់ពួកគេ និងសម្រាប់មាតាបិតារបស់ពួកគេ។



សកម្មភាពអនុវត្ត : ការភ្ជាប់ការសិក្សាជាមួយជីវភាពរស់នៅក្នុងសហគមន៍

ចូរត្រួតពិនិត្យឡើងវិញនូវកម្មវិធីសិក្សាជាតិ ហើយស្រង់ជាបញ្ជីនូវប្រធានបទសំខាន់ៗរបស់វា ដោយផ្អែកលើមូលដ្ឋាននៃអ្វីដែលកុមារ របស់អ្នកបានរៀនរួចហើយ និងអ្វីដែលអ្នកគិតថា ពួកគេគួរដឹងក្នុងទំនាក់ទំនងជាមួយជីវភាពរស់នៅប្រចាំថ្ងៃរបស់ពួកគេ។ ចូរព្យាយាម ភ្ជាប់ប្រធានបទនានាដែលស៊ីគ្នានឹងការ

កើតមានច្រើដែល។ប្រចាំឆ្នាំរបស់សហគមន៍ ដូចជា ប្រតិទិនកសិកម្ម ឬនេសាទត្រី ឬប្រធានបទនានាដែលជួយពួកគេរស់រានជីវិត ដូចជា ប្រធានបទស្តីពីសុខភាព។

ចូរគិតអំពីកុមារនៅក្នុងថ្នាក់ ឬសហគមន៍របស់អ្នក។ តើអ្នកដឹងពីមុខរបររបស់មាតាបិតាពួកគេឬទេ? តើអ្នកដឹងថា កុមារភាគ ច្រើនរស់នៅកន្លែងណា? តើកុមារជាច្រើនអវត្តមានមិនមកសាលាឬ? តើពួកគេអវត្តមាននៅពេលណា? តើសាលារបស់អ្នកមានប្រវត្តិ សង្ខេបស្តីពីការសិក្សារបស់កុមារដែលមាននិយាយពីព័ត៌មាននេះ (ចូរមើលកម្រងសៀវភៅទី ៣) ឬទេ ?

ចូរពិចារណាអំពីប្រធានបទដែលអ្នកនឹងបង្រៀននៅវគ្គសិក្សានេះ ហើយចូរបំពេញតារាងដូចតារាងដែលបានបង្ហាញនៅទីនេះ។ ចូរស្រង់ជាបញ្ជីនូវប្រធានបទនានា ពិនិត្យមើលថាតើប្រធានបទមានការទាក់ទងគ្នាយ៉ាងម៉េចទៅនឹងជីវភាពរស់នៅប្រចាំថ្ងៃរបស់កុមារ ហើយចូរគិតអំពីមធ្យោបាយនានាដើម្បីធ្វើឱ្យប្រធានបទទាំងនេះកាន់តែមានខ្លឹមសារឡើង។

ប្រធានបទ	ទំនាក់ទំនងជាមួយជីវភាពរស់នៅប្រចាំថ្ងៃរបស់កុមារ	វិធីកែសម្រួលប្រធានបទ
ឧទាហរណ៍ : ដើមឈើនៅក្នុងព្រៃក្រាស់	សហគមន៍ដែលកុមារកំពុងរស់នៅមានដើមឈើជាច្រើន ឬមានទីតាំងស្ថិតនៅក្បែរព្រៃដែលមិនមែនជាព្រៃក្រាស់។	ដំបូង រៀនអំពីព្រៃក្នុងភូមិស្រុក ដោយអង្កេត និងអនុវត្តជាក់ស្តែង ទាក់ទងនឹងមុខវិជ្ជាវិទ្យាសាស្ត្រ គណិតវិទ្យា និងភាសា។ បន្ទាប់មក ភ្ជាប់ខ្លឹមសារមេរៀនជាមួយនឹងព្រៃឈើនៅក្នុងតំបន់ ហើយនៅចុងបញ្ចប់ ទៅនឹងព្រៃឈើនៅលើពិភពលោក ដូចជាព្រៃក្រាស់ ។។
ឧទាហរណ៍ :		

បង្កើតបរិយាកាសរៀនមេត្រី សម្រាប់ការសិក្សាដែលមានអត្ថន័យខ្លឹមសារ

ត្រៀមខ្លួនដើម្បីការសិក្សាដែលមានអត្ថន័យខ្លឹមសារ

"ការរៀនដែលមានខ្លឹមសារ" មានន័យថា យើងផ្សារភ្ជាប់អ្វីដែលកំពុងរៀន (ប្រធានបទ ឬខ្លឹមសារ) និងវិធីបង្រៀនវា ជាមួយជីវភាព ប្រចាំថ្ងៃរបស់កុមារ និងគ្រួសាររបស់ពួកគេ។ ដូចយើងទាំងអស់គ្នាដឹងហើយថា ការបង្រៀនគឺជាសកម្មភាពស្មុគស្មាញមួយ។ យើងត្រូវ ពិចារណាបញ្ហាជាច្រើននៅពេលរៀបចំ

តាក់តែងការរៀនដែលមានខ្លឹមសារ។ ដំបូង គ្មានអ្នកណាអាចបង្ខំឱ្យកុមាររៀនបានទេ។ កុមារនឹង រៀននៅពេលពួកគេត្រូវបានជំរុញទឹកចិត្តដើម្បីរៀន។ ពួកគេនឹងរៀននៅពេលត្រូវបានផ្តល់ឱកាសរៀនប្រកបដោយប្រសិទ្ធភាព និងនៅពេល ពួកគេមានអារម្មណ៍ថា ជំនាញដែលពួកគេមាននឹងនាំទៅរកជ័យជម្នះ។ ពួកគេនឹងរៀននៅពេលពួកគេទទួលបានចម្លើយត្រលប់វិជ្ជមានពីមិត្តភក្តិ គ្រូបង្រៀន និងមាតាបិតា ដែលសរសើរពួកគេថា ពួកគេកំពុងរៀនពូកែដល់កម្រិតណាមួយ។ តើយើងអាចរៀបចំការរៀនដែលមានខ្លឹមសារ ដូចម្តេច? ទាំងនេះជាសំណួរខ្លះដើម្បីសួរខ្លួនអ្នកក្នុងការរៀបចំ កិច្ចតែងការបង្រៀន។

- **ការជំរុញទឹកចិត្ត :** តើប្រធានបទមានខ្លឹមសារ និងទាក់ទងនឹងកុមារឬទេ? តើពួកគេចាប់អារម្មណ៍ពីអ្វីដែលពួកគេនឹងរៀនឬទេ?
- **ឱកាស :** តើឱកាសនានាសមស្របឬទេចំពោះកម្រិតវិកចម្រើនរបស់កុមារ? (តើប្រធានបទពិបាកពេក ឬងាយពេកសម្រាប់កុមារជាច្រើន?) តើសកម្មភាពនានាសមស្របឬទេសម្រាប់ទាំងកុមារា និងកុមារី? តើវាសមស្របឬទេសម្រាប់កុមារដែលមានប្រវត្តិ និងសមត្ថភាពខុសៗ គេ។
- **ជំនាញ :** តើកុមារមានជំនាញ ដើម្បីសម្រេចបានលទ្ធផលរំពឹងទុកឬទេ?
- **ចម្លើយត្រលប់ :** តើប្រភេទនៃការវាយតម្លៃ និងចម្លើយត្រលប់ដែលបានផ្តល់ដល់កុមារត្រូវបានរៀបចំឡើងដើម្បីបង្កើនការជំរុញទឹកចិត្តឱ្យបន្តការរៀនឬ?



សកម្មភាពអនុវត្ត : ការភ្ជាប់ការរៀនសូត្រជាមួយជីវភាពរស់នៅរបស់កុមារ

ចូរព្យាយាមគិតម្តងទៀតអំពីប្រធានបទមួយដែលអ្នកនឹងបង្រៀន។ ចូរបន្ថែមវាទៅក្នុងតារាងខាងលើ។ តើអ្នកអាចធ្វើទំនាក់ទំនងជាមួយសកម្មភាពប្រចាំថ្ងៃរបស់កុមារបានឬទេ?

ឧទាហរណ៍ :

- ការងារផ្ទះ (រៀបចំអាហារ មើលថែរក្សាប្អូនប្រុស-ស្រី ការសំអាត)។
- មើលថែទាំសត្វ។
- ស្វែងរកអាហារ ដោយការប្រមាញ់ ការនេសាទ ឬការប្រមែប្រមូល។
- ការដាំបណ្តុះអាហារ និងធ្វើការនៅទីវាល។

បង្កើតបរិយាកាសរៀនមេត្រីដែលធានាឱ្យការសិក្សាមានអត្ថន័យខ្លឹមសារ

ដើម្បីធ្វើឱ្យការរៀនប្រែកបដោយខ្លឹមសារកើតមាន ថ្នាក់រៀនគួរមាន "បរិយាកាសរៀនមេត្រី"។ ថ្នាក់រៀនដែលមានបរិយាកាសរៀនមេត្រី លើកទឹកចិត្តសិស្សឱ្យសួរសំណួរដោយចំហ រកឱ្យឃើញបញ្ហា ចាប់ផ្តើមការសន្ទនា និងពិភាក្សាពីដំណោះស្រាយនានាជាមួយគ្នា មិត្តភក្តិ និងគ្រួសារ។ កុមារទាំងអស់ – កុមារា និងកុមារី ព្រមទាំងកុមារដែលមានប្រវត្តិ និងសមត្ថភាពខុសៗគ្នា– មានជំនឿជឿជាក់ និងមានអារម្មណ៍សុខស្រួលចូលរួមយ៉ាងពេញលេញ។

នៅក្នុងថ្នាក់រៀនដែលមានបរិយាកាសរៀនមេត្រី អ្នកត្រូវដើរតួនាទីផ្សេងៗគ្នា។ នៅអតីតកាល តួនាទីរបស់យើងគឺជាតួនាទីមួយធ្វើជា "អ្នកផ្តល់ព័ត៌មាន"។ ប៉ុន្តែ ដើម្បីជួយកុមាររបស់យើងរៀនឱ្យបានពេលលេចបំផុត យើងត្រូវពង្រីកតួនាទីរបស់យើងធ្វើជាអ្នកសម្របសម្រួល ជាអ្នកគ្រប់គ្រង ជាអ្នកអង្កេតមើល និងជាអ្នករៀន។ តើតួនាទីថ្មីៗទាំងនេះតម្រូវឱ្យធ្វើអ្វីខ្លះ?។

- **ជាអ្នកសម្របសម្រួល :** យើងត្រូវផ្តល់ឱកាសរៀនសមរម្យសម្រាប់កុមារ និងលើកទឹកចិត្តពួកគេឱ្យបញ្ចេញគំនិតដោយសេរី និងនិយាយអំពីបញ្ហាសំខាន់ៗក្នុងនិយស្ថាបនា។
- **ជាអ្នកគ្រប់គ្រង :** ដើម្បីធ្វើជាអ្នកសម្របសម្រួលដ៏ជោគជ័យម្នាក់ យើងត្រូវរៀបចំដែនការឱ្យបានល្អ និងដឹកនាំការ ពិភាក្សានានា ដោយផ្តល់ឱកាសឱ្យកុមារម្នាក់ៗបញ្ចេញទស្សនៈរបស់ខ្លួន។
- **ជាអ្នកអង្កេតមើល :** ការអង្កេតមើលកុមារនៅពេលកុមារធ្វើការជាក្រុមមួយ ជាគូ ឬម្នាក់ឯង នឹងជួយយើងយល់ពីកុមារ និងរៀបចំសកម្មភាពសិក្សាប្រែកបដោយខ្លឹមសារថែមទៀត។ ឧទាហរណ៍ តើសកម្មភាព មួយដែលកុមារពីរនាក់កំពុងធ្វើការជាគូបានល្អអាចត្រូវបានពង្រីកទៅជាសកម្មភាពក្រុមមួយបានឬទេ? តើកុមារទាំងពីរអាចធ្វើជាអ្នកដឹកនាំក្រុមបានឬទេ?
- **ជាអ្នករៀន :** យើងក្លាយជាអ្នករៀននៅពេលយើងឆ្លុះបញ្ចាំងលើថ្នាក់រៀនរបស់យើង និងលើកម្រិតល្អដែលកុមារបានរៀន។ បន្ទាប់មក យើងអាចអភិវឌ្ឍមធ្យោបាយនានា ដើម្បីធ្វើឱ្យអ្វីដែលកំពុងរៀនកាន់តែមានខ្លឹមសារឡើង។ ឧទាហរណ៍ តើសកម្មភាពមួយមានប្រសិទ្ធភាពក្នុងការជួយកុមារឱ្យយល់ពីប្រធានបទ ឬគំនិតពិបាកឬទេ? តើគេអាច អនុវត្តសកម្មភាពនេះចំពោះប្រធានបទ និងគំនិតដទៃទៀតបានឬទេ?

ការបង្កើតបទពិសោធសិក្សាដើម្បីស្វែងយល់អំពីបញ្ហាយេនឌ័រ

យើងបានរៀននៅក្នុងសេចក្តីផ្តើមនៃឯកសារគោលនេះដែលថា "យេនឌ័រ" សំដៅលើតួនាទីសង្គមដែលបុរស និងស្ត្រីត្រូវបានចាត់តាំងនៅក្នុងវប្បធម៌ដែលបានផ្តល់ ដូចជា "បុរសជាមេគ្រួសារ" ហើយ "ស្ត្រីជាអ្នកថែទាំកូន"។ តួនាទីយេនឌ័រត្រូវបានបង្កើតឡើងដោយសង្គម ហើយត្រូវបានរៀនពីជំនាន់មួយទៅជំនាន់មួយ

ជាផ្នែករបស់វប្បធម៌សង្គម។ តួនាទីយេនឌ័រមិននៅស្ថិតស្ថេរឡើយ ពីព្រោះវាប្រែប្រួលតាមពេលវេលា ស្រដៀងគ្នានឹងការយល់ដឹង និងប្រពៃណីវប្បធម៌ដទៃទៀតផងដែរ។ ជាអកុសល តួនាទីទាំងនេះអាចធ្វើឱ្យគ្រោះថ្នាក់ដល់ការសិក្សារបស់កុមារ ពីព្រោះតួនាទីទាំងនេះជារឿយៗ។ បានរីតបន្តឹងរបៀបសម្តែងអាកប្បកិរិយារបស់កុមារា និងកុមារី និងអ្វីដែលពួកគេត្រូវបានអនុញ្ញាតឱ្យរៀន។ ការសិក្សាករណីខាងក្រោម ជាឧទាហរណ៍បង្ហាញអំពីបញ្ហាដែលបានកើតឡើង។

រឿងរបស់សួន

សួន បានរស់នៅក្នុងភូមិមួយនៅក្បែរប៉ាក់សេ (Pakse) ភាគខាងត្បូងប្រទេសឡាវ។ នាងមានអាយុ ៩ ឆ្នាំ ហើយរៀនថ្នាក់ទី ៣។ នាងចូលចិត្តដើរទៅសាលាជាមួយបងប្អូនប្រុសរបស់នាងពីរនាក់ឈ្មោះ លី និងហ៊ឹង។ នាងជាសិស្សល្អម្នាក់ ហើយនៅសាលា នាងខិតខំរៀនយ៉ាងខ្លាំង ប៉ុន្តែនាងមិនបានយល់ថាសាលារៀនមានលក្ខណៈងាយស្រួលឡើយ។ ភាពពិបាករបស់សួនបង្កឡើងដោយការងារដែលនាងត្រូវធ្វើនៅផ្ទះ មុនពេលនាងមកសាលា។ នាងមានការងារជាច្រើនត្រូវធ្វើ។ បងស្រីរបស់សួនបានជាន់មីននៅពេលលេង ហើយបានដាច់ជើងម្ខាង។ បងស្រីរបស់សួនតែងដាស់សួនដើម្បីជួយមើលលួងលោមនាង ព្រោះនាងមានអារម្មណ៍នៅឈឺចាប់នៅឡើយ។ រាល់ព្រឹក សួនត្រូវក្រោកពីដេកមុនសមាជិកគ្រួសារដទៃទៀតដើម្បីប្រមូលអុស និងដុតភ្លើង។ នាងត្រូវបុកស្រូវដើម្បីដាំបាយ។ ក្រោយមកទៀត នាងត្រូវលុបលាង និងរៀបចំបាយមួបឱ្យគ្រួសារ។ នៅពេលសួនមកដល់សាលា នាងហត់ទ្បើយយ៉ាងខ្លាំង។ បងប្អូនប្រុសរបស់នាងមិនដែលត្រូវប្រើឱ្យជួយការងារនៅផ្ទះឡើយ។ ពួកគេតឹ្រមតែទៅរកត្រីជាមួយឱពុកខ្លួននៅចុងសប្តាហ៍ប៉ុណ្ណោះ ដូច្នេះពួកគេមានពេលធ្វើកិច្ចការសាលា។

នៅពេលសួនទៅសាលារៀន នាងព្យាយាមយកចិត្តទុកដាក់យ៉ាងខ្លាំង។ ទោះជាយ៉ាងណាក្តី នាងយល់ថាមានការលំបាកក្នុងការយកចិត្តទុកដាក់គ្រប់ពេល ពីព្រោះនាងអស់កម្លាំងយ៉ាងខ្លាំង ហើយប្រធានបទដែលនាងសិក្សាមានលក្ខណៈខុសគ្នាយ៉ាងខ្លាំងពីជីវភាពរស់នៅប្រចាំថ្ងៃ របស់នាង។ គ្រូបង្រៀនតែងខឹងនាងជាពិសេស ថ្ងៃមួយនៅពេលនាងបានដេកលក់ក្នុងពេលកំពុងរៀន។

ក្រោយពីត្រូវទទួលការស្តីបន្ទោសពីគ្រូ សួនបានសម្រេចចិត្តអវត្តមានមិនទៅសាលា។ នាងបានគិតថា នាងនឹងអាចជួយឱពុកម្តាយ ប្រសិនបើនាងនៅផ្ទះរាល់ថ្ងៃ ដើម្បីវែកទឹក និងរកអុស មើលថែរក្សាបងស្រី និងរៀនពីការចិញ្ចឹមសត្វ។ ដូច្នេះ សួនបានចាប់ផ្តើមអវត្តមាន មិនទៅសាលាកាន់តែញឹកញាប់ ហើយទីបំផុត នាងសម្រេចចិត្តឈប់ទៅសាលា។ នាងនៅផ្ទះរាល់ថ្ងៃ ហើយជួយម្តាយរបស់នាង។ នាងមិនបានរៀនចប់ថ្នាក់ទី ៣ ឡើយ។ បងប្អូនប្រុសរបស់នាង លី និងហ៊ឹង បានរៀនចប់សាលាបឋមសិក្សាទាំងពីរនាក់។ ពួកគេអាចអាន និង សរសេរបាន ហើយត្រៀមខ្លួនរៀនបន្តនៅអនុវិទ្យាល័យ។

សួន ជាឧទាហរណ៍មួយបង្ហាញពីរបៀបដែលតួនាទី និងការកិច្ចយេនឌ័រអាចនាំទៅរកភាពចន្លោះប្រហោង និងការចោះបង់សាលារបស់កុមារី។ យេនឌ័រ អាចប៉ះពាល់ដល់ការរៀនរបស់កុមារាផងដែរ នៅពេលពួកគេមានអារម្មណ៍ថា សាលារៀនគ្មានន័យ ហើយការសំខាន់សម្រាប់ពួកគេគឺត្រូវធ្វើការ និងផ្គត់ផ្គង់គ្រួសាររបស់ខ្លួន។ ជាងនេះទៀត កុមារី និងកុមារាបានសម្របខ្លួនក្នុងសង្គមទៅក្នុងរបៀបមួយស្តីពីការគិតអំពីខ្លួនពួកគេ និងអ្វីដែលពួកគេអាចធ្វើបាន។ ឧទាហរណ៍ អ្នកអាចឮ "កុមារាមិនចេះយំ" ឬ "កុមារីមិនគួរលេងល្បែងមិនល្អឡើយ"។ ក្នុងរបៀបដដែលនេះដែរ កុមារីខ្លះអាចមិនមានអារម្មណ៍ជឿជាក់ខ្លួនឯងផ្នែកគណិតវិទ្យា ឬវិទ្យាសាស្ត្រ ពីព្រោះពួកគេត្រូវបាន ច្រាប់ថា មុខវិជ្ជាទាំងនេះ គឺជា "មុខវិជ្ជារបស់កុមារា"។ ទោះជាយ៉ាងណាក្តី កុមារទាំងអស់អាចសម្រេចជលបានល្អនៅពេលពួកគេត្រូវបាន ផ្តល់ឱ្យនូវឱកាសត្រឹមត្រូវ។

ប្រសិនបើយើងត្រូវរាប់បញ្ចូលកុមារទាំងអស់នៅក្នុងថ្នាក់រៀនដែលមានបរិយាកាសរៀនមេត្រីដោយបញ្ចូលគ្រប់សមាសភាព យើងត្រូវការសួរខ្លួនរបស់យើង : "តើកុមារទាំងអស់របស់ខ្ញុំមានពេលនិងថាមពលដើម្បីបំពេញភារកិច្ចដែលខ្ញុំបានចាត់តាំងឱ្យឬទេ?"។ មធ្យោបាយមួយដើម្បីជួយឆ្លើយសំណួរនេះគឺត្រូវធ្វើគម្រោងការងារតូចមួយរបស់ថ្នាក់រៀនស្តីពីទំហំការងារដែលកុមារី និងកុមារាបានធ្វើនៅផ្ទះ។ ចូរស្នើឱ្យកុមាររបស់អ្នកជជែក ឬសរសេររឿងខ្លីមួយស្តីពី "អ្វីដែលខ្ញុំធ្វើនៅផ្ទះ"។ អ្នកអាចមានការភ្ញាក់ផ្អើលចំពោះទំហំការងារ ដែលសិស្សរបស់អ្នកធ្វើ ជាពិសេសកុមារីត្រូវធ្វើការបម្រើគ្រួសារ។ បន្ទាប់មក អ្នកអាចសម្រួលដែនការសិក្សារបស់អ្នក ដើម្បីឱ្យស៊ីគ្នាជាមួយតម្រូវការរបស់កុមារ។



សកម្មភាពអនុវត្ត : ការលើកកម្ពស់ការយល់ដឹងអំពីយេនឌ័រ

ខាងក្រោមនេះជាសកម្មភាពពីរដែលអ្នកអាចអនុវត្តបាន ដើម្បីលើកកម្ពស់ការយល់ដឹងពីយេនឌ័រក្នុងចំណោមសិស្សរបស់អ្នក :

១. ចូរពិភាក្សាជាមួយកុមារជាក្រុម។ (កុមារីនៅរួមគ្នា កុមារានៅរួមគ្នា ព្រមទាំងក្រុមដែលលាយចម្រុះគ្នា) ស្តីពីអ្វីដែលពួកគេគិត ថានឹងកើតមានចំពោះពួកគេ ដោយសារការធ្វើជាមនុស្សប្រុសឬស្រី។ តើកុមារា និងកុមារីគិតដូចម្តេចអំពីតួនាទី ឬការរំពឹងគិតរបស់គ្នាទៅវិញទៅមក? តើពួកគេបានឃើញ បំលាស់ប្តូរនានាឬទេ?

២. ចូរស្នើឱ្យកុមារា និងកុមារីរកឱ្យឃើញនូវចរិតលក្ខណៈរបស់កុមារា និងកុមារី។ ចូរបង្កើតជាពីរជួរ។ ក្នុងជួរទីមួយ ចូរស្រង់ជាបញ្ជី នូវអ្វីដែលគេដឹងថា ជាចរិតលក្ខណៈមនុស្សស្រី។ ក្នុងជួរទីពីរ ចូរស្រង់ជាតារាងមួយកត់បញ្ចូលនូវអ្វីដែលគេដឹងថា ជាចរិតលក្ខណៈមនុស្សប្រុស។ នៅពេលចប់សព្វគ្រប់ហើយ ចូរប្តូរពាក្យ "មនុស្សស្រី" ដាក់ចូលក្នុងជួរដែលនិយាយពីចរិតលក្ខណៈមនុស្សប្រុស ហើយប្តូរពាក្យ "មនុស្សប្រុស" ដាក់ទៅក្នុងជួរដែលជាចរិតលក្ខណៈមនុស្សស្រី។ សុំឱ្យ

កុមារគិតមើលថា តើតួនាទីទាំងនេះអាចអនុវត្តបានឬទេ ចំពោះភេទផ្សេងគ្នា? អាចអនុវត្តបានទាំងអស់ ឬមួយចំនួន? ហេតុអ្វី? យើងសង្ឃឹមថា កុមារនឹងសន្និដ្ឋានថា តួនាទីយេនឌ័រទាំងអស់អាចផ្លាស់ប្តូរ និងកែប្រែបានលើកលែងតែតួនាទីជីវសាស្ត្រប៉ុណ្ណោះ។



សកម្មភាពឆ្លុះបញ្ចាំង :ការយល់ដឹងពីយេនឌ័រនៅក្នុងការបង្រៀន

ចូរពិចារណាសេចក្តីថ្លែងមួយចំនួនដូចខាងក្រោមនេះ។ ចូរបំពេញតារាង ហើយរិះរកសកម្មភាពចាំបាច់នានា ដើម្បីកែលំអស្ថានភាពនៅក្នុងថ្នាក់រៀនរបស់អ្នក។

គំនិត	ញឹកញាប់	ម្តងម្កាល	មិនដែល	តាមការចាំបាច់
ខ្ញុំពិនិត្យមើលសម្ភារសិក្សារបស់ខ្ញុំថា តើមានគំរូស្តីពីតួនាទីវិជ្ជមាន សម្រាប់កុមារា និង កុមារីឬទេ។				
ខ្ញុំលើកទឹកចិត្តកុមារីឱ្យសម្រេចបានជោគជ័យក្នុងមុខវិជ្ជា គណិតវិទ្យា និងវិទ្យាសាស្ត្រ។				
ខ្ញុំប្រើវិធីសាស្ត្ររៀនដោយសហការ មិនមានតម្រូវការវិនិយ័ តឹងតែងឡើយ។				
កុមារីអាយុច្រើនដែលទទួលពិន្ទុបានល្អ នឹងជួយកុមារីអាយុក្មេងជាងដែក គណិតវិទ្យា និងវិទ្យាសាស្ត្រ។				
កុមារទាំងអស់ក្នុងថ្នាក់របស់ខ្ញុំ ត្រូវបានផ្តល់ឱកាសឱ្យសម្តែងចេញដោយខ្លួនឯង និងសម្រេចជោគជ័យមុខវិជ្ជាសំខាន់ៗ។				

ដើម្បីជួយកុមារីឱ្យមានអារម្មណ៍កាន់តែសុខស្រួលនៅសាលា និងដើម្បីជានាឱ្យមានឱកាសស្មើភាពគ្នា ចូរធ្វើការជាមួយសហការី និងអ្នករដ្ឋបាលសាលា ដើម្បីអនុវត្តការងារខាងក្រោម :

- គាំទ្រចំពោះការកែលំអឡើងវិញនូវសម្ភារសិក្សា និងការបំបាត់ចោលភាពលំអៀងយេនឌ័រ និងភាពលំអៀងដទៃទៀត (ចូរអានគោល៤.២) ដូចជា ការខ្វះខាតនៃការរួមបញ្ចូលកុមារពិការ ឬកុមារជនជាតិភាគតិចនៅក្នុងអត្ថបទសិក្សា ឬការបង្ហាញលក្ខណៈគំរូទៅនៃកុមារក្រីក្រ កុមារតាមចិញ្ចើមថ្នល់ និងកុមារកំពុងធ្វើការងារ។ នេះគឺជាការកិច្ចសម្រាប់សាលាទាំងមូលត្រូវធ្វើ ប៉ុន្តែគ្រូម្នាក់ៗត្រូវការដឹងវិធីដើម្បីធ្វើសកម្មភាពផងដែរ។ គ្រាន់តែប្រើការ និងក្រដាសមួយសន្លឹកបិទលើសៀវភៅណាមួយអាចបង្ហុលបង្ហាញថា សៀវភៅនោះមានលក្ខណៈលំអៀងក្នុងរបៀបណាមួយ ហើយវាអាចនាំទៅរកការពិភាក្សាក្នុងថ្នាក់រៀនដែលមានលក្ខណៈស្ថាបនាស្តីពីការដាក់បញ្ចូលគ្រប់សមាសភាព (ចូរមើលកម្រងសៀវភៅលេខ ១)។
- ណែនាំបង្ហាញកម្មវិធីសិក្សា និងសម្ភារស្វ័យសិក្សាដែលមានលក្ខណៈទន់ភ្លន់បត់បែនជាងមុន ដោយហេតុថា កុមារីមួយចំនួនមានតម្រូវការពេលវេលាជាច្រើន ដូចជា ការងារផ្ទះ និងការមើលថែទាំបងប្អូន។ ទាំងកុមារា និងកុមារីមកពីគ្រួសារក្រីក្រតែងតែមានពេលតិចតួចណាស់ដើម្បីធ្វើការងារសាលា ព្រោះគ្រួសារត្រូវការជំនួយពីសមាជិកគ្រប់គ្នាដើម្បីរស់រាន។ ចូរព្យាយាមបំពេញសកម្មភាពសិក្សាក្នុងពេលនៅសាលា ហើយផ្តល់ជម្រើសមួយថា នឹងត្រូវផ្តល់ការងារសាលា សម្រាប់ធ្វើនៅផ្ទះពេលណា។
- ជាធម្មតា គ្រូបង្រៀននិយាយទៅកាន់កុមារាច្រើនជាងកុមារីក្នុងថ្នាក់ដំបូងៗជាច្រើន។ ចូរចងចាំថា ត្រូវផ្តល់ពេលវេលា ("ពេលរង់ចាំ") សម្រាប់កុមារឆ្លើយសំណួររបស់អ្នក។ ប្រសិនបើអ្នកមិនមានសហការីណាម្នាក់ ដើម្បីអង្កេតមើលអ្នកក្នុងថ្នាក់រៀនទេនោះ អ្នកអាចសាកល្បងសកម្មភាពចូលរួមមួយជាមួយកុមារ ដើម្បីវាយតម្លៃថា តើអ្នកអាចមានសកម្មភាព ទៅលើកុមារា និងកុមារីផ្សេងគ្នាឬទេ។ ឧទាហរណ៍ ចូរស្នើកុមារម្នាក់ៗប្រមូលថ្មចំនួន ៥ ដុំ (អ្នកអាចមានវត្ថុប្រមូលរួចស្រេចហើយសម្រាប់ប្រើនៅក្នុងមុខវិជ្ជាគណិតវិទ្យា)។ ចូរស្នើកុមារម្នាក់ៗដាក់ថ្មមួយដុំនៅផ្នែកម្ខាងនៃតុរបស់ខ្លួនរាល់ពេល ដែលអ្នកនិយាយទៅកាន់ពួកគេម្នាក់ៗ។ ចូរសួរសំណួរណាមួយដល់ពួកគេ ឬឱ្យពួកគេឆ្លើយ។ អ្នកអាចវាយតម្លៃរួមគ្នាអំពីគំរូនៃការទំនាក់ទំនង ហើយពិភាក្សាពីមូលហេតុដែលអាចនាំឱ្យកើតមាននូវទំនាក់ទំនងនេះ។ តើយុទ្ធសាស្ត្រដទៃៗទៀតអ្វីខ្លះដែលអ្នកអាចប្រើ ដើម្បីធ្វើសកម្មភាពលើកុមារឱ្យបានកាន់តែស្មើគ្នា? តើជំនាញអ្វីខ្លះដែលកុមារនីមួយត្រូវការរៀន ដើម្បីឱ្យពួកគេអាចចូលរួមបានស្មើគ្នា?

សមាសភាពទាំងអស់នេះនឹងពង្រឹងសមត្ថភាពរបស់អ្នក ដើម្បីបង្កើតបរិយាកាសរៀនមេត្រីមួយ សម្រាប់កុមារា និងកុមារី។ យើងអាចប្រើរបៀបដាក់ជាក្រុម ។ដែលមានភេទដូចគ្នាសម្រាប់សកម្មភាព អនុវត្តមួយចំនួន ដើម្បីឱ្យកុមារីអាចអភិវឌ្ឍទូវជំនឿជឿជាក់របស់ខ្លួន និងមិនឱ្យទទួលឥទ្ធិពលគ្រប់សង្កត់ ពីកុមារា។ បន្ទាប់មក រៀបជាក្រុមដែលមានភេទចម្រុះ ដើម្បីឱ្យកុមារី និងកុមារារៀនសហការរួមគ្នា។

សកម្មភាពជាច្រើនខាងលើនឹងត្រូវការការគាំទ្រពីមាតាបិតា ឬអាណាព្យាបាលដទៃទៀត។ សម្រាប់ មូលហេតុនេះ បញ្ហាទាំងនេះ គួរពិភាក្សានៅឯជំនួបប្រជុំគណៈកម្មការសាលា ហើយគួរអភិវឌ្ឍដែនការ សកម្មភាពមួយ។ វានឹងជួយគ្រូបង្រៀនទាំងអស់ ប្រសិនបើគោលនយោបាយសាលាស្តីពីបញ្ហានានាដូចជា វិន័យ និងភាពលំអៀងយេនឌ័រត្រូវបានពិភាក្សា និងបានទទួលការឯកភាពពីគ្រូបង្រៀន និងពីមាតាបិតា។

ការសិក្សាដែលសកម្ម និងមានការចូលរួម

កុមាររៀនគ្រប់ពេលទាំងនៅខាងក្នុង និងខាងក្រៅថ្នាក់រៀន។ ពួកគេគួរមានភាពសកម្មនៅក្នុង ការសិក្សារបស់ពួកគេ ដើម្បីអនុវត្តអ្វីដែលពួកគេបានរៀន និងទទួលបានសមត្ថភាព។ កុមារគួរត្រូវ លើកទឹកចិត្តជាដែរ ដើម្បីធ្វើការជាមួយកុមារដទៃ។ទៀត និងកុមារដែលមានប្រវត្តិ និងសមត្ថភាពខុសគេ។ កិច្ចសហប្រតិបត្តិការលើកទឹកចិត្តឱ្យមានការយល់ និងការព្រមទទួលយក។ ការងារជាក្រុម និងជាគូធ្វើឱ្យ មានការចូលរួម និងការទាក់ទងកាន់តែប្រសើរឡើងក្នុងចំណោមកុមារ និងជួយបង្កើតភាពឯករាជ្យ ព្រមទាំង សមត្ថភាព ដើម្បីធ្វើការជាមួយអ្នកដទៃក្នុងន័យស្ថាបនា។ ឧទាហរណ៍មួយចំនួនស្តីពីឱកាសសិក្សាដ៏ល្អ រួមមាន ការចុះធ្វើកម្មសិក្សា និងល្បែងនានាសម្រាប់សិក្សា។



សកម្មភាពអនុវត្ត : ការចុះកម្មសិក្សា

ក្នុងការចុះធ្វើកម្មសិក្សា កុមារចេញក្រៅថ្នាក់រៀន ឧទាហរណ៍ ទៅសួនច្បារសាលា ទៅអណ្តូងទឹក ឬទំនប់សហគមន៍ ឬទៅមជ្ឈមណ្ឌលសហគមន៍មួយ។ ពួកគេអាចអង្កេតមើលអង្គការលេខជាក់លាក់ ឬបាតុភូតធម្មជាតិ ព្រមទាំងរៀនពីអ្នកជំនាញនានា (រៀនបន្ថែមទៀតក្នុងកម្រងសៀវភៅលេខ១៦ ស្តីពី របៀបណាមួយដែលការចុះកម្មសិក្សាបែបនេះអាចជំរុញសុខភាព និងអនាម័យកាន់តែប្រសើរ)។

ការចុះកម្មសិក្សាដើម្បីគាំទ្រការងារជាក្រុម

ឧទាហរណ៍ ក្នុងការចុះកម្មសិក្សានៅទំនប់សហគមន៍មួយ ក្រុមនីមួយ ។នៃសិស្សថ្នាក់ទី ៥ អាចត្រូវបាន ផ្តល់ការងារមួយចំនួន។ មុនពេលទៅទំនប់នេះ សមាជិកនានារបស់ក្រុមអាចរៀនអំពីសារៈសំខាន់របស់

ទឹកចំពោះជីវិតមនុស្ស និងកសិកម្ម។ នៅកន្លែងទំនប់ ក្រុមនីមួយៗ អាចត្រូវបានស្នើឱ្យ : ប៉ាន់ប្រមាណពីទំហំនៃទំនប់ គូរដែនទីតំបន់នេះភ្លាមៗដែលទទួលឥទ្ធិពលពីទំនប់នេះ គូរដើមឈើផ្សេងៗជុំវិញទំនប់ ឬរៀបចំសំណួរនានាក្នុងខណៈដែលពួកគេស្តាប់ព័ត៌មានដែលវិស្វករដ្ឋាភិបាលម្នាក់ផ្តល់ដល់ថ្នាក់ទាំងមូល។

នៅពេលសិស្សរៀលត្រលប់ពីទំនប់នេះ ក្រុមនីមួយៗអាចប្រើព័ត៌មានដែលពួកគេបានប្រមូលដើម្បីរៀបចំការបង្ហាញផ្សេងៗ ឬ រចាយការណ៍ស្តីពីការអង្កេតមើលរបស់ខ្លួន។ ពួកគេអាចពិភាក្សាជាមួយគ្រួសាររបស់ពួកគេផងដែរអំពីសារៈសំខាន់នៃទំនប់ទឹកនេះ។

ក្នុងការចុះកម្មសិក្សានៅសួនច្បារសាលា ក្រុមនីមួយៗអាចត្រូវបានស្នើឱ្យអនុវត្តការងារមួយ ដោយការងារនីមួយៗបំពេញ បន្ថែមការងារដទៃទៀត ឧទាហរណ៍ : ស្រង់ជាបញ្ជីនូវប្រភេទផ្សេងៗនៃសត្វល្អិត និងវាយតម្លៃចំនួនសត្វល្អិត ស្រង់ជាបញ្ជីនូវប្រភេទ និងចំនួនរុក្ខជាតិ រកសញ្ញាស្តីពីជនិកសត្វ ដូចជារន្ធសត្វនានា រូងសត្វ ឬ ឫសឈើដែលត្រូវបានសត្វកកេរ ឬ គូរដែនទី និងវាស់វែងសួនច្បារ។ នៅក្នុងថ្នាក់រៀន ក្រុមនីមួយៗអាចសរសេរបន្ថែមរបាយការណ៍របស់ខ្លួនសម្រាប់ "មជ្ឈមណ្ឌលរបាយការណ៍ស្តីពីសួនច្បារ" របស់ថ្នាក់រៀនមួយ ឬបង្កើតនូវការតាំងបង្ហាញពីសួនច្បាររបស់ថ្នាក់រៀនមួយ។ ដោយផ្អែកលើលក្ខណៈនៃការចុះកម្មសិក្សា អ្នកអាចធ្វើសកម្មភាពផ្សេងៗ មុនពេលចុះកម្មសិក្សា ដើម្បីឱ្យកុមារអាចរៀនបានកាន់តែល្អ នៅពេលពួកគេស្ថិតនៅកន្លែងចុះកម្មសិក្សា។ សកម្មភាពដែលអ្នកអាចធ្វើ ជាមួនរួមមាន :


- ធ្វើការស្រាវជ្រាវត្រៀម ការពិភាក្សាថ្នាក់ទាំងមូល ឬការសាកសួរអំពីអ្វីដែលកុមារអាចឃើញក្នុងពេលចុះកម្មសិក្សា។
- ទទួលជំនួយពីអ្នកជួយផ្សេងៗ ឬសមាជិកគ្រួសារ ដើម្បីរៀបចំការចុះកម្មសិក្សា និងចូលរួមក្នុងកម្មសិក្សា។
- ស្វែងរកឱកាសស្តាប់ និងសួរសម្ភាសជាមួយអ្នកជំនាញ។
- ចាត់តាំងសកម្មភាពជាក់លាក់នានាសម្រាប់ក្រុមផ្សេងៗ ការងារជាគូ ឬសិស្សម្នាក់ៗ ដែលនឹងជួយពួកគេយល់នូវអ្វី ដែលពួកគេនឹងឃើញក្នុងពេលចុះកម្មសិក្សា។

ការចុះកម្មសិក្សាអាចផ្តល់នូវការសិក្សាដែលមានខ្លឹមសារ។ វាក៏ជាគំរូមួយនៃការសិក្សាដែលត្រូវបានធ្វើសមាហរណកម្ម ឧទាហរណ៍ នៅពេលការស្រាវជ្រាវស្តីពីទំនប់ ឬសួនច្បារទាក់ទងនឹងមុខវិជ្ជាគណិតវិទ្យា វិទ្យាសាស្ត្រ និងការសិក្សាសង្គម។

វង្វង់នៃការសិក្សា

នេះជាសកម្មភាពមួយដ៏ល្អដែលត្រូវធ្វើដោយខ្លួនអ្នកផ្ទាល់ ដើម្បីរៀបចំកិច្ចតែងការបង្រៀនរបស់អ្នក។ វាក៏ជាសកម្មភាពមួយដែលអ្នកអាច ធ្វើជាមួយសិស្សរបស់អ្នកបានដែរ។

ចូរកត់ឃើញនូវឱកាសផ្សេងៗគ្នាទាំងអស់សម្រាប់ការចុះធ្វើកម្មសិក្សានៅកន្លែងដែលជិតថ្នាក់រៀនរបស់អ្នក។ នៅចំកណ្តាល ក្រដាសមួយសន្លឹក ចូរគូរវង្វង់មូល ឬវង្វង់រាងពងក្រពើតូចមួយដើម្បីតំណាងឱ្យថ្នាក់រៀនរបស់អ្នក។ នៅជុំវិញវង្វង់នេះ ចូរគូរវង្វង់មួយទៀត តំណាងសាលារបស់អ្នក។ នៅជុំវិញវង្វង់តំណាងសាលា ចូរគូសវង្វង់មួយធំជាងនេះ ដើម្បីតំណាងសហគមន៍ ក្រុង ឬ ស្រុករបស់អ្នក។ ចូរចាប់ផ្តើម



ជាមួយវង្វង់សាលា។ តើសាលាចិញ្ចឹមសត្វពាហនៈ ឬប្រភេទសត្វដទៃៗទៀតឬទេ? តើមានសួនច្បារឬទេ? តើមានដើមឈើ ឬទីវាលឬទេ? តើមានសំបុកសត្វបក្សី ឬដំបូកកណ្តៀរឬទេ? នៅក្នុងវង្វង់សាលា ចូរស្រង់ជាបញ្ជីនូវឈ្មោះនៃឱកាសសិក្សានានានៅខាងក្រៅថ្នាក់រៀន។ តើអ្នកអាចបង្កើតបរិយាកាសរៀនថ្មីមួយសម្រាប់កុមារ ឧទាហរណ៍ សួនច្បារសាលា ឬទេ?

បន្ទាប់មក ចូរបន្តទៅវង្វង់សម្រាប់សហគមន៍ ក្រុង ឬស្រុករបស់អ្នក។ ចូរពិចារណាអំពីហាង និងក្រុមហ៊ុនជំនួញនានាដែលគួរឱ្យចាប់អារម្មណ៍សម្រាប់កុមារក្នុងការសិក្សា។ តើមានអ្នកចម្ការណាម្នាក់ដែលមានពូជដំណាំពិសេស ដូចជា ដើមក្រូច ឬសត្វពាហនៈពិសេសៗ ឬទេ? តើមានសារមន្ទីរ ព្រៃឈើ សួនឧទ្យាន ឬទីវាលឬទេ? ចូរសរសេរឈ្មោះឱកាសសិក្សាទាំងនេះនៅក្នុងវង្វង់នេះ?

ចូរប្រើទីតាំងក្នុងបរិវេណសាលារបស់អ្នក ដើម្បីជួយសិស្សរបស់អ្នករៀនអំពីអាកប្បកិរិយាដ៏សមរម្យនៅក្រៅថ្នាក់រៀន និងដើម្បីរៀនពីវិធីធ្វើការរួមគ្នាជាក្រុម។។

ចូរចងចាំអំពីកុមារទាំងឡាយដែលមានបញ្ហាពិបាកក្នុងការដើរ ឬភាពពិការដទៃទៀត។ តើពួកគេនឹងអាចទទួលបានឱកាសរៀន ទាំងនេះដូចម្តេច? អ្នកអាចត្រូវការធ្វើការពិនិត្យពីបញ្ហាផ្លូវជាមុនសិន។ អ្នកក៏អាចត្រូវការជំនួយពីមាតាបិតា ឬសិស្សដទៃទៀតដែរ។



សកម្មភាពអនុវត្ត : ល្បែងសិក្សា

កុមារចូលចិត្តលេងល្បែង ហើយដោយត្រូវបានផ្តល់ឱកាសត្រឹមត្រូវ ពួកគេនឹងបង្កើតវិធានានា សម្រាប់ល្បែងថ្មី។ ក្នុងល្បែងទាំងនេះ ពួកគេអាចប្រើបាល់ គម្របដប ដុំថ្ម ខ្សែ ស្លឹកឈើ ឬសម្ភារផ្សេង។ ល្បែងដែលទាក់ទងការសម្តែងជាតួ ការដោះស្រាយបញ្ហា ឬការប្រើជំនាញ និងព័ត៌មានជាក់លាក់ គឺជាមធ្យោបាយដ៏ល្អ ដើម្បីឱ្យកុមារចាប់អារម្មណ៍នូវអ្វីដែលពួកគេកំពុងរៀន។

ល្បែងអាចបញ្ចូលការសិក្សាដ៏សកម្មដែលអាចកែលំអជំនាញប្រាស្រ័យទាក់ទងរបស់កុមារ ព្រមទាំងជំនាញរបស់ពួកគេក្នុងការវិភាគ និងធ្វើការសម្រេចចិត្ត។ ឧទាហរណ៍ស្តីពីល្បែងបែបនេះរួមមាន : ល្បែងឡូតូ ល្បែងដូមីណូ និងល្បែង ៥ សំណួរ (ជាល្បែងដែលកុមារព្យាយាមទាយវត្ថុមួយជាអ្វី ដោយការសួរតែ ៥ សំណួរប៉ុណ្ណោះ)។ អ្នក និងសិស្សរបស់អ្នកអាចរចនាសម្ភារ ផ្សេងៗសម្រាប់ល្បែងជាច្រើន ហើយអ្នកអាចសម្របសម្រួលល្បែងតែមួយសម្រាប់គោលបំណងផ្សេងៗគ្នា និងកម្រិតថ្នាក់ផ្សេងៗគ្នា។

ល្បែងទាំងនេះ និងសម្ភាររបស់វាអាចផ្លាស់ប្តូរបាន ដើម្បីធ្វើឱ្យកាន់តែមានទំនាក់ទំនងថែមទៀតជាមួយកម្មវិធីសិក្សា។ ឧទាហរណ៍ អ្នកអាចបង្កើតបៀដូមីណូដែលមានរូបរាងធរណីមាត្រ ដែលគេអាចផ្គូរផ្គងជាមួយគ្នាទៅវិញទៅមក។ ឧទាហរណ៍ រាងការ៉េលើ ដូមីណូមួយអាចត្រូវបានផ្គូរផ្គងជាមួយដូមីណូមួយដែលមាន ឈ្មោះរូបរាងជាពាក្យ (ការ៉េ)។

ល្បែងសិក្សា : តើអ្នក និងសិស្សរបស់អ្នកអាចបង្កើតសកម្មភាពសិក្សានានា ដោយផ្អែកលើល្បែងធម្មតាៗបានឬទេ?.ខាងក្រោមនេះ ជាវិធីសម្រាប់បង្កើតសកម្មភាពសិក្សាទាំងនេះ!

- ចូរអង្កេតមើល ឬពិភាក្សាជាមួយសិស្សរបស់អ្នកថា តើល្បែងអ្វីកុមារអាចលេងនៅក្រៅថ្នាក់បាន។ តើវិធាន អ្វីដែលពួកគេប្រើដើម្បីរក្សាពិន្ទុ? តើពួកគេច្រៀងចម្រៀង ឬប្រើពាក្យចុងចួន? តើមានល្បែងផ្សេងគ្នា សម្រាប់ កុមារី និងកុមារាឬ? ហេតុអ្វី?
- ស្នើកុមារអភិវឌ្ឍសៀវភៅល្បែងមួយក្បាលសម្រាប់ឱ្យកុមារផ្សេងទៀតអាចរៀនបាន។ តើកុមារអាចស្រាវជ្រាវល្បែងនានាដែលសមាជិកគ្រួសារចាស់ៗរបស់ខ្លួនអាចបានលេងកាលពួកគេនៅសាលា ឬអ្វីៗដែលជាផ្នែកមួយ នៃវប្បធម៌ក្នុងស្រុក ឬវប្បធម៌នានាឬទេ?។
- ចូរភ្ជាប់ល្បែង ឬសកម្មភាពណាមួយជាមួយមេរៀនមួយដែលអ្នកបង្រៀន។ ឧទាហរណ៍ រៀនគណិតវិទ្យាមួយ។

ទាំងការចុះកម្មសិក្សា និងល្បែងអាចជំរុញកុមារទាំងអស់ឱ្យចំរើន។ ខាងក្រោមនេះជាមធ្យោបាយខ្លះទៀត ដើម្បីបង្កើនការជំរុញទឹកចិត្ត :

- ប្រើឧទាហរណ៍ជាក់ស្តែងពីតំបន់ក្នុងស្រុកដែលមានខ្លឹមសារចំពោះកុមារា និងកុមារី ព្រមទាំងកុមារដែលមានប្រវត្តិ និង សមត្ថភាពខុសគេ។
- ផ្តល់ឱកាសសម្រាប់កុមារទាំងនេះប្រើអ្វីដែលពួកគេបានរៀននៅក្នុងសកម្មភាពប្រចាំថ្ងៃពួកគេ ដូចជា ការនេសាទ ការដាំស្រូវ ឬការយួរទឹក។
- ប្រើវិធីសាស្ត្របង្រៀនផ្សេងៗដែលគួរឱ្យចាប់អារម្មណ៍ ហើយជំរុញកុមារឱ្យចូលរួមយ៉ាងសកម្មក្នុងការរៀនសូត្រ។

បង្រៀនគណិតវិទ្យា វិទ្យាសាស្ត្រ និងភាសា ឱ្យមានអត្ថន័យខ្លឹមសារសម្រាប់ទាំងអស់គ្នា

គណិតវិទ្យា វិទ្យាសាស្ត្រ និងភាសា (ការអាន និងសរសេរ) គឺជាមុខវិជ្ជាសំខាន់នៅក្នុងសាលាភាគច្រើនរបស់យើង។ មុខវិជ្ជាទាំងនេះជាមុខវិជ្ជាដែលមានការប្រកួតប្រជែងបំផុត។ នៅក្នុងមុខវិជ្ជាទាំងនេះ កុមាររៀនពីគំនិតអរូបីដែលអាចធ្វើឱ្យពួកគេពិបាកយល់ ប្រសិនបើកុមាររបស់អ្នកមិនអាចភ្ជាប់គំនិតអរូបីទាំងនេះជាមួយអ្វីដែលពួកគេធ្វើនៅក្នុងជីវភាពប្រចាំថ្ងៃ។ នៅពេលកុមារភ្ជាប់ទំនាក់ទំនងនេះ ហើយអាចយល់គំនិតអរូបីមួយ ពួកគេអាចចាប់ផ្តើមអនុវត្តគំនិតនោះតាមរយៈជំនាញសំខាន់មួយ ឬច្រើន។ ផ្នែកផ្សេងៗខាងក្រោមនេះ នឹងផ្តល់ដល់អ្នកនូវគំនិតខ្លះស្តីពីវិធីដែលអ្នកអាចធ្វើឱ្យមុខវិជ្ជាទាំងនេះកាន់តែមានលក្ខណៈរៀនមេត្រីសម្រាប់សិស្សទាំងអស់របស់អ្នក និង កាន់តែមានលក្ខណៈសប្បាយក្នុងការបង្រៀនរបស់អ្នក។

គណិតវិទ្យាដែលមានបរិយាកាសរៀនមេត្រី

យើងប្រើគណិតវិទ្យានៅពេលយើងទាយថា តើយើងនឹងត្រូវចំណាយពេលប៉ុន្មានដើម្បីដើរទៅផ្ទះ។ យើងប្រើគណិតវិទ្យា ដើម្បីវាយតម្លៃថា តើនឹងត្រូវការទឹកប៉ុន្មាន ដើម្បីបំពេញក្នុងធុងមួយ ហើយតើដំឡូងបារាំងទម្ងន់ ៣ ដោននឹងមានតម្លៃប៉ុន្មាននៅទីផ្សារ។ យើងប្រើគណិតវិទ្យានៅពេលយើងកំពុងលក់ត្រីតាមដងផ្លូវ។ យើងប្រើគណិតវិទ្យានៅពេលយើងរាំ (ចំនួនជំហាន) នៅពេលយើងលេងភ្លេង និងនៅពេលយើងច្រៀង (ប្រើចង្វាក់ និងពេល)។

ទោះជាយ៉ាងណាក្តី ជារឿយៗ នៅសាលា មុខវិជ្ជាគណិតវិទ្យាហាក់ដូចជាមិនទាក់ទងជាមួយសកម្មភាពនានាដែលយើងធ្វើរាល់ថ្ងៃឡើយ។ ប្រសិនបើយើងព្យាយាម យើងអាចជួយកុមារធ្វើទំនាក់ទំនងរវាងជំនាញគណិតវិទ្យា គំនិតគណិតវិទ្យា និងការគិត និងគណិតវិទ្យាសម្រាប់ជីវភាពប្រចាំថ្ងៃ ដូចជាគណិតវិទ្យាដែលប្រើនៅទីផ្សារ។ ឧទាហរណ៍ ការសម្តែងតួ ដោយកុមារធ្វើជាទៅផ្សារអាចជាការ កំសាន្ត និងមានខ្លឹមសារសម្រាប់កុមារក្នុងការរៀនគណិតវិទ្យា។ វាក៏ជាឱកាសដ៏ដែរសម្រាប់ឱ្យកុមារអភិវឌ្ឍជំនឿជឿជាក់ នៅពេលនិយាយចំពោះមុខសិស្សទាំងអស់។

បង្កើតជំនាញមូលដ្ឋានដោយប្រើវត្ថុជាក់ស្តែង

កុមារក្មេងៗអាចយល់កាន់តែងាយអំពីការបូកលេខ ការដក ការគុណ និងការចែក នៅពេលពួកគេប្រើវត្ថុនានា ដូចជាដុំថ្មតូចៗ គ្រាប់សណ្តែកស្ងួត សំបកលៀស កំណាត់ឈើតូចៗ ឬគ្រាប់ពូជផ្លែឈើ។ វត្ថុទាំងនេះអាចជួយធ្វើអ្វីមួយទាក់ទងនឹងគណិតវិទ្យា ដែលសិស្សអាចមើលឃើញ ឬមានអារម្មណ៍ (ឧទាហរណ៍ សម្រាប់កុមារដែលមានបញ្ហាការមើល)។

នៅពេលកុមារឃើញ ឬប៉ះ និងបន្ទាប់ ធ្វើចលនាវត្ថុទាំងនេះ កុមារទទួលបានបទពិសោធផ្នែករាងកាយ និងផ្លូវចិត្ត បន្តិចម្តងៗ។ អ្នករៀនដែលអាចមើលឃើញ និងអ្នកដែលរៀនដោយការស្តាបអាចទទួលប្រយោជន៍យ៉ាងច្រើនដោយប្រើសម្ភារអនុវត្តដូច្នេះ។

ចូរចាំថា កុមារីអាចមានបទពិសោធក្នុងការប្រើសម្ភារតិចតួចជាងកុមារា ដូចជាសម្ភារដែល ធ្ងន់ៗ។ ត្រូវធានាឱ្យកុមារា និងកុមារីលេងជាមួយសម្ភារដែលទន់ និងរឹង (ដូចជា កំណាត់ និងថ្ម) ព្រមទាំងសម្ភារដែលមានទម្ងន់ស្រាល និងធ្ងន់។ កុមារី និងកុមារា គួរលើកទឹកចិត្តឱ្យចូលរួមគ្រប់សកម្មភាព ដើម្បីឱ្យពួកគេអាចទទួលបានទំនុកចិត្តក្នុងការប្រើចំណេះដឹង និងជំនាញរបស់ខ្លួន។ ពួកគេនឹងកែលំអសមត្ថភាពដើម្បីធ្វើការជាមួយអ្នកដទៃដែលមានលក្ខណៈខុសពីរូបពួកគេ។

ប្រើវត្ថុដែលមានរូបរាងខុសៗគ្នា

វត្ថុដែលមានរូបរាងខុសៗគ្នាអាចជួយកុមារឱ្យយល់ពីមាឌ ទំហំ និងធរណីមាត្រ។ វត្ថុទាំងនេះរួមមានគូប ពីរ៉ាមីត ចតុកោណ ស៊ីឡាំង និងរូបសណ្ឋានផ្សេងៗទៀតដែលធ្លាក់ចេញពីឈើ ឬធ្វើដោយការបត់ក្រដាសក្រាស់ៗ។ ស្នើក្រុមការងារកុមារស្រាវជ្រាវពីសាលា និងបរិយាកាសសាលាដើម្បីរករូបសណ្ឋានផ្សេងៗ ដែលបានប្រើក្នុងជីវភាពប្រចាំថ្ងៃ។ ឧទាហរណ៍ កំប៉ុងសំណប៉ាហាំងគឺជាបំពង់ស៊ីឡាំងមួយ ដុំឥដ្ឋមានរាងចតុកោណ រាងត្រីកោណធ្វើជាឧបករណ៍ទ្រដំបូលៗល។

គ្រូបង្រៀននៅប្រទេសទីម័រខាងកើតបានចំណាយពេលកន្លះម៉ោងក្នុងពេលធ្វើសិក្ខាសាលាដើម្បីស្រាវជ្រាវពីតំបន់ជុំវិញសាលាសម្រាប់រកវត្ថុ ដែលមានរាងធរណីមាត្រ។ ពួកគេបានរកឃើញប្រអប់មួក កំប៉ុង ចាល់ៗល។ ហើយបានដាក់តាំងវត្ថុទាំងនេះ ដើម្បីពន្យល់បង្ហាញពីវត្ថុ ដែលមានរូបរាងផ្សេងគ្នាចំនួនបីដែលអាចរកឃើញនៅក្នុង និងជុំវិញសាលា។ ដោយធ្វើជាក្រុម។ កុមារបានយកគំរូមួយ ហើយញ៉ាំយាមរកទំនាក់ទំនងអំពីប្រវែងនៃ ចំហៀង ផ្ទៃក្រឡា និងមាឌ។ ពួកគេបានអភិវឌ្ឍរូបមន្តមួយដែលអាចអនុវត្តចំពោះគំរូដទៃៗទៀតដែលមានរូបរាងដូចគ្នា។ ក្រុមការងារមួយបំពេញកោណមួយដោយប្រើទឹកដើម្បីប្រៀបធៀបមាឌជាមួយមាឌបំពង់ស៊ីឡាំង។ ក្នុងពេលកំពុងបណ្តុះបណ្តាល ការរៀនពីទ្រឹស្តីមិនគ្រប់គ្រាន់ឡើយ។ គ្រូបង្រៀនត្រូវការអនុវត្តទ្រឹស្តី ដោយប្រើវិធីសាន់ៗជាច្រើន ដើម្បីឱ្យពួកគេអាចបង្កើត តែងការមេរៀនប្រកបដោយខ្លឹមសារ។

ប្រើវិធីសាស្ត្របង្រៀនផ្សេងៗគ្នា : ធ្វើ និយាយ និងកត់ត្រា

ដើម្បីអភិវឌ្ឍជំនាញគណិតវិទ្យារបស់ខ្លួន កុមារត្រូវការចូលរួមក្នុងសកម្មភាពអនុវត្តនានា។ កុមារត្រូវការរៀនពីវិធីនិយាយអំពីគណិតវិទ្យា ហើយកុមារត្រូវការកត់ត្រា (សរសេរ)អំពីវិធីដែលពួកគេបានព្យាយាម ដើម្បីដោះស្រាយបញ្ហាគណិតវិទ្យានានា។

- ផ្នែក **ធ្វើ** នៃដំណើរការនេះទាក់ទងនឹងសកម្មភាព (ឧទាហរណ៍ ការរាប់គ្រាប់សណ្តែក ហើយបន្ទាប់មក ដកគ្រាប់សណ្តែកចេញមួយចំនួន)។
- ផ្នែក **និយាយ** គឺជាការពិភាក្សាជាមួយដៃគូ ឬក្នុងក្រុមតូចមួយ ដូចជា "ខ្ញុំគិតថា វាគួរតែ ៦ មិនមែន ៥ ទេ ពីព្រោះ....."។
- ផ្នែក **កត់ត្រា** គឺជាការកត់ត្រាពីដំណើរការ និងចម្លើយ ដើម្បីឱ្យគ្រូបង្រៀនអាចនិយាយជាមួយកុមារអំពីវិធីផ្សេងៗ ដើម្បីដោះស្រាយបញ្ហា។

ឧទាហរណ៍ កុមារអាចត្រូវបានស្នើឱ្យវាស់រូបសណ្ឋានដាក់លាក់ និងគណនាបរិមាត្រ និងផ្ទៃក្រឡា (ធ្វើ)។ ក្រុមនីមួយៗអាចពិភាក្សាពីវង្វាស់របស់ពួកគេ (និយាយ)។ លទ្ធផលរបស់ក្រុមនីមួយៗអាចបញ្ចូលគ្នាជាមួយលទ្ធផលរបស់ក្រុមដទៃទៀត ហើយបន្ទាប់មកកត់ត្រាទុក ដើម្បីបង្ហាញលទ្ធផលរបស់ថ្នាក់រៀនទាំងមូល (កត់ត្រា)។ ការពិភាក្សាក្នុងថ្នាក់នឹងអាចធ្វើតាមក្រោយផងដែរ។

សម្រាប់ប្រភាគ កុមារអាចទទួលបាននូវបំណែកផ្លែឈើ ឬបន្លែដែលបានចិត ដើម្បីជួយពួកគេឱ្យគិតនិងយល់ពីចំនួនពាក់កណ្តាល និងចំនួនមួយភាគបួន (ធ្វើ)។ កុមារអាចពិភាក្សាថា តើចំនួនពាក់កណ្តាលគឺធំជាងចំនួនមួយភាគបួនឬទេ (និយាយ) ហើយកុមារអាចរៀន ពីវិធីសរសេរប្រភាគមួយ ឧទាហរណ៍ ១/២ (កត់ត្រា)។ ជាថ្មីម្តងទៀត ការប្រើសម្ភារពិតប្រាកដ ដូចជាផ្លែឈើ និងបន្លែអាចឱ្យកុមារប្រើញាណផ្សេងៗ របស់ខ្លួន ដូចជា ចក្ខុវិញ្ញាណ និងកាយវិញ្ញាណ ដើម្បីភ្ជាប់គណិតវិទ្យាទៅនឹងសកម្មភាពក្នុងជីវភាពប្រចាំថ្ងៃ។

ការភ្ជាប់គណិតវិទ្យាទៅនឹងជីវភាពរស់នៅប្រចាំថ្ងៃ

ដោយការធ្វើឱ្យគណិតវិទ្យាមានប្រយោជន៍ អ្នកអាចជួយកុមារឱ្យធ្វើទំនាក់ទំនងរវាងប្រតិបត្តិការធម្មតា និងប្រតិបត្តិការដែលកាន់តែស្មុគស្មាញថែមទៀត។ ការផ្តោតលើមុខងារគណិតវិទ្យាក្នុងជីវភាពរស់នៅប្រចាំថ្ងៃ ដូចជា ការគណនាពេលវេលា និងចម្ងាយសម្រាប់ធ្វើដំណើរពីផ្ទះទៅសាលា ការប៉ាន់ប្រមាណចំនួនផ្លែដែលចាំបាច់សម្រាប់ទីលានចាល់ចោះ ការប៉ាន់ប្រមាណតម្លៃបន្លែដែលត្រូវទិញនៅទីផ្សារ។ល។ ដោយបញ្ហាទាំងនេះជាការកិច្ចដ៏មានប្រយោជន៍ ហើយផ្តោតលើសមាសភាពដែលសិស្សស្គាល់បញ្ហាទាំងនេះ អាចអភិវឌ្ឍជំនាញគណិតវិទ្យាតាមរយៈការប្រើវត្ថុជាក់ស្តែង មិនមែនគំនិតអរូបីឡើយ។

កុមារអាចបង្កើតថែមទៀតនូវការយល់គំនិតគណិតវិទ្យារបស់ខ្លួន នៅពេលពួកគេប្រើភាសា ដើម្បីរៀបរាប់វិធីនានាដែលពួកគេកំពុងអនុវត្តគណិតវិទ្យា។ ត្រូវផ្តល់ដល់កុមារី និងកុមារានូវឱកាសឱ្យបានញឹកញាប់ ដើម្បីសរសេរ ឬពណ៌នាដោយផ្ទាល់មាត់ ដោយប្រើសំដី ផ្ទាល់ខ្លួន ពីដំហានទីមួយៗក្នុងដំណោះស្រាយរបស់ពួកគេ និងពីអត្ថន័យនៃដំហានទីមួយៗ។ ដូចក្នុងមុខវិជ្ជាដទៃទៀតដែរ អ្នកត្រូវសង្កេតមើលកុមារ ធ្វើការហើយជជែកជាមួយពួកគេអំពីវិធីរកចម្លើយរបស់ពួកគេ។ អ្នកត្រូវការការអត់ធ្មត់ ហើយសាកល្បងវិធីសាស្ត្រផ្សេង។ ប្រសិនបើកុមារកំពុងមានបញ្ហាពិបាក។

អ្នកអាចជួយកុមារដែលមានរបៀបសិក្សាខុសគ្នា និងតម្រូវការសិក្សាខុសគ្នា ដោយការផ្គែកការយល់ដឹងពីគណិតវិទ្យារបស់ពួកគេ ទៅលើសកម្មភាពខុសៗគ្នាមួយចំនួន ដូចជា សកម្មភាពដែលពួកគេធ្វើជាប្រចាំនៅពេលថ្ងៃ។ អ្នកអាចជួយកុមារ ដោយការប្រើវត្ថុជាក់ស្តែង និងដោយការរៀបរាប់គំនិតគណិតវិទ្យាដោយផ្ទាល់មាត់ និងតាមរយៈការស្ទាបប៉ះ។ ហេតុដូច្នេះ យើងកំពុងធានាឱ្យការសិក្សាគណិតវិទ្យាមានខ្លឹមសារសម្រាប់កុមារទាំងអស់គ្នា។



សកម្មភាពអនុវត្ត : គណិតវិទ្យា និងសហគមន៍

ចូរស្រង់ជាបញ្ជីនូវមធ្យោបាយផ្សេងៗដែលសហគមន៍របស់អ្នកប្រើគណិតវិទ្យា។ ឧទាហរណ៍ ចូរសុំឱ្យសិស្សរបស់អ្នកធ្វើការស្ទាបស្ទង់ធម្មតាមួយស្តីពីវិធីប្រើគណិតវិទ្យានៅផ្ទះ។ នេះគឺជាមធ្យោបាយមួយដ៏ល្អដើម្បីឱ្យសិស្សគិត។ ចូរចាប់ផ្តើមជាមួយការងារប្រចាំថ្ងៃ និងសកម្មភាពជាក់ស្តែង ហើយស្រង់ជាបញ្ជីរាល់មធ្យោបាយដែលអ្នកប្រើគណិតវិទ្យាក្នុងអំឡុងពេលអាទិត្យមុន។

ចូរនិយាយជាមួយកុមារ ឬសមាជិកសហគមន៍របស់អ្នក ហើយរកឱ្យឃើញថាតើមានរឿង ឬរឿងនិទានក្នុងស្រុកណាមួយឬទេ ដែលទាក់ទងនឹងពេល ឬចម្ងាយ ឬថាតើមានបទចម្រៀង ឬរបាំណាមួយ ឬទេដែលមានចង្វាក់ ឬកាដង់គួរចាប់អារម្មណ៍។ ចូរបញ្ចូលបញ្ហាទាំងនេះទៅក្នុងកិច្ចតែងការបង្រៀនរបស់អ្នក។

ចូរប្រើឈ្មោះ ឬទីកន្លែងក្នុងស្រុកនានា ដើម្បីឱ្យកុមារអាចយល់សំណួររបស់អ្នកបានប្រសើរថែមទៀត។ ឧទាហរណ៍ ចនដើរពីផ្ទះរបស់ខ្លួនចម្ងាយកន្លះគីឡូម៉ែត្រ ដើម្បីយួរទឹកពីអណ្តូងសហគមន៍។ ធុងទឹករបស់ចនអាចផ្ទុកទឹកបាន ៥ លីត្រ។ តើចនត្រូវដើរយួរទឹកពេញធុងទៅផ្ទះចម្ងាយប៉ុន្មាន? (ដោយប្រើឧទាហរណ៍នេះ នឹងអាចមានការពិភាក្សាគ្នាមួយស្តីពីភារកិច្ចនានាដែលកុមារា និងកុមារីត្រូវធ្វើនៅក្នុងគ្រួសារ និងសហគមន៍ខ្លួន)។



សកម្មភាពអនុវត្ត : គណិតវិទ្យា និងសុខភាព

មានឱកាសជាច្រើនសម្រាប់កុមាររៀនអំពីសុខភាព និងការអភិវឌ្ឍរបស់ខ្លួនតាមរយៈសកម្មភាពគណិតវិទ្យាដែលមានប្រយោជន៍របស់ពួក គេ។ ឧទាហរណ៍ :

- *កុមារអាចវាស់កម្ពស់ និងទម្ងន់របស់ខ្លួន។ ការវាស់ទាំងនេះត្រូវបានកត់ត្រាទុកនៅលើក្រាហ្វិកសម្រាប់កុមារទាំងអស់ ហើយត្រូវធ្វើជាថ្មីឡើងវិញជារឿយៗ។ ក្នុងគម្រោងការស្តីពីកុមារនៅប្រទេសថៃ កុមារក្នុងថ្នាក់ទី៥ និងទី៦ ត្រូវបានបណ្តុះបណ្តាលជា "អ្នកជំរុញការត្រួតពិនិត្យការរីកធំធាត់" ដែលវាស់ ត្រួតពិនិត្យ និងផ្តល់អនុសាសន៍សម្រាប់កែលំអ ស្ថានភាពអាហារូបត្ថម្ភរបស់ខ្លួនផ្ទាល់ និងរបស់មនុស្សដែលមានវ័យប្រហាក់ប្រហែលគ្នា[6]។ ព័ត៌មានរបស់ពួកគេជួយសាលា និងបុគ្គលិកសុខាភិបាលក្នុងស្រុកឱ្យរកឃើញកុមារដែលមានការផ្តល់អាហារូបត្ថម្ភមិនល្អ ដើម្បីឱ្យកុមារទាំងនេះអាចចុះឈ្មោះនៅក្នុងកម្មវិធីអាហារថ្ងៃត្រង់របស់សាលា (ចូរមើលកម្រងសៀវភៅទី ៦)។*

ការស្ទាបស្ទង់ពីជំងឺអាចត្រូវធ្វើឡើងនៅក្នុងថ្នាក់ ឬនៅក្នុងសាលា។ ឧទាហរណ៍ កុមារអាចកត់ត្រាចំនួនមិត្តរួមថ្នាក់របស់ ខ្លួនដែលមានជំងឺកញ្ជ្រឹល ស្រែង គ្រុនចាញ់ ឬបញ្ហាសុខភាពដទៃទៀត ក្នុងរយៈពេលជាក់លាក់មួយ។ លទ្ធផលត្រូវបានផ្តល់ជាចំនួនភាគរយ។ បន្ទាប់មក គេអាចធ្វើសកម្មភាពការពារជំងឺខ្លះ។



សកម្មភាពឆ្លុះបញ្ចាំង : តើខ្ញុំបង្រៀនគណិតវិទ្យាដូចម្តេច?

ចូរវិភាគពីវិធីបង្រៀនគណិតវិទ្យារបស់អ្នក ដោយការបំពេញតារាងខាងក្រោមនេះ :

វិធីសាស្ត្រ/សកម្មភាព	ខ្ញុំតែងតែធ្វើញឹកញាប់	មិនញឹកញាប់	អ្វីដែលខ្ញុំត្រូវធ្វើ
លើកទឹកចិត្តកុមារា និង កុមារីឱ្យប្រើសម្ភារអនុវត្តជាក់ស្តែង។			
ផ្សារភ្ជាប់សំណួរគណិតវិទ្យាជាមួយនឹងសុខភាព ឬ សកម្មភាពសហគមន៍។			
ប្រើជ្រុងសិក្សាគណិតវិទ្យា។			
ពិនិត្យសម្ភារសិក្សាដើម្បីរកភាពលំអៀងយេនឌ័រ។			

មុខវិជ្ជាវិទ្យាសាស្ត្រដែលមានបរិយាកាសរៀនមេត្រី

នៅពេលយើងសិក្សាពីវិទ្យាសាស្ត្រ យើងស្រាវជ្រាវរកផ្នែកដែលកើតមានដ៏តូចបំផុត និងជីវិត ដូចជា អាតូម ព្រមទាំងការឈាន ទៅក្នុងលំហដ៏ធ្លាយបំផុត។ បញ្ហាពិបាកគឺថា យើងដឹងថា អាតូម និងកញ្ចុំផ្កាយកើតមាន។ ទោះដោយ៉ាងណាក្តី យើង រួមទាំងកូនរបស់យើងផង មើលមិនឃើញវាទាំងនោះឡើយ យើងមិនគិតអំពីវាជាប្រចាំឡើយ ឬយើងមិននិយាយអំពីវាប្រចាំថ្ងៃឡើយ។ ដូច្នេះហើយ ដើម្បីធ្វើឱ្យមុខវិជ្ជាវិទ្យាសាស្ត្រមានបរិយាកាសរៀនមេត្រី យើងត្រូវការធ្វើឱ្យមានតុល្យភាពរវាងអ្វីដែលពិត (អ្វីដែលយើងឃើញ ប៉ះ ឬធុំក្លិនជាប្រចាំ) និងអ្វីដែលគេស្គាល់ (វត្ថុអរូបី ដូចជាអាតូម និងកញ្ចុំផ្កាយ)។ ដោយការចាប់ផ្តើមជាមួយអ្វីដែលពិត ហើយដោយការភ្ជាប់មុខវិជ្ជាវិទ្យាសាស្ត្រទៅនឹងអ្វីដែលកុមារឃើញ ឬធ្វើរាល់ថ្ងៃ យើងអាចជួយកុមារឱ្យអភិវឌ្ឍជំនាញប្រាស្រ័យទាក់ទងកាន់តែប្រសើរឡើង។ កុមារអាចនិយាយបានកាន់តែស្រួលពីវិទ្យាសាស្ត្រ និង "ជីវភាពពិតប្រាកដ"។ ហេតុដូច្នេះហើយ កុមារអាចធ្វើការឆ្ពោះទៅរកការយល់ដឹង និងការនិយាយអំពីគំនិតយោបល់ ឬគំនិតទូទៅដែលមានភាពកាន់តែអរូបីផ្នែកវិទ្យាសាស្ត្រ។

ដូចក្នុងមុខវិជ្ជាគណិតវិទ្យាដែរ ការសិក្សាពីវិទ្យាសាស្ត្រ អាចត្រូវលើកទឹកចិត្តតាមរយៈសកម្មភាពជាក់ស្តែងអំពីប្រធានបទ ដូចជា រុក្ខជាតិ និងសត្វ ដងខ្លួនមនុស្ស ទឹក និងទម្រង់ដី បរិស្ថានធម្មជាតិ និងបរិស្ថានដែលបង្កើតដោយមនុស្ស សម្លេង និងភ្លើង ប្រព័ន្ធព្រះអាទិត្យ។ល។ ជាងនេះទៀត ការបិទស្លាកលើគំនូររុក្ខជាតិមួយ ជាមធ្យោបាយមួយក្នុងការធ្វើសមាហរណកម្មជំនាញសរសេរ និងគូរ ហើយវាជាទម្រង់ដ៏ល្អនៃការប្រាស្រ័យទាក់ទងក្នុងមេរៀនវិទ្យាសាស្ត្រ។ វាក៏ជាដំហានដ៏ល្អមួយដោយត្រូវបិទស្លាកលើវត្ថុដទៃទៀតដែលកាន់តែអរូបី ដូចជាភពផែនដី ឬសរីរាង្គខាងក្នុងនៃដងខ្លួនមនុស្ស។

ក្នុងវិស័យទាំងអស់នេះ បញ្ហាគន្លឹះគឺត្រូវរកឱ្យឃើញមធ្យោបាយនានា ដើម្បីឱ្យកុមារស្រាវជ្រាវរកបទពិសោធផ្ទាល់ខ្លួន ដោយប្រើប្រធានបទទាំងនេះ។ ឧទាហរណ៍ ដើម្បីរៀនអំពីសម្លេង និងភ្លើង កុមារអាចមានបទពិសោធផ្នែករលកសម្លេង និងរំញ័រ ដោយប្រើឧបករណ៍ខ្សែ ឬឧបករណ៍ដែលផលិតនៅក្នុងផ្ទះ។ ដើម្បីរៀនពីប្រព័ន្ធពន្លឺព្រះអាទិត្យ កុមារអាចអង្កេតមើលដំនាក់ការរបស់ព្រះចន្ទ ឬកុមារគួសគំនូសតាងចលនានៃព្រះអាទិត្យ ដោយប្រើកំណាត់ឈើមួយ និងដោយការវាស់មុំនៃស្រមោលរាល់ម៉ោង។

បទពិសោធជាក់ស្តែងទាំងនេះអាចគាំទ្រតាមរយៈការណែនាំបង្ហាញល្អ ៗពីដំណើរការវិទ្យាសាស្ត្រ។ ក្នុងពេលសិក្សាពីវិទ្យាសាស្ត្រ សិស្សអាចអនុវត្តជំនាញសួរ និងជំនាញអង្កេតមើលរបស់ខ្លួន។ សិស្សក៏អាចរៀបចំការពិសោធនានា ដើម្បីឆ្លើយសំណួរផ្ទាល់របស់ខ្លួនផងដែរ។

កុមារអាចត្រូវបានណែនាំឱ្យស្គាល់ពីតួនាទីរបស់វិទ្យាសាស្ត្រ និងវិធីសាស្ត្រវិទ្យាសាស្ត្រក្នុងសង្គម។ ឧទាហរណ៍ នៅពេលកុមារី និងកុមារធ្វើពិសោធន៍ពីវិធីហាលផ្លែឈើក្នុងឧបករណ៍ហាលប្រើពន្លឺព្រះអាទិត្យ ឬពីវិធីធ្វើជីកំប៉ុក ពួកគេកំពុងរៀនពីវិទ្យាសាស្ត្រដ៏ល្អ ក្នុងខណៈកំពុងស្វែងរកដំណោះស្រាយមានប្រយោជន៍ដល់បញ្ហាសហគមន៍។

---

6 For more information, see http://www.inmu.mahidol.ac.th/CHILD/

ជាការសំខាន់ណាស់ យើងជាគ្រូបង្រៀនត្រូវរៀនពីគំនិតវិទ្យាសាស្ត្រសំខាន់ៗ ដើម្បីធ្វើទំនាក់ទំនងយ៉ាងងាយនូវសកម្មភាពរបស់កុមារជាមួយគំនិតទាំងនោះ និងជួយកុមារក្នុងការរៀន។ ឧទាហរណ៍ ការចាត់ជាប្រភេទ ជាគំនិតសំខាន់មួយក្នុងមុខវិជ្ជាវិទ្យាសាស្ត្រ។ ការចាត់ជាប្រភេទនៃវត្ថុមានជីវិត និងវត្ថុគ្មានជីវិត ជាចំណុចចាប់ផ្តើមដ៏ល្អ។ អ្នកអាចប្រើដុំថ្ម និងបន្លែជាឧទាហរណ៍ដ៏មានប្រយោជន៍។ គំរូមួយសម្រាប់ជួយកុមារឱ្យយល់អំពីការចាត់ជាប្រភេទមានដូចខាងក្រោម :

ជំហានសម្រាប់ជួយកុមារតូចៗឱ្យយល់អំពីការបែងចែកប្រភេទ

១. តើខ្ញុំចង់ចាត់អ្វីជាប្រភេទ?

២. តើវត្ថុអ្វីខ្លះដូចគ្នាដែលខ្ញុំអាចដាក់ចូលក្នុងក្រុមមួយបាន?

៣. តើវត្ថុទាំងនេះមានលក្ខណៈអ្វីខ្លះដូចគ្នា?

៤. តើខ្ញុំអាចបង្កើតក្រុមអ្វីខ្លះផ្សេងទៀត?

៥. តើឥឡូវនេះអ្វីៗបានបញ្ចូលក្នុងក្រុមហើយឬ?

៦. តើជាការប្រសើរឬទេក្នុងការបែងចែកក្រុមណាមួយ ឬត្រូវច្រៀបាច់បញ្ចូលគ្នា?

៧. តើខ្ញុំអាចគូសដ្យាក្រាមមួយ តំណាងពីវិធីដែលខ្ញុំបានចាត់វត្ថុផ្សេងៗជាប្រភេទបានឬទេ?

មធ្យោបាយផ្សេងសម្រាប់យកមកគិត និងការដឹង

ក្នុងសហគមន៍ និងវប្បធម៌ជាច្រើន មនុស្សបានអភិវឌ្ឍមធ្យោបាយផ្សេងៗដើម្បីយល់ពីធម្មជាតិ និងពិភពជុំវិញខ្លួន។ មធ្យោបាយយល់ ដឹងទាំងនេះអាចទាក់ទងនឹងបទពិសោធសង្គម ឬការអង្កេតមើល ជាជាងការធ្វើពិសោធន៍វិទ្យាសាស្ត្រ។ កុមារខ្លះអាចទៅជាយល់ច្រឡំ ពីព្រោះវិធីពន្យល់អ្វីផ្សេងៗនៅសាលាអាចមានលក្ខណៈខុសគ្នាពីរឿងរ៉ាវនានាដែលពួកគេបានដឹងឮនៅផ្ទះ។ ឧទាហរណ៍ សមាជិកសហគមន៍អាចស្គាល់ពីរុក្ខជាតិពិសេស។ ឬមធ្យោបាយព្យាបាលផ្សេង។ ឬពួកគេអាចច្រៀបាច់រឿងនានា ដែលពន្យល់ពីការកើតមានដីជុំវិញពួកគេដែលអាចមិនស្របតាមព័ត៌មានក្នុងសៀវភៅអត្ថបទរបស់យើង។ ទោះជាយ៉ាងនេះក្តី រឿងទាំងនេះគឺជាផ្នែកមួយដ៏សំខាន់នៃវប្បធម៌សហគមន៍ ហើយត្រូវបានបង្រៀនពីជំនាន់មួយទៅជំនាន់មួយទៀត។

ការរៀនដែលដាក់បញ្ចូលគ្នាគ្រប់សមាសភាពមានន័យថា ការបញ្ចូលគំនិតផ្សេងៗគ្នារបស់កុមារ និងវិធីសិក្សារបស់កុមារ។ កុមារត្រូវការដឹងថា មានមធ្យោបាយផ្សេងៗជាច្រើនដើម្បីពន្យល់ពីវត្ថុ ឬហេតុការណ៍នានា ហើយយើងមានបំណងទទួលយកការពន្យល់ផ្សេង។ ដោយគ្មានការវិនិច្ឆ័យខុសត្រូវឡើយ។ អ្នករៀនក្មេងៗអាចរៀនរួចហើយពីរឿងនិទាន សុភាសិត និងសូម្បីតែវិធីពិសេសៗនៃការដឹង និងការព្យាបាលក៏បានរៀនហើយដែរ។ ជាគ្រូបង្រៀន យើងត្រូវការរកមធ្យោបាយនានា ដោយគោរពតាមវិធីគិតទាំងនេះនៅក្នុងខណៈអ្នកកំពុងជួយអ្នករៀនឱ្យយល់ពី វិទ្យាសាស្ត្រ ដែលជាទម្រង់ពិសេសមួយនៃចំណេះដឹង។

នៅទីមំរោងកើត មានរឿងមួយស្តីពីសត្វក្រៀពើ ដែលទាក់ទងនឹងប្រភពដើមនៃកោះដែលមានរាងដូចជាសត្វក្រៀពើ។ នៅក្នុងថ្នាក់ រឿងនេះអាចនាំឱ្យមានការពិភាក្សាអំពីទេសភាព លំនៅឋាន និងភាពវិលវល់នៃជីវិត ព្រមទាំងគំនិតដទៃទៀត ដូចជាការភ័យខ្លាច និងគ្រោះថ្នាក់។



សកម្មភាពអនុវត្ត : វិទ្យាសាស្ត្រ និងជីវភាពប្រចាំថ្ងៃ

រកមធ្យោបាយមួយចំនួនដើម្បីបង្ហាញថា ចំណេះដឹងវិទ្យាសាស្ត្រអាចរួមចំណែកធ្វើឱ្យយើងយល់ពីរបៀបរស់នៅរបស់យើង។ ឧទាហរណ៍ ទឹកគឺជាប្រធានបទមួយដែលគេអាចរុករកឃើញក្នុងវិធីជាច្រើន ហើយវាមានសារៈសំខាន់សម្រាប់ជីវិតរបស់មនុស្សគ្រប់រូប។ ដោយការសិក្សាពីទឹក យើងអាចបញ្ចូលទម្រង់ផ្សេងៗនៃចំណេះដឹងវិទ្យាសាស្ត្រ ព្រមទាំងផ្សារភ្ជាប់ជាមួយមុខវិជ្ជាដទៃទៀត ដូចជា គណិតវិទ្យា ភាសា និងសិក្សាសង្គម។ ឧទាហរណ៍ នៅពេលយើងដាំទឹក ដើម្បីបន្សុតវា គឺយើងបានសំលាប់អតិសុខុមជ្រាណដែលយើងមើលមិនឃើញ និងមិនស្គាល់ មុនអ្នកវិទ្យាសាស្ត្របានរកឃើញអតិសុខុមជ្រាណទាំងនេះទៅទៀត។ នៅពេលយើងប្រើស្នប់ដៃមួយដើម្បីបូមទឹកចេញពីអណ្តូង យើងកំពុងប្រើមាំស៊ីនធម្មតាមួយ និងដែកគំនាស់ដើម្បីបង្កើតសុញ្ញកាស។ នៅពេលពពកផ្តុំគ្នា រន្ទះបាញ់ និងភ្លៀងធ្លាក់ យើងទទួលបានបទពិសោធស្តីពីកម្លាំងធម្មជាតិ។

ចូររៀបចំមេរៀនថ្មីមួយដោយភ្ជាប់ចំណេះដឹងវិទ្យាសាស្ត្រ និងការអង្កេតតាមដានជាមួយនឹងជីវភាពរស់នៅប្រចាំថ្ងៃ។

- *តើអ្នកនឹងប្រើធនធានអ្វី ដើម្បីបង្រៀនសិស្សរបស់អ្នក?*
- *តើអ្នកសិក្សាត្រូវបានស្នើឱ្យរិះរកសំណួរណាមួយឬ? ឧទាហរណ៍ តើស្រមោលដែលបង្កើតដោយកំណាត់ឈើ នៅម៉ោង ៩ ព្រឹក វែងជាងនៅពេលថ្ងៃត្រង់ឬ?*
- *តើអ្នកសិក្សាអាចធ្វើសកម្មភាពអ្វី ដើម្បីសាកល្បងសំណួររបស់ខ្លួន?*
- *តើពួកគេអាចប្រើធនធានព័ត៌មាន (ដូចជាសៀវភៅអត្ថបទ) អ្វីខ្លះ?*
- *តើអ្នកនឹងវាយតម្លៃការយល់ដឹងពីសកម្មភាពរបស់ពួកគេ ដោយរបៀបណា?*

ប្រធានបទ	ការអង្កេតតាមដានជាក់ស្តែង	សម្ភារដែលមានក្នុងស្រុក	ការភ្ជាប់ជាមួយជីវភាពរស់នៅប្រចាំថ្ងៃ	វិធីសាស្ត្រវាយតម្លៃ

កិច្ចតែងការបង្រៀន និងការបង្រៀន

មុខវិជ្ជាវិទ្យាសាស្ត្រដ៏មានប្រយោជន៍ត្រូវការរៀបចំតាក់តែងដោយយកចិត្តទុកដាក់ ដើម្បីឱ្យកុមារទាំងអស់អាចចូលរួមប្រកបដោយទំនុកចិត្ត។ ចូរពិចារណាអំពីប្រធានបទមួយចំនួនក្នុងកម្មវិធីសិក្សាមុខវិជ្ជាវិទ្យាសាស្ត្ររបស់អ្នកដែលអាចទាក់ទងយ៉ាង ជិតស្និទ្ធជាមួយនឹងជីវភាព រស់នៅប្រចាំថ្ងៃរបស់កុមារ។

*នៅពេលរៀបចំកិច្ចតែងការបង្រៀន ចាំបាច់ត្រូវរៀបចំពីវិធីដែលកុមារនឹងចូលរួមរៀនសូត្រ។ ជាធម្មតា បញ្ហានេះអាស្រ័យលើវិធីសាស្ត្របង្រៀនដែលយើងត្រូវប្រើ។ ឧទាហរណ៍មួយស្តីពីវិធីសាស្ត្របង្រៀនប្រកបដោយប្រសិទ្ធភាពគឺ : **គិត សរសេរ ធ្វើការជាគូ ចែករំលែក**។ វិធីសាស្ត្រនេះលើកទឹកចិត្តសិស្សឱ្យចូលរួម សូម្បីសិស្សទុយមុយ ឬសិស្សទាំងឡាយដែលមាន អារម្មណ៍ថា ត្រូវបានគេច្រានចោលក៏ដោយ។*

- *សួរកុមារនូវសំណួរចំហមួយ ដូចជាសំណួរដែលស្នើពួកគេឱ្យសម្រេចចិត្តលើបញ្ហាអ្វីមួយ ឬឱ្យបញ្ចេញគំនិតអ្វីមួយ។*
- *ឱ្យកុមារគិតពីចម្លើយរបស់ខ្លួន។*
- *ស្នើកុមារ សរសេរ ចម្លើយរបស់ខ្លួន (ក្តារឆ្នូនមានសារៈប្រយោជន៍ណាស់សម្រាប់សរសេរកំណត់ត្រាខ្លីៗក្នុងវិធីសាស្ត្រនេះ)។*
- *ស្នើកុមារផ្លាស់ប្តូរយោបល់ជាមួយដៃគូម្នាក់ (ការធ្វើជាគូ)។*
- *ស្នើសុំអ្នកស្ម័គ្រចិត្ត (កុមារី និងកុមារា) ដើម្បីចែករំលែកលទ្ធផលនៃការពិភាក្សារបស់ខ្លួនជាមួយថ្នាក់រៀនទាំងមូល។*

វិធីសាស្ត្រនេះធានាឱ្យកុមារទាំងអស់មានឱកាសឆ្លើយ និងពិភាក្សាអំពីគំនិត ឬចម្លើយរបស់ខ្លួន។ វិធីសាស្ត្រនេះមានសារៈសំខាន់ណាស់។ ចូរសួរខ្លួនអ្នក "ក្នុងថ្នាក់រៀនខ្ញុំ តើមានកុមារដែលតែងតែលើកដៃមុនគេ ដើម្បីឆ្លើយសំណួររបស់ខ្ញុំឬទេ?" បញ្ហាគឺថា នៅពេលកុមារទាំងនេះលើកដៃឆ្លើយសំណួររបស់អ្នក

កុមារដទៃទៀតលែងគិតរកចម្លើយ។ ពួកគេអាចត្រូវការពេលវេលាវែងជាងនេះ ដើម្បីរៀបចំចម្លើយ ឬ ពួកគេគិតថា កុមារដទៃទៀតនឹងឆ្លើយសំណួររបស់អ្នក។ ជាងនេះទៀត កុមារជាច្រើនមានការភ័យខ្លាចមិន-ហ៊ាននិយាយ ជាពិសេសប្រសិនបើភាសាកំណើតរបស់ខ្លួនប្រើមិនបានធម្មតានៅក្នុងថ្នាក់រៀន។ ជួនកាលកុមារីបានខាតបង់ប្រយោជន៍ តាមរយៈការសួរសំណួររបស់គ្រូ ឬប្រសិនបើគ្រូតែងតែសួរកុមារាឱ្យឆ្លើយសំណួរ ដូចជាសំណួរនៅក្នុងមុខវិជ្ជាវិទ្យាសាស្ត្រ និងគណិតវិទ្យា។ ហេតុដូច្នេះ ទាំងកុមារា និងកុមារីត្រូវការឱកាស ដើម្បីយល់សំណួរ និងដើម្បីពង្រីកជំនឿទុកចិត្តក្នុងការឆ្លើយសំណួរនោះ។ ការងារធ្វើជាគូដែលបានបង្ហាញក្នុងវិធីសាស្ត្របង្រៀនខាងលើអាចធ្វើឱ្យកុមារទាំងអស់ហ៊ឺកហាត់វាក្យសព្ទបានត្រឹមត្រូវ និងសម្តែងចេញពី ទស្សនៈរបស់ខ្លួនម្នាក់ៗ។ ការដោះដូរទស្សនៈនេះបង្កើតទំនុកចិត្តរបស់កុមារ ហើយលើកទឹកចិត្តកុមារឱ្យចូលរួមក្នុង ការឆ្លើយសំណួររបស់គ្រូ ឬសំណួរទាំងឡាយ ដែលមិត្តរួមថ្នាក់របស់ខ្លួនបានសួរ។

ការភ្ជាប់មុខវិជ្ជាវិទ្យាសាស្ត្រជាមួយជីវភាពរស់នៅប្រចាំថ្ងៃ

ការភ្ជាប់មុខវិជ្ជាវិទ្យាសាស្ត្រជាមួយជីវភាពរស់នៅប្រចាំថ្ងៃធ្វើឱ្យមុខវិជ្ជានេះកាន់តែមានខ្លឹមសារឡើងសម្រាប់កុមារ។ វាក៏អាចជួយយើង រៀបចំកិច្ចតែងការបង្រៀនផងដែរ។ មធ្យោបាយមួយដ៏ល្អបំផុតដើម្បីធ្វើដូច្នេះ គឺត្រូវចាប់ផ្តើមជាមួយអ្វីដែលកុមារបានដឹងរួចហើយ ដោយ ការប្រើវិធីសាស្ត្រ **ដ ច រ រប**។

ដ	ច	រ	រប

ដ : *សំដៅលើការជួយសិស្សឱ្យចង់ចាំអ្វីដែលគេ **ដឹង** អំពីមុខវិជ្ជាដែលគេរៀន។*

ច : *សំដៅលើការជួយសិស្សឱ្យកំណត់នូវអ្វីដែលពួកគេ **ចង់** រៀន។*

រ : *សំដៅលើការជួយសិស្សឱ្យរកឃើញអ្វីដែលពួកគេបាន **រៀន** បន្ទាប់ពីពួកគេបានអាន ឬ អនុវត្តសកម្មភាពមួយ។*

រប : *សំដៅលើ **របៀបដូចម្តេច** ដែលសិស្សអាចរៀនបានថែមទៀត (រៀនពីប្រភពផ្សេង។ទៀត ដែលគេអាចរកព័ត៌មានបន្ថែមស្តីពី ប្រធានបទ/គេអាចសួរសំណួរថែមទៀត)*

ជំនាញភាសាដែលមានបរិយាកាសរៀនមេត្រី

ជំនាញភាសាមានសារៈសំខាន់យ៉ាងខ្លាំង ពីព្រោះវាប៉ះពាល់ដល់សមត្ថភាពក្នុងការរៀនគ្រប់មុខវិជ្ជារបស់កុមារ។ ការរៀនប្រកបដោយខ្លឹមសារនឹងកើតមាន ប្រសិនបើភាសាបង្រៀនមានអត្ថន័យពេញលេញ។ ជួនកាលត្រូវប្រើភាសានៅផ្ទះ (ក្នុងស្រុក) ដើម្បីឱ្យកុមារទាំងអស់ អាចទទួលបានព័ត៌មានគ្រប់គ្រាន់

អាចធ្វើការច្រាស្រ័យទាក់ទងពីគំនិតរបស់ខ្លួន និងអាចឱ្យគេយល់បានក្នុងរបៀបមួយដែលមានខ្លឹមសារ។

ការនិយាយ ការស្តាប់ ការអាន និងការសរសេរគឺជាជំនាញដែលត្រូវការប្រើ និងច្របាច់បញ្ចូលគ្នា ដើម្បីឱ្យកុមារទាំងអស់ អាចអភិវឌ្ឍសមត្ថភាពភាសាគ្រប់ផ្នែកបាន។ សកម្មភាពចំនួនពីរដែលអាចជួយអ្នកបានគឺ :

- បង្កើតឱកាសសម្រាប់ការស្តាប់ និងការអាន ពីព្រោះអ្នករៀនយល់ព័ត៌មាន និងបង្កើតការយល់តាមរយៈមធ្យោបាយ ទាំងពីរ និង
- ប្រើការងារជាក្រុមតូច។ ឬជាគូ ដើម្បីជួយកុមារស្តាប់ និងបញ្ចេញយោបល់ផ្ទាល់ខ្លួន។ ឧទាហរណ៍ ស្នើកុមារបង្កើត រឿងខ្លី។ ដែលនឹងជួយពួកគេបញ្ចេញយោបល់ ដោយប្រើភាសាផ្ទាល់ខ្លួនពួកគេ និងរៀនអំពីការបន្តហេតុការណ៍ក្នុងរឿងមួយ (មានន័យថា ហេតុការណ៍នេះបានកើតឡើង ហើយបន្ទាប់មក ហេតុការណ៍នេះកើតឡើង ហើយទីបំផុត ហេតុការណ៍នេះបានកើតឡើង)។

អ្នកអាចបង្កើតឱកាសនានាសម្រាប់កុមារស្តាប់ តាមរយៈការអានរឿងឮៗ ដល់ថ្នាក់ទាំងមូល។ អ្នកក៏អាចអញ្ជើញមនុស្សពីសហគមន៍របស់អ្នកមកថ្នាក់រៀន ដើម្បីនិយាយច្រាប់ពីការងាររបស់ពួកគេ ការរស់នៅរបស់ពួកគេ ឬប្រវត្តិសាលារបស់អ្នក។ ត្រូវច្បាកដថា នឹងអញ្ជើញមនុស្សដែលមានវ័យចំណាស់ ពីព្រោះពួកគេអាចមានរឿងជាច្រើន និងពេលវេលាច្រើនក្នុងការនិយាយច្រាប់កុមារ។ នៅពេលអញ្ជើញមនុស្សមកដំបូង ត្រូវរៀបចំជាមួយមនុស្សនោះសិន តាមរយៈការពន្យល់ពីគោលបំណងនៃការអញ្ជើញនេះ។ ត្រូវជួយកុមារី និងកុមារាឱ្យអភិវឌ្ឍជំនាញសង្គមរបស់ពួកគេ។ តើអ្នកណានឹងស្វាគមន៍ភ្ញៀវ? តើយើងត្រូវស្វាគមន៍អ្នកណាម្នាក់ដែលយើងមិនស្គាល់ដូចម្តេច? តើយើងនិយាយជាមួយមនុស្សចាស់ដូចម្តេច? តើភ្ញៀវនឹងអង្គុយនៅកន្លែងណា? តើយើងអរគុណអ្នកណាម្នាក់ដែលបានជួយយើងដូចម្តេច?។ ទាំងនេះក៏ជាមធ្យោបាយដ៏ល្អសម្រាប់ការហ្វឹកហាត់ជំនាញច្រាស្រ័យទាក់ទង និងជំនាញសង្គមជាដែរ។

វិធីសាស្ត្រស្តីពីការអាន

មាតាបិតាជាច្រើនព្រួយបារម្ភណ៍អំពីការរៀនអានរបស់កូនខ្លួន។ ជួនកាល ភាពកង្វល់នេះដាក់សម្ពាធលើកុមារ ហើយអាចធ្វើឱ្យការរៀនអានជាទណ្ឌកម្មមួយជំនួសការកំសាន្តសប្បាយ។ ការអានមានភាពស្មុគស្មាញ។ មានមធ្យោបាយផ្សេងៗក្នុងការជួយកុមាររៀនអាន។ វិធីសាស្ត្រចំនួនពីរដែលត្រូវប្រើគឺ វិធីសាស្ត្រសូរសម្លេង និងវិធីសាស្ត្រភាសាទាំងមូល។

ក្នុងវិធីសាស្ត្រសូរសម្លេង ពាក្យសរសេរមួយត្រូវបានបំបែកទៅជាអក្សរដែលជាធាតុផ្សំរបស់វា។ អក្សរដែលត្រូវបានសរសេរទាំងនេះ ត្រូវបានផ្គូរផ្គងជាមួយសម្លេងរបស់វា ហើយបន្ទាប់មកត្រូវបានលាយបញ្ចូលគ្នា ដើម្បីបង្កើតជាពាក្យនោះ។

វិធីសាស្ត្រភាសាទាំងមូលមានការទាក់ទិននឹងការបង្កើតអត្ថន័យរវាងពាក្យទាំងមូល និងពាក្យដែលបាននិយាយ ជាធម្មតានៅ ក្នុងបរិបទស្តីពីវិធីប្រើពាក្យនោះ។ គេអាចបង្ហាញពាក្យនោះក្នុងឃ្លាខ្លីមួយ ដូចជា "បាល់ពណ៌ខៀវមួយ....."។

គេគួរប្រើវិធីសាស្ត្រទាំងពីរព្រោះអ្នករៀនផ្សេងគ្នានឹងរៀនអានក្នុងរបៀបផ្សេងៗគ្នា។ ដើម្បីបង្រៀនអានដល់អ្នករៀនផ្សេងគ្នា ដែលមានរបៀបរៀន និងប្រវត្តិផ្សេងៗគ្នាត្រូវ :

- ប្រើវិធីសាស្ត្រផ្សេងៗគ្នា។
- កុំញែកបំបែកជំនាញចេញពីអត្ថន័យ
- ចងចាំថា អ្នកអានទាំងឡាយរៀនអាន និងសរសេរ ពីព្រោះពួកគេចង់ធ្វើការច្រៃស្រីយទាក់ទងគ្នា។
- ដឹងថា ការរៀនអាន កើតមាននៅក្នុងបរិយាកាសគាំទ្រមួយ ដែលក្នុងនោះ កុមារអាចបង្កើតកិរិយាមារយាទ អវិជ្ជមានអំពីខ្លួនឯង និងភាសា
- ត្រូវអានប្រចាំថ្ងៃដល់កុមារតូចៗ ដើម្បីណែនាំពួកគេឱ្យដឹងពីការអានសម្រាប់ទទួលព័ត៌មាន និងសម្រាប់ការកំសាន្ត ហើយក៏ត្រូវបង្ហាញពួកគេថា រូបអ្នកក៏ចូលចិត្តអានដែរ។

មធ្យោបាយដទៃទៀតដើម្បីគាំទ្រការអាន

កុមារគួរមានសៀវភៅ និងអត្ថបទសមរម្យដើម្បីអាន ហើយសម្ភារទាំងនេះអាចមានក្នុង "កន្លែងពិសេសរបស់អ្នកនិពន្ធ និងរបស់អ្នកអាន"។ ប្រសិនបើសៀវភៅទាំងនេះមិនមានទេនោះ អ្នកអាចបង្កើតសៀវភៅផ្ទាល់របស់អ្នក ដែលបង្ហាញរឿងក្នុងស្រុក និងរឿងនិទាននានា (អ្នកក៏អាចបង្កើត "សៀវភៅធំ" សម្រាប់ការអានរបស់សិស្សក្នុងក្រុមផ្សេងៗផងដែរ)។ គំនិតដទៃទៀតមានដូចខាងក្រោម :

- ស្នើកុមារមួយចំនួននិយាយរឿងនានាអំពីការអង្កេតមើលរបស់ខ្លួនស្តីពីពិភពលោកជុំវិញខ្លួន និងអំពីហេតុការណ៍នានាក្នុងជីវភាពរស់នៅរបស់ខ្លួន ដូចជាវិស្សមកាល ឬការធ្វើពិធីអ្វីមួយរបស់គ្រួសារ។ កុមារ នឹងរៀនរបៀបបន្តហេតុការណ៍ក្នុងរឿងមួយ និងរបៀបផ្លាស់ប្តូរប្រភេទភាសាដែលពួកគេប្រើ ដែលអាស្រ័យលើគោលបំណងរបស់រឿង និងអ្នកស្តាប់រឿង។ ប្រសិនបើពួកគេមានការពិបាកក្នុងការសរសេរ មនុស្សម្នាក់ (ដូចជាកុមារដែលមានអាយុច្រើនជាង ឬមាតា ឬបិតា) អាចសរសេររឿងតាមកុមារនិយាយ។ ដូច្នេះ កុមារអាចពន្យល់បង្ហាញរឿងផ្ទាល់របស់ខ្លួនបាន។
- បង្កើតបរិយាកាស "សរសេរ និងអាន" របស់ថ្នាក់រៀនមួយ ដោយការធ្វើជាផ្នាំងបដានូវគំនូសតាងអក្ខរក្រម រូបភាព បញ្ជីពាក្យ និងព័ត៌មានផ្សេងទៀត។ ព័ត៌មានទាំងនេះអាចបាន ពីរឿងនានាមេរៀន ឬការងារផ្ទាល់របស់កុមារ។ អ្នកក៏អាចដាក់ស្លាកលើវត្ថុនានាជុំវិញបន្ទប់។ ប្រសិនបើមានផ្ទៃជញ្ជាំងតូច អ្នកអាចព្យួរអក្សរ ពាក្យ និងរូបភាពនានាលើខ្សែមួយនៅក្នុងបន្ទប់។ ប្រសិនបើ

មានការសែតក្នុងស្រុក ចំណងជើងអត្ថបទ និងរូបភាពអាចដាក់តាំងបង្ហាញ ដើម្បីពន្យល់ពីការប្រើភាសាខុសៗគ្នា។

- *បញ្ចូលការអនុវត្តភាសាទៅក្នុងមុខវិជ្ជាដទៃទៀត។ ឧទាហរណ៍ នៅពេលកុមារបានអភិវឌ្ឍជំនាញផ្នែកសរសេរ ពួកគេអាចសរសេររៀបរាប់ពីសត្វល្អិត ឬរុក្ខជាតិ ឬប្រភពទឹកស្អាតសម្រាប់ថ្នាក់វិទ្យាសាស្ត្រ។ ចូរឱ្យកុមារសរសេរពីបញ្ហានៃរឿងមួយ សម្រាប់គ្នាទៅវិញទៅមកក្នុងមុខវិជ្ជាគណិតវិទ្យា ឬពួកគេអាចសរសេរពីវិធីដោះស្រាយបញ្ហាវិទ្យាសាស្ត្រមួយ ឬឆ្លើយសំណួរមួយ។*
- *ធ្វើការណែនាំអ្នករៀនអាយុច្រើនក្នុងពេលពិភាក្សាជាក្រុមតូច។ ព្រមទាំងសម្លឿរឿងនានាដែលបាន ពីថ្នាក់ទៅជារឿងល្ខោននាដកម្ម ដើម្បីផ្តល់ឱកាសដល់ពួកគេព្រាងគំនិតនានា ដោយប្រើភាសាសរសេរតាមគេយល់។ ដោយការដើរតួសម្តែងបង្ហាញពីស្ថានភាពនានារបស់សាលា ឬដោយការ ប្រើអាយ៉ង ដើម្បីផ្តោតលើបញ្ហាសង្គម ដូចជាការសម្លុតគំរាម កុមារនឹងអភិវឌ្ឍ "សុខុមាលភាព ផ្នែកអារម្មណ៍" របស់ខ្លួន ហើយ អភិវឌ្ឍវិធីគ្រប់គ្រងស្ថានភាពពិបាកៗបានល្អ។*
- *ចូរផ្តល់ឱកាសឱ្យសិស្សសរសេរ ចែករំលែកអ្វីដែលបានសរសេរ ដោយអាន ឮៗ និងនិយាយពីការសរសេររបស់ពួកគេ។ អ្នកសរសេរទាំងអស់ទទួលប្រយោជន៍ពីការអាន ការងាររបស់ខ្លួនចំពោះខ្លួនឯងផ្ទាល់ នៅពេលពួកគេកំពុងធ្វើការលើការងារនោះ ព្រមទាំងចំពោះអ្នកដទៃទៀត។ ការធ្វើការជា "ការសរសេរជាគូ" អាចជួយសិស្សរបស់អ្នកសាកល្បងគំនិតរបស់គេ និងសម្រេចចិត្តក្នុងការប្រើវាក្យសព្ទណាដែលល្អបំផុត។ កុមារទាំងអស់ លើកលែងអ្នកដែលសរសេរលើកដំបូងបំផុត អាចទទួលប្រយោជន៍ពីក្រុមពិនិត្យជ្វើងផ្ទាត់ដែលជាមិត្តរួមថ្នាក់ ដែលក្នុងនោះ ពួកគេអានការងាររបស់ខ្លួន ចែករំលែកការទិតៀនដែលមានន័យស្តាបនា និងកែលំអឡើងវិញ។*

ដំបូន្មានសម្រាប់ការបង្រៀនសរសេរ

ការបង្រៀនសរសេរមានសារៈសំខាន់ ប៉ុន្តែវាមានការលំបាក។ ប្រសិនបើអ្នកផ្តល់ឱកាសដល់សិស្សឱ្យសរសេរបានញឹកញាប់ និងឱកាសកែលំអ និងជម្រើសការសរសេររបស់ពួកគេ អ្នកនឹងបង្កើតគ្រឹះសម្រាប់ការសរសេរប្រកបដោយជោគជ័យ។ ជាបឋម ចូរធ្វើឱ្យការសរសេរមានខ្លឹមសារពេញលេញ។ អ្នកសរសេរវ័យក្មេងទាំងកុមារា និងកុមារីអាចសម្តែងចេញដោយខ្លួនឯងនូវប្រធានបទនានា ដែលមានសារៈសំខាន់ចំពោះជីវិតរបស់ពួកគេ។ ប្រធានបទទាំងនេះអាចរួមមាន គ្រួសាររបស់ពួកគេ ហេតុការណ៍ពិសេសៗនៅក្នុងសហគមន៍ ប្រធានបទនានាក្នុងមុខវិជ្ជាសិក្សាសង្គមជាដើម។

ការសរសេររបស់កុមារគួរមានគោលបំណង និងសវនកម្មាស់លាស់មួយ។ កុមារតែងតែសរសេរតាមការប្រើរបស់គ្រូ ប៉ុន្តែក្នុងជីវភាពរស់នៅ យើងប្រើការសរសេរសម្រាប់អ្នកស្តាប់ជាច្រើនប្រភេទ។ យើងត្រូវការផ្លាស់ប្តូររបៀបសរសេររបស់យើង ដើម្បីតម្រូវតាមគោលបំណង និងអ្នកស្តាប់។ ឧទាហរណ៍ បញ្ជី

លិខិត ឬសារខ្លីៗសម្រាប់ខ្លួនយើង ផ្ទាំងបដា ឬរឿងណាមួយសម្រាប់កុមារតូចៗ។ នេះគឺជាការសរសេរ ដែលមានខ្លឹមសារពេញលេញ។ ខាងក្រោមនេះជាដំបូន្មានមួយចំនួនផ្សេងទៀត :

- ស្នើកុមារសរសេរដោយសេរីដោយគ្មានការបារម្ភអំពីភាពត្រឹមត្រូវ។ កុមារដែលទើបរៀនសរសេរអាចបង្កើតសំណង់ប្រយោគ និងឃ្លាបាន ទោះបីជាពួកគេប្រើការប្រកបអក្សរតាមការស្រមើស្រមៃ និងវណ្ណយុត្តិចំឡែកៗក៏ដោយ។ ការប្រកបអក្សរដែលមានលក្ខណៈស្រមៃ និងច្នៃប្រឌិតគឺជាផ្នែកធម្មតាមួយនៃការអភិវឌ្ឍការសរសេរ។ កុមារកំពុង"ស្តាប់ឮ" និងកំពុងព្យាយាមសម្រេចចិត្តលើលក្ខណៈអ្វីមួយរបស់ពាក្យ។ ដំបូង ពួកគេត្រូវការប្រើយុទ្ធសាស្ត្រផ្ទាល់ខ្លួន។ កុមារត្រូវការព្យាយាម និងដោះស្រាយការប្រកបអក្សរដោយផ្ទាល់ខ្លួន។ ទន្ទឹមគ្នានេះដែរ កុមារគួររៀនពីវិធីចងចាំ និងវិធីប្រើវចនានុក្រម។
- ពាក្យទាំងឡាយគួររៀនក្នុងបរិបទដែលមានរូបភាពរបស់ពាក្យ ដូចជា "ផ្ទះ ឬចាល់មួយ" ឬដែលប្រើពាក្យក្នុងឃ្លាមួយដូចជា "ផ្ទះពណ៌លឿង" ឬ"ចាល់ពណ៌ស្វាយ"។
- អ្នកអាចបង្រៀនកុមារក្មេងៗរបស់អ្នកប្រកបអក្សរក្នុងរបៀបជាច្រើន ដូចជា ការប្រកបអក្សរឮៗ។ ល្បែងប្រកបអក្សរ និងចំណោទពាក្យខ្វែង។ នៅពេលកុមារសរសេរ និងមានការបារម្ភខ្លាំងពេកជាមួយការប្រកប និងការប្រើវណ្ណយុត្តត្រឹមត្រូវ កុមារអាចមានការពិបាកក្នុងការបង្កើតទំនាក់ទំនងឱ្យកាន់តែស៊ីជម្រៅចំពោះភាសា។ ជំនួសការប្រកបឱ្យបានត្រឹមត្រូវ អ្នកត្រូវអង្កេតមើល និងកត់ត្រាបញ្ហាការសរសេររបស់កុមារ (មិនមែនកំហុសនៃការប្រកបអក្សរ ឬវណ្ណយុត្តិឡើយ)។ បន្ទាប់មក អ្នកអាចវិភាគបញ្ហាពិបាករបស់កុមារ និងផ្តល់ឱ្យកុមារនូវការគាំទ្រ ជាក់លាក់ក្នុងវិស័យនោះ ដូចជា វិធីប្រើគុណនាមឱ្យមានប្រសិទ្ធភាព ឬបង្កើតការប្រៀបធៀបដែលមានខ្លឹមសារពេញលេញ (សទិសសព្ទ)។

គោលដៅនៃការសរសេរគឺត្រូវធ្វើការច្រៀស្រ័យទាក់ទងគំនិតមួយប្រកបដោយប្រសិទ្ធភាព ដើម្បីឱ្យអ្នករាល់គ្នាយល់ពីគំនិតនេះ។ វិធានសំខាន់នៃការសរសេរសម្រាប់គ្រូបង្រៀន គឺត្រូវបង្កើតឱកាសសម្រាប់ច្រៀស្រ័យទាក់ទងប្រកបដោយខ្លឹមសារ។ ខាងក្រោមនេះជា វិធីខ្លះៗដើម្បីបង្កើតឱកាសដូច្នេះ :

- ស្នើអ្នករៀនក្មេងៗនិយាយរឿងនានាដើម្បីឱ្យ "អ្នកសរសេរម្នាក់" អាចជារូបអ្នក គ្រូបង្រៀន អ្នកស្ម័គ្រចិត្តម្នាក់ មកពីសហគមន៍ ឬសិស្សអាយុច្រើនម្នាក់សរសេរតាម។ (ចូរបំប្លែកអ្នករៀនឱ្យមានការអត់ធ្មត់ ហើយនិយាយមួយៗទៅកាន់មនុស្សដែលកំពុងសរសេរ)។ បន្ទាប់មក អ្នកនិយាយរឿងក្មេងៗទាំងនេះអាចពន្យល់បង្ហាញរឿងរបស់ខ្លួន។ លំហាត់នេះនឹងបង្កើតស្ពានទំនាក់ទំនងមួយរវាងការនិយាយ និងការសរសេរ។ លំហាត់នេះក៏ជាសកម្មភាពមួយ ដែលយើងអាចប្រើជង់ដែរដើម្បីជួយកុមារដែលមើលឃើញ ឱ្យរៀនពីកុមារដែលមិនអាចមើលឃើញ។
- ស្នើអ្នករៀនក្មេងៗសរសេរអំពីជីវិតរស់នៅ និងបទពិសោធរបស់ពួកគេ។ ទោះវាជាការទៅសួរសុខទុក្ខជីដូនជីតារបស់ពួកគេ ឬបទពិសោធណាមួយនៅក្រៅថ្នាក់រៀន ក៏ដោយ អ្នកសរសេរក្មេងៗ

អាចសរសេរបាន ល្អបំផុត នៅពេលពួកគេសរសេរអំពីអ្វីមួយដែលពួកគេស្គាល់ច្បាស់។

- ស្នើអ្នកសរសេរក្មេងៗចូលរួមក្នុងការសរសេរអ្វីមួយខ្លី។ សម្រាប់កុមារក្រោមអាយុ ៨ ឬ ៩ ឆ្នាំ ពួកគេអាចធុញទ្រាន់ក្នុងការកាន់ខ្មៅដៃ ឬដីស សរសេរអក្សរ ក្នុងពេលដែលចង់ពន្យល់ខ្លឹមសារ ដែលគេចង់និយាយ និងសរសេរ។ ជារឿយៗ ការសរសេរយ:ពេលខ្លីៗតែងតែមានប្រសិទ្ធភាព ជាងការព្យាយាមសរសេរយ:ពេលវែង។

- លើកទឹកចិត្តអ្នកសរសេរក្មេងៗឱ្យរក្សាទិនានុប្បវត្ត ឬកំណត់ហេតុប្រចាំថ្ងៃ ដើម្បីជួយពួកគេឱ្យ ស្គាបនាគំនិតរបស់ខ្លួន។ ការសរសេរតែងសេចក្តីមានសារ:សំខាន់ណាស់ ពីព្រោះវាមិនមាន លក្ខណ:សាធារណ:ពេក។ សម្រាប់អ្នកសរសេរ វាអាចជាឱកាសមួយដើម្បីសរសេររៀបដោយ សេរីមួយ។ ដោយមូលហេតុនេះ ប្រសិនបើអ្នកមានផែនការប្រមូល និងត្រួតពិនិត្យឡើងវិញនូវ តែងសេចក្តីរបស់កុមារ អ្នកត្រូវច្បាប់ពួកគេឱ្យដឹងជាមុន។

- ផ្តល់ដល់អ្នកសរសេរនូវឱកាសកែប្រែការសរសេររបស់ពួកគេ។ អ្នកសរសេរជាអាជីពអាច ចំណាយពេលរហូតដល់ ៨៥% ដើម្បីកែប្រែពង្រាងលើកដំបូងរបស់ខ្លួន។ ក្នុងកាងារសរសេរក្នុង ថ្នាក់ វាមានសារ:សំខាន់ណាស់ ដែលត្រូវលើកទឹកចិត្តសិស្សឱ្យសរសេរដោយសេរី និងដោយពាក្យ ផ្ទាល់របស់ខ្លួន។ ពួកគេគួរព្យាយាមគ្របដណ្តប់គំនិតទាងអស់របស់ខ្លួនលើប្រធានបទមួយ។ (ការកែប្រែមានសារ:សំខាន់ណាស់សម្រាប់សិស្សអាយុលើស ៨ ឬ ៩ ឆ្នាំ ដែលចាប់ផ្តើមសរសេរ កាន់តែមានលក្ខណ:ធម្មតាឡើង)។ ត្រូវផ្តល់ការពន្យល់លើគំនិត និងការបន្តហេតុការណ៍នៃរឿង របស់ពួកគេ។ ត្រូវបង្ហាញពួកគេពីវិធីប្រើវចនានុក្រម ដើម្បីឱ្យពួកគេអាចរៀនប្រកបបាន ត្រឹមត្រូវ ឬជាមួយដៃគូប្រកបអក្សរម្នាក់។

- ផ្តល់ឱកាសឱ្យមានការសរសេរដែលមានលក្ខណ:ស្រមើស្រមៃ នៅពេលអ្នកសរសេរអាយុច្រើន សរសេរពីវិធី ដែលពួកគេដោះស្រាយបញ្ហាវិទ្យាសាស្ត្រ ឬគណិតវិទ្យាមួយ ឬពីរបៀបដែល អាកាសធាតុប៉ះពាល់លើជីវភាពរស់នៅរបស់សមាជិកគ្រួសារខ្លួន ពួកគេកំពុងប្រើការសរសេរ ជាឧបករណ៍ដ៏មានប្រសិទ្ធភាពមួយ។

- ត្រូវផ្សព្វផ្សាយការសរសេរដើម្បីធ្វើឱ្យវាមានខ្លឹមសារពេញលេញ។ ការសរសេររបស់កុមារ និងកុមារីអាចត្រូវ បានផ្សព្វផ្សាយបិទលើជញ្ជាំងថ្នាក់រៀន ឬធ្វើទៅជាសៀវភៅធម្មតា។។ ការសរសេរនេះអាចត្រូវបានចែករំលែកជាមួយអ្នករៀនក្នុងថ្នាក់ដទៃទៀត ជាមួយគ្រួសារ និង សហគមន៍ និងជាមួយមិត្តភក្តិ។ នៅពេលអ្នកសិក្សា សរសេរលិខិតទៅអ្នកដឹកនាំសហគមន៍ ម្នាក់ ឬអ្នកមកទស្សនាម្នាក់ ទោះជាដើម្បីសួរសំណួរ ឬដើម្បីផ្តល់យោបល់ ឬសម្តែងចេញពីការ វាយតម្លៃសម្រាប់ការមកទស្សនា ពួកគេមានឱកាសសរសេរពីអ្វីៗដែលមាន សារ:សំខាន់ចំពោះ ពួកគេ និងដែលមានគោលបំណងពិតប្រាកដមួយ និងសវនាការមួយ។



សកម្មភាពឆ្លុះបញ្ចាំង : ការបង្រៀនភាសាប្រកបដោយខ្លឹមសារ

ចូរគិតអំពីការអនុវត្តការបង្រៀនថ្មីៗរបស់អ្នក និងអំពីកុមារក្នុងថ្នាក់របស់អ្នក។

- *តើមធ្យោបាយនៃការប្រើភាសាណាខ្លះទទួលបានការយកចិត្តទុកដាក់តិចតួចក្នុងថ្នាក់របស់អ្នក? តើអ្នកអាចកែលំអស្ថានភាពនេះដូចម្តេច?*
- *តើអ្នកបានផ្តល់ឱកាសសម្រាប់កុមារជជែកគ្នាជាគូ និងពិភាក្សាជាក្រុមមានគ្នា ៤ នាក់?*
- *តើអ្នកអាចធ្វើឱ្យការរៀន និងការប្រើភាសាកាន់តែគួរឱ្យចាប់អារម្មណ៍ មានការទាក់ទង និងមានខ្លឹមសារដោយរបៀបណា?*

អង្គការក្រៅរដ្ឋាភិបាលមួយនៅក្នុងប្រទេសបង់ក្លាដេស ឈ្មោះ រង្វើការងារសម្រាប់ជីវភាពកាន់តែប្រសើរឡើង បានរៀបចំឱ្យសិស្សពិភាក្សាអំពីបញ្ហានានាដែលកុមារយល់ថា មានសារៈសំខាន់ និងកំពុងប៉ះពាល់ជីវភាពរបស់ពួកគេ។ ពួកគេរៀនអំពីវិធីដើម្បី ពិភាក្សា ពួកគេអាចរកឃើញបញ្ហានានា ពួកអាចសរសេរអំពីបញ្ហាទាំងនោះ (ឬគូរគំនូរ ឬធ្វើផ្ទាំងបដានានា) ហើយពួកគេជូនព័ត៌មានដល់អ្នកដទៃ កុមារក្មេងៗក្នុងសាលា។ ជួនកាល មាតាបិតាចូលរួមក្នុងការពិភាក្សា ឬគ្រូបង្រៀន ឬសាលាពិភាក្សាគ្នាទៅវិញទៅមក។ សិស្សមួយក្រុមអាចធ្វើឱ្យគ្រូបង្រៀនឈប់ជក់បារីក្នុងសាលា និងក្នុងថ្នាក់រៀនបាន!។

ផ្អែកលើអត្ថបទនៅក្នុង http://www.workingforbetterlife.org/index.htm



គោលទី ៤.៤
តើយើងបានរៀនពីបទពិសោធអ្វីខ្លះនាពេលកន្លងមក?

ការសិក្សាអំពីសកម្មភាពរៀន និងអ្នករៀន

- កុមារទាំងអស់អាចរៀន ប៉ុន្តែពួកគេរៀន ក្នុងវិធីផ្សេងៗគ្នា និងក្នុងកម្រិតផ្សេងៗគ្នា។
- ជាគ្រូបង្រៀន យើងត្រូវការផ្តល់ឱកាសសិក្សាផ្សេងៗសម្រាប់កុមារ។
- កុមាររៀនដោយភ្ជាប់ព័ត៌មានថ្មីៗជាមួយអ្វីដែលបានដឹងរួចហើយ ដែលហៅថា សំណង់ខួរក្បាល។
- យើងក៏ត្រូវជួយមាតាបិតា និងអាណាព្យាបាលដទៃទៀត ដើម្បីគាំទ្រការសិក្សារបស់កុមារ ដើម្បីឱ្យកុមារដឹងពីរបៀប ផ្សារភ្ជាប់អ្វីដែលពួកគេរៀនក្នុងថ្នាក់ជាមួយនឹងជីវភាពនៅផ្ទះរបស់ពួកគេ ព្រមទាំងដឹងពីវិធីផ្សារភ្ជាប់អ្វីដែលពួកគេ រៀននៅផ្ទះជាមួយអ្វីដែលពួកគេកំពុងរៀនក្នុងថ្នាក់។
- ការនិយាយ និងការសួររួមគ្នា (ទំនាក់ទំនងសង្គម) ក៏អាចលើកកម្ពស់ការរៀនសូត្រផងដែរ។ ហេតុដូច្នេះហើយ ការងារជាគូ និងជាក្រុមតូចៗមានសារៈសំខាន់ណាស់ ប្រសិនបើរៀបចំបានល្អ។

នៅពេលដឹងថែមទៀតពីវិធីដែលកុមាររៀនបានល្អ យើងអាចពិនិត្យឡើងវិញនូវឧបសគ្គមួយចំនួនចំពោះការសិក្សារបស់កុមារ។ ឧបសគ្គចម្បងមួយគឺ ការគោរពខ្លួនឯងតិចតួច។ ការគោរពខ្លួនឯងតិចតួចកាត់បន្ថយនូវការជំរុញទឹកចិត្តរបស់កុមារក្នុងការរៀន ហើយអាចមានលទ្ធផលមិនល្អលើការអភិវឌ្ឍការយល់ដឹង និងសង្គម។ ការគោរពខ្លួនឯងអាចត្រូវបានជំរុញតាមរយៈបរិយាកាសសិក្សាដែលមានការកែលំអមួយ។ បរិយាកាសនេះ ជាបរិយាកាសមួយដែលនឹងផ្តល់ការសរសើរសមស្របមួយពេលកុមារទទួលបានជោគជ័យ ជាបរិយាកាស ដែលមានការលើកទឹកចិត្តការងារជាក្រុមមេត្រី និងមានកិច្ចសហការគ្នា ជាបរិយាកាសដែលកុមារដឹងថា ពួកគេត្រូវបានគេយកចិត្តទុកដាក់ និងជាបរិយាកាសដែលនឹងគាំទ្រកុមារនៅពេលកំពុងរៀន។

ការដោះស្រាយនានាភាពក្នុងថ្នាក់រៀន

ក្នុងសៀវភៅនេះ យើងបានរិះរកមធ្យោបាយនានា ដើម្បីធ្វើឱ្យកម្មវិធីសិក្សាអាចឈានដល់ និងទាក់ទងចំពោះកុមារទាំងអស់ស្តីពីអ្វីដែលអ្នកបង្រៀន (ខ្លឹមសារ) វិធីដែលអ្នកបង្រៀន និងវិធីដែលកុមាររៀនបានល្អ (ដំណើរការ) និងបរិយាកាសដែលកុមារកំពុងរស់នៅ និងកំពុងរៀន។ នៅពេលរៀបចំកិច្ចតែងការបង្រៀន ចាំបាច់ត្រូវគិតអំពីកត្តាចម្បងបីគឺ **ខ្លឹមសារមេរៀន ដំណើរការ** (សកម្មភាពរៀន និងបង្រៀន) និង **បរិយាកាស**។

យើងក៏ពិនិត្យមើល **អ្វីៗដែលគំរាមកំហែង** ចំពោះការសិក្សារបស់កុមារ ជាពិសេសការសម្គុតគំរាម។ យើងត្រូវចងចាំថា :

- អ្វីៗដែលគំរាមកំហែង និងការភ័យខ្លាចអ្នកដទៃ (គ្រូបង្រៀន មាតាបិតា និងកុមារដទៃទៀត) អាចរារាំងកុមារមិនឱ្យរៀន។
- ភាពខុសៗគ្នា ដូចជា ជនជាតិភាគតិច សាសនា និងវណ្ណៈសង្គម អាចត្រូវបានប្រើដោយអ្នកសម្គុតគំរាមគេ ដើម្បីធ្វើយុត្តិកម្មការសម្គុតគំរាមរបស់ខ្លួន។
- ការអង្កេតមើល គឺជាជំនាញសំខាន់មួយសម្រាប់គ្រូបង្រៀន ហើយយើងត្រូវការអង្កេតមើលកុមារក្នុងអំឡុងពេល កំពុងលេង និងក្នុងថ្នាក់រៀន ដើម្បីរកឱ្យឃើញទំនាក់ទំនងក្នុងសង្គមរដ៏តិចតួចរវាងកុមារទាំងឡាយ ដែលអាចគំរាមកំហែងការសិក្សារបស់ពួកគេ ហើយ
- នៅពេលគ្រូបង្រៀនវាយតម្លៃស្ថានភាពរបស់កុមារ គ្រូត្រូវសកម្មភាព និងមានចន្លុះវិជ្ជមាន ដើម្បីទប់ស្កាត់ឱកាសសម្គុតគំរាម ប្រតិកម្មអវិជ្ជមានចំពោះស្ថានភាពមួយបន្ទាប់ពីបានកើតឡើងរួចហើយ។

ភាពលំអៀង និងការរើសអើង ក៏ជាឧបសគ្គចំពោះការសិក្សារបស់កុមារផងដែរ។ ឧបសគ្គទាំងនេះអាចធ្ងន់បញ្ហាំង ដោយអចេតនា ក្នុងកម្មវិធីសិក្សា និងសម្ភារសិក្សារបស់យើង។ ជាពិសេស នេះជាករណីសម្រាប់កុមារដែលមានប្រវត្តិ និងសមត្ថភាពខុសគេ។

យើងបានរាប់បញ្ចូលបញ្ជីត្រួតពិនិត្យមួយសម្រាប់វិភាគសៀវភៅអត្ថបទ ដើម្បីរកភាពលំអៀង។ តើអ្នកអាចត្រួតពិនិត្យឡើងវិញ នូវសៀវភៅអត្ថបទ និងសម្ភារសិក្សារបស់អ្នក ដើម្បីរកភាពលំអៀងឬការរើសអើងដោយអចេតនា? តើសកម្មភាពអ្វីដែលអ្នកនឹងធ្វើ ពេលអ្នករកឃើញភាពលំអៀងនេះ? ឧទាហរណ៍ តើអ្នកអាចផ្តល់គំនូរលំអិតថ្មីៗឬទេ?

កុមារដែលមានបញ្ហាលំបាកក្នុងការសិក្សាអាចត្រូវបានផ្តល់បរិយាកាសមួយសម្រាប់ឱ្យពួកគេរៀនពីវិធីដួយខ្លួនឯង។ តើអ្នកស្គាល់កុមារដែលមានបញ្ហាក្នុងការសិក្សាទាំងនោះឬទេ? មូលហេតុអ្វីបានជាមានបញ្ហាលំបាកក្នុងការសិក្សា? តើសកម្មភាពអ្វីដែលអ្នកនឹងធ្វើដើម្បីជួយកុមារទាំងនោះ? កុមារខ្លះត្រូវការទទួលការយល់ដឹង និងការគាំទ្រពីកុមារដទៃទៀត ប៉ុន្តែគោលដៅ គឺត្រូវផ្តល់សកម្មភាពសិក្សាដែលពួកគេធ្វើបានដោយគ្មានការសុំជំនួយពីអ្នកដទៃ។

ក្នុងបណ្តាប្រទេសជាច្រើន កុមារដែលផ្ទុកមេរោគអេដស៍/ជំងឺអេដស៍ ឬកុមារដែលរស់នៅក្នុងគ្រួសារដែលមានសមាជិកម្នាក់មានមេរោគអេដស៍/ជំងឺអេដស៍ អាចទទួលរងនូវការរើសអើង។ តើអ្នកស្គាល់ច្បាស់ឬទេពីមេរោគអេដស៍/ជំងឺអេដស៍ ក្នុងសហគមន៍របស់អ្នក? តើអ្នកបានពិភាក្សា បញ្ហាសំខាន់ៗ ដូចជាមេរោគអេដស៍/ជំងឺអេដស៍ ជាមួយគ្រូបង្រៀនដទៃទៀតឬទេ?

ការធ្វើឱ្យការសិក្សាមានខ្លឹមសារសម្រាប់ទាំងអស់គ្នា

គំនិតសំខាន់នៅក្នុងសៀវភៅនេះ គឺវិធីដើម្បីធ្វើឱ្យការសិក្សាមានខ្លឹមសារថែមទៀតសម្រាប់កុមារទាំងអស់។ យើងត្រូវការធ្វើឱ្យការសិក្សា មានខ្លឹមសារ ដើម្បីឱ្យកុមារទាំងអស់ចង់មកសាលា ត្រូវបានជំរុញទឹកចិត្តឱ្យរៀន ហើយនឹងដឹងថា អ្វីដែលពួកគេរៀនមានការទាក់ទងនឹង ពួកគេ។

អ្នកនឹងត្រូវផ្សារភ្ជាប់បញ្ហានានាក្នុងសហគមន៍របស់អ្នកជាមួយកម្មវិធីសិក្សា និងប្រធានបទ ដែលអ្នកនឹងបង្រៀន។ ត្រូវឱ្យកុមារ នាំមកថ្នាក់រៀននូវចំណេះដឹងដែលពួកគេ និងមាតាបិតាពួកគេបានចេះ។

សកម្មភាពដែលមានខ្លឹមសាររួមបញ្ចូលការងារជាគូ និងជាក្រុមតូច ។នៅក្រៅថ្នាក់រៀនដែលជាកន្លែងកុមារអាចស្វែងរក និង យល់ពីបរិយាកាសជុំវិញរបស់ពួកគេ។

ការធ្វើឱ្យការសិក្សាមានខ្លឹមសារអាចត្រូវការកែសម្រួលកម្មវិធីសិក្សាជាតិ ដើម្បីឱ្យស៊ីគ្នានឹងបរិបទក្នុងស្រុកនៃសាលារបស់អ្នក។ បញ្ហានេះគេអាចធ្វើបានប្រកបដោយប្រសិទ្ធភាពតាមរយៈការធ្វើការងារជាមួយគ្រូបង្រៀនក្នុងស្រុកផ្សេង ។ទៀត។

តើអ្នកអាចសម្រួលឧទាហរណ៍ក្នុងសៀវភៅអត្ថបទ និងសកម្មភាពនានា ដើម្បីធ្វើឱ្យទាក់ទងប្រសើរឡើង ជាមួយតំបន់ក្នុងស្រុករបស់អ្នកឬទេ?

មុខវិជ្ជាសំខាន់ ។នៅសាលាមាន គណិតវិទ្យា វិទ្យាសាស្ត្រ និងភាសា។ អ្នកអាចជំរុញទឹកចិត្តកុមារឱ្យចង់រៀនមុខវិជ្ជាទាំងនេះ ដោយការអភិវឌ្ឍ និងការលេងល្បែងកំសាន្តនានា។ ល្បែងគណិតវិទ្យា និងភាសាអាចធ្វើឱ្យការសិក្សាមានលក្ខណៈសប្បាយ ព្រមទាំង មានខ្លឹមសារ។ ប្រសិនបើអ្នកអាចធ្វើការជាមួយគ្រូបង្រៀន ឬមាតាបិតាមួយក្រុម អ្នកអាចអភិវឌ្ឍល្បែងជាច្រើនសម្រាប់ប្រើក្នុងថ្នាក់រៀន។

*គេអាចធ្វើឱ្យមុខវិជ្ជា **គណិតវិទ្យា** កាន់តែមានខ្លឹមសារ និងមានសារៈសំខាន់ឡើង ដោយប្រើសម្ភារអនុវត្តជាក់ស្តែងមួយចំនួន និងការដោះស្រាយបញ្ហាដែលមានលក្ខណៈទូទៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃ។ បញ្ហាទាំងនេះអាចទាក់ទងនឹងការវាស់វែង និងការគណនាជុំវិញសាលា នៅផ្ទះ ឬនៅទីផ្សារ។*

*ក្នុងមុខវិជ្ជា **វិទ្យាសាស្ត្រ** បទពិសោធជាក់ស្តែងអាចជួយកុមារយល់ពីគំនិតវិទ្យាសាស្ត្រ។ ក្នុងការសិក្សាពីវិទ្យាសាស្ត្រ សិស្សអាចហ៊ឺកហាត់ជំនាញអង្កេតមើលរបស់ខ្លួន។ ពួកគេអាចត្រូវបានលើកទឹកចិត្តឱ្យសួរសំណួរនានា និងរៀបចំការពិសោធ ដើម្បីរុករកចម្លើយផ្សេង ។ចំពោះសំណួរផ្ទាល់របស់ខ្លួន។*

ដោយការអង្កេតលើតំបន់ក្នុងស្រុករបស់ពួកគេ កុមារអាចត្រូវបានណែនាំឱ្យស្គាល់ពីតួនាទីរបស់វិទ្យាសាស្ត្រនៅក្នុងសង្គម។ កុមារអាចស្វែងរកឃើញដំណោះស្រាយដ៏មានប្រយោជន៍ចំពោះបញ្ហាសហគមន៍នៅពេលកំពុងរៀនពីគំនិត និងជំនាញវិទ្យាសាស្ត្រដ៏មានតម្លៃ។

តើអ្នកអាចរកពេលវេលាដើម្បីឱ្យកុមារធ្វើការអង្កេតលើបញ្ហានានា ជាជាងរៀនតែពីចម្លើយនៅក្នុងសៀវភៅអត្ថបទឬទេ?

យើងបានពិចារណាវិធីសាស្ត្របង្រៀនផ្សេងៗ ដូចជា "ធ្វើ និយាយ និងកត់ត្រា" និង "គិត ធ្វើជាគូ ចែករំលែក"។ វិធីសាស្ត្រទាំងនេះជួយកុមារបកស្រាយគំនិតរបស់ពួកគេរួមគ្នា កែលំអការយល់ដឹង និង បង្កើនការចូលរួមរបស់កុមារក្នុងសកម្មភាពរៀននៅថ្នាក់រៀន។

តើអ្នកអាចប្រើវិធីសាស្ត្របង្រៀនផ្សេងៗគ្នាក្នុងមុខវិជ្ជាវិទ្យាសាស្ត្រ និងគណិតវិទ្យាឬទេ? តើអ្នកមាន សម្ភារអនុវត្តក្នុងថ្នាក់ ដើម្បីឱ្យកុមារស្រាវជ្រាវពីគំនិតវិទ្យាសាស្ត្រ និងគណិតវិទ្យា ឬទេ?

ភាសា មិនត្រឹមតែជាមុខវិជ្ជាមួយប៉ុណ្ណោះទេ វាគឺជាជំនាញមួយដែលកុមារត្រូវការចូលរួមក្នុង កម្មវិធីសិក្សា និងដើម្បីជួយឱ្យកុមារចេះគិត និងរៀន។ កុមារត្រូវការនិយាយ ស្តាប់ អាន និងសរសេរក្នុង ស្ថានភាពជារៀងច្បើន។ យើងអាចអភិវឌ្ឍជំនាញទាំងនេះនៅគ្រប់មុខវិជ្ជាទាំងអស់។

តើអ្នកអាចធ្វើឱ្យការរៀនភាសាមានខ្លឹមសារតាមរយៈការផ្តល់ឱកាសរៀនភាសាផ្នែកវិទ្យាសាស្ត្រ និងគណិតវិទ្យាឬទេ?

តើអ្នកអាចរៀនថែមទៀតនៅកន្លែងណា?

ឯកសារយោង និង Websites ខាងក្រោមគឺជាប្រភពធនធានដ៏មានតម្លៃសម្រាប់បង្កើតថ្នាក់រៀន ដែលបញ្ចូលគ្រប់សមាសភាព។

ឯកសារយោង

Baily D, Hawes H and Bonati B. (1994) Child-to-Child: A Resource Book. Part 2: The Child-to-Child Activity Sheets. London: The Child-to-Child Trust. This is an excellent resource for activities that children can undertake in terms of understanding child growth and development, nutrition, personal and community hygiene, safety, recognizing and helping those with disabilities, disease prevention, safe lifestyles and understanding children in difficult circumstances.

Council on Interracial Books for Children. (1980) Guidelines for Selecting Bias-Free Textbooks and Storybooks. New York.
O'Gara, C and Kendall N. (1996) Beyond Enrollment: A Handbook for Improving Girls' Experiences in Primary Classrooms. Washington, DC: Creative Associates International, Inc. for the ABEL 2 Project, US Agency for International Development.

Sell A and Power L. (2003) Active Learning: A Self-Training Module. Save the Children (UK), London

Sharp S and Smith PK (Eds.). (1994) Tackling Bullying in Your School: A Practical Handbook for Teachers. Routledge.

Swanson HL. (1999). Instructional components that predict treatment outcomes for students with learning disabilities: Support for a combined strategy and direct instruction model. Learning Disabilities Research and Practice, 14 (3), 129-140.

UNESCO. Guides for Special Education. Paris.

UNESCO (1993) Teacher Education Resource Pack: Special Needs in the Classroom. Paris.

UNESCO (2001) Understanding and Responding to Children's Needs in Inclusive Classrooms: A Guide for Teachers. Paris.

UNESCO Asia and Pacific Regional Bureau for Education (2003) Gender in Education Network in Asia (GENIA) A Toolkit for promoting Gender Equality in Education. Bangkok.

Web Sites

Bullying. No Way!
http://www.bullyingnoway.com.au

BULLYING-the no-blame approach.
http://www.luckyduck.co.uk/approach/NoBlame-HowItWorks.pdf

Bullying and gender.
http://www.bullyingnoway.com.au/issues/gender.html

Countering discrimination. http://www.esrnational.org/sp/we/end/stereotypes.htm#prejudicesituations

Diversity and disability. Inclusive Education Training in Cambodia.
http://www.eenet.org.uk/key_issues/teached/cambodia_contents.shtml

Meaningful, engaged learning.
http://www.ncrel.org/sdrs/engaged.htm

Multiple intelligences. Pathways to learning.
http://www.thomasarmstrong.com/multiple_intelligences.htm.
http://www.educationalvoyage.com/multiintell.html

Partnership on Sustainable Strategies for Girls' Education.
http://www.girlseducation.org

UNICEF Teachers Talking about Learning.
http://www.unicef.org/teachers/

Working for Better Life.
http://www.workingforbetterlife.org/index.htm

ក : សម្ភារៈគ្រូបង្រៀន

កម្រងសៀវភៅលេខ : ៥

គ្រប់គ្រងថ្នាក់រៀនកុមារមេត្រី ដោយបញ្ចូលគ្រប់សមាសភាព

ការអប់រំមានគុណភាពសម្រាប់ទាំងអស់គ្នា និងការអប់រំពេញមួយជីវិត



បរិយាកាសរៀនមេត្រី
ដោយបញ្ចូលគ្រប់សមាសភាព

UNESCO

សេចក្តីណែនាំអំពីគោល

កម្រងសៀវភៅនេះផ្តល់ឲ្យអ្នកនូវគំនិតយោបល់ស្តីពីការគ្រប់គ្រងថ្នាក់រៀនផ្សេងៗ។ និងពន្យល់អំពីរបៀបរៀបចំដែនការសម្រាប់បង្រៀន និងរៀន របៀបប្រើធនធានឲ្យមានប្រសិទ្ធភាព របៀបគ្រប់គ្រងការងារជាក្រុមក្នុងថ្នាក់រៀន និងរបៀបវាយតម្លៃការរីកចម្រើនរបស់សិស្សក្នុងថ្នាក់រៀនផងដែរ ។

គោល

គោល ៥.១ ការរៀបចំកិច្ចតែងការបង្រៀន និងការសិក្សារបស់សិស្ស..... ៣

ការងារប្រចាំថ្ងៃក្នុងថ្នាក់រៀន ៣

ការទទួលខុសត្រូវរបស់កុមារ ៤

ការរៀបចំមេរៀន ៥

គោល ៥.២ រកធនធានដែលមានស្រាប់ ឱ្យបានច្រើនដល់កម្រិតអតិបរមា..... ១១

ទំហំផ្ទៃថ្នាក់រៀនជាក់ស្តែង ១២

ជ្រុងសិក្សា ១៣

កន្លែងដាក់តាំងសមិទ្ធិផល ១៤

បណ្ណាល័យក្នុងថ្នាក់រៀន ១៥

គោល ៥.៣ ការគ្រប់គ្រងការងារជាក្រុម និងការសិក្សាដែលមានកិច្ចសហការគ្នា..... ១៨

វិធីសាស្ត្រធ្វើការងារជាក្រុម ១៨

ការប្រើវិធីរៀបចំជាក្រុមសិក្សាផ្សេងៗ ១៩

ការសិក្សាដែលមានកិច្ចសហការគ្នា ២០

ជំនាញទំនាក់ទំនងជាមួយមនុស្សផ្សេងក្នុងការរៀនសូត្រ ២២

ការបង្កើតវិន័យសម្រាប់ការងារជាក្រុម ២៣

ការគ្រប់គ្រងការសិក្សាជាមួយមិត្តភក្តិ ២៤

ស្វ័យសិក្សា ២៦

ការរៀបចំដែនការសម្រាប់ធ្វើឲ្យមានលក្ខណៈផ្សេងៗគ្នា..... ២៧

ការគ្រប់គ្រងអាកប្បកិរិយាក្នុងថ្នាក់រៀន ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព..... ៣០

ការគ្រប់គ្រងថ្នាក់រៀនដែលមានសកម្មភាពរស់រើក និងដោយមាន
បរិយាកាសដាក់បញ្ចូលគ្រប់សមាសភាព ៣៦

គោល ៥.៤ ការវាយតម្លៃយ៉ាងសកម្ម និងត្រឹមត្រូវ ៤០
តើការវាយតម្លៃជាអ្វី? ៤០
លទ្ធផលសិក្សា ៤១
វិធីសាស្ត្រ និងបច្ចេកទេសវាយតម្លៃត្រឹមត្រូវ ៤៣
ចម្លើយត្រលប់ និងការវាយតម្លៃ ៤៩
ការវាយតម្លៃលើបំណិន និងឥរិយាបថ ៥០
តើការវាយតម្លៃអាចខុសនៅកន្លែងណា? ៥២

គោល ៥.៥ តើយើងបានរៀនអ្វីខ្លះពីបទពិសោធ នាពេលកន្លងមក? ៥៦

កម្រងសៀវភៅបង្កើតបរិយាកាសរៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព



គោល ៥.១
ការរៀបចំកិច្ចតែងការបង្រៀន និងការសិក្សារបស់សិស្ស

ចួន ជាគ្រូបង្រៀនម្នាក់នៅប្រទេសហ្វីលីពីន ធ្វើការក្នុងសាលារៀនតូចមួយនៅតំបន់ភ្នំ។ គាត់មិនធ្លាប់ទទួលការបណ្តុះបណ្តាលច្រើនឡើយ ប៉ុន្តែគាត់បានស្ម័គ្រចិត្តបង្រៀនក្នុងខណៈពេលដែលគ្មានគ្រូបង្រៀនចង់ទៅធ្វើការនៅតំបន់ឆ្ងាយពីទីក្រុង។ ទោះបីជាគាត់ចូលចិត្តកុមារក៏ដោយ ក៏គាត់យល់ថា ការបង្រៀនមានលក្ខណៈប្រកួតប្រជែងយ៉ាងខ្លាំង។ មានបញ្ហាជាច្រើនដែលត្រូវគិត : តើត្រូវបង្រៀនអ្វី? តើត្រូវប្រើសម្ភារអ្វី? តើទទួលបានសម្ភារទាំងនោះពីកន្លែងណា? តើត្រូវបង្រៀនថ្នាក់មួយដែលមានសិស្សច្រើន ហើយមានកម្រិតសមត្ថភាពខុសៗគ្នាដូចម្តេច? តើត្រូវរៀបចំកិច្ចតែងការបង្រៀនសម្រាប់កម្រិតផ្សេងៗគ្នាដូចម្តេច? តើគ្រូម្នាក់អាចធ្វើអ្វីផ្សេងៗបានឬទេ ហើយធ្វើដោយរបៀបណា?

នៅបណ្តាប្រទេសជាច្រើន ជាពិសេសនៅតាមតំបន់ជនបទ គ្រូបង្រៀនអាចយល់ឃើញថា ការងាររបស់គ្រូមានការប្រកួតប្រជែងយ៉ាងពិសេស។ ទោះជាយើងអាចមានប្រតិកម្ម ចំពោះផលប្រយោជន៍របស់កុមារក៏ដោយ ក៏យើងត្រូវរៀបចំ និងត្រៀមខ្លួនឲ្យបានល្អជង់ដែរ។ យើងត្រូវគ្រប់គ្រងការបង្រៀន និងការរៀនសូត្ររបស់សិស្សជង់ដែរ។ គោលនេះ នឹងផ្តល់ដល់អ្នកនូវគំនិតជាច្រើន អំពីការរៀបចំដែនការបង្រៀន និង ការរៀនសូត្រ ដោយប្រើធនធានដែលមាន ព្រមទាំងនិយាយអំពីថ្នាក់រៀនដែលមានបរិយាកាសរៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព ដោយមានកុមារដែលមានប្រវត្តិ និងសមត្ថភាពខុសៗគ្នាចូលរួម។

ការងារប្រចាំថ្ងៃក្នុងថ្នាក់រៀន

សកម្មភាពថ្នាក់រៀនជាប្រចាំជួយកុមារចាប់ផ្តើមសិក្សាបានយ៉ាងរហ័ស ប្រកបដោយអត្ថន័យនៅថ្ងៃចូលរៀនដំបូង។ កុមារគួរយល់ស្របតាមវិធាន និងការងារក្នុងថ្នាក់ជាប្រចាំ ហើយកុមារគួររៀបចំបង្កើតវិធាន និងការងារទាំងនោះដោយខ្លួនឯង។ ឧទាហរណ៍ គណៈកម្មាធិការសិស្ស ឬសិស្សមួយក្រុម អាចទទួលខុសត្រូវចុះបញ្ជីវត្តមាន ហើយរាយការណ៍ដល់គ្រូបង្រៀនអំពីចំនួនសិស្សអវត្តមាន។

ពេលកំពុងធ្វើការងារប្រចាំថ្ងៃជាមួយសិស្ស ជាការសំខាន់គ្រូត្រូវពន្យល់ និងសម្រេច : (ក) តើនឹងត្រូវធ្វើអ្វីខ្លះ? (ខ) តើអ្នកណានឹងធ្វើ? (គ) តើនឹងត្រូវធ្វើនៅពេលណា? (ឃ) ហេតុអ្វីបានជាចាំបាច់ត្រូវធ្វើសកម្មភាពប្រចាំថ្ងៃទាំងនេះ? ខាងក្រោមនេះជាគំនិតខ្លះៗស្តីពីការងារប្រចាំថ្ងៃដែលអ្នកអាចរៀបចំបង្កើតជាមួយសិស្ស :

- តើគេត្រូវធ្វើការងារអ្វីនៅពេលណាមួយ ជាពិសេសអ្នកដែលមកយឺត ព្រោះកុមារទាំងនោះត្រូវដើរផ្លូវច្រើយ និងសម្រាប់កុមារដែលកំពុងរង់ចាំការចាប់ផ្តើមរៀននៅក្នុងថ្នាក់។
- តើសៀវភៅ និងសម្ភារសិក្សាត្រូវធ្វើការចែកចាយ ប្រមូល និងរក្សាទុកដោយរបៀបណា ហើយតើអ្នកណាគួរទទួលខុសត្រូវសម្រាប់សកម្មភាពទាំងនេះ (ប្រសិនបើជាការទទួលខុសត្រូវនេះត្រូវផ្លាស់ប្តូរវេនគ្នាក្នុងចំណោមកុមារទាំងឡាយ កុមារី និងកុមារា ឬក្រុមការងារកុមារ)។
- តើកុមារអាចទទួលបានការជួយគ្នាទៅវិញទៅមកដោយរបៀបណា នៅពេលដែលពួកគេត្រូវការជំនួយ ហើយគ្រូបង្រៀនមិនអាចជួយបាន?
- តើនឹងត្រូវធ្វើអ្វី នៅពេលកុមារបានបញ្ចប់សកម្មភាពណាមួយហើយ?
- តើនឹងត្រូវទទួលបានការយកចិត្តទុកដាក់ពីគ្រូបង្រៀនក្នុងលក្ខណៈមិនរំខាន ដោយរបៀបណា?
- តើការឡូឡាក្នុងថ្នាក់របស់សិស្សអាចទទួលយកបានក្នុងកម្រិតណា?
- តើត្រូវដើរជុំវិញថ្នាក់រៀនក្នុងលក្ខណៈមិនឲ្យរំខានដោយរបៀបណា?
- តើត្រូវចាកចេញពីថ្នាក់រៀន ដោយរបៀបណា?

កុមារគួរចូលរួមយ៉ាងសកម្មក្នុងការអភិវឌ្ឍវិធានខ្លះក្នុងចំណោមវិធានទាំងនេះ ព្រោះពួកគេទំនងជាត្រូវអនុវត្តតាមវិធានទាំងនេះ ប្រសិនជាពួកគេបានចូលរួមបង្កើតវិធានទាំងនេះ។ ទោះជាយ៉ាងណាក៏ដោយ វិធានខ្លះមិនអាចចរចាបានឡើយ ជាពិសេសពេលដែលវិធានទាំងនោះមានគោលដៅគាំពារកុមារ។ ឧទាហរណ៍ វិធានស្តីពីពេលវេលាដែលកុមារចាកចេញពីថ្នាក់រៀន ឬវិធានស្តីពីការនិយាយស្តីជាមួយគ្រូមុនពេលកុមារចាកចេញពីបរិវេណសាលារៀន ជាពិសេសប្រសិនជាមនុស្សចាស់ណាម្នាក់ដែលមិនមែនជាមាតាបិតា ឬ អាណាព្យាបាលរបស់កុមារមកទទួល។

ការទទួលខុសត្រូវរបស់កុមារ

កុមារទាំងអស់គួរចូលរួមក្នុងការជួយបំពេញភារកិច្ច និងការងារក្នុងថ្នាក់រៀន។ ដោយធ្វើរបៀបនេះ អ្នកនឹងជួយខ្លួនអ្នកក្នុងការគ្រប់គ្រងថ្នាក់រៀន ក្នុងខណៈដែលអ្នកកំពុងបង្រៀនសិស្សឲ្យចេះទទួលខុសត្រូវ។ ខាងក្រោមនេះ ជាឧទាហរណ៍ស្តីពីការទទួលខុសត្រូវមួយចំនួនដែលអ្នកអាចចាត់តាំងសិស្សឲ្យចូលរួមធ្វើ :

- ធ្វើជាគ្រូបង្រៀនម្នាក់សម្រាប់កុមារតូច។ ឬសម្រាប់អ្នកដែលត្រូវការជំនួយ ជាពិសេសក្នុងការសិក្សា។


- ធ្វើជាអ្នកដឹកនាំក្រុម ឬសមាជិកគណៈកម្មាធិការ ដែលទទួលខុសត្រូវក្នុងការបំពេញការងារប្រចាំថ្ងៃនៅក្នុងថ្នាក់រៀន ឬសកម្មភាពសិក្សាណាមួយ ហើយរាយការណ៍អំពីដែលបានរៀន និងបានបំពេញដោយជោគជ័យ។
- ធ្វើជាសមាជិកម្នាក់នៃគណៈកម្មាធិការសុខភាព ដែលត្រូវធានាឲ្យមានទឹក និងសាប៊ូ ឬជេះសម្រាប់លាងដៃ និងទឹកស្អាតសម្រាប់ផឹក។
- ស្រង់បញ្ជីឈ្មោះសិស្សវត្តមាន ហើយកត់ត្រាទុកលើតារាងវត្តមាន។
- ដោះស្រាយ និងកត់ត្រាសំណូមពរផ្សេងៗដែលមានក្នុងប្រអប់សំណូមពររបស់សិស្ស។

ការជ្រើសរើសការទទួលខុសត្រូវណាមួយដែលត្រូវឲ្យកុមារធ្វើគឺអាស្រ័យលើអាយុ និងកម្រិតពេញវ័យរបស់កុមារ។ ប៉ុន្តែ មិនមែនសម្រាប់តែកុមារដែលមានប្រាជ្ញា ឬដឹងហេតុផលជាងគេទេដែលត្រូវទទួលខុសត្រូវការងារទាំងនោះ។ កុមារទាំងអស់នៅក្នុងថ្នាក់គួរចូលរួមទទួលខុសត្រូវ ដោយមិនគិតពីភេទ សមត្ថភាពសិក្សា ឬប្រវត្តិអប់រំផ្សេងៗរបស់កុមារឡើយ។ ជាងនេះទៀត យើងត្រូវប្រយ័ត្ន មិនត្រូវបង្ខាំឲ្យអនុវត្តនូវលក្ខណៈ គំរូយេនឌ័រមិនល្អ ដែលស្នើឲ្យកុមារីស្រោចផ្កា ហើយឲ្យកុមារសែងតុ។ ដោយបានផ្តល់នូវការគាំទ្រគ្រឹមត្រូវ កុមារទាំងអស់អាចចូលរួម និងទទួលប្រយោជន៍ពីការងារជាប្រចាំ និងភារកិច្ចទាំងឡាយនៅក្នុងថ្នាក់។

ការរៀបចំមេរៀន

ដើម្បីប្រើប្រាស់ពេលវេលាបង្រៀន និងពេលវេលាសម្រាប់សិស្សរៀនឲ្យបានល្អបំផុត មេរៀនត្រូវតែរៀបចំឲ្យបានល្អ។ ជាការពិត កិច្ចតែងការបង្រៀនត្រូវការចំណាយពេលវេលានៅពេលដំបូង ប៉ុន្តែវាជាជំនាញអាជីពដ៏សំខាន់មួយសម្រាប់គ្រូបង្រៀនទាំងអស់ និងជាអ្នកសន្សំពេលសម្រាប់ដំណើរការដ៏យូរអង្វែង។

ក្របខ័ណ្ឌសកម្មភាពមួយដែលអ្នកអាចប្រើសម្រាប់ការរៀបចំមេរៀនគឺ ត្រីកោណកម្មវិធីសិក្សា។



ក្នុងក្របខ័ណ្ឌនេះ **ខ្លឹមសារ** មានន័យថា តើប្រធានបទអ្វីដែលត្រូវសរសេរនៅក្នុងកម្មវិធីសិក្សាជាតិ។ ទោះជាយ៉ាងណាក្តី ជាពិសេសសម្រាប់ថ្នាក់រៀនដែលមានកុមារមានប្រវត្តិ និងសមត្ថភាពខុសៗគ្នា ខ្លឹមសារនេះត្រូវមានន័យគ្រប់គ្រាន់សម្រាប់កុមារទាំងអស់ ហើយត្រូវសម្របសម្រួលឲ្យត្រូវនឹងតម្រូវការរបស់សហគមន៍ ដែលកុមាររស់នៅ។

ដំណើរការ មានន័យថា ខ្លឹមសារត្រូវបានបង្រៀនដោយរបៀបណា។ បញ្ហានេះអាចពាក់ព័ន្ធនឹងការប្រើវិធីសាស្ត្របង្រៀនផ្សេងៗគ្នា ដើម្បីឆ្លើយតបតាមតម្រូវការនៃរបៀបសិក្សាខុសៗគ្នា ឬដើម្បីបង្កើនឲ្យដល់អតិបរមានូវពេលវេលាដែលមានសម្រាប់ការបង្រៀន និងការរៀនសូត្ររបស់សិស្ស (ចូរមើលការបង្រៀនអ្នកដែលមានវិយប្រហាក់ប្រហែលគ្នាខាងក្រោម)។

បរិយាកាស រួមមានបរិយាកាសជាក់ស្តែង (រួមមាន ធនធានសិក្សាសម្រាប់មេរៀនដែលអាចមានក្នុងកម្មវិធីសិក្សា) ព្រមទាំងបរិយាកាសសង្គម និងចិត្តសាស្ត្រ។ ឧទាហរណ៍ ការសង្កត់ធ្ងន់មួយទៅលើការបង្កើតឲ្យមានការចេះគោរពខ្លួនឯងតាមរយៈសកម្មភាពជាក្រុម ដែលទាមទារការសហការគ្នា។

សកម្មភាព : ចូរចាប់ផ្តើមមេរៀនមួយ ដែលមានលេង "ល្បែងហៅឈ្មោះ" ដើម្បីឲ្យកុមារចងចាំឈ្មោះគ្នាទៅវិញទៅមកនៅដើមឆ្នាំ។ សកម្មភាពនេះជួយបង្កើតឲ្យមានសាមគ្គីភាពនៅក្នុងថ្នាក់រៀន។ សកម្មភាពមួយផ្សេងទៀត ហៅថា "ការផ្តល់អំណោយ"។ កុមារធ្វើការជាគំរូ និយាយរកគ្នាទៅវិញទៅមក និងចោទជាសំណួរសួរគ្នាទៅវិញទៅមក។ ពីរ ឬបីនាទីក្រោយមក កុមារត្រូវសរសេរអ្វីដែលគេបានស្តាប់ឮពីដៃគូ ហើយបន្ទាប់មក រាយការណ៍ដល់ថ្នាក់ទាំងមូលអំពីលក្ខណៈសម្បត្តិផ្ទាល់ខ្លួន ឬ "អំណោយ" របស់ដៃគូ។ កុមារអាចរាយការណ៍ ដូចនេះ : មិត្តភក្តិរបស់ខ្ញុំឈ្មោះ មារីយ៉ា ហើយនាងមានចំណុចល្អជាច្រើន សម្រាប់និយាយឲ្យមិត្តក្នុងថ្នាក់ស្តាប់។ សកម្មភាពនេះបង្ហាញថា អ្នករាល់គ្នាអាចនាំយកអ្វីមួយមកថ្នាក់រៀន និងបង្ហាញថាលក្ខណៈសម្បត្តិផ្ទាល់ខ្លួនទាំងនេះត្រូវបានផ្តល់តម្លៃនៅក្នុងថ្នាក់រៀន។

កុមាររៀនពូកែបំផុត នៅពេលដែលពួកគេមានសកម្មភាព និងការគិត។ កុមារអាចរៀនបានល្អជង់ដែរនៅពេលដែលសកម្មភាពទាំងឡាយបានផ្អែកទៅលើបរិបទ និងបទពិសោធជីវភាពរស់នៅពិតប្រាកដ ដើម្បីឲ្យកុមារអាចអនុវត្តចំណេះដឹងរបស់ខ្លួនមានប្រសិទ្ធភាពថែមទៀត។ គ្រូបង្រៀនដែលស្គាល់សិស្ស និងសហគមន៍ច្បាស់លាស់អាចបញ្ចូលឧទាហរណ៍កាន់តែងាយស្រួលថែមទៀតក្នុងកិច្ចតែងការបង្រៀន។

ប៉ុន្តែជាអកុសល គ្រូបង្រៀនជាច្រើនមិនដែលទទួលបានការណែនាំអំពីវិធីរៀបចំកិច្ចតែងការបង្រៀនឡើយ។ គ្រូបង្រៀនត្រូវបានបង្រៀនឲ្យពឹងផ្អែកលើសៀវភៅមេរៀន។ នៅក្នុងករណីខ្លះ ការបង្រៀនដូចនេះក៏ដោយសារតែ សៀវភៅមេរៀនគឺជាជំនួយសម្រាប់ការបង្រៀនដែលអាចមានតែមួយគត់។ ក្នុងករណីណាមួយក៏ដោយ គ្រូបង្រៀន ត្រូវតែធ្វើកិច្ចតែងការបង្រៀនថា តើនឹងត្រូវធ្វើទំនាក់ទំនងព័ត៌មាននៅក្នុងសៀវភៅ

មេរៀននេះដោយរបៀបណា ក្នុងលក្ខណៈមួយដើម្បីឲ្យសិស្សងាយយល់។ សម្រាប់ថ្នាក់រៀនដែលមានបញ្ចូលគ្រប់សមាសភាព កិច្ចតែងការបង្រៀន មិនមែនជាការរៀបចំមួយដ៏ប្រណិតនោះទេ វាគឺជាតម្រូវការចាំបាច់មួយ ពីព្រោះយើងត្រូវតែពិចារណាអំពីតម្រូវការរបស់កុមារដែលមានប្រវត្តិ និងសមត្ថភាពខុសៗគ្នា។ យ៉ាងហោចណាស់ យើងត្រូវការដឹងបញ្ហា ដូចខាងក្រោម :

- តើយើងនឹងបង្រៀនអ្វី (ប្រធានបទ ខ្លឹមសារ) ?
- ហេតុអ្វីបានជាយើងបង្រៀនអំពីខ្លឹមសារនេះ (គោលដៅ/វត្ថុបំណង)?
- តើយើងនឹងបង្រៀនវាដោយរបៀបណា (វិធីសាស្ត្រ/ដំណើរការ) ?
- តើកុមារបានស្គាល់ ឬដឹងអ្វីរួចជាស្រេចហើយ (ការរៀនមុនៗ ការធ្វើលំហាត់មុនសាកល្បងមុនការបង្រៀន)?
- តើសិស្សនឹងធ្វើអ្វីខ្លះ (សកម្មភាព)?
- តើយើងនឹងគ្រប់គ្រងមេរៀនដោយវិធីណា (រួមមាន ការរៀបចំបង្កើតបរិយាកាសជាក់ស្តែង និងសង្គម)?
- តើសកម្មភាពទាំងឡាយ នឹងសមស្របសម្រាប់កុមារទាំងអស់ឬទេ?
- តើកុមារនឹងមានឱកាសធ្វើការជាគូ ឬជាក្រុមដែរឬទេ?
- តើកុមារនឹងកត់ត្រាអ្វីដែលបានធ្វើ (ផលិតផលសម្ភារសិក្សា ដូចជាគំនូរ) ដោយរបៀបណា?
- តើយើងនឹងដឹងថា កុមារកំពុងរៀន (ការឆ្លើយតប និងការវាយតម្លៃ) ដោយរបៀបណា?
- តើយើងត្រូវធ្វើអ្វីបន្ទាប់មកទៀត (ការឆ្លុះបញ្ចាំង និងការរៀបចំដែនការអនាគត)?

មធ្យោបាយខ្លះដែលយើងអាចរៀបចំបង្កើតដោយខ្លួនយើងផ្ទាល់ និងកិច្ចតែងការបង្រៀនយើងបានលួគឺតាមរយៈការប្រើតារាងកិច្ចតែងការបង្រៀនដ៏សាមញ្ញមួយ គម្រោងកិច្ចតែងការបង្រៀនមួយ ឬរបៀបរៀបចំកិច្ចតែងការបង្រៀនប្រចាំថ្ងៃមួយដូចជា ក្នុងឧទាហរណ៍នៅទីនេះ។ ចូរព្យាយាមប្រើមធ្យោបាយណាមួយខាងលើដើម្បីធ្វើកិច្ចតែងការបង្រៀនរបស់អ្នក។ អ្នកអាចចាប់ផ្តើមជាមួយប្រធានបទ ឬមេរៀនណាមួយ។ មធ្យោបាយ ទាំងនេះនឹងផ្តល់ឲ្យដល់អ្នកនូវការចាប់ផ្តើមដ៏រឹងប៉ឹងមួយ កិច្ចតែងការបង្រៀនផ្តល់ឲ្យអ្នកនូវមធ្យោបាយមួយ ដើម្បីពិនិត្យថា តើសិស្សកំពុងយល់អ្វីដែលអ្នកបង្រៀន ឬអត់ ហើយផ្តល់ដល់អ្នកនូវឱកាសមួយដើម្បីគិត អំពីអ្វីដែលនឹងត្រូវធ្វើបន្ទាប់ ហើយត្រូវកែលំអការបង្រៀនរបស់អ្នកដោយរបៀបណា។

តារាងកិច្ចតែងការបង្រៀន

ប្រធានបទ	វត្ថុបំណង	វិធីសាស្ត្របង្រៀន	លំហាត់សាកល្បង	ការរៀបចំថ្នាក់	សកម្មភាពសិស្ស	ផលិតផលសិក្សា	ចម្លើយត្រលប់	កំណត់សម្គាល់

គម្រោងកិច្ចតែងការបង្រៀន

មុខវិជ្ជា : _____

ថ្នាក់ ឬក្រុមសម្រាប់បង្រៀន : _____

ចំនួនសិស្ស : _____

ពេលម៉ោង : _____

វត្ថុបំណងមេរៀន : _____

តើអ្នកចង់ឲ្យកុមាររៀនអំពីអ្វីនៅក្នុងមេរៀននេះ?

ចូរគិតអំពីចំណេះដឹង ជំនាញ និងឥរិយាបថដែលអ្នកចង់ឲ្យពួកគេរៀន។ ចូរជ្រើសរើសជំនាញ ចំណេះដឹង ឬឥរិយាបថពីរ ឬបី ដែលត្រូវផ្តោតការយកចិត្តទុកដាក់ក្នុងមេរៀនមួយ។

ធនធាន :

តើធនធានអ្វីដែលអ្នកត្រូវការសម្រាប់មេរៀន? សម្ភារអ្វីដែលកុមារត្រូវការ? តើកុមារអាចជួយដោយរបៀបណា ដើម្បីទទួលបាននូវធនធានទាំងនេះ?

កុមារដែលមានតម្រូវការពិសេស :

តើមានកុមារនៅក្នុងក្រុមត្រូវការជំនួយបន្ថែមឬទេ?

តើអ្នកនឹងត្រូវការការគាំទ្រអ្វីខ្លះ ដើម្បីផ្តល់ដល់កុមារទាំងនេះ?

តើអ្នកត្រូវការជួយពួកគេដោយផ្អែកលើមូលដ្ឋានកុមារម្នាក់ៗឬ?

តើអ្នកត្រូវការធានាឲ្យកុមារទាំងនោះអង្គុយក្នុងកន្លែងសមរម្យមួយនៅក្នុងថ្នាក់រៀនឬ? (ជារឿយៗ ក្នុងថ្នាក់ដែលមានសិស្សរៀនខ្លាយ ហើយត្រូវការឲ្យគ្រូជួយ គ្រូត្រូវអនុញ្ញាតឲ្យសិស្សខ្លាយអង្គុយមុខ បើថ្នាក់របស់អ្នកមានសិស្សច្រើន ដើម្បីងាយស្រួលមើល និងជួយសិស្សខ្លាយនោះ។

សេចក្តីផ្តើម :

ចូរច្រាប់កុមារអំពីអ្វីដែលអ្នកចង់ឲ្យពួកគេរៀននៅក្នុងមេរៀននេះ។ គ្រូបង្រៀនខ្លះសរសេរអំពីវត្ថុបំណងនេះនៅលើក្តារខៀននៅពេលចាប់ផ្តើមរៀន។ ចូរគិតថា តើអ្នកនឹងត្រូវចាប់ផ្តើមបង្រៀនមេរៀនដោយរបៀបណា។ ចូរចងចាំថា ត្រូវរំលឹកយ៉ាងខ្លីនូវអ្វីដែលកុមារបានរៀនក្នុងមេរៀនមុន។ ចូរសាកល្បងចាប់ផ្តើម ជាមួយបញ្ហាណាមួយសម្រាប់ឲ្យកុមារដោះស្រាយជាមួយសំណួរគ្មានកំណត់មួយ ឬជាមួយរូបភាពមួយដើម្បីពិភាក្សា ដែលអាចនាំបន្តទៅសកម្មភាពសំខាន់ៗទៀត។

សកម្មភាពសំខាន់ៗ :

តើអ្នកចង់ឲ្យកុមារធ្វើអ្វីនៅក្នុងផ្នែកសំខាន់នៃមេរៀន? ចូរដឹងច្បាស់ដថា ការកិច្ចរបស់អ្នកត្រូវធានាឲ្យកុមារសម្រេចបានវត្ថុបំណងនៃការរៀន។

ចូរព្យាយាមបញ្ចូលនូវសកម្មភាពផ្សេងៗ។ ឧទាហរណ៍ សាកល្បងស្នើសិស្សឲ្យធ្វើការជាគូ ឬជាក្រុមតូចៗ។

ចូរកំណត់អំពីរបៀបដែលអ្នកនឹងត្រូវណែនាំ និងពន្យល់អំពីការកិច្ចនានាឲ្យសិស្សបំពេញ។

ចូរសម្រេចថា អ្នកនឹងត្រូវចំណាយពេលយ៉ាងណា នៅពេលដែលកុមារកំពុងអនុវត្តការកិច្ចណាមួយ។ ជារឿយៗ នេះជាពេលដ៏ល្អ ដើម្បីគាំទ្រ កុមារដែលត្រូវការជំនួយបន្ថែម។

សេចក្តីសន្និដ្ឋាន :

ចូរជ្រើសរើសសកម្មភាព ឬការពិភាក្សាណាមួយនៅពេលបញ្ចប់មេរៀន ដែលតម្រូវឲ្យអនុវត្តនូវវត្ថុបំណងនៃការរៀន។ ចូរសួរកុមារថា តើពួកគេបានរៀនអ្វីខ្លះ។

ការឆ្លុះបញ្ចាំងខ្លួនឯងបន្ទាប់ពីអ្នកបានបង្រៀនមេរៀនមួយ :

ចូរប្រើចន្លោះនេះដើម្បីសរសេរកំណត់ហេតុយ៉ាងលឿនមួយសម្រាប់ខ្លួនអ្នកផ្ទាល់ ស្តីពីមេរៀនដែលបានបង្រៀន បានប្រព្រឹត្តទៅដោយរបៀបណា ហើយអ្នកអាចកែលំអការបង្រៀននេះយ៉ាងណានៅពេលក្រោយ។ តើកុមារសម្រេចបាននូវវត្ថុបំណងនៃការរៀនឬទេ? តើកុមារទាំងអស់បានចូលរួមឬទេ? តើអ្នកអាចធ្វើអ្វីផ្សេងពីនេះនៅពេលក្រោយ?

គំរូទម្រង់កិច្ចតែងការបង្រៀនប្រចាំថ្ងៃរបស់គ្រូ		
កាលបរិច្ឆេទ :		
១.	*វត្ថុបំណងនៃការរៀន* *រចនាសម្ព័ន្ធមេរៀន*	*ធនធាន*
២.	*វត្ថុបំណងនៃការរៀន* *រចនាសម្ព័ន្ធមេរៀន*	*ធនធាន*
៣.	*វត្ថុបំណងនៃការរៀន* *រចនាសម្ព័ន្ធមេរៀន*	*ធនធាន*
៤.	*វត្ថុបំណងនៃការរៀន* *រចនាសម្ព័ន្ធមេរៀន*	*ធនធាន*
៥.	*វត្ថុបំណងនៃការរៀន* *រចនាសម្ព័ន្ធមេរៀន*	*ធនធាន*



គោល ៥.២
រកធនធានដែលមានស្រាប់ ឱ្យបានច្រើនដល់កម្រិតអតិបរមា

គ្រូបង្រៀនដែលទទួលបានជោគជ័យរក្សានូវបរិយាកាសរៀនដែលគួរឲ្យចាប់អារម្មណ៍សម្រាប់កុមារទាំងអស់ ដោយមិនគិតពីអាយុ ភេទ សមត្ថភាព ឬប្រវត្តិ។ ថ្នាក់រៀនរបស់គ្រូទាំងនោះ ជាកន្លែងគួរឲ្យរំភើប និងជំរុញទឹកចិត្តដើម្បីរៀន។ ទោះបីជាសម្ភារសិក្សាមិនសំបូរ ហើយគ្រឿងសង្ហារឹមខ្សត់ខ្សោយក៏ដោយ ក៏ថ្នាក់រៀនអាចមានសណ្តាប់ធ្នាប់ល្អ ស្អាតបាត ហើយគួរឲ្យចាប់អារម្មណ៍ជាមួយនឹងគំនិតច្នៃប្រឌិតណាមួយ និងឆន្ទៈស្នើសុំជំនួយ។ នេះគឺជាគំនិតខ្លះគួរទុកពិចារណា។

ប្រសិនជាអាចធ្វើបាន តុ ឬកៅអីគួរតែអាចផ្លាស់ប្តូរទីតាំងបានដោយងាយ ដើម្បីសម្រួលការងារជាក្រុម។ ក្តារខៀន ឬផ្ទៃសម្រាប់សរសេរដទៃទៀត គួរតែមានលើសពីមួយ។ គួរតែមានផ្ទៃតាំងបង្ហាញការងាររបស់កុមារគ្រប់គ្រាន់ ដើម្បីឲ្យកុមារមានមោទនភាពក្នុងការបង្ហាញដល់អ្នកដទៃទៀតថា ពួកគេកំពុងរៀនបានល្អកម្រិតណា។ គួរតែមានផ្នែកសម្រាប់រៀន និងធ្វើសកម្មភាពសម្រាប់មុខវិជ្ជាជាក់លាក់នានា ឬ គួរតែមាន "បណ្ណាល័យ" តូចមួយ។

យើងអាចយើញថា មានការលំបាកដើម្បីរក្សាថ្នាក់រៀនមួយឲ្យមានសណ្តាប់ធ្នាប់ និងមានការជំរុញទឹកចិត្ត ជាពិសេស ប្រសិនជា សត្វ និងអ្នកបំផ្លិចបំផ្លាញអាចបំផ្លាញសម្ភារថ្នាក់រៀនដោយងាយស្រួល។ ដោយហេតុនេះ យើងត្រូវការធ្វើការជាមួយមាតាបិតា និងអ្នកដឹកនាំសហគមន៍ ដើម្បីការពារសម្ភារសិក្សា និងសម្ភារតាំងបង្ហាញ។ សម្ភារខ្លះអាចត្រូវបានទុកដាក់រាល់ថ្ងៃនៅក្នុងទូ ឬប្រអប់សុវត្ថិភាពមួយ។ កុមារអាចទទួលខុសត្រូវយកសម្ភារមួយចំនួនទៅផ្ទះ ហើយនាំយកមកវិញនៅថ្ងៃបន្ទាប់។

ឧទាហរណ៍ សាលារៀនជនបទមួយនៅប្រទេសជាដអាចមានទូដែកដើម្បីរក្សាសៀវភៅ ព្រោះមានសត្វកណ្តៀរ និងសត្វល្អិត ដទៃទៀតអាចបំផ្លាញ សម្ភារសិក្សាទាំងនេះបានយ៉ាងងាយ។

នៅប្រទេសបង់ក្លាដែស គេអាចយើញក្តារខៀនជាច្រើននៅជុំវិញថ្នាក់រៀននៅកម្រិតសិក្សារបស់កុមារដើម្បីឲ្យកុមារអាចអង្គុយជាក្រុម ហើយប្រើក្តារខៀនសម្រាប់រៀបចំគម្រោងការ ពិភាក្សាគំនិតផ្សេង។ និងការដោះស្រាយបញ្ហា ។ល។ នៅតាមថ្នាក់រៀនខ្លះ កង្វះខាតតុ និងកៅអីបានបង្ហាញឲ្យយើញថាមានគុណប្រយោជន៍។ ផ្ទៃសម្រាប់រៀនសូត្រដ៏ធំទូលាយ ដែលគ្របដណ្តប់ដោយកម្រាលព្រំធ្វើក្នុងស្រុកដ៏ស្អាតបាតអាចត្រូវបានប្តូរទម្រង់ ដោយងាយពីផ្ទៃសម្រាប់ការអង្កេតផ្នែកវិទ្យាសាស្ត្រ ទៅជាផ្ទៃសម្រាប់

រឿងល្ខោនវិនាដកម្ម ហើយ ក្រុមផ្សេងៗអាចត្រូវបានបង្កើត ឬបង្កើតឡើងវិញដោយងាយ ដោយមានការខិានតិចតួចដល់ថ្នាក់ដទៃ។

នៅរដ្ឋមួយដែលមានចំនួនប្រជាជនខ្ពស់នៃប្រទេសឥណ្ឌា ផ្ទៃជញ្ជាំងទាបៗត្រូវបានលាបពណ៌ខ្មៅ ហើយ កុមារប្រើវាជាផ្ទៃសម្រាប់សរសេរផ្ទាល់ខ្លួន ដោយគូររូប និងសរសេរជាមួយដីសរ។ សាលានេះត្រូវបានសាងសង់ឡើងក្រោមកម្មវិធីអប់រំបឋមសិក្សាស្រុករបស់ឥណ្ឌា ដែលបានធ្វើឲ្យសាលារៀនកើតមានក្នុងរង្វង់១គីឡូម៉ែត្រពីផ្ទះរបស់កុមារ សូម្បីនៅតំបន់ដាច់ស្រយាលក៏ដោយ។ អគារសិក្សាត្រូវបានរចនា និងសាងសង់ជាពិសេស មានលក្ខណៈកុមារមេត្រី ដូចជាការខ្វៀនរបស់កុមារដែលបានរៀបរាប់ខាងលើ។

ទំហំផ្ទៃថ្នាក់រៀនជាក់ស្តែង

ប្តូរទីតាំងក្នុងបន្ទប់រៀន

កុមារត្រូវការឲ្យមានការផ្លាស់ប្តូរដោយសេរីរវាងក្រៅមតុ ឬកៅអី (ឬរវាងកុមារដទៃទៀតដែលអង្គុយនៅលើឥដ្ឋ) ដោយមិនរំខានអ្នកដទៃ។ ចូរផ្លាស់ប្តូរការរៀបចំកន្លែងអង្គុយដើម្បីឲ្យអ្នក និងកុមារអាចរកឃើញការរៀបចំកន្លែងអង្គុយដ៏ល្អបំផុតសម្រាប់ថ្នាក់ទាំងមូល និងការងារជាក្រុមតូចៗ។

កំណត់សម្គាល់ដែលត្រូវចងចាំ : តើកុមារពិការអាចចូល និងផ្លាស់ប្តូរទីតាំងជុំវិញថ្នាក់រៀនបានងាយស្រួល ឬទេ? តើកុមារដែលមានប្រវត្តិ និងសមត្ថភាពខុសៗគ្នាកំពុងអង្គុយជាមួយកុមារដទៃទៀត និងមិនត្រូវបានគេបំបែកចេញ? តើកុមារា និងកុមារីកំពុងអង្គុយរួមគ្នា ឬ ផ្សេងពីគ្នា?

ពន្លឺ កំដៅ និងខ្យល់ចេញចូល

ចូររៀបចំតុ ដើម្បីឲ្យកុមារមិនចាំបាច់ធ្វើការបែរមុខចំពន្លឺព្រះអាទិត្យផ្ទាល់។ ពន្លឺគួរតែចេញពីកន្លែងដែលកុមារអង្គុយ។

ខ្លួរក្បាលត្រូវការខ្យល់អុកស៊ីសែន។ ផ្នែកផ្សេងៗរបស់ថ្នាក់រៀនអាចហាប់ស្អុះស្អាប់។ ប្រសិនជាមានខ្យល់ចេញចូល តិចតួចនៅក្នុងថ្នាក់របស់អ្នក អ្នកអាចអនុញ្ញាតឲ្យសិស្សរបស់អ្នកធ្វើសកម្មភាពនៅខាងក្រៅថ្នាក់។ ចូរប្តូរទីតាំង កន្លែងអង្គុយ ដើម្បីកុំឲ្យកុមារអង្គុយនៅផ្នែក ដែលមានពន្លឺ និងខ្យល់ចេញចូលតិចតួច។

កុមារខ្លះអាចមានការលំបាកក្នុងការមើល និងស្តាប់។ ចូរប្រាកដថាកុមារទាំងអស់ត្រូវបានសាកល្បង និងមានកន្លែងអង្គុយសមរម្យ។

ជ្រុងសិក្សា

ជារឿយៗ កុមារចង់ដឹងចង់ឮអំពីពិភពធម្មជាតិជុំវិញខ្លួន។ ជ្រុងសិក្សាវិទ្យាសាស្ត្រ និងគណិតវិទ្យាអាចជំរុញការចង់ដឹងរបស់កុមារ និងកែលំអការសិក្សារបស់កុមារ។ កុមារអាចប្រមូល និងរៀបចំបង្កើតអ្វីផ្សេងៗដែលពួកគេចាប់អារម្មណ៍ ហើយធនធានទាំងនេះ អាចឲ្យកុមារទាំងអស់ប្រើប្រាស់បាន។ កុមារអាចដាំបណ្តុះគ្រាប់ពូជនៅជ្រុងទាំងនេះ ប្រមូលផ្លែឈើ និងដាក់តាំងបង្ហាញវត្ថុផ្សេងៗដែលពួកគេបានរកឃើញដូចជា សំបកលៀសសមុទ្រ ជាដើម។ អ្នកនឹងត្រូវការគិតដោយយកចិត្តទុកដាក់ថា តើជ្រុងសិក្សាទាំងនេះត្រូវមានទីតាំងស្ថិតនៅកន្លែងណា ដែលល្អបំផុត ដើម្បីឲ្យកុមារធ្វើការនៅជ្រុងទាំងនេះដោយមិនរំខានអ្នកដទៃ។

- សម្រាប់ជ្រុងសិក្សាវិទ្យាសាស្ត្រ និងធម្មជាតិ សត្វមានជីវិត ដូចជាត្រីអាចមានលក្ខណៈសមរម្យសម្រាប់សកម្មភាពរៀនក្នុងថ្នាក់។ នៅពេលនោះដែរ កុមារត្រូវការរៀនរបៀបថែរក្សាសត្វមានជីវិតទាំងនេះ កាត់បន្ថយភាពសាហាវយង់ឃ្នង និងលែងសត្វទាំងនោះទៅព្រៃវិញ ក្រោយពីបានសិក្សារួច ប្រសិនជាអាចធ្វើបាន។

- ក្នុងជ្រុងសិក្សាគណិតវិទ្យា កំប៉ុងទទេ (ដែលមានគម្រប) និងកញ្ចប់ផ្សេងៗអាចដាក់លើធ្នើរ ហើយអាចប្រើជាសម្ភារសិក្សា (ឧទាហរណ៍ សមាមាត្រលេខដោយប្រើវត្ថុ) និងជាកន្លែងរក្សាសម្ភារផ្សេងៗទៀត ដូចជាលុយសេន និងរូបិយវត្ថុធនាគារ។ គេអាចធ្វើ "លុយក្រដាស" ពីក្រដាសកាតុង និងក្រដាសធម្មតា ហើយប្រើក្នុងសកម្មភាពដើរតួសំដែង ដូចជា ទៅផ្សារទិញឥវ៉ាន់។ សម្ភារដែលនៅសេសសល់ អាចស្តុកទុកនៅទីនេះសម្រាប់ប្រើពេលក្រោយ ដូចជាក្រដាសកាតុងខ្សែ ខ្សែភ្លើង សុត ផ្នែកផ្សេងៗ នៃសម្ភារ សម្លៀកបំពាក់ ឬកំណាត់ ប្លាស្ទិក ។ល។

វត្ថុផ្សេងៗដែលរកបាន ដាក់ស្លាកសម្គាល់ តាំងបង្ហាញ និងប្រើដោយកុមារ ជួយកុមារឲ្យបង្កើតទំនាក់ទំនង រវាងសាលា ជីវិតប្រចាំថ្ងៃ និងសហគមន៍មូលដ្ឋាន។ សិប្បកម្មក្នុងស្រុក និងតន្ត្រីករអាចទៅទស្សនានៅសាលា និងជជែកលេងជាមួយកុមារបាន។ ក្រមនេះប្រហែលជាអាចផ្តល់វត្ថុផ្សេងៗ ដូចជាឧបករណ៍ប្រើដោយដៃ និងឧបករណ៍ផ្សេងៗទៀត សម្រាប់ឲ្យកុមារធ្វើការស្រាវជ្រាវ និងគូរគំនូរ បានយ៉ាងហោចណាស់ ក៏រយៈពេលខ្លីដែរ។ ពេលបានទទួលវត្ថុមានតម្លៃ ត្រូវតែគិតពិចារណា អំពីបញ្ហាសន្តិសុខ ។

កុមារគួរតែចូលរួមឲ្យបានពេញលេញក្នុងការរៀបចំ និងគ្រប់គ្រងថ្នាក់រៀន និងសម្ភារសិក្សា។ អាចបង្កើតឲ្យមានជាក្រុមតូច។ ក្រុមការងារ ឬគណៈកម្មាធិការថ្នាក់ ដើម្បីថែរក្សាជ្រុងសិក្សា។ ការចូលរួមរបស់កុមារនឹងជួយគ្រប់គ្រងសម្ភារសិក្សាក្នុងថ្នាក់រៀន ហើយជួយកុមារឲ្យអភិវឌ្ឍការទទួលខុសត្រូវ និងជំនាញ ស្តីពីភាពជាពលរដ្ឋ។ គណៈកម្មាធិការថ្នាក់រៀន អាចរួមមានអ្នកសម្របសម្រួលម្នាក់ និងលេខាធិការម្នាក់ ដែលសិស្សក្នុងថ្នាក់ទាំងអស់បានផ្តល់ការទទួលខុសត្រូវ ដើម្បីមើលខុសត្រូវលើពួកគេឲ្យបានហ្មត់ចត់។

ថ្នាក់រៀនខ្លះមិនមានទំហំធំល្មម ដើម្បីរៀបចំឲ្យមានជ្រុងសិក្សាដាច់ដោយឡែកពីគ្នាឡើយ។ នៅប្រទេសទីមីរខាងកើត មាតាបិតា តា្បាកញ្ជែងដាក់គរជាជង់នៅលើកម្រាលឥដ្ឋ ដែលបំពេញទៅដោយសំបកលៀស ដុំថ្ម គ្រាប់ពូជ និងវត្ថុផ្សេងៗទៀត ដែលគេអាចប្រើ នៅក្នុងមេរៀនគណិតវិទ្យា និងវិទ្យាសាស្ត្រ។ អ្វីដែលសំខាន់ជាមួយសម្ភារសិក្សាទាំងនេះ គឺថា សម្ភារទាំងនេះត្រូវបានប្រើដោយកុមារ។

កន្លែងដាក់តាំងសមិទ្ធិផល

វត្ថុតាំងដ៏សមរម្យដែលជាវត្ថុជំនួយសម្រាប់ការបង្រៀន និងការងាររបស់កុមារនៅក្នុងថ្នាក់រៀននឹងជួយកុមារឲ្យទទួលបាននូវការចាប់អារម្មណ៍ក្នុងការសិក្សារបស់ខ្លួន និងមានអារម្មណ៍ថា ខ្លួនជាផ្នែកមួយរបស់ថ្នាក់រៀន។ មាតាបិតានឹងកាន់តែមានការចាប់អារម្មណ៍ និងយល់ច្បាស់ថែមទៀតអំពីការងារដែលបានប្រព្រឹត្តទៅក្នុងថ្នាក់រៀន។ ការងាររបស់កុមារទាំងអស់គួរតែដាក់តាំងបង្ហាញឲ្យសមរម្យ ដើម្បីបង្ហាញសមត្ថភាពពិសេសរបស់ពួកគេ។

កុមារចង់ឃើញឈ្មោះរបស់ខ្លួននៅក្បែរការងាររបស់ពួកគេ ព្រោះវាធ្វើឲ្យពួកគេមានមោទនភាព។ ចូរផ្លាស់ប្តូរ វត្ថុតាំងបង្ហាញជាប្រចាំ ដើម្បីឲ្យកុមាររក្សានូវការចាប់អារម្មណ៍ ហើយត្រូវឲ្យកុមារម្នាក់ៗដាក់តាំងការងារលួណាមួយនៅក្នុងអំឡុងពេលសិក្សានីមួយៗ។ ការងារដែលបានតាំងបង្ហាញ និងដកយកចេញអាចប្រើដើម្បីបង្កើត**ផលប័ត្រ**របស់កុមារសម្រាប់ធ្វើការឆ្លុះបញ្ចាំង (ចូរមើលគោលទី ៤. ៥ ដើម្បីរៀនអំពី **ផលប័ត្រ និងការវាយតម្លៃផលប័ត្រ**)។

ផ្ទាំងសម្រាប់តាំងបង្ហាញដែលគួរឲ្យចាប់អារម្មណ៍ អាចជាវត្ថុជំនួយសម្រាប់ការបង្រៀនដ៏ល្អមួយ ហើយវានឹងផ្តល់ការផ្តោតការយកចិត្តទុកដាក់ដ៏រស់រវើកមួយនៅក្នុងថ្នាក់រៀន។ គេអាចធ្វើផ្ទាំងសម្រាប់ដាក់តាំងបង្ហាញ សម្ភារទាំងនេះនៅក្នុងស្រុក ដូចជាស្លឹកត្នោតតា្បាញ ដោយមានជំនួយពីសហគមន៍ក្នុងស្រុក។ ផ្ទាំងសម្រាប់តាំងបង្ហាញទាំងនេះមានសារៈសំខាន់ណាស់ ពីព្រោះវាអាចផ្តល់ដល់អ្នកនូវឱកាស :

- ផ្តល់ព័ត៌មានដល់កុមារ។
- តាំងបង្ហាញលទ្ធផលការងាររបស់កុមារ និងកែលំអការគោរពខ្លួនឯងរបស់កុមារ។
- ឲ្យអនុវត្តមេរៀនទាំងឡាយដែលអ្នកបានបង្រៀន។
- ផ្តល់ព័ត៌មានដែលជាចម្លើយតបស្តីពីសកម្មភាពសំខាន់ៗ ដូចជា "សកម្មភាពស្វែងរក"នៅផ្ទះ និងការងារសាកសួរនៅក្នុងសហគមន៍។
- លើកទឹកចិត្តកុមារឲ្យធ្វើការរួមគ្នា និងគាំទ្រគ្នាទៅវិញទៅមក ដោយមិនគិតពីប្រវត្តិ និងសមត្ថភាពរបស់ពួកគេឡើយ។
- បញ្ជាក់ថាកុមារទាំងអស់អាចរៀនពីសមិទ្ធិផលការងាររបស់គ្នាទៅវិញទៅមក។

ប្រសិនជាថ្នាក់រៀនរបស់អ្នកមិនមានជញ្ជាំងឆីង៉មាំទេ អ្នកអាចព្យួរការងារសរសេរ ឬគំនូររបស់កុមារលើខ្សែ ដោយប្រើស្នុត គ្រាប់កិប ឬបន្លា។ "ខ្សែហាលខោអាវ" នេះក៏អាចប្រើផង៉ដែរសម្រាប់ព័ត៌មានគណិតវិទ្យា និង៉ភាសា (កន្លែង៉សម្រាប់សិក្សាដោយការព្យួរវត្ថុ)។

នៅប្រទេសទីម័រខាង៉កើត គ្រូបង្រៀនបានប្រើជំត្រាចាក់ជាគ្រោង៉សម្រាប់គ្រឿង៉តុបតែង៉ដោយចង៉ខ្សែដែលមានតួអក្សរអក្ខរក្រម រូបភាពផ្សេង៉ ។ល។ សម្រាប់អនុវត្តសកម្មភាពភាសា។ ខ្សែសម្រាប់ព្យួរវត្ថុជំនួយជាក់ស្តែង៉ គឺធ្វើពីស្លឹកត្នោត ឬស្លឹកចេកក្បាញ។ ការដែលមាន លក្ខណៈជាប្រពៃណីបានមកពីផ្លែឈើ។ មាតាបិតា និង៉អាណាព្យាបាលដទៃទៀតបានជួយផ្តល់សម្ភារក្នុង៉ស្រុកទាំង៉នេះ ហើយពួកគេបានយល់ដឹង៉ច្រើន ថែមទៀត ពីការបង្រៀន និង៉ការរៀននៅក្នុង៉ដំណើរការនេះ។ បច្ចុប្បន្ននេះ ពួកគេអាចនិយាយជាមួយកូនៗខ្លួន អំពីការសិក្សារបស់ពួកគេនៅសាលា។

បណ្ណាល័យក្នុងថ្នាក់រៀន

សហគមន៍ជនបទជាច្រើនខ្វះសម្ភារឧបទេសបណ្ណាល័យ ដូចនេះកុមារមិនអាចអានសៀវភៅច្រើនបានឡើយ។ បណ្ណាល័យក្នុង៉ថ្នាក់រៀនមួយ អាចត្រូវបានបង្កើតឡើង៉ ដោយគ្រាន់តែប្រើប្រអប់ក្រដាសកាតុង៉ដែលត្រូវបានតុបតែង៉លំអ ហើយបន្ទាប់មកបំពេញដោយសៀវភៅដែលផលិតក្នុង៉ស្រុក។ ពេលដែលកុមារបង្កើតសៀវភៅផ្ទាល់របស់ខ្លួន ទោះជាសាមញ្ញយ៉ាង៉ណាក្តី កុមារមានមោទនភាព ដោយបានឃើញរឿង៉របស់ខ្លួន "បានចោះពុម្ព"។ ពួកគេក៏បានរៀនផង៉ដែរអំពីរបៀបធ្វើសៀវភៅ ការចាត់ជាប្រភេទ និង៉ការថែរក្សា។ អ្នកអាចឲ្យកុមារបង្កើតសៀវភៅដែលជាផ្ទាំង៉ក្រដាសបត់ចុះឡើង៉។ សៀវភៅទាំង៉នេះត្រូវធ្វើពីក្រដាសដែលបត់ចុះឡើង៉ ពីរ ឬបីដង៉ ដោយមានអត្ថបទនៅលើ "ទំព័រ" នីមួយៗ ដូចកូនសៀវភៅផ្សាយពាណិជ្ជកម្ម។ កុមារអាចតែង៉លំអសៀវភៅទាំង៉នេះដោយរូបភាព ហើយសៀវភៅទាំង៉នេះអាចក្លាយជាសម្ភារសម្រាប់អានដ៏មានតម្លៃ ពេលដែលសៀវភៅមួយចំនួនបានបង្កើតឡើង៉។

សៀវភៅដែលកុមារបានបង្កើត អាចធ្វើជាវត្ថុជំនួយសម្រាប់ការបង្រៀនដ៏មានប្រសិទ្ធភាព។ ការពន្យល់ ឬរូបភាពផ្សេង៉ៗដែលកុមារបានដាក់បញ្ចូលក្នុង៉សៀវភៅ អាចជួយកុមារផ្សេង៉ទៀតឲ្យយល់ អំពីគំនិតសំខាន់ៗ។ កុមារសំឡឹង៉មើលបញ្ហាទាំង៉ឆ្ងាយក្នុង៉របៀបមួយដែលខុសពីមនុស្សពេញវ័យ។ កុមារប្រើភាសាដែលង៉ាយយល់ជាង៉មនុស្សចាស់ ហើយអាចទាក់ទង៉បានដោយជោគជ័យនូវព័ត៌មានសំខាន់ៗ បន្ទាប់ពីគ្រូបរាជ័យក្នុង៉ការច្រាស្រ័យទាក់ទង៉។ ចូរង៉ចាំអានសៀវភៅដ៏មានប្រយោជន៍ដែលសិស្សបង្កើត។

ជាងនេះទៀត សៀវភៅមិនត្រឹមតែប្រើសម្រាប់អានប៉ុណ្ណោះទេ អាចប្រើសម្រាប់បង្រៀនជំនាញផ្សេងទៀត ជាពិសេសសម្រាប់កុមារដែលមានបញ្ហាក្នុងការមើល។ ឧទាហរណ៍ គេអាចធ្វើ"សៀវភៅ" មួយក្បាល ដោយយកការមកបិទរបស់ផ្សេងៗលើទំព័រនីមួយៗ។ កុមារអាចដឹងថា វត្ថុទាំងនេះជាអ្វីដោយការស្ទាប។ ឧទាហរណ៍ គេបិទត្រីកោណមួយលើទំព័រសៀវភៅមួយ ដើម្បីឲ្យកុមារដែលមើលមិនឃើញ អាចដឹងថាត្រីកោណនោះមានរៀងដូចម្តេច។ សូម្បីសិស្សដែលអាចមើលឃើញច្បាស់ក៏ដោយ ក៏ចូលចិត្តសៀវភៅបែបនេះដែរ ហើយកុមារអាចហ្វឹកហាត់ប្រើសៀវភៅទាំងនេះដោយការបិទភ្នែក។ កុមារអាចបង្កើតផ្ទាំងផ្សាយពាណិជ្ជកម្មដែលផ្អែកទៅ **លើការស្ទាបជាងការមើលផងដែរ** ហើយត្រូវដាក់នៅកន្លែងតាំងបង្ហាញសមិទ្ធផល។

នៅប្រទេសខ្លះ បណ្ណាល័យក្នុងថ្នាក់រៀន ឬក្នុងសាលា ជាធនធានរបស់សហគមន៍ដ៏សំខាន់មួយ ជាពិសេសនៅពេលដែលកុមារ "ចោះពុម្ពផ្សាយ" លទ្ធផលនៃគម្រោងការប្រមូលទិន្នន័យសហគមន៍ (ដូចជាផែនទីសហគមន៍ និងសាលា ដែលបានបង្ហាញក្នុងកម្រងសៀវភៅលេខ៣)។ ព័ត៌មានស្តីពីអាកាសធាតុ ផ្ទាំងថ្ម និងដីរយៈពេលនៃការធ្វើកសិកម្ម ទីតាំងសម្រាប់លំនៅឋាន។ល។ អាចប្រើដោយបុគ្គលិកសហគមន៍ និងអង្គការមិនមែនរដ្ឋាភិបាល ពេលរៀបចំផែនការសកម្មភាពអភិវឌ្ឍន៍សហគមន៍។



សកម្មភាពអនុវត្ត : ការវាយតម្លៃធនធាន

ចូរក្រឡេកមើលជុំវិញបន្ទប់រៀនរបស់អ្នក រួចបញ្ជាក់ថា នៅពេលនេះអ្នកមានធនធានអ្វីខ្លះ ហើយអ្នកនិង សិស្សរបស់អ្នកអាចបង្កើតអ្វីខ្លះ ក្នុងអំឡុងឆ្នាំសិក្សានេះ។ ចូរសួរកុមារថាតើពួកគេចង់បានអ្វីនៅក្នុងថ្នាក់រៀន រួចបំពេញបន្ថែមអ្វីដែលចង់បាននៅក្នុងតារាងខាងក្រោម

ធនធានរបស់ថ្នាក់រៀន	តើយើងគួរចាប់ផ្តើមគម្រោងនេះនៅពេលណា?	តើយើងត្រូវការធនធានអ្វីខ្លះ ហើយអាចរកធនធានទាំងនេះនៅកន្លែងណា?	តើខ្ញុំអាចទទួលបានជំនួយអ្វីខ្លះ?	តើកុមារនឹងប្រើ ឬ រៀនអំពីធនធានទាំងនេះដូចម្តេចខ្លះ?
ផ្ទាំងក្តារតាំងបង្ហាញការងាររបស់សិស្ស				
ជ្រុងសម្រាប់សិក្សា ឬកន្ត្រកសម្រាប់រៀនគណិតវិទ្យា និងវិទ្យាសាស្ត្រ				
កន្លែងរៀនភាសាដោយការនិទានរឿង បណ្ណាល័យតូចមួយ				
មានក្តារខៀនលើសពីមួយ				
បានបង្កើតគណៈកម្មាធិការថ្នាក់ដើម្បីរៀបចំបង្កើតសម្ភារសិក្សា				
បណ្ណាល័យក្នុងថ្នាក់តូចមួយ ដែលមានសៀវភៅ ឬសម្ភារដទៃទៀតបង្កើតដោយសិស្ស				



គោល ៥.៣
ការគ្រប់គ្រងការងារជាក្រុម និង ការសិក្សាដែលមានកិច្ចសហការគ្នា

វិធីសាស្ត្រធ្វើការងារជាក្រុម

ការបង្រៀនប្រកបដោយប្រសិទ្ធភាព ជាការដាក់បញ្ចូលគ្នានូវវិធីសាស្ត្ររៀន និងបង្រៀន ដែលមានលក្ខណៈខុសប្លែកគ្នាច្រើន។ ការបង្រៀនដូចនេះ អាចឆ្លើយតបតាមតម្រូវការរបស់កុមារ ហើយធ្វើឲ្យថ្នាក់រៀនជាកន្លែងដែលមានភាពរស់រវើក មានការប្រលងប្រណាំង និងមានមេត្រីភាព។ អ្នកអាចប្រើវិធីសាស្ត្របួនដូចខាងក្រោម :

(១) **ការបង្រៀនផ្តាល់ដល់សិស្សទាំងអស់។** *វិធីសាស្ត្រនេះអាចដំណើរការល្អ ជាពិសេសសម្រាប់ការណែនាំសិស្សឲ្យស្គាល់ប្រធានបទ ដោយអ្នកត្រូវរៀបចំសំណួរជាមុន ដើម្បីសួរសិស្សដែលមានកម្រិតយល់ដឹងខុសៗគ្នា។ អ្នកអាចប្រើវិធីសាស្ត្របង្រៀនសិស្សទាំងមូល ដោយការនិទានរឿងណាមួយ ឬបង្កើតរឿងមួយរួមគ្នាជាមួយសិស្ស ដោយការនិពន្ធកំណាព្យ ឬចំរៀងមួយបទ ដោយការបង្កើតល្បែងដោះស្រាយបញ្ហា ឬដោយការធ្វើអង្កេតអ្វីមួយ។ ដោយហេតុថា ថ្នាក់នីមួយៗមានកុមារដែលមានដំណាក់កាលអភិវឌ្ឍន៍ខុសៗគ្នា អ្នកចាំបាច់ត្រូវជ្រើសរើស និងសម្រួលខ្លឹមសារដែលអ្នកបង្រៀនដើម្បីឲ្យសមស្របសម្រាប់គ្រប់កម្រិត និង សមត្ថភាពរបស់សិស្ស។*

ដើម្បីលើកទឹកចិត្តកុមារទាំងអស់ឲ្យចូលរួមគ្រប់សកម្មភាពសិក្សា យើងត្រូវផ្តល់ការកិច្ចខុសៗគ្នាដល់ក្រុមផ្សេងៗគ្នារបស់កុមារ។ ឧទាហរណ៍ អ្នកអាចផ្តល់ការនិពន្ធរឿងដល់ក្រុមមួយ ការបំពេញប្រយោគដល់ក្រុមមួយទៀត ហើយការធ្វើគំរូដល់ក្រុមមួយទៀត។ អ្នកអាចផ្តល់ការងារដូចគ្នាដល់សិស្សទាំងអស់បាន ប៉ុន្តែ អ្នកគួរគិតថា នឹងបានទទួលលទ្ធផលខុសៗគ្នា។ (ចូរចាំថា : កុមារពីរក្រុម ឬពីរនាក់មិនមានលទ្ធផលដូចគ្នាឡើយ។ គ្រប់ថ្នាក់ទាំងអស់សុទ្ធតែខុសៗគ្នា)។ ឧទាហរណ៍ សម្រាប់ការងារមួយដូចគ្នា សិស្សមួយក្រុមអាចបង្កើតជារឿងមួយ សិស្សមួយក្រុមទៀតអាចតែបញ្ជីប្រយោគឲ្យបានត្រឹមត្រូវ ហើយក្រុមមួយទៀតផលិតផ្ទាំងផ្សាយពាណិជ្ជកម្ម។

(២) **ការបង្រៀនផ្តាល់ដល់សិស្សមួយក្រុមដែលមានកម្រិតដូចគ្នា (ជាពិសេសក្នុងថ្នាក់ដែលមានកម្រិតសមត្ថភាពចម្រុះ)។** *នៅពេលអ្នកកំពុងបង្រៀនសិស្សមួយក្រុម សិស្សនៅក្រុមផ្សេងៗទៀត*

ត្រូវធ្វើការងារផ្ទាល់របស់ខ្លួន។ ការបង្រៀនមិត្តភក្តិអាចមានប្រយោជន៍ជាពិសេស នៅពេលដែលកុមារមានជំនឿជឿជាក់។ ដំបូងក្រុមទាំងអស់នឹងមិនអភិវឌ្ឍជំនាញ ដើម្បីធ្វើការបានជាប់លាប់ដោយគ្មានការណែនាំនោះទេ ក៏ប៉ុន្តែ ដោយមានការហ្វឹកហាត់ និងសកម្មភាពដែលផ្តែកលើជំនាញជាក់លាក់ ពួកគេអាចចេះធ្វើការដោយមានកិច្ចសហការគ្នាល្អ។

(៣) **ការបង្រៀនសិស្សម្នាក់** គឺពេលដែលអ្នកបង្រៀនកុមារម្នាក់ ដោយផ្តែកលើមូលដ្ឋានម្នាក់ម្តង។ ការបង្រៀនដូចនេះអាចជួយកុមារដែលរៀនមិនទាន់គេ ដោយសារអវត្តមាន ឬកុមារដែលមានបញ្ហាពិបាកក្នុងការសិក្សា ឬកុមារចំណូលថ្មី។ អ្នកក៏ត្រូវការបង្រៀនសិស្សម្នាក់ៗផងដែរ ដើម្បីជួយ"កុមារដែលមានទេពកោសល្យ" និងលើកទឹកចិត្តកុមារទាំងនោះឲ្យធ្វើការងារ ដែលមានលក្ខណៈប្រកួតប្រជែងថែមទៀតផង។ ទោះជាយ៉ាងណាក្តី អ្នកត្រូវបង្រៀនសិស្សម្នាក់ៗក្នុងរយៈពេលដ៏ខ្លីនៅពេលបង្រៀនមេរៀន ដើម្បីឲ្យអ្នកអាចបង្រៀនកុមារភាគច្រើនក្នុងថ្នាក់បាន។

(៤) **ការបង្រៀនក្រុមតូចៗ** គឺនៅពេលអ្នកបែងចែកថ្នាក់ទាំងមូលទៅជាក្រុមតូចៗសម្រាប់រៀន។ នេះគឺជាយុទ្ធសាស្ត្រដ៏មាន ប្រសិទ្ធភាពមួយ ប៉ុន្តែអ្នកត្រូវរៀបចំឲ្យបានល្អ និងមានសណ្តាប់ធ្នាប់។ វាអាចចំណាយពេលក្នុងការរៀបចំ ហើយកុមារត្រូវត្រៀមខ្លួនចំធ្វើការរួមគ្នាផងដែរ។ ទោះជាយ៉ាងណាក្តី នេះគឺជាវិធីដ៏មានប្រសិទ្ធភាពមួយក្នុងការឆ្លើយតបទៅនឹងតម្រូវការសិស្សផ្សេងៗគ្នា។

ការប្រើវិធីរៀបចំជាក្រុមសិក្សាផ្សេងៗ

អ្នកអាចរៀបកុមារជាក្រុមដោយមានវិធីខុសៗគ្នាជាច្រើន។ ឧទាហរណ៍ ក្រុមដែលមានកម្រិតសមត្ថភាពដូចគ្នា ក្រុមដែលមានកម្រិតសមត្ថភាពចម្រុះ ក្រុមដែលមានភេទដូចគ្នា ក្រុមចម្រុះភេទ ក្រុមដែលមានសមត្ថភាពដូចគ្នា ក្រុមដែលមានសមត្ថភាពចម្រុះ ក្រុមចំណាប់អារម្មណ៍ ក្រុមមិត្តភាព/សង្គម ក្រុមដែលមានគ្នាពីរនាក់ បីនាក់ ឬបួននាក់។ កុមារទទួលផលប្រយោជន៍ជាច្រើនពីការរៀបជាក្រុមដោយប្រើវិធីខុសៗគ្នា នៅពេលខុសៗ គ្នា។

ត្រូវចេះបត់បែន។ ផ្លាស់ប្តូរកុមារតាមក្រុមផ្សេងៗ។ ត្រូវផ្តល់ដល់កុមារនូវឱកាសអង្គុយ និងធ្វើការជាមួយមិត្តរួមថ្នាក់របស់គេឲ្យបានច្រើនតាមដែលអាចធ្វើទៅបាន ជាមួយកុមារដែលមានអាយុក្មេង ឬចាស់ជាង ព្រមទាំងកុមារដែលមានប្រវត្តិ និងសមត្ថភាពខុសគ្នា។ ការធ្វើបែបនេះនឹងជួយបង្រៀនកុមារឲ្យចេះអត់ធ្មត់ ហើយចង់ចាំទេពកោសល្យកុមារទាំងអស់នៅក្នុងថ្នាក់។

ចូរប្រយ័ត្នក្នុងការចាត់ទុកកុមារជាអ្នករៀនខ្សោយ។ កុមារខ្លះអាចរៀនខ្សោយជាងកុមារដទៃទៀតផ្នែកគណិតវិទ្យា ប៉ុន្តែពូកែផ្នែកអនុវត្តការងារប្រើដោយដៃ ដូចជា ការរៀបចំធ្វើគម្រោងការងារវិទ្យាសាស្ត្រ ឬធ្វើសៀវភៅសម្រាប់កុមារ។ យើងត្រូវប្រយ័ត្ន ពីព្រោះកុមារដែលមានអារម្មណ៍ថា គេជាសិស្សខ្សោយនៅក្នុងកែវភ្នែករបស់គ្រូ នៅពេលមិនយូរនឹងយល់ថា រូបគេពិតជាសិស្សខ្សោយច្រាកដមែន។ ពួកគេអាចបាត់បង់

ការចាប់អារម្មណ៍រៀនសូត្រនៅសាលាជាទូទៅ ពីព្រោះពួកគេមិនទទួលបានរង្វាន់ណាមួយពីការរៀនសូត្រឡើយ។ ពួកគេចាប់ផ្តើមជឿថា ពួកគេគ្មានសមត្ថភាពរៀនពូកែឡើយ ដូចនេះពួកគេអាចបោះបង់ចោលការរៀនសូត្រ និងទៅរកលុយសម្រាប់គ្រួសារ។

រៀបចំសម្ភារដើម្បីឱ្យសិស្សធ្វើការជាក្រុម។ ចូរចងចាំថា ល្បែងនានា បណ្តុំ និងសម្ភារផ្សេងទៀត ទោះជាត្រូវចំណាយពេល ដើម្បីធ្វើក៏ដោយ ក៏អ្នកអាចប្រើម្តងហើយម្តងទៀត។ សម្ភារទាំងនេះអាចដោះដូរបាន ឬចម្លងបាននៅក្នុងអំឡុងពេលប្រជុំរបស់សាលា។ ចូរកុំភ្លេចថា សិស្សរបស់អ្នកអាចជួយអ្នកធ្វើសម្ភារទាំងនេះបាន ហើយសិស្សនឹងជួយសម្រាលបន្ទុកការងាររបស់អ្នកនៅពេលអ្នកផ្តល់នូវឱកាសរៀនសូត្រដ៏មានតម្លៃដល់កុមារ និងការទទួលខុសត្រូវដល់កុមារ។

គិតអំពីប្លង់ថ្នាក់រៀនរបស់អ្នក។ តើត្រូវរៀបចំគ្រឿងសង្ហារឹមឲ្យបានល្អ រហ័ស និងងាយស្រួលសម្រាប់ធ្វើការជាក្រុមដោយរបៀបណា? កុមារត្រូវរៀនរៀបចំ និងរៀបចំឡើងវិញនូវថ្នាក់រៀន ផ្អែកទៅតាមសកម្មភាពរៀននៅក្នុងថ្នាក់ជាក់ស្តែង។ ចូរធ្វើការជាមួយកុមារ ដើម្បីសម្រេចអំពីការរៀបចំថ្នាក់រៀនបានល្អបំផុតសម្រាប់សិស្សគ្រប់សមាសភាព។

ត្រូវបញ្ជាក់ឱ្យច្បាស់ថា ការងារប្រចាំថ្ងៃបានបង្កើតយ៉ាងរឹងមាំ។ កុមារត្រូវការយល់ដឹងឲ្យច្បាស់ថានឹងត្រូវផ្លាស់ប្តូរទៅក្រុមណាមួយដោយរបៀបណា នឹងត្រូវចាប់ផ្តើមដោយរបៀបណា នឹងត្រូវធ្វើអ្វីពេលដែលពួកគេបានបញ្ចប់ការងាររបស់ខ្លួនរួចហើយ ។ល។

គួរផ្តល់ការទទួលខុសត្រូវដឹកនាំក្រុមដល់កុមារទាំងអស់។ អ្នកដឹកនាំក្រុមត្រូវដើរតួនាទីសំខាន់មួយក្នុងការជួយគ្រូបង្រៀន ដូចជា ការច្រាប់បន្តស្តីពីការណែនាំរបស់គ្រូ ការចែកចាយសម្ភារ ការដឹកនាំក្រុមតាមរយៈសកម្មភាព ការរាយការណ៍ដល់គ្រូបង្រៀន ។ល។

> នៅប្រទេសកូរ៉ុបុី ក្រដាសមួយសន្លឹកធំសម្រាប់ត្រួតពិនិត្យការវិវឌ្ឍរបស់សិស្សត្រូវបានភ្ជាប់ទៅលើជញ្ជាំង។ កុមារចុះហត្ថលេខាលើក្រដាសនេះ ពេលដែលពួកគេបានបំពេញចប់សកម្មភាពណាមួយ ហើយបន្ទាប់មក គ្រូបង្រៀនបន្ថែមមួយកម្រិតទៀត។ ការធ្វើដូចនេះនឹងអាចទប់ស្កាត់ការឈរតម្រង់ជួររបស់សិស្សនៅតុរបស់គ្រូ ដែលរង់ចាំគ្រូដាក់ពិន្ទុលើការងាររបស់ខ្លួន។

ការសិក្សាដែលមានកិច្ចសហការគ្នា

ការសិក្សាដែលមានកិច្ចសហការគ្នា កើតមាននៅពេលកុមារចែករំលែកគ្នានូវការទទួលខុសត្រូវនិងធនធាន ព្រមទាំងនៅពេលដែលកុមារ ធ្វើការសំដៅសម្រេចគោលដៅរួមមួយ។ ការអភិវឌ្ឍនូវជំនាញរបស់ក្រុមការងារដែលមានកិច្ចសហការគ្នាមានការទាក់ទងនឹងពេលវេលា ការហ្វឹកហាត់ និងការអនុវត្តនូវ

អាកប្បកិរិយាសមរម្យ។ គ្រូបង្រៀនដើរតួនាទីយ៉ាងសំខាន់ក្នុងការបង្កើតបរិយាកាសគាំទ្រមួយដែលធ្វើឲ្យកុមារមានអារម្មណ៍ និងយល់ថាមានសុវត្ថិភាព ហើយជាបរិយាកាសដែលឲ្យតម្លៃលើមតិយោបល់របស់កុមារ។

ការងារជាក្រុមដែលមានកិច្ចសហការគ្នាអាចជួយអ្នកសិក្សាបង្កើនការយល់ដឹង ព្រមទាំងជំរុញភាពវិករាយ និងភរិយាបថវិជ្ជមានចំពោះការងារ និងចំពោះខ្លួនឯងផ្ទាល់។ ប៉ុន្តែ ដើម្បីឲ្យកុមារទាំងអស់ទទួលបានផលប្រយោជន៍ពីសកម្មភាពជាក្រុមដែលមានកិច្ចសហការគ្នា កុមារត្រូវការឱកាស ដើម្បីអភិវឌ្ឍជំនាញ និងតួនាទីផ្សេងៗ។ ឧទាហរណ៍ កុមារីអាចត្រូវការបទពិសោធជាអ្នកដឹកនាំកម្មវិធីទូរទស្សន៍ ឬវិទ្យុ ហើយ កុមារាអាចត្រូវការបទពិសោធជាអ្នកកត់ត្រាពេលប្រជុំ។ កុមារទាំងអស់ត្រូវការអភិវឌ្ឍជំនាញនិយាយ និងស្តាប់ដ៏ប៉ិនប្រសព្វ។

កុមារខ្លះមិនដែលរៀនអំពីវិធីឲ្យតម្លៃលើគំនិតរបស់អ្នកដទៃទេ។ បញ្ហានេះអាចបង្ហាញឃើញការពិតជាក់ស្តែងពេលដែលកុមារត្រូវធ្វើការជាក្រុមចម្រុះ។ ជារឿយៗ កុមារីព្រមទទួលយកគំនិតរបស់កុមារាដើម្បីបញ្ចៀសជម្លោះ។ កុមារជាច្រើនហាក់ដូចជាចង់ច្រានចោល ឬសើចចំអកគំនិតរបស់កុមារី។ ស្ថានភាពដូចគ្នាដែលនេះអាចកើតមានក្នុងចំណោមកុមារ ដែលមកពីក្រុមជនជាតិភាគតិច ឬមិនចេះនិយាយភាសាដែលខ្លួនកំពុងរៀនច្បាស់លាស់។ កុមារទាំងនោះត្រូវងាកមកស្តាប់តាមកុមារដែលស្ថិតក្នុងក្រុមធំជាង។

ប្រសិនជាកុមារខ្លះមានឥទ្ធិពលគ្របដណ្តប់លើពេលវេលានៃការពិភាក្សារហូត កុមារដទៃទៀតបាត់បង់ឱកាសដើម្បីសំដែង និងអះអាងបញ្ហាក់ពីគំនិត និងយោបល់របស់ខ្លួន។ តើកុមារដែលមានប្រវត្តិ និងសមត្ថភាព ផ្សេងគ្នាអាចមានជំនឿជឿជាក់ ដើម្បីអះអាងពី គំនិតរបស់ខ្លួនបានដោយរបៀបណា? ក្នុងករណីខ្លះអាចជាការចាំបាច់ដោយនៅពេលដំបូងត្រូវរៀបកុមារជាក្រុមដែលមានលក្ខណៈដូចគ្នា (ឧទាហរណ៍ ក្រុមដែលមានភេទដូចគ្នា) ដើម្បីឲ្យអភិវឌ្ឍជំនាញ និងជំនឿជឿជាក់របស់កុមារ។ បន្ទាប់មក ក្រុមទាំងនេះត្រូវលាយបញ្ចូលគ្នានៅ ពេលកុមារបានអភិវឌ្ឍជំនាញទំនាក់ទំនងរបស់ខ្លួន។

ក្នុងវប្បធម៌ខ្លះ ប្រជាជនយល់ថា ការរៀនពិតប្រាកដគឺចេញមកពីគ្រូបង្រៀនតែប៉ុណ្ណោះ។ ដូចនេះហើយពួកគាត់មិនបានឃើញតម្លៃ ឬផលប្រយោជន៍នៃការធ្វើការងារជាក្រុម ។ដែលមានកិច្ចសហការគ្នាឡើយ។ ថ្វីបើ គេគួរទទួលស្គាល់ការយល់ឃើញបែបនេះក៏ដោយ ជំនាញដែលកុមារអភិវឌ្ឍតាមរយៈការរៀនសូត្រដែលមានកិច្ចសហការគ្នាមានសារៈសំខាន់យ៉ាងខ្លាំងចំពោះកុមារ ដោយមិនគិតពីប្រវត្តិខុសៗគ្នារបស់ពួកគេឡើយ។ ជាការសំខាន់គឺត្រូវផ្តល់ព័ត៌មានដល់មាតាបិតាកុមារអំពីការផ្លាស់ប្តូរនានាក្នុងវិធីសាស្ត្ររៀននិងការបង្រៀន។ ឧទាហរណ៍ ការបង្កើតវត្ថុជំនួយជាក់ស្តែងសម្រាប់ការបង្រៀន ឬល្បែងនានាអាចជួយឲ្យមាតាបិតា យល់នូវអ្វីដែលគ្រូកំពុងព្យាយាមបង្រៀនសិស្ស។

ជំនាញសហប្រតិបត្តិការអាចរីកចម្រើនយ៉ាងមានប្រសិទ្ធភាពបំផុតនៅក្នុងបរិបទដ៏មានអត្ថន័យ។ សកម្មភាពទាំងឡាយ ដែលគ្មានដែនកំណត់ និងតម្រូវឲ្យមានការគិតផ្សេងៗគ្នា (ដូចជាការដោះស្រាយបញ្ហា) មានលក្ខណៈសមរម្យ ជាពិសេសសម្រាប់ការអភិវឌ្ឍជំនាញការងារជាក្រុមដែលមានកិច្ចសហប្រតិបត្តិការ។

ជំនាញទំនាក់ទំនងជាមួយមនុស្សផ្សេងក្នុងការរៀនសូត្រ

ការបង្កើតស្មារតីសាមគ្គីជាក្រុមនឹងនាំឲ្យថ្នាក់ទាំងមូលទទួលបានជោគជ័យ។ ការប្រកួតប្រជែងដែលបំបែកកុមារី ពីកុមារា ឬបំបែកកុមារដែលមានប្រវត្តិ និងសមត្ថភាពខុសពីគេ ព្រមទាំងការចូលចិត្តនិយមក្រុមមួយ។ អាចរារាំងដល់ការរៀនសូត្ររបស់កុមារទាំងអស់។ ក្នុងឋានៈជាគ្រូបង្រៀន អ្នកអាចជួយកុមារឲ្យគិតថា កុមារទាំងអស់គឺជាក្រុមការងារតែមួយ ដែលក្នុងនោះការទទួលបានជោគជ័យរបស់កុមារណាម្នាក់នឹងជួយអ្នករាល់គ្នាឲ្យទទួលបានជោគជ័យដែរ។

ការច្រាស្រ៊ែយទាក់ទងប្រកបដោយប្រសិទ្ធភាពមានការពាក់ព័ន្ធទៅនឹងការស្តាប់ ការនិយាយ និងការផ្លាស់ប្តូរវេនគ្នា។ ទាំងនេះជាជំនាញចាំបាច់សម្រាប់ការងារជាក្រុមដែលមានកិច្ចសហប្រតិបត្តិការ និងជាជំនាញសម្រាប់ភាពជាពលរដ្ឋដែលមានលក្ខណៈប្រជាធិបតេយ្យ។ គ្រូបង្រៀនដ៏ល្អម្នាក់ត្រូវគ្រប់គ្រងការច្រាស្រ៊ែយទាក់ទងគ្នា ដើម្បីឲ្យដឹងច្បាស់ថា កុមារខ្លះមិនបានឆ្លើយសំណួរអ្វីទាំងអស់ ឬកុមារខ្លះបានគ្របដណ្តប់លើការពិភាក្សាទាំងមូល។

កុមារទទួលខុសត្រូវក្នុងការស្តាប់ និងយល់អ្វីដែលបាននិយាយគ្នាទៅវិញទៅមក។ ការស្តាប់ដ៏យកចិត្ត ទុកដាក់គឺជាផ្នែកមួយដ៏ សំខាន់នៃបរិយាកាសសិក្សា។ ការនិយាយបានច្បាស់ ព្រមទាំងការលើកឡើងពីគំនិត និងអារម្មណ៍ដែលមិនជ្រៀតជ្រែកសិទ្ធិរបស់អ្នកដទៃក៏មានសារៈសំខាន់ផងដែរ។ ការយកភាសាក្នុងស្រុកមកប្រើក្នុងថ្នាក់រៀនក៏ជួយកុមារទាំងអស់ឲ្យចូលរួមក្នុងសកម្មភាពសិក្សាផ្សេងៗផងដែរ។

សរុបសេចក្តី :

- កិច្ចសហការគ្នា អាចជួយអ្នកសិក្សាឲ្យធ្វើការរួមគ្នា ព្រមទាំងចែករំលែកជាមួយគ្នានូវការទទួលខុសត្រូវ សម្ភារសិក្សា តួនាទី និងឱកាសសិក្សា។
- ក្រុមតូចៗរបស់កុមារ អាចបែងចែកតួនាទី និងចែករំលែកការទទួលខុសត្រូវនានា។ ក្នុងសកម្មភាពផ្នែកវិទ្យាសាស្ត្រ កុមារម្នាក់អាចថ្លឹងសម្ភារផ្សេងៗ។ ចំណែកកុមារម្នាក់ទៀត អាចកត់ត្រាពីលទ្ធផល។ បន្ទាប់ពីធ្វើសកម្មភាពបានពាក់កណ្តាល កុមារអាចធ្វើការផ្លាស់ប្តូរតួនាទីគ្នា។ កិច្ចសហការត្រូវតែអនុវត្ត ប្រសិនជាក្រុមកុមារទាំងនោះធ្វើការដោយឯករាជ្យដាច់ពីគ្នា។
- ការដោះស្រាយបញ្ហា និងការចរចាជួយអ្នកសិក្សាដោះស្រាយជម្លោះ និងធ្វើការសម្រេចចិត្ត។ កុមារត្រូវរៀន និងអនុវត្តជំនាញគ្រប់គ្រងជម្លោះ ដែលផ្អែកលើជំនាញទំនាក់ទំនងគ្នាល្អ និងតវិយាបថចេះអត់ធ្មត់។

- ដើម្បីរៀនពីរបៀបក្នុងការគិត ចាំបាច់ត្រូវលើកទឹកចិត្តកុមារឲ្យឯកភាពតាមគោលដៅ វាយតម្លៃជម្រើសផ្សេង។ សម្រេចចិត្ត និងគាំទ្រសេចក្តីសម្រេចទាំងនោះ ព្រមទាំងអនុវត្តបន្ត ដើម្បីដឹងពីលទ្ធផលនៃជម្រើសរបស់ខ្លួន។ ដំណើរការទាំងអស់នេះ ត្រូវពឹងផ្អែកលើស្មារតីជាក្រុម ការច្រាស្រៃយទាក់ទង និងកិច្ចសហប្រតិបត្តិការ។

ការបង្កើតវិន័យសម្រាប់ការងារជាក្រុម

គោលការណ៍ណែនាំសម្រាប់ការចូលរួម ឬ "ច្បាប់ការងារជាក្រុម" អាចជួយអ្នកឲ្យចេះរៀបចំពេលសម្រាប់ការពិភាក្សាជាមួយសិស្ស។ គោលការណ៍ណែនាំទាំងនេះផ្តល់មូលដ្ឋានសម្រាប់កិច្ចសន្ទនា និងពិភាក្សាគ្នាប្រកបដោយការគោរពគ្នា និងដោយចំហ ហើយអាចឲ្យកុមារទាំងអស់ចូលរួមពិភាក្សា។

មធ្យោបាយដ៏ល្អបំផុត ដើម្បីបង្កើតច្បាប់ការងារជាក្រុម គឺត្រូវឲ្យកុមាររៀបចំបង្កើតបញ្ជីមួយ។

១. ស្តាប់ដោយយកចិត្តទុកដាក់ គោរពអ្នកដទៃពេលដែលគេកំពុងនិយាយ ប៉ុន្តែត្រូវចូលរួមយ៉ាងពេញលេញ។

២. និយាយពីបទពិសោធផ្ទាល់របស់អ្នក (ប្រើពាក្យ "ខ្ញុំ" ជំនួសពាក្យ "អានេះ ឬអានោះ")។

៣. កុំធ្វើការនិយាយវាយប្រហារផ្ទាល់ខ្លួន ត្រូវផ្តោតទៅលើគំនិត មិនត្រូវផ្តោតលើមនុស្សឡើយ។

ជាការសំខាន់ផងដែរដោយត្រូវកំណត់វិធានមូលដ្ឋានមួយស្តីពីវិធីសម្រាប់គ្រប់គ្រងការចូលរួម។ ឧទាហរណ៍ ដោយហេតុថា អ្នករាល់គ្នាមានឱកាសក្នុងការនិយាយ ក្រុមការងារអាចប្រើ "ឧក្អោសនៈសព្វវេទមន្ត"មួយ។ "ឧក្អោសនៈសព្វវេទមន្ត"នេះ អាចជាសំបកខ្យង ឬ ដុំថ្មដែលត្រូវហុចបន្តដុំវិញ ហើយពេលដែលអ្នកណាម្នាក់ទទួលបានសំបកខ្យង ឬដុំថ្មនោះ អ្នកនោះដល់វេនត្រូវនិយាយ ប្រសិនជាចង់និយាយ។ ប្រសិនជាគេចង់ "បញ្ជូនបន្ត" គេអាចហុចសំបកខ្យង ឬ ដុំថ្មនោះបន្តទៅអ្នកបន្ទាប់ទៀត។ ការធ្វើដូចនេះអាចកាត់បន្ថយនូវការគ្រប់ដណ្តប់ដោយអ្នកពូកែនិយាយមួយនាក់ ឬពីរនាក់។

ចូរមើលវិធានមូលដ្ឋានម្តងទៀត ហើយប្រសិនជាមានពេល ចូរសួរថាតើកុមារចង់បន្ថែមវិធានថ្មីណាមួយ ឬប្តូរវិធានចាស់ណាមួយឬទេ។



សកម្មភាពអនុវត្ត :ការវាយតម្លៃជំនាញអន្តរបុគ្គល

ការសង្កេតមើលគឺជាជំនាញសំខាន់មួយសម្រាប់វាយតម្លៃជំនាញអន្តរៈបុគ្គល។ ចូរព្យាយាមវិភាគរបៀបធ្វើការរបស់ក្រុមការងារនីមួយៗ។

ជំនាញ	កុមារ ក	កុមារ ខ	កុមារ គ
ស្តាប់បានច្បាស់			
សំដែងចេញច្បាស់			
ប្រកាន់យកតួនាទីដឹកនាំ			
គាំទ្រអ្នកដទៃ			

ដោយផ្អែកលើការសង្កេតមើលរបស់អ្នក អ្នកអាចផ្តល់សកម្មភាពបន្ថែមសម្រាប់កុមារខ្លះដើម្បីអភិវឌ្ឍជំនាញ ជាក់លាក់មួយដែលចាំបាច់សម្រាប់ការងារជាក្រុម។

ការគ្រប់គ្រងការសិក្សាជាមួយមិត្តភក្តិ

ការបង្រៀនមិត្តភក្តិ

ការបង្រៀនមិត្តភក្តិ ឬហៅថាការរៀនសូត្រពីកុមារម្នាក់ទៅម្នាក់ កើតមាន នៅពេលកុមារអាយុច្រើនបន្តិច ឬមានសមត្ថភាពជាង់បញ្ចប់ការងារផ្ទាល់របស់ខ្លួន ហើយបន្ទាប់មកជួយអ្នករៀនអាយុក្មេងជាងគេ ឬអ្នករៀនដទៃទៀត។ គេរក្សាពេលវេលា ពិសេសរាល់ថ្ងៃសម្រាប់ឲ្យកុមារជួយគ្នា ទៅវិញទៅមក ដើម្បីរៀនគណិតវិទ្យា ឬភាសា ដោយបង្រៀនម្នាក់ទល់ម្នាក់ ឬបង្រៀនជាក្រុមតូច។។

ការបង្រៀនអ្នកមានអាយុប្រហាក់ប្រហែលគ្នាគឺជាបច្ចេកទេសអប់រំដ៏មានតម្លៃមួយ ពីព្រោះវាជួយឆ្លើយតបតម្រូវការរបស់កុមារម្នាក់ៗ។ វាជួយជំរុញជង់ដែរនូវវិធីសាស្ត្រសហការគ្នាជាជាង់វិធីសាស្ត្រប្រកួតប្រជែងក្នុងការរៀនសូត្រ។ ការគោរព និងយោគយល់គ្នាទៅវិញទៅមកត្រូវបានបង្កើតរវាង់អ្នកដែលធ្វើការរួមគ្នា។ កុមារ "ដែលជាអ្នកបង្រៀន" មានមោទនភាពក្នុងការបង្រៀន ហើយក៏រៀនពីបទពិសោធន៍នៃការបង្រៀននេះដង់ដែរ។ ការបង្រៀនក៏ជួយពង្រឹងជង់ដែរនូវអ្វីដែលកុមារបានរៀន ហើយកុមារទទួលផលប្រយោជន៍ជាច្រើនពីការផ្តល់ឲ្យនូវការទទួលខុសត្រូវនៅក្នុងថ្នាក់រៀន។ ពេលកុមារកំពុងរៀនជាមួយ "គ្រូបង្រៀនវ័យប្រហាក់ប្រហែលគ្នា" អ្នករៀនបានអភិវឌ្ឍសមត្ថភាពកាន់តែប្រសើរឡើងក្នុងការស្តាប់ ផ្តោតការយកចិត្តទុកដាក់ និងយល់អ្វីដែលកំពុងរៀនប្រកបដោយអត្ថន័យ។ ការពន្យល់របស់កុមារដល់គ្នាទៅវិញទៅមក ជួនកាលអាចទទួលបានជោគជ័យ ប្រសើរជាង់ការពន្យល់របស់គ្រូដែលទទួលបរាជ័យ។ កុមារសម្លឹងមើលបញ្ហានានាក្នុងរបៀបមួយខុសពីមនុស្សពេញវ័យ ហើយពួកគេប្រើភាសាប្រកបដោយមេត្រីភាពសម្រាប់អ្នករៀនទាំងអស់គ្នា។

ការបង្រៀនរៀនអានដល់មិត្តភក្តិ

ក្នុងការរៀនអាន ការបង្រៀនមិត្តភក្តិអាចជួយអ្នកមានបញ្ហាក្នុងការអាន ឬអាចផ្តល់ការអានបន្ថែមដល់អ្នកមានអាយុក្មេងជាងគេក្នុងថ្នាក់។

- វាអាចមានឥទ្ធិពលវិជ្ជមាន ទាំងផ្នែកអប់រំ និងសង្គម ទៅលើអ្នកបង្រៀនជាកុមារ និងអ្នករៀនជាកុមារ។
- វាអាចជាមធ្យោបាយសំខាន់មួយដែលជាជំនួយជួយដល់កុមារក្នុងការអាន។
- ជាការគួរឲ្យក្រាក់ផ្អើលផងដែរគឺថា កម្រិតអានរបស់អ្នកបង្រៀនជាកុមារកាន់តែល្អប្រសើរឡើង។
- ពេលវេលាដែលកុមារអាយុក្មេងជាងគេចូលរួមយ៉ាងសកម្មក្នុងការអាននឹងត្រូវបង្កើនថែមទៀតដោយការប្រើបច្ចេកទេសនេះ។ អ្នកអានដែលខ្សោយ ឬមានអាយុក្មេងជាងទទួលបានប្រយោជន៍ជាច្រើនពីការយកចិត្តទុកដាក់របស់អ្នកដទៃ។ ជារឿយៗ គ្រូបង្រៀនមិនមានពេលគ្រប់គ្រាន់ដើម្បីផ្តល់ជំនួយប្រភេទនេះដល់កុមារម្នាក់ៗឡើយ។

ទោះជាយ៉ាងណាក្តី ជាការចាំបាច់ត្រូវពន្យល់អ្នកបង្រៀនជាកុមារដោយយកចិត្តទុកដាក់ពីអ្វីមួយពិតប្រាកដដែលអ្នកចង់ឲ្យពួកគេធ្វើ។ អ្នកបង្រៀនទាំងនោះត្រូវយល់ពីអ្វីដែលអ្នកចង់បានពីពួកគេ។ ពួកគេត្រូវធ្វើការ ជាមួយកុមារអាយុក្មេងជាងក្នុងរបៀបគាំទ្រដោយមានមេត្រីភាព និងស្ងាត់ស្ងៀម។ គួរបញ្ជៀសនូវភាពមិនចេះអត់ធ្មត់។ ខាងក្រោមជាឧទាហរណ៍មួយស្តីពីបច្ចេកទេសបង្រៀនអ្នកមានអាយុប្រហាក់ប្រហែលគ្នាក្នុងការអាន។

បច្ចេកទេសអានជាគូ បច្ចេកទេសនេះត្រូវផ្អែកលើការអានតាមរបៀបនេះ :

(ក) ត្រូវឆ្លាស់គ្នារវាងការអានរួមគ្នាពីៗទាំងអ្នកបង្រៀន និងអ្នករៀន និងការអានតែឯងដោយអ្នករៀន។

(ខ) ប្រើសំដីពន្យល់វិជ្ជមាន ក្នុងការបង្គាប់អ្នករៀនអានតែឯងឲ្យត្រឹមត្រូវ។

ត្រូវបណ្តុះបណ្តាលអ្នកបង្រៀនជាកុមារ :

- ឲ្យចេះណែនាំបង្ហាញពីសៀវភៅក្នុងរបៀបមួយដែលមានការលើកទឹកចិត្ត។

- ពន្យារការកែកំហុស ដោយទុកពេលឲ្យអ្នករៀនព្យាយាមកែដោយខ្លួនឯង។
- ពិភាក្សាអំពីអត្ថបទក្រោយពីអានរួច។
- ពិនិត្យលើការអនុវត្តរបស់ខ្លួនជាអ្នកបង្រៀន និងលើការវិភាគចម្រើនរបស់អ្នករៀន ដោយការបំពេញបំណុរាយការណ៍ និងបញ្ជីត្រួតពិនិត្យ។

វិធីសាស្ត្រនេះអនុវត្តតាមគំនិតស្តីពីការអានរួមគ្នាដែលទទួលបានប្រជាប្រិយភាពនៅតាមសាលានៃកោះមហាសមុទ្រប៉ាស៊ីហ្វិក តាមរយៈការណែនាំឲ្យស្គាល់នូវគំនិតផ្តួចផ្តើមដូចជា រត្បិមខ្លួនដើម្បីអាន។ បទពិសោធនៃសៀវភៅអានរួមគ្នាពាក់ព័ន្ធនឹងសៀវភៅធំៗដែលមានការចោះពុម្ពធំល្មមសម្រាប់ថ្នាក់ទាំងមូលអាន ជាមួយគ្រូបង្រៀន។ គ្រូបង្រៀនលើកោះមួយចំនួនបានចូលរួមការបណ្តុះបណ្តាលវិភ្រឹត្យការស្តីពីបច្ចេកទេសនេះ ហើយបានសរសេរ និងចងក្រងបង្កើត "សៀវភៅធំ" របស់ខ្លួនផ្ទាល់។

- Pacific Literacy and the Essential Dimensions of Reading
http://www.learningmedia.com/html/cr_us_pl-share.htm

ស្វ័យសិក្សា

ស្វ័យសិក្សាមានសារៈសំខាន់ណាស់ ព្រោះកុមារត្រូវការរៀនដោយឯករាជ្យពីគ្រូបង្រៀន។ ការរៀនបែបនេះអាចឲ្យសិស្ស និងគ្រូប្រើប្រាស់បានល្អបំផុតនូវពេលវេលាដែលមាន។ ខាងក្រោមនេះជាគំនិតខ្លះៗ ដើម្បីជួយបង្កើនការរៀនដោយឯករាជ្យនៅក្នុងថ្នាក់រៀន :

- អ្នកអាចស្នើឲ្យកុមាររៀនផ្នែកណាមួយនៃមេរៀនពីសៀវភៅមេរៀន ឬរៀបចំមេរៀនថ្មីមួយ។
- កុមារអាចធ្វើការស្ទង់មតិណាមួយ ដើម្បីទទួលបានទិន្នន័យផ្ទាល់ខ្លួនសម្រាប់រៀនក្នុងមេរៀនមួយ។
- អ្នកអាចផ្តល់លំហាត់អនុវត្តន៍ដល់កុមារដែលមានសមត្ថភាពកម្រិតខ្ពស់ ដើម្បីអភិវឌ្ឍគំនិតថ្មីៗ និងណែនាំឲ្យស្គាល់ខ្លឹមសារថ្មីៗ។
- អ្នកអាចប្រើវិធីសាស្ត្រទំនាក់ទំនងពីកុមារម្នាក់ទៅកុមារម្នាក់ ដើម្បីឲ្យកុមាររៀបចំដែនការ និងធ្វើសកម្មភាពកែលំអសុខភាព ឬវិស័យផ្សេងទៀត។ បន្ទាប់មក អ្នកអាចវាយតម្លៃសកម្មភាពរបស់ពួកគេជាក្រោយ។

គោលបំណងនៃការប្រើវិធីសាស្ត្របង្រៀន និងការរៀបចំក្រុមផ្សេងៗគ្នា (ដូចជា ការបង្រៀនអ្នកមានអាយុប្រហាក់ប្រហែលគ្នា និងការរៀនដោយស្វ័យគ្រប់គ្រង) គឺដើម្បីផ្លាស់ប្តូរពីការរៀនដែលដឹកនាំដោយគ្រូទៅជាការរៀនដែលផ្តោតទៅលើអ្នករៀន។ កត្តានេះនឹងជំរុញកុមារឲ្យមានការអភិវឌ្ឍទៅជាអ្នករៀនដែលឯករាជ្យ និងស្វ័យគ្រប់គ្រង ហើយនឹងធ្វើឲ្យគ្រូធូរស្រាលក្នុងការដោះស្រាយតម្រូវការរបស់កុមារ និងក្រុមការងារផ្សេងៗ។

ការរៀបចំផែនការសម្រាប់ធ្វើឱ្យមានលក្ខណៈផ្សេងៗគ្នា

ការធ្វើឲ្យមានលក្ខណៈផ្សេងៗគ្នាគឺជាការគ្រិះរិះពិចារណាធម្មតាចំពោះតម្រូវការសិក្សារបស់កុមារណាម្នាក់ ឬកុមារមួយក្រុមតូច ជាជាងការគ្រិះរិះពិចារណាលើគំរូជាតួយ៉ាងសម្រាប់បង្រៀនកុមារក្នុងថ្នាក់ទាំងមូល ហាក់ដូចជាកុមារទាំងអស់មានលក្ខណៈដូចគ្នា។ ខាងក្រោមនេះជាគោលការណ៍គ្រិះមួយចំនួនដែលគាំទ្រការធ្វើឲ្យមាន លក្ខណៈផ្សេងៗគ្នា :

- **ថ្នាក់រៀនដែលមានភាពផ្សេងៗគ្នាត្រូវទន់ភ្លន់ងាយបត់បែន។** គ្រូបង្រៀន និងកុមារយល់ថា សម្ភារនានា របៀបរៀបចំកុមារជាក្រុម របៀបវាយតម្លៃការសិក្សា និងសមាសធាតុរបស់ថ្នាក់រៀនដទៃទៀត គឺជាឧបករណ៍ដែលគេប្រើក្នុងមធ្យោបាយផ្សេងគ្នា ដើម្បីជំរុញឲ្យកុមារម្នាក់ៗ និងថ្នាក់ទាំងមូល បានជោគជ័យ។

- **ការធ្វើឱ្យមានលក្ខណៈផ្សេងៗគ្នានៃការបង្រៀនគឺចេញមកពីការវាយតម្លៃជាប់លាប់ប្រកបដោយប្រសិទ្ធភាពអំពីតម្រូវការរបស់អ្នកសិក្សា។** ក្នុងថ្នាក់រៀនដែលមានភាពផ្សេងៗគ្នា ភាពខុសគ្នារបស់កុមារត្រូវបានរំពឹងទុក ត្រូវបានវាយតម្លៃ និងកត់ត្រាទុកជាមូលដ្ឋានមួយសម្រាប់កិច្ចតែងការបង្រៀន។ គោលការណ៍នេះធ្វើឲ្យយើង នឹកឃើញអំពីទំនាក់ទំនងជិតស្និទ្ធដែលគួរកើតមានរវាងការវាយតម្លៃ និងការបង្រៀន។ យើងអាចបង្រៀនកាន់តែមានប្រសិទ្ធភាព ប្រសិនជាយើងដឹងពីតម្រូវការសិក្សា និងការចាប់អារម្មណ៍របស់កុមារ។ ក្នុងថ្នាក់រៀនដែលមានភាពផ្សេងៗគ្នា គ្រូបង្រៀនត្រូវចាត់ ទុកអ្វីៗដែលកុមារម្នាក់និយាយ ឬបង្កើតជាព័ត៌មានដែលមានប្រយោជន៍សម្រាប់ យល់ដឹងពីកុមារនោះ និងកិច្ចតែងការបង្រៀនសម្រាប់កុមារនោះ។

- **កុមារទាំងអស់ត្រូវមានការងារសមរម្យ។** ក្នុងថ្នាក់រៀនដែលមានភាពផ្សេងៗគ្នា គោលដៅរបស់គ្រូបង្រៀន គឺធ្វើឲ្យកុមារម្នាក់ៗមានអារម្មណ៍ចង់ប្រែងគ្រប់ពេល ហើយកុមារម្នាក់ៗយល់ឃើញថា កាងារបស់ខ្លួនគួរឲ្យចាប់អារម្មណ៍គ្រប់ពេល។

- **គ្រូបង្រៀន និងកុមារគឺជាអ្នកសហការគ្នាក្នុងការសិក្សា។** គ្រូបង្រៀនវាយតម្លៃពីតម្រូវការសិក្សា ជួយសម្រួលការសិក្សា និងរៀបចំកម្មវិធីសិក្សាមួយ ដែលមានប្រសិទ្ធភាព។ ក្នុងថ្នាក់រៀន

ដែលមានភាពផ្សេងៗគ្នា គ្រូបង្រៀនត្រូវសិក្សាពីកូនសិស្សរបស់ខ្លួន ហើយជំរុញពួកគេចូលរួមធ្វើសេចក្តីសម្រេចចិត្តអំពីថ្នាក់រៀន។ ជាលទ្ធផលកុមារក្លាយជាអ្នកសិក្សាដែលកាន់តែមានភាពឯករាជ្យផ្ទើង។ តើអ្វីខ្លះដែលអាចបង្ហាញ ឲ្យឃើញនូវភាពខុសៗគ្នា?

ខ្លឹមសារ : ខ្លឹមសាររួមមាន ហេតុការណ៍ គំនិត ឱកាសកម្ម ឬគោលការណ៍ សិរីយាបថ និងបំណិនទាក់ទងនឹងមុខវិជ្ជា និងប្រធានបទកំពុងសិក្សា។ ខ្លឹមសាររួមបញ្ចូលនូវអ្វីដែលគ្រូរៀបចំសម្រាប់ឲ្យកុមាររៀនព្រមទាំងរបៀបដែលកុមាររៀន ចំណេះដឹងអ្វីមួយ ការយល់ដឹង និងបំណិនផ្សេងៗ។ ក្នុងថ្នាក់រៀនដែលមានភាពផ្សេងៗគ្នាច្រើន ហេតុការណ៍សំខាន់ៗ សម្ភារដែលត្រូវយល់ដឹង និងជំនាញផ្សេងៗ រក្សានូវភាពចិតថេរមិនផ្លាស់ប្តូរសម្រាប់អ្នករៀនទាំងអស់។ អ្វីទំនងជានឹងត្រូវផ្លាស់ប្តូរ ក្នុងថ្នាក់ដែលមានភាពផ្សេងៗគ្នានោះគឺថាកុមារអាចទទួលបានការសិក្សាដ៏សំខាន់ដោយរបៀបណា។ គ្រូអាចបង្ហាញនូវភាពខុសៗគ្នានៃការប្រើខ្លឹមសារ ដោយមធ្យោបាយមួយចំនួនដូចខាងក្រោម :

- ប្រើវត្ថុផ្សេងៗជាមួយអ្នកសិក្សាមួយចំនួន ដើម្បីជួយឲ្យកុមារយល់ពីគំនិតវិទ្យាសាស្ត្រ ឬគណិតវិទ្យាថ្មីមួយ។
- ប្រើអត្ថបទអានលើសពីកម្រិតអានរបស់សិស្ស។
- ប្រើរបៀបរៀបចំដៃគូអានផ្សេងៗ ដើម្បីគាំទ្រ និងជំរុញកុមារដែលកំពុងអានអត្ថបទផ្សេងៗ។
- បង្រៀនម្តងទៀតចំពោះកុមារដែលត្រូវការស្រាយបំភ្លឺបន្ថែម។
- ប្រើអត្ថបទមាំស៊ីនថតសម្លេង ផ្ទាំងផ្សាយពាណិជ្ជកម្ម និងវីដេអូជាមធ្យោបាយក្នុងការពាំនាំគំនិតសំខាន់ៗ ថ្មីៗដល់អ្នកសិស្ស។

សកម្មភាព : សកម្មភាពដែលមានប្រសិទ្ធភាពមួយអាចធ្វើឲ្យសិស្សប្រើបំណិនសំខាន់ណាមួយដើម្បីយល់ពីគំនិតសំខាន់មួយ ហើយសកម្មភាពនោះត្រូវមានគោលដៅសិក្សាជាក់លាក់មួយ។ ឧទាហរណ៍ អ្នកអាចបង្ហាញនូវភាពខុសគ្នានៃសកម្មភាពមួយ ដោយផ្តល់ជម្រើសផ្សេងៗនៅកម្រិតពិបាកខុសគ្នា (ដូចជាជម្រើសទី១ មានភាពងាយស្រួល ជម្រើសទី២ ពិបាកល្មម ឬជម្រើសទី៣ ពិបាកខ្លាំង)។ អ្នកក៏អាចបង្ហាញឲ្យឃើញ ភាពខុសគ្នានៃសកម្មភាពមួយ ដោយផ្តល់ជម្រើសផ្សេងៗដែលផ្អែកទៅលើការចាប់អារម្មណ៍ផ្សេងៗគ្នារបស់កុមារ។ អ្នកអាចផ្តល់ជំនួយផ្សេងគ្នានៃការគាំទ្ររបស់សិស្ស និងគ្រូសម្រាប់សកម្មភាពនីមួយៗ។

ផលិតផល : អ្នកអាចបង្ហាញភាពខុសគ្នានៃផលិតផល។ ផលិតផល ជាវត្ថុដែលកុមារណាម្នាក់អាចប្រើដើម្បីបង្ហាញអ្វីដែលខ្លួនបានរៀន និងយល់។ ឧទាហរណ៍ ផលិតផលអាចជា **ផលប័ត្រ**មួយស្តីពីការងាររបស់កុមារ ការបង្ហាញដំណោះស្រាយចំពោះបញ្ហាមួយ ឬគម្រោងការងារមួយដែលបានបញ្ចប់។ ផលិតផលដ៏ល្អមួយអាចធ្វើឲ្យកុមារគិតឡើងវិញ នូវអ្វីដែលពួកគេបានរៀន អនុវត្តអ្វីដែលពួកគេអាចធ្វើបាន និងពង្រីកការយល់ដឹង និង បំណិនរបស់ខ្លួន។

មធ្យោបាយមួយចំនួនដើម្បីបង្ហាញឲ្យឃើញភាពខុសគ្នានៃផលិតផលមានដូចខាងក្រោម :

- ឲ្យកុមារជួយរចនាផលិតផលនានាទាក់ទងនឹងគោលដៅសិក្សាសំខាន់ៗ។
- លើកទឹកចិត្តកុមារឲ្យសំដែងចេញដោយរបៀបផ្សេងៗនូវអ្វីដែលពួកគេបានរៀន។
- អនុញ្ញាតឲ្យមានរបៀបរៀបចំការងារផ្សេងៗ (ឧទាហរណ៍ ធ្វើការម្នាក់ឯង ជាផ្នែកមួយនៃក្រុមការងារដើម្បីសម្រេចបានផលិតផល)។
- ផ្តល់ ឬលើកទឹកចិត្តឲ្យមានការប្រើធនធានផ្សេងៗដើម្បីរៀបចំផលិតផល។
- ប្រើវិធីសាស្ត្រវាយតម្លៃផ្សេងៗគ្នា។



សកម្មភាពឆ្លុះបញ្ចាំង : កិច្ចតែងការបង្រៀន

ពេលធ្វើកិច្ចតែងការបង្រៀន តើអ្នកអាចបង្ហាញឲ្យឃើញភាពខុសគ្នានៃខ្លឹមសារសម្រាប់រៀន និងភាពខុសគ្នានៃសកម្មភាពឬទេ?

តើកុមារទាំងអស់អាចប្រើប្រាស់ព័ត៌មាន និងសកម្មភាពខុសៗគ្នា ដើម្បីរៀនដោយវិធីផ្ទាល់ខ្លួន និងនៅកម្រិតដ៏សមរម្យមួយឬទេ?

តើខ្ញុំប្រើ "ផលិតផល" ល្អផ្សេងៗគ្នា ដើម្បីបង្ហាញអ្វីដែលកុមារម្នាក់ៗបានរៀនឬទេ?

គ្រប់គ្រងអាកប្បកិរិយាក្នុងថ្នាក់រៀន ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព

កុមារអាចមានអាកប្បកិរិយាមិនល្អ ប្រសិនជាកុមារមិនត្រូវបានគេមើលដោយយកចិត្តទុកដាក់។ កុមារអាចត្រូវការការយកចិត្តទុកដាក់ជាពិសេស ប្រសិនជាកុមារមិនបានទទួលការយកចិត្តទុកដាក់គ្រប់គ្រាន់នៅផ្ទះ។ ជាងនេះទៀត យើង (ជាមនុស្សពេញវ័យ/មនុស្សមានវ័យប្រហាក់ប្រហែលគ្នា) អាចជំទាស់នឹងអាកប្បកិរិយាខ្លះ ប៉ុន្តែបញ្ហានេះមិនគួរមានន័យថា ជាការជំទាស់ចំពោះកុមារក្នុងការធ្វើជាមនុស្សម្នាក់ទេ។ ជាការសំខាន់ គឺត្រូវតែញែកអាកប្បកិរិយាចេញពីកុមារ។ មធ្យោបាយមួយចំនួនដើម្បីដោះស្រាយអាកប្បកិរិយាមិនល្អ មានដូចខាងក្រោម :

- *ថ្នាក់រៀនត្រូវការវិធានចំបងមួយ ពោលគឺ ការគោរពគ្នាទៅវិញទៅមក។*
- *ប្រសិនជាយើងបង្កើតកម្មវិធីសិក្សាគួរឲ្យចាប់អារម្មណ៍មួយដែលមានសម្ភារសិក្សាមានខ្លឹមសារចំពោះកុមារ ដូច្នេះកុមារ នឹងមានការចាប់អារម្មណ៍ ហើយនឹងមានការចូលរួម។*
- *យើងត្រូវការជំនាញសង្កេតមើល និងកត់ត្រាដ៏ល្អ ដើម្បីកំណត់អ្វីជាបុព្វហេតុបណ្តាលឲ្យមានបញ្ហាអាកប្បកិរិយាមិនល្អអ្វីមួយកើតឡើង។*
- ***សំខាន់បំផុតនោះគឺថា** យើងត្រូវការបង្កើតបរិយាកាសមួយឲ្យកុមារចូលរួមយ៉ាងសកម្ម។ បរិយាកាសនោះ ជាការបង្រៀនដ៏ល្អសម្រាប់កុមារទាំងអស់។ មានន័យផងដែរថា គ្រូបង្រៀនមិនត្រឹមតែជាមនុស្សដែលតែងតែគ្រប់គ្រងថ្នាក់នោះទេ តែគ្រូបង្រៀនក៏ជាមនុស្ស ម្នាក់ក្នុងក្រុមការងារអ្នកដោះស្រាយបញ្ហា ដែលរួមមានកុមារ មាតាបិតា និងគ្រូបង្រៀនដទៃទៀតដែរ។*

យុទ្ធសាស្ត្រទូទៅដទៃទៀតសម្រាប់បង្រៀនខ្លឹមសារមេរៀន និងដោះស្រាយបញ្ហាអាកប្បកិរិយា រួមមានការបង្រៀនអ្នកមានវ័យប្រហាក់ប្រហែលគ្នា និងការរៀនបែបសហការរួមគ្នា (ចូរអានផ្នែកខាងលើ)។

វិធីសាស្ត្រដោះស្រាយបញ្ហា

វិធីសាស្ត្រដោះស្រាយបញ្ហាពាក់ព័ន្ធនឹងក្រុមការងារមួយ ដែលរួមមាន កុមារ មាតាបិតា ឬអាណាព្យាបាល គ្រូបង្រៀន និងអ្នកមានអាជីពនានា ដែលសួរសំណួរអំពីបរិយាកាសថ្នាក់រៀនជាក់ស្តែងទំនាក់ទំនងសង្គម បរិយាកាសបង្រៀន ព្រមទាំងលំហូរខ្ទង់ទានានៅក្រៅសាលា។

ដូចយើងបានឃើញក្នុងគោលមុនស្តីពីការពិភាក្សាអំពីការសម្គុតគំរាមកុមារ។ វាមិនត្រឹមតែជាអាកប្បកិរិយា ដែលយើងចាប់អារម្មណ៍នោះទេ ប៉ុន្តែថែមទាំងជាមូលហេតុបង្ហាញអំពីអាកប្បកិរិយាមិនល្អ។ យើងត្រូវការដឹងអ្វីមួយ អំពីតម្រូវការរបស់កុមារ និងអ្វីដែលកុមារកំពុងព្យាយាមទំនាក់ទំនង។

អ្វីៗដែលកុមារត្រូវការធ្វើការជ្រាស្រ័យទាក់ទង

តម្រូវការផ្ដាល់ខ្លួន	វាមានលក្ខណៈដូចម្ដេច?
ការពេញចិត្ត	ខ្ញុំត្រូវការវាឥឡូវនេះ
ការបញ្ចៀសការកិច្ច	ខ្ញុំមិនចង់ធ្វើឡើយ
ការភ័យស្លន់ស្លោ	ខ្ញុំភ័យខ្លាច
តម្រូវការសង្គម	**វាមានលក្ខណៈដូចម្ដេច?**
ស្វែងរកការយកចិត្តទុកដាក់	ចូរក្រឡេកមើលខ្ញុំ
ស្វែងរកអំណាច	ខ្ញុំចង់ទទួលខុសត្រូវ
ការសង៉ាវ	ខ្ញុំមិនចង់ចូលរួមក្នុងក្រុមនេះឡើយ



សកម្មភាពអនុវត្ត: ការវិភាគអាកប្បកិរិយាដែលមានបញ្ហា

ចូរជ្រើសរើសកុមារដែលធ្វើឲ្យអ្នកកង្វល់ដោយសារតែអាកប្បកិរិយាមិនសមរម្យរបស់កុមារនោះ ហើយចូរកត់ត្រាពីមូលហេតុដែលអាកប្បកិរិយានេះធ្វើឲ្យអ្នកខ្វល់។ តើវាជាអាកប្បកិរិយាដែលរំខានមេរៀនរបស់អ្នកឬ? តើវាប៉ះពាល់ដល់ការរៀនសូត្ររបស់កុមារដទៃឬ? តើអាកប្បកិរិយានេះទាក់ទងនឹងពេលវេលានៃថ្ងៃ ថ្ងៃនៃសប្ដាហ៍ ឬសកម្មភាពកម្មវិធីសិក្សាជាក់លាក់ណាមួយឬទេ? តើស្ថានភាពនៅផ្ទះសម្រាប់កុមារមានលក្ខណៈដូចម្ដេច? អ្នកអាចពិភាក្សាពីជីវប្រវត្តិសង្ខេបរបស់កុមារ ប្រសិនជាសាលារបស់អ្នកមានប្រវត្តិសង្ខេបនេះ។

ចូរចាប់ផ្ដើមសិក្សាស្វែងយល់អំពីកុមារនោះ ដើម្បីពិចារណារាល់កត្តាទាំងអស់ដែលមានឥទ្ធិពលប៉ះពាល់ដល់អាកប្បកិរិយារបស់កុមារនោះ។

តើសកម្មភាពអ្វីខ្លះដែលអ្នកអាចធ្វើជាមួយកុមារ ជាមួយអ្នកមានអាយុប្រហាក់ប្រហែលកុមារ មាតាបិតា និងក្នុងថ្នាក់របស់អ្នក ដែលអាចជួយកុមារនោះផ្លាស់ប្ដូរអាកប្បកិរិយាខ្លួន? ចូរសាកល្បងសកម្មភាពនីមួយៗទាំងនេះ។

តើសកម្មភាពណាខ្លះទំនងជាអាចជួយកុមារនោះបាន? ចូរកត់ត្រារាល់សកម្មភាពដែលបានជោគជ័យ។ អ្នកអាចត្រូវការប្រើ សកម្មភាពទាំងនេះម្ដងទៀតជាមួយកុមារដទៃ។

គ្រូបង្រៀនត្រូវសង្កេតមើលអាកប្បកិរិយារបស់កុមារ និងកត់ត្រាអាកប្បកិរិយានេះជាប្រចាំ ដើម្បីសង្កេតមើលពីគំរូនៃអាកប្បកិរិយាប្លែករបស់កុមារ។ នៅពេលដែលថ្នាក់រៀនជាកន្លែងមួយដែលមានសុវត្ថិភាព និងមានកិច្ចសហប្រតិបត្តិការ ថែមទៀតក្នុងការរៀនសូត្រ ទំនងជាមានការពិបាកតិចតួចជាមួយបញ្ហាអាកប្បកិរិយា។

វិន័យវិជ្ជមាន

មានពេលជាច្រើនដែលចាំបាច់ក្នុងការបង្កើតវិន័យ។ ប៉ុន្តែមានសំណួរមួយគឺថា "តើវិន័យប្រភេទណាដែលល្អបំផុត?" ចូរចាំថា គោលដៅរបស់វិន័យគឺមិនមែនត្រួតត្រាកុមារ និងបង្ខំឲ្យកុមារស្តាប់បង្គាប់នោះទេ។ គោលដៅនោះគឺត្រូវផ្តល់ឲ្យកុមារនូវជំនាញសម្រាប់ធ្វើការសម្រេចចិត្ត ទទួលបានបន្តិចម្តងៗនូវការត្រួតត្រាខ្លួនឯង និងការទទួលខុសត្រូវអាកប្បកិរិយាផ្ទាល់របស់ខ្លួន។ ចូរចាំផងដែរថា អាកប្បកិរិយាមិនល្អគឺជាឱកាសមុយសម្រាប់ការបង្រៀនអាកប្បកិរិយាថ្មី។



សកម្មភាពឆ្លុះបញ្ចាំង: តើអ្វីជាវិធីសាស្ត្រដោះស្រាយរបស់អ្នកចំពោះបញ្ហាវិន័យ

ចូរអានប្រអប់នីមួយៗនៅក្នុងតារាងខាងក្រោម រួចចូរគូសសញ្ញា(✓) ក្នុងប្រអប់ដែលអ្នកគិតថាសមស្រប។ អ្នកត្រូវមានភាពទៀងត្រង់។ ចូរប្រើតារាងនេះ ដើម្បីស្វែងរកវិធីសាស្ត្រដោះស្រាយចំពោះបញ្ហាវិន័យ និងការក្សាថ្នាក់រៀនរបស់អ្នកឲ្យមានសណ្តាប់ធ្នាប់។ ដោយការឆ្លុះបញ្ចាំង និងការប្រឈមមុខចំពោះវិធីសាស្ត្ររបស់អ្នក អ្នកអាចរកឃើញវិស័យនានា ដែលក្នុងនោះ អ្នកអាចអនុវត្តសកម្មភាពផ្សេងៗ ព្រមទាំងវិស័យផ្សេងៗដែលអាចឲ្យអ្នកប្រើវិន័យប្រកបដោយប្រសិទ្ធភាព។

វិធានការវិន័យអវិជ្ជមាន	គូសសញ្ញា ✓ បើយល់ស្រប	វិធានការវិន័យវិជ្ជមាន	គូសសញ្ញា ✓ បើយល់ស្រប
ខ្ញុំច្រាប់អ្នកសិក្សានូវអ្វីដែលមិនត្រូវធ្វើជារឿយៗ ដោយចាប់ផ្តើមជាមួយសំដីអវិជ្ជមាន។		ខ្ញុំបង្ហាញអ្នកសិក្សានូវជម្រើសផ្សេងៗដែល អាចជ្រើសរើសបាន និងផ្តោតលើអាកប្បកិរិយាវិជ្ជមានរបស់ពួកគេផ្ទាល់។	
ខ្ញុំព្យាយាមគ្រប់គ្រង អាកប្បកិរិយារបស់អ្នកសិក្សាដោយការដាក់ទោសពិន័យចំពោះអាកប្បកិរិយាមិនល្អ។		ខ្ញុំផ្តោតលើការផ្តល់រង្វាន់សម្រាប់កិច្ចប្រឹងប្រែងរបស់គេ ព្រមទាំងសម្រាប់អាកប្បកិរិយាល្អរបស់ពួកគេ។	

សិស្សរបស់ខ្ញុំគោរពតាមវិធានទានា ដោយសារតែការភ័យខ្លាចការគំរាម ឬការស៊ីសំណូក។		កូនសិស្សខ្ញុំគោរពតាមវិធានទានា ពីព្រោះ ពួកគេបានចូលរួម ចំណែកក្នុងការបង្កើតវិធាន ទាំងនោះ និងបានយល់ព្រមតាមវិធានទាំងនោះ។	
ផលវិបាកនៃការល្មើសវិធានណាមួយ ត្រូវទទួលទោស ហើយមិនទាក់ទង អាកប្បកិរិយារបស់អ្នកសិក្សាឡើយ។		ផលវិបាកនៃការល្មើសវិធានណាមួយគឺ ទាក់ទងដោយផ្ទាល់ជាមួយនឹង អាកប្បកិរិយារបស់អ្នកសិក្សា។	
ពេលខ្ញុំប្រើពេលវេលានៅក្រៅសាលា មានន័យថា ត្រូវផ្តាច់ចេញ និង បោះបង់ចោលការសិក្សាមួយរយៈ។		ពេលខ្ញុំប្រើពេលវេលានៅក្រៅសាលា ពេលវេលានោះគ្មានដែនកំណត់ ហើយគ្រប់គ្រងដោយអ្នកសិក្សា។ អ្នកសិក្សាកំណត់ការផ្លៀមខ្លួន ដើម្បីទទួលបានទូវ ការគ្រប់គ្រងខ្លួនឯង និង រីលត្រលប់មកថ្នាក់រៀនវិញ។	
ខ្ញុំមិនពិចារណាអំពីតម្លៃវការ និងកាល:ទេស: របស់អ្នករៀនឡើយ។		ខ្ញុំផ្តែករាល់សកម្មភាពរបស់ខ្ញុំលើការ យល់ចិត្ត និងការយល់ពីតម្លៃវការ របស់បុគ្គលម្នាក់ៗ សមត្ថភាព កាល:ទេស: និង ដំណាក់ការអភិវឌ្ឍ។	
ខ្ញុំចាត់ទុកកុមារជាមនុស្សកំពុង ត្រូវការការត្រួតត្រាពីប្រភពខាងក្រៅ ឧទាហរណ៍ ខ្លួនខ្ញុំផ្ទាល់ នាយកសាលា និងមាតាបិតារបស់កុមារ។		ខ្ញុំទទួលស្គាល់ថា កុមារមានកាយល់ដឹង អំពីវិន័យផ្ទាល់ខ្លួនពីកំណើត ហើយអាច ដឹកនាំដោយខ្លួនឯងបាន។ ពួកគេអាចត្រូវ ណែនាំឲ្យរៀន ពីការគ្រប់គ្រង ខ្លួនឯងដោយខ្លួនពួកគេផ្ទាល់។	
សូម្បីតែបញ្ហា ឬកំហុសតូចតាច ខ្ញុំស្តីបន្ទោស ឬ ដាក់ទោសសិស្ស របស់ខ្ញុំជាដរាប។		ខ្ញុំចាត់ទុកកំហុសនានាជាឱកាសមួយ សម្រាប់សិស្សរបស់ខ្ញុំ និងខ្ញុំផ្ទាល់ រៀនសូត្រ។ ខ្ញុំប្រព្រឹត្តលើសិស្សរបស់ខ្ញុំ ដោយយល់ចិត្ត និង ផ្តល់ឱកាសឲ្យពួកគេ សោកស្តាយដ៏ស្មោះចំពោះអាកប្បកិរិយា មិនល្អរបស់ខ្លួន។	
ខ្ញុំរិះគន់អ្នកសិក្សាពីព្រោះតែ អាកប្បកិរិយារបស់ពួកគេ។		ខ្ញុំផ្តោតលើអាកប្បកិរិយា មិនមែនលើ អ្នករៀនទេ និង លើការជួយកុមារ ដើម្បីផ្លាស់ប្តូរអាកប្បកិរិយានៅក្នុង មធ្យោបាយស្ថាបនា និងវិជ្ជមាន។	

នៅសាលាកុមារមេត្រីមួយនៅភាគខាងជើងប្រទេសថៃ មានកុមារីម្នាក់ចូលចិត្តរំខានសិស្សដទៃក្នុងថ្នាក់ ហើយចូលចិត្តលួចរបស់របរ និងលុយរបស់មិត្តភក្តិក្នុងថ្នាក់។ កុមារីនេះរៀនខ្សោយ និងអវត្តមានញឹកញាប់ ហើយនាងប្រលងធ្លាក់ស្ទើរគ្រប់ពេល។ គ្រូរបស់នាងមិនបានដាក់ទណ្ឌកម្ម ហើយក៏មិនបណ្តេញនាងចេញពីសាលាដែរ ប៉ុន្តែអ្នកគ្រូបែរជាឲ្យការងារនាងធ្វើកាន់តែច្រើន។ ឧទាហរណ៍ អ្នកគ្រូឲ្យកុមារីនោះធ្វើជាប្រធានថ្នាក់ ពេលណាអ្នកគ្រូចេញក្រៅថ្នាក់មួយរយៈពេលខ្លី។ អ្នកគ្រូឲ្យកុមារីនេះជួយមើលសិស្សតូចៗជាងក្នុងថ្នាក់ ហើយឲ្យជួយរៀបចំសម្ភារក្នុងថ្នាក់រៀន ទាំងមុនចូលរៀន និងក្រោយមៅងរៀន។ មិនយូរប៉ុន្មាន កុមារីនេះ ប្តូរចរិត និងអាកប្បកិរិយា។ កុមារីនោះបានក្លាយជាកុមារម្នាក់ដែលស្ងៀមស្ងាត់ និងយកចិត្តទុកដាក់ជួយមិត្តភក្តិ ហើយមករៀនទៀងទាត់។ លើសនេះទៀត ការសិក្សារបស់កុមារីនេះ ក៏បានល្អប្រសើរជាងមុនដែរ។

វិធីសាស្ត្រដោះស្រាយចំពោះវិន័យដែលមានលក្ខណៈវិជ្ជមាន

តើអ្នកអាចបង្កើតបរិយាកាសវិន័យដែលមានលក្ខណៈវិជ្ជមានមួយនៅក្នុងថ្នាក់រៀនរបស់អ្នកដោយរបៀបណា? ខាងក្រោមនេះជាសំណើរមួយចំនួនសម្រាប់បង្កើតវប្បធម៌សិក្សា និងការបង្រៀនដែលមានលក្ខណៈវិជ្ជមាន[2]។

ត្រូវអនុម័តវិធីសាស្ត្រមួយសម្រាប់សាលាទាំងមូល ហើយអ្នកត្រូវធានាឲ្យវិន័យក្នុងថ្នាក់រៀនរបស់អ្នកឆ្លុះបញ្ចាំងពីគោលនយោបាយសាលា។

ត្រូវបង្កើតវិធានមូលដ្ឋាន នៅក្នុងថ្នាក់របស់អ្នក ហើយឲ្យសិស្សរបស់អ្នកចូលរួមបង្កើតវិធានទាំងនោះ។ ត្រូវមានលក្ខណៈច្បាស់ដប្រជា និងជាប់លាប់ក្នុងការអនុវត្តវិធានទាំងនេះ។

ត្រូវស្គាល់សិស្ស ហើយផ្តោតការយកចិត្តទុកដាក់លើការអភិវឌ្ឍទំនាក់ទំនងវិជ្ជមានជាមួយសិស្ស។

ត្រូវគ្រប់គ្រងដំណើរការសិក្សា និងបរិយាកាសសិក្សាដោយអំណរសាទរ និងប្រកបដោយវិជ្ជាជីវៈ។ ត្រូវឈានមួយដំហានមុន តាមរយៈ ការរៀបចំមេរៀនដ៏ល្អ។ ឧទាហរណ៍ ត្រូវប្រែមើលមើលថាកុមារខ្លះ អាចបញ្ចប់ការងាររបស់ខ្លួនមុនកុមារដទៃទៀត ហើយត្រូវមានអ្វីមួយឲ្យពួកគេធ្វើនៅពេលដែលពួកគេកំពុងរង់ចាំអ្នកដទៃ ដូចជា ជំរុញពួកគេឲ្យបង្កើតវត្ថុតាំងបង្ហាញក្នុងថ្នាក់រៀន។ ត្រូវចេះទិតៀនខ្លួនឯង។ ប្រសិនជាអ្វីមួយមិនដំណើរការ ចូរពិចារណាគ្រប់មូលហេតុ ហេតុអ្វីបានជាដូច្នេះ ដោយរាប់បញ្ចូលនូវមូលហេតុ ដែលអ្នកប្រែហែលជាអាចបានធ្វើអ្វីមួយផ្សេង។

---

๒. ខែប្រែសម្រួលពី : ជម្រើសចំពោះពិន័យលើរូបកាយ : បទពិសោធសិក្សា។ (๒๐๐๐) នាយកដ្ឋានអប់រំនៃក្រសួងអប់រំ Pretoria អាហ្វ្រិកខាងត្បូង ព្រមទាំងការអភិវឌ្ឍវិយកុមារភាព MCH និងកម្មវិធីអប់រំមាតាបិតា។ http://www.health.state.ok.us/program/mchecd/posdisc.html

ត្រូវអភិវឌ្ឍសម្ភារសិក្សា វិធីសាស្ត្របង្រៀន និងការហ្វឹកហាត់ការគ្រប់គ្រងថ្នាក់រៀន ដែលរួមមាន ការគ្រប់គ្រងជម្លោះ ការដោះស្រាយបញ្ហា ការចេះអធ្យាស្រ័យ ការប្រចាំនឹងការប្រកាន់ពូជសាសន៍ ការយល់ដឹងពីបញ្ហាយេនឌ័រជាដើម។

ត្រូវបញ្ចូលគ្រប់សមាសភាព។ ការទុកអ្នកសិក្សាចោល ឬមិនយល់ពីតម្រូវការ និងកាល:ទេស: របស់អ្នកសិក្សាអាចធ្វើឲ្យពួកគេលែងមានភាពជិតស្និទ្ធ។

ត្រូវផ្តល់ឱ្យអ្នកសិក្សានូវឱកាសទទួលជោគជ័យ។ អ្នកសិក្សាដែលមានអារម្មណ៍វិជ្ជមានអំពីខ្លួនឯង និងសមត្ថភាពពួកគេក្នុងការទទួលជោគជ័យនឹងក្លាយជាអ្នកសិក្សាកាន់តែប្រែពៃរឿង។

ត្រូវឱ្យអ្នកសិក្សាទទួលខុសត្រូវ ។ ត្រូវផ្តល់ដល់អ្នកសិក្សានូវឱកាសទទួលខុសត្រូវ ចំពោះអ្វីដែលខ្លួនបានប្រព្រឹត្ត ក្នុងថ្នាក់ក្នុងការរៀបចំគម្រោងការងាររបស់សហគមន៍ ក្នុងការថែរក្សាសត្វចិញ្ចឹមក្នុងថ្នាក់ ឬក្នុងការបំពេញបញ្ជីវត្តមានសម្រាប់គ្នា។

ត្រូវផ្តល់ការយកចិត្តទុកដាក់អ្នកត្រូវការជំនួយ ។ ទោះបីជាអ្នកសិក្សាណាម្នាក់ ចង់ទទួលបានការយកចិត្តទុកដាក់ ដោយប្រើអាកប្បកិរិយាមិនសមរម្យក៏ដោយ ក៏ត្រូវរកមធ្យោបាយដែលអ្នកអាចធ្វើបានឲ្យអ្នកសិក្សានោះចូលរួមក្នុងមធ្យោបាយវិជ្ជមានមួយ ថ្វីបើមធ្យោបាយនោះធ្វើឡើង តាមរយៈយុទ្ធសាស្ត្រសាមញ្ញៗក្តី ដូចជាដាក់កិច្ចការឲ្យសិស្សនោះធ្វើ ឲ្យគេចេញក្រៅបន្ទប់ពីរ ឬបីនាទី ឲ្យគេទទួលខុសត្រូវលើការងារអ្វីមួយ ឬការងារអ្វីផ្សេងទៀតដែលនឹងទទួលស្គាល់ពួកគេ។

ត្រូវធ្វើជាមនុស្សគំរូ កុមារតែងតែធ្វើត្រាប់តាមមនុស្សពេញវ័យក្នុងជីវិតរបស់ពួកគេ។ កុមារនឹងចម្លងលក្ខណៈ សូរសម្លេង ភាសា និងសកម្មភាព ទាំងសមរម្យ និងមិនសមរម្យ។ ជំនាញបង្រៀនដ៏មានឥទ្ធិពលបំផុត ដែលអ្នកអាចរៀនគឺ ត្រូវធ្វើជាគំរូអោកប្បកិរិយា ដែលគេរំពឹងថា កុមារនឹងធ្វើតាម។ ការធ្វើជាគំរូដ៏ល្អមានសារៈសំខាន់ណាស់ក្នុងការបង្រៀន។

ត្រូវផ្តោតលើដំណោះស្រាយជំនួសផលវិបាក។ គ្រូបង្រៀនជាច្រើនព្យាយាមបន្លំទណ្ឌកម្ម ដោយការហៅវាថា ជាផលវិបាកពិតប្រាកដ។ ត្រូវឲ្យកុមារចូលរួមស្វែងរកដំណោះស្រាយដែលទាក់ទង ដោយមានការគោរព និង សមហេតុផល។

ត្រូវនិយាយដោយគោរព។ ការច្រានស្រឹយទាក់ទងជាមួយកុមារមិនអាចធ្វើដោយមានប្រសិទ្ធភាពពីចំងាយបានទេ។ ពេលវេលាដែលត្រូវចំណាយក្នុងការនិយាយជាមួយកុមារ និងក្នុងការទាក់ទងដោយភ្នែកជាមួយកុមារ គឺជាពេលវេលាប្រកបដោយគុណភាព។ គ្រូបង្រៀនជាច្រើនបានកត់សម្គាល់ឃើញនូវបំលាស់ប្តូរយ៉ាងរហ័ស ចំពោះ "កុមារដែលមានបញ្ហា" បន្ទាប់ពីបានចំណាយពេល ៥នាទី ចែករំលែកទស្សនៈធម្មតានូវអ្វីដែលពួកគេចូលចិត្ត និងធ្វើដើម្បីការកំសាន្តសប្បាយ។

ត្រូវច្រាប់ពួកគេនូវអ្វីដែលអ្នកត្រូវការ។ កុមារឆ្លើយតបកាន់តែប្រសើរឡើងចំពោះអ្វីដែលត្រូវបានច្រាប់ឲ្យធ្វើ ជាជាងការច្រាប់មិនឲ្យធ្វើ។ ឧទាហរណ៍ ជំនួសការនិយាយ "ឈប់ធាក់តុ" ដោយនិយាយ "សូមដាក់ជើងរបស់អ្នកនៅលើឥដ្ឋ"។

ត្រូវផ្តល់ជម្រើសផ្សេងៗ។ ការផ្តល់ដល់កុមារនូវជម្រើសផ្សេងៗអាចឲ្យកុមារនូវអំណាចសមរម្យមួយចំនួនក្នុងជីវិតរបស់ខ្លួន ហើយលើកទឹកចិត្តឲ្យចេះធ្វើការសម្រេចចិត្ត។ ជម្រើសផ្សេងៗដែលបានផ្តល់ត្រូវស្ថិតក្នុងដែនកំណត់ដែលអាចទទួលយកបាន និងក្នុងសមត្ថភាពផ្នែកស្មារតី និងការវិកចម្រើនរបស់កុមារ។ នៅពេលកុមារមានវ័យវិកចម្រើនឡើង ពួកគេអាចត្រូវបានផ្តល់ជម្រើសផ្សេងៗកាន់តែទូលំទូលាយឡើង ហើយនឹងត្រូវបានអនុញ្ញាតឲ្យទទួលយកផលវិបាកនានានៃជម្រើសរបស់ខ្លួន។

ត្រូវប្រើជំនួយវិជ្ជាជីវៈ។ ប្រសិនជាមានអ្នកសិក្សាបង្ហាញការលំបាកនានាក្នុងថ្នាក់ ហើយជាពិសេសប្រសិនជាវាមានការទាក់ទិននឹងការសម្លុត គំរាម ឬកិរិយាកំរោល ត្រូវស្វែងរកជំនួយពីសហសេវិករបស់អ្នក ហើយប្រសិនជាចាំបាច់ ពីអ្នកដែលមានវិជ្ជាជីវៈនានា ដូចជា អ្នកចិត្តសាស្ត្រ ឬ អ្នកពិគ្រោះយោបល់។

ការគ្រប់គ្រងថ្នាក់រៀនដែលមានសកម្មភាពរស់រវើក និងដោយមានបរិយាកាសដាក់បញ្ចូលគ្នាគ្រប់សមាសភាព

ការគ្រប់គ្រងការសិក្សាឲ្យមានសកម្មភាពរស់រវើកមានការពាក់ព័ន្ធនឹងសមាសភាពផ្សេងៗជាច្រើន។ នៅពេលដែលមានតុល្យភាពរវាង ស្វ័យសិក្សា ការបង្រៀនអ្នកមានអាយុប្រហាក់ប្រហែលគ្នា ការងារជាក្រុម និងការបង្រៀនផ្ទាល់ វាធ្វើឲ្យការងាររបស់យើងកាន់តែងាយស្រួលឡើង ហើយវាជួយកុមារឲ្យរៀនតាមវិធីជាច្រើន។ ខាងក្រោមនេះជាចំណុចគន្លឹះមួយចំនួនដែលអ្នកអាចពិចារណា នៅពេលអ្នកបង្កើនកម្រិតសិក្សាឲ្យមានសកម្មភាព រស់រវើកក្នុងថ្នាក់រៀនរបស់អ្នក។

ការរៀបចំផែនការ។ ចូរបង្កើតផែនការប្រចាំសប្តាហ៍ដែលកំណត់កម្មវិធីសកម្មភាពថ្នាក់រៀនផ្សេងៗ។ ចូរចង្អុរបង្ហាញថា តើកុមារនឹងធ្វើការដោយឯករាជ្យជាក្រុម ឬជាមួយថ្នាក់ទាំងមូល។ ក្នុងថ្នាក់រៀនដែលមានកម្រិតយល់ដឹងចម្រុះ ក្រុមមួយៗអាចធ្វើការលើសកម្មភាព មួយផ្សេងគ្នា។

ការត្រៀមរៀបចំ។ ចូររៀបចំសម្រាប់សកម្មភាពថ្នាក់រៀននីមួយៗ ដោយការត្រួតពិនិត្យឡើងវិញសៀវភៅបង្រៀនរបស់អ្នក ឬកិច្ចតែងការបង្រៀន។ ត្រូវពិនិត្យដើម្បីធានាឲ្យសិស្សទាំងអស់របស់អ្នកអាចចូលរួមក្នុងសកម្មភាពសិក្សាទាំងនេះ។

ការប្រមូលធនធាននានា។ ចូរប្រមូល ឬបង្កើតធនធាននានាដែលចាំបាច់សម្រាប់ធ្វើសកម្មភាព។ ធនធានទាំងនេះអាចជា ដុំថ្ម ឬកំណាត់ឈើ សម្រាប់ប្រើជាវត្ថុរៀនគណិតវិទ្យា សំបកលៀសសមុទ្រ សម្រាប់ប្រើនៅក្នុងសកម្មភាពសិល្បៈ ឬគ្រាប់សណ្តែក ដែលនឹងត្រូវបណ្តុះនៅក្នុងមុខវិជ្ជាវិទ្យាសាស្ត្រ ដើម្បីមើលពីការរីកលូតលាស់របស់រុក្ខជាតិ។

ការធ្វើឱ្យអ្នកសិក្សាទាក់ទងនឹងសកម្មភាពនានា។ ទោះជាសកម្មភាពសិក្សា ជាការពិភាក្សាក្នុងថ្នាក់ទាំងមូល ឬជាគម្រោងការនានាដែលអនុវត្តដោយក្រុមផ្សេង។ អ្នកអាចណែនាំសកម្មភាពនេះដល់ថ្នាក់របស់អ្នកតាមរយៈការបង្រៀនដោយផ្ទាល់។ ចូរព្យាយាមបង្កើតព័ត៌មាន ឬជំនាញផ្សេងៗដែលនឹងត្រូវរៀនដោយមានខ្លឹមសារសម្រាប់កុមារ។

ការធ្វើឱ្យអ្នកសិក្សាទាក់ទងគ្នាទៅវិញទៅមក។ ចូរទាញយកប្រយោជន៍ពីមធ្យោបាយនានា ដែលកុមារអាចជួយគ្នាទៅវិញទៅមកក្នុងការរៀនជាគូ និងជាក្រុម។ ចូរជំរុញឱ្យមានការបង្រៀនអ្នកមានវិយប្រហាក់ប្រហែលគ្នា នៅពេលណាដែលអាចធ្វើបាន។

ការណែនាំ និងការសង្កេតមើល។ នៅពេលកុមារកំពុងធ្វើការដោយឯករាជ្យលើសកម្មភាពនិងគម្រោងនានា (ដោយខ្លួនឯងផ្ទាល់ ជាគូ ឬជាក្រុម) ចូរដើរត្រួតពិនិត្យក្នុងថ្នាក់រៀន។ ចូរសួរសំណួរ និងណែនាំអ្នកសិក្សាដើម្បីជម្នះឧបសគ្គនានា។ ចូរប្រើពេលនេះជាដែរសម្រាប់វាយតម្លៃ។ ឧទាហរណ៍ វាយតម្លៃ-ថា កុមារកំពុងផ្តោតការយកចិត្តទុកដាក់បានល្អកម្រិតណា និង វិធីនានាដែលពួកគេកំពុងទាក់ទងគ្នា។

ត្រូវផ្តោតលើការចូលរួម។ វិធីសាស្ត្រ និងគំនិតទាំងអស់នេះជួយបង្កើតឱ្យមាន ឱកាសសិក្សាដ៏រស់រវើកសម្រាប់ទាំងអស់គ្នា។ ឧទាហរណ៍ នៅក្នុងថ្នាក់រៀន កុមារីមិនត្រូវបានគ្រប់សង្កត់ពីកុមារា កុមារមានអាយុក្មេងមិនត្រូវបានគ្រប់សង្កត់ពីអ្នកមានអាយុចាស់ជាង ហើយកុមារដែលមានប្រវត្តិ និងសមត្ថភាពខុសគេមិនត្រូវបានប្រើឱកាសឡើយ ឬមិនឱ្យចូលរួមក្នុងសកម្មភាព ឬ ឱកាសរៀនណាមួយ។



សកម្មភាពឆ្លុះបញ្ចាំង : តើអ្នកវាយតម្លៃថ្នាក់រៀនរបស់អ្នកដោយរបៀបណា?

ថ្នាក់រៀនរបស់ខ្ញុំ	១ យល់ស្រប	២ អាចធ្វើ ល្អជាងមុន	៣ ត្រូវការ កែលំអ ជាច្រើនទៀត
ថ្នាក់រៀនរបស់ខ្ញុំមានសណ្តាប់ធ្នាប់			
ខ្ញុំប្រើផ្ទៃថ្នាក់រៀនរបស់ខ្ញុំបានល្អ			
មានពន្លឺគ្រប់គ្រាន់ក្នុងថ្នាក់រៀនរបស់ខ្ញុំ			
មានវត្ថុគួរឲ្យចាប់អារម្មណ៍ច្រើននៅក្នុងថ្នាក់រៀន (១) នៅលើជញ្ជាំង និង/ឬ (២) នៅជ្រុងរៀនគណិតវិទ្យា ឬវិទ្យាសាស្ត្រអនុវត្ត			
កុមារទាំងអស់អាចប្រើប្រាស់សម្ភារអនុវត្តន៍នានា សម្រាប់ការរៀនគណិតវិទ្យា។			
កុមារទាំងអស់អាចផ្លាស់ប្តូរទីតាំងដោយសេរីនៅក្នុងបន្ទប់រៀន ដើម្បីយកសម្ភារសិក្សា។			
កុមារទាំងអស់ចាប់អារម្មណ៍នឹងការសិក្សារបស់ខ្លួន			
កុមារទាំងអស់អាចធ្វើការដោយងាយស្រួល (១) ជាមួយដៃគូណាម្នាក់ និង/ឬ (២) ជាក្រុមតូច។។			
កុមារទាំងអស់សួរសំណួរជារឿយ។។			
កុមារទាំងអស់មានការជឿជាក់ក្នុងការឆ្លើយសំណួរ។			
កុមារដែលមានបញ្ហាការមើល និងការស្តាប់អាចប្រើប្រាស់សម្ភារនានា ដែលអាចជួយពួកគេបាន។			
សម្ភារសិក្សាត្រូវបានកែសម្រួលដើម្បីចៀសវាងការលំអៀងពូជសាសន៍ និងបញ្ហាយេនឌ័រ។			
កុមារទាំងអស់ក្នុងថ្នាក់របស់ខ្ញុំអាចទទួលយកការទទួលខុសត្រូវ។			

អនុវត្តសកម្មភាព

ចូរគិតអំពីអ្វីដែលអ្នកបានអាន ហើយចូរពិចារណាថា តើអ្នកអាចអនុវត្តគំនិតខ្លះចំពោះថ្នាក់រៀន-របស់អ្នក ដោយរបៀបណា? ពេលដែលអ្នកបានគិតអំពីសំណួរ និងឧទាហរណ៍នៅក្នុងតារាងខាងក្រោម រួចហើយចូរកត់ឲ្យឃើញនូវសកម្មភាពណាមួយដែលនឹងអាចធ្វើបានជាមួយថ្នាក់របស់អ្នក។

នៅចុងសប្តាហ៍ :

ការឆ្លុះមើលខ្លួនឯង	ឧទាហរណ៍	សកម្មភាពដែលបានគ្រោងទុក
តើខ្ញុំបានគ្រោងរៀបចំសកម្មភាពនានាសម្រាប់ឲ្យកុមារទាំងអស់ទទួលបាននូវឱកាសសំដែងចេញពីអារម្មណ៍របស់ខ្លួនឬទេ?	ក្រោយពីអានរឿងមួយ ចូរសួរកុមារថា តើពួកគេមានអារម្មណ៍ដូចម្តេចអំពីអ្វីដែលបានកើតឡើង។ តើពួកគេគិតថាវាជាការបញ្ចប់រឿងដោយក្រៀមក្រំ ឬដោយរីករាយ?	
តើខ្ញុំបានគ្រោងរៀបចំសកម្មភាពសម្រាប់ឲ្យកុមារទាំងអស់ធ្វើសកម្មភាពដោយរស់រវើកឬទេ?	ចូរផ្តល់ឱកាសសម្រាប់លេងល្បែងនានា កីឡាបាល់ទះ។ល។ ឬដើរជុំវិញទីធ្លាសាលាដើម្បីមើលថាតើកុមារទាំងអស់កំពុងលេងឬទេ។	
តើខ្ញុំបានគ្រោងរៀបចំសកម្មភាពដែលនឹងជំរុញការប្រកួតប្រជែងបញ្ហាទាំងកុមារី និងកុមារាឬទេ?	ចូរផ្តល់ពេលវេលាដល់កុមារដើម្បីធ្វើការ លើសកម្មភាពដោះស្រាយបញ្ហាមួយ។	
តើខ្ញុំបានគ្រោងរៀបចំសកម្មភាពដែលឲ្យកុមារទាំងអស់ធ្វើការទំនាក់ទំនងគ្នាជាលក្ខណៈសង្គមឬទេ?	ចូររៀបចំកុមារជាក្រុម។ ដើម្បីបង្កើតគំរូមួយ ដោះស្រាយបញ្ហាមួយដោយសហការគ្នាធ្វើការនៅក្នុងសួនច្បារធ្វើជាសមាជិកនៃគណៈកម្មាធិការថ្នាក់ ។ល។	



គោល ៥.៤
ការវាយតម្លៃយ៉ាងសកម្ម និងត្រឹមត្រូវ

ម៉ាឡា កំពុងអង្គុយយំនៅកន្លែងកាច់ជ្រុងមួយ។ នាងបានប្រលងធ្លាក់នៅចុងបញ្ចប់នៃថ្នាក់ទី៣។ នាងបានខិតខំព្យាយាមយ៉ាងខ្លាំងក្នុងអំឡុងពេលនៃឆ្នាំសិក្សា ហើយបានទទួលពិន្ទុល្អៗពេលអង្កេត អនុវត្ត និងលំហាត់សាកល្បងរៀងរាល់សប្តាហ៍។ បីសប្តាហ៍ មុនការប្រលង ម្តាយរបស់នាងបានធ្លាក់ខ្លួនឈឺ ហើយម៉ាឡាទទួលខុសត្រូវទាំងអស់សម្រាប់ការមើលថែរក្សាប្អូនប្រុស-ស្រីរបស់នាង។ ថ្ងៃខ្លះនាងត្រូវខកខានមិនបានទៅសាលា នៅក្នុងខណៈដែលគេរាល់គ្នានៅក្នុងថ្នាក់របស់នាងកំពុងតែត្រៀមខ្លួនសម្រាប់ការប្រលង។ យប់មុនថ្ងៃ ប្រលង នាងមិនបានដេកពេញមួយយប់ ដោយជាប់រវល់មើលថែម្តាយឈឺ។ ក្នុងអំឡុងពេលប្រលង នាងមិនអាចផ្តោតអារម្មណ៍ និងមិនអាចចងចាំច្រើនទូវអ្វីដែលនាងបានរៀន ពីព្រោះនាងឆ្ងើយហត់យ៉ាងខ្លាំង។ ការយំរបស់នាងសំដែងចេញនូវការខកចិត្ត។ នាងត្រូវរៀនត្រួតថ្នាក់ពេញមួយឆ្នាំទៀតវិញ។ នាងនឹងមិនអាចបន្តរៀនជាមួយមិត្តភក្តិនាងបានទៀយ។ នាងមានអារម្មណ៍ ដូចជា ត្រូវគេច្រានចេញពីសាលា។

កុមារជាច្រើន ជាពិសេសកុមារី ចោះបង់ចោលសាលាមុនថ្នាក់ទី ៦ ដោយសារតែតម្រូវការនៅជួះ ហើយជួនកាល ពីព្រោះកុមារីខ្លះមិនចូលចិត្តរៀន។ រឿងខាងលើពន្យល់បង្ហាញបញ្ហានេះ ហើយវាក៏បានបង្ហាញបញ្ហានៃការធ្វើលំហាត់សាកល្បងកុមារមួយដងក្នុងមួយឆ្នាំ ដើម្បីវាយតម្លៃការរីកចម្រើននៃការរៀនសូត្រ។ ជាគ្រូបង្រៀន យើងត្រូវយល់ពីកុមារឲ្យបានប្រសើរឡើង ហើយត្រូវរៀនរបៀបវាយតម្លៃលើការសិក្សារបស់សិស្សក្នុងវិធីជាច្រើនបែប។ ធ្វើដូចនេះ យើងអាចមើលឃើញការអភិវឌ្ឍ និងលទ្ធផលរៀនសូត្ររបស់កុមារបានត្រឹមត្រូវ និងច្បាស់លាស់។

តើការវាយតម្លៃជាអ្វី?

ការវាយតម្លៃជាមធ្យោបាយមួយនៃការសង្កេតមើល ការប្រមូលព័ត៌មាន ហើយបន្ទាប់មកធ្វើការសម្រេចចិត្ត ដោយផ្អែកលើព័ត៌មាននោះ។ ការវាយតម្លៃជាប្រចាំមានន័យថា ការធ្វើការសង្កេតជាដំរាប ដើម្បីរកឲ្យឃើញថា តើកុមារចេះអ្វី? តើកុមារយល់អ្វីខ្លះ? តើកុមារអាចធ្វើអ្វីខ្លះ? ការសង្កេតទាំងនេះត្រូវធ្វើជាច្រើនដងក្នុងអំឡុងពេលនៃឆ្នាំសិក្សា ឧទាហរណ៍ នៅដើមពាក់កណ្តាល និងចុងវគ្គសិក្សា ឬកាន់តែញឹកញាប់ជាងនេះ។ ការវាយតម្លៃជាដំរាបអាចសម្រេចបានតាមរយៈការសង្កេតមើលផលបឹត្រ បញ្ជីពិនិត្យ បំណិន ចំណេះដឹង និងអាកប្បកិរិយា លំហាត់ សាកល្បង និងចំណោទសួរ និងការវាយតម្លៃខ្លួនឯង និងកិច្ចការសរសេរវែងៗដាក់ឲ្យកុមារធ្វើ។

ការវាយតម្លៃជាប្រចាំធានាឲ្យកុមារទាំងអស់មានឱកាសទទួលជ័យជម្នះនៅសាលា។ ដោយការប្រើការវាយតម្លៃជាប្រចាំ គ្រូបង្រៀនអាចសម្រួលការរៀបចំ និងការបង្រៀនរបស់ខ្លួនឲ្យត្រូវតាមតម្រូវការរបស់អ្នក សិក្សា ដូច្នេះកុមារទាំងអស់នឹងមានឱកាសរៀន និងទទួលជោគជ័យ។

ក្នុងការវាយតម្លៃជាប្រចាំ អ្នកសិក្សាទាំងអស់មានឱកាសបង្ហាញអ្វីដែលខ្លួនចេះ និងអាចធ្វើក្នុងមធ្យោបាយផ្សេង។ យោងទៅតាមរបៀបសិក្សាផ្សេង។របស់ពួកគេ។ ការវាយតម្លៃជាប្រចាំអាចប្រាប់អ្នកថាកុមារណាខ្លះកំពុងតែរៀនមិនទាន់គេក្នុងការយល់ពីមេរៀនណាមួយ។ ដូច្នេះ អ្នកអាចរៀបចំឱកាសសិក្សាថ្មី។ សម្រាប់កុមារទាំងនោះ។ ចម្លើយតបជាដំរាបដែលកុមារទទួលបានតាមរយៈដំណើរការនេះជួយពួកគេឲ្យដឹងថា តើពួកគេកំពុងរៀនបានពូកែឬទេ ព្រមទាំងដឹងថា តើសកម្មភាពអ្វីខ្លះដែលគេត្រូវធ្វើ ដើម្បីទទួលបានការរីកចម្រើន។

ការវាយតម្លៃជាប្រចាំអាចជួយអ្នកក្នុងការនិយាយជាមួយមាតាបិតា និងអាណាព្យាបាលអំពីភាពខ្លាំងនិងភាពខ្សោយរបស់កុមារ ដើម្បីឲ្យពួកគេអាចចូលរួមក្នុងកម្មវិធីសមាហរណកម្មមួយ ដូចជាកម្មវិធីមួយដែលផ្សារភ្ជាប់សកម្មភាពថ្នាក់រៀនជាមួយសកម្មភាពនៅផ្ទះ។ ជាធម្មតា លទ្ធផលនៃការប្រលងបញ្ចប់ឆ្នាំកើតមានយឺតពេកសម្រាប់មាតាបិតាក្នុងការជួយកុមារដែលរៀនខ្សោយ។

លទ្ធផលសិក្សា

ដូចយើងបានរៀននៅក្នុងគោលចុងក្រោយហើយថា សកម្មភាពសិក្សានីមួយ។គួរមានវត្ថុបំណងមួយដែលទាមទារឲ្យមានការវាយតម្លៃ ក្នុងរបៀបណាមួយ។ ការវាយតម្លៃគួររៀបរាប់ពីលទ្ធផលនៃការសិក្សា មានន័យថា ការវាយតម្លៃគួរប្រាប់យើងថា តើកុមារមានការអភិវឌ្ឍជំនាញចំណេះដឹង និងអាកប្បកិរិយាលើសកម្មភាពសិក្សា ប្រធានបទ ឬមេរៀននៃកម្មវិធីសិក្សាដោយកម្រិតណា។ ការរៀបរាប់ពីលទ្ធផលនៃការសិក្សាជារឿយ។ ត្រូវបានហៅថា ស្តង់ដា ឬវត្ថុបំណងនៃការសិក្សា ហើយវាអាចត្រូវបានសម្គាល់យើញសម្រាប់មុខវិជ្ជាជំនាញ និងកម្រិតថ្នាក់ជាក់លាក់។

សកម្មភាពសិក្សា និងការវាយតម្លៃអាចតែលំអបានពេលដែលគ្រូបង្រៀនរកឃើញលទ្ធផលសិក្សាជាក់លាក់។ ពេលរៀបចំសកម្មភាពសិក្សាថ្មីមួយ ត្រូវចាប់ផ្តើមដោយរកឲ្យឃើញលទ្ធផលសិក្សា។ អ្នកអាចឆ្លើយសំណួរខាងក្រោមនៅពេលរៀបចំសកម្មភាពរបស់អ្នក :

- តើកុមារនឹងប្រើ ឬអភិវឌ្ឍជំនាញអ្វី ?
- តើនឹងត្រូវរៀនព័ត៌មានអ្វី?
- តើនឹងត្រូវហ្វឹកហាត់អាកប្បកិរិយាបែបណា?

ចម្លើយចំពោះសំណួរទាំងនេះអាចហៅថាជាលទ្ធផលសិក្សា។ ឧទាហរណ៍ ប្រសិនជាអ្នកបង្កើតមេរៀនមួយសម្រាប់អ្នកសិក្សាថ្នាក់ទី ៥ រៀនអំពីសមាមាត្រវាង់ចម្ងាយ និងពេលវេលាក្នុងមុខវិជ្ជាគណិតវិទ្យា អ្នកអាចអភិវឌ្ឍលទ្ធផលដូចខាងក្រោម :

- អ្នកសិក្សាដែលធ្វើការដោយឯករាជ្យនឹងប្រើការលេខគុណ និងចែកលេខ ដើម្បីដោះស្រាយសមាមាត្រវាង់ចំងាយ និងពេលវេលា ជាកិច្ចការសម្រាប់ធ្វើនៅផ្ទះ។
- អ្នកសិក្សាដែលធ្វើការជាគូនឹងសរសេរបញ្ហារឿងគណិតវិទ្យាផ្ទាល់ខ្លួន ដែលសំដែងចេញនូវសមាមាត្រវាង់ចម្ងាយ និងពេលវេលាក្នុងការធ្វើដំណើរក្នុងលំហ។

យើងអាចឃើញថា លទ្ធផលសិក្សាទាំងនេះបញ្ជាក់នូវ :

១. អ្នកណា

២. តើនឹងត្រូវធ្វើអ្វី និង

៣. ក្រោមលក្ខខណ្ឌអ្វី។

បន្ទាប់មក សមាសភាពទាំងនេះត្រូវបញ្ចូលគ្នា ដូចជានៅក្នុង :

១. អ្នកសិក្សាដែលធ្វើការក្នុងក្រុមតូចមួយ

២. នឹងបង្កើតដែនទីនៃទីធ្លាសាលា ហើយ

៣. ក្នុងមាត្រដ្ឋានមួយម៉ែត្រ។

ឧទាហរណ៍ផ្សេងទៀតរួមមាន :

- (១) អ្នកសិក្សា (២) នឹងអាចប្រើលេខបូកធម្មតា ដើម្បីដោះស្រាយបញ្ហាមួយ (៣) នៅក្នុងបរិបទពិតប្រាកដ មួយ។
- (១) អ្នកសិក្សា (២) នឹងអាចធ្វើការជាសមាជិកនៃក្រុមមួយ ដើម្បីបំពេញសកម្មភាព ស្រាវជ្រាវ និងការរកឃើញបច្ចុប្បន្ន (៣) ដោយការសរសេរ។

ពេលយើងក្រឡេកមើលលទ្ធផលជាក់លាក់ ដូចជា ក្នុងមុខវិជ្ជាវិទ្យាសាស្ត្រ ឬគណិតវិទ្យា វានឹងផ្តល់ប្រយោជន៍ប្រសិនជាយើងមានគោលការណ៍ណែនាំមួយដែលបញ្ជាក់នូវកម្រិតផ្សេងៗគ្នានៃលទ្ធផលដែលយើងចង់បានសម្រាប់សកម្មភាពជាក់លាក់មួយ។ ខាងក្រោមនេះ គឺជាគោលការណ៍មួយបែបនេះ។

លទ្ធផលបែងចែកចំណាត់ថ្នាក់

៤- កុមាររៀបវត្ថុដាក់ជាក្រម ៗដោយមានអត្ថន័យពេញលេញ។ កុមារពិភាក្សាលក្ខណៈសំខាន់របស់ក្រមនីមួយ ៗ។ កុមារធ្វើការសន្និដ្ឋាន។

៣- កុមាររៀបវត្ថុដាក់ជាក្រម ៗដោយមានអត្ថន័យពេញលេញ។ កុមារពិភាក្សាលក្ខណៈសំខាន់ ៗ របស់ក្រមនីមួយ ៗ។

២- កុមាររៀបវត្ថុដាក់ជាក្រម ៗដែលមិនមានអត្ថន័យច្រើនឡើយ។

១- កុមាររៀបវត្ថុដាក់ជាក្រម ៗដោយមិនមានអត្ថន័យសោះឡើយ។

0- កុមារមិនព្យាយាមធ្វើការងារនេះឡើយ។

វិធីសាស្ត្រ និងបច្ចេកទេសវាយតម្លៃត្រឹមត្រូវ

ការវាយតម្លៃត្រឹមត្រូវមានន័យថា ជាការចលនាឲ្យកុមារចូលរួមក្នុងការវាយតម្លៃសមិទ្ធផលផ្ទាល់។ ការវាយតម្លៃត្រឹមត្រូវមានមូលដ្ឋានលើការអនុវត្តជាក់ស្តែង និងការបង្រៀនសមរម្យ។ ការសង្កេតមើលរួមជាមួយនឹងការជជែកជាមួយកុមារអំពីការសិក្សារបស់សិស្សអាចកើតមាននៅ ពេលណាមួយ។

ការសង្កេត

ក្នុងអំឡុងពេលនៃការសង្កេតមើលជាយថាក្រម គួរសង្កេតមើលកុមារក្មេង ៗនៅពេលដែលពួកគេកំពុងធ្វើការម្នាក់ឯង ជាគូ ជាក្រមតូច ៗ នៅពេលផ្សេង ៗក្នុងថ្ងៃរៀន ហើយនិងនៅក្នុងបរិបទផ្សេង ៗ។ ការសង្កេតមើលរួមបញ្ចូលចំណុចដូចខាងក្រោម :

ឯកសារប្រវត្តិពិត *: នេះគឺជាកំណត់ហេតុពិតប្រាកដស្តីពីសកម្មភាពនានារបស់កុមារ។ វាមានប្រយោជន៍សម្រាប់កត់ត្រា ហេតុការណ៍ដែលកើតដោយឯកឯង។*

សំណួរ *: វិធីសាស្ត្រដ៏មានប្រយោជន៍មួយក្នុងការប្រមូលព័ត៌មាន ត្រូវសាកសួរកុមារនូវសំណួរផ្ទាល់ដែលគ្មានដែនកំណត់។ សំណួរគ្មានដែនកំណត់ ដូចជា " ខ្ញុំចង់ឲ្យអ្នកប្រាប់ខ្ញុំអំពី....." និងជួយអ្នកឲ្យវាយតម្លៃសមត្ថភាពកុមារក្នុងការនិយាយ។ ជាងនេះទៀត ការសួរកុមារអំពីសកម្មភាពរបស់ពួកគេនឹងផ្តល់នូវការយល់ស៊ីជម្រៅនូវមូលហេតុដែលគេសំដែងអាកប្បកិរិយាដូចបច្ចុប្បន្ន។*

ការប្រលងសម្រាំង : ការប្រលងទាំងនេះត្រូវប្រើដើម្បីរកឃើញនូវជំនាញ និងចំណុចខ្លាំងដែលកុមារមានរួចជាស្រេច ដើម្បីឲ្យគ្រូបង្រៀនអាចរៀបចំបទពិសោធសិក្សាប្រកបដោយខ្លឹមសារពេញលេញសម្រាប់កូនសិស្ស។ លទ្ធផលគួរប្រើរួមជាមួយព័ត៌មានដែលមានក្នុងចិត្ត ដូចជាព័ត៌មានដែលដាក់នៅក្នុងផលបត្រដែលនឹងត្រូវពិភាក្សាខាងក្រោម។ ព័ត៌មានវាយតម្លៃមិនគួរប្រើដើម្បីដាក់ចំណាត់ថ្នាក់កុមារឡើយ។

ការសង្កេតមើលអាចផ្តុះបញ្ចាំងពីជ័យជម្នះនៃការសិក្សា ការប្រជែងក្នុងការសិក្សា និងអាកប្បកិរិយារៀនសូត្រ ដូចមាននៅក្នុងឧទាហរណ៍នៃការសង្កេតរបស់គ្រូម្នាក់ស្តីពីការវិកចម្រើនរបស់ហ្សង់ស៊ីសស្កូ ជាកុមារជនជាតិទីម័រខាងកើតកំពុងរៀនភាសាអង់គ្លេសជាភាសាទី ២ របស់ខ្លួន ។

ហ្សង់ស៊ីសស្កូ

ថ្ងៃទី ១២ ខែ មីនា ហ្សង់ស៊ីសស្កូកំពុងសរសេរជីវៈប្រវត្តិអំពីគ្រួសាររបស់ខ្លួននៅទីម័រខាងកើត។ ហ្សង់ស៊ីសស្កូ កំពុងរៀបចំបង្កើតព័ត៌មានពិតប្រាកដរបស់ខ្លួន ប៉ុន្តែប្រើកាលកិរិយាសព្ទមិនត្រឹមត្រូវឡើយនៅក្នុងសំណេររបស់ខ្លួន។

ថ្ងៃទី ១៦ ខែ មីនា ហ្សង់ស៊ីសស្កូ បានកែលំអសំណេរជាមួយសិស្ស ៤ នាក់ផ្សេងទៀត ដោយផ្តោតលើការប្រើវេយ្យាករណ៍ អតីតកាល ដើម្បីរៀបរាប់ក្នុងសំណេរ (សរសេរពីហេតុការណ៍អតីតកាល)។ ហ្សង់ស៊ីសស្កូកំពុងពិនិត្យផ្ទៀងផ្ទាត់ ពង្រាងរបស់ខ្លួន។

ថ្ងៃទី ២០ ខែ មីនា ហ្សង់ស៊ីសស្កូបញ្ចប់ការប្រើកាលអតីតកាលក្នុងសំណេររៀបរាប់របស់ខ្លួន។ ហ្សង់ស៊ីសស្កូត្រូវការពន្យល់ថែមទៀតលើសំណេរនេះ។

ថ្ងៃទី ០១ ខែ មេសា ហ្សង់ស៊ីសស្កូ និង ចូលធ្វើរួមគ្នាបានល្អ ដោយប្រើសៀវភៅប្រវត្តិសាស្ត្រ ដើម្បីស្រាវជ្រាវរកហេតុការណ៍ពិតអំពីប្រទេសទីម័រខាងកើត។ ហ្សង់ស៊ីសស្កូកត់ត្រាយ៉ាងត្រឹមត្រូវ និងសង្ខេបព័ត៌មានសំខាន់ៗតាមសៀវភៅនេះ។

ការវាយតម្លៃផលប័ត្រ

ខ្លឹមសារ

វិធីសាស្ត្រមួយនៃការវាយតម្លៃត្រឹមត្រូវគឺត្រូវបង្កើត និងត្រួតពិនិត្យឡើងវិញនូវផលប័ត្រ ស្តីពីការងាររបស់កុមារ។ ផលប័ត្រ ជារបាយការណ៍នៃដំណើរការសិក្សារបស់សិស្ស មានន័យថា អ្វីដែលកុមារបានរៀនហើយ កុមារបានរៀនដោយរបៀបណា។ ផលប័ត្រអាចជួយកុមារឲ្យចូលរួម ក្នុងការវាយតម្លៃការងារផ្ទាល់របស់ខ្លួន។ ផលប័ត្ររក្សាផ្លូវនៃការវិកចម្រើនរបស់កុមារ។ ផលប័ត្រនេះ បង្ហាញអំពីជ័យជម្នះរបស់កុមារជាជាងបរាជ័យរបស់កុមារ។ ជាងនេះទៀត ផលប័ត្រគួរតែបញ្ជូនទៅតាមកុមារ ប្រសិនជាកុមារត្រូវផ្លាស់ទៅសាលាថ្មី។

គំរូការងារដែលអាចដាក់នៅក្នុងផលបត្រមាន : គំរូសរសេរ ដូចជានិក្ខេបបទ រឿង និងរបាយការណ៍ រូបភាពតែងលំអ ដែនទី និងដ្យាក្រាម ព្រមទាំងក្រដាសការងារគណិតវិទ្យា កិច្ចការដទៃទៀត និងក្រាហ្វិក។ សកម្មភាពក្រៅកម្មវិធីសិក្សារបស់កុមារអាចត្រូវបានកត់ត្រាចូលផងដែរ ដូចជា ការទទួលខុសត្រូវក្នុងគណៈកម្មាធិការថ្នាក់រៀន។

អ្នកអាចជ្រើសរើសគំរូនានាដែលពន្យល់បង្ហាញពីទិដ្ឋភាពជាក់លាក់នៃការងាររបស់កុមារ។ អ្នកក៏អាចស្នើកុមារជ្រើសរើសពីការងាររបស់ខ្លួននូវគំរូនានាដែលគេចង់ដាក់នៅក្នុងផលបត្ររបស់ខ្លួន សម្រាប់ឲ្យមាតាបិតាចុះហត្ថលេខា។ ដូច្នេះ រាល់ឆមាស ឬវគ្គសិក្សា ការងារទាំងមូលត្រូវផ្តល់ដល់គ្រួសារកុមារសម្រាប់ត្រួតពិនិត្យឡើងវិញ។

ពេលកុមារឡើងទៅរៀននៅថ្នាក់ថ្មី គ្រូបង្រៀនអាចបញ្ជូនផ្នែកជាក់លាក់នៃផលបត្ររបស់កុមារបន្តទៅគ្រូបង្រៀនថ្នាក់ថ្មី។ ការធ្វើដូចនេះនឹងជួយគ្រូបង្រៀនទាំងនេះស្គាល់ពីទេពកោសល្យ និងតម្រូវការផ្សេងៗរបស់សិស្សថ្មី។

ការបញ្ចូលព័ត៌មានក្នុងផលបត្រនីមួយៗគួរចុះកាលបរិច្ឆេទ ហើយគួរផ្តល់បរិបទនៃព័ត៌មាននេះ។ បរិបទអាចត្រូវបញ្ជាក់ដូចនេះ "នេះគឺជាផ្នែកមួយនៃការសរសេរដែលមិនមានជំនួយពីអ្នកដទៃ។ មានតែផ្នែករឿង និងវាក្យសព្ទមូលដ្ឋានខ្លះៗប៉ុណ្ណោះត្រូវបានផ្តល់ឲ្យ។ ការងារនេះត្រូវផ្តល់រយៈពេល ៣០ នាទី "។

ការប្រើផលបត្រក្នុងការវាយតម្លៃ

ព័ត៌មាននៅក្នុងផលបត្រគួររៀបចំតាមលំដាប់កាលបរិច្ឆេទ។ នៅពេលដែលផលបត្រត្រូវបានរៀបចំ គ្រូបង្រៀនអាចវាយតម្លៃសមិទ្ធិផលរបស់កុមារ។ ការវាយតម្លៃសមស្របតែងតែប្រៀបធៀបការងារបច្ចុប្បន្នរបស់កុមារ ជាមួយការងារមុនៗ។ ផលបត្រមិនមានន័យថា ត្រូវបានប្រើដើម្បីប្រៀបធៀបកុមារជាមួយគ្នាទៅវិញទៅមកនោះឡើយ។ ផលបត្រត្រូវបានប្រើដើម្បីបង្ហាញជាឯកសារអំពីការរីកចម្រើនរបស់កុមារម្នាក់ៗលើរយៈពេលមួយ។ សេចក្តីសន្និដ្ឋានរបស់គ្រូអំពីសមិទ្ធិផល សមត្ថភាព ចំណុចខ្លាំង ចំណុចខ្សោយ និងតម្រូវការរបស់កុមារម្នាក់គួរផ្អែកលើទំហំពេញលេញនៃការអភិវឌ្ឍរបស់កុមារ ដូចដែលបានបង្ហាញជាឯកសារក្នុងផលបត្រ និងចំណេះដឹងផ្ទាល់ខ្លួនអំពីរបៀបណាមួយដែលកុមារកំពុងរៀន។

ការប្រើផលបត្រដើម្បីវាយតម្លៃកុមារផ្តល់ដល់គ្រូបង្រៀននូវប្រព័ន្ធដែលបង្កើតជាផ្នែកមួយសម្រាប់រៀបចំការប្រជុំវាងមាតាបិតា និងគ្រូបង្រៀន។ ដោយយកផលបត្រធ្វើជាមូលដ្ឋានសម្រាប់ការពិភាក្សា គ្រូបង្រៀន និងមាតាបិតាអាចត្រួតពិនិត្យឡើងវិញនូវឧទាហរណ៍ ជាក់ស្តែងនៃការងាររបស់កុមារជាជាងការព្យាយាមពិភាក្សាពីការរីកចម្រើនរបស់កុមារក្នុងភាពអរូបី។

ករណីសិក្សា

ការវាយតម្លៃយ៉ាងសកម្មនៅប្រទេសហ្វីលីពីន *ការសម្ភាសមួយជាមួយអ្នកគ្រូ* Marissa J. Pascual *ជាគ្រូបង្រៀនពោរពេញដោយបទពិសោធម្នាក់មកពីសហគមន៍នៃសាលាអ្នកសិក្សាសម្រាប់កុមារនៅប្រទេសហ្វីលីពីន។ គាត់គឺជាអ្នកបណ្តុះបណ្តាលផង់ដែរសម្រាប់កម្មវិធីអប់រំចម្រុះថ្នាក់ ដែលឧបត្ថម្ភដោយ អង្គការ យូនីសេហ្វ*[3]*។*

សំណួរ :

តើអ្នកចាត់ចែងការវាយតម្លៃដោយរបៀបណា?

តើអ្នកធ្វើសមាហរណកម្មការងារវាយតម្លៃទៅក្នុងការសិក្សាបន្ថែម ដោយរបៀបណា?

តើបំលាស់ប្តូរនានាដែលកំពុងតែមានការយកចិត្តទុកដាក់មានន័យដូចម្តេចចំពោះអ្នក?

ធម្មតា ខ្ញុំបង្កើនឲ្យដល់កម្រិតអតិបរមាក្នុងរយៈពេលពីរ ឬបីសប្តាហ៍ដំបូង ដើម្បីប្រមូលព័ត៌មានដ៏មានតម្លៃស្តីពីកម្រិតយល់ដឹង និងសមត្ថភាពបច្ចុប្បន្នរបស់សិស្ស ដោយប្រើមធ្យោបាយផ្សេង។

ការសង្កេត

ខ្ញុំបានដឹងជាច្រើនឆ្នាំថា ព័ត៌មានជាច្រើនអាចទទួលបានពីការសង្កេតមើលធម្មតា។ ព័ត៌មានដែលមានតម្លៃនេះមានប្រយោជន៍ជួយខ្ញុំ កំណត់វត្ថុបំណងសមរម្យសម្រាប់បុគ្គលម្នាក់។ និងជ្រើសរើសកម្មភាព ដែលសមស្របនឹងសមត្ថភាព និងតម្រូវការសិស្ស។ ជាធម្មតា ខ្ញុំធ្វើជាបញ្ជីនូវអ្វីដែលខ្ញុំត្រូវការសង្កេតមើលអំពីកុមារម្នាក់ ឬកុមារមួយក្រុមសម្រាប់សប្តាហ៍នីមួយ។ ដោយដឹងនូវអ្វីដែលខ្ញុំត្រូវផ្តោតអារម្មណ៍ សម្រាប់សប្តាហ៍នីមួយ។ ធ្វើឲ្យខ្ញុំអាចរៀបចំសកម្មភាព និងកម្មវិធីរបស់ខ្ញុំសម្រាប់ការសង្កេតមើល។ ដោយដឹងអ្វីដែលត្រូវសង្កេតមើល និងពេលវេលា ដែលត្រូវសង្កេតមើលអាចជួយខ្ញុំឲ្យធ្វើការងារកាន់តែមានប្រសិទ្ធភាពថែមទៀត។

នៅសប្តាហ៍ដំបូង។ ខ្ញុំតែងយល់ឃើញថាមានសារៈសំខាន់ ដើម្បីសង្កេតមើលកុមារក្នុងស្ថានភាពអានផ្សេង។ ដូចជា ការអានដោយឯករាជ្យ ក្នុងអំឡុងពេលអានស្ងាត់ស្ងៀម ការអានជាមួយកុមារមួយក្រុមនៅពេលក្រុមអក្សរសាស្ត្រអានរួមគ្នា ការអានជ្រើសមាត់នៅក្នុងថ្នាក់ ឬទៅកាន់មិត្តភក្តិម្នាក់ ឬទៅកាន់មនុស្សពេញវ័យណាម្នាក់នៅក្នុងថ្នាក់ និងការអានរកព័ត៌មានជាក់លាក់អំពីប្រធានបទដែលផ្តល់ឲ្យ។ វាជួយខ្ញុំឲ្យទទួលបានព័ត៌មានស្តីពីសមត្ថភាពរបស់សិស្សក្នុងការបង្កើតអត្ថន័យពីអត្ថបទ ក្នុងការអនុវត្តយុទ្ធសាស្ត្ររៀបចំផ្សេង។ (ដូចជា ការប្រើរូបភាព និងតម្លៃយផ្សេង។ ការសង្ខេបប្រយោគ និង លំហាត់ដាក់ពាក្យជំនួស) នៅពេលដែលកុមារប្រឈមនឹងពាក្យពិបាកថ្មី។នៅក្នុងអត្ថបទ ការកែកំហុសដោយខ្លួនឯង និងអាចឲ្យខ្ញុំបញ្ចេញប្រតិកម្ម រិះគន់អ្វីដែលសិស្សអាន។

ការសង្កេតដំបូង អាចឲ្យខ្ញុំឃើញផង់ដែរថា កុមារមើលឃើញយ៉ាងម៉េចអំពីការអាន ហើយគិតថាខ្លួនឯងជាអ្នកអានដូចម្តេច។ នៅពេលចាប់ផ្តើមឆ្នាំសិក្សា ខ្ញុំដាក់សំណួរឲ្យសិស្សឆ្លើយ ដើម្បីឆ្លុះបញ្ចាំងពីឥរិយាបថផ្ទាល់ខ្លួនចំពោះការអាន និងការចាត់ទុកខ្លួនជាអ្នកអានដូចម្តេច។

[3] www.unicef.org/teachers/forum/0199.htm

ការធ្វើលំហាត់វិភាគវេយ្យាករណ៍ ការប្រកបវាក្យសព្ទ និងការសរសេរ

លទ្ធផលនៃការវាយតម្លៃទាំងនេះ បញ្ចូលគ្នាជាមួយព័ត៌មានដែលខ្ញុំបានទទួលពីការសង្កេតជួយខ្ញុំសម្រេចថា តើត្រូវផ្លាស់ប្តូរអ្វី ក្នុងកម្មវិធីសិក្សាដែលខ្ញុំបានរៀបចំដំបូងសម្រាប់បង្រៀននៅរដូវ ក្តៅ។ វាជួយខ្ញុំកំណត់មេរៀនដែលខ្ញុំត្រូវបង្រៀនដល់ថ្នាក់ទាំងមូល ឬដល់ក្រុមកុមារក្នុងសប្តាហ៍ខាងមុខ។

ផលប័ត្រនៃការសរសេរនៅខែដំបូង

ការបញ្ចូលព័ត៌មានដំបូងរបស់សិស្សទៅក្នុងផលប័ត្រសំណេរ ផ្តល់ជូនដែរនូវព័ត៌មានដ៏មានតម្លៃអំពីសមត្ថភាពសរសេរនៅពេលបច្ចុប្បន្នរបស់សិស្ស។ ព័ត៌មានបញ្ចូលជាលើកដំបូងរបស់សិស្សរួមមានភាគច្រើនជាលទ្ធផលក្នុងអំឡុងពេលនៃការធ្វើសកម្មភាពសរសេរ ដែលមានការច្នៃប្រឌិតរបស់សិស្ស និងរបាយការណ៍ខ្លី។ ដែលសិស្សរៀបចំបន្ទាប់ពីបានស្រាវជ្រាវមុខវិជ្ជាដទៃទៀត។ ជាថ្មីម្តងទៀត បញ្ជានេះជួយខ្ញុំកំណត់ថា តើមេរៀនអ្វីដែលត្រូវផ្តល់អាទិភាព ព្រមទាំងកំណត់ពីរបៀបរៀបចំសិស្សជាក្រុម។ សម្រាប់ត្រីមាសទី ១ នៃឆ្នាំសិក្សា។

ក្នុងអំឡុងពេលនៃឆ្នាំសិក្សា ខ្ញុំប្រើវិធីសាស្ត្រវាយតម្លៃទាំងផ្លូវការ និងមិនផ្លូវការ។ វិធីសាស្ត្រមិនផ្លូវការ ជាធម្មតា ត្រូវបានបង្កើតឡើង សម្រាប់សកម្មភាពសាលា និងថ្នាក់រៀនប្រចាំថ្ងៃ ។ រាល់សកម្មភាពរៀន និងបង្រៀនដែលខ្ញុំបង្រៀនរាល់ថ្ងៃទាក់ទងនឹងដំណើរការវាយតម្លៃ សមត្ថភាពរបស់កុមារ ដើម្បីសម្រេចនូវការកិច្ចមួយ និងគោលដៅបង្រៀនមួយ។

ខ្ញុំសង្កេតមើលទាំងដំណើរការ និងលទ្ធផលនៃការចូលរួមរបស់សិស្សក្នុងសកម្មភាពមួយ ឬនៅពេលកំពុងធ្វើការលើភារកិច្ចមួយដែលឲ្យសិស្សបំពេញ។ ឧទាហរណ៍ ការមើលលទ្ធផលលំហាត់ខ្លី។ បន្ទាប់ពីមេរៀនតូចមួយ ផ្តល់ឲ្យខ្ញុំនូវគំនិតមួយថា តើខ្ញុំត្រូវបង្រៀនឡើងវិញនូវគំនិតជាក់លាក់មួយដោយប្រើវិធីសាស្ត្រផ្សេងគ្នា ឬត្រូវផ្តល់ពេលវេលាថែមទៀតដល់កុមារដើម្បីធ្វើលំហាត់នានាទាក់ទងនឹងមេរៀននោះ។ ការពិនិត្យមើលផលប័ត្រសំណេររបស់សិស្សអាចឲ្យខ្ញុំមើលឃើញជូនដែរថា តើសិស្សអាចអនុវត្តគំនិតវេយ្យាករណ៍ដែលបានរៀនក្នុងថ្នាក់ឬទេ។ ជាថ្មីម្តងទៀត កត្តានេះផ្តល់លក្ខណៈពិសេសនៃដំណើរការធ្វើការសម្រេចចិត្តស្តីពីបទពិសោធ ឬយុទ្ធសាស្ត្រសិក្សាបន្ត បន្ទាប់។

ដោយហេតុថាតម្លៃវាការ និងសមត្ថភាពរបស់សិស្សខ្ញុំ ព្រមទាំងល្បឿនបំពេញការងាររបស់សិស្សមានភាពផ្សេងគ្នា ចាំបាច់ត្រូវធ្វើការពិចារណាបញ្ហាទាំងនេះនៅពេលតាក់តែងមេរៀន និងសកម្មភាពនានាដែលខ្ញុំនឹងផ្តល់នៅក្នុងថ្នាក់។ ដើម្បីសម្រួលការគ្រប់គ្រងថ្នាក់រៀន កត្តាសំខាន់ត្រូវកំណត់ថា តើអ្នកណាខ្លះក្នុងចំណោមសិស្សរបស់អ្នកមានតម្លៃវាការ និងចំណុចខ្លាំងរួមគ្នា ហើយបន្ទាប់មកត្រូវរៀបចំដាក់ពួកគេជាក្រុម។ ការធ្វើដូចនេះអាចជួយឲ្យខ្ញុំរៀបចំថ្ងៃ ឬសប្តាហ៍របស់ខ្ញុំមានប្រសិទ្ធភាពថែមទៀត ដើម្បីធានាឆ្លើយតបតាមតម្លៃវាការបច្ចុប្បន្នរបស់សិស្ស។

ខ្ញុំប្រើវិធីសាស្ត្រវាយតម្លៃផ្លូវការនៅក្នុងថ្នាក់ជូនដែរ។ វិធីសាស្ត្រទាំងនេះ រួមមាន លំហាត់សាកល្បង ឬចំណោទសំណួរខ្លី។ ការងារ និងគម្រោងការងារសម្រាប់ម្នាក់ៗ (ដូចជា ការសរសេរគម្រោង

ការងារ ឬស្រាវជ្រាវឯកសារ) និងគម្រោងការងារធ្វើជាក្រុម បន្ថែមពីលើលំហាត់សាកល្បង ដែលបានផ្តល់ក្នុងអំឡុងពេលសប្តាហ៍វាយតម្លៃប្រចាំត្រីមាស។

កម្រិតលទ្ធផលសិក្សារបស់សិស្ស និងការអនុវត្តរបស់សាលាតែងតែផ្អែកលើការដាក់បញ្ចូលគ្នាទាំងការវាយតម្លៃមិនផ្លូវការ/ការឲ្យពិន្ទុជាប្រចាំ និងការវាយតម្លៃតាមដំណាក់កាល និងការវាយតម្លៃផ្លូវការ។ នៅក្នុងន័យនេះ ការវាយតម្លៃមានលក្ខណៈត្រួតលើគ្នាច្រើនដង។ ខ្ញុំក៏ពិចារណាលើការវិនិយោគរបស់សិស្សក្នុងដំណើរការរៀន និងបង្រៀន ដោយផ្អែកលើសក្តានុភាពរបស់ពួកគេ។ ក្រោយត្រីមាសនីមួយៗ ខ្ញុំសង្ខេបរាល់ចំណុចខ្លាំង និងតម្រូវការរបស់សិស្សម្នាក់ៗនៅក្នុងថ្នាក់របស់ខ្ញុំ។ ខ្ញុំកំណត់វត្ថុបំណងថ្មីៗ សម្រាប់ត្រីមាសដែលទទួលជោគជ័យ ហើយរៀបចំសកម្មភាពថ្មីៗដែលនឹងអាចជួយខ្ញុំក្នុងការឆ្លើយតបនឹងវត្ថុបំណងមេរៀន ដែលខ្ញុំបានកំណត់។ ខ្ញុំក៏តែងអរគុណរៀបចំសិស្សជាក្រុមៗនៅពេលចាំបាច់ផងដែរ។

សម្រាប់ខ្លួនខ្ញុំផ្ទាល់ ដំណើរការវាយតម្លៃមិនពេញលេញឡើយ បើគ្មានទិន្នន័យដែលសិស្សបំពេញដោយខ្លួនឯង។ នៅចុងត្រីមាសនីមួយៗ ខ្ញុំចែកបញ្ជីសំណួរសម្រាប់ វាយតម្លៃផ្ទាល់ខ្លួនដល់សិស្សទាំងឡាយឆ្លើយព្រមទាំងរៀបចំការប្រជុំដោយឡែកៗ ដើម្បីវាយតម្លៃការងារប្រចាំត្រីមាស រួមគ្នាពិនិត្យគោលដៅឡើងវិញ និងកំណត់គោលដៅថ្មីៗសម្រាប់ត្រីមាសក្រោយៗ។ ដំណើរការវាយតម្លៃផ្នែកនេះមានសារៈសំខាន់សម្រាប់ខ្ញុំ ពីព្រោះវាផ្តល់ឱកាសឲ្យខ្ញុំជួយសិស្សស្វែងយល់ពីខ្លួនឯង និងពីសមត្ថភាពរបស់ខ្លួន។ ការវាយតម្លៃនេះក្លាយជាផ្នែកមួយជាមូលដ្ឋាន ដើម្បីកំណត់គោលដៅថ្មីៗសម្រាប់ត្រីមាសក្រោយៗ។ នៅក្នុងអំឡុងពេលប្រជុំ ខ្ញុំស្នើសិស្សម្នាក់ឲ្យបង្ហាញឯកសារការងាររបស់ខ្លួន សៀវភៅសរសេរ ផលប័ត្រ សំណេរ និងគម្រោងការងារដទៃទៀតដែលខ្លួនបានធ្វើក្នុងរយៈពេលមួយត្រីមាស។

រយៈពេលជាច្រើនឆ្នាំ ខ្ញុំចាប់ផ្តើមដឹងថា រាល់ព័ត៌មានស្តីពីកុមារម្នាក់ដែលគ្រូអាចទទួលបាននៅរយៈពេលផ្សេងៗ ក្នុងអំឡុងពេលមួយឆ្នាំ (ទោះជាតាមវិធីផ្លូវការ ឬមិនផ្លូវការក្តី) ត្រូវតែបញ្ចាក់ និងបញ្ចាក់ឡើងវិញដោយយកចិត្តទុកដាក់ មុននឹងសម្រេចចិត្តសំខាន់ៗស្តីពីកម្មវិធីសិក្សា។ ឧទាហរណ៍ ការទទួលពិន្ទុល្អក្នុងលំហាត់ វេយ្យាករណ៍មួយមិនអាចធានាថា កុមារមានជំនាញប្រសព្វ ច្បាស់លាស់នៅឡើយទេ។ តាមបទពិសោធរបស់ខ្ញុំ មានឧទាហរណ៍ជាច្រើន ពេលសិស្សម្នាក់អាចទទួលពិន្ទុល្អក្នុងលំហាត់វេយ្យាករណ៍មួយ ប៉ុន្តែមានការលំបាកក្នុងការអនុវត្តគំនិតនេះពេលសរសេរ តែងសេចក្តីរបស់ខ្លួន។ នៅពេលមានភាពខុសគ្នារវាងការអនុវត្តរបស់កុមារម្នាក់ក្នុងការធ្វើលំហាត់ និងក្នុងតែងសេចក្តី ខ្ញុំយល់ឃើញថា ចាំបាច់ត្រូវផ្តល់ឱកាសថែមទៀតសម្រាប់ធ្វើតែងសេចក្តីជាក្រុមជាមួយគ្រូបង្រៀនដែលធ្វើជាអ្នកសម្របសម្រួល។ ការធ្វើដូចនេះអាចឲ្យខ្ញុំយកជាគំរូនូវការប្រើគំនិតវេយ្យាករណ៍ជាក់លាក់មួយក្នុងអំឡុងពេលសរសេរតែងសេចក្តី។

ជាគ្រូបង្រៀនម្នាក់ ចាំបាច់ខ្ញុំត្រូវដុះបញ្ចាំងលើព័ត៌មានថ្មីៗដែលខ្ញុំទទួលបានស្តីពីកុមារណាម្នាក់ឬកុមារមួយក្រុម នៅពេលជាក់លាក់ណាមួយ។ ខ្ញុំតែងតែញ៉ាយាមវិភាគអំពីការជំពាក់ទាក់ទងគ្នានៃព័ត៌មានថ្មីៗ។ ឧទាហរណ៍ ប្រសិនជាមានគំរូមួយសម្រាប់សង្កេតមើលកំហុសនានា ដែលសិស្សម្នាក់បង្កើតក្នុងការអាន ឬក្នុងការសរសេរតែងសេចក្តី វាអាចចង្អុលបង្ហាញថា សិស្សនេះអាចទទួលបានប្រយោជន៍ពី

ការ បង្រៀន ផ្តើមវិញនូវគំនិតជាក់លាក់ណាមួយ ឬថាសិស្សអាចត្រូវការធ្វើបន្តសកម្មភាពនានា ដើម្បីចេះ ច្បាស់លាស់នូវជំនាញជាក់លាក់មួយ។

ចម្លើយត្រលប់ និងការវាយតម្លៃ

ចម្លើយត្រលប់ ជាសមាសភាពដ៏សំខាន់មួយសម្រាប់វាយតម្លៃការសិក្សារបស់សិស្ស។ មុនពេលផ្តល់ចម្លើយត្រលប់ សំខាន់ត្រូវមានទំនាក់ទំនងល្អ និងប្រកបដោយសុវត្ថិភាព មានការធានា និងគួរឲ្យទុកចិត្តរវាងគ្រូបង្រៀន និងសិស្ស។

កុមារទទួលផលពីឱកាសមានចម្លើយត្រលប់ផ្លូវការតាមរយៈការសិក្សាក្នុងថ្នាក់ទាំងមូល និងការសិក្សាជាក្រុម។ នៅពេលដែលការងារនេះប្រព្រឹត្តទៅបានល្អ និងមានការផ្លាស់ប្តូរពីគ្រូបង្រៀនដែលប្រាប់សិស្សអ្វីដែលសិស្សបានធ្វើខុស ទៅសិស្សដែលជឹងខ្លួនដោយខ្លួនឯងថា សិស្សត្រូវធ្វើអ្វីដើម្បីកែលំអ ហើយបន្ទាប់មក លើកយកមកពិភាក្សាជាមួយគ្រូបង្រៀន។

ចម្លើយត្រលប់អវិជ្ជមានអាចត្រូវបានពន្យល់បង្ហាញដោយសំដី "ហេតុអ្វីបានជាអ្នកមិនអាចកែលំអការប្រកបអក្សរបាន? អ្នកតែងតែប្រកបអក្សរខុស"។ ចម្លើយត្រលប់អវិជ្ជមានកាត់បន្ថយការគោរពខ្លួនឯងរបស់កុមារ និងមិនផ្តល់ការគាំទ្រដល់ការកែលំអការសិក្សារបស់សិស្សឡើយ។

ចម្លើយត្រលប់វិជ្ជមាន និងមានន័យស្តាបនាអាចត្រូវបានពន្យល់បង្ហាញដោយសំដីដូចនេះ "ស៊ីតាខ្ញុំចូលចិត្តរបៀបដែលអ្នកបានចាប់ផ្តើមរឿងរបស់អ្នក ហើយការបញ្ចប់រឿងមានលក្ខណៈគួរឲ្យរំភើប ណាស់។ ប្រសិនជាអ្នកប្រើវចនានុក្រមពិនិត្យមើលពាក្យខ្លះ ពាក្យដែលអ្នកសរសេរនឹងបាន ល្អប្រសើរជាងនេះ។ ប្រសិនជាអ្នកមិនច្បាស់ដអំពីអក្សរដំបូង។ត្រូវសួរ (ចូរ)"។ ចម្លើយត្រលប់វិជ្ជមានទទួលស្គាល់នូវចំណុចខ្លាំងអត្តសញ្ញាណ ចំណុចខ្សោយ និងបង្ហាញពីការវិកចម្រើនកម្រិតណាមួយដែលបានធ្វើ តាមរយៈពាក្យសំដីដែលមានលក្ខណៈស្តាបនា។

ចរិតលក្ខណៈនៃចម្លើយត្រលប់ដែលមានប្រសិទ្ធភាព

- ចម្លើយត្រលប់កាន់តែមានប្រសិទ្ធភាពផ្តើង ប្រសិនជាវាផ្តោតទៅលើការងារ ហើយត្រូវបានផ្តល់ជាប្រចាំនៅពេលដែលវាជាប់ទាក់ទងនៅឡើយ។
- ចម្លើយត្រលប់មានប្រសិទ្ធភាពបំផុតពេលដែលវាបញ្ជាក់ថា សិស្សកំពុងតែដំណើរការបានល្អហើយ នៅពេលដែលវាជំរុញឲ្យមានការកែលំអកំហុស ឬការកែលំអផ្សេង។ទៀតក្នុងការងារ។
- រាល់សំណូមពរកែលំអនានាគួរធ្វើសកម្មភាពដូចជា "**រន្ធាទំរ**" មានន័យថា គួរជួយសិស្សប្រើ

ចំណេះដឹងរបស់ខ្លួនឲ្យបានច្រើនដែលអាចធ្វើបាន។ មិនគួរផ្តល់ឲ្យសិស្សនូវដំណោះស្រាយពេញលេញឡើយនៅពេលដែលពួកគេមានបញ្ហាលំបាក។ គួរជួយកុមារឲ្យគិតអ្វីផ្សេង។ដោយខ្លួនឯង។

- លក្ខណៈសម្បត្តិនៃការពិភាក្សាស្តីពីចម្លើយវិលត្រលប់មានសារៈសំខាន់ណាស់ ហើយការស្រាវជ្រាវជាច្រើន បានបង្ហាញថា ចម្លើយតបផ្ទាល់មាត់មានប្រសិទ្ធភាពជាងចម្លើយសរសេរ។
- សិស្សត្រូវការជំនាញនានា ដើម្បីស្នើសុំជំនួយ និងមានអារម្មណ៍ល្អក្នុងការធ្វើដូចនេះនៅក្នុងថ្នាក់រៀន។

ការវាយតម្លៃខ្លួនឯង

កុមារត្រូវការ :

- ឆ្លុះបញ្ចាំងវាយតម្លៃលើការងារផ្ទាល់ខ្លួន។
- ការគាំទ្រឲ្យទទួលស្គាល់បញ្ហានានាដោយគ្មានប៉ះពាល់ដល់ការគោរពខ្លួនឯង។
- ការផ្តល់ពេលគ្រប់គ្រាន់ ដើម្បីដោះស្រាយបញ្ហា។

ការវាយតម្លៃខ្លួនឯងកើតមាននៅពេលអ្នកសិក្សារៀបរាប់ពីសមត្ថភាព ចំណេះដឹង ឬការរីកចម្រើនរបស់ខ្លួនផ្ទាល់។ ការវាយតម្លៃខ្លួនឯងបានរួមចំណែកដល់ការបង្កើនចំណេះដឹង និងការចូលចិត្តការសិក្សា។ ការវាយតម្លៃខ្លួនឯងអាចកើតមានក្នុងការពិភាក្សានានាជាមួយកុមារ ឬក្នុងសៀវភៅកំណត់ហេតុប្រចាំថ្ងៃ។

នៅពេលកុមារចេះសរសេរ គួរស្នើកុមារកត់ត្រាបទពិសោធសិក្សារបស់ខ្លួននៅក្នុងសៀវភៅកំណត់ហេតុប្រចាំថ្ងៃរបស់សិស្ស។ ពេលបំពេញចប់សកម្មភាពសិក្សា ឬមេរៀនសិក្សាណាមួយ អ្នកអាចស្នើកុមារម្នាក់ៗឲ្យឆ្លុះបញ្ចាំងលើការរីកចម្រើនរបស់ខ្លួន។

ការវាយតម្លៃបំណិន និងឥរិយាបថ

ការវាយតម្លៃគោលដៅជាច្រើនក្នុងការអប់រំមានការលំបាក។ ទោះជាយ៉ាងណាក្តី ជំនាញ និងឥរិយាបថជាមូលដ្ឋានសំខាន់សម្រាប់ការសិក្សា និងអនាគតរបស់កុមារ។ ហេតុដូច្នេះ យើងគួរព្យាយាមវាយតម្លៃជំនាញ និងកិរិយាមារយាទរបស់កុមារឲ្យបានល្អប្រសើរតាមដែលអាចធ្វើបាន។ ខាងក្រោម នេះជាឧទាហរណ៍ស្តីពីលំហាត់ដែលបានប្រើដើម្បីវាយតម្លៃកម្រិតបួនយ៉ាងនៃជំនាញ និង សមិទ្ធិផល ឥរិយាបថ[4]។

---

[4] ផ្នែកនេះសំអាងលើឯកសាររបស់ : Miriam S. (1993) Learning from Experience. World Studies. Trentham Books Ltd., United Kingdom.

ជំនាញទូទៅ : កិច្ចសហប្រតិបត្តិការ *(ចូរចាំថា កិច្ចសហប្រតិបត្តិការមានជំនាញជាច្រើន ដូចជា ការស្តាប់ និយាយសំដីច្បាស់ៗងាយយល់ ។ល។)។ កិច្ចសហប្រតិបត្តិការមានន័យថា ធ្វើការជាមួយអ្នកដទៃ ហើយព្រមទទួលយកតួនាទីផ្សេងៗដែលទាក់ទងនឹងការស្តាប់ ការពន្យល់ ចរចា និងសម្របសម្រួល។*

	កុមារ ក	កុមារ ខ
កម្រិតទី ១ : អាចធ្វើការជាមួយដៃគូណាម្នាក់ដោយប្តូរ វេនគ្នាស្តាប់ និយាយ និងចែករំលែកគំនិត និងធនធាន។		
កម្រិតទី ២ : អាចទទួលយក និងអាចចរចា ទស្សនៈរិះគន់ខុសៗគ្នាផ្សេងៗគ្នា។		
កម្រិតទី ៣ : អាចធ្វើការក្នុងក្រុមចម្រុះណាមួយ (អាយុ/សមត្ថភាព/ភេទ)។		
កម្រិតទី ៤: អាចដឹកនាំក្រុមចម្រុះណាមួយ។ អាចលើកសំណូមពរឲ្យមានដំណោះស្រាយផ្សេងៗចំពោះបញ្ហាដោយប្រើយុទ្ធសាស្ត្រសហការ។		

ឥរិយាបថ : ការយល់ចិត្ត *គឺត្រូវមានចន្លុះគិតពីអារម្មណ៍ និងសេចក្តីសង្ឃឹមរបស់អ្នកដទៃ។*

	កុមារ ក	កុមារ ខ
កម្រិតទី ១ : អាចទទួលស្គាល់ថា នីមួយអាចមានភាគីលើសពីមួយ មានការជំទាស់។ អាចចែករំលែកអារម្មណ៍ និងអាចពន្យល់ពីអាកប្បកិរិយានានា។		
កម្រិតទី ២ : អាចរៀបរាប់ពីមនោសញ្ចេតនារបស់តួអង្គផ្សេងៗក្នុងរឿងនានា។ អាចទទួលស្គាល់ថា កុមារ ឬមនុស្សពេញវ័យម្នាក់ទៀតមានមូលហេតុចង់បានអ្វីមួយខុសគ្នាពីអ្នក។		
កម្រិតទី ៣ : អាចពន្យល់ថា មនុស្សទាំងឡាយ ធ្វើអ្វីផ្សេងៗខុសៗគ្នាពីព្រោះតែប្រវត្តិ និង ស្ថានភាពរបស់ពួកគេ។ អាចប្រជែងចំពោះការប្រើពាក្យបណ្តើចិត្តនៅក្នុងសាលា ដោយបញ្ហា យេនឌ័រ ពិការភាព ជនជាតិ ឬភាពក្រីក្រ។		
កម្រិតទី ៤ : អាចប្រជែងចំពោះពាក្យសំដីដែលមានលក្ខណៈគំរូដែលបានធ្វើឡើងស្តីពីមនុស្ស ទាំងឡាយដែលខុសពីខ្លួនគេជ្រាល់។		

សកម្មភាពដែលបានប្រើជាញឹកញាប់នៅក្នុងការវាយតម្លៃជាប្រចាំ និងត្រឹមត្រូវរួមមានការវាយតម្លៃការអនុវត្ត និងការវាយតម្លៃផលិតផល។ ការវាយតម្លៃការអនុវត្តអាចរាប់បញ្ចូលនូវ : ការស្រាវជ្រាវវិទ្យាសាស្ត្រ ការដោះស្រាយបញ្ហាគណិតវិទ្យាដោយប្រើវត្ថុពិត។ ការសំដែងរបាំ ការលេងសំដែងតួជាមួយមនុស្សម្នាក់ ឬមនុស្សពីរនាក់ផ្សេងទៀត ការអានរឿង និងការលេងកីឡាបាល់ទាត់ ។ល។

ផលិតផលដែលអាចវាយតម្លៃបានរួមមាន : រូបភាពលំអ ឬរូបគំនូរមួយ គំរូមួយទាក់ទងនឹងបាតុភូតវិទ្យាសាស្ត្រ និក្ខេបបទ ឬរបាយការណ៍មួយ ឬចំរៀងមួយបទដែលត្រូវបានសរសេរ និងចង់ក្រងដោយកុមារ។

តើការវាយតម្លៃអាចខុសនៅកន្លែងណា?

លទ្ធផលចុងក្រោយសម្រាប់កុមារគួរទាក់ទងជាមួយនឹងអ្វីដែលកុមារបានធ្វើ**ពីមុន** និងអ្វីដែលអាចធ្វើនៅ**ពេលឥឡូវនេះ**។ វាមិនគួរទាក់ទង នឹងការធ្វើលំហាត់សាកល្បងជាស្តង់ដាទូទៅមួយនៅចុងឆ្នាំឡើយ។ កុមារដែលនៅក្នុងក្រុមឆ្នាំសិក្សាដូចគ្នា (ថ្នាក់ ឬកម្រិត) អាចមានភាពខុសគ្នាយ៉ាងតិច ៣ ឆ្នាំ ផ្នែកសមត្ថភាពទូទៅរវាងពួកគេ ហើយនៅក្នុងផ្នែកគណិតវិទ្យាវិញ អាចមានភាពខុសគ្នារហូតដល់ ៧ ឆ្នាំ។ នេះមានន័យថា ការប្រៀបធៀប កុមារដោយប្រើលំហាត់សាកល្បងជាស្តង់ដាមួយគឺមិនយុត្តិធម៌ចំពោះកុមារជាច្រើនឡើយ។

គ្រូបង្រៀន មាតាបិតា ឬអាណាព្យាបាលមិនគួរចាត់ទុកលំហាត់សាកល្បងនៅចុងឆ្នាំថា ជាការវាយតម្លៃដ៏សំខាន់បំផុតចំពោះកុមារឡើយ។ ប្រភពមួយក្នុងចំណោមប្រភពជាច្រើនដែលធ្វើឲ្យកុមារមានការគោរពខ្លួនឯងទាបនោះគឺ ការប្រើវិធីប្រៀបធៀប ជាពិសេសនៅក្នុងសាលា។ លំហាត់សាកល្បងនៅចុងឆ្នាំគួរតែជាសមាសភាពមួយនៃការវាយតម្លៃរួមអំពីការរីកចម្រើនរបស់កុមារ។ ការវាយតម្លៃនេះសំដៅលើកកម្ពស់ការយល់ដឹងរបស់គ្រូ កុមារ និងមាតាបិតា ឬអាណាព្យាបាលអំពីសមត្ថភាពរបស់កុមារ។ ការវាយតម្លៃនេះគួរត្រូវបានប្រើជាដំណែរ ដើម្បីអភិវឌ្ឍយុទ្ធសាស្ត្រសម្រាប់ការរីកចម្រើនបន្ថែម។ យើងមិនគួរសង្កត់ធ្ងន់លើភាពខ្វះខាត ឬចំណុចខ្សោយរបស់កុមារឡើយ។ យើងគួរអបអរនូវអ្វីដែលកុមារសម្រេចបាន និងគួរសម្រេចចិត្តថា តើយើងអាចជួយកុមារដោយរបៀបណា ដើម្បីឲ្យពួកគេរៀនបានបន្តទៀត។

ការវាយតម្លៃជាដរាប និងត្រឹមត្រូវអាចរកឃើញអ្វីដែលកុមារកំពុងរៀន ព្រមទាំងរកឃើញមូលហេតុមួយចំនួនដែលកុមារមិនរៀន (ជួនកាលត្រូវបានពាណិនាថាជា "ការរួញរាក្នុងការសិក្សា") ។ មូលហេតុទាំងនេះមានដូចខាងក្រោម :

- កុមារមិនបានរៀនជំនាញធ្វើកិច្ចការ។ កិច្ចការសិក្សាជាច្រើនត្រូវធ្វើតាមលំដាប់ ជាពិសេសក្នុងផ្នែកគណិតវិទ្យា និង ភាសា។ កុមារត្រូវការរៀនបំណិនមួយ ដូចជា ការរាប់លេខពី ១ ដល់ ១០ ជាមុនសិន មុនពេលរៀនវិធីធ្វើលេខដក។

- វិធីសាស្ត្របង្រៀនមិនមែនជាវិធីសាស្ត្រតឹមត្រូវសម្រាប់កុមារ។
- កុមារអាចត្រូវការពេលវេលាថែមទៀត ដើម្បីហ្វឹកហាត់អ្វីដែលខ្លួនបានរៀន។
- កុមារកំពុងទទួលរងភាពស្រេកឃ្លាន ឬការផ្តល់អាហារូបត្ថម្ភមិនល្អ និងមិនត្រូវបានជំរុញលើកទឹកចិត្ត។
- កុមារមានបញ្ហាអារម្មណ៍ ឬរាងកាយដែលបង្កឲ្យមានការលំបាកក្នុងការសិក្សា។

ប្រសិនជាកុមារកំពុងមានបញ្ហាពិបាក ការវាយតម្លៃជាប្រចាំដោយប្រើវិធីសាស្ត្រ ដ៏ត្រឹមត្រូវអាចបង្ហាញឲ្យឃើញនូវការលំបាកទាំងនេះ ដូច្នេះ អាចឲ្យយើងផ្តល់ជំនួយដោះស្រាយបញ្ហាដល់កុមារ។ យើងគួរយល់ថា មិនមែនកុមារទាំងអស់រៀនបានក្នុងរបៀបដូចគ្នា និង ល្បឿនដូចគ្នាឡើយ។ កុមារខ្លះអាចបានអវត្តមានក្នុងអំឡុងពេលដំណាក់កាលសំខាន់នៃដំណើរការសិក្សា។ ការបង្រៀនបន្តែមក្នុងពេលសមស្របអាចផ្តល់ដល់កុមារដែល រៀនមិនទាន់គេនូវមធ្យោបាយដទៃៗទៀត ដើម្បីរៀនចំណេះដឹង និងជំនាញផ្សេងៗ។ "ដៃគូរៀនជាមួយគ្នា" ដែលទទួលបាននូវជំនាញដល់កម្រិតស្តង់ដាល្អមួយអាចត្រូវបានស្នើឲ្យជួយកុមារទាំងឡាយណាដែលបានអវត្តមាន ឬដែលត្រូវការការយកចិត្តទុកដាក់ថែមទៀត។



សកម្មភាពឆ្លុះបញ្ចាំង : ការវាយតម្លៃការរីកចម្រើន

ចូរគិតពីវគ្គសិក្សាចុងក្រោយ។ គិតពីមុខវិជ្ជាមួយ ដូចជាមុខវិជ្ជាគណិតវិទ្យា ឬវិទ្យាសាស្ត្រ។ តើអ្នកវាយតម្លៃ ការរីកចម្រើនរបស់សិស្សដោយរបៀបណា? តាមរយៈការសង្កេតមើល ការធ្វើលំហាត់សាកល្បងប្រចាំសប្តាហ៍ អ្វីមួយដែលគេបានផលិត (ផលិតផល) ផលប័ត្រ ការប្រលងបញ្ចប់វគ្គសិក្សា ។ល។ ?

តើអ្នកនឹងរាយការណ៍ដល់មាតាបិតា ឬអាណាព្យាបាលដោយរបៀបណា? តាមរយៈការពិភាក្សាមិនផ្លូវការមួយ បណ្ណរាយការណ៍ ឬនៅកន្លែងប្រជុំរវាងគ្រូបង្រៀន និងមាតាបិតា?

ការយល់ដឹងពីសកម្មភាព

ពេលនេះ អ្នកយល់ដឹងបានប្រសើរហើយអំពីតម្លៃនៃការវាយតម្លៃជាប្រចាំ តើអ្នកត្រូវធ្វើសកម្មភាពអ្វីខ្លះដើម្បីទទួលបានរូបភាពកាន់តែប្រសើរថែមទៀតស្តីពីចំណុចខ្លាំង ឬចំណុចខ្សោយរបស់កុមារ? តើអ្នកអាចបង្កើតការវាយតម្លៃផលប័ត្រនៅសាលារបស់អ្នក ឬយ៉ាងហោចណាស់នៅក្នុងថ្នាក់របស់អ្នក បានឬទេ?

ចូរព្យាយាមដោះស្រាយដែនការវាយតម្លៃមួយសម្រាប់ឆ្នាំសិក្សាទាំងមូល។ ចូរព្យាយាមគិតអំពីមធ្យោបាយផ្សេង។ ដែលអាចគ្រប់គ្រងបាននៅក្នុងបរិបទរបស់អ្នក ដោយត្រូវដ្ដល់រូបភាពពេញលេញនៃការរីកចម្រើនរបស់កុមារក្នុងមួយឆ្នាំ។ ចូរចាំផងដែរថា ការវាយតម្លៃគួររាប់បញ្ចូលនៅក្នុងការតាក់តែងដំបូងនៃប្រធានបទនិងមេរៀន។

	សង្កេត	**សកម្មភាព**	**ផលប័ត្រ**	**ការធ្វើលំហាត់សាកល្បង**	**ផ្សេងៗ**
ប្រចាំថ្ងៃ					
ប្រចាំសប្ដាហ៍					
ប្រចាំធមាស					
ប្រចាំឆ្នាំ					



គោល ៥.៥
តើយើងបានរៀនអ្វីខ្លះពីបទពិសោធនាពេលកន្លងមក?

នៅក្នុងកម្រងសៀវភៅនេះ យើងបានស្រាវជ្រាវរកបញ្ហាការគ្រប់គ្រងសំខាន់ៗជាច្រើនដែលនឹងត្រូវដោះស្រាយ ប្រសិនជាថ្នាក់រៀនយើងមានបំណងនឹងផ្តល់ឱកាសសិក្សាសម្រាប់កុមារទាំងអស់ រួមបញ្ចូលទាំងកុមារដែលមានសមត្ថភាព និងប្រវត្តិខុសគេ។ សំណួរមួយចំនួនដែល យើងត្រូវពិចារណារួមមាន :

- តើមាតាបិតាដែលជាអាណាព្យាបាលអាចជួយយើងគ្រប់គ្រងថ្នាក់រៀនបានឬទេ?
- តើកុមារអារៀនទទួលខុសត្រូវចំពោះការសិក្សារបស់ខ្លួននៅក្នុងថ្នាក់រៀនឬទេ?
- តើយើងអាចប្រើធនធានសម្រាប់ធ្វើជាសម្ភារសិក្សាបានល្អឬទេ?
- តើកុមារអាចជួយគ្នាទៅវិញទៅមកតាមរយៈការបង្រៀនអ្នកមានអាយុប្រហាក់ប្រហែលគ្នា ឬទេ?
- តើយើងអាចតាក់តែងមេរៀនប្លែក។ដើម្បីឲ្យកុមារអាចទទួលជោគជ័យក្នុងល្បឿនរៀនផ្ទាល់របស់ខ្លួនឬទេ?
- តើយើងអាចគាំទ្រឲ្យមានសកម្មភាពរស់រវើកឬទេ ពេលយើងកំពុងគ្រប់គ្រងអាកប្បកិរិយាក្នុងថ្នាក់រៀន?
- នៅពេលចាំបាច់ តើយើងអាចប្រើវិនីយជាឧបករណ៍វិជ្ជមានសម្រាប់ការសិក្សាឬទេ?

ប្រសិនជាថ្នាក់រៀនមួយមានការគ្រប់គ្រងល្អ មេរៀនតាក់តែងបានល្អ ហើយអ្នកពាក់ព័ន្ធទាំងអស់មានការចាប់អារម្មណ៍នឹងការសិក្សារបស់កុមារ ដូច្នេះ កុមារទាំងអស់អាចទទួលជោគជ័យក្នុងការសិក្សារបស់ខ្លួន។

យើងត្រូតពិនិត្យឡើងវិញជាដំណែរនូវមធ្យោបាយមួយចំនួនសម្រាប់វាយតម្លៃការសិក្សារបស់កុមារក្នុងរយៈពេលមួយឆ្នាំ។ យើងត្រូវការដឹងថាតើកុមារម្នាក់ៗចាប់ផ្តើមពីកន្លែងណា ពីព្រោះយើងដឹងថា កុមារដែលមានអាយុស្រករគ្នាអាចរៀនដោយល្បឿនផ្សេងគ្នា។ យើងត្រូវការផ្តល់ដល់កុមារនូវចម្លើយតបនៅពេលពួកគេកំពុងរៀន (ជួនកាល ហៅថា "ការវាយតម្លៃអប់រំ") ហើយយើងត្រូវការដឹងថា កុមារមានការរីកចម្រើនអ្វីខ្លះនៅចុងឆ្នាំ ("ការវាយតម្លៃសរុប")។ យើងចាត់ទុកការវាយតម្លៃត្រឹមត្រូវថា ជាមធ្យោបាយផ្តល់ការវាយតម្លៃអប់រំសម្រាប់កុមារ និងមាតាបិតា ឬអាណាព្យាបាលដទៃទៀត។

យើងដឹងថា ការវាយតម្លៃត្រឹមត្រូវពាក់ព័ន្ធនឹងមធ្យោបាយផ្សេងៗសម្រាប់វាយតម្លៃការរីកចម្រើនរបស់កុមារ ដែលរួមមាន ការសង្កេតមើលផ្ទាល់ ផលបត្រ សកម្មភាពដោះស្រាយបញ្ហា (អាចជាគូ ឬជាក្រុមតូច។) ការបង្ហាញ (ឧទាហរណ៍មួយនៃផលិតផល សកម្មភាពសិក្ខាមួយ) និងការសួរសំណួរ ដោយប្រើក្រដាស និងដៃខ្មៅ។

តើអ្នកមានទំនុកចិត្តឬទេ នៅពេលរាយការណ៍ដល់មាតាបិតា ឬអាណាព្យាបាលស្តីពីការរីកចម្រើនរបស់កុមារទាំងអស់ក្នុងថ្នាក់អំឡុងពេលពាក់កណ្តាលឆ្នាំសិក្សា? តើមានមធ្យោបាយណាខ្លះ ដែលអ្នកអាចរាប់បញ្ចូលកុមារនៅក្នុងដំណើរការនៃការវាយតម្លៃ ឧទាហរណ៍ ដោយឲ្យកុមារជ្រើសរើសការងារណាមួយដើម្បីបញ្ចូលក្នុងផលបត្រៃរបស់ខ្លួន?

តើអ្នកអាចរៀនថែមទៀតអំពីប្រធានបទនេះនៅកន្លែងណា?

ការចោះពុម្ពផ្សាយ និង **Web sites** *ខាងក្រោមគឺជាធនធានដ៏មានតម្លៃសម្រាប់គ្រប់គ្រងថ្នាក់រៀនដោយបញ្ចូល គ្រប់សមាសភាព។*

ឯកសារយោង

Alternatives to Corporal Punishment: The Learning Experience. (2000) Department of Education, Ministry of Education, Pretoria, South Africa.

Miriam S. (1993) Learning from Experience. World Studies. Trentham Books Ltd., United Kingdom.

UNESCO (1993) Teacher Education Resource Pack: Special Needs in the Classroom. Paris.

UNESCO (2001) Understanding and Responding to Children's Needs in Inclusive Classrooms: A Guide for Teachers. Paris.

Web Sites

Authentic Assessment:
a briefing. http://home.ecn.ab.ca/~ljp/edarticles/assessment.htm

Classroom routines.
http://www.ioe.ac.uk/multigrade/practical_advice.htm

Cooperative learning.
http://www.jigsaw.org/ and http://www.co-operation.org

Guidelines for Portfolio Assessment in Teaching English by Judy Kemp and Debby Toperoff.
http://www.etni.org.il/ministry/portfolio

Managing group work and cooperative learning.
http://www.tlc.eku.edu/tips_cooperative_learning.htm

Multigrade Teacher Training Materials.
http://www.ioe.ac.uk/multigrade/teacher_training.htm

Positive Discipline.
http://www.positivediscipline.com

Quality Education for Every Student. This is a good Web site for explaining portfolio assessment.
http://www.pgcps.org/~elc/portfolio.html

UNICEF Teachers Talking about Learning.
http://www.unicef.org/teachers

ក្រសួងអប់រំ យុវជន និងកីឡា

កម្រងសៀវភៅលេខ : ៦

បង្កើតបរិយាកាសរៀនមេត្រី ដោយបញ្ចូលគ្រប់សមាសភាព ដែលមានសុខភាព និងសុវត្ថិភាព

ការិយាល័យសុខភាពសិស្ស និងសុវត្ថិភាពសាលារៀន
នាយកដ្ឋានសុខភាពសិស្ស និងសុវត្ថិភាពសាលារៀន



បរិយាកាសរៀនមេត្រី
ដោយបញ្ចូលគ្រប់សមាសភាព

UNESCO

សេចក្តីណែនាំអំពីគោល

កម្រងសៀវភៅលេខ៦នេះ ជួយអ្នក និងសហការីរបស់អ្នកឱ្យចាប់ផ្តើមរៀបចំសាលាប្រកបដោយបរិយាកាសរៀនមេត្រី មានជាសុកភាព និងមានសុវត្ថិភាពល្អ។ កម្រងសៀវភៅលេខ៦នេះ បង្ហាញអំពីវិធីដែលត្រូវធ្វើដើម្បីប្រមូលកុមារទាំងអស់ឱ្យបានចូលរៀន។ ប្រសិនបើការខិតខំរបស់យើងបានជោគជ័យ កុមារជាច្រើនដែលមានជីវប្រវត្តិ និងសមត្ថភាពផ្សេងៗគ្នាជាច្រើន មានឱកាសបានចូលរៀនក្នុងថ្នាក់ដែលមានបរិយាកាសកុមារមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព។ ប្រសិនបើមានឱកាសចូលរៀនក្នុងសាលាដែលបរិយាកាសប្រកបដោយសុខភាពនិងសុវត្ថិភាព កុមារទាំងអស់នេះនឹងទទួលបានចំណេះដឹងច្រើនជាងគេ។

គោល

គោលទី ៦.១ រៀបចំគោលនយោបាយដែលធានាឱ្យមានសុខភាព និងសុវត្ថិភាព សម្រាប់កុមារគ្រប់រូប ---------- ៣

គាំទ្រឱ្យមានគោលនយោបាយសុខភាពសិក្សា ---------- ៥

ការបង្កើតឱ្យមានការឯកភាពគ្នាជារួម ---------- ៧

ពិនិត្យ និងវាយតម្លៃស្ថានភាពគោលនយោបាយសុខភាពសិក្សានៅក្នុងសាលារបស់យើង ---------- ១០

ដោះស្រាយអំពើហិង្សា : ប្រែក្លាយគោលនយោបាយឱ្យទៅជាការអនុវត្តជាក់ស្តែង ---------- ១៥

គោលទី ៦.២ បណ្តុះបណ្តាលបំណិនជីវិតដល់កុមារ ---------- ២៥

ការអប់រំជំនាញសុខភាពបឋម ---------- ២៥

តើជំនាញ និងបំណិនអ្វីដែលកុមារត្រូវការ ---------- ២៨

តើគ្រូត្រូវបង្រៀនជំនាញទាំងនេះដោយរបៀបណា? ---------- ៣៤

ការអប់រំជំនាញសុខភាពមូលដ្ឋានដើម្បីទប់ស្កាត់ការឆ្លងអេដស៍ ---------- ៣៦

គោលទី ៦.៣ ផ្តល់អាហារូបត្ថម្ភ និងសេវាសុខភាពនៅសាលា និងបរិក្ខារចាំបាច់ ----------២៧

វាយតម្លៃស្ថានភាពបច្ចុប្បន្ន ---------- ៤៩

កម្មវិធីអាហារ និងអាហារូបត្ថម្ភក្នុងសាលា : ជួយកុមារដែលពុំមានអាហារគ្រប់គ្រាន់នៅផ្ទះ ---------- ៥២

គំនិតសម្រាប់បង្កើតបរិយាកាសសាលាស្អាត ---------- ៥៤

គោលទី ៦.៤ តើយើងបានរៀនអ្វីខ្លះពីបទពិសោធ នាពេលកន្លងមក? ---------- ៦២



គោល ៦.១
រៀបចំគោលនយោបាយដែលធានាឱ្យមានសុខភាព និងសុវត្ថិភាពសម្រាប់កុមារគ្រប់រូប

ការធានាថា កុមារទាំងអស់មានសុខភាពល្អ មានសុវត្ថិភាព និងអាចរៀនបាន ជាផ្នែកមួយដ៏សំខាន់របស់បរិយាកាសរៀនមេត្រីដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព។ កម្រងសៀវភៅនេះ ណែនាំបង្ហាញអំពីសកម្មភាពមួយចំនួនដែលអ្នកអាចប្រើ ដើម្បីស្វែងរកការគាំទ្រមតិឱ្យមានគោលនយោបាយសុខភាព សិក្សា និងដើម្បីស្វែងរកការគាំទ្រ ដើម្បីអនុវត្តគោលនយោបាយនោះ ព្រមទាំងកំណត់រកគោលនយោបាយ និងកម្មវិធីណាដែលជាអាទិភាពខ្ពស់បំផុតថែមទៀត។

លើកកម្ពស់សុខភាព និងការសិក្សារបស់សិស្សតាមរយៈកម្មវិធីសុខភាពសិក្សា និងសុវត្ថិភាពពុំមែនជាការងារថ្មីទេ។ សាលាជាច្រើនមានកម្មវិធីបែបនេះរួចហើយ ព្រោះសាលាទាំងនោះបានយល់ថា សមត្ថភាពរបស់កុមារក្នុងការសម្រេចសក្តានុពលភាពសិក្សាគឺអាស្រ័យលើសុខភាពល្អ មានអាហារូបត្ថម្ភគ្រប់គ្រាន់ និងមានបរិយាកាសរៀនសូត្រប្រកបដោយសុវត្ថិភាព។ កុមារអាចរៀនដោយកក់ក្តៅ លុះណាកុមារមានអារម្មណ៍ថាមានសុវត្ថិភាពគ្រប់គ្រាន់។

គោលនយោបាយសុខភាពសិក្សាបញ្ជាក់ពីសកម្មភាពដែលយើងត្រូវបំពេញដើម្បីលើកកម្ពស់សុខភាពអនាម័យ អាហារ និងសុវត្ថិភាពរបស់កុមារ ជាពិសេសកុមារដែលមានប្រវត្តិ និងសមត្ថភាពខុសគេ។ គោលនយោបាយទាំងនេះ ធានាថា សាលារបស់យើងមានសុវត្ថិភាព និងស្ថិរភាព និងជំរុញឱ្យមានបរិយាកាសយោគយល់គ្នា និងទាក់ទាញសម្រាប់កុមារគ្រប់ៗរូប។ កុមារទាំងអស់អាចប្រឹងអស់ពីសមត្ថភាពក្នុងការសិក្សានៅពេលដែលកុមារមានអារម្មណ៍សុខស្រួល និងមានសុវត្ថិភាព។

ដើម្បីរៀបចំគោលនយោបាយសុខភាពសិក្សាឱ្យបានល្អ ចាំបាច់ត្រូវមានដៃគូចូលរួមច្រើន រួមទាំងគ្រូ កុមារ ឪពុកម្តាយ អ្នកដឹកនាំសហគមន៍ និងអ្នកផ្តល់សេវាសុភាពសង្គម ។ គោលបំណងគឺ ឱ្យមនុស្សទាំងនេះចាប់ផ្តើមគិតពិចារណា និយាយគ្នា និងព្រមព្រៀងគ្នាដើម្បីអនុវត្តសកម្មភាព។ កម្រងសៀវភៅនេះ និយាយអំពីសកម្មភាពដែលអ្នកគួរប្រើ ដើម្បីគាំទ្រឱ្យមានគោលនយោបាយសុខភាពសិក្សា ព្រមព្រៀងគ្នាក្នុងការអនុម័ត និងកំណត់គោលនយោបាយផ្សេងទៀតដែលចាំបាច់។

តើគោលនយោបាយសុខភាពសិក្សាមានខ្លឹមសារអ្វីខ្លះ? ហើយគោលនយោបាយនោះជាអ្វី? តារាងខាងក្រោមបង្ហាញអំពីបញ្ហាមួយចំនួនដែលសាលាជួបការលំបាក ក្នុងការប្រែក្លាយឱ្យទៅជាសាលាដែលមានសុខភាព និងសុវត្ថិភាព និងខ្លឹមសារគោលនយោបាយមួយចំនួន ដែលអាចធានាឱ្យទៅជាបរិយាកាសសិក្សាដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព ប្រកបដោយសុខភាព និងសុវត្ថិភាពសម្រាប់សិស្សទាំងអស់។

ឧទាហរណ៍មួយចំនួននៃគោលនយោបាយសុវត្ថិភាព និងសុខភាពសិក្សា

បញ្ហាគោលនយោបាយ	ឧទាហរណ៍នៃគោលនយោបាយសាលា
ការមានផ្ទៃពោះនៅវ័យក្មេង ដោយមិនចង់បាន និងការបញ្ឈប់ការសិក្សា	◆ មិនត្រូវបញ្ឈប់ការសិក្សារបស់ក្មេងស្រីដែលមានផ្ទៃពោះទេ។ លើកទឹកចិត្តពួកគេឱ្យចូលរៀនវិញ បន្ទាប់ពីសម្រាលកូនហើយ។ ◆ បញ្ចូលកម្មវិធីអប់រំបំណិនជីវិតនៅក្នុងកម្មវិធីសិក្សា។ ◆ ហាមឃាត់រាល់ទម្រង់នៃការរើសអើងទាក់ទងនឹងភេទ។
សាលាដែលមានផ្សែងថ្នាំ និងសាលាដែលមិនមានផ្សែងថ្នាំ	◆ ហាមជក់ថ្នាំនៅក្នុងសាលាទាំងគ្រូ និងសិស្ស។ ◆ ហាមមិនឱ្យលក់ថ្នាំឱ្យកុមារ។ ◆ ហាមមិនឱ្យផ្សាយពាណិជ្ជកម្មថ្នាំ។
អនាម័យ និងសុខភាព	◆ សង់បង្គន់អនាម័យដាច់គ្នាសម្រាប់អ្នកគ្រូ/សិស្សស្រី និងលោកគ្រូ/សិស្សប្រុស។ ◆ មានទឹកស្អាតនៅគ្រប់សាលាទាំងអស់។ ◆ បំផុសឱ្យសមាគមគ្រូ និងមាតាបិតាសិស្ស ឬ គណៈកម្មការសាលាចូលរួមរក្សាទឹកស្អាត និងបង្គន់
មេរោគអេដស៍/ជំងឺអេដស៍ និងការបោះបង់ចោលសាលា	◆ ការអប់រំជំនាញសុខភាព ដោយយកចិត្តទុកដាក់ទប់ស្កាត់ការឆ្លងរាលដាលនៃមេរោគអេដស៍/ជំងឺអេដស៍។ ◆ ជំរុញឱ្យមានការគាំទ្រគ្នា និងពិគ្រោះយោបល់គ្នាអំពីមេរោគអេដស៍/ជំងឺអេដស៍ក្នុងសាលារៀន។ ◆ មិនត្រូវរើសអើងចំពោះសិស្ស/គ្រូដែលមានផ្ទុកមេរោគ/ជំងឺអេដស៍នោះទេ។ ◆ ធានាឱ្យមានវិធានការទប់ស្កាត់ការឆ្លងរាលដាលនៃមេរោគអេដស៍/ជំងឺអេដស៍។
ការបៀតបៀនផ្លូវភេទដល់សិស្សស្រី ដោយសិស្សគ្នាឯង ឬដោយគ្រូ	◆ ត្រូវឱ្យមានច្បាប់ធានាថា ការបៀតបៀនផ្លូវភេទ និងការរំលោភបំពានដោយសិស្សក៏ដោយ ដោយគ្រូក៏ដោយ ត្រូវបានហាមឃាត់ជាដាច់ខាត។ ◆ ត្រូវផ្សព្វផ្សាយច្បាប់ឱ្យបានទូលំទូលាយ និងទួលយកដោយមនុស្សគ្រប់រូប ប្រគល់សិទ្ធិ និងអំណាចឱ្យមនុស្សគ្រប់រូប រាយការណ៍ពីករណីរំលោភបំពានផ្សេងៗ និងពង្រឹងវិធានការវិន័យឱ្យមានប្រសិទ្ធភាពចំពោះអ្នកដែលប្រព្រឹត្តអំពើលាមក។

ចែកចាយសំណុំឯកសារស្តីពី សុខភាពសិក្សា និងរបប អាហារហូបចុក	◆ បណ្តុះបណ្តាល និងប្រើប្រាស់គ្រូឱ្យផ្សព្វផ្សាយពីអនាម័យសិក្សា និងរបបអាហារហូបចុក ដោយសហការជាមួយ នឹងបុគ្គលិកសុខាភិបាល និងដោយមានការចូលរួមពី សហគមន៍មូលដ្ឋាន។ ◆ ប្រកាសសេចក្តីណែនាំស្តីពីនំចំណី និងគុណភាពចំណីអាហារ អនាម័យ និងស្តង់ដាគុណភាពរបស់នំចំណី។

ប្រភព: Focusing Resources on Effective School Health. Core Intervention 1: Health Related School Policies. http://www.freshschools.org/schoolpolicies-0.htm

គាំទ្រឱ្យមានគោលនយោបាយសុខភាពសិក្សា

អនុម័តគោលនយោបាយដើម្បីធានាឱ្យមានបរិយាកាសសិក្សាដែលមានបញ្ចូលគ្រប់សមាសភាព មានសុខភាព និងសុវត្ថិភាពល្អទាមទារឱ្យមានការគាំទ្រពីគ្រប់ភាគីទាំងអស់។ បានទទួលការគាំទ្រត្រូវចាប់ផ្តើមឡើង ដោយការតស៊ូតិ ពោលគឺ ការរៀបចំអត្ថបទដែលមានខ្លឹមសារពេញលេញ ជាយយល់និងទាក់ទាញ ដើម្បីឱ្យអ្នកតាក់តែងគោលនយោបាយមើលឃើញថា គោលនយោបាយសុខភាពសិក្សានេះពិតជាចាំបាច់។



សកម្មភាពអនុវត្ត : រៀបចំអត្ថបទសម្រាប់គោលនយោបាយដែលមានសុខភាព សុវត្ថិភាព និងដាក់បញ្ចូលគ្នាគ្រប់សមាសភាព

◆ ជួបប្រជុំក្រុមតូចជាមួយសហការីណាដែលមានចំណាប់អារម្មណ៍ក្នុងការលើកកម្ពស់សុខភាពសិក្សា និងលើកកម្ពស់គុណភាពរៀនសូត្ររបស់សិស្ស។ អ្នកទាំងនេះអាចជាអ្នកដែលធ្វើការយ៉ាងសកម្ម ដើម្បីប្រមូលកុមារទាំងអស់ឱ្យបានចូលរៀន ឬអ្នកដែលបានចូលរួមក្នុងការរៀបចំជែនទីព័ត៌មានសហគមន៍ ឬរៀបចំឯកសារជីវប្រវត្តិរបស់សិស្ស ដូចបានពិភាក្សាក្នុងកម្រងសៀវភៅលេខ៣។ (ក្នុងកម្រងសៀវភៅលេខ៣ អ្នកអាចយកខ្លឹមសារមកប្រើដើម្បីដាក់បញ្ចូលក្នុងសកម្មភាពនេះផងដែរ)។

◆ បែងចែកសមាជិកជាពីរ ឬបីក្រុម ហើយឱ្យក្រុមទាំងនោះគិតដោយស្ងៀមស្ងាត់ថា តើបញ្ហាសុខភាព និងសុវត្ថិភាពរបស់កូនចៅ និងគ្រួសារប៉ះពាល់យ៉ាងណាខ្លះដល់សាលារៀន។ ពួកគេអាចគិតទាំងកត្តាវិជ្ជមាន និងអវិជ្ជមាន។ សមាជិកម្នាក់ៗគួរតែកត់ត្រានូវអ្វីដែលគិតឃើញជាលាយលក្ខណ៍អក្សរ។ ត្រូវចំណាយពេលវេលាលើការងារនេះ ប្រហែលពី៥ ទៅ ១០នាទី។

- ចែកក្រដាសកាតុងពីរផ្ទាំងមួយសន្លឹកសម្រាប់ក្រុមនីមួយៗ។ ឱ្យក្រុមនីមួយកត់ត្រាជាលាយលក្ខណ៍អក្សរ អំពីបញ្ហាសុខភាពរបស់កុមារ និងគ្រួសារដែលប៉ះពាល់ដល់សាលាអ្នកខ្លះ។
- បន្ទាប់ពីក្រុមនីមួយធ្វើចប់ហើយ ផ្លាស់ប្តូរបទពិសោធរវាងក្រុម និងក្រុម។ បន្ទាប់មកជ្រើសរើសបញ្ហារួមចំនួន ៣ ឬ ៤ បញ្ហាដែលក្រុមនីមួយៗបានលើកឡើង។
- ទីបញ្ចប់ ធ្វើការជាមួយគ្នាដើម្បីរៀបចំជាអត្ថបទតស៊ូមតិនានាដែលអ្នកអាចប្រើប្រាស់ដើម្បីធ្វើជាហេតុផលពន្យល់គោលនយោបាយសុខភាពសិក្សា ដែលអាចយកទៅដោះស្រាយបញ្ហាសុខភាព និងសុវត្ថិភាពដែលអ្នកបានកត់ត្រា។ អ្នកយកឧទាហរណ៍ខាងដើមធ្វើជាគំរូ។ អត្ថបទតស៊ូមតិខាងក្រោម អាចប្រើប្រាស់ធ្វើជាមូលដ្ឋានគ្រឹះដើម្បីបង្កើតឱ្យមានការព្រមព្រៀងរួមគ្នាមួយ។

ហេតុផលដែលត្រូវរៀបចំឱ្យមានគោលនយោបាយសុខភាព និងសុវត្ថិភាព នៅសាលាដែលមានបរិយាកាសរៀនមេត្រីដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព[1]

<u>បញ្ហា</u>: យើងប្រឹងប្រែងធ្វើការដើម្បីឱ្យកូនរបស់យើងទទួលបានចំណេះដឹង និងជំនាញចាំបាច់សម្រាប់ប្រើក្នុងជីវិត។ ប៉ុន្តែការចូលរៀនរបស់កុមារត្រូវថយចុះ នៅពេលដែលកុមារ ឬសមាជិកគ្រួសារឈឺ ពេលសាលាមិនស្អាត ឬ ពុំមានបរិក្ខារអនាម័យត្រឹមត្រូវ ឬនៅពេលសិស្សខ្លាចអំពើហិង្សា ឬការបៀតបៀនផ្សេងៗ នៅពេលធ្វើដំណើរពីផ្ទះទៅសាលា និងពីសាលាទៅផ្ទះ។

អត្ថបទតស៊ូមតិ : ប្រាក់កាស ពេលវេលា និងធនធាន ដែលបានលះបង់សម្រាប់សាលាជាការវិនិយោគដ៏ធំដែលយើងគួរធ្វើ។ ប៉ុន្តែការវិនិយោគរបស់យើងក្នុងការអប់រំ នឹងទទួលបានផលចំណេញមកវិញ ប្រសិនបើកូនចៅរបស់យើងបានចូលរៀនទាំងអស់គ្នា។

<u>បញ្ហា</u>: កុមារ ជាពិសេសកុមារី ដែលមានជំងឺឃ្លាន ខ្សោយដោយជំងឺប៉ារ៉ាស៊ីត ខ្លាច ឬឆ្ងាយហត់ដោយធ្វើការងារច្រើន មិនអាចរៀនបានល្អទេ។ បញ្ហាសុខភាពផ្លូវចិត្ត និងផ្លូវកាយដែលអាចការពារបានទាំងនេះ អាចប៉ះពាល់ដល់ការសិក្សា ជាពិសេសការសិក្សារបស់កុមារដែលធ្វើការធ្ងន់។

អត្ថបទតស៊ូមតិ : យើងអាចបង្រៀនបានល្អ លុះណាតែកុមារដែលមករៀនអាចមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ទាំងផ្លូវកាយ និងផ្លូវចិត្ត។

---

[1] Adapted from: World Health Organization (2000) Local Action: Creating Health Promoting Schools. Geneva.

បញ្ហា: ការចូលរៀនត្រូវថយចុះ នៅពេលឪពុកម្តាយបារម្ភពីសុវត្ថិភាពរបស់កូន ឬនៅពេលដែលសាលាពុំមានធនធានសម្ភារសម្រាប់សេវាអនាម័យ និងសុខភាពសម្រាប់កូន។។

អត្ថបទតស៊ូមតិ : ដោយហេតុថា ធនធានរបស់សាលាយើងតែងមានកំណត់ បើចង់ឱ្យមានធនធានបន្ថែម គឺអាស្រ័យលើគ្រួសារ និងសហគមន៍។ ប៉ុន្តែ បើមិនទុកចិត្តសាលា ដោយហេតុថាសាលាពុំមានគោលនយោបាយធានាសុវត្ថិភាព និងសុខភាពកុមារទេ ការកៀរគរធនធានបន្ថែមពីគ្រួសារ និង សហគមន៍ ជាកិច្ចការដែលមិនអាចធ្វើបានទេ។

ការបង្កើតឱ្យមានការឯកភាពគ្នាជារួម

នៅពេលអត្ថបទតស៊ូមតិរបស់យើងត្រូវបានរៀបចំរួចស្រេចហើយ យើងត្រូវផ្សព្វផ្សាយ ដូច្នេះយើងអាចទទួលបានការគាំទ្រតាមដែលយើងត្រូវការដើម្បីដួចផ្តើមគោលនយោបាយសុខភាពសិក្សា។ វិធីមួយដើម្បីទទួលការគាំទ្រគឺ ការផ្សព្វផ្សាយគំនិត និងឧទាហរណ៍អំពីបរិយាកាសសាលាដែលមានសុខភាព សុវត្ថិភាព អំពីអ្វីដែលសាលាកំពុងធ្វើ និងអំពីអ្វីដែលសាលាអាចផ្តល់ដល់កុមារ គ្រួសារ គ្រូ និងសហគមន៍ទាំងមូល។ ធ្វើបែបនេះ សាលានឹងបានទទួលផលមកវិញពីអ្វីដែលសហគមន៍គិតអំពីបញ្ហាសុខភាព និងសុវត្ថិភាព និងពីវិធីដែលសាលាអាចធ្វើ ដើម្បីដោះស្រាយបញ្ហាទាំងអស់នេះ។ យើងអាចចាប់ផ្តើមដោយធ្វើសកម្មភាពពីរ។



សកម្មភាពអនុវត្ត : ការឯកភាពមតិ សម្រាប់បង្កើតគោលនយោបាយ

ប្រមែប្រមូលមនុស្សមួយក្រុមតូចដែលចាប់អារម្មណ៍លើការលើកកម្ពស់សុខភាព និងលទ្ធផលសិក្សារបស់សិស្ស : *មនុស្សទាំងនោះ អាចជាក្រុមសម្របសម្រួលបរិយាកាសរៀនមេត្រី ដោយដាក់បញ្ចូលគ្នាគ្រប់សមាសភាព ឬក្រុមផ្សេងទៀតដែលអ្នកអាចរកបាន។ រួមទាំងនាយក ឬនាយិកា បុគ្គលិករដ្ឋបាល ឬសមាជិកសមាគមន៍ មាតាបិតា លោកគ្រូ អ្នកគ្រូ សិស្ស និងអ្នកដឹកនាំសហគមន៍ ដូចជា មេសាសនា អាជ្ញាធរមូលដ្ឋាន ឬអ្នកដែលធ្វើការជាមួយកុមារ និងយុវជនក្រៅសាលា។ ទាក់ទងជាមួយបុគ្គលិកសុខាភិបាលមូលដ្ឋាន ឬអ្នកដទៃទៀត ដូចជាអ្នកផ្តល់សេវាសង្គមកិច្ចដែលអាចជួយអ្នកកត់សម្គាល់ និងពន្យល់ពីការលើកកម្ពស់សុខភាព និងការសិក្សារបស់កុមារ។ ព្យាយាមបញ្ចូលគ្រូពេទ្យអាជីពដែលចេះដឹងអំពីបញ្ហាសុខភាពកុមារ និងមើលឃើញពីសារៈសំខាន់នៃតម្រូវការ នៃការលើកកម្ពស់សុខភាពក្នុងសាលា។ ក្រុមមនុស្សដែលអ្នកបានប្រមែប្រមូលនេះ អាចក្លាយជាក្រុមសុខភាពសិក្សាដែលដឹកនាំ និងតាមដានគោលនយោបាយ និងកម្មវិធីនានាដើម្បីលើកកម្ពស់អនាម័យសិក្សាជាមិនខាន។*

សុំឱ្យពួកគេលើកយកគំរូគោលនយោបាយមួយឬពីរ ក្នុងសាលា ឬក្នុងសហគមន៍ដែលជួយធានាឱ្យមានការលើកកម្ពស់សុខភាព សុវត្ថិភាព និងការសិក្សារបស់កុមារ ជាពិសេសកុមារដែលមានប្រវត្តិ និងសមត្ថភាពខុសគេ។ *កត់ត្រាគំរូគោលនយោបាយទាំងនោះ លើផ្ទាំងក្រដាសធំ។ ឬកន្លែងផ្សេងទៀតដែលអាចសរសេរបាន។ (សកម្មភាពនេះគួរធ្វើជាក្រុមតូចៗជាជាងធ្វើជាបុគ្គល)។*

សុំឱ្យពួកគេលើកយកគោលនយោបាយមួយឬពីរដែលត្រូវកែតម្រូវ ដើម្បីលើកកម្ពស់សុខភាព សុវត្ថិភាព និងការសិក្សារបស់សិស្ស។ *កត់ត្រាគោលនយោបាយទាំងនេះលើផ្នែកខាងឆ្វេងនៃក្រដាស។*

ធ្វើជាមួយគ្នាក្នុងក្រុមតែមួយ ដើម្បីបង្ហាញពីហេតុផលដែលត្រូវកែប្រែគោលនយោបាយទាំងនេះ ។ *កត់ត្រាហេតុផលទាំងនេះក្នុងប្រលោះមួយ (នៅផ្នែកខាងស្តាំនៃក្រដាស)។*

ធ្វើជាមួយគ្នាដើម្បីរៀបចំផែនការសកម្មភាពដើម្បីកែសម្រួលគោលនយោបាយនេះ *(មើលកម្រងសៀវភៅលេខ១ និង ៣ សម្រាប់រៀបចំផែនការសកម្មភាព)។*



សកម្មភាពអនុវត្ត : បង្កើតឱ្យមានការឯកភាពគ្នារួម តាមរយៈការផ្លាស់ប្តូរគំនិត

បង្កើតឱ្យមានការគាំទ្រកាន់តែច្រើនដោយផ្លាស់ប្តូរគំនិត និងឧទាហរណ៍អំពីសកម្មភាពទាក់ទងនឹងសុខភាពសិក្សា។ *ការជ្រើសរើសមនុស្សដែលមានការងារខុសៗគ្នាជាការសំខាន់ណាស់ ដូចជាអ្នកដឹកនាំទាំងផ្លូវការ និងក្រៅផ្លូវការ បុរស និងស្ត្រី និងសិស្ស។ សកម្មភាពមួយចំនួនដែលអាចជួយអ្នកធ្វើការងារនេះ មានដូចខាងក្រោម[2] :*

- *និយាយពីការគំរាមកំហែងដល់សុខភាពដែលអាចធ្វើឱ្យប៉ះពាល់ដល់ការសិក្សារបស់កុមារ និងអំពីអត្ថប្រយោជន៍ដែលគោលនយោបាយ និងកម្មវិធីរបស់សាលាអាចជាប្រយោជន៍ដល់កុមារ បុគ្គលិក និងសហគមន៍។ ជួបប្រជុំជាមួយអ្នកដឹកនាំសហគមន៍ដើម្បីពិភាក្សាគំនិតទាំងនេះ។*
- *ពិភាក្សាជាមួយសិស្ស និងឪពុកម្តាយសិស្សដើម្បីឱ្យពួកគេយល់ដឹងពីគោលនយោបាយ និងស្តាប់យោបល់ពីពួកគាត់ពីបញ្ហានេះ។*
- *អញ្ជើញឪពុកម្តាយសិស្ស និងសមាជិកសហគមន៍នានាឱ្យចូលរួមប្រជុំ ឬធ្វើការពិភាក្សាគ្នាបន្ទាប់ពីពិធីបុណ្យសាលា ដែលជាពេលមនុស្សម្នាជាច្រើនបានមកជួបជុំគ្នា។*

---

[2] Adapted from: World Health Organization (2000) Local Action: Creating Health Promoting Schools. Geneva.

- ជំរុញឱ្យមានគោលនយោបាយ និងកម្មវិធីសុខភាពសិក្សាតាមរយៈវិធីអប់រំសាធារណៈ ដូចជា ទិតប័ណ្ណ វិទ្យុ សុន្ទរកថា បដា (សិស្សក៏អាចជួយរៀបចំបានដែរ)។
- រៀបចំឱ្យមានការប្រែលង់សរសេរជាពាក្យកាព្យស្តីពីប្រធានបទនានានៅក្នុងមូលដ្ឋាន។
- ជួយឧបត្ថម្ភឱ្យមានការដាក់តាំងបង្ហាញនៅតាមតំបន់មហាជ្រីកនានារបស់សហគមន៍អំពីការលើកកម្ពស់សុខភាពសិក្សា សុវត្ថិភាព និងការសិក្សារបស់សិស្ស។ លើកទឹកចិត្តសិស្សនៅម៉ោងរៀនមុខវិជ្ជា សិល្បៈឱ្យគូររូបតុបតែងសាលា និងមណ្ឌលសហគមន៍អំពីការលើកកម្ពស់សុខភាព។

នៅពេលអ្នកលើកកម្ពស់តម្រូវការឱ្យមានគោលនយោបាយ និងកម្មវិធីសុខភាពសិក្សា ជាពិសេសគោលនយោបាយ និងកម្មវិធី ដែលមានគោលបំណងដោះស្រាយតម្រូវការរបស់កុមារដែលមានប្រវត្តិ និងសមត្ថភាពខុសគេ អ្នកនឹងឃើញថា កម្មវិធីនេះនឹងមានអ្នកគាំទ្រច្រើនក្នុងសហគមន៍។ អ្នកទាំងនេះអាចជាអ្នកគាំទ្រដោយអស់ពីចិត្ត ហើយពួកគេអាចជួយអ្នកក្នុងការដោះស្រាយរាល់បញ្ហាមិនចុះសម្រុងគ្នានានាដែលអាចកើតមានដោយសារវឿងអាស្រូវ សុខភាព ដូចជាមេរោគអេដស៍/ជំងឺអេដស៍ជាដើម។ រៀបចំឱ្យមានគណៈកម្មការ ពិគ្រោះយោបល់សហគមន៍ ដែលតំណាងឱ្យគ្រប់ផ្នែកនៃសហគមន៍ នឹងជាជំនួយដ៏សំខាន់ដើម្បីឱ្យការងារនេះបានជោគជ័យ។

កំណត់ចំណាំ :

គោលនយោបាយសុខភាពសិក្សានឹងមានប្រយោជន៍ដល់ក្មេងប្រុស **និងស្រីមកពីគ្រប់ក្រុមទាំងអស់**ក្នុងសង្គម មិនមែនសម្រាប់តែអ្នកដែលមានប្រវត្តិ និងសមត្ថភាពខុសគេនោះទេ។ គោលនយោបាយ ដែលដោះស្រាយតម្រូវការរបស់កុមារគ្រប់រូបអាចនឹងបានទទួលការគាំទ្រ និងអាចទទួលជោគជ័យ។ រៀបចំគោលនយោបាយ ដាច់ដោយឡែកផ្សេងគ្នាសម្រាប់កុមារមួយក្រុមត្រូវចំណាយពេលវាលា និងច្រាក់ច្រើន ហើយអាចបណ្តាលឱ្យមានជម្លោះទៀតផង។

ពិនិត្យ និងវាយតម្លៃស្ថានភាពគោលនយោបាយសុខភាពសិក្សាក្នុងសាលា

នៅពេលអ្នកទទួលបានការឧបត្ថម្ភដើម្បីរៀបចំគោលនយោបាយសុខភាពសិក្សា និងសុវត្ថិភាពសិស្ស សំណួរបន្ទាប់ ដែលយើងត្រូវឆ្លើយគឺ **"តើយើងត្រូវធ្វើអ្វីបន្ទាប់ទៀត?"** វិធីសាស្ត្រមួយដ៏ល្អគឺការពិនិត្យ និងវាយតម្លៃ គោលនយោបាយសិក្សាដែលមានស្រាប់ ក៏ដូចជា បញ្ហាសុខភាពដែលមាននៅក្នុងសហគមន៍។ វិធីមួយ ដើម្បីធ្វើសកម្មភាពនេះគឺប្រើបញ្ជីសម្រាប់ត្រួតពិនិត្យដូចដែលមាននៅក្នុងតារាងខាងក្រោម :



សកម្មភាពអនុវត្ត : ពិនិត្យ និងវាយតម្លៃគោលនយោបាយសាលា

តារាងត្រួតពិនិត្យខាងក្រោមត្រូវបានរៀបចំដើម្បីកំណត់ (ក) ថាតើគោលនយោបាយសុខភាពសិក្សាបានអនុវត្តហើយឬនៅ ប្រសិនបើមិនទាន់ ចាំបាច់ត្រូវតែធ្វើ (ខ) ប្រសិនបើគោលនយោបាយនោះ បានរៀបរៀងរួចហើយ ថាតើសាលាមានកម្មវិធីយ៉ាងណាខ្លះដើម្បីអនុវត្តគោលនយោបាយទាំងនោះ បើសិនជាមិនទាន់មានទេ ត្រូវរៀបចំបង្កើតសកម្មភាពថ្មី។ តារាងត្រួតពិនិត្យនេះមិនមែនចប់ត្រឹមប៉ុណ្ណោះទេ អ្នកអាចបន្ថែមចំណុចផ្សេងទៀតទៅតាមស្ថានភាពសាលា។ សកម្មភាពល្អដែលត្រូវអនុវត្តជាផ្នែកមួយនៃការតាមដានការគេសង្កេត និងការឯកភាពគ្នា ដែលបានពិភាក្សាខាងលើ។ សកម្មភាពនេះ ផ្តល់ឱ្យអ្នក និងក្រុមរបស់អ្នកនូវឱកាសមួយដើម្បីគិតឡើងវិញ នូវអ្វីដែលត្រូវអនុវត្តមុនគេ ក្នុងដំណើរការសកម្មភាព[3]។

តើសាលារបស់ខ្ញុំមានគោលនយោបាយប្រឆាំងនឹងការរើសអើង ដែលធានាថា មាន : (គួរសញ្ញា X សម្គាល់ ប្រសិនបើមាន)

_____ *ការគោរពសិទ្ធិមនុស្ស និងឱកាសស្មើគ្នា ការប្រព្រឹត្តមកលើដូចគ្នា ដោយមិនគិតភេទ រូបរាងបញ្ញា វណ្ណៈសង្គម ចិត្ត ភាសា និងលក្ខណៈផ្សេងៗជាច្រើន។*

_____ *ការការពារមិនឱ្យមានការបៀតបៀនផ្លូវភេទ ឬការប៉ះពាល់ដល់យសិស្ស ឬបុគ្គលិកសាលា និងវិធានការវិន័យមានប្រសិទ្ធភាពសម្រាប់អ្នកដែលប្រព្រឹត្តខុស។*

_____ *សម្ភារពិសេសសម្រាប់សិស្សពិការ ដើម្បីឱ្យពួកគេអាចធ្វើដំណើរទៅកាន់ថ្នាក់រៀនដោយស្រួល និងសម្ភារផ្សេងទៀតដែលធ្វើឱ្យបរិយាកាសសិក្សាទាក់ទាញសម្រាប់កុមារពិការ។*

_____ *កុមារមានផ្ទៃពោះនឹងមិនត្រូវបញ្ឈប់ពីការសិក្សាទេ។*

_____ *មាតាដែលនៅក្មេងទទួលបានការលើកទឹកចិត្តឱ្យចូលរៀនវិញ។*

_____ *កុមារដែលមានប្រវត្តិ និងសមត្ថភាពខុសគ្នាទទួលបានការអប់រំដែលមានគុណភាពដូចកុមារទូទៅដែរ កុមារទាំងនេះរួមមាន កុមារី កុមារកំព្រា កុមារជនជាតិភាគតិច និងកុមារដែលស្ថិតនៅក្នុងស្ថានភាពមិនធម្មតា និងមានវិបត្តិ។*

---

[3] Adapted from: UNESCO (2002) FRESH: A Comprehensive School Health Approach to Achieve EFA. Paris. (ED-2002/WS/8 Rev.)

_____ គ្រូ និងបុគ្គលិកដទៃទៀតត្រូវទទួលបានការបណ្តុះបណ្តាល ការឧបត្ថម្ភ និងច្បាស់ខែដូចគ្នា។

តើសាលាខ្ញុំមានគោលនយោបាយប្រឆាំងអំពើហិង្សា និងការប៉ះពាល់ផ្សេងៗដែលធានាថា :

_____ សាលាមានសុវត្ថិភាព សុខភាពល្អ មានបរិយាកាស និងចិត្តសាស្ត្រជំរុញឱ្យមានការសិក្សាល្អ។

_____ មិនអត់អោនឱ្យអំពើហិង្សា ហាមឃាត់មិនឱ្យមានអាវុធក្នុងទីធ្លាសាលា។

_____ បរិយាកាសដែលមិនមានថ្នាំញៀន គ្រឿងស្រវឹង និងបារី។

តើសាលាខ្ញុំមានគោលនយោបាយទឹកស្អាត អនាម័យ និងបរិស្ថានល្អដែលធានាឱ្យមាន :

_____ ទឹកស្អាតគ្រប់គ្រាន់ (សម្រាប់លាងដៃ និងផឹក)។

_____ បង្គន់អនាម័យដាច់ដោយឡែកសម្រាប់បុរស ស្ត្រី ក្មេងប្រុស និងក្មេងស្រី។

_____ ចំនួនបង្គន់អនាម័យគ្រប់គ្រាន់។

_____ កន្លែងចោះចោលសំរាមត្រឹមត្រូវ។

_____ ការថែទាំសម្ភារឱ្យបានស្អាតបាត ជាពិសេសសម្ភារសម្រាប់ដងទឹក និងអនាម័យ។

_____ ការអប់រំស្តីពីការកែច្នៃរបស់ចាស់ៗ។

តើសាលាខ្ញុំមានគោលនយោបាយលើកកម្ពស់ការអប់រំសុខភាពបឋមដែលធានាឱ្យមាន :

_____ ការអប់រំសុខភាពសមស្របតាមអាយុ និងការអប់រំអំពីជីវិតក្នុងគ្រួសារដល់ក្មេងប្រុស និងស្រី ជាផ្នែកមួយនៃកម្មវិធីអប់រំមូលដ្ឋាន។

_____ កម្មវិធីការពារ និងកាត់បន្ថយអាកប្បកិរិយាដែលនាំឱ្យមានផ្ទៃពោះដោយមិនបានគ្រោងទុក និងអាកប្បកិរិយាដែលនាំឱ្យឆ្លងមេរោគអេដស៍/ជំងឺអេដស៍។

_____ ការគាំទ្រសង្គម និងពិគ្រោះយោបល់ដល់សិស្សដែលមានផ្ទុកមេរោគអេដស៍/ជំងឺអេដស៍ និងកុមារកំព្រា។

_____ ផ្តល់សេវាអប់រំសុខភាពតាមសហគមន៍ ដើម្បីដោះស្រាយបញ្ហាសុខភាពរបស់មនុស្សពេញវ័យជាពិសេសស្ត្រី។

តើសាលាខ្ញុំមានគោលនយោបាយលើកកម្ពស់សេវាសុខភាព និងរបបអាហារ ដែលធានា :

_____ ការថែរក្សាឯកសារសុខភាពសិក្សាសម្រាប់សិស្សគ្រប់រូប។

_____ ការពិនិត្យសុខភាពទូទៅ សុខភាពមាត់ធ្មេញ និងរបបអាហារទៀងទាត់។

_____ ឱកាសស្មើគ្នាក្នុងការធ្វើលំហាត់ប្រាណ និងការកំសាន្តរបស់ក្មេងប្រុស និងស្រី។

_____ បណ្តុះបណ្តាលគ្រូ និងការឧបត្ថម្ភដើម្បីឱ្យពួកគាត់អាចផ្តល់សេវាសុខភាពមូលដ្ឋាន។

_____ យន្តការឆ្លើយតបទៅនឹងការសង្គ្រោះបន្ទាន់ទាន់ពេល និងមានប្រសិទ្ធភាព ក្នុងករណីមានអាសន្ន ដូចជា របួស និងគ្រោះធម្មជាតិជាដើម។

_____ មានអាហារសម្រាប់សិស្សដែលក្រីក្រដែលពុំមានអាហារហូបចុកគ្រប់គ្រាន់នៅផ្ទះ។

_____ សេចក្តីណែនាំដល់អ្នកលក់អាហារដើម្បីធានាថា អាហារមានគុណភាព មានអនាម័យ និងស្តង់ដាគ្រឹមត្រូវ។

_____ ការចូលរួមរបស់សហគមន៍ក្នុងការរៀបចំ និងផ្តល់ការអប់រំ និងផ្តល់សេវាសុខភាព សម្រាប់ទារក និងកុមារគ្រប់អាយុចូលរៀននៅបឋមសិក្សា។

កំណត់ចំណាំ

ចូរធ្វើដោយសន្សឹមៗ : ដំណើរការនៃការរៀបចំគោលនយោបាយ និងការចាប់ផ្តើមកែសម្រួលត្រូវធ្វើដោយសន្សឹមៗ ដើម្បីធ្វើឲ្យភាគីពាក់ព័ន្ធមានអារម្មណ៍ពេញចិត្តទទួលយកការកែប្រែទាំងនេះ និងយល់ច្បាស់អំពីតម្រូវការឱ្យមានការកែប្រែបែបនេះ។



សកម្មភាពអនុវត្ត : ពិនិត្យ និងវាយតម្លៃបញ្ហាសុខភាពសហគមន៍

លទ្ធភាពនៃការចូលរៀនរបស់កុមារ ជាពិសេសកុមារដែលមានប្រវត្តិ និងសមត្ថភាពខុសពីកុមារទូទៅ គឺអាស្រ័យលើគោលនយោបាយ និងកម្មវិធីរបស់សាលា និងអាស្រ័យលើបញ្ហាសុខភាពរបស់សហគមន៍ដែលកុមារស្នាក់នៅផងដែរ។

គោលនយោបាយ និងកម្មវិធីសិក្សាសាលា ត្រូវតែរៀបចំឡើងដើម្បីដោះស្រាយបញ្ហាទាំងឡាយដែលប៉ះពាល់ដល់កុមារ និងបរិយាកាសសិក្សា ដោយសហការយ៉ាងជិតស្និទ្ធជាមួយមេដឹកនាំសហគមន៍ គ្រួសារ និងសមាជិកសហគមន៍ទូទៅ។ តារាងខាងក្រោមនេះ ជាឯកសារសម្រាប់ពិនិត្យ និងវាយតម្លៃបញ្ហាសុខភាព

បញ្ហាសុខភាព	ធ្ងន់ធ្ងរប៉ុណ្ណា	ការប៉ះពាល់ដល់សិស្ស គ្រូ សាលា និងសហគមន៍	គោលនយោបាយសាលា និងការអនុវត្ត
ការប្រើប្រាស់គ្រឿងស្រវឹង	១ ២ ៣ ៤ ៥		
ការជក់បារី	១ ២ ៣ ៤ ៥		
ជំងឺដែលមានថ្នាំបង្ការ	១ ២ ៣ ៤ ៥		
របួស	១ ២ ៣ ៤ ៥		
បញ្ហាចក្ខុ និងសោតវិញ្ញាណ	១ ២ ៣ ៤ ៥		
សត្វល្អិត (ព្រូន) ជំងឺឆ្លង	១ ២ ៣ ៤ ៥		
ជំងឺគ្រុនចាញ់	១ ២ ៣ ៤ ៥		
សរសៃប្រសាទ	១ ២ ៣ ៤ ៥		
ការខ្វះវីតាមីនអា/អ៊ីយ៉ូត ជាតិដែក	១ ២ ៣ ៤ ៥		
ការខ្វះប្លែតអ៊ីនថាមពល (អាហារូបត្ថម្ភ)	១ ២ ៣ ៤ ៥		
បញ្ហាសុខភាពមាត់/ធ្មេញ	១ ២ ៣ ៤ ៥		
រលាកផ្លូវដង្ហើម	១ ២ ៣ ៤ ៥		
ទឹកស្អាត	១ ២ ៣ ៤ ៥		
ការខ្វះអនាម័យ	១ ២ ៣ ៤ ៥		
មេរោគអេដស៍/ជំងឺអេដស៍ និងកាមរោគ	១ ២ ៣ ៤ ៥		
ការខ្វះច្នៃបពេលសម្រាលកូន	១ ២ ៣ ៤ ៥		
អំពើហិង្សា	១ ២ ៣ ៤ ៥		
បញ្ហាផ្សេងទៀត _____	១ ២ ៣ ៤ ៥		

[4] Adapted from: World Health Organization (2000) Local Action: Creating Health Promoting Schools. Geneva.

ក្នុងសហគមន៍។ តារាងនេះ ជាដំណាក់កាលដំបូងនៃដំហានសហការជាមួយមេដឹកនាំសហគមន៍ ដើម្បីរៀបចំកម្មវិធីនិងគោលនយោបាយសមស្របមួយសម្រាប់អនុវត្តសកម្មភាពទាក់ទងនឹងបញ្ហាសុខភាព សហគមន៍[4]។

ការណែនាំ : ផ្អែកលើចំណេះដឹងរបស់អ្នកអំពីសុខភាពសហគមន៍ ចូរប្រើប្រាស់តារាងខាងក្រោមដើម្បីវាយតម្លៃបញ្ហាសុខភាពសហគមន៍ ដោយគូសវង្វង់ជុំវិញលេខ តាមការណែនាំនិយមដូចខាងក្រោម :

1 = មិនមានបញ្ហាទាល់តែសោះ 2 = មានបញ្ហាបន្តិចបន្តួច 3 = មានបញ្ហាធ្ងន់ធ្ងរបង្គួរ
4 = មានបញ្ហាធ្ងន់ធ្ងរ 5 = មានបញ្ហាធ្ងន់ធ្ងរណាស់

បន្ទាប់មក រៀបរាប់ថា តើបញ្ហាទាំងនេះ ប៉ះពាល់របៀបណា ដល់កុមារ គ្រូ/បុគ្គលិកសាលា និងសហគមន៍ ប៉ះពាល់ដល់សុខភាព សុខុមាលភាព វត្តមាន លទ្ធផលសិក្សា ការត្រួតថ្នាក់ សកម្មភាពសេដ្ឋកិច្ច គុណភាពនៃការបង្រៀន និងបន្ទុកសេវាសុខភាព។ ចុងក្រោយបង្អស់ កំណត់គោលនយោបាយដែលសាលាត្រូវអនុម័តដើម្បីកាត់បន្ថយភាពធ្ងន់ធ្ងរនៃបញ្ហាទាំងនោះ។ ឧទាហរណ៍ ប្រសិនបើការជក់បារី ប៉ះពាល់ដល់សុខភាពគ្រូ សមាជិកគ្រួសារ និងកុមារ (តាមរយៈការជក់បារីផ្ទាល់ ឬផ្សែងបារីដែលអ្នកនៅជុំវិញបានជក់) សាលាត្រូវរៀបចំគោលនយោបាយហាមឃាត់មិនឱ្យមានផ្សែងបារីក្នុងទីធ្លាសាលា។ គោលនយោបាយនេះរួមមាន ការហាមឃាត់មិនឱ្យគ្រូ និងបុគ្គលិកផ្សែងទៀត ជក់បារីនៅទីធ្លាសាលា។ ធ្វើបែបនេះ ពួកគេនឹងក្លាយជាគំរូល្អសម្រាប់កុមារ ក៏ដូចជាសមាជិកសហគមន៍ផ្សែងទៀតផងដែរ។

ដោះស្រាយអំពើហិង្សា : ប្រែក្លាយគោលនយោបាយឱ្យទៅជាការអនុវត្តជាក់ស្តែង

ក្នុងសាលា កុមារដែលមានជីវប្រវត្តិ និងសមត្ថភាពខុសពីកុមារដទៃ ជាកុមារដែលងាយទទួលរងនូវការរើសអើង អំពើហិង្សា និងការចំអកមើលងាយ ហើយជាញឹកញាប់បណ្តាលមកពី "ភាពខុសគ្នា" ពីកុមារដទៃនៅក្នុងសាលា។ កាន់តែធ្ងន់ធ្ងរទៅទៀត បញ្ហាទាំងនេះច្រើនទាក់ទងនឹងការបៀតបៀនផ្លូវភេទ អំពើហិង្សាលើរាងកាយ ដែលជួនកាលអាចដល់ស្លាប់។

អំពើហិង្សាអាចមានច្រើនរូបភាព ហើយត្រូវបានយល់ឃើញខុសៗគ្នាតាមទម្លាប់ និងវប្បធម៌ផ្សេងៗគ្នា។ ក្នុងកម្រងសៀវភៅនេះ អំពើហិង្សា ជាការប្រើប្រាស់ដោយចេតនានូវអំណាច កម្លាំងកាយ ដើម្បីគំរាមកំហែង ឬធ្វើឱ្យមានគ្រោះថ្នាក់ដល់ខ្លួនឯង ឬអ្នកដទៃ ឬក្រុមមនុស្ស ឬប្រជាជនទូទៅ ក្នុងសហគមន៍។ ជាញឹកញាប់ អំពើហិង្សាបន្សល់ទុកនូវស្នាមរបួស ស្លាប់ វិបត្តិផ្លូវចិត្ត ប៉ះពាល់ដល់ការលូតលាស់ នៃរាងកាយ និងការផ្តាច់ខ្លួនចេញពីសង្គម។

យើងធ្លាប់តែគិតថា អំពើហិង្សាកើតឡើងនៅពេលមានមនុស្សម្នាក់វាយធ្វើបាបមនុស្សម្នាក់ទៀត តែតាមការពិត អំពើហិង្សាមាន ៣ ទម្រង់ខុសៗគ្នា។

អំពើហិង្សាលើខ្លួនឯង ទាក់ទងទៅនឹងអាកប្បកិរិយាគ្រោះថ្នាក់ដោយចេតនាមកលើខ្លួនឯង ដែលលទ្ធផលចុងក្រោយបណ្តាលឱ្យស្លាប់ខ្លួនឯង និងសម្លាប់អ្នកដទៃ។ អំពើហិង្សាលើខ្លួនឯងផ្សេងទៀតរួមមានការប៉ុនប៉ង សម្លាប់ខ្លួន អាកប្បកិរិយាដែលបំផ្លាញខ្លួនឯង ប៉ុន្តែមិនបណ្តាលដល់ស្លាប់ (ដូចជា ការបំផ្លាញអវយវៈណាមួយជាដើម)។

អំពើហិង្សារវាងបុគ្គល និងបុគ្គល គឺជាអាកប្បកិរិយាហិង្សារវាងបុគ្គលម្នាក់លើបុគ្គលម្នាក់ទៀត។ អំពើហិង្សាបែបនេះអាចពណ៌នាថា ជាទំនាក់ទំនង "ជនរងគ្រោះ-អ្នកប្រព្រឹត្តអំពើហិង្សា"។ អំពើហិង្សាបែបនេះមានការបៀតបៀនផ្លូវភេទ និងការសម្លុតគំរាមកំហែង។

អំពើហិង្សាគ្រោងទុក គឺជាអាកប្បកិរិយាហិង្សាដែលបង្កឡើងដោយក្រុមសង្គម ឬក្រុមនយោបាយ ដែលបញ្ចើចបញ្ចើរដោយក្រុមនយោបាយ សេដ្ឋកិច្ច និងក្រុមសង្គមមួយទៀត។ ឧទាហរណ៍នៃអំពើហិង្សាបែបនេះរួមមានទំនាស់នយោបាយ ទំនាស់ជាតិសាសន៍ និងទំនាស់សាសនា។

តើបុព្វហេតុនៃអំពើហិង្សាមានអ្វីខ្លះ? មូលហេតុទាំងនេះមានលក្ខណៈស្មុគស្មាញណាស់ និងខុសៗគ្នា។ ខាងក្រោមនេះគឺជាមូលហេតុមួយចំនួនដែលគេគិតថា ជាដើមទងដែលបណ្តាលឱ្យមានអំពើហិង្សា។ អ្នកអាចប្រើប្រាស់កត្តាទាំងអស់នេះ ឬបន្ថែមកត្តាផ្សេងទៀត ដើម្បីវាយតម្លៃមើលថា តើសាលា គ្រួសារ និងសហគមន៍របស់អ្នកប្រឈមមុខនឹងអំពើហិង្សាយ៉ាងណាខ្លះ ហើយថា តើគោលនយោបាយ និងកម្មវិធីសាលាអាចធ្វើអ្វីខ្លះដើម្បីដោះស្រាយបញ្ហាអំពើហិង្សាទាំងនោះ។

បុព្វហេតុដែលនាំឱ្យមានអំពើហិង្សា : តើបុព្វហេតុទាំងនេះកើតមានក្នុងសាលារបស់ខ្ញុំឬទេ?

កត្តាកុមារដែលជំរុញឱ្យមានអំពើហិង្សា

- ចំណេះដឹង ឥរិយាបថ ចិញ្ចឹមចិត្តហិង្សា និងការខ្វះជំនាញ ដូចជាជំនាញប្រាស្រ័យទាក់ទងគ្នា
- ការប្រើប្រាស់គ្រឿងញៀន និងការសេពគ្រឿងស្រវឹង
- ធ្លាប់បានជួបប្រទះអំពើហិង្សា ឬជាជនរងគ្រោះដោយអំពើហិង្សា
- អាចរកគ្រោះដោយសារគ្រឿងអាវុធ និងឧបករណ៍ដែលអាចបង្កឱ្យរបួសស្នាមដោយងាយស្រួល។

កត្តាគ្រួសារដែលជំរុញឱ្យមានអំពើហិង្សា

- ការខ្វះការស្រលាញ់ និងយកចិត្តទុកដាក់ពីឪពុកម្តាយ
- ជួបប្រទះអំពើហិង្សាញឹកញាប់នៅផ្ទះ
- ទទួលរងការដាក់ទណ្ឌកម្ម និងការធ្វើបាបតាមរូបភាពផ្សេងទៀត
- មានឪពុកម្តាយ ឬបងប្អូនជាប់ទាក់ទងនឹងអំពើឧក្រិដ្ឋ ឬមានអាកប្បកិរិយាដូចជនឧក្រិដ្ឋ

កត្តាសហគមន៍ និងបរិយាកាសផ្សេងទៀតដែលនាំឱ្យមានអំពើហិង្សា

- វិសមភាពសេដ្ឋកិច្ច សង្គមកិច្ច ការរីកដុះដាលតំបន់ក្រីក្រ និងការហូរចូលមករស់នៅតំបន់ទីក្រុងលើសលប់
- អត្រាអត់ការងារធ្វើខ្ពស់ក្នុងចំណោមយុវជនវ័យក្មេង
- ឥទ្ធិពលនៃការផ្សព្វផ្សាយហិង្សាជាសាធារណៈ
- សីលធម៌សង្គមដែលជំរុញឱ្យមានអំពើហិង្សា
- ភាពសម្បូរបែបនៃអាវុធ



សកម្មភាពអនុវត្ត : ប្រមែប្រមូលព័ត៌មានទាក់ទងអំពើហិង្សា

យើងគ្រប់គ្នាមិនបានគិតថាសាលា និងសហគមន៍របស់យើងគឺជាកន្លែង ដែលមានអំពើហិង្សានោះទេ។ ប៉ុន្តែ ជាអកុសល មានអំពើហិង្សាជាច្រើនបានរំលងភ្នែករបស់យើង ដោយហេតុថា ទាំងជនរងគ្រោះ ទាំងអ្នកប្រព្រឹត្តមិនចង់ឱ្យគ្រូ និងសាលាដឹងទេ។ លើសពីនេះទៀត អំពើហិង្សាអាចកើតមាននៅក្រៅសាលា ប៉ុន្តែឥទ្ធិពលរបស់វាអាចមានបន្តរហូតដល់សាលា និងថ្នាក់រៀន។

កំណត់ទំហំអំពើហិង្សានៅក្នុងសាលា អាចធ្វើបានដោយវិធីច្រើនយ៉ាង ដូចជា តាមរយៈការស៊ើបសួរសិស្ស ដោយប្រើកម្រងសំណួរ (ដូចបង្ហាញនៅក្នុងកម្រងសៀវភៅលេខ ៤) ឬណែនាំសិស្សឱ្យចូលរួមនៅ ក្នុងក្រុមពិភាក្សា ឬតាមរយៈដែនទីព័ត៌មានសហគមន៍។

គោលបំណងនៃការប្រមែប្រមូលព័ត៌មានទាក់ទងនឹងអំពើហិង្សា គឺដើម្បីឱ្យបានដឹងពីពេលវេលា និងទីកន្លែងដែលមានអំពើហិង្សា និងប្រភេទនៃអំពើហិង្សា (អំពើហិង្សាមកលើខ្លួនឯង អំពើហិង្សាដែលម្នាក់ជាជនរងគ្រោះ និងម្នាក់ជាអ្នកប្រព្រឹត្ត និងអំពើហិង្សាដែលបានគ្រោងទុក) និងដើម្បីបានដឹងថា នរណាជាអ្នករងគ្រោះ និងអ្នកណាជាអ្នកប្រព្រឹត្ត។ ដំណើរការនៃការប្រមូលព័ត៌មាន ជាដំណើរការយ៉ាងសំខាន់សម្រាប់ពិនិត្យ និងត្រួតត្រាអំពើហិង្សា ពីព្រោះដំណើរការនេះ អាច :

១. លើកទឹកចិត្តសិស្ស គ្រូ និងអ្នករដ្ឋបាលសាលាឱ្យចាប់ផ្តើមនិយាយអំពីអំពើហិង្សាក្នុងសាលា ដែលនឹងនាំឱ្យមានគោលនយោបាយដែលកាន់តែមានប្រសិទ្ធភាព។

២. ជួយវាយតម្លៃកម្មវិធីប្រឆាំងអំពើហិង្សា ដែលកម្មវិធីទាំងនេះត្រូវបានគេបង្កើតដើម្បីគាំទ្រគោលនយោបាយប្រឆាំងនឹងអំពើហិង្សាក្នុងសាលា។

៣. បង្កើនការចូលរួមរបស់សាលាក្នុងសកម្មភាពអន្តរាគមន៍ទប់ស្កាត់អំពើហិង្សា។

---

5 Adapted from: World Health Organization (1998) WHO Information Series on School Health, Document Three - Violence Prevention: An Important Element of a Health-Promoting School, Geneva·

ដើម្បីប្រមូលព័ត៌មានអំពើហិង្សាក្នុងសាលារបស់អ្នក អ្នកអាចប្រើដំណើរការស្រដៀងគ្នាទៅនឹងដំណើរការប្រមូលព័ត៌មានសហគមន៍ដែលបានរៀបរាប់ខាងដើមដែរ។ ចាប់ផ្តើមដោយឱ្យគ្រូ និងសិស្ស រៀបចំជែនទីសហគមន៍ ឬអាចរៀបចំជែនទីមួយផ្សេងដោយខ្លួនឯង ហើយបន្ទាប់មកឱ្យពួកគេកត់សម្គាល់ទីកន្លែង ពេលវេលា និងលក្ខណៈ ដែលគេគិតថា អាចមានអំពើហិង្សា និងអ្នកដែលពាក់ព័ន្ធក្នុងអំពើហិង្សា។ បន្ទាប់មកអ្នកអាចវិភាគជែនទីនេះ ដើម្បីកត់សម្គាល់ទីតាំងដែលមានអំពើហិង្សា។

គ្រូដទៃទៀត បានប្រើវិធីនេះរួចហើយ ហើយលទ្ធផលបង្ហាញថា អំពើហិង្សាកើតមានក្នុងពេលវេលា និងទីកន្លែងក្បែរ។សាលាដែលគេអាចដឹងទុកមុន[6]។ មិនមានអ្វីដែលគួរឱ្យភ្ញាក់ផ្អើលទេថា អំពើហិង្សាច្រើនកើតឡើងនៅទីកន្លែងដែលគ្មានវត្តមានគ្រូ ឬមានដែរ តែចំនួនតិចតួចប៉ុណ្ណោះ។

គោលនយោបាយដែលផ្តួចផ្តើម និងអនុវត្តដោយគ្រូ អាចនឹងទទួលបានជោគជ័យខ្លាំងណាស់ ក្នុងការកាត់បន្ថយអំពើហិង្សាក្នុងសាលា។ ទោះជាយ៉ាងនេះក្តី ចាំបាច់ត្រូវមានការចូលរួមពីសិស្សផងដែរ។ ការពិភាក្សាតាមក្រុម គួរតែធ្វើដើម្បីពិភាក្សាអំពី "ទីកន្លែងក្តៅ" នៃអំពើហិង្សាក្នុងសាលា ហេតុអ្វីបានជាកុមារមួយចំនួនត្រូវរងអំពើហិង្សា និងពិភាក្សាអំពីវិធីដែលត្រូវអនុវត្តដើម្បីកាត់បន្ថយអំពើហិង្សានៅទីកន្លែងទាំងនេះ និងពិភាក្សាអំពីកុមារដែលទទួលរងគ្រោះដោយអំពើហិង្សា។

បង្កើនការចូលរួមរបស់សមាជិកសហគមន៍ក្នុងការបញ្ឈប់អំពើហិង្សានៅសាលា ក៏អាចជួយលើកកម្ពស់បរិយាកាសគ្មានហិង្សាក្នុងសហគមន៍ផងដែរ។ ការចូលរួមនេះ មានសារៈសំខាន់ណាស់ ជាពិសេសនៅពេលដែលអំពើហិង្សាកើតមាននៅក្រៅសាលា ដូចជានៅពេលដែលកុមារធ្វើដំណើរទៅសាលា និងមកពីសាលា។ យុទ្ធសាស្ត្រនៃការប្រមូលព័ត៌មានដោយប្រើជែនទី អាចប្រើច្រាស់ដើម្បីកំណត់ទីកន្លែង និងពេលវេលាដែលអាចមានអំពើហិង្សា ទាំងនៅសាលា និងក្នុងសហគមន៍។

លំហាត់ស្តីពីការប្រមូលព័ត៌មានសហគមន៍ដែលបានលើកឡើងក្នុងកម្រងសៀវភៅលេខ ៣ អាចយកមកប្រើច្រាស់នៅកន្លែងនេះដែរ ដោយឱ្យកុមារកំណត់ទីកន្លែងក្នុងសហគមន៍ដែលមានអំពើហិង្សាញឹកញាប់ ប្រភេទនៃអំពើហិង្សា និងអ្នកដែលពាក់ព័ន្ធក្នុងអំពើហិង្សា និងអ្នកណាជាជនរងគ្រោះ និងអ្នកប្រព្រឹត្តអំពើហិង្សានេះ។ ការកំណត់ព័ត៌មានបែបនេះ ជាដំណាក់កាលទីមួយដ៏ល្អបំផុត ក្នុងការសហការជាមួយសមាជិកសហគមន៍ ដើម្បីកត់សម្គាល់ទីតាំងជាក់លាក់មួយចំនួនដែលងាយនឹងរងអំពើហិង្សា ដើម្បីលើកអនុសាសន៍ជាដំណោះស្រាយ និងដើម្បីរៀបចំកម្មវិធីអន្តរាគមន៍រួម រវាងសាលា និងសហគមន៍ឲ្យមានប្រសិទ្ធភាព។

---

6 Monitoring School Violence: Publications and Related Research Summaries. Global Program on Youth, University of Michigan, School of Social Work. http://gpy.ssw.umich.edu/. This is an excellent Web site for resources on dealing with violence in the school.

កន្លែងមានសុវត្ថិភាពសម្រាប់កុមារី

ឪពុកម្តាយជាច្រើននៅប្រទេសណេប៉ាល់បដិសេធមិនបញ្ជូនកូនស្រីទៅសាលា ដោយខ្លាចថា កូនស្រីអាចនឹងជួបគ្រោះថ្នាក់នៃការបៀតបៀន ដែលនឹងនាំឱ្យខូចកិត្តិយសគ្រួសារ។ តើកុមារ ជាពិសេសកុមារី ត្រូវកែប្រែបរិយាកាសដោយរបៀបណា ដើម្បីឱ្យមានសុវត្ថិភាព និងងាយស្រួលចូលរៀន? តើគ្រោះថ្នាក់នេះ អាចប៉ះពាល់យ៉ាងណាដល់ជីវិតសិក្សារបស់ក្មេងស្រី? គម្រោងជួយសង្គ្រោះកុមារនៅប្រទេសណេប៉ាល់ ដែលបានសម្របសម្រួលការស្រាវជ្រាវមួយ ដោយកុមារបានរិះរកមធ្យោបាយ ដើម្បីប្រែក្លាយកន្លែងដែលធ្លាប់មានគ្រោះថ្នាក់ឱ្យទៅជាកន្លែងដែលមានសុវត្ថិភាពសម្រាប់កុមារ។ ដោយបានចែករំលែកនូវលទ្ធផលនៃការស្រាវជ្រាវនេះ និងដោយការទំនាក់ទំនងជាមួយអាជ្ញាធរមូលដ្ឋាន លោកគ្រូ/អ្នកគ្រូ និងឪពុកម្តាយ និងកុមារទាំងនោះ អាចកៀរគរធនធាន ដើម្បីគាំទ្រការកែប្រែស្ថានភាពបែបនោះ។

កុមារីក្នុងស្រុកសូខេត នៃប្រទេសណេប៉ាល់ និយាយដោយជឿជាក់ពីភាពងាយគ្រោះថ្នាក់ក្នុងសហគមន៍ ។ អង្គការជួយសង្គ្រោះកុមារអង់គ្លេស បានរៀបចំគម្រោងមួយដែលក្នុងគម្រោងនោះ កុមារីជាអ្នកស្រាវជ្រាវដោយខ្លួនឯង ដោយស្វែងយល់ និងវិភាគទីកន្លែង និងស្ថានភាពរស់នៅ។ ដោយប្រើប្រាស់ឧបករណ៍ស្រាវជ្រាវ "ការលើកកម្ពស់ការចូលរួមរបស់អ្នកជនបទ" កុមារីទាំងនោះ អាចកំណត់សូចនាករដែលចង្អុលបង្ហាញអំពីបរិយាកាសមានសុវត្ថិភាព ហើយអាចរៀបចំផែនការដើម្បីចាត់វិធានការបង្កើតបរិយាកាសសុវត្ថិភាព។ កុមារីក៏បានកំណត់ព្រំដែនតំបន់ដែលគ្មានសុវត្ថិភាព ក្នុងភូមិផងដែរ ក្មេងប្រុសចូលរួមក្នុងដំណើរការនេះ តែក្នុងករណីដែលចាំបាច់ប៉ុណ្ណោះ។ ដើម្បីទាមទារកាន់កាប់កន្លែងរស់នៅ កុមារីកត់សម្គាល់តម្រូវការឱ្យ : (ក) ឪពុកម្តាយទទួលស្គាល់សារៈសំខាន់នៃការអប់រំកូនស្រី (ខ) ជៀសវាងប្រពៃណីអកិរក្ស ដូចជា ការរើសអើងភេទក្នុងវណ្ណៈនីមួយ។ ការរើសអើងរវាងកូនប្រុស និងកូនស្រី និងការចាប់រៀបចំគូស្រករកូនស្រី (គ) កុមារីអាចបង្ហាញស្នាដៃ និងសមត្ថភាពក្នុងសហគមន៍ (ឃ) ប្រជាពលរដ្ឋនិយាយអំពីអំពើអយុត្តិធម៌ និងការគាបសង្កត់កុមារី និង (ង) លើកកម្ពស់ការយល់ដឹងអំពីសិទ្ធិកុមារី និងត្រូវបង្កលក្ខណៈឱ្យកុមារីទទួលបានឱកាសស្មើភាពគ្នាជាមួយកុមារ។

ជាលទ្ធផលនៃដំណើរការការងារទាំងនេះ គេឃើញមានការកែប្រែច្រើនក្នុងសហគមន៍។ សមាជិកសហគមន៍ជាច្រើនបានមកពិគ្រោះយោបល់ជាមួយក្រុមយុវនារីទាំងនេះលើប្រធានបទនានា ដូចជា ការបៀតបៀន ការធ្វើបាប និងការគាបសង្កត់នានា។ គ្រូ និងក្មេងប្រុសក្នុងសាលា និងក្នុងសហគមន៍ បង្ហាញនូវការគោរពកាន់តែច្រើនដល់កុមារី ដែលពីមុនមកករណីបែបនេះមិនដែលមានទេ។ ក្មេងប្រុសដែលពីមុនធ្លាប់តែចំអន់កុមារី បែរជាជួយគាំទ្រកុមារីក្នុងកិច្ចខិតខំប្រឹងប្រែងឱ្យមានការកែប្រែនៅពេលនោះ។ ក្រុមជំនួយត្រូវបានបង្កើតឡើងសម្រាប់ជួយដល់កុមារីដែលទទួលរងការធ្វើបាប។ លើសពីនេះទៀត អាជ្ញាធរមូលដ្ឋានជឿជាក់ថា សហគមន៍ទាំងមូលផ្តល់នូវការគាំទ្រពេញទំហឹងដល់ការងាររបស់កុមារី ដោយពួកគេតែងនាំគ្នានិយាយអំពីរឿងជោគជ័យនានារបស់កុមារី និងថែមទាំងអញ្ជើញកុមារីឱ្យចូលរួមក្នុងព្រឹត្តិការណ៍នានា ដើម្បីនិយាយអំពីសិទ្ធិ និងសុវត្ថិភាពរបស់កុមារី និងក្នុងករណីខ្លះ គេបានផ្តល់ជំនួយហិរញ្ញវត្ថុសម្រាប់គម្រោងការងារ ថ្លៃក្រោយទៀតផង។

អត្ថបទរបស់: Irada Gautam, Sulochana Pokharel, Jasmine Rajbhandary;
Funded by: Save the Children (UK). 28 January 2002; Accessible through
http://www.id21.org

សញ្ញាដែលត្រូវភ័យព្រួយសម្រាប់កុមារដែលទទួលរងការធ្វើបាប

ជួនកាលទាំងកុមារា និងកុមារីមិននិយាយច្រាប់យើងថា ពួកគេជាជនរងគ្រោះក្នុងអំពើហិង្សាទេ ឬ ថាពួកគេកំពុងមានវិបត្តិនោះទេ។ តែអាកប្បកិរិយា និងឥរិយាបថរបស់គេ បង្ហាញច្រាប់យើង។ ទោះបីជាការប្រែប្រួលអាកប្បកិរិយា អាចមានហេតុផលច្រើនក៏ដោយ ក៏ជួនកាល បណ្តាលមកពីពួកគេមានភាពតានតឹងក្នុងចិត្ត ដែលបណ្តាលមកពីការទទួលរងការធ្វើបាបទាំងផ្លូវចិត្ត និងផ្លូវកាយ។ គ្រូដែលជាអ្នកចាប់ដឹងហេតុការណ៍អំពីការប្រែប្រួលបែបនេះ អាចធ្វើអន្តរាគមន៍ដោយមិនឱ្យកុមារទាំងនោះដឹងខ្លួនឡើយ។ ខាងក្រោមនេះ ជាតារាងអត្តចរិតដែលបង្ហាញថា កុមារកំពុងទទួលរងការធ្វើបាប[7]។ ប៉ុន្តែត្រូវចងចាំថា សញ្ញាណខ្លះ ជាសញ្ញាណធម្មតាសម្រាប់កុមារមួយចំនួនក្នុងពេលខ្លះ។ ដូចនេះ ជាការចាំបាច់ណាស់ យើងត្រូវយកចិត្តទុកដាក់ចំពោះអាកប្បកិរិយាធម្មតារបស់កុមារ ដើម្បីឱ្យយើងដឹងថា អាកប្បកិរិយាមួយណាធម្មតា និងអាកប្បកិរិយាមួយណាមិនធម្មតា។ ប្រសិនបើឪពុកម្តាយអង្កេតឃើញសញ្ញាណមិនធម្មតារបស់កុមារ ឪពុកម្តាយត្រូវផ្តល់ការពិគ្រោះយោបល់ ឬវិធានការសមស្របផ្សេងទៀត (សេវាផ្លូវច្បាប់ និងសង្គមកិច្ច។ល។)។

វិធីសម្គាល់កុមារដែលទទួលរងការធ្វើបាប (ទាំងផ្លូវកាយ និងផ្លូវចិត្ត)

កុមារដែលទទួលរងការធ្វើបាបតែងតែ

- ភ័យខ្លាចអ្នកដទៃ ឬតែងយល់ស្របនឹងអ្នកដទៃដោយគ្មានការតវ៉ា
- ផ្តាច់ខ្លួនចេញពីគេ ធាប់ខឹង សកម្មការងារខុសពីប្រក្រតី
- មូរម៉ៅជាប់ជានិច្ច គ្មានកម្លាំងកំហែង កណ្តោចកណ្តែងម្នាក់ឯង
- គ្មានការស្រលាញ់ ឬស្រលាញ់ហួសហេតុ

សញ្ញាណរាងកាយ

- ជាំ រលាក សំលាក បាក់ឆ្អឹង របួសដោយគ្មានហេតុផល
- ជំងឺកាមរោគ
- ឈឺអវយវៈភេទ ឈាម ឬក្រហាយ

សញ្ញាណស្តែងចេញតាមសកម្មភាព ឬទម្លាប់

- រកើរវាយ
- ខ្លាចមិនហ៊ានចូលផ្ទះ ឬធ្វើដំណើរទៅកន្លែងផ្សេង
- ខ្លាចមិនហ៊ាននៅជាមួយអ្នកដទៃ
- រត់ចេញពីផ្ទះ
- អាកប្បកិរិយាគ្មានសីលធម៌
- ដេកសំដិលល្ងិតល្ងៃ

---

7 Source: National Center for Assault Prevention (NCAP). Education, Information and Resource Center, Sewell, New Jersey, 2000. http://www.ncap.org/identify.htm. NCAP also has an international division with some materials translated in Spanish, French, Vietnamese, Cantonese, Romanian, Russian and Japanese. Learn more about this at: http://www.ncap.org/cap_international.htm.

អាកប្បកិរិយាខុសប្លែកពីអាយុ

- បៀមដៃ
- ការយល់ដឹង ឬសកម្មភាពផ្លូវភេទ
- អាកប្បកិរិយាគិតភ័យខ្លាចមានការចាប់រំលោក
- នោមពេលកំពុងដេក
- ការសេពគ្រឿងស្រវឹង និងសារធាតុផ្សេងទៀត
- ជេរបញ្ឆោរក្មេងអាយុតិចជាង
- ទទួលខុសត្រូវធ្វើការងារដូចមនុស្សធំ

ការព្រួយចារម្តពីការអប់រំ

- មានការចង់ចេះចង់ដឹង ឬស្រមើស្រមៃហួសហេតុ
- បរាជ័យក្នុងការសិក្សា
- ដេកនៅពេលកំពុងរៀនក្នុងថ្នាក់
- មិនអាចផ្តោតអារម្មណ៍លើការសិក្សា

សូចនាករអារម្មណ៍

- ការកើតទុក្ខ
- ខ្លាច ខ្លាចទីកន្លែងងងឹត ខ្លាចបន្ទប់ទឹករួម
- ជំងឺប្រចាំកាយ
- បង្កគ្រោះថ្នាក់លើខ្លួនឯង
- ចូលចិត្តបង្កគ្រោះថ្នាក់ដល់សត្វ និងសម្លាប់សត្វ
- ធាប់គិតភ័យហួសហេតុពេក
- ការខ្វះសមត្ថភាពឆ្លើយតបវិញភ្លាម។ ឬខ្វះការច្នៃប្រឌិត

សញ្ញាណបង្ហាញថា កុមារកំពុងមានគ្រោះថ្នាក់

កុមារមួយចំនួនរស់ក្នុងស្ថានភាពមានគ្រោះថ្នាក់ ក្នុងគ្រួសារ សហគមន៍ និងសាលា។ ទោះបីជាពួកគេមិនទទួលរងការធ្វើបាបដោយផ្ទាល់ ពួកគេក៏ត្រូវការនូវការការពារ និងការយកចិត្តទុកដាក់ពីសំណាក់មនុស្សនៅជុំវិញខ្លួនដែរ។ កាលៈទេសៈ និងអាកប្បកិរិយាខុសប្លែកពីធម្មតា អាចឱ្យឪពុកម្តាយកត់សម្គាល់ថាកុមារកំពុងតែមានគ្រោះថ្នាក់។ ពិសេសជាងនេះទៀត ការប្រើប្រាស់ឧបករណ៍ផ្សេងទៀត ដូចជា ឯកសារប្រវត្តិកុមារ និងឯកសារកត់ត្រាអាកប្បកិរិយាកុមារ ក៏អាចមានប្រយោជន៍សម្រាប់តាមដានដែរ។ ខាងក្រោមនេះជាអត្ថបទមួយចំនួនដែលបង្ហាញថា កុមារកំពុងមានគ្រោះថ្នាក់ និងវិធីសាស្ត្រដែល ជួយកុមារ[8]។

---

8 Source: Education Queensland. Identifying At Risk Students.
http://education.qld.gov.au/health-safety/promotion/drug-education/html/m_risk.html

របៀបសម្គាល់កុមារមានគ្រោះថ្នាក់ និងវិធីដែលត្រូវជួយ

កុមារអាចមានគ្រោះថ្នាក់ ប្រសិនបើកត្តាមួយ ឬរួមគ្នាកើតមានចំពោះកុមារ :

- គ្រួសារដែលមានដំណើរការមិនល្អ
- ឪពុកម្តាយដែលប្រើប្រាស់គ្រឿងញៀន ឬមានជំងឺសរសៃប្រសាទ
- ការធ្វើប្រើយកន្តើយ
- អាកប្បកិរិយាច្រលោត និងមិនសមរម្យនៅក្នុងថ្នាក់រៀន
- ការសិក្សាមិនបានទៀងទាត់ ឬលទ្ធផលមិនល្អ
- ការខ្វះជំនាញសង្គម
- មិត្តភក្តិដែលប្រើគ្រឿងញៀន ឬប្រព្រឹត្តអំពើដែលមានគ្រោះថ្នាក់
- មានស្ថានភាពសេដ្ឋកិច្ចទាប
- ធ្លាប់ប្រើគ្រឿងញៀនកាលពីនៅក្មេង
- អាកប្បកិរិយាដែលងាយរងនូវការប្រើគ្រឿងញៀន និងបារី

សញ្ញាណ ឬរោគសញ្ញាខាងក្រោមបង្ហាញថាកុមារកំពុងប្រើប្រាស់គ្រឿងញៀន :

- ការកែប្រែអត្តចរិតខ្លាំង អារម្មណ៍ធីងធោង
- ប្រែប្រួលរាងកាយ ដូចជាកម្ពស់ ស្រកទម្ងន់ ឬកើនទម្ងន់ និយាយមិនច្បាស់ ដំណើរទ្រេតទ្រោត សរសេរកិច្ចការវែងអន្លាយតែគ្មានន័យច្បាស់លាស់ បែកញើសខុសធម្មតា និយាយច្រើនឥតប្រយោជន៍ ស្រលាញ់ជ្រុល ស្អប់ជ្រុល និងរកកលចង់ក្លែត។
- លទ្ធផលសិក្សាប្រែប្រួលខុសពីធម្មតា
- ត្រូវការច្រាក់ខុសពីធម្មតា
- ទៅណាមកណាតែងមានគេតាមការពារ

កត្តាវិជ្ជមានទាំងនេះអាចជួយសម្រាលឥទ្ធិពលគ្រោះថ្នាក់

- ទំនាក់ទំនងគ្រួសារជិតស្និទ្ធ ការយកចិត្តទុកដាក់របស់គ្រួសារលើជីវិតរបស់កុមារ
- ជោគជ័យនៅក្នុងការសិក្សា
- ជំនាញសង្គមច្បាស់លាស់
- ចូលរួមនៅក្នុងសកម្មភាពនានានៅក្នុងសហគមន៍
- មានទំនាក់ទំនងកក់ក្តៅជាមួយមនុស្សចាស់យ៉ាងហោចណាស់ក៏ម្នាក់ដែរ ដូចជាគ្រូជាដើម

សាលាអាចជួយសម្រាលឥទ្ធិពលគ្រោះថ្នាក់ដោយធ្វើដូចខាងក្រោម :

- លើកកម្ពស់ទំនាក់ទំនងសុវត្ថិភាព និងទំនុកបម្រុង
- ធានាឱ្យមានការចូលរៀនទៀងទាត់
- អភិវឌ្ឍជំនាញសង្គម និងជំនាញបុគ្គល
- លើកកម្ពស់ជំនាញសិក្សា
- កសាងបណ្តាញគាំទ្រសង្គម
- លើកកម្ពស់គុណធម៌វិជ្ជមាន
- បង្រៀនពីរបៀបរកព័ត៌មាន
- បង្រៀនវិធីសាស្ត្រផ្តាច់គ្រឿងញៀន និងជៀសវាងអាកប្បកិរិយាមានគ្រោះថ្នាក់
- ជួយសម្រួលឱ្យទទួលបានការពិគ្រោះយោបល់

វិធីទប់ស្កាត់កុំឱ្យមានអំពើហិង្សាក្នុងចំណោមកូនចៅរបស់យើង

អ្នកអាចចាត់វិធានការដូចខាងក្រោមនេះដើម្បីទប់ស្កាត់អំពើហិង្សានៅក្នុងសាលា[9]។

១. ដាក់ទិន្នន័យតឹងរឹងលើអាកប្បកិរិយាហិង្សាឱ្យទៀងទាត់ និងស្ថិតស្ថេរ។

២. បង្រៀនក្មេងៗនូវអាកប្បកិរិយាដែលមានសុខភាព និងអហិង្សា។

៣. **រៀន និងប្រើប្រាស់គំរូអហិង្សានៃការដាក់ពិន័យដល់សិស្ស និងការកែប្រែសិស្សឱ្យបានស្ថិតស្ថេរ នៅពេលដែលសិស្សប្រព្រឹត្តខុស (ការដាក់ទណ្ឌកម្មរាងកាយបង្រៀនកុមារថាអំពើហិង្សាជាអំពើមួយដែលគេអាចត្រូតបាន)។ (អានកម្រងសៀវភៅលេខ៥ ដើម្បីប្រើប្រាស់វិន័យវិជ្ជមានទាំងនេះ)។**

៤. ធ្វើខ្លួនជាមនុស្សគំរូល្អក្នុងការដោះស្រាយជម្លោះដោយអហិង្សា។

៥. បង្កើតទំនាក់ទំនងល្អក្នុងការនិយាយស្តីជាមួយកូនចៅរបស់អ្នក (ដូចជាការស្តាប់កូនចៅនិយាយដោយយកចិត្តទុកដាក់)។

៦. តាមដានការចូលរួមរបស់កុមារនៅក្នុងប្រព័ន្ធផ្សព្វផ្សាយ សាលា ក្រុមបក្សពួកគេ និងអង្គការសហគមន៍។

៧. បង្ហាញពីក្តីសង្ឃឹមច្រាប់កូនចៅទាំងអស់របស់គេ។

៨. លើកទឹកចិត្ត និងលើកសរសើរកូនដែលបានជួយដោះស្រាយបញ្ហាអ្នកដទៃដោយអហិង្សា។

៩. កត់សម្គាល់បញ្ហាគ្រឿងញៀន គ្រឿងស្រវឹង និងសារធាតុផ្សេងទៀត ដែលងាយនាំឱ្យមានអំពើហិង្សា

១០. បង្រៀនយន្តការសមស្របដើម្បីដោះស្រាយការមានវិបត្តិ។

១១. សុំជំនួយពីអ្នកមានមុខរបរជាអាជីព (មុនពេលបញ្ហារាហួសពេលដោះស្រាយ)។

១២. ដឹកនាំការប្រឹងប្រែងរបស់សហគមន៍ដើម្បីធ្វើការវិភាគអំពីអំពើហិង្សានៅក្នុងសាលា និងនៅក្នុងសហគមន៍ (ដូចជាតាមរយៈការធ្វើលំហាត់ប្រមូលព័ត៌មានដែនទីសហគមន៍) អភិវឌ្ឍ សម្របសម្រួល អនុវត្តឱ្យមានប្រសិទ្ធភាពនូវសេវាគាំទ្រសាលា–សហគមន៍។

១៣. ផ្តល់ឱកាសដល់កុមារដើម្បីអនុវត្តជំនាញជីវិត ជាពិសេសវិធីសាស្ត្រដោះស្រាយបញ្ហាដោយអហិង្សា។

---

9 Adapted from: World Health Organization (1998) WHO Information Series on School Health, Document Three - Violence Prevention: An Important Element of a Health-Promoting School. Geneva.



គោល ៦.២
បណ្តុះបណ្តាលបំណិនជីវិតដល់កុមារ

ការអប់រំជំនាញសុខភាពបឋម

កុមារទាំងអស់ ជាពិសេសកុមារដែលមានជីវប្រវត្តិ និងសមត្ថភាពខុសគេ ត្រូវការជំនាញ ដើម្បីប្រើប្រាស់ចំណេះដឹងអំពីសុខភាព ដើម្បីអនុវត្តទម្លាប់ដែលមានសុខភាព និងជៀសវាងទម្លាប់គ្រោះថ្នាក់ដល់សុខភាព។ វិធីមួយដើម្បីផ្សព្វផ្សាយចំណេះដឹងនេះ គឺតាមរយៈ"ការអប់រំចំណេះដឹងសុខភាពបឋម"។

សាលាភាគច្រើនមានបង្រៀនមេរៀនអប់រំសុខភាព ប៉ុន្តែរបៀបបង្រៀនជំនាញអប់រំសុខភាពបឋមខុសពីការអប់រំសុខភាពទូទៅ[10]។

- *ការអប់រំជំនាញសុខភាពបឋមយកចិត្តទុកដាក់លើការកែប្រែអាកប្បកិរិយាសុខភាព ចំណេះដឹង ឥរិយាបថ និងបំណិន។ ការបង្រៀនបែបនេះជួយកុមារឱ្យជ្រើសរើស និងអនុវត្តអាកប្បកិរិយាប្រកបដោយសុខភាព (មិនមែនរៀនតែទ្រឹស្តី)។*
- *កម្មវិធីអប់រំជំនាញសុខភាពបឋមត្រូវបានគេរៀបចំឡើងដោយគិតទៅដល់ **តម្រូវការ និងសិទ្ធិកុមារជាមុន** ធ្វើបែបនេះទើបកម្មវិធីអប់រំនេះមានសារប្រយោជន៍ដល់ជីវិតប្រចាំថ្ងៃរបស់កុមារ។*
- *សេវាសុខភាពបឋមមាន**តុល្យភាព**កម្មវិធីសិក្សាលើ (១) ចំណេះដឹង និងព័ត៌មាន (២) ឥរិយាបថ និងគុណធម៌ និង (៣)បំណិនជីវិត។ គោលបំណងគឺ**ការប្រែក្លាយចំណេះដឹងឱ្យទៅជាសកម្មអនុវត្តភ្លាមៗ**។*
- *ជាជាងអ្នកទទួលព័ត៌មានអសកម្ម កុមារចូលរួមយ៉ាងសកម្មក្នុងការសិក្សា តាមរយៈវិធីសាស្ត្រៀន និងបង្រៀនដែលមានការចូលរួម។*
- *កម្មវិធីទាំងនេះឆ្លើយតបទៅនឹង**តម្រូវការយេនឌ័រ** មានន័យថា កម្មវិធីនេះ ដោះស្រាយតម្រូវការ និងការលំបាករបស់កុមារា និងកុមារីផង។*

ក្នុងជំនាញអប់រំសុខភាពបឋម កុមារចូលរួម ដោយរួមបញ្ចូលបទពិសោធន៍រៀនសូត្រ ដើម្បីអភិវឌ្ឍចំណេះដឹង ឥរិយាបថ និងបំណិនជីវិត។ ជំនាញទាំងនេះ ជួយកុមារឱ្យសម្រេចចិត្តត្រឹមត្រូវ និងចាត់វិធានការវិជ្ជមានដើម្បីរក្សាខ្លួនឱ្យមានសុខភាពល្អ និងមានសុវត្ថិភាព។ ជំនាញទាំងនេះ អាចជាបំណិនជាក់ស្តែង ជំនាញ

10 This section was originally developed from:
www.unicef.org/programme/lifeskills/whatwhy/distinguish.html

"ធ្វើ" ដូចជា ចេះជួយសង្គ្រោះបន្ទាន់។ ជំនាញទាំងនេះអាចជាវិធីនៃការគិតគូរ ដូចជារបៀបដោះស្រាយបញ្ហា ឬវិធីទំនាក់ទំនងគ្នា ដែលអាចជួយកុមារឱ្យមានទំនាក់ទំនងល្អជាមួយអ្នកដទៃទៀត ជាពិសេស កុមារដែលមានប្រវត្តិ និងសមត្ថភាពខុសគេ។

ជំនាញទាំងនេះហៅថា "បំណិនជីវិត" ព្រោះជំនាញទាំងនេះមានសារៈសំខាន់សម្រាប់ជីវិតសុខសប្បាយ និងវិកវាយ។ ការបង្រៀនជំនាញទាំងនេះត្រូវបានគេហៅថា "ការអប់រំបំណិនជីវិតមូលដ្ឋាន" ពាក្យដែលគេប្រើផ្គាស់ប្តូរជាមួយនឹងពាក្យ "ការអប់រំជំនាញសុខភាពបឋម"។ ភាពខុសគ្នានៃជំនាញទាំងពីរ ថិតត្រង់ខ្លឹមសារ និងប្រធានបទដែលត្រូវយកមកបង្រៀន។ មិនមែនប្រធានបទទាំងអស់សុទ្ធតែទាក់ទងនឹងបញ្ហាសុខភាពនោះទេ។ ឧទាហរណ៍ អក្ខរកម្ម និងឥន្ធនៈបំណិនជីវិត ការអប់រំជំនាញសន្តិភាព[11]។

ពាក្យ "បំណិនជីវិត" និយាយដល់ជំនាញប្រទាក់ក្រឡាគ្នាមួយក្រុម ទាំងផ្នែកចិត្តសាស្ត្រ សង្គម និងបុគ្គលិកលក្ខណៈមនុស្ស ដែលអាចជួយកុមារសម្រេចចិត្តបានត្រឹមត្រូវ ទំនាក់ទំនងគ្នាមានប្រសិទ្ធភាព និងអភិវឌ្ឍជំនាញគ្រប់គ្រងខ្លួនឯង ដែលអាចជួយកុមារឱ្យដឹកនាំជីវិតប្រកបដោយសុខភាពល្អ និងការរីកចម្រើន។ បំណិនជីវិត អាចមានគោលបំណងអភិវឌ្ឍសកម្មភាពបុគ្គល សកម្មភាពចំពោះអ្នកដទៃ និងសកម្មភាពផ្គាស់ប្តូរបរិយាកាសជុំវិញខ្លួនដើម្បីឱ្យមានសុខភាពល្អ។

បំណិនជីវិតមានទំនាក់ទំនងទៅនឹងការអភិវឌ្ឍវិយោបថល្អ។ ឧទាហរណ៍ បំណិនជីវិតមួយដែលកុមារគ្រប់រូបគួររៀនគឺជំនាញក្នុងការស្តាប់អ្នកដទៃនិយាយ។ នៅពេលអ្នកស្តាប់គេនិយាយ អ្នកបង្ហាញនូវការគោរពដល់អ្នកនិយាយ។ ធ្វើបែបនេះបង្ហាញថា អ្នកមានវិយោបថល្អ។ វិយោបថ ៤ ប្រការក្នុងចំណោមវិយោបថសំខាន់ៗ ដែលត្រូវអភិវឌ្ឍ តាមរយៈការអប់រំជំនាញសុខភាពអប់រំបឋម មានដូចខាងក្រោមនេះ[12]។

១. គោរពខ្លួនឯង ដូចជា ខ្ញុំចង់ស្អាត ចង់ល្អ ចង់បានសុខភាពល្អ និងកាយសម្បទាមាំមួន។

២. ផ្តល់កិត្តិយស និងទំនុកចិត្តដល់ខ្លួនឯង ដូចជា ខ្ញុំដឹងថា ខ្ញុំអាចផ្គាស់ប្តូរទម្លាប់ក្នុងគ្រួសារខ្ញុំ ទោះបីជាខ្ញុំនៅក្មេងក៏ដោយ។

៣. គោរពអ្នកដទៃ ដូចជា ខ្ញុំត្រូវស្តាប់ការនិយាយគ្នា ដើម្បីបង្ហាញពីការគោរពដល់អ្នកនិយាយ និងគោរពទំនៀមទម្លាប់របស់អ្នកនិយាយ ទោះបីជាអ្នកនិយាយខុសពីខ្ញុំ ឬខ្ញុំមិនយល់ស្របក៏ដោយ។

៤. ចេះខ្វល់អំពីអ្នកដទៃ ដូចជា ខ្ញុំត្រូវប្រឹងឱ្យអស់សមត្ថភាព ដើម្បីជួយអ្នកដទៃឱ្យមានសុខភាពល្អជាងមុន ជាពិសេសអ្នកដែលត្រូវការជំនួយ។

---

11 This section was originally developed from: http://unicef.org/programme/lifeskills/whatwhy/define.html

12 Son V, Pridmore P, Nga B, My D and Kick P (2002) Renovating the Teaching of Health in Multigrade Primary Schools: A Teacher's Guide to Health in Natural and Social Sciences (Grades 1,2,3) and Science (Grade 5). British Council /National Institute of Educational Sciences: Hanoi, Vietnam.

ការអភិវឌ្ឍវិជ្ជាបថដែលជំរុញឱ្យមានសមភាពយេនឌ័រ និងការគោរពគ្នាទៅវិញទៅមក រវាងក្មេបប្រុស និងក្មេងស្រី និងការអភិវឌ្ឍជំនាញជាក់លាក់ ដូចជា ដោះស្រាយការគាបសង្កត់ពីមិត្តភក្តិ មានសារៈសំខាន់ណាស់ សម្រាប់អប់រំជំនាញសុខភាពបឋម។ នៅពេលកុមារមានចំណេះដឹងអំពីជំនាញទាំងនេះ កុមារងាយនឹងទទួលយកទម្លាប់ដែលមានសុខភាពល្អ ទាំងពេលនៅរៀន និងពេលក្រោយទៀតនៃជីវិត។



សកម្មភាពឆ្លុះបញ្ចាំង : បំណិនជីវិត និងខ្លួនអ្នក

ការបណ្តុះបណ្តាលជំនាញដល់កុមារ ទាមទារឱ្យយើង ដែលជាមនុស្សពេញវ័យធ្វើជាគំរូ បង្កើត និងប្រើប្រាស់ជំនាញទាំងនេះក្នុងជីវិតរបស់យើង។ សម្រាប់សកម្មភាពនេះ សូរខ្លួនឯងថា "តើខ្ញុំបង្ហាញការគោរពខ្លួនឯង ផ្តល់កិត្តិយស និងទំនុកចិត្តលើខ្លួនឯង គោរពអ្នកដទៃ និង ព្រួយបារម្ភអំពីអ្នកដទៃ ដោយរបៀបណា?" ចូរបំពេញតារាងខាងក្រោម ហើយកត់សម្គាល់សកម្មភាពអ្វីដែលអ្នកអាចធ្វើបាន ដើម្បីធ្វើឱ្យមានអាកប្បកិរិយាល្អសម្រាប់ខ្លួនអ្នក និងដើម្បីជាប្រយោជន៍សម្រាប់សិស្ស។ ចូរសាកល្បងអាកប្បកិរិយាទាំងនេះ ក្នុងរយៈពេល២សប្តាហ៍។ តើអ្នកឃើញមានអារម្មណ៍ប្លែកឬទេ? តើអ្នកឃើញអ្នកដទៃ ធ្វើអំពើមកលើអ្នកដោយរបៀបណា?

	អ្វីដែលខ្ញុំកំពុងធ្វើ	**អ្វីដែលខ្ញុំអាចធ្វើបាន** *(អាកប្បកិរិយាថ្មី)*
ការគោរពខ្លួនឯង *(របៀបកែលំអខ្លួន)*		
ការផ្តល់កិត្តិយស និង ទំនុកចិត្តលើខ្លួនឯង *(របៀបដែលខ្ញុំបង្ហាញថា ខ្ញុំគឺជាមនុស្សមានប្រយោជន៍)*		
ការគោរពចំពោះអ្នកដទៃ *(របៀបដែលខ្ញុំបង្ហាញការសរសើរដល់អ្នកដទៃ ឬក្រែងចិត្តអ្នកដទៃ)*		
ព្រួយបារម្ភអំពីអ្នកដទៃ *(របៀបដែលខ្ញុំជួយអ្នកដទៃលើកកម្ពស់ខ្លួនគេ)*		

បន្ទាប់ពីអ្នកសាកល្បងសកម្មភាពនេះរួចហើយ សូមកុំភ្លេចសាកល្បងជាមួយសិស្សរបស់អ្នកផង។ ឱ្យសិស្សម្នាក់ៗបំពេញតារាង ហើយសម្រេចពីវិធីដែលត្រូវកែលំអអាកប្បកិរិយារបស់គេទាក់ទងនឹងការគោរពខ្លួនឯង ការផ្តល់កិត្តិយស និងទំនុកចិត្តលើខ្លួនឯង ការគោរពអ្នកដទៃ និងការព្រួយបារម្ភអ្នកដទៃ។ សកម្មភាពទាំងនេះអាចដាក់បញ្ចូលក្នុងកម្មវិធីអប់រំជំនាញសុខភាពបឋម និងកម្មវិធីអប់រំបំណិនជីវិត។

តើជំនាញ និងបំណិនអ្វីដែលកុមារត្រូវការ?

ជំនាញទំនាក់ទំនង និងរវាងបុគ្គល	ជំនាញសម្រេចចិត្ត និងត្រិះរិះពិចារណាឬត់ចត់	ជំនាញដោះស្រាយបញ្ហា និងគ្រប់គ្រងខ្លួន
ជំនាញទំនាក់ទំនង និងរវាងបុគ្គល • ទំនាក់ទំនងដោយប្រើ និង មិនប្រើពាក្យសំដី • ស្តាប់ដោយយកចិត្តទុកដាក់ • បង្ហាញអារម្មណ៍ ផ្តល់យោបល់ (មិនបន្ទោស) ទទួលយោបល់ **ជំនាញចរចា/បដិសេធ** • ចរចា និងដោះស្រាយទំនាស់ • ជំនាញអំណះអំណាងការពារ • ជំនាញបដិសេធ **ការអាណិតអាសូរ** • សមត្ថភាពក្នុងការស្តាប់ និងយល់ដឹងតម្រូវការ និងកាលៈទេសៈរបស់អ្នកដទៃ និងបង្ហាញឱ្យឃើញនូវការយល់ដឹងរបស់យើង **ការសហការ និងការធ្វើការងារជាក្រុម** • បង្ហាញការគោរពចំពោះការរួមចំណែក វិធីសាស្ត្រ ផ្សេងគ្នារបស់អ្នកដទៃ • វាយតម្លៃសមត្ថភាពខ្លួនឯង និងចូលរួមចំណែកដល់ក្រុម **ជំនាញតស៊ូមតិ** • ជំនាញបង្ហាញពីឥទ្ធិពលលើអ្នកដទៃ • ជំនាញបញ្ចុះបញ្ចូល • ជំនាញទំនាក់ទំនងបណ្តាញ និងចេះលើកទឹកចិត្ត	**ជំនាញសម្រេចចិត្ត និងដោះស្រាយបញ្ហា** • ជំនាញប្រមូលព័ត៌មាន • វាយតម្លៃលទ្ធផលអនាគតខ្លួនឯង និងអ្នក ដទៃ ដោយផ្អែកលើសកម្មភាពបច្ចុប្បន្ន • កំណត់ជម្រើសដំណោះស្រាយចំពោះបញ្ហា • ជំនាញវិភាគទាក់ទងនឹងឥទ្ធិពលនៃតម្លៃ និងឥរិយាបថរបស់ខ្លួន និងរបស់អ្នកដទៃ **ជំនាញគិតគូរពិចារណា** • វិភាគឥទ្ធិពលមិត្តភក្តិ និងបណ្តាញផ្សព្វផ្សាយ • វិភាគឥរិយាបថ តម្លៃ ទម្លាប់សង្គម និងជំនឿ • កត់សម្គាល់ព័ត៌មាន មានសារៈសំខាន់ និងប្រភពព័ត៌មាន	**ជំនាញបង្កើនកម្លាំងចិត្តខ្លួនឯង** • ជំនាញផ្តល់កិត្តិយស និងទំនុកចិត្តលើខ្លួនឯង • ជំនាញស្គាល់ខ្លួនឯង រួមបញ្ចូលការស្គាល់សិទ្ធិ ឥទ្ធិពល តម្លៃ ឥរិយាបថ សិទ្ធិ ចំណុចខ្លាំង ចំណុចខ្សោយ • ជំនាញកំណត់គោលដៅ • ជំនាញវាយតម្លៃខ្លួនឯង និងជំនាញត្រួតពិនិត្យខ្លួនឯង **ជំនាញគ្រប់គ្រងចិត្ត និងអារម្មណ៍** • ការគ្រប់គ្រងកំហឹងដើម្បីទប់ទល់ នឹងទុក្ខព្រួយ និងអន្ទះសា • ជំនាញទប់ទល់សម្រាប់ដោះស្រាយ ការបាត់បង់ ការធ្វើបាប និងវិបត្តិនានា **ជំនាញសម្រាប់ទប់ទល់ភាពតានតឹងក្នុងចិត្ត** • ការគ្រប់គ្រងពេលវេលា • គំនិតវិជ្ជមាន • ជំនាញក្នុងការសម្រាក និងសម្រាលអារម្មណ៍

ជំនាញ និងបំណិនជីវិតពុំមានកំណត់ត្រឹមណានោះទេ។ តារាងខាងក្រោមកត់ត្រានូវជំនាញ និងបំណិនដែលបានគិត និងស្គាល់ជាទូទៅថា មានសារៈសំខាន់[13]។ តើត្រូវជ្រើសរើសជំនាញមួយណា អាស្រ័យលើប្រធានបទ ស្ថានភាពសាលា ឬសហគមន៍ និងពិសេសជាងគេគឺតម្រូវការរបស់សិស្ស។ ទោះបីជាប្រភេទនៃជំនាញត្រូវបានបំបែកចេញពីគ្នាក៏ដោយ ការពិតជំនាញទាំងនេះអាចជាន់គ្នាទៅវិញទៅមក។ ឧទាហរណ៍ ជាញឹកញាប់ ការធ្វើសេចក្តីសម្រេច ទាក់ទងនឹងការគិតគូរដោយគំនិតច្នៃប្រឌិត និងស៊ីជំរៅ (តើខ្ញុំមានជម្រើសអ្វីខ្លះ) និងការបញ្ជាក់ពីអត្តប្រយោជន៍ (អ្វីដែលមានសារៈសំខាន់សម្រាប់ខ្ញុំ)។ ជាចុងក្រោយ នៅពេលជំនាញទាំងអស់រួមបញ្ចូលគ្នា ការកែប្រែអាកប្បកិរិយាធំៗនឹង កើតឡើង ជាពិសេសនៅពេលមានយុទ្ធសាស្ត្រផ្សេង។ ជួយគាំទ្រ ដូចជា គោលនយោបាយសុខភាព និងសេវាព័ត៌មានរបស់សាលា។

ក្នុងគោលខាងដើម យើងស្វែងរកគំនិត ដែលជួយអ្នកឱ្យរៀបចំគោលនយោបាយសាលាឱ្យកាន់តែមានប្រសិទ្ធភាព ដូចជា ការបង្ការអំពើហិង្សា និងការធ្វើទុក្ខបុកម្នេញ ការលើកកម្ពស់គុណភាពទឹកស្អាត និងអនាម័យទូទៅ និងលើកកម្ពស់សុខភាពសហគមន៍។ ផ្នែកសំខាន់មួយនៃការអនុវត្ត និងតាមដាន ត្រួតពិនិត្យគោលនយោបាយ គឺដើម្បីបណ្តុះកុមារនូវចំណេះដឹង ឥរិយាបថ និងជំនាញដើម្បីចាប់យកអាកប្បកិរិយាដែលមានសុខភាពល្អ និងមានសុវត្ថិភាព។

ប្រើប្រាស់ព័ត៌មានដែលបានមកពីការវិភាគគោលនយោបាយក្នុងគោលខាងដើម សហការជាមួយសហការីរបស់អ្នក ដើម្បីកំណត់ជំនាញថា តើជំនាញមួយណាក្នុងតារាង មានសារៈសំខាន់ជាងគេសម្រាប់សិស្ស។ បន្ទាប់មកវិះរកវិធី ដើម្បីបញ្ចូលជំនាញទាំងនេះទៅក្នុងមុខវិជ្ជា ដែលអ្នកបង្រៀន។ គំនិតដែលបានមកពីឯកសារស្តីពីមេរោគអេដស៍/ជំងឺអេដស៍ ដែលមាននៅផ្នែកខាងក្រោយនៃឯកសារនេះ អាចជួយអ្នកបាន។ សូមកុំភ្លេចថា កុមារអាចជួយអ្នកបានយ៉ាងច្រើនក្នុងដំណើរការនេះ។

តើកុមារអាចយកជំនាញទាំងអស់នេះទៅប្រើដោយរបៀបណា?

នៅពេលកុមារមានចំណេះដឹងលើជំនាញដែលយើងបានបង្រៀនដូចក្នុងតារាងខាងលើ កុមារអាចដោះស្រាយបញ្ហាជាច្រើនក្នុងការរស់នៅ ដែលបញ្ហាទាំងនោះប៉ះពាល់ដល់សុខភាពរបស់កុមារផ្ទាល់ និងរបស់អ្នករស់នៅជុំវិញ ។ ខាងក្រោម ជាវិធីសាស្ត្រមួយចំនួនដែលការអប់រំជំនាញសុខភាពបឋម អាចប្រើក្នុងសាលារបស់អ្នក ដើម្បីទប់ស្កាត់បញ្ហាសុខភាពចម្បង។[14]។ ពិភាក្សាជាមួយសហការី ដោយរកហេតុផលថាតើបញ្ហាទាំងនេះប៉ះពាល់ដល់សិស្សរបស់អ្នកឬអត់ ហើយថា តើជំនាញដែលបានកត់ត្រា ក្នុងតារាងខាងដើមគួរតែយកមកបញ្ចូលក្នុងកម្មវិធីសិក្សារបស់អ្នកឬមិនយក។ ប្រសិនបើយកសកម្មភាពដែលមានរាយក្នុងតារាង បន្ទាប់ពីផ្នែកមេរោគអេដស៍/ជំងឺអេដស៍ អាចយកមកកែច្នៃដើម្បីដោះស្រាយបញ្ហាទាំងអស់នេះបាន។

---

13 This section was originally developed from:
www.unicef.org/programme/lifeskills/whatwhy/skills.html

14 This section was originally developed from:
www.unicef.org/programme/lifeskills/whatwhy/skills.html

ការទប់ស្កាត់មិនឱ្យមានការប្រើប្រាស់សារធាតុញៀន

ការបង្ខំឱ្យប្រើប្រាស់សារធាតុញៀនមានន័យថា ការប្រើប្រាស់គ្រឿងញៀនហួសកំណត់។ គ្រឿងញៀនមានដូចជា ថ្នាំ បារី និងគ្រឿងស្រវឹង។ ដើម្បីកត់សម្គាល់សិស្សដែលទទួលរងផលប៉ះពាល់ដោយការប្រើគ្រឿងញៀន អ្នកត្រូវតាមអង្កេតអាកប្បកិរិយារបស់សិស្សឱ្យជិតដល់។ អ្នកក៏ត្រូវបង្កើតទំនាក់ទំនងល្អ ជាមួយសិស្ស និងគ្រួសារ ដើម្បីឱ្យឪពុកម្តាយទុកចិត្ត និងបញ្ជូនកូនមករៀន ហើយពិភាក្សា អំពីការបារម្ភរបស់កុមារ ជាមួយឪពុកម្តាយ។ គ្រូត្រូវប្រើជំនាញមួយ ឬច្រើនបញ្ចូលគ្នា ដើម្បីទប់ស្កាត់សិស្សកុំឱ្យប្រើប្រាស់គ្រឿងញៀន។

- តវ៉ាមិនឱ្យមានការគាបសង្កត់ពីមិត្តភក្តិដែលបង្ខំអ្នកឱ្យប្រើគ្រឿងញៀន (ជំនាញសម្រេចចិត្ត ជំនាញនិយាយទំនាក់ទំនង ជំនាញទប់ចិត្ត)
- តវ៉ាមិនឱ្យមានការគាបសង្កត់ពីមិត្តភក្តិដែលបង្ខំអ្នកឱ្យប្រើគ្រឿងញៀន តែមិនឱ្យបាត់បង់កត្តិយស និងមិត្តភក្តិ (ជំនាញសម្រេចចិត្ត ជំនាញទំនាក់ទំនងជាមួយអ្នកដទៃ និងជំនាញច្រាស្រៃយទាក់ទង)។
- កត់សម្គាល់កត្តាសង្គម ដែលអាចបណ្តាលឱ្យកុមារប្រើប្រាស់គ្រឿងញៀន ហើយសម្រេចចិត្តថាតើត្រូវដោះស្រាយមូលហេតុទាំងនោះដោយវិធីណា (ជំនាញវិភាគ គិតគូរ ជំនាញដោះស្រាយបញ្ហា ជំនាញសម្រេចចិត្ត)
- និយាយច្រាប់អ្នកដទៃអំពីគ្រោះថ្នាក់ និងហេតុផលផ្ទាល់ខ្លួនដែលធ្វើឱ្យអ្នកមិនប្រើប្រាស់គ្រឿងញៀន (ជំនាញនិយាយទំនាក់ទំនង ជំនាញស្គាល់ខ្លួនឯង និងជំនាញទំនាក់ទំនងជាមួយអ្នកដទៃ)
- ទទួចសុំឱ្យមានបរិយាកាសមួយដែលគ្មានផ្សែងបារី ថ្នាំ និងគ្រឿងស្រវឹង (ជំនាញច្រាស្រៃយទាក់ទង)
- រៀបចំ និងផ្សព្វផ្សាយខ្លឹមសារតស៊ូមតិតាមរូបភាពផ្សាយពាណិជ្ជកម្ម និងឯកសារយោសនាផ្សេងទៀត (ជំនាញវិភាគ គិតគូរ ជំនាញនិយាយចរចា ជំនាញស្គាល់ខ្លួនឯង)
- គាំទ្រអ្នកដែលព្យាយាមផ្តាច់ខ្លួនពីគ្រឿងញៀន (ជំនាញទំនាក់ទំនងជាមួយអ្នកដទៃ ជំនាញទប់ចិត្ត ជំនាញទប់ទល់ភាពតានតឹង ជំនាញដោះស្រាយបញ្ហា)
- ទប់ទល់ការប្រើប្រាស់គ្រឿងញៀនដោយឪពុកម្តាយ និងអ្នកដទៃ (ជំនាញទំនាក់ទំនងជាមួយអ្នកដទៃ ជំនាញទប់ចិត្ត ជំនាញទប់ទល់ភាពតានតឹងក្នុងអារម្មណ៍ ជំនាញដោះស្រាយបញ្ហា)

ការទប់ស្កាត់មិនឱ្យមានអំពើហិង្សា

ដើម្បីទប់ស្កាត់កុំឱ្យមានអំពើហិង្សា បំណិនជីវិតមួយ ឬច្រើនចូលគ្នាអាចជួយសិស្សឱ្យ :

- កត់សម្គាល់ និងប្រកាន់យកដំណោះស្រាយដោយសន្តិភាព សម្រាប់ដោះស្រាយជម្លោះ (ជំនាញដោះស្រាយបញ្ហា ជំនាញសម្រេចចិត្ត ជំនាញត្រិះរិះពិចារណា ជំនាញទប់ទល់នឹងភាពតានតឹង ជំនាញទប់ចិត្ត ជំនាញនិយាយទំនាក់ទំនង ជំនាញទំនាក់ទំនងជាមួយអ្នកដទៃ)
- កត់សម្គាល់ និងជៀសវាងស្ថានភាពគ្រោះថ្នាក់ (ជំនាញត្រិះរិះពិចារណា ជំនាញដោះស្រាយបញ្ហា ជំនាញសម្រេចចិត្ត)
- វាយតម្លៃយុទ្ធសាស្ត្រជៀសវាងអំពើហិង្សាដោយជោគជ័យ ដូចបានឃើញតាមបណ្តាញផ្សព្វផ្សាយ (ជំនាញត្រិះរិះពិចារណា)
- ទប់ទល់ការគាបសង្កត់ និងបង្ខំពីមិត្តភក្តិ និងអ្នកដទៃឱ្យអ្នកមានអាកប្បកិរិយាហិង្សា (ជំនាញដោះស្រាយបញ្ហា ជំនាញសម្រេចចិត្ត ជំនាញត្រិះរិះពិចារណា ជំនាញទប់ទល់ភាពតានតឹង ជំនាញទប់ចិត្ត ជំនាញនិយាយទំនាក់ទំនង និងជំនាញទំនាក់ទំនងជាមួយអ្នកដទៃ)
- ធ្វើខ្លួនជាអ្នកសម្របសម្រួល និងរំងាប់អារម្មណ៍អ្នកដែលពាក់ព័ន្ធក្នុងអំពើហិង្សា (ជំនាញស្គាល់ខ្លួនឯង ជំនាញដោះស្រាយបញ្ហា ជំនាញសម្រេចចិត្ត ជំនាញត្រិះរិះពិចារណា ជំនាញទប់ចិត្ត ជំនាញទប់ទល់ ភាពតានតឹង ជំនាញនិយាយទំនាក់ទំនង និងជំនាញទំនាក់ទំនងជាមួយអ្នកដទៃ)
- ជួយទប់ស្កាត់បទឧក្រិដ្ឋនានានៅក្នុងសហគមន៍ (ជំនាញដោះស្រាយបញ្ហា ជំនាញសម្រេចចិត្ត ជំនាញនិយាយទំនាក់ទំនងជាមួយអ្នកដទៃ ជំនាញទប់ចិត្ត)
- កាត់បន្ថយការប្រកាន់ពូជសាសន៍ និងបង្កើនការអត់អោនឱ្យគ្នាដើម្បីឱ្យមានភាពចំរុះ (ជំនាញត្រិះរិះពិចារណា ជំនាញទប់ចិត្ត ជំនាញទប់ទល់ភាពតានតឹង ជំនាញនិយាយទំនាក់ទំនង និងជំនាញទំនាក់ទំនងវាងបុគ្គល ជំនាញនិយាយចរចា)

របបអាហារដែលមានសុខភាពល្អ

ដើម្បីឱ្យរបបអាហារមានសុខភាពល្អ ជំនាញមួយ ឬច្រើនបញ្ចូលគ្នាត្រូវប្រើដើម្បីជួយសិស្សឱ្យ :

- កត់សម្គាល់ការពេញចិត្តសម្រាប់ខ្លួនឯងនូវអាហារដែលមានសារធាតុទ្រទ្រង់ អាហារសម្រន់ដែលមិន សូវមានសារធាតុបំប៉នមិនច្រើនហួសហេតុ (ជំនាញស្គាល់ខ្លួនឯង ជំនាញសម្រេចចិត្ត)

- កត់សម្គាល់ និងទប់ទល់ការគាបសង្កត់ពីមិត្តភក្តិក្នុងការហូបចុកដែលធ្វើឱ្យខូចសុខភាព (ជំនាញវិភាគ ត្រិះរិះពិចារណា ជំនាញនិយាយទំនាក់ទំនង)
- បញ្ចុះបញ្ចូលឪពុកម្តាយឱ្យជ្រើសរើសម្ហូបដែលមានសុខភាព (ជំនាញទំនាក់ទំនងជាមួយមនុស្សដទៃ ជំនាញ និយាយចរចា)
- វាយតម្លៃការអះអាងនៅក្នុងការផ្សាយពាណិជ្ជកម្មទាក់ទងរឿងម្ហូបអាហារ (ជំនាញវិភាគ ត្រិះរិះពិចារណា)។

លើកកម្ពស់អនាម័យ និងសុខភាព

លើកកម្ពស់អនាម័យ ការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យម្ហូបអាហារអាចជួយទប់ស្កាត់ជំងឺផ្សេងៗ។ ផ្នែកសំខាន់មួយនៃការកែលំអអនាម័យគឺការអប់រំអនាម័យ។ ប្រើប្រាស់វិធីសាស្ត្រអប់រំជំនាញសុខភាពបឋមសម្រាប់ការអប់រំអនាម័យ គឺប្រសើរជាងការផ្តល់តែព័ត៌មានមួយមុខអាចជួយសិស្សឱ្យ :

- កត់សម្គាល់ និងជៀសវាងអាកប្បកិរិយា និងស្ថានភាពបរិស្ថាន ដែលអាចធ្វើឱ្យនឹងបណ្តាលឱ្យមានជំងឺដែលឆ្លងពីទឹក និងការខ្វះអនាម័យ (ជំនាញដោះស្រាយបញ្ហា ជំនាញសម្រេចចិត្ត)
- ផ្សព្វផ្សាយខ្លឹមសារអំពីជំងឺ និងការចម្លងដល់គ្រួសារ មិត្តភក្តិ និងសមាជិកសហគមន៍ (ជំនាញនិយាយទំនាក់ទំនង ជំនាញទំនាក់ទំនងជាមួយអ្នកដទៃ)
- លើកទឹកចិត្តអ្នកដទៃ (ដូចជា មិត្តភក្តិ បងប្អូន និងសមាជិកគ្រួសារ សហគមន៍) ឱ្យផ្លាស់ប្តូរទម្លាប់មិនល្អ (ជំនាញត្រិះរិះពិចារណា ជំនាញនិយាយទំនាក់ទំនង ជំនាញទំនាក់ទំនងជាមួយអ្នកដទៃ)។

ការលើកកម្ពស់សុខភាពផ្លូវចិត្ត

សម្រាប់សុខភាពផ្លូវចិត្ត ជំនាញអប់រំសុខភាពបឋម អាចជាផ្នែកមួយនៃការខិតខំប្រឹងប្រែងធំ ដើម្បីបង្កើតបរិយាកាសចិត្តសាស្ត្រសង្គមល្អ ក្នុងសាលា។ បរិយាកាសសាលាល្អ លើកកម្ពស់សុខុមាលភាពផ្លូវចិត្ត និងចិត្តសាស្ត្រសង្គមរបស់សិស្ស និងលទ្ធផលសិក្សារបស់សិស្ស ប្រសិនបើបាន :

- ជំរុញឱ្យមានការសហការគ្នាជាជាងការប្រណាំងប្រជែង។
- ជួយសម្រួលឱ្យមានការច្រាស្រ៊ែយទាក់ទងគ្នាដោយបើកចំហ និងគាំទ្រគ្នាទៅវិញទៅមក។
- មើលឃើញសារៈសំខាន់នៃឱកាសនានា។
- ទប់ស្កាត់មិនឱ្យមានការដាក់ទណ្ឌកម្មរាងកាយ ការសម្តែតក្នុងសាលា ការប៉ះពាល់ និងអំពើហិង្សា។

តើគ្រូត្រូវបង្រៀនជំនាញទាំងនេះដោយរបៀបណា?

កុមារអាចរៀនបំណិនជីវិតបាន បើយើងប្រើប្រាស់វិធីសាស្ត្របង្រៀន ដែលអនុញ្ញាតឱ្យកុមារអនុវត្តបំណិនជីវិត។ ដូចនេះយើងអាចនិយាយបានថា "របៀប" បង្រៀនមានសារៈសំខាន់ដូច "អ្វី" ដែលយើងបង្រៀន។ ខាងក្រោម ជាគន្លឹះមួយចំនួនសម្រាប់ឱ្យការសិក្សាអំពីបំណិនជីវិតកាន់តែសកម្ម[15]។

វិធីសាស្ត្ររៀនសូត្រដែលសកម្ម	គន្លឹះសម្រាប់បង្រៀនឱ្យបានជោគជ័យ
ពិភាក្សាតាមក្រុម ១. ជួយសិស្សទាំងអស់ឱ្យចូលរួម ចែករំលែកបទពិសោធ និងផ្លាស់ប្តូរយោបល់លើប្រធានបទសុខភាពសំខាន់ៗ។ ២. ជួយសិស្សឱ្យរៀនច្រាស្រៃយទាក់ទងជាមួយអ្នកដទៃទៀត ហើយចេះស្តាប់អ្នកដទៃនៅពេលគេចែករំលែកបទពិសោធរបស់គេ។	១. រក្សាចំនួនក្នុងក្រុមតិច (៥–៧ នាក់) ២. រើសអ្នកដឹកនាំដោយប្រុងប្រយ័ត្ន ដោយធានាឱ្យមាន ទាំងក្មេងស្រី និងក្មេងប្រុសធ្វើជាអ្នកដឹកនាំ។ ៣. ធានាថាទាំងអស់គ្នាមានឱកាសចូលរួមស្មើគ្នា ៤. ធានាថាការកិច្ចបែងចែកច្បាស់លាស់ ហើយសមាជិក ក្នុងក្រុមដឹងថានឹងត្រូវធ្វើអ្វី សរសេរបាយការណ៍អ្វី និងដោយរបៀបណា។ ៥. ធានាថា ប្រធានបទសុខភាពដែលបានជ្រើសរើស លើកទឹកចិត្តសិស្សគិត និងផ្សារភ្ជាប់ទៅនឹងបទពិសោធរបស់សិស្ស។
រឿង ១. បង្ហាញព័ត៌មានតាមរបៀបដែលគួរឱ្យចាប់អារម្មណ៍ ដើម្បីធ្វើឱ្យសិស្សធាប់យល់ និងចងចាំ ២. លើកយកប្រធានបទពិបាកៗយល់មកបង្រៀន ៣. បង្កើនជំនាញស្រមើស្រមៃដល់សិស្ស ៤. អភិវឌ្ឍជំនាញច្រាស្រៃយទាក់ទងដល់សិស្ស (ស្តាប់ និយាយ សរសេរ)	១. ប្រើប្រាស់រឿងដើម្បីបង្រៀនគំនិត និងប្រធានបទសុខភាពថ្មី។ ធ្វើឱ្យរឿងទាំងនេះមានការចាប់អារម្មណ៍ដល់សិស្ស។ ២. ធានាថា សិស្សចេះចាំចំណុចសំខាន់ៗរបស់រឿង រួមបញ្ចូលទាំងមនោសញ្ចេតនារបស់តួអង្គជាង ៣. បំបែកចេញពីការនិទានរឿងទៅជាសកម្មភាពផ្សេងទៀត ដូចជា ការសម្តែងជាឈុតឆាក និងគូរគំនូរជាដើម។ ៤. លើកទឹកចិត្តសិស្សឱ្យនិយាយរឿង ដែលបានអាន ហើយឱ្យសិស្សផ្សេងទៀត និងសមាជិកក្នុងគ្រួសារបានស្តាប់ដែរ។ លើកទឹកចិត្តសិស្សឱ្យសរសេររឿង និងនិយាយរឿងដែលបានសរសេរ។

15 Adapted from: Son V, Pridmore P, Nga B, My D and Kick P (2002) Renovating the Teaching of Health in Multigrade Primary Schools: A Teacher's Guide to Health in Natural and Social Sciences (Grades 1,2,3) and Science (Grade 5). British Council /National Institute of Educational Sciences: Hanoi, Vietnam.

វិធីសាស្ត្ររៀនសូត្រដែលសកម្ម	គន្លឹះសម្រាប់បង្រៀនឱ្យបានជោគជ័យ
ការបង្ហាញជាក់ស្តែង ១. ធ្វើឱ្យមានទំនាក់ទំនងគ្នារវាងខ្លឹមសារអរូបី ឱ្យទៅជារូបី។ ២. អភិវឌ្ឍជំនាញអង្កេត និងជំនាញជាក់ស្តែង ៣. ជំរុញឱ្យមានការគិតពិចារណាសមហេតុផល	១. ប្រើច្រាស់របស់ពិត (ដូចជា ម្ជូប ដង្កូវ។ល។) ជំនួសរូបបើអាចរករបស់ពិតយកមកប្រើបាន។ ២. ឱ្យសិស្សអនុវត្តក្នុងការបង្ហាញជាក់ស្តែង។ ក្នុងនាមអ្នកជាគ្រូ ធ្វើបន្តិចបន្តួចបានហើយ។ ៣. ឱ្យសិស្សរៀបរាប់អ្វីដែលគេកំពុងតែធ្វើ និងពីហេតុផលដែលគេធ្វើដល់សិស្សដទៃទៀត។ ៤. សិស្សអាចប្រើច្រាស់ខ្លួនរបស់គេ ដូចជានៅពេល រៀនអំពីខ្លួនច្រាណ ដើម្បីបង្ហាញពីការជួយសង្គ្រោះបន្ទាន់។
ការសម្តែង ១. អភិវឌ្ឍជំនាញច្រាស្រ៍យទាក់ទងគ្រប់ប្រភេទ។ ២. អនុញ្ញាតឱ្យសិស្សស្វែងយល់ភាវៈយាបថ មនោសញ្ចេតនា និងបញ្ហាស្មុគស្មាញ ពិបាកដោះស្រាយ ដូចជា ជំងឺអេដស៍ និងពិការភាព។ ៣. អភិវឌ្ឍជំនឿទុកចិត្តលើខ្លួនឯង។ ៤. ដឹកនាំឱ្យមានសកម្មភាព ដែលជួយសិស្សឱ្យគិតឱ្យបានច្បាស់លាស់ និងសម្រេចចិត្ត។	១. ជួយ និងជំរុញសិស្សឱ្យរៀបចំបង្កើតឈុតឆាកសម្រាប់ការសម្តែងដោយខ្លួនឯង។ គ្រូមិនត្រូវរៀបចំសម្រាប់ កូនសិស្សទេ។ ២. រៀបចំ និងប្រើច្រាស់សម្ភារៈសម្តែងសាមញ្ញ។ ៣. ប្រើច្រាស់ការសម្តែងខ្លីឱ្យបានញឹកញាប់ ដូចជា "តាំងខ្លួនថាអ្នកបានឃើញអ្នកណាម្នាក់ធ្វើការអ្វីមួយ តើអ្នកអាចនិយាយ និងធ្វើយ៉ាងណាដែរ"? ៤. ដឹកនាំចេញពីការសម្តែងទៅជាការពិភាក្សា ឧទាហរណ៍ "ហេតុអ្វីបានជាគេធ្វើបែបនេះ? តើមានអ្វីនឹងកើតឡើង នៅពេលបន្ទាប់"? ៥. ត្រូវធានាឱ្យបានជាប់លាប់ថា ក្រោយពីបញ្ចប់ការសម្តែង សិស្សបានរៀនខ្លឹមសារស្តីពីសុខភាព។ ៦. តាមដានពិនិត្យអាកប្បកិរិយារបស់គេនៅក្រៅថ្នាក់ថា តើពួកគេបានយកខ្លឹមសារទាំងនោះមកអនុវត្តដែរឬទេ។ ៧. នៅក្នុងស្ថានភាពលំបាក ប្រហែលជានៅពេលដែល កុមារកំពុងតែទទួលការចំអកឡកឡឺយលើកទឹកចិត្តសិស្ស របស់អ្នកឱ្យគិត ពីអ្វីដែលកំពុងតែកើតឡើង និងវិធី ដែលអាចជួយកុមារបាន។ ប្រើច្រាស់ការសម្តែងដើម្បីធ្វើការសាកល្បងជាមុនសិន។

ការអប់រំជំនាញសុខភាពបឋមដើម្បីទប់ស្កាត់ការឆ្លងអេដស៍

ខ្លឹមសារនៃផ្នែកនេះរៀបរាប់ពីរបៀបដែលការអប់រំជំនាញសុខភាពបឋម អាចបង្ការមេរោគអេដស៍/ជំងឺអេដស៍ និងកាត់បន្ថយការមើលងាយដល់អ្នកដែលមានផ្ទុកមេរោគអេដស៍។ សកម្មភាពក្នុងផ្នែកនេះទាមទារឱ្យមានការកែសម្រួល មុននឹងប្រើ ដើម្បីដោះស្រាយបញ្ហាសុខភាព ដូចដែលបានពិភាក្សាខាងដើម។

ការអប់រំ ជាយុទ្ធសាស្ត្រគន្លឹះដើម្បីកាត់បន្ថយភាពស្លាកស្នាមទុយ៉ិស និងបង្កើនការយល់ដឹងពីជំងឺអេដស៍។ សាលារបស់អ្នក ជាទីកន្លែងសំខាន់សម្រាប់អប់រំកុមារអំពីមេរោគអេដស៍/ជំងឺអេដស៍ និងសម្រាប់បញ្ឈប់ការឆ្លងរាលដាលនៃមេរោគអេដស៍។ ការជោគជ័យក្នុងការងារនេះ គឺអាស្រ័យលើកម្រិតយល់ដឹងរបស់កុមារ និងមនុស្សជំទង់ក្នុងការប្រកាន់យកឥរិយាបថវិជ្ជមាន និងការពារមិនឱ្យមានឥរិយាបថដែលជំរុញឱ្យក្មេង។ ធ្លាក់ចូលក្នុងស្ថានភាពគ្រោះថ្នាក់។

ការទទួលខុសត្រូវដ៏សំខាន់របស់យើង គឺបង្ការបង្ហាញមនុស្សទូទៅឱ្យជៀសវាងការទទួល ឬចម្លងមេរោគអេដស៍ដល់អ្នកដទៃ។ លើសពីនេះ យើងត្រូវរៀបចំគោលនយោបាយសាលាដែលនិយាយអំពីជំងឺអេដស៍។ ធ្វើបែបនេះ យើងអាចលើកកម្ពស់គុណភាពនៃការអប់រំសុខភាព ដែលយើងបណ្តុះបណ្តាលដល់ក្មេង។ ក្នុងសាលារបស់យើង ហើយយើងក៏អាចធ្វើឱ្យសុខភាពក្នុងភូមិរបស់យើងមានការរីកចម្រើនដែរ។

វិធីសាស្ត្របង្រៀនអំពីបញ្ហាសុខភាពទាក់ទងមេរោគអេដស៍/ជំងឺអេដស៍ ដោយប្រើវិធីសាស្ត្រចូលរួមនឹងអាច :

- ជួយបុគ្គលម្នាក់ៗឱ្យវាយតម្លៃកម្រិតគ្រោះថ្នាក់ដោយខ្លួនឯង។
- ពិនិត្យមើលគុណធម៌ និងជំនឿខ្លួនគេ។
- សម្រេចថា តើសកម្មភាពមួយណាដែលសិស្សគួរធ្វើដើម្បីការពារខ្លួន និងការពារអ្នកដទៃឱ្យរួចផុតពីការឆ្លងរាលដាលនៃមេរោគអេដស៍/ជំងឺអេដស៍។
- ទទួលបានជំនាញដែលអាចជួយសិស្សឱ្យចេះសម្រេចចិត្តប្រកបដោយភាពវៃឆ្លាត។

ការអប់រំជំនាញសុខភាពមូលដ្ឋានដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃមេរោគអេដស៍/ជំងឺអេដស៍អាចទាក់ទងទៅនឹងបញ្ហាផ្សេងទៀត ដែលសាលាយើងបានដោះស្រាយរួចមកហើយ ដូចជា ការមានផ្ទៃពោះសុខភាពបន្តពូជ ការអប់រំ ប្រជាសាស្ត្រ ការអប់រំជីវិតគ្រួសារ និងការទប់ស្កាត់ការប្រើថ្នាំស្រវឹងញៀន។

តើយើងអាចប្រើថ្នាំវិធីអ្វីខ្លះ ដើម្បីចាប់ផ្តើមកម្មវិធីអប់រំសុខភាពមូលដ្ឋានដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃមេរោគអេដស៍/ជំងឺអេដស៍ ក្នុងចំណោមកូនចៅរបស់យើង? ចូរពិនិត្យមើលវិធីទាំងនេះ តាមរយៈសកម្មភាពដែលយើងធ្វើនៅក្នុង សាលា និងអ្វីដែលយើងអាចធ្វើសម្រាប់កូនចៅរបស់យើង។



សកម្មភាពអនុវត្ត : អ្វីដែលគ្រូ និងសាលាអាចធ្វើ[16]

១. ត្រង់ត្រាប់ទទួលព័ត៌មាន និងសកម្ម

- ទទួលព័ត៌មានថ្មីៗ ទាក់ទងនឹងអេដស៍ វិធីឆ្លង និងវិធីការពារ និងផលប៉ះពាល់ដល់សង្គម។
- ស្គាល់តរិយាបថ គុណធម៌ អាកប្បកិរិយាខ្លួនឯងទាក់ទងនឹងមេរោគអេដស៍/ជំងឺអេដស៍ និងបង្កើនជំនឿទុកចិត្ត ក្នុងការច្រាស្រ៊ែយទាក់ទងជាមួយសិស្សអំពីបញ្ហាទាំងនេះ។

២. បង្កើតភាពជាដៃគូ

- បង្កើតឱ្យមានទំនាក់ទំនងដៃគូ យ៉ាងហោចណាស់ជាមួយមនុស្សម្នាក់នៅក្នុងសាលា។ បំផុសសិស្សឱ្យធ្វើការងារជាក្រុម។
- ស្វែងយល់អំពីអង្គការ និងសេវានានា ដែលធ្វើការទាក់ទងនឹងការបង្ការមេរោគអេដស៍/ជំងឺអេដស៍នៅក្នុងសហគមន៍។ ជួបនិយាយជាមួយតំណាងអង្គការ ហើយសាកសួរដើម្បីសុំយកព័ត៌មានឧបករណ៍បង្រៀន និងធនធានផ្សេងទៀត។

៣. ណែនាំឱ្យមានការច្រាស្រ៊ែយទាក់ទងគ្នាដោយចំហ

- ត្រៀមខ្លួនដើម្បីពិភាក្សាដោយចំហលើបញ្ហាពិបាកដោះស្រាយចំនួន ៥-១០ ប្រភេទនៅក្នុងថ្នាក់។ កំណត់ និងពន្យល់អត្ថន័យឱ្យបានច្បាស់លាស់។ ពិនិត្យពិចារណារកគុណសម្បត្តិ និងគុណវិបត្តិ ហើយ បន្ទាប់មក ពិភាក្សាជាមួយសហការីរបស់អ្នក។

៤. ប្រើវិធីសាស្ត្របង្រៀនដោយមានការចូលរួម

- ទទួលបទពិសោធ និងចំណេះដឹងក្នុងការប្រើប្រាស់វិធីរៀនសូត្រសកម្ម និងចូលរួម។ អនុវត្តសាកល្បងវិធីទាំងនេះជាមួយសិស្សគំរូមួយក្រុម មុនពេលអ្នកចាប់ផ្តើមបង្រៀនសិស្សមួយថ្នាក់។
- គ្រូមិនត្រូវនិយាយតែម្នាក់ឯងទេ។ ត្រូវឱ្យសិស្សចូលរួមយ៉ាងសកម្មនៅក្នុងសកម្មភាពរៀន និងបង្រៀននៅក្នុងថ្នាក់។ ជួយសិស្សរបស់អ្នកឱ្យក្លាយជាដៃគូសំខាន់នៅក្នុងការប្រមូល និងវិភាគព័ត៌មាន ពិភាក្សាពីការវិកដុះដាលនៃជំងឺនិងរកវិធីដើម្បីទប់ស្កាត់ការរាតត្បាត។
- លើកទឹកចិត្តសិស្សឱ្យសួរសំណួរ ចូលរួមក្នុងការពិភាក្សា និងបណ្តុះគំនិតថ្មីៗ។

---

16 Adapted from: Schenker II, Nyirenda JM. (2002) Preventing HIV/AIDS in Schools. International Academy of Education and the International Bureau of Education. Educational Practices Series 9. Paris.

๕. ប្រើប្រាស់ពេលម៉ោងបង្រៀនប្រកបដោយការច្នៃប្រឌិត

- ប្រើប្រាស់កម្មវិធីសិក្សាណាដែលអាចបង្រៀនដោយប្រើវិធីសាស្ត្រចំរុះ ដោយធ្វើឱ្យការបង្រៀនអំពីមេរោគអេដស៍/ជំងឺអេដស៍ជាមេរៀនសំខាន់ មានសារប្រយោជន៍ និងគួរជាទីចាប់អារម្មណ៍សម្រាប់សិស្ស។
- រៀបចំឱ្យមានការបង្រៀនច្រើនម៉ោងដាច់គ្នា យ៉ាងហោចណាស់ក៏ត្រូវបង្រៀន ៤ ដង ដាច់គ្នានៅក្នុងរយៈពេលកំណត់ណាមួយដែរ។ (ឧទាហរណ៍ បង្រៀន ៤ ថ្ងៃ ក្នុងរយៈពេល ១ សប្តាហ៍)
- តាមរយៈការបង្រៀនដោយមានការចូលរួម ខ្លឹមសារស្តីពីការទប់ស្កាត់ការឆ្លងរាលដាលនៃមេរោគអេដស៍/ជំងឺអេដស៍អាចផ្សព្វផ្សាយដល់គ្រួសារសិស្ស។ រៀបចំសំបុត្រ និងទិតប័ណ្ណព័ត៌មានដែលសិស្ស "អាចយកទៅជាប់តាមខ្លួន" ហើយស្នើឱ្យឪពុកម្តាយនិយាយ ជាមួយកូនៗអំពីអេដស៍ដោយចំហ និងមិនលាក់លៀម។
- ឱ្យមានការចូលរួមពីឪពុកម្តាយ និងសមាជិកសកម្មផ្សេងទៀតនៅក្នុងសហគមន៍។ រៀបចំការបង្រៀនដាច់ដោយឡែកពីគ្នាសម្រាប់ឪពុកម្តាយ អាចជួយបង្កើនទំនាក់ទំនងច្រាស្រ័យទាក់ទងគ្នាជាមួយកូនស្តីពីការទប់ស្កាត់ការឆ្លងរាលដាលនៃមេរោគអេដស៍/ជំងឺអេដស៍។

๖. ប្រើប្រាស់វិធីឆ្លើយតបយេនឌ័រ

- ដោះស្រាយបញ្ហាទាំងរបស់ក្មេងប្រុស និងរបស់ក្មេងស្រី ហើយជំរុញឱ្យមានការរៀនសូត្រអំពីមេរោគអេដស៍/ជំងឺអេដស៍ ទាំងនៅក្នុងក្រុមដែលមានតែសិស្សស្រី ឬមានតែសិស្សប្រុស និងក្រុមដែលមាន សិស្សទាំងពីរភេទចូលរួម។
- ធ្វើឱ្យការបង្រៀនរបស់អ្នកទាក់ទងនឹងតុល្យភាពនៃអំណាចរវាងក្មេងប្រុស និងក្មេងស្រី និងពង្រឹងជំនាញចរចារបស់ក្មេងស្រី។
- បង្ហាញសេណារីយ៉ូដោយប្រុងប្រយ័ត្ន នៅលើស្ថានភាពជាក់ស្តែង ក្នុងគោលបំណងលើកកម្ពស់ក្មេងស្រីឱ្យនិយាយថា "ទេ" ចំពោះស្ថានការគ្រោះថ្នាក់នានា។

๗. ដោះស្រាយខ្លឹមសារដែលទាក់ទងនឹងបញ្ហាវប្បធម៌

- កម្មវិធីបង្ការដែលធ្វើនៅក្នុងមូលដ្ឋានមានប្រសិទ្ធភាពខ្ពស់ នៅពេលគេបញ្ចូលទំនៀមទម្លាប់មូលដ្ឋាន ទាំងខ្លឹមសារ ពាក្យពេជន៍ និងវិធីសាស្ត្របង្រៀន។
- កត់សម្គាល់ចំណេះដឹង ឥរិយាបថ ជំនឿ គុណធម៌ ជំនាញ និងសេវាក្នុងសហគមន៍ដែលមានឥទ្ធិពលលើអាកប្បកិរិយា និងលក្ខខណ្ឌទាក់ទងនឹងមេរោគអេដស៍/ជំងឺអេដស៍ទាំងវិជ្ជមាន និងអវិជ្ជមាន។
- ផ្តល់ឧទាហរណ៍ជាក់ស្តែងពីវប្បធម៌ និងទំនៀមទំលាប់របស់សិស្ស ពេលពិភាក្សាជាមួយសិស្សអំពីការការពារកុំឱ្យឆ្លងអេដស៍។

៨. តម្លៃនៃការគាំទ្ររបស់មិត្តភក្តិ

- រៀបចំឱ្យមានកន្លែងមានសុវត្ថិភាពដើម្បីធ្វើការពិភាក្សានៅក្នុងថ្នាក់។ លើកទឹកចិត្តសិស្សឱ្យចេះគាំទ្រគ្នាទៅវិញទៅមកក្នុងការសិក្សាអំពីការបង្ការការឆ្លងរាលដាលនៃមេរោគអេដស៍/ជំងឺអេដស៍ និងនិយាយអំពីគ្រោះថ្នាក់នៃមេរោគអេដស៍/ជំងឺ អេដស៍។
- ត្រូវទទួលស្គាល់ថាក្រុមនីមួយ ៗមានចរិតលក្ខណៈរៀង ៗខ្លួនរបស់គេ។ ព្យាយាមតំរង់ទិសគេដើម្បីធ្វើឱ្យគេទទួលយកចរិតលក្ខណៈ ដែលប្រកាន់យកនូវការរួមភេទមានសុវត្ថិភាព និងការការពារ មិនឱ្យមានការចម្លងមេរោគអេដស៍/ជំងឺអេដស៍ និងការប្រើប្រាស់គ្រឿងញៀន។
- ប្រើប្រាស់ជំនាញនៃការដឹកនាំរបស់អ្នកដើម្បីប្រែក្លាយអ្នកដែលមានជួកមេរោគ/ជំងឺអេដស៍ឱ្យក្លាយជាអ្នកអប់រំអំពីមេរោគអេដស៍/ជំងឺអេដស នៅក្នុងថ្នាក់របស់អ្នក។

៩. ប្រើប្រាស់ការអប់រំជំនាញសុខភាពមូលដ្ឋានឱ្យសកម្ម

- លើកកម្ពស់ការអប់រំជំនាញសុខភាពមូលដ្ឋានដែលផ្តោតលើ :
- បំណិនជីវិត (ការចរចា អំណះអំណាង ការបដិសេធ និងការប្រាស្រ័យទាក់ទង)
- បំណិនប្រាជ្ញា (ការដោះស្រាយបញ្ហា ការត្រិះរិះពិចារណា និងការសម្រេចចិត្ត)
- បំណិនទប់ទល់ (ការគ្រប់គ្រងភាពតានតឹង ការគ្រប់គ្រងចិត្ត) និង
- បំណិនអនុវត្តជាក់ស្តែង (ប្រើប្រាស់ស្រមោមអនាម័យ)



សកម្មភាពអនុវត្ត : តើយើងត្រូវធ្វើយ៉ាងណាជាមួយក្មួនរបស់យើង[17]?

សិស្សានុសិស្សគឺជាអនាគតរបស់សហគមន៍ ដូចនេះសិស្សត្រូវតែរៀនទទួលខុសត្រូវចំពោះខ្លួនឯង និងចំពោះអ្នកដទៃ។ ដោយទទួលការណែនាំពីលោកគ្រូ អ្នកគ្រូ គ្រូពេទ្យ និងមេដឹកនាំសហគមន៍ សិស្សអាចរៀនពីរបៀបការពារគ្រួសារ ដៃគូ និងការពារខ្លួនកុំឱ្យឆ្លងមេរោគអេដស៍។ កុមារ និងមនុស្សជំទង់គ្រប់រូបអាចសម្រេចចិត្តប្រកាន់យកអាកប្បកិរិយាបែបណាដែលមានសុវត្ថិភាពសម្រាប់ខ្លួនឯង និងសម្រាប់សហគមន៍។

---

17 Source: Baily D, Hawes H and Bonati B. (1994) Child-to-Child: A Resource Book. Part 2: The Child-to-Child Activity Sheets. London: The Child-to-Child Trust. This is an excellent source for increasing children's participation in HIV/AIDS as well as other important health and child development issues. Readers are strongly encouraged to use it.

គ្រូទាំងអស់ មិនមែនតែគ្រូ ដែលបង្រៀនមុខវិជ្ជាសុខភាពនោះទេ មានតួនាទីបង្រៀនអំពីអេដស៍ សុខភាពផ្លូវភេទ និងការឆ្លងរាលដាលនៃមេរោគអេដស៍/ជំងឺអេដស៍។ មានឱកាសជាច្រើនទៀតសម្រាប់បង្រៀនអំពីអេដស៍ ដូចជាពេលដែលកុមារ និងយុវជនជួបជុំគ្នានៅតាមក្លឹប ការជួបជុំនៅតាមវត្តអារាម និងទីកន្លែងផ្សេងទៀត។ មនុស្សធំ ដែលដឹកនាំការប្រជុំអាចជ្រើសរើសសកម្មភាពសមស្របណាមួយ។ (នៅក្នុងឧទាហរណ៍ខាងក្រោមនេះ ពាក្យ "គ្រូ" អាចជំនួសដោយអ្នកណាក៏ដោយ ឱ្យធ្វើការជាមួយកុមារ)។

អ្វីដែលកុមារគ្រប់រូបគួរយល់ដឹង

សាលាត្រូវរៀបចំឱ្យមានគោលនយោបាយសុខភាព ដែលកុមារគ្រប់រូបពេលចេញពីសាលាត្រូវតែដឹងអំពីការពិតទាំងអស់អំពីសុខភាព។ គ្រូពេទ្យ និងអ្នកដឹកនាំយុវជន អាចធ្វើការងារប្រហាក់ប្រហែលគ្នាដើម្បីផ្សព្វផ្សាយចំណេះដឹងអំពីអេដស៍។

ជំងឺអេដស៍គឺជាអ្វី? *អេដស៍គឺជាជំងឺដែលបង្កឡើងដោយមេរោគអេដស៍/ជំងឺអេដស៍ ។ អេដស៍ធ្វើឱ្យប្រព័ន្ធសារពាង្គកាយមនុស្សមិនអាចការពារខ្លួនទប់ទល់នឹងជំងឺច្រើនប្រភេទទៀត ដូចជា រាក របេង និងរលាកសួត។ ដោយសារអេដស៍ ជំងឺទាំងអស់នេះអាចធ្វើឱ្យមនុស្សឈឺធ្ងន់ ហើយស្លាប់។*

តើមេរោគអេដស៍/ជំងឺអេដស៍ចម្លងពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀតដោយរបៀបណា?

- *មេរោគអេដស៍ឆ្លងពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀតតាមរយៈ:*
- *ការរួមភេទជាមួយអ្នកដែលមានមេរោគអេដស៍ ដោយគ្មានសុវត្ថិភាព*
- *ពេលដែលឈាមមានមេរោគអេដស៍ឆ្លងពីរាងកាយមនុស្សម្នាក់ ទៅរាងកាយមនុស្សម្នាក់ទៀត ដូចជាពេលបញ្ចូលឈាម ការប្រើម្ជុលរួមគ្នា និងការមុតរបស់ស្រួច។*
- *ពីម្តាយមានមេរោគអេដស៍ទៅកូនដែលមិនទាន់កើត។*

មេរោគអេដស៍/ជំងឺអេដស៍មិនចម្លងតាមសត្វទិច ស្តាបអង្អែល ឬការមើលថែទាំអ្នកដែលមានផ្ទុកមេរោគអេដស៍/ជំងឺអេដស៍នោះទេ។

ពេលវេលា និងទីកន្លែងដែលត្រូវពិភាក្សាអំពីអេដស៍

- *នៅក្នុងមណ្ឌលសុខភាព ឬទីកន្លែងពិសេសប្រចាំងនឹងមេរោគអេដស៍/ជំងឺអេដស៍ ដែលជាកន្លែងដែលកុមារអាចស្វែងយល់ពីទីការចម្លង និងបង្ការអេដស៍ និងការប្តេជ្ញាចិត្តការពារខ្លួនកុំឱ្យឆ្លង។*

- ជួនកាល ការពិភាក្សាគ្នាអំពីបញ្ហាអេដស៍ អាចងាយស្រួលជាង ប្រសិនបើការពិភាក្សា ធ្វើក្នុងចំណោមមនុស្សដែលមានភេទដូចគ្នា។ ក្រុមក្មេងស្រី ឬក្មេងប្រុស អាចពិភាក្សាគ្នា ចែករំលែកបទពិសោធ និងការបារម្ភដោយចំហ ហើយគាំទ្រគ្នាទៅវិញទៅមក ដើម្បីឱ្យមានជំនឿក្នុងការសម្រេចចិត្ត។ ប្រសើរជាងនេះទៀត ប្រសិនបើមនុស្សជំរដែលដឹកនាំក្នុងក្រុមក៏មានភេទដូចគ្នា។

ដោយមានការយល់ដឹងច្បាស់អំពីអេដស៍ កុមារអាច :

- លេងល្បែងពិត មិនពិត។ គ្រូសរសេរអំណះអំណាងពិត/មិនពិតអំពីអេដស៍នៅលើក្រដាសដាច់ដោយឡែកពីគ្នា ដូចជា "អ្នកអាចចម្លងមេរោគអេដស៍ពីមូសទាំ"(មិនពិត)។ "អ្នកមិនអាចចម្លងមេរោគអេដស៍តាមរយៈការចាប់ដៃ" (ពិត)។ សរសេរពាក្យបីនេះនៅលើដី : "ពិត" "មិនពិត" និង"មិនដឹង"។ កុមារម្នាក់ចាប់យកអំណះអំណាងមួយ ហើយបន្ទាប់មកដាក់នៅក្នុងកន្លែងដែលមានសរសេរពាក្យទាំងបីនេះ ("ពិត""មិនពិត" និង"មិនដឹង")។ បន្ទាប់មក ឱ្យកុមារម្នាក់នោះត្រូវពន្យល់ហេតុផលអំពីការជ្រើសរើសនោះ។ សិស្សផ្សេងទៀតអាចសួរដេញដោលពីការពន្យល់នោះ។

- សរសេរសំណួរទាក់ទងនឹងអេដស៍ ហើយបន្ទាប់មកពិភាក្សាជាមួយដៃគូ។

- ប្រសិនបើអាចធ្វើបាន ប្រមូលព័ត៌មានពីសារព័ត៌មាន (ដូចជាការសែត ទស្សនាវដ្តី) និងប្រមូលពីកន្លែងពាក់ព័ន្ធធ្វើការងារអំពីអេដស៍ នៅក្នុងសហគមន៍ និងក្នុងប្រទេស។ ហេតុអ្វីបានជាការប្រមូលព័ត៌មានជួបការលំបាក? តើជនទូទៅមានឥរិយាបថយ៉ាងណាចំពោះមេរោគអេដស៍/ជំងឺអេដស៍? ហេតុអ្វីបានជាតួលេខទាំងនេះមិនសមនជាតួលេខពិតប្រាកដ?

- ធ្វើទស្សនកិច្ចទៅកាន់មណ្ឌលសុខភាពសហគមន៍។ បុគ្គលិកសុខាភិបាលនៅទីនោះអាចនិយាយអំពីហេតុអ្វីបានជាគេចាក់ថ្នាំ ហើយបង្ហាញពីការរំងាប់មេរោគនៅលើម្ជុល និងស៊ីរាុំង។

ក្នុងការពិភាក្សា និងសម្តែងអំពីមេរោគអេដស៍/ជំងឺអេដស៍ កុមារអាច :

- ស្រមៃអំពីរបៀបដែលមេរោគអេដស៍/ជំងឺអេដស៍អាចបំផ្លាញជីវិតមនុស្ស។ កុមារអាចបិទភ្នែក ហើយស្រមៃពីជីវិតរបស់គេក្នុងរយៈពេល២ឆ្នាំបន្ទាប់។ គ្រូអាចសួរសំណួរមួយចំនួន ដូចជា "តើអ្នកនឹងរស់នៅជាមួយអ្នកណា?" "តើមិត្តភក្តិរបស់អ្នកមានអ្នកណាខ្លះ?" "តើអ្នកនឹងបង្ហាញពីការស្រលាញ់ និងមិត្តភាពរបស់អ្នកដោយរបៀបណា? "តើអ្នកនឹងប្រើប្រាស់ថ្នាំញៀន ជីកគ្រឿងស្រវឹង និងជក់បារីឬទេ?" តើមេរោគអេដស៍/ជំងឺអេដស៍នឹងបំផ្លាញជីវិតរបស់អ្នក គ្រួសារអ្នក និងមិត្តភក្តិអ្នកដោយរបៀបណា?"។ បន្ទាប់មកកុមារស្រមៃពីជីវិតក្នុង រយៈពេល ១០ ឆ្នាំបន្ទាប់ និងឆ្លើយសំណួរដដែល។ បន្ទាប់មកកុមារនឹងស្រមៃថា គេមានកូនអាយុ១៣ឆ្នាំ តើគេត្រូវផ្តល់ដំបូន្មានយ៉ាងណាខ្លះដល់កូន?

- ឱ្យកុមារសម្តែងជាតួគូស្រែករដែលរៀបការហើយច្រើនគូដែលមានលក្ខណៈខុសៗគ្នា បន្ទាប់មកឱ្យគេសម្រេចថាតើគូមួយណាមានសុភមង្គលជាងគេ?

- ពិភាក្សាស្ថានភាពដែលជូនកាលពិបាកនិយាថា "ទេ" ហើយកត់ត្រាហេតុផលដែលធ្វើឱ្យគេ ពិបាកនិយាយថា "ទេ"។ កុមារអាចសម្តែងជាគូៗ នៅក្នុងស្ថានភាពខុសៗគ្នា ដោយស្រមើស្រមៃពីរបៀបដែលមនុស្សម្នាក់ព្យាយាមបញ្ចុះបញ្ចូលមនុស្សម្នាក់ទៀតឱ្យអ្វីមួយ ហើយអ្នកដែលត្រូវគេបញ្ចុះបញ្ចូលអាចនិយាយថា "ទេ" ដោយម៉ឺងម៉ាត់តែគួរសម។ ស្ថានភាពទាំងនេះអាចជា :

  ✓ ជក់បារី

  ✓ ទៅទីណាមួយជាមួយមនុស្សដែលយើងមិនដែលស្គាល់

  ✓ ជើរកំសាន្តពេលរាត្រី

នៅក្នុងការពិភាក្សា និងសម្តែងអំពីឥរិយាបថចំពោះអ្នកដទៃដែលមានជំងឺអេដស៍ កុមារអាច :

- ប្រមូលព័ត៌មានពីសារព័ត៌មាននានាដែលនិយាយអំពីអេដស៍ និងពិភាក្សាអំពីឥរិយាបថដែលសារព័ត៌មានបានលើកឡើង។

- សរសេរអត្ថបទកំណាព្យឆ្លុះបញ្ចាំងអារម្មណ៍របស់គេអំពីមេរោគអេដស៍/ជំងឺអេដស៍ និងផលប៉ះពាល់របស់វាលើជីវិតផ្ទាល់ខ្លួន និងជីវិតអ្នកដទៃ។

- ប្រើប្រាស់រូបភាព ដូចជា មនុស្សម្នាក់កំពុងតែមើលថែទាំមិត្តភក្តិដែលមានមេរោគអេដស៍ ដើម្បីជួយកុមារឱ្យស្រមើស្រមៃអំពីអារម្មណ៍របស់គេ ប្រសិនបើគេជាមនុស្សក្នុងរូបភាពនោះ។ ពួកគេអាចសួរអំពីមូលហេតុដែលនាំឱ្យមានស្ថានភាពដូចដែលបង្ហាញ នៅក្នុងរូបភាព និងអ្វីដែលអាចនឹងកើតឡើងទៅថ្ងៃអនាគត។

- រៀបចំជារឿងសម្តែងខ្លីៗ ឧទាហរណ៍ អំពីការថែទាំអ្នកជំងឺអេដស៍នៅផ្ទះ។ ដំបូងពួកគេអាចសម្តែងដោយខ្លួនឯង បន្ទាប់មកកុមារម្នាក់ៗអាចធ្វើជារូបតុក្កតាតំណាងឱ្យតួរបស់គេ ហើយប្រើប្រាស់រូបតុក្កតានេះដើម្បីសម្តែងនៅក្នុងសាលា និងនៅក្នុងសហគមន៍។

- បំពេញបន្ថែមខ្លឹមសារលំអិតនៅក្នុងសាច់រឿង ដូចជា រឿងដែលនិយាយអំពីសិស្សសាលា ដែលមានមេរោគអេដស៍។ បែងចែកកុមារជាក្រុមតូចៗ ដែលតំណាងឱ្យ សិស្សដែលកើតអេដស៍ សិស្សដទៃទៀត គ្រូ និងឪពុកម្តាយ។ ដោយធ្វើការដាច់ដោយឡែកពីគ្នា ក្រុមនីមួយៗ ពិចារណាលើ "តើខ្ញុំមានអារម្មណ៍បែបណា?" "តើផលប៉ះពាល់ខ្លាំងៗអ្វីខ្លះដែលមានមកលើរូបខ្ញុំ?" "តើខ្ញុំចង់ឱ្យមានអ្វីកើតឡើង?" បន្ទាប់ពី ១៥ នាទីក្រោយមក សមាជិកក្នុងក្រុមទាំងអស់មកជួបជុំគ្នាវិញ ដើម្បីចែករំលែកបទពិសោធ ពិភាក្សាគ្នាអំពីគំនិតរបស់គេរៀងៗខ្លួន។

◆ *អានរឿងខាងក្រោមនេះ ហើយបន្ទាប់មកព្យាយាមឆ្លើយសំណួរទាំងនេះ :*

ស្ត្រីក្មេងខ្ចីម្នាក់ទើបតែវិលត្រឡប់ពីទីក្រុងមកកាន់ភូមិកំណើតរបស់នាងវិញ។ នៅពេលដែលនាង ដើរកាត់ហ្វូងមនុស្ស ពួកគេបានស្រែកដាក់នាងថា "អេដស៍! អេដស៍!" ឪពុកចុងរបស់នាងបានឱ្យនាងធ្វើតេសឈាម ហើយលទ្ធផលគឺ "វិជ្ជមាន"។

ក្មេងស្រីម្នាក់ដែលឪពុករបស់នាងមានរោគអេដស៍ ត្រូវបានគេបដិសេធមិនឱ្យចូលរៀនថ្នាក់ជាមួយ។ ដោយមានការគាបសង្កត់ពីឪពុកម្តាយរបស់សិស្សដទៃទៀតខ្លាំងពេក ក្មេងស្រីដែលឪពុកកើតអេដស៍នោះត្រូវគេបណ្តេញចេញ ឈប់ឱ្យនាងចូលរៀនតទៅទៀត។

◆ *តើអ្នកគិតយ៉ាងណាដែរអំពីស្ថានភាពទាំងពីរនេះ?*

◆ *ហេតុអ្វីបានជាមនុស្សទូទៅមានប្រតិកម្មរបៀបនេះ?*

◆ *តើប្រតិកម្មបែបនេះនឹងជួយកាត់បន្ថយការរាលដាលនៃជំងឺអេដស៍ឬទេ?*

◆ *តើអ្នកនឹងធ្វើអ្វី ប្រសិនបើអ្នកជាតួអង្គរងគ្រោះនៅក្នុងរឿងទាំងពីរនេះ?*

ក្នុងការនិយាយប្រាស្រ័យទាក់ទងនូវអ្វីដែលកុមារបានរៀន កុមារអាច :

◆ *តែងកំណាព្យ សម្តែងរឿង (ដោយផ្ទាល់ ឬដោយប្រើតុក្កតា) អំពីមេរោគអេដស៍/ជំងឺអេដស៍។*

◆ *បង្កើតផ្ទាំងគំនូរធំៗដើម្បីដាក់តាំងនៅក្នុងថ្នាក់ និងទីសាធារណៈ។*

◆ *ចូលរួមនៅក្នុងការជំរុញវិស័យកីឡាដើម្បីលើកកម្ពស់សុខភាពរបស់អ្នកដែលមានផ្ទុកមេរោគអេដស៍/ជំងឺអេដស៍។*

ក្នុងការវាយតម្លៃថាតើកុមារយល់ដឹងយ៉ាងណាអំពីមេរោគអេដស៍/ជំងឺអេដស៍ គ្រូអាច :

◆ *សួរកុមារនូវសំណួរខុសគ្នាៗដើម្បីឱ្យដឹងថាតើកុមារដឹងពីសកម្មភាពដែលអាចចម្លង និងមិនអាចចម្លងមេរោគអេដស៍។*

◆ *ឱ្យកុមារសរសេររឿងអំពីមនុស្សដែលបានចម្លងមេរោគអេដស៍ និងអំពីការថែទាំអ្នកដែលមានមេរោគអេដស៍។ បន្ទាប់មកពិនិត្យរឿងទាំងនោះ។ តើរឿងទាំងនោះប្រាប់យើងអំពីចំណេះដឹង និងឥរិយាបថរបស់កុមារទាក់ទងនឹងមេរោគអេដស៍/ជំងឺអេដស៍យ៉ាងណាដែរ។*

- ឱ្យកុមារស្រាវជ្រាវដើម្បីរកឱ្យឃើញថា តើនៅក្នុងសហគមន៍ មានសាលាណាខ្លះ ក្លឹបណាខ្លះ ដែលបង្រៀន និងធ្វើការទាក់ទងនឹងជំងឺអេដស៍។ តើគេបង្រៀន និងធ្វើអ្វីខ្លះ? មានកុមារចូលរួមនៅក្នុងសកម្មភាពទាំងនោះដែរឬទេ?
- ឱ្យកុមាររកមើលថា តើមានកុមារចូលរួមនៅក្នុងយុទ្ធនាការប្រយុទ្ធប្រឆាំងនឹងមេរោគអែដស៍/ជំងឺអេដស៍ ជួយកុមារដែលមានផ្ទុកមេរោគអេដស៍/ជំងឺអេដស៍ និងព្រមានកុមារ ផ្សេងទៀតអំពីមេរោគអេដស៍/ជំងឺអេដស៍។



សកម្មភាពអនុវត្ត : ជួយសិស្សឱ្យយល់ ហើយអនុវត្ត[18]

ការយល់ដឹង

១. ប្រមូលព័ត៌មានស្តីពីមេរោគអេដស៍/ជំងឺអេដស៍ និងជំងឺកាមរោគ ដែលមាននៅក្នុងសហគមន៍ ហើយពិភាក្សារកមូលហេតុដែលធ្វើឱ្យមេរោគអេដស៍/ជំងឺអេដស៍ជាជំងឺដែលមានគ្រោះថ្នាក់ការចម្លង និងវិធីសាស្ត្រ ដែលអាចជួយយើងឱ្យជៀសផុតពីការឆ្លងជំងឺនេះ។

២. សួរសំណួរប្រភេទ (ពិត ឬមិនពិត) ដើម្បីវាស់វែងការយល់ដឹងរបស់សិស្សអំពីមេរោគអេដស៍/ជំងឺអេដស៍។

៣. លេងល្បែងខ្សែជីវិតដើម្បីឱ្យដឹងថា សិស្សទាំងអស់មានការយល់ដឹងត្រឹមត្រូវអំពីអាកប្បកិរិយាដែលមានគ្រោះថ្នាក់ និងអាកប្បកិរិយាដែលពុំមានគ្រោះថ្នាក់។ គូសបន្ទាត់ដិតធំមួយនៅលើដីនៅក្នុងបន្ទប់រៀន (បន្ទាត់នេះតំណាងឱ្យខ្សែជីវិត) ហើយបន្ទាប់មក ដាក់ក្រដាសកាតុង ៣ សន្លឹកនៅលើបន្ទាត់នោះ។ ដាក់ក្រដាសទី ១ "គ្មានគ្រោះថ្នាក់" នៅចុងម្ខាង។ ដាក់ក្រដាសទី ២ "មានគ្រោះថ្នាក់ខ្លាំង" នៅចុងម្ខាងទៀត។ ដាក់ក្រដាសទី ៣ "មានគ្រោះថ្នាក់ខ្លះ" នៅពាក់កណ្តាលបន្ទាត់។ ចូរគិតរកអាកប្បកិរិយាចំនួន ១២ ហើយសរសេរអាកប្បកិរិយាទាំងនេះលើក្រដាសផ្សេងទៀត។ ឱ្យអាកប្បកិរិយា ២ ឬ ៣ ទៅសិស្ស ២នាក់ ហើយបន្ទាប់មកឱ្យសិស្សពិភាក្សាគ្នាថា តើអាកប្បកិរិយាដែលគេមាននោះជាអាកប្បកិរិយាដែលគ្មានគ្រោះថ្នាក់ មានគ្រោះថ្នាក់ខ្លះ ឬមានគ្រោះថ្នាក់ខ្លាំង ដែលនាំឱ្យឆ្លងមេរោគអេដស៍។ ឱ្យសិស្សតាមគូនីមួយៗធ្វើសរសេរអាកប្បកិរិយាដែលគេពិភាក្សាគ្នាទៅតាមក្រដាសនីមួយៗ នៅលើបន្ទាត់ខ្សែជីវិត ព្រមទាំងការពន្យល់ផង។ ឱ្យសិស្សដទៃទៀតមានយោបល់លើចម្លើយនីមួយៗ បន្ទាប់មក ទើបអ្នកពន្យល់បន្ថែមអំពីកិច្ចការ

---

18 Source: Son V, Pridmore P, Nga B, My D and Kick P (2002) Renovating the Teaching of Health in Multigrade Primary Schools: A Teacher's Guide to Health in Natural and Social Sciences (Grades 1,2,3) and Science (Grade 5). British Council /National Institute of Educational Sciences: Hanoi, Vietnam. This is an excellent source that can be used in a variety of educational settings, not only multigrade primary schools. Readers are strongly encouraged to use it.

ដែលសិស្សបានធ្វើហើយ។ អាកប្បកិរិយាមួយចំនួនអាចមាន : ថើបគ្នា ងូតទឹកជាមួយគ្នា ប្រើប្រាស់គ្រឿងញៀន រួមភេទ ចាប់ដៃ បំបៅដោះកូន ដឹកទឹកកែវជាមួយគ្នា ចាក់ថ្នាំការពារជំងឺឆ្លង បញ្ចូលឈាម ប្រើប្រាស់ច្រាសដុសធ្មេញជាមួយគ្នា ដើរម្នាក់ឯងនៅទីងងឹត។ល។

៤. ធ្វើការជាក្រុម ពិភាក្សា និងគូសដ្យាក្រាមបង្ហាញហេតុផល ដែលធ្វើឱ្យក្មេងៗរួមភេទដោយគ្មានសុវត្ថិភាព ឬហេតុផលចាក់ថ្នាំញៀន។

៥. ពិភាក្សាពីកាលៈទេសៈដែលយើងពិបាកបដិសេធនូវការគាបសង្កត់របស់សង្គម។ ឱ្យសិស្សស្រមៃថា តើសិស្សអាចជួបការបង្ខុះបង្ខូលឱ្យប្រព្រឹត្តអំពើមានគ្រោះថ្នាក់ដោយរបៀបណា ហើយត្រូវដោះស្រាយរបៀបណាដើម្បីជៀសឱ្យផុតពីស្ថានភាពគ្រោះថ្នាក់នេះ។

៦. សម្តែងជាក្រុមដើម្បីអភិវឌ្ឍបំណិនជីវិត។ ឱ្យសិស្សជ្រើសរើសបរិយាកាសណាមួយ ដែលអាចប្រឈមមុខនឹងការគាបសង្កត់ពីសង្គម ដូចជាការប្រើប្រាស់គ្រឿងញៀន។ បែងចែកសិស្សជា ២ ក្រុម។ សិស្ស ២ ឬ ៣ នាក់ជាអ្នកបង្ខុះបង្ខូល ហើយ២ ឬ ៣ នាក់ទៀតជាអ្នកតវ៉ាមិនទទួលយកការបង្ខុះបង្ខូល។ ឱ្យអ្នកបង្ខុះបង្ខូលព្យាយាមបង្ខុះបង្ខូលអ្នកដទៃឱ្យចូលរួមប្រព្រឹត្តអំពើដែលនាំឱ្យគ្រោះថ្នាក់។ បន្ទាប់មក នាំសិស្សពិភាក្សាអំពីអារម្មណ៍ តើសិស្សមានអារម្មណ៍យ៉ាងណានៅពេលត្រូវអ្នកណាម្នាក់បង្ខុះបង្ខូល ឬបង្ខំឱ្យប្រព្រឹត្តអំពើមានគ្រោះថ្នាក់ ហើយនៅពេលដែលអ្នកបង្ខុះបង្ខូលទាំងនោះមិនព្រមស្តាប់ នៅតែបង្ខំ។ នៅក្នុងជីវិតជាក់ស្តែង តើមានកត្តាអ្វីខ្លះដែលធ្វើឱ្យអ្នកផ្លាស់ប្តូរចិត្ត ឥរិយាបថ? នៅទីបញ្ចប់ សង្ខេបផ្តើងវិញនូវប្រការសំខាន់ៗដែលអាចជៀសឆ្ងាយពីស្ថានភាពគ្រោះថ្នាក់ និងវិធីសាស្ត្រទប់ទល់នឹងការគាបសង្កត់ពីសង្គម។

៧. បង្កើតជារឿងល្ខោនខ្លីស្តីអំពីការមើលថែទាំអ្នកមានជម្ងឺរមេរោគអេដស៍/ជំងឺអេដស៍។ ពិភាក្សាគ្នាអំពីអារម្មណ៍របស់អ្នកមានមេរោគអេដស៍ និងអារម្មណ៍របស់អ្នកថែទាំអ្នកមានជម្ងឺរមេរោគអេដស៍/ជំងឺអេដស៍។

៨. ស្តាប់រឿងនិទានប្រឌិតមួយរបស់សិស្សម្នាក់ដែលគេបានគិតថាមានជម្ងឺរមេរោគ អេដស៍/ជំងឺអេដស៍។ បែងចែកសិស្ស ជាក្រុម ម្នាក់តំណាងឱ្យសិស្សមានជម្ងឺរមេរោគអេដស៍/ជំងឺអេដស៍ មួយក្រុមទៀតតំណាងឱ្យសិស្សនៅក្នុងថ្នាក់ មួយ ក្រុមទៀត តំណាងឱ្យគ្រូ និងមួយក្រុមទៀតតំណាងឱ្យឪពុកម្តាយ។ សួរសិស្សនៅក្នុងក្រុមនីមួយ។ ថាពិចារណា លើសំណួរ "តើខ្ញុំមានអារម្មណ៍យ៉ាងណា?"។ "តើខ្ញុំចង់ឱ្យមានអ្វីកើតឡើង?" "តើវាមានផលប៉ះពាល់ យ៉ាងណាលើរូបខ្ញុំ?" បន្ទាប់មកពិភាក្សាទាំងអស់គ្នា។

សកម្មភាព

១. ជជែសឱ្យធ្លាយពីសកម្មភាពដែលនាំឱ្យមានគ្រោះថ្នាក់។

២. មានស្មារតីរឹងមាំក្នុងការនិយាយថា "ទេ" ចំពោះការប្រព្រឹត្តនានាមិនមានសុវត្ថិភាព។

៣. ចេះជួយទុក្ខធុរៈអ្នកដែលមានផ្ទុកមេរោគអេដស៍/ជំងឺអេដស៍។

៤. សរសេរពាក្យកាព្យខ្លីៗអំពីអេដស៍ ហើយបន្ទាប់មកអានឱ្យញាតិមិត្ត និងបងប្អូនស្តាប់។

៥. សម្តែងរឿងល្ខោនអំពីតួអង្គដ៏គ្រោះថ្នាក់ ដែលមានឈ្មោះថា "អេដស៍" ដែលព្យាយាមនាំមនុស្សទូទៅឱ្យចូលក្នុងអំពើគ្រោះថ្នាក់។ អ្នកខ្លះជាអ្នកបញ្ចុះបញ្ចូល ហើយអ្នកខ្លះទៀតជាអ្នកតវ៉ាមិនព្រមធ្វើតាម។ កុមារមួយក្រុមមានការយល់ដឹងអំពីអេដស៍ ហើយព្យាយាមពន្យល់អ្នកដទៃទៀត។ តួអង្គអេដស៍ដឹងថា មានមនុស្សកាន់តែតិចទៅៗ ដែលស្តាប់ការពន្យល់របស់ខ្លួន។ សិស្សអាចសម្តែងបែបនេះឱ្យឪពុកម្តាយ ឬមនុស្សម្នានៅក្នុងសហគមន៍អំពីបញ្ហានេះ។

៦. រៀបចំជាផ្ទាំងគំនូរធំៗដើម្បីដាក់តាំងនៅតាមមណ្ឌលសុខភាព សាលា និងទីសាធារណៈនានានៅក្នុងសហគមន៍។

៧. ចូលរួមក្នុងក្លឹបដែលប្រយុទ្ធប្រឆាំងនឹងមេរោគអេដស៍/ជំងឺអេដស៍ ហើយជួយរៀបចំដែនការសកម្មភាពប្រចាំ សប្តាហ៍ ដូចជា ការជើរសួរសុខទុក្ខ ពិភាក្សា សម្តែង តន្ត្រី រៀបចំផ្ទាំងគំនូរធំៗ និងសរសេរកំណាព្យ ឬចំរៀងជាដើម។



គោល ៦.៣
ផ្តល់អាហារូបត្ថម្ភ និងសេវាសុខភាព នៅសាលា និងបរិក្ខារចាំបាច់

ទោះបីជាយើងមិនលើកបង្ហាញចំៗក៏ដោយ ក៏បរិយាកាសក្នុងសាលាអាចធ្វើឱ្យមានគ្រោះថ្នាក់ដល់សុខភាពកុមារ ជាពិសេសវាបង្កើតឱកាសនៃការប្រឈមមុខចំពោះគ្រោះថ្នាក់របស់កុមារ ដូចជា ការឆ្លងជំងឺជាដើម។ កុមារដែលមានប្រវត្តិ និងសមត្ថភាពខ្សោយគេជាអ្នកដែលងាយមានបញ្ហាអាហារ និងសុខភាព។ សេវាអាហារ និងសុខភាពសាលា អាចមានសារប្រយោជន៍សម្រាប់កុមារទាំងនេះច្រើនណាស់ តាមរយៈការផ្តល់អាហារដែលលើកកម្ពស់ទម្លាប់មានអនាម័យល្អ និងតាមរយៈការសហការជាមួយឪពុកម្តាយ និងសហគមន៍ ដើម្បីបង្កើនប្រភពទឹក និងការប្រើប្រាស់ទឹកស្អាត។

សាលារបស់យើង អាចផ្តល់ដោយប្រសិទ្ធភាពនូវសេវាអាហារ និងសុខភាព ប្រសិនបើសេវាទាំងនោះជាសេវាងាយៗ និងសុវត្ថិភាព ហើយដែលសេវាទាំងនោះដោះស្រាយបញ្ហាដែលមាននៅក្នុងសហគមន៍។ ជាពិសេសជាងនេះទៀត នៅក្នុងគោលខាងដើម យើងបានសិក្សាពីជំនាញជីវិតសំខាន់ៗ។ ក្នុងការអប់រំកុមារឱ្យប្រកាន់យកទម្លាប់ល្អ។ ប៉ុន្តែការអប់រំបែបនេះពុំសូវទទួលបានការជឿទុកចិត្តពីប្រជាពលរដ្ឋទេ ប្រសិនបើសាលារបស់យើងពុំមានទឹកស្អាត និងសម្ភារនានាដែលបម្រើដល់ប្រយោជន៍អនាម័យល្អ។

គោលដៅជាក់ស្តែងគឺដើម្បីធានាថា សាលារបស់យើងផ្តល់សេវាសុខភាព និងអាហារត្រឹមត្រូវ ដូចជា ផ្តល់សម្ភារមានអនាម័យ និងទឹកស្អាតជាដើម។ ដោយការផ្តល់សេវា និងសម្ភារទាំងនេះ យើងអាចពង្រឹងបំណិនជីវិត និងអនាម័យ ជាខ្លឹមសារដែលយើងលើកយកមកពិគ្រោះជាហូរហែរ ហើយសាលាអាចធ្វើជាគំរូសម្រាប់សិស្ស និងប្រជាជនទូទៅក្នុងសហគមន៍។ ធ្វើបែបនេះអាចជួយឱ្យមានសេវា និងសម្ភារប្រហាក់ប្រហែលគ្នា ដែលរៀបចំដោយសហគមន៍។ លើសពីនេះទៀត ប្រសិនបើយើងបានជោគជ័យនៅពេលនោះ សហគមន៍នឹងមើលឃើញយើង និងសាលារបស់យើងដោយវិជ្ជមាន ហើយយើងចាត់ទុកខ្លួនឯងថា ជាអ្នកមានតួនាទីសំខាន់ទាំងក្នុងសាលា និងក្នុងសហគមន៍។ គោលនេះនឹងជួយអ្នក ក្នុងដំណើរការនេះដោយផ្តល់មធ្យោបាយដើម្បីឱ្យអ្នកវាយតម្លៃសេវាអាហារ សុខភាព និងសម្ភារប្រើប្រាស់ក្នុងសាលា ដោយបង្ហាញជាដំណាក់កាល។ សម្រាប់រៀបចំកម្មវិធីអាហារសាលា និងវិធីឱ្យកុមារចូលរួមកសាងបរិស្ថានល្អ។

វាយតម្លៃស្ថានភាពបច្ចុប្បន្ន

មុនពេលបង្កើតគោលបំណង ហើយរៀបចំឱ្យមានដែនការសកម្មភាព យើងត្រូវវាយតម្លៃសេវាអាហារ និងសេវាសុខភាពនៅសាលាជាមុនសិន។ ដំណើរការនេះប្រហាក់ប្រហែលគ្នាទៅនឹងអ្វីដែលយើងបានវាយតម្លៃគោលនយោបាយសាលានៅក្នុងកម្រងសៀវភៅលេខ ១ ដែរ។ ដំណើរការមាន ៣ ដំណាក់កាល។

១. បំពេញបញ្ជីត្រួតពិនិត្យខាងក្រោម។ មិនត្រូវភ្លេចលើកទឹកចិត្តឱ្យមានការចូលរួមរបស់សមាជិកសហគមន៍ គ្រូពេទ្យ ឪពុកម្តាយ និងកុមារនៅក្នុងការវាយតម្លៃ និងដំណើរការរៀបចំដែនការសកម្មភាព។ សកម្មភាពដែលមានការចូលរួមមួយចំនួនទៀត ដែលអ្នកគួរធ្វើរួមមាន :

- សហការគ្នាដើម្បីរៀបចំបញ្ចប់គោលនយោបាយសាលា និងឯកសារវាយតម្លៃសុខភាពសហគមន៍ ដែលបានពិភាក្សានៅក្នុងកម្រងសៀវភៅលេខ ១ នៃកម្រងសៀវភៅនេះស្តីពីការបង្កើតគោលនយោបាយសុខភាពសិក្សា។
- គូរដែនទីសាលា និងសហគមន៍ ដោយមានបញ្ជាក់ច្បាស់ពីទីតាំងសេវាសុខភាព ប្រភពទឹកបង្គន់អនាម័យ និងទីតាំងដែលកុមារ និងមនុស្សពេញវ័យបត់ជើងធំ បត់ជើងតូច (នេះអាចជាផ្នែកមួយនៃការកំណត់ព័ត៌មានដែនទីសហគមន៍ ដូចបានពិភាក្សានៅក្នុងកម្រងសៀវភៅលេខ ៣)។
- និពន្ធរឿងដែលគ្មានទីបញ្ចប់ ដែលឆ្លុះបញ្ចាំងស្ថានភាពសុខភាពនៃជីវិតពិត នៅក្នុងសហគមន៍
- ឱ្យកុមារគូរ ឬសរសេរអត្ថបទដែលឆ្លុះបញ្ចាំងពី "សាលា និងសហគមន៍ស្អាតតាមការស្រមៃចង់បាន"។

២. បន្ទាប់មក រៀបសេវា និងសម្ភារទាំងនេះតាមលំដាប់អាទិភាព ដែលត្រូវការបន្ទាន់នៅក្នុងសាលា និងនៅក្នុងសហគមន៍។

៣. រៀបចំដែនការសកម្មភាពដើម្បីរៀបចំឱ្យមានសេវា និងសម្ភារទាំងនេះ ដើម្បីលើកកម្ពស់ស្ថានភាព អាហារ និងសុខភាពសហគមន៍។ អ្នកអាចប្រើប្រាស់ដំណើរការដែនការសកម្មភាពដែលបានលើកឡើង នៅក្នុងកម្រងសៀវភៅលេខ ១ និង លេខ ៣ ដើម្បីដឹកនាំធ្វើដែនការ។

តារាងបញ្ជីសម្រាប់ត្រួតពិនិត្យសេវា និងបរិក្ខារសុខភាព និងអាហារ[19]

តារាងបញ្ជីត្រួតពិនិត្យនេះត្រូវបានគេរៀបចំឡើងដើម្បីពិនិត្យមើលថាតើសេវាអាហារ និងសុខភាពរបស់សាលារៀនគ្រប់គ្រាន់ ឬមិនគ្រប់គ្រាន់។ តារាងនេះមិនមែនចប់តែប៉ុណ្ណោះទេ អ្នកអាចបន្ថែមខ្លឹមសារផ្សេងទៀត អាស្រ័យទៅលើស្ថានភាពរបស់សាលា។

តើសាលារបស់ខ្ញុំផ្តល់សេវាខាងក្រោមឬទេ? (សូមគូសសញ្ញា (X) សម្គាល់ ប្រសិនបើមាន)

_____ បង្កើត និងរក្សាឯកសារសុខភាព និងសុខភាពមាត់ធ្មេញសិស្ស

_____ ការត្រួតពិនិត្យកម្ពស់ និងទម្ងន់ដើម្បីកត់សម្គាល់កុមារដែលទទួលទានមិនគ្រប់គ្រាន់

_____ ការត្រួតពិនិត្យ និងព្យាបាលរោគការខ្វះវីតាមីន និងជាតិផ្សេងទៀត (វីតាមីនអា ដែក និងអ៊ីយ៉ូត) ដែលធ្វើឱ្យប៉ះពាល់ការសិក្សារបស់សិស្ស

_____ កម្មវិធីផ្តល់អាហារ ដូចជា អាហារសុខភាព និងអាហារសម្រន់ជាដើម

_____ ការត្រួតពិនិត្យ និងព្យាបាលប៉ារ៉ាស៊ីត ដែលបង្កឱ្យមានជំងឺនិងការខ្វះរបបអាហារ

_____ តាមដានពិនិត្យ និងព្យាបាលការអន់ថយចក្ខុ និងត្រចៀក

_____ ការបណ្តុះបណ្តាលជំនាញសង្គ្រោះបន្ទាន់

_____ អប់រំកីឡា និងកាយសម្បទាន និងថ្នាក់ទស្សនកិច្ចសិក្សាកំសាន្តសប្បាយ

_____ សេវាសម្រាប់យុវវ័យនៅក្រៅសាលា ឬសេវានៅសាលា ដែលផ្តល់ដោយបុគ្គលិកដែលបានទទួលការបណ្តុះបណ្តាលពិសេស សម្រាប់ការទប់ស្កាត់ ពិនិត្យរោគសញ្ញា ព្យាបាល និងការគាំទ្រផ្លូវចិត្ត ឬពិគ្រោះយោបល់ស្តីពីអេដស៍ ការមានផ្ទៃពោះ ការប្រើថ្នាំសន្សំញៀន និងការរួមភេទ។ល។

_____ បង្កើតប្រព័ន្ធបញ្ជូនអ្នកត្រូវការសេវាទៅឱ្យអ្នកផ្តល់សេវានៅក្នុងសហគមន៍ ដូចជា សេវាសុខាភិបាល និងសេវាផ្លូវចិត្តដើម្បីឱ្យសិស្សដឹងថា មានសេវាអ្វីខ្លះទាក់ទងនឹងសុខភាពដែលសាលាផ្តល់ និងសេវាដែលសាលាមិនផ្តល់

---

19 Adapted from: (1) UNESCO. FRESH: A Comprehensive School Health Approach to Achieve EFA. Paris, 2002 (ED-2002/WS/8 Rev.), and (2) UNICEF and the International Water and Sanitation Centre. A Manual on School Sanitation and Hygiene. Water, Environment and Sanitation Technical Guidelines Series - No. 5. New York, 1998.

_____ ទំនាក់ទំនងជាមួយយន្តការសង្គមកិច្ច និងសុខុមាលភាពសង្គម ជាពិសេសសម្រាប់កុមារកំព្រា

_____ ជៀសវាងការទុកអ្នករងរបួសដោយគ្មានការព្យាបាល

_____ សម្ភារសម្រាប់បម្រើការងារសង្គ្រោះបន្ទាន់

_____ បរិយាកាសជុំវិញ ដែលមានជាសុកភាព និងអំណោយផលដល់ការសិក្សា លេងកំសាន្ត និងកាត់បន្ថយគ្រោះថ្នាក់ និងការបៀតបៀនផ្សេងៗ

_____ កន្លែងស្នាក់អាស្រ័យសម្រាប់កុមារពិការ

_____ ពន្លឺគ្រប់គ្រាន់ទាំងក្នុង និងក្រៅថ្នាក់រៀន

_____ ការទប់ស្កាត់មិនឱ្យមានការប្រឈមមុខនឹងសម្ភារដែលអាចបង្កឱ្យមានគ្រោះថ្នាក់។

តើសាលារបស់ខ្ញុំមានសម្ភារដែលផ្តល់ : (សូមគូសសញ្ញាសម្គាល់ ប្រសិនបើមាន)

_____ ទឹកស្អាតគ្រប់គ្រាន់ និងនៅជិតៗ សម្រាប់ផឹក លាងដៃ និងលាងបង្គន់?

_____ ត្បែតពិនិត្យ និងថែទាំឧបករណ៍សម្រាប់ផ្គត់ផ្គង់ទឹក?

_____ បង្គន់អនាម័យដាច់ដោយឡែកសម្រាប់ក្មេងប្រុស និងក្មេងស្រី និងគ្រូប្រុស និងគ្រូស្រី?

_____ ចំនួនបង្គន់អនាម័យគ្រប់គ្រាន់សម្រាប់មនុស្សទាំងអស់នៅក្នុងសាលា?

_____ ការប្រើប្រាស់ទឹកដោយសន្សំសំចៃ និងមានប្រសិទ្ធភាព (ប្រើប្រាស់ប្រាស ឬក្រណាត់បន្ថែមពេលលាងដៃ)?

_____ ធ្វើការសំអាតបង្គន់ និងសម្ភារប្រើប្រាស់នៅក្នុងបង្គន់ឱ្យបានស្អាតបាត និងឱ្យងាត់?

_____ ប្រព័ន្ធបង្ហូរទឹកកខ្វក់ត្រឹមត្រូវ?

_____ ចោលលាមក និងកាកសំណល់នានា ដោយសុវត្ថិភាព មានអនាម័យ និងប្រសិទ្ធភាពខ្ពស់?

_____ យន្តការប្រើប្រាស់វត្ថុកែច្នៃ (ប្រើរបស់តៗគ្នាបើអាចធ្វើបាន)?

កម្មវិធីអាហារ និងអាហារូបត្ថម្ភក្នុងសាលា : ជួយកុមារដែលពុំមានអាហារគ្រប់គ្រាន់នៅផ្ទះ

កុមារដែលឃ្លានមិនអាចរៀនកើតទេ។ នៅពេលដែលកុមារមិនមានអាហារគ្រប់គ្រាន់នៅផ្ទះ (ប្រសិនបើគេមានផ្ទះ) សាលារបស់អ្នកអាចជាកន្លែងដ៏សំខាន់ក្នុងការផ្តល់អាហារបន្ថែមដល់សិស្ស ព្រោះកុមារដែលមានជំងឺដោយការខ្វះអាហារត្រូវបានគេធានាថា យ៉ាងហោចណាស់ក៏ត្រូវទទួលអាហារ ១ ពេលនៅសាលាដែរក្នុង ១ ថ្ងៃ។ អាហារនេះមានសារៈសំខាន់ណាស់សម្រាប់កុមារដែលត្រូវធ្វើការផង រៀនផង ដែលរស់នៅតាមផ្លូវ ដែលគ្រួសារ គេមានបញ្ហាជីវភាពដោយសារមេរោគអេដស៍/ជំងឺអេដស៍។

លើសពីនេះទៀត ផ្តល់អាហារមានជីវជាតិដល់កុមារនៅសាលា គឺវិធីងាយស្រួល តែមានប្រសិទ្ធភាព ដើម្បីលើកកម្ពស់អត្រាអក្ខរកម្ម និងជួយកុមារឱ្យរួចផុតពីភាពក្រីក្រ។ ពេលអាហារសាលាត្រូវផ្តល់ឱ្យ កុមារគេសង្កេតឃើញអត្រាចុះឈ្មោះ និងអត្រាចូលរៀនមានការកើនឡើងគួរឱ្យកត់សម្គាល់។ ក្នុងវប្បធម៌បុរាណដែលក្មេងស្រីត្រូវរក្សាទុកឱ្យនៅផ្ទះ ការផ្តល់អាហារសាលា និង"របបអាហារសម្រាប់យកទៅផ្ទះ" អាចបញ្ចុះបញ្ចូលឪពុកម្តាយឱ្យបញ្ជូនកូនស្រីទៅសាលា។ ក្នុងករណីបន្ទាន់។ ការផ្តល់អាហារសាលា ជាប្រភពដ៏សំខាន់នៃអាហារមានជីវជាតិសម្រាប់កុមារ និងធានាមិនឱ្យមានការរំខានដល់ការសិក្សារបស់កុមារ[20]។

អាហារសាលាធានាថាកុមារទាំងអស់ទទួលអាហារមានជីវជាតិគ្រប់គ្រាន់ ដែលកុមារត្រូវការសម្រាប់ការធំធាត់ និងលូតលាស់ប្រកបដោយសុខភាព។ អាហារទាំងនេះរួមមាន ប្លែតេអ៊ីន ខ្លាញ់ កាបូអ៊ីដ្រាត និងអាហារមានវីតាមីនផ្សេងទៀត ដូចជា វីតាមីន A ដែក និងអ៊ីយ៉ូត។ ជីវជាតិ និង វីតាមីនទាំងអស់នេះធ្វើឱ្យប៉ះពាល់ដល់ការលូតលាស់របស់កុមារទាំងរាងកាយ និងបញ្ញា ប្រសិនបើគ្មានអាហារទាំងនេះផ្តល់ឱ្យកុមារទេ។

អនុវត្តកម្មវិធីអាហារសាលាសម្រាប់សិស្សត្រូវធ្វើឡើងតាម៥ដំណាក់កាល។ ដូចសេវាផ្សេងទៀតដែរ ការគាំទ្រ និងចូលរួមពីសំណាក់មាតាបិតាសិស្ស និងសហគមន៍ នឹងជួយបង្កើនធនធានដែលចាំបាច់សម្រាប់កម្មវិធីនេះបានទទួលជោគជ័យ។

ដំណាក់កាលទី ១: *បង្កើតដៃគូជាមួយអ្នកផ្តល់សេវាសុខភាពមូលដ្ឋាន ដែលមានជំនាញគ្រប់គ្រាន់ដែលអាចកំណត់សម្គាល់សិស្សដែលខ្វះវីតាមីន និងប្លែតេអ៊ីន (តាមរយៈការវាស់កម្ពស់ និងថ្លឹងទម្ងន់)។ ប្រសិនបើ សាលារបស់អ្នកមានគ្រូពេទ្យ គាត់អាចបំពេញការងារនេះបាន។*

---

20 World Food Programme (2002) Fact Sheet: School Feeding. Rome.

ដំណាក់កាលទី ២ : នៅខែទី ១ នៃឆ្នាំសិក្សា វាយតម្លៃសុខភាពកុមារទាំងអស់ ហើយកត់ត្រាអ្នកដែលមានជំងឺខ្វះជីវជាតិក្នុងកម្មវិធីទទួលការថែទាំ ក្រោមការតាមដានរបស់អ្នកផ្តល់សេវាសុខភាពបឋម។ ទម្ងន់របស់កុមារនីមួយៗប្រាប់អ្នកថា តើកុមារទទួលអាហារគ្រប់គ្រាន់ ឬមិនគ្រប់គ្រាន់ (ទម្ងន់ស្រាលជាងទម្ងន់មធ្យមរបស់កុមារដែលមានអាយុប្រហែលគ្នា) ហើយកម្ពស់នីមួយៗប្រាប់ថា តើកុមារមានជំងឺក្រិន ឬមិនមាន (ទម្ងន់ស្រាលជាងទម្ងន់មធ្យមរបស់កុមារដែលមានអាយុប្រហែលគ្នាច្រើន)។ អាយុ និងទម្ងន់របស់កុមារ គួរលូតលាស់ទៅតាមអាយុ ប្រសិនបើកុមារមិនមានបញ្ហាអ្វីទេ។ ដូចនេះ យើងត្រូវផ្តល់អាហារតាមតម្រូវការរបស់កុមារម្នាក់ៗ។ កុមារដែលខ្វះវីតាមីន A អាចទទួលថ្នាំគ្រាប់ដើម្បីជំនួយបន្ថែម ហើយអាហារត្រូវសម្បូរបន្ថែមស្លឹកពណ៌បៃតង និងផ្លែឈើពណ៌លឿង (ដូចជា ស្វាយ និងល្អុង) និងក្រូច។ សម្រាប់កុមារដែលខ្វះជាតិអ៊ីយ៉ូត អាចលេបថ្នាំគ្រាប់ជាតិអ៊ីយ៉ូត ឬបរិភោគអំបិលអ៊ីយ៉ូតក្នុងអាហារ។

ដំណាក់កាលទី ៣ : ផ្អែកលើព័ត៌មានដែលប្រមូលបានក្នុងដំណាក់កាលទី ២ ត្រូវសម្រេចចិត្តអំពីប្រភេទអាហារដែលសាលាត្រូវផ្តល់បន្ថែម ដើម្បីឆ្លើយតបនឹងតម្រូវការរបស់កុមារ។ សុំឱ្យគ្រូពេទ្យជំនាញខាងអាហារជួយធ្វើផែនការអាហារប្រចាំសប្តាហ៍។ នៅពេលនេះ ចាំបាច់ត្រូវមានការចូលរួមរបស់គ្រួសារ និងអ្នកដឹកនាំសហគមន៍ ព្រោះថា អ្នកដឹកនាំសហគមន៍ អាចជាប្រភពនៃការផ្តល់ជំនួយសម្រាប់បង្កើតកម្មវិធីអាហារសាលា។ ឧទាហរណ៍ អ្នកដឹកនាំសហគមន៍ អាចរៀបចំអាហារដ្ឋានសម្រាប់ផ្តត់ផ្គង់អាហារថ្ងៃត្រង់ដល់សិស្ស។ អ្នកដឹកនាំសហគមន៍អាចជួយរៀបចំសួនច្បារសាលា ឬអាចដាក់វេនគ្នាជួយរៀបចំអាហារថ្ងៃត្រង់ ឬអាហារសម្រន់សម្រាប់កុមារ។

ដំណាក់កាលទី ៤ : បន្ថែមលើការបណ្តុះបណ្តាលជំនាញ ត្រូវបង្រៀនកុមារអំពីរបបអាហារដែលត្រូវបរិភោគដើម្បីឱ្យមានសុខភាពល្អ ហើយត្រូវចាត់ទុកថា ការបង្រៀនបែបនេះ ជាផ្នែកមួយនៃកម្មវិធីអប់រំសុខភាព។ ឧទាហរណ៍ កុមារអាចពិភាក្សាអំពី :

- តើកុមារមានស្គាល់កុមារផ្សេងទៀតដែលស្គមខុសធម្មតា ហើយហូបចុកមិនគ្រប់គ្រាន់ឬទេ?
- តើការស្គមខុសពីធម្មតា បណ្តាលមកពីមូលហេតុអ្វី?

មិនត្រូវភ្លេចលើកទឹកចិត្តកុមារដែលមានអាយុច្រើនជាងឱ្យពិភាក្សាអំពីមូលហេតុកាន់តែស៊ីជម្រៅ ដូចជា ហេតុអ្វីបានជាកុមារម្នាក់នេះមានជំងឺខ្វះជីវជាតិ? ហេតុអ្វីបានជាកុមារខ្វះអាហារ? ប្រសិនបើចម្លើយថា មកពី "គ្រួសាររបស់កុមារក្រពេក" អញ្ចឹងត្រូវពិភាក្សាបន្តទៀតថា :

- ហេតុអ្វីបានជាគ្រួសារកុមារក្រីក្រ?
- តើត្រូវធ្វើយ៉ាងណាដើម្បីជួយកុមារដែលមានជំងឺខ្វះជីវជាតិ?
- តើខ្ញុំត្រូវធ្វើយ៉ាងណាដើម្បីជៀសវាងពីជំងឺខ្វះជីវជាតិ?

កុមារអាចរួមចំណែកក្នុងការតាមដានសុខភាពផ្ទាល់ខ្លួន និងក្នុងការរៀបចំកម្មវិធីអាហារសាលា។ ឧទាហរណ៍ ក្នុងគម្រោងកុមារនៅប្រទេសថៃ កុមារត្រូវបានលើកទឹកចិត្តឱ្យក្លាយជា "អ្នកតាមដានការរីកចម្រើនរបស់កុមារ" ដែលវាស់វែង និងតាមដានកម្ពស់និងទម្ងន់កុមារ ហើយបន្ទាប់មកកត់សម្គាល់វិធី ដែលអាចលើកកម្ពស់សុខភាពផ្ទាល់ខ្លួន និងសុខភាពមិត្តភក្តិ។ ក្រុមកុមារនេះក៏ត្រូវបានស្គាល់ជា "អ្នកជំរុញឱ្យមានការទទួលទានអ៊ីយ៉ូត" ដែលជាអ្នកកត់សម្គាល់អាហារដែលមានជាតិអ៊ីយ៉ូតច្រើន និងអាហារដែលមិនមានជាតិអ៊ីយ៉ូត។ ពួកគេក៏ពិភាក្សាអំពីផលប៉ះពាល់នៃការខ្វះជាតិអ៊ីយ៉ូតមកលើគ្រួសារ និងការពិនិត្យមើលជាតិអ៊ីយ៉ូតក្នុងអំបិលដែលគ្រួសារប្រើប្រាស់ដែរ។ ចំណេះដឹងរបស់គេ ក៏អាចប្រើប្រាស់សម្រាប់លើកកម្ពស់កម្មវិធីអាហារសាលាបានដែរ[21]។

ដំណាក់កាលទី ៥ : ការតាមដានទៅដំណាច់ឆ្នាំសិក្សា ត្រូវធ្វើដំណាក់កាលទី២ ឡើងវិញ ដើម្បីពិនិត្យមើលថា តើសុខភាពកុមារមានការរីកចម្រើនឬមិនមាន? នេះជាដំណាក់កាលសំខាន់សម្រាប់ធ្វើផែនការអាហាររបស់សាលាសម្រាប់ឆ្នាំបន្ទាប់។ ជាថ្មីម្តងទៀត ឪពុកម្តាយ និងថ្នាក់ដឹកនាំសហគមន៍ ត្រូវតែចូលរួមយ៉ាងសកម្មក្នុងដំណើរការនេះ ហើយត្រូវលើកទឹកចិត្តពួកគេឱ្យផ្តល់អាហារឱ្យបានត្រប់គ្រាន់ដល់កូននៅអំឡុងពេលឈប់សម្រាក។

ទោះជាយុទ្ធសាស្ត្រទាំងនេះត្រូវបានលើកយកមករៀបរាប់នៅពេលនេះសម្រាប់លើកកម្ពស់សុខភាពអាហាររបស់កុមារ ដំណើរការប្រហាក់ប្រហែលគ្នាអាចយកទៅប្រើដើម្បីពិនិត្យ និងធ្វើសកម្មភាពលើបញ្ហាសុខភាពផ្សេងទៀត ដូចជាសុខភាពមាត់ធ្មេញ ជំងឺឆ្លងចាំរាស៊ីត និងតាមដានការរីកចម្រើននៃវិធានការទាំងនេះ។

គំនិតសម្រាប់បង្កើតបរិយាកាសសាលាស្អាត

ដៃស្អាត និងទឹកស្អាតត្រូវតែធ្វើឡើងនៅពេលតែមួយ ដើម្បីទប់ស្កាត់ជំងឺក្នុងសាលា និងនៅផ្ទះ។ ទោះបីជាទម្លាប់ធម្មតាក៏ដោយ ទឹកស្អាត និងដៃស្អាត ជាបញ្ហាមួយដែលសាលាជាច្រើនពិបាកដោះស្រាយ។ ជួនកាល កុមារមិនមានចិត្តចង់លាងដៃឱ្យស្អាត ប៉ុន្តែជាញឹកញាប់ លោកគ្រូ អ្នកគ្រូមិនដឹងថា ត្រូវបង្រៀនមុខវិជ្ជាអនាម័យ និងសុខភាពដោយរបៀបណា ដើម្បីឱ្យមានសុវត្ថិភាព និងការកៀរគរធនធានចាំបាច់ –ជាញឹកញាប់ពីសហគមន៍– ដើម្បីសង់បង្គន់មានសុវត្ថិភាព និងមានអនាម័យ។ យុទ្ធសាស្ត្រមានប្រសិទ្ធភាពត្រូវបានគេប្រើប្រាស់សព្វថ្ងៃនេះ គឺ វិធីអប់រំអំពីទឹកស្អាត និងអនាម័យរវាងកុមារ និងកុមារ និង រវាងកុមារ និងមនុស្សចាស់។ ខាងក្រោមនេះ ជាសកម្មភាពមួយចំនួន ដែលអ្នកអាចពិចារណាប្រើប្រាស់ ដើម្បីលើកកម្ពស់សុខភាព និងសុវត្ថិភាពទឹកស្អាតក្នុងសាលា។

---

21 CHILD Project Update. Promoting Children's Participation.
http://www.inmu.mahidol.ac.th/CHILD

គំរូកិច្ចតែងការ ៖ អំពីជំងឺរាក

វត្ថុបំណង ៖ *ជួយសិស្សឱ្យពន្យល់មូលហេតុនៃជំងឺរាក*

សម្ភារជំនួយ ៖ *រូប (បង្ហាញគ្មានគម្រប រុយ អាហារដែលមានរុយរោម កុមារទទួលទានអាហារ ឈឺពោះ រាករូសញើកញាប់)។*

សកម្មភាពរៀន/បង្រៀន

១. ឱ្យកុមារពិនិត្យមើលជាក្រុម ហើយឆ្លើយសំណួរខាងក្រោម។

ក. តើអ្នកមើលឃើញអ្វីខ្លះ?
ខ. តើមានអ្វីកើតឡើងចំពោះកុមារនៅក្នុងរូប? ហេតុអ្វី?

២. និយាយច្រាប់សិស្សថា កុមារនៅក្នុងរូបកំពុងឈឺពោះ រាករូស ហើយក្អួតចង្អោរម្តងម្កាលទៀត។ និយាយច្រាប់សិស្សថា នេះគេហៅថា "ជំងឺរាក"។

៣. ពន្យល់ច្រាប់សិស្សបន្តទៀតថា ជំងឺរាកបណ្តាលមកពី ៖

ក. ទទួលទានអាហារដោយប្រើដៃមិនស្អាត
ខ. ទទួលទានអាហារដែលគ្មានអនាម័យត្រឹមត្រូវ
គ. ទទួលទានអាហារដែលមានរុយរោម
ឃ. ទទួលទានអាហារដែលមិនស្រស់ ឬសល់យូរ
ង. ផឹកទឹកមិនស្អាត

ប្រភព ៖ Zarchin J, Aung TM and Jenkins J. (2001) Skills-based Health Education and Life Skills – The Myanmar Experience. SHAPE Project, UNICEF Country Office for Myanmar.



សកម្មភាពអនុវត្ត ៖ ឱ្យកុមារចូលរួមក្នុងការអប់រំអនាម័យ

ជំងឺរាក ព្រូន អាសន្នរោគ គ្រុនពោះវៀន ស្វិតដៃជើង និងជំងឺមួយចំនួនទៀត គឺបណ្តាលមកពីមេរោគ។ មេរោគទាំងនេះ អាចចម្លងពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀត តាមការចាប់ដៃ តាមធូលី អាហារ និងទឹក។ ខាងក្រោមនេះ ជាសកម្មភាពមួយចំនួន ដែលអ្នកអាចបញ្ចូលក្នុងកម្មវិធីអប់រំសុខភាពបឋមដើម្បីលើកកម្ពស់ និងកែលំអទម្លាប់របស់កុមារ ដែលនាំឱ្យមានសុខភាពល្អ[22]។

22 The source for this activity is: Baily D, Hawes H and Bonati B. (1994) Child-to-Child: A Resource Book. Part 2: The Child-to-Child Activity Sheets. London: The Child-to-Child Trust.

ពិភាក្សាតាមក្រុម : *ហេតុអ្វីបានជាកុមារមួយចំនួន ជាពិសេសកុមារី មិនចង់ប្រើបង្គន់? តើមានកុមារ ដែលមិនចង់ មកសាលាដោយសារ មិនមានបង្គន់សមរម្យដែរឬទេ? ពិភាក្សារកហេតុផល និងរកមធ្យោបាយបំផុសឱ្យសិស្សប្រើបង្គន់។ បញ្ហាបង្គន់នេះ គឺជាឧទាហរណ៍ដ៏សំខាន់មួយ បង្ហាញពីការខ្វះបរិក្ខារអនាម័យសម្រាប់កុមារី គឺជាដើមហេតុដែលរារាំង មិនឱ្យកុមារីចង់មកសាលារៀន ជាពិសេស នៅអាស៊ីខាងត្បូង) បើសិនជាមានបង្គន់ ត្រូវដាច់ដោយឡែកពីបង្គន់សម្រាប់កុមារា។ កុមារីមិនចង់ប្រើបង្គន់រួមជាមួយកុមារាទេ ដោយហេតុផលថា កុមារីត្រូវតែសុភាពរាបសារ និងសុវត្ថិភាព)។ តាមរបាយការណ៍របស់ប្រទេសមួយនៅអាស៊ីខាងត្បូងបង្ហាញថា កុមារីមានបញ្ហារលាកតំរងនោមច្រើន ដោយសារមិនបានប្រើបង្គន់ក្នុងអំឡុងពេលពេញមួយពេលរៀន។*

ពិភាក្សាតាមក្រុម : *និយាយអំពីការបង្រៀនក្មេង។ ទាំងប្រុស ទាំងស្រី ឱ្យប្រើច្រាស់បង្គន់ និងរក្សាបង្គន់ឱ្យស្អាតជានិច្ច ហើយបង្រៀនអំពីសារៈសំខាន់នៃការសំអាតបង្គន់។ ក្មេងដែលមានអាយុច្រើនជាងអាចពិភាក្សាពីវិធីដែលមេរោគអាចបម្លងពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀត។ ឧទាហរណ៍ យកក្រដាស/កំណាត់មកកិតលាមក ហើយចោះចោលពាសវាលពាសកាល ឬទុកកុមារឱ្យស្រាតហើយដាក់កុមារឱ្យលេងនៅលើដីជាដើម។*

- **សម្តែងស្តីពីទម្លាប់ដែលមានអនាម័យល្អ :** *ទម្លាប់ល្អនៅសាលា ដូចជា ប្រើបង្គន់អនាម័យ រក្សាបង្គន់ស្អាត លាងដៃស្អាតបន្ទាប់ពីបន្ទោបង់ និងមុនពេលបរិភោគអាហារ។ លើកទឹកចិត្តកុមារឱ្យសម្តែងពីរបៀបដែលគេរក្សាទម្លាប់ដែលមានអនាម័យល្អ។*
- **រឿងនិទាន :** *ឱ្យកុមារសរសេររឿងនិទានអំពីពេល ហេតុផល និងរបៀបនៃទម្លាប់ដែលមានអនាម័យស្អាតបាត។*
- **ការងារជាក្រុម :** *បែងចែកក្រុមតាមដានពិនិត្យបង្គន់អនាម័យ។ សមាជិកក្នុងក្រុម ត្រូវពិនិត្យថាមាត់បង្គន់ត្រូវតែស្អាត។ ប្រសិនបើមិនស្អាត សមាជិកក្នុងក្រុមត្រូវរាយការណ៍ជូនគ្រូ ឬគ្រូពេទ្យដើម្បីសុំយោបល់ពីរបៀបរក្សាបង្គន់ឱ្យស្អាតជានិច្ច។ សកម្មភាពនេះនឹងជួយសិស្សឱ្យចេះអភិវឌ្ឍជំនាញ បំណិនជីវិត ដូចជាការសម្រេចចិត្ត ការច្រាស្រ៊ែយទាក់ទងគ្នា និងទំនាក់ទំនងរវាងបុគ្គល។*
- **ការបង្ហាញ (សាលា ឬសហគមន៍)** *កុមារដែលមានអាយុច្រើនអាចសង់បង្គន់ខ្នាតតូច ក្នុងទីធ្លាសាលាដើម្បីធ្វើជាគំរូដោយជីករណ្តៅ និងចាក់ពុម្ពបានបង្គន់។ គ្រូឬមនុស្ស ពេញវ័យណាម្នាក់ទៀតត្រូវតាមដានកុមារដែលសង់បង្គន់នេះ។ ឪពុកម្តាយអាចជួយជាសម្ភារ ដូចជា ឡាច់ ស៊ីម៉ង់ត៍ ឈើ។ល។ គ្រូអាចបែងចែកកុមារជាក្រុមតាមក្រុមកុមារដែលមកពីភូមិ ជាមួយគ្នា។ ក្នុងថ្នាក់កុមារអាចធ្វើផែនការដើម្បីជួយគ្នាទៅវិញទៅមក ក្នុងការសង់បង្គន់ខ្នាតតូចសម្រាប់កុមារនៅតាមផ្ទះ។ ត្រូវរៀបចំតារាងបង្ហាញចំនួនបង្គន់នៅតាមគ្រួសារ ដែលមានក្មេងតូច និងបានសង់បង្គន់ហើយ ដោយការដាក់សញ្ញាសម្គាល់មួយ និងសញ្ញាសម្គាល់មួយទៀតសម្រាប់កុមារដែលបានប្រើច្រាស់បង្គន់។ តារាងនេះត្រូវរៀបចំដាច់គ្នាសម្រាប់ក្មេង ប្រុស និងក្មេងស្រី។*

- **តាមដានការសិក្សា :** *ការពិភាក្សាជាក្រុម ឬតាមរយៈការសរសេរតែងសេចក្តី ឱ្យកុមារពន្យល់ :*
  - ✓ *តើជំងឺរាកបណ្តាលមកពីអ្វី ហើយតើយើងត្រូវជៀសវាងជំងឺរាកដោយរបៀបណា?*
  - ✓ *ហេតុអ្វីគេត្រូវប្រែងប្រែយ័ត្នអំពីលាមករបស់កុមារ?*
  - ✓ *តើទម្លាប់អនាម័យល្អមានអ្វីខ្លះ ដែលអាចទប់ស្កាត់ការរាលដាលមេរោគ?*
  - ✓ *តើសាលាមានបង្គន់អនាម័យ និងកន្លែងសម្រាប់លាងដៃឬទេ?*
  - ✓ *តើមានគ្រួសារប៉ុន្មានដែលមានបង្គន់ដាច់ដោយឡែកសម្រាប់កុមារតូចៗបន្ទោបង់?*
  - ✓ *តើកុមារបានចូលរួមក្នុងការធ្វើបង្គន់អនាម័យអ្វីខ្លះ?*
  - ✓ *តើកុមារដែលមានអាយុច្រើនជួយប្អូនប្រុស/ស្រីគេឱ្យមានទម្លាប់មានអនាម័យល្អអ្វីខ្លះ? ឱ្យគេរៀបរាប់នូវអ្វីដែលគេបានធ្វើ។*
- **លើកទឹកចិត្តឱ្យមានការចូលរួមពីសហគមន៍ :** *គ្រូ និងគ្រូពេទ្យត្រូវសង្កត់ធ្ងន់ពីសារៈសំខាន់នៃការប្រើប្រាស់ និងរក្សាបង្គន់អនាម័យឱ្យស្អាត ដើម្បីជៀសវាងជំងឺរាករូស។ មេរៀនវិទ្យាសាស្ត្រអនុវត្តអាចយកមកបង្រៀនបន្ថែមអំពីការឆ្លងរាលដាលនៃមេរោគរាករុះ ឧទាហរណ៍ តើមេរោគគឺជាអ្វី? តើមេរោគឆ្លងរាលដាលដោយរបៀបណា? គ្រូ និងឪពុកម្តាយអាចសហការជាមួយកូនធំៗដើម្បីរៀបចំផែនការសង់បង្គន់តូចៗសម្រាប់កុមារ។*
- **លើកទឹកចិត្តឱ្យកុមារចូលរួម :** *កុមារនៅសាលា និងតាមរយៈក្លឹប ក្រុមសាសនា អាចផ្សព្វផ្សាយគំនិតស្តីអំពីអនាម័យល្អ ម្ហូបអាហារមានជីវជាតិ ទឹកស្អាត និងបរិស្ថានស្អាត តាមរយៈការប្រតិបត្តិល្អរបស់មនុស្សគ្រប់រូប។ គ្រូ និងមាតាបិតាអាចបង្រៀនក្មេងៗឱ្យចេះប្រើបង្គន់ និងរក្សាខ្លួនច្រាណស្អាតបាត ហើយសង់បង្គន់ខ្នាតតូចសម្រាប់កុមារប្រសិនបើត្រូវការ។*



សកម្មភាពអនុវត្ត : ឱ្យកុមារចូលរួមនៅក្នុងសកម្មភាពទឹកស្អាត

នៅក្នុងការបង្រៀនកុមារអំពីទឹកស្អាត និងអនាម័យ គ្រូត្រូវនិយាយច្រាប់សិស្សថា ទឹកមានសារៈសំខាន់ណាស់សម្រាប់ជីវិតរស់នៅរបស់សត្វលោក ប៉ុន្តែទឹកខ្វក់អាចធ្វើឱ្យយើងឈឺ។ យើងត្រូវមានការប្រែងប្រែយ័ត្នក្នុងការរក្សាទឹកឱ្យស្អាត និងមានអនាម័យជាពិសេសនៅពេលយើងដងទឹកពីអណ្តូង ពេលយើងត្រូវរក្សាទឹកទុក និងពេលយើងប្រើប្រាស់វា។ ខាងក្រោមនេះគឺជាសកម្មភាពមួយចំនួនដែលអ្នកអាចបញ្ចូលទៅក្នុងកម្មវិធីអប់រំជំនាញសុខភាពមូលដ្ឋាន ដើម្បីបង្កើនសុវត្ថិភាពក្នុងការប្រើប្រាស់ទឹក[23]។

---

23 The source for this activity is: Baily D, Hawes H and Bonati B. (1994) Child-to-Child: A Resource Book. Part 2: The Child-to-Child Activity Sheets. London: The Child-to-Child Trust.

- **កុមារអាចពិភាក្សា :** ហេតុអ្វីបានជាទឹកមានសារៈសំខាន់? កត់ត្រាពីការប្រើប្រាស់ទឹកនៅផ្ទះ នៅក្នុងសហគមន៍ នៅក្នុងមន្ទីរពេទ្យ នៅកសិដ្ឋាន និងនៅក្នុងប្រទេសទាំងមូល។ តើគ្រប់សកម្មភាពទាំងអស់ដែលយើងបានកត់ត្រាសុទ្ធតែត្រូវការទឹកស្អាតឬទេ? តើទឹកដែលផ្លា និងមានរសជាតិផ្អាញ់ សុទ្ធតែជាទឹកដែលមានសុវត្ថិភាពមែនឬទេ? (ចម្លើយគឺទេ។ តើមូលហេតុអ្វី?) តើមេរោគចម្លងទៅក្នុងទឹកដោយរបៀបណា? តើទឹកអាចជួយយើងដោយរបៀបណា? តើទឹកមានគ្រោះថ្នាក់ដល់យើងដោយរបៀបណា? តើកុមារមួយចំនួនដែលតែងឈឺពោះ និងមានជំងឺរាកដែរឬទេ? តើមានសមាជិកក្នុងគ្រួសារណាទៀតដែលឈឺពោះ មានជំងឺរាកញឹកញាប់ដូចកុមារឬទេ? ចំណែកទារកវិញយ៉ាងណាដែរ? តើអ្នកគិតថាអ្វីទៅដែលបណ្តាលឱ្យពួកគេឈឺពោះ និងរាក?រួស

- **ការងារជាក្រុមនៅក្នុងសហគមន៍ :** ក្នុងក្រុមតូចៗ ឱ្យកុមារទៅកប្រែភពទឹកនៅក្នុង សហគមន៍ ហើយគូរដែនទីបង្ហាញទឹកន្លែង (ប្រើប្រាស់ដែនទីសហគមន៍ដែលអ្នកបានរៀបចំនៅក្នុងកម្រងឯកសារលេខ៣)។ កត់សម្គាល់មើលថាតើប្រែភពមួយណាដែលមានទឹកស្អាត និងថែរក្សាបានល្អ និងប្រែភពមួយណាមានទឹកមិនស្អាត ឬថែទាំមិនបានល្អ។ ដាក់កំណត់សម្គាល់នៅលើដែនទី។ ប្រសិនបើប្រែភពមិនស្អាត តើវាបណ្តាលមកពីមូលហេតុអ្វី? ពិនិត្យមើលថា តើពលរដ្ឋនៅក្នុងសហគមន៍ដងទឹកពីណា តើគេយកទឹកមកផ្ទះដោយរបៀបណា? តើគេរក្សាទឹកទុកបានស្អាតឬទេ? ពិភាក្សានូវអ្វីដែលអ្នកបានកត់សម្គាល់ជាមួយសិស្សផ្សេងទៀត។

- **ការងារក្រុមនៅសាលា :** កត់ត្រាជំងឺទាំងឡាយដែលបណ្តាលមកពីទឹកមិនស្អាត ហើយពិភាក្សាគ្នាបន្តែមអំពីបញ្ហាទាំងនេះ។ ពិនិត្យមើលប្រែភពទឹកនៅក្នុងសាលា។ តើសាលាបានទឹកមកពីណា? តើបង្គន់នៅក្បែរប្រែភពទឹកឬទេ? តើគេលាងឧបករណ៍ដាក់ទឹកញឹកញាប់ឬទេ? តើគេមានប្រើកែវឬទេ? តើគេលាងកែវឬទេ បន្ទាប់ពីប្រើហើយម្តងៗ? តើមានកន្លែងលាងដៃឬទេ មុនពេលទទួលទានអាហារ? តើកុមារតែងតែប្រើកន្លែងលាងដៃនោះឬទេ?

- **ការងារម្នាក់ៗតាមផ្ទះ :** ឱ្យកុមារកត់ត្រានូវរបស់របរទាំងឡាយដែលប្រើសម្រាប់ដង/ដាក់ទឹកនៅផ្ទះរបស់គេ។ កត់ត្រាអ្នកដែលធ្លាប់មានជំងឺដោយសារទឹកមិនស្អាត។ តើនរណាជាអ្នករកទឹកសម្រាប់ប្រើប្រាស់នៅក្នុងគ្រួសារ? តើអ្នកអាចជួយបានឬទេ? តើអ្នកណាជាអ្នករក្សាទឹកទុកឱ្យស្អាត? តើរបស់របរសម្រាប់រក្សាទឹកមានគម្រប និងដៃសម្រាប់យួរឬទេ? តើពួកគេលាងដៃត្រឹមត្រូវ បន្ទាប់ពីបន្ទោបង់ហើយ និងមុនពេលទទួលទាន? សូមយោបល់ពីគ្រូពេទ្យដើម្បីធ្វើឱ្យទឹកយើងប្រើប្រាស់ស្អាត និងមានសុវត្ថិភាព។

កុមារអាចជួយ

កុមារអាចជួយរក្សាទឹកឱ្យស្អាត។ ពួកគេអាចរកសកម្មភាពដែលសមស្របនឹងអាយុរបស់គេ ហើយអាចធ្វើ ដោយខ្លួនគេ ឬជាក្រុម។ ខាងក្រោមនេះគឺជាសកម្មភាពមួយចំនួនដែលកុមារអាចធ្វើបាន។

- **នៅកន្លែងប្រភពទឹក :** *កុមារអាចជួយរក្សាប្រភពទឹកឱ្យស្អាត។ ពន្យល់កុមារទាំងអស់ថា ពួកគេមិនត្រូវបន្ទោបង់នៅទីជិតប្រភពទឹកនោះទេ។ ប្រមូលសំរាមដែលនៅក្បែរៗប្រភពទឹក ហើយទៅដុតចោលនៅទីធ្លាយ។ មិនត្រូវឱ្យមានសត្វពាហន:នៅក្បែរប្រភពទឹកទេ។ នៅកន្លែងដែលមានអណ្តូងបូម ត្រូវបង្ហាត់បង្រៀនប្រជាជនពីរបៀបប្រើ និងថែរក្សាវា។ លើសពីនេះ កុមារអាចជួយដងទឹកសម្រាប់មនុស្សចាស់ជរាទៀតផង។ មិនត្រូវភ្លេចបិទរ៉ូប៊ីនេទឹកទេ បន្ទាប់ពីប្រើច្រាស់រួចហើយ។ នៅកន្លែងដែលមានអណ្តូង ទីជុំវិញអណ្តូង ត្រូវតែស្អាតជានិច្ច។ ធ្វើទម្រសម្រាប់ ញ្ជួរធុងដងទឹកពីអណ្តូង។ មិនត្រូវដាក់ធុងសម្រាប់ដងទឹកពីអណ្តូងផ្ទាល់ដីទេ ហើយប្រជាជនមិនត្រូវប្រើធុងរបស់គេសម្រាប់ដងទឹកពីអណ្តូងទេ។ ប្រសិនបើអណ្តូងពុំមានគម្របទេ គេត្រូវជួយគ្នាធ្វើ គម្របអណ្តូង។ ប្រសិនបើអណ្តូងស្ងួប់ គេត្រូវប្រើច្រាស់វាដោយប្រុងប្រយ័ត្ន។ គេត្រូវសង្កត់បូមខ្លាំងៗពេកទេ ហើយគេមិនត្រូវបូមទឹកគ្រាន់ជាការលេងកំសាន្តនោះឡើយ។*

- **ពេលដងទឹក ហើយយកមកផ្ទះ :** *ត្រូវពន្យល់ពួកគេឱ្យរក្សាប្រដាប់ដង និងដាក់ទឹកឱ្យស្អាតជានិច្ច។ ប្រសិនបើទឹកដងចេញពីប្រភពមិនស្អាត ពន្យល់ច្បាប់ប្រជាជនថាគេត្រូវចម្រោះ ឬដាំ ទឹកឱ្យពុះសិន មុននឹងប្រើច្រាស់។*

- **នៅផ្ទះ :** *ពន្យល់ក្មេងតូចៗថា ពួកគេមិនត្រូវយកដៃ របស់លេង ឬអ្វីផ្សេងទៀតក្រៅពីដុំលទៅដាក់ក្នុងទឹកទេ។ រក្សាឧបករណ៍ដាក់ទឹកឱ្យស្អាតជានិច្ច ដោយការលាងសំអាតឱ្យបានទៀងទាត់ និងបិទជិតជានិច្ច។ ពន្យល់ក្មេងតូចៗឱ្យប្រើច្រាស់ដុំលឱ្យបានត្រឹមត្រូវដើម្បីដងទឹកចេញពី កន្លែងដាក់ទឹក។ ច្រាប់ឱ្យគ្របគម្របឱ្យបានត្រឹមត្រូវបន្ទាប់ពីដងទឹកប្រើហើយ។ មិនត្រូវដាក់គម្របលើដីទេ។ មិនត្រូវឱ្យទឹកកំពប់លើដីទេ។ ត្រូវដាក់ដុំល ឬរបស់ផ្សេងសម្រាប់ដងទឹកនៅកន្លែងស្អាត។ មិនត្រូវរក្សាវានៅក្នុងទឹកនោះទេ។ ដាក់ឱ្យជុតពីសត្វពាហន: និងមិនត្រូវដាក់លើ ដីឡើយ។*

ការតាមដាន

បន្ទាប់ពីច្រើនសប្តាហ៍ ឬច្រើនខែមក គេអាចឱ្យកុមារពិភាក្សាគ្នាអំពីអ្វីដែលនៅចងចាំ អ្វីដែលបានធ្វើ ដើម្បីរក្សាទឹកឱ្យស្អាត និងមានសុវត្ថិភាព ហើយអ្វីដែលត្រូវធ្វើបន្តទៀត។

តើមានកន្លែងដែលអាចដងទឹកស្អាតជាងនេះឬទេ? តើកុមារបានប្រមូលសំរាមចេញអស់ហើយឬនៅ? តើកុមារបានសំអាតឧបករណ៍ដាក់ទឹកស្អាតជានិច្ចឬទេ? តើកុមារកាន់តែច្រើនបានលាងដៃមុនពេលទទួលទាន និងបន្ទោរបង់រួចឬទេ? តើមានមនុស្សប៉ុន្មាននាក់ដែលនៅតែមានកើតជំងឺដោយសារទឹកមិនស្អាត?

គន្លឹះក្នុងការរក្សាបរិស្ថានសាលាឱ្យស្អាត

(ព័ត៌មានខាងក្រោមនេះ ដែលរៀបចំដោយ Karin Metell បង្ហាញពីរបៀបរក្សាបរិស្ថានសាលាឱ្យស្អាត និងមានសុវត្ថិភាព)

១. វាយតម្លៃបរិស្ថានសាលា។ តើអ្នកត្រូវធ្វើយ៉ាងណាដើម្បីឱ្យវាកាន់តែមេត្រី មានសុវត្ថិភាព និងអនាម័យជាងមុន? កត់សម្គាល់ ៥ ចំណុចដែលងាយស្រួលក្នុងការកែលំអ ដោយធ្វើផែនការកែលំអនេះជាមួយនឹងសិស្ស។

២. វាយតម្លៃទម្លាប់អនាម័យរបស់កុមារ និងឪពុកម្តាយរបស់គេទាំងនៅសាលា និងនៅផ្ទះ។ កត់សម្គាល់អាកប្បកិរិយាមិនល្អ ៥ យ៉ាងដែលធ្វើឱ្យប៉ះពាល់សុខភាពកុមារ និងរៀបចំផែនការដើម្បីកែលំអអាកប្បកិរិយាទាំងនេះ។

៣. ត្រូវធ្វើយ៉ាងណាឱ្យកុមារមានទឹកស្អាត និងមានសុវត្ថិភាពសម្រាប់ទទួលទាននៅសាលា។

៤. រៀបចំ "ទិវាសាលាសុខភាព" ឱ្យទៀងទាត់។ ឧទាហរណ៍ កុមារទាំងអស់ត្រូវធ្វើពលកម្មសំអាតទីធ្លាសាលាម្តងក្នុងមួយសប្តាហ៍។

៥. ជ្រើសរើស "អ្នកតាមដានសុខភាពកុមារ" ដើម្បីធ្វើរបាយការណ៍ពីការឆ្លងរាលដាលនៃជំងឺនៅក្នុងសហគមន៍។ ភ្ជាប់ទំនាក់ទំនងការតាមដានសុខភាពនេះទៅនឹងសកម្មភាពបរិស្ថាន។

៦. ឱ្យកុមាររៀបចំផែនទីបរិស្ថាននៅក្នុងសហគមន៍របស់គេ ដើម្បីកត់សម្គាល់ធនធាន និងទីតាំង ដែលត្រូវការពារ និងកែលំអ។ ចូរចាប់ផ្តើមសកម្មភាព មិនមែនត្រឹមតែរៀបចំផែនការនោះទេ។

៧. ឱ្យឪពុកម្តាយចូលរួមនៅក្នុងសកម្មភាពជាក់ស្តែងដើម្បីលើកកម្ពស់សម្ភារអនាម័យនៅសាលា ដូចជាធ្វើបង្គន់ជាដើម។

៨. រៀបចំឱ្យបានរួសរាន់ក្នុងការប្រែក្លាយសាលាឱ្យទៅជាសាលាបរិស្ថានមេត្រី ដោយការប្រើវត្ថុកែច្នៃដោយការបង្កើតឱ្យមានធុងសំរាម សួនច្បារ និងដាំដើមឈើ ធ្វើយ៉ាងណាមិនត្រូវខ្ជះខ្ជាយទឹកទេ។

៩. រៀបចំឱ្យមានកន្លែងលាងដៃ ជាមួយសាប៊ូ ឬជេះ នៅក្បែរៗបង្គន់។ ហើយលើកទឹកចិត្តកុមារឱ្យប្រើប្រាស់វាឱ្យបានត្រឹមត្រូវ។

ប្រភព: Exploring Ideas. UNICEF Website: Teachers Talking about Learning. www.unicef.org/teachers



គោល ៦.៤
តើយើងរៀនបានអ្វីខ្លះពីបទពិសោធ នាពេលកន្លងមក?

រៀបចំគោលនយោបាយសុវត្ថិភាព និងសុខភាព

គោលនយោបាយសាលា ដែលធានាឱ្យមានបរិស្ថានសាលាមានសុខភាព និងសុវត្ថិភាព គឺជាឯកសារណែនាំ ដែលយើងត្រូវការសម្រាប់ធ្វើដែនការសកម្មភាពដើម្បីលើកកម្ពស់លទ្ធផលនៃការសិក្សារបស់សិស្ស។ ដើម្បីសម្រេចថា តើគោលនយោបាយមួយណាដែលចាំបាច់ទាមទារឱ្យមានការចូលរួមពីអ្នកពាក់ព័ន្ធជាច្រើននៅក្នុងសាលា និងសហគមន៍។ រៀបចំបង្កើត និងអនុវត្តគោលនយោបាយទាំងនេះ ពីការតស៊ូមតិរហូតដល់ការស្រុះស្រួលគ្នា ការឆ្លុះបញ្ចាំង ការកំណត់គោលនយោបាយ និងសកម្មភាព គឺជាដំណើរការនៃការលើកកម្ពស់ការយល់ដឹង និងការចូលរួមជាដៃគូ។ យើងអាចទទួលបានផលប្រយោជន៍ច្រើនតាមរយៈការសហការគ្នាជិតស្និទ្ធជាមួយគ្រូពេទ្យ និងមន្ត្រីសុខាភិបាល ក៏ដូចជាគ្រូ សិស្ស ឪពុកម្តាយ និងមេដឹកនាំសហគមន៍។

នៅពេលដែលគោលនយោបាយត្រូវបានរៀបចំរួចហើយ គេត្រូវតែអនុវត្តតាមដោយត្រឹមត្រូវ និងមានការតាមដានពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់ រួមបញ្ចូលទាំងសិស្ស ដើម្បីធានាថាគោលនយោបាយនេះផ្តល់ផលប្រយោជន៍ស្មើគ្នាសម្រាប់កុមារគ្រប់រូប។

ឥឡូវសួរខ្លួនអ្នក "តើគោលនយោបាយណាដែលគួរតែប្រែនៅក្នុងសាលារបស់អ្នក?" ពិភាក្សាសំណួរនេះជាមួយសហការី និងសិស្សរបស់អ្នក ហើយបន្ទាប់មករៀបចំផែនការសកម្មភាពដើម្បីធ្វើឱ្យសាលារបស់អ្នកជាកន្លែងដែលកាន់តែមានសុវត្ថិភាព និងសុខភាពសម្រាប់ការសិក្សា។

ផ្តល់បំណិនជីវិតដល់កុមារ

តាមរយៈការអប់រំជំនាញសុខភាពមូលដ្ឋាន កុមារអាចអភិវឌ្ឍចំណេះដឹង ឥរិយាបថ និងបំណិនជីវិត។ កុមារអាចសម្រេចចិត្ត និងធ្វើសកម្មភាពវិជ្ជមាន ដើម្បីលើកកម្ពស់អាកប្បកិរិយា និងបរិស្ថានដែលមានសុវត្ថិភាព និងសុខភាព។

កម្មវិធីអប់រំសុខភាពមូលដ្ឋានផ្តោតលើការកែប្រែអាកប្បកិរិយារបស់មនុស្សទាក់ទងនឹងបញ្ហាសុខភាព ជាពិសេសទាក់ទងនឹងតម្រូវការសុខភាពរបស់ក្មេងប្រុស និងក្មេងស្រី។ កុមារចូលរួមដោយសកម្មនៅក្នុងការទទួលព័ត៌មាន និងជាពិសេស ប្រែក្លាយចំណេះដឹងឱ្យទៅជាសកម្មភាពអនុវត្តជាក់ស្តែង។

បំណិនជីវិតសំខាន់ៗមួយចំនួន ដែលកុមារបានរៀនរួមមាន ការច្រាស្រៃយទាក់ទង ជំនាញទំនាក់ទំនងជាមួយអ្នកដទៃ ជំនាញសម្រេចចិត្ត ជំនាញត្រិះរិះពិចារណា ជំនាញទប់ចិត្ត និងជំនាញគ្រប់គ្រងខ្លួនឯង។ ជំនាញបំណិនជីវិតទាំងនេះជួយកុមារឱ្យចេះដោះស្រាយបញ្ហាមួយចំនួន ដូចជា ការទប់ស្កាត់ការប្រើប្រាស់គ្រឿងញៀន និងអំពើហិង្សា និងជំរុញឱ្យមានរបបហូបចុកមានជីវជាតិ អនាម័យ និងសុខភាពខួរក្បាល។ ជំនាញទាំងនេះមានសារប្រយោជន៍ណាស់សម្រាប់ទប់ស្កាត់ការឆ្លងរាលដាលមេរោគអេដស៍/ជំងឺអេដស៍ ការកាត់បន្ថយការរើសអើងចំពោះអ្នកមានមេរោគអេដស៍/ជំងឺអេដស៍។

វិធីសាស្ត្រមួយចំនួន ដែលយើងអាចបញ្ចូលកម្មវិធីអប់រំសុខភាពមូលដ្ឋាន នៅក្នុងការបង្រៀន គឺតាមរយៈវិធីសាស្ត្របង្រៀនដែលមានការចូលរួមយ៉ាងសកម្ម ដូចជា ការពិភាក្សាតាមក្រុម សម្តែង ការបង្ហាញ និង ការនិពន្ធរឿង និងកំណាព្យ។

ឥឡូវសួរខ្លួនអ្នក "តើខ្ញុំត្រូវកែប្រែការបង្រៀនរបស់ខ្ញុំយ៉ាងណាដើម្បីលើកកម្ពស់ការយល់ដឹងអំពីសុខភាពរបស់សិស្ស?" ចូរលើកឡើងឱ្យបានយ៉ាងហោចណាស់ក៏គោលដៅ ៣ យ៉ាងដែរសម្រាប់ប្រៀបធៀប និងពិភាក្សាជាមួយសហការី និងសិស្សរបស់អ្នក។ ១ខែក្រោយមក ប្រៀបធៀបឡើងវិញថាតើអ្នកមានការរីកចម្រើនដល់ណាដែរ។

ផ្តល់សេវាសុខភាព សម្ភារ និងអាហារដើម្បីលើកកម្ពស់លទ្ធផលសិក្សា

កុមារដែលមានប្រវត្តិ និងសមត្ថភាពខ្សោយ ជាយនឹងជួបប្រទះការខ្វះខាតអាហារណាស់។ អាហារសាលា និងសេវាសុខភាព និងសម្ភារអាចជាជំនួយសំខាន់ណាស់សម្រាប់កុមារទាំងអស់នេះ តាមរយៈការផ្តល់អាហារ ការលើកទឹកចិត្តឱ្យមានទម្លាប់ដែលមានអនាម័យ សហការជាមួយឪពុកម្តាយ និងគ្រួសារដើម្បីបង្កើនប្រភពទឹកស្អាត និងសម្ភារដែលទាក់ទងនឹងអនាម័យទឹក។

សាលារបស់យើង អាចផ្តល់សេវាអាហារសាលាដោយប្រសិទ្ធភាព ប្រសិនបើវាជួយដោះស្រាយបញ្ហាដែលគេទទួលស្គាល់ថាកំពុងតែរាលដាលនៅក្នុងសហគមន៍ ហើយបញ្ហាទាំងនោះអាចដោះស្រាយដោយខ្លួនឯងដោយមិនចាំបាច់មានជំនួយធំដុំពីខាងក្រៅនោះទេ។

សេវាអាហារ និងសុខភាពសាលាអាចមានប្រយោជន៍ច្រើនណាស់សម្រាប់បង្រៀនកុមារនូវជំនាញបំណិនជីវិត និងការអនុញ្ញាតឱ្យគេអនុវត្តជាក់ស្តែងនៅក្នុងសាលា។

សាលារបស់យើង គួរតែជាកន្លែងគំរូសម្រាប់សហគមន៍ និងកូនរបស់យើង។ យើងមិនគ្រាន់តែបង្រៀនអំពីសុខភាពល្អ អនាម័យល្អ និងទម្លាប់ល្អប៉ុណ្ណោះទេ តែយើងត្រូវអនុវត្តជាក់ស្តែងតែម្តង។

ឥឡូវសួរខ្លួនអ្នក "តើសាលារបស់ខ្ញុំត្រូវការសេវាអ្វី និងសម្ភារអ្វីខ្លះ ឬតើសាលារបស់ខ្ញុំត្រូវកែលំអកន្លែងណាខ្លះ?" ពិភាក្សាជាមួយសហការី និងសិស្សរបស់អ្នក បន្ទាប់មករៀបចំជាផែនការសកម្មភាពដើម្បីលើកកម្ពស់សេវាទាំងនេះក្នុងសាលារបស់អ្នក។

តើអ្នកអាចទទួលបានព័ត៌មានបន្ថែមពីទីណា?

ខ្លឹមសារនៅក្នុងកម្រងសៀវភៅនេះដកស្រង់ចេញពីឯកសារខាងក្រោមនេះ ហើយយើងសូមបង្ហាញនូវការដឹងគុណចំពោះអ្នកនិពន្ធទាំងនោះ។ ប្រិយមិត្តអ្នកអានទាំងឡាយគួរតែអានឯកសារយោងទាំងនេះដើម្បីបានទទួលព័ត៌មានលំអិតបន្ថែម ដើម្បីរៀបចំសាលាមេត្រីដែលមានបញ្ចូលគ្រប់សមាសភាពឱ្យល្អប្រសើរ។

ឯកសារយោង

Baily D, Hawes H and Bonati B. (1994) Child-to-Child: A Resource Book. Part 2: The Child-to-Child Activity Sheets. London: The Child-to-Child Trust. This publication is an excellent resource for promoting children's participation in several areas. Readers are encouraged to use it in developing their lesson plans and activities.

Commonwealth Secretariat and Healthlink Worldwide (2001) Gender and Relationships: A Practical Action Kit for Young People. London.

Seel A and Power L. (2003) Active Learning: A Self-Training Module.

Son V, Pridmore P, Nga B, My D and Kick P (2002) Renovating the Teaching of Health in Multigrade Primary Schools: A Teacher's Guide to Health in Natural and Social Sciences (Grades 1,2,3) and Science (Grade 5). British Council/National Institute of Educational Sciences: Hanoi, Vietnam.

Schenker II, Nyirenda JM. (2002) Preventing HIV/AIDS in Schools. International Academy of Education. Educational Practices Series 9. Paris.

UNESCO. Best Practices of Non-Violent Conflict Resolution in and out-of-school: some examples. Paris. Also obtainable from the Web site http://unesdoc.unesco.org/images/0012/001266/126679e.pdf

UNESCO (2002) FRESH: A Comprehensive School Health Approach to Achieve EFA. Paris. (ED-2002/WS/8 Rev.)

UNICEF and the International Water and Sanitation Centre (1998) A Manual on School Sanitation and Hygiene. Water, Environment and Sanitation

Technical Guidelines Series – No. 5. New York.

World Food Programme (2002) Fact Sheet: School Feeding. Rome.

World Health Organization (2000) Local Action: Creating Health Promoting Schools. Geneva.

World Health Organization (1998) WHO Information Series on School Health. Document 3. Violence Prevention: An Important Element of a Health-Promoting School. Geneva.

World Health Organization (1998) WHO Information Series on School Health. Document 4. Healthy Nutrition: An Essential Element of a Health-Promoting School. Geneva.

World Health Organization (1998) WHO Information Series on School Health. Document 6. Preventing HIV/AIDS/STI and Related Discrimination: An Important Responsibility of Health Promoting Schools. Geneva.

ឯកសារដែលដកស្រង់ចេញពីគេហទំព័រ

Barriers to Girls' Education: Strategies and Interventions. UNICEF Teachers Talking About Learning.
http://www.unicef.org/teachers/girls_ed/barriers_02.htm

Education Queensland. Identifying At Risk Students.
http://education.qld.gov.au/health-safety/promotion/drug-education/html/m_risk.html

Focusing Resources on Effective School Health. http://www.fresh-schools.org

International Academic of Education. IAE has many publications in its "Educational Practice Series" including such topics as teaching, parents and learning, effective educational practices, teaching additional languages, how children learn, and preventing behaviour problems, amongst many others. You can download copies at
http://www.curtin.edu.au/curtin/dept/smec/iae

International Bureau of Education. Copies of IAE's "Educational Practice Series" as well as other valuable publications are available at:

http://www.ibe.unesco.org

National Center for Assault Prevention.
http://www.ncap.org/identify.htm. NCAP also has an international division with some materials translated in Spanish, French, Vietnamese, Cantonese, Romanian, Russian and Japanese. Learn more about this at:
http://www.ncap.org/cap_international.htm.

School Health Web Site. http://www.schoolsandthealth.org

The Global Program on Youth. Monitoring School Violence.
http://gpy.ssw.umich.edu

UNESCO. Non-Violence Education.
http://www.unesco.org/education/nved/index.html